ក្រុមជំនុំនៃប្រពៃណីនិងទម្លាប់
COMMISSION DES MŒURS & COUTUMES

ភាសាសង្គម

ៈសង្គ្រាវដ្ឋី ជ្បាយជំណាំងខាងសាសនា នំងអក្សរសាស្ត្រ

ឆ្នាំទី ២៥ ខែមករា លេខ ១

ព.ស. ២៤៩៥ – គ.ស. ១៩៥៣

ចុះបញ្ជីសៀវភៅបណ្ណាល័យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ព្រះពុទ្ធសាសនា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— ព្រះពុទ្ធសាសនានៅប្រទេសចិន (តមក) ..	លោក ភ័យ-ប៊ុក	៣
— ពលធម៌	ព្រះមហា យ៉ត-ទ្រុលន់	១១
— រឿងកុណ្ឌលកេសីថេរី	ព្រះមហាសុខុមាលី-សេន ...	២៤
ផ្នែកអក្សរសាស្ត្រ		
— ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម ...	៣៦
— រឿងសាមកុក (តមក)	ឧកញ៉ា ឆ្វ-កន	៤៣
— រឿងអាវ៉ក្សថ្លែងរឿងម្តែប្រាំ (តមក)	លោក ភ័យ-ប៊ុក	៥៤
កំណត់ទឹកប្រវត្តិការណ៍		
— សន្និសិទព្រះពោធិវង្ស ហួត-តាត អំពី សមាជសាកលលើកទី ២ នៃពុទ្ធសាសនា...	ពុទ្ធសាសនបណ្ឌិត្យ	៦២
— សុន្ទរកថាសម្តេចសង្ឃនាយក នៅប្រទេស ស៊ីឡង់ ថ្លែងក្នុងសមាជសាកលលើកទី ២ ...	ពុទ្ធសាសនបណ្ឌិត្យ	៦៩
— សកម្មភាពនៃពុទ្ធសាសនបណ្ឌិត្យ និងសាលា-បាលីដាន់ខ្ពស់	លោក ចាប-ពិន	៧២
— បញ្ជីរាយនាមថៅអធិការដែលគាំងថ្មី (តមក).	ក្រសួងធម្មការ	៧៧

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដាវ ១៩២រ, ០១

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

		Pages
PARTIE RELIGIEUSE		
— Le Bouddhisme en Chine(suite)	M. Ray-Buc	3
— BALADHARMA	Preah Maha YOT-TRALON . .	11
— Histoire de Neang "KUNDALA-KESITHERI"	Preah Maha SUKHUMALI-SEN	24
PARTIE LITTERAIRE		
— Education morale (suite).....	Vén. Pœung-Pam	36
— Histoire de SAMKOK (suite) .	Oknha Nou-Kan	43
— Les vingt cinq récits du Mauvais Génie (suite)	M. Ray-Buc	54
NOTES ET CHRONIQUES		
— Conférence du Vén. Preah Bodhi vangs HOUTH-TATH sur le 2e Congrés Mondial Bouddhique	Institut Bouddhique	62
— Discours du Très vénérable, Chef de la secte maha nikaya de ceylan au 2e Congrés Mondial Bouddhique	— —	69
— Activité de l'Institut Bouddhique et de l'École Supérieure de Pali	M. CHAP-PIN	72
— Nomination des nouveaux Chauadhikar (suite)	Ministère des Cultes	77

Prix d'abonnement annuel (comprenant 12 numéros): 192800

ព្រះពុទ្ធសាសនានៅប្រទេសចិន

លោកវ៉ាយ-ប៊ុក ក្រមការ រៀបរៀង

(តមក)

---

១)- សេចក្តីអនុគ្រោះនៃព្រះពុទ្ធសាសនា នៅសន្តតិ-វង្សត្សុង:

នៅសន្តតិវង្សត្សុង, ព្រះពុទ្ធសាសនា បានថ្កុំថ្កើងរុងរឿងជាអនេកប្បការ ។ ព្រះពុទ្ធសាសនា បានផ្សាយអក្សរសាស្ត្រចិន ដោយមានការបកប្រែគម្ពីរព្រះពុទ្ធសាសនា, ធ្វើវចនានុក្រម, ទំនៀវកៅព្រះពុទ្ធសាសនាផ្សេង។ ជាច្រើន, និងានពុទ្ធសាសនាខាងសីលធម៌មួយរយៈពុទ្ធកាសិតជាដើម ។

តអំពីព្រះចាខតៃ-ត្សុងមក, មានសម្តេចព្រះមាតាមួយអង្គឧទ្ទិសព្រះនាមវ៉ូ-ហៅ ឡើងសោយរាជសម្បត្តិ ពីឆ្នាំ ៦៨៩ ទៅដល់ឆ្នាំ ៧០៥; ព្រះនាងមានព្រះទ័យកាចសាហាវ ឧទ្ទិសឫទ្ធិព្រះពុទ្ធប្លាទ័យ និងសាមណេរមួយអង្គដែលឧទ្ទិសព្រះរាជានុញ្ញាត ឲ្យយកប្រាក់កងព្រះរាជឃ្លាំងស្អាងព្រះវិហារមួយធំសម្បើមអស្ចារ្យ ដល់ក្រោយព្រះនាងបែរទៅជាមានព្រះទ័យទោមនស្សពិយាតសាមណេរនោះចោលទៅ ។ ព្រះនាងបានឧបត្ថម្ភព្រះពុទ្ធសាសនា និងពួកតាវ-ត្សឺ ហើយពិយាតពួកបណ្ឌិត ។

តពីព្រះសង្ឃពោធិធម៌មកមានព្រះសង្ឃក្រោំអង្គ តមកតាំងសម្ដេច
នាមជា "បេតេយ្យបុរសនៃបូពាទ្វីប" ។ បេតេយ្យបុរសទីបួនបានទទួល
សេចក្ដីអញ្ជើញពីព្រះអធិពជនី ឲ្យចូលទៅកាន់ព្រះបរមពជវាំង, បេតេយ្យ-
បុរសនេះ មិនព្រមទទួលព្រះពជបញ្ជា ។ ព្រះអធិពជនីទ្រង់គ្រាស់
បង្គាប់ឲ្យលើកកងទ័ពទៅព័ទ្ធវត្តនោះ, លោកបានចាត់ឲ្យព្រះសង្ឃឡើង
លើកំពែងជញ្ជាំងសូត្រប្រាប់ថាបារមី ។ ពួកកងទ័ពក៏អន់ថយអានុភាព
ចេញទៅវិញ ។

គ.ស. ៧៦០ ព្រះអធិពជ សូ-តុង បានជួយឧបត្ថម្ភព្រះពុទ្ធ-
សាសនា, ទ្រង់បានចាត់ឲ្យធ្វើបុណ្យព្រះពុទ្ធសាសនា ហៅថាបុណ្យ
ចំរើនព្រះជន្មនៅព្រះបរមពជវាំងរៀងពាល់ឆ្នាំ ។

ព្រះរដ្ឋមាយាទព្រះនាម តាវ-តុង ទ្រង់បានចាត់ឲ្យព្រះសង្ឃនិមន្ត
ទៅសូត្រធម៌ចំពោះមុខ ទ័ពបច្ចាមិត្តបាក់បបរខ្ចាចចេញចាកសមរភូមិ
ទៅ ។ ក្នុង គ.ស. ៧៦៨ ទ្រង់មានកសាងវត្តអារាមជាច្រើនហើយ
ទ្រង់បានចាត់ធ្វើពិធីបូជាប្រែតក្នុងព្រះពុទ្ធសាសនា នៅព្រះបរមពជវាំង ។

គ.ស. ៨១៩, ព្រះចាទហៀង-តុង ទ្រង់បានចាត់ឲ្យមន្ត្រីជា
ទៅនាំព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធមកកាន់ព្រះរាជធានី, ធ្វើបុណ្យជា
ឧឡារិក ។

ការឧបត្ថម្ភព្រះពុទ្ធសាសនានៅសន្តតិវង្សតុង នាំឲ្យពួកនិកាយទាំង
ពីរពេមនស្សជាខ្លាំង: ពួក តាវ-សេ បានចាប់ព្រះអធិពជ ប៊ូ-សៀង ។

ឆ្នាំ ៨៤៥, ព្រះពុទ្ធសាសនា បានទទួលគ្រោះថ្នាក់ជាយ៉ាងទម្ងន់; មាន ព្រះរាជប្រកាសព្រះបាទ រ៉ុ - សៀងត្រាស់បង្គាប់ឲ្យលុបវត្ត ៤៦.០០០, នៅតែក្រុងនឹង ៤០ ០០០ វត្តនៅខាងខេត្តកូមិកាគនិគមជនបទ ។ វត្ត ទាំងនេះ ត្រូវចាត់ជាសាធារណៈប្រយោជន៍ទុកជាគេហដ្ឋាន ពួកមន្ត្រីទៅវិញ; កណ្តឹងនឹងព្រះពុទ្ធរូបត្រូវយកទៅរំលាយធ្វើជារូបិយវត្ថុ; ព្រះ សង្ឃ ៤៦០.០០០ ត្រូវលាចាកសិក្ខាបទទៅជាគ្រហាស ។

គ)- និកាយកើតពីលទ្ធិលោក ឆាគ-ជុង និកាយលិន-ត្សុ:

ពួកបេតេយ្យបុរស រលត់រលាយចាត់អំណាចខាងព្រះពុទ្ធសាសនា ធ្លាក់មកលើលោក មូ-ត្សូ ដែលកាន់គណៈ ចាំង ស៊ី (វិបស្សនាធុរៈ) ។ និកាយពីរទៀតកាន់ខាងវិនិយ (គន្ថធុរៈ) មានពួកកាន់ព្រះពុទ្ធសាសនា ពីបឋមពោធិកាល ទឹងពួក ហ្វា ដ៏ ជាអ្នកអប់រំខាងការសិក្សាព្រះពុទ្ធ-សាសនា ។

លំដាប់តមក, មាននិកាយ ជុំ, តែនិកាយដែលប្រជាកស្តុនិយមកាន់ គឺនិកាយលិន ត្សុ ដែលយល់ថា ចិត្តឫមនោ គឺព្រះពុទ្ធ ។ និកាយ នេះបងិសន្ធិនៅខេត្ត សឹង-ទុង, បានផ្សាយទៅកាន់ខេត្តជប់ជុំបី នៃ ប្រទេសចិនត្រមាំងប្រទេសជប៉ុន ។ ជនកបុរស ដែលស្ថាបនានៅ និកាយនេះអនិច្ចកម្មនៅឆ្នាំ ៨៦៨ ។ នៅប្រទេសជប៉ុន, និកាយនេះ គេ ហៅថានិកាយ "សេន" ។

ចំពោះព្រះពុទ្ធសាសនា "អរិយធម៌" នៃប្រទេសចំនួនមាននិកាយធំៗ គឺ:

១ – និកាយវិន័យ ស្លៀកខ្មៅ ។

២ – និកាយខាងអប់រំនូវយោគៈមានមន្តអាគមជាដើម ។

៣ – និកាយវៃ ដ៏-សៀង-គីយ៉ាវ ដែលកើតពីសាស្ត្រៈវៃ-ស៊ីលុន នឹងគម្ពីរឯទៀតជាច្រើន ដែលពោធិសត្វពីរអង្គបានតែង គឺ យ៉ូ-ចូ នឹងដៀង-គ្យីន ។ លំដាប់ព្រះពោធិសត្វទាំងពីរអង្គមានឥណ្ឌូ គីយ៉ាវ-គៀង, រួចបានហ៊ីយុន-តូវ៉ាន់នឹងកៃ-គី ។ និកាយនេះ គេហៅថា និកាយពន្យល់អំពីធម្មជាតិ នឹងន័យលទ្ធិព្រះពុទ្ធសាសនាដែលសរសេរដៃ ។

៤ – និកាយទីបួនបានយកនាមពីសាស្ត្រៈជុន លុនៃនៃបណ្ឌិតនាគ-ជុន; តមកមានសាវ័កលោកពោធិធម៌ នឹងលោកដ៏-កៃនៃគៀង-តៃ ។

៥ – និកាយចុងគ្រោយគឺលោកហ្សា-ស្ហុន ជាជនកបុរស ។ សាវ័កចុងគ្រោយបង្អស់នៃ ហ្សា-ស្ហុន គឺ ហ៊ាន-ស្ហឺ បានស្ថាបនានូវលទ្ធិ "ធម្ម-ជាតិពិត" នៃលទ្ធិដែលគេបានសរសេរដៃ ។

លំដាប់តពីនោះមក, មាននិកាយបទុម ឬ ផែនដីបរិសុទ្ធដែលជាស្ថានសួគ៌របស់ព្រះអមិតាភៈ, មហាមេឃបស្ថិម; ស្ថាននេះ បើតាមយោបល់នៃពុទ្ធសាសនិកជនបានយកមកជំនួស ហៅថា ស្ថានព្រះនិព្វាន, តាមព្រះពុទ្ធសាសនាចិននឹងទីបេត៍ ។

មហាមេឃបស្ងំមនោះ ដែលគេហោថា ផែនដីបរិសុទ្ធនៃទិសបស្ចិម គឺជាកពប្ផស្ថានមួយមានលំអអស្ចារ្យ គឺជាស្ថាននៃមនុស្សក្នុងកពនោះ ទឹងខេវតាមានអានុភាពជាយ៉ាងក្រៃលែង ។ ពួកពលវជ្ជនៅស្ថាននោះ មានបរិចិត្តវិជ្ជាអាចយល់ចាក់ធ្លុះនូវហេតុផលនៃវឿងរ៉ាវផ្សេង ។ ជីនោះគឺមាសសុទ្ធ; នៅស្ថានដែលប្រកបដោយសប្បាយបរិសុទ្ធ ប្លុងចាំងឡាយគ្មានស្ងួតស្រពោនឡើយ ។ បង្កេះកំនឹងឃ័ មានថ្នាក់សុទ្ធតែធ្វើពីពេជ្រនឹងថ្មយុគ ។ បក្សាចាំងអស់ច្រៀងវិន័យតថាគត ។ គុម្ពោតក្រៃបញ្ចេញសូរសព្ទសំឡេងពិរោះដូចក្នេងតូរ្យជន្ត្រី ។ មានបុប្ផាអ៊ុំពទុមិនចេះស្ងួតស្រពោនអ្វីឡើយ បញ្ចេញនូវគន្ធពិជោតអូបឈ្ងុយឈ្ងប់ពាសពេញព្រៃ ។ នៅស្ថាននេះជាទីមហាសន្និបាតព្រះពុទ្ធចាំងជម្លង់ ដែលទ្រង់មានសេចក្តីសរសើរជានិរន្តរ៍ នៅស្ថាននេះ ដែលជាស្ថាននៃពួកអរិយបុគ្គល ស្ថិតនៅសុខស្រួលលើសស្ថានចាំងពួង ។ បុគ្គលណាដែលចូលទៅស្ថិតនៅស្ថាននោះ ផ្ទាស់ប្តូររូបកាពជាអនិច្ចតាធម៌ ទៅជារូបក្តីមានរស្មីចាំងចែងអស្ចារ្យ ។ ជីវិតាពនៃបុគ្គលចាំងនោះ មានសភាពសុខស្រួលជារៀងរាល់ ។ នៅជុំវិញមានព្រៃមានពណ៌ខៀវស្រងាត់, ខាងលើមានមេឃភ្លឺស្រឡះ ។ គ្មានព្រះអាទិត្យរះចាលកំដៅទេ, គ្មានព្រះពាយុបោកបក់ខ្យល់ងាយដូចទឹកកកទេ ។ គ្មានដូវងារ, រដូវក្តៅ នៅទឹងព្រះបរមកជពាំង ដែលធ្វើពីពេជ្រនោះឡើយ ។

ការកាន់ច្រឡំមិនមាន, ច្រណែនដែលស្មុគស្មាញគ្មាន ។ ការរស់នៅមិនដែលមានកង្វល់, ទុក្ខ, ព្រួយ, ខ្វាចអ្វីឡើយ ។ សច្ចធម៌បញ្ចាំងចេញពីទីងងឹត ដូចជាគ្មានច្របែះធា គ្មានមន្ទិល ។

លំដាប់តមកនឹងពាក្យបន្ទូចអំពីព្រះពុទ្ធ អមិទៈ ។

ព្រះពុទ្ធអមិទៈ ទ្រង់គង់ញញឹមនៅស្ថាននោះផ្សាយមេត្តាដល់សត្វសត្វ ។ ព្រះកាយមានបញ្ចេញរស្មីចោលឆ្ងាយ ធ្វើឲ្យសត្វដែលមានទុក្ខត្រឡប់ទៅជាសុខសប្បាយទៅវិញ ។ អំពីលំអនៃរូបនោះមិនអាចមានពាក្យអ្វី យកមកប្រៀបធៀបបានឡើយ ។ មានបុប្ផាបទុមស្ថិតនៅជិតព្រះអង្គដូចជាកើតនៅបាទទ្រង់ បើបុគ្គលណាចង់ចូលទៅកាន់ព្រះវិហារដែលព្រះអង្គស្ថិតនៅ ត្រូវដំកល់ចិត្តឲ្យនឹងនៅនឹងព្រះរូបភ្លឺចាំងចែងប្រៀបដូចជាព្រះចន្ទរះពេញបូណ៌មីនៅលើមេឃដែលគ្មានពពក ។ ព្រះអង្គទ្រង់ស្រោចស្រង់ទៅលើសត្វលោក នូវព្រះរស្មីដែលផ្សាយជាវង់មូលចេញពីប្រកេស, ព្រះសុរិយាកង់ពេលថ្ងៃត្រង់មិនស្មើមានអានុភាពស្មើនឹងព្រះអង្គ, ព្រះមេត្តាព្រះអង្គប្រៀបដូចជាមហាសាគរដែលកែលែង ។ ព្រះហស្តសម្បុរមាសលើកតម្កើងទៅកាន់ពួកពុតត ដើម្បីនឹងជួយសម្រាលទុក្ខនៃអ្នកដែលយំសោក, រំលែកសេចក្តីទុក្ខព្រួយនៃអ្នកដែលមានកំភ្លៀកភ្លឹមកំភ្លឹ ។ ព្រះទ័យរបស់ព្រះអង្គប្រកបដោយព្រហ្មវិហារគ្មានអ្វីយកមកប្រៀបធៀបឲ្យស្មើបាន ហើយកង់ការកុសលជាច្រើនឆ្នាំ មិនអាចយកមកធៀបនឹងបុណ្យដែលព្រះអង្គធ្វើចំពោះសត្វលោក ។

៦)—ការតស៊ូព្រះពុទ្ធសាសនាមកដល់សន្តតិវង្សមុង្គោល:

ព្រះអធិរាជ អ៊ី-ត្សុង ដែលឡើងសោយរាជ្យក្នុង គ.ស. ៨៦០ ទ្រង់ ប្រាន់ចំព្យាយាមសិក្សាខាងគម្ពីរព្រះពុទ្ធសាសនា ។ ក្នុងពេលនោះ មាន ព្រះសង្ឃទិមន្តមកពីប្រទេសក្រៅជាច្រើន, មានព្រះសង្ឃអង្គខ្លះអួតបេះ មន្តអាគម ហើយអាចសូត្រឲ្យភ្ញៀងធ្លាក់បាន, ព្រះសង្ឃអង្គខ្លះទៀត និមន្តពីវដ្តកូរេ នឹងប្រទេសជប៉ុន ។

តមកព្រះអធិរាជ ហ៊ីអ៊ុន-ត្សុង បានធ្វើការឮនិមានមួយនៃតារ៉ា-តិក: គីង ដែលមានវណ្ណនាតាំងពីអនាធិបតេយ្យនៃសន្តតិវង្សគាំងប្រាំពីរ ។ ព្រះអង្គទ្រង់ត្រាស់បង្គាប់ឲ្យយកព្រះនាមព្រះពុទ្ធទៅសម្មតិថា ជាអារក្ស មួយខាងពួកតារ៉ា ។

នៅរជ្ជកាលនៃព្រះអធិរាជ ក្នុងសន្តតិវង្សតាំងបានសាងព្រះវិហារ សម្រាប់ឡា-ត្សឺ ។ ព្រះអធិរាជសោយរាជ្យចុងក្រោយក្នុងសន្តតិវង្សនេះ ទ្រង់មានព្រះរាជឧង្ការឲ្យត្រឡប់ចំពោះបុគ្គល ដែលចូលទៅឧបសម្បទា ក្នុងវត្តតារ៉ា ឬ វត្តព្រះពុទ្ធសាសនា ។

ព្រះមហាក្សត្រក្នុងសន្តតិវង្ស ដ៏ ធ្ងើនយោបាយជួយនឹងព្រះពុទ្ធ-សាសនា ។ មានព្រះរាជបែកាសត្រាស់បង្គាប់ឲ្យរុះរើព្រះវិហារ នឹង ហាមមិនឲ្យព្រះសង្ឃធ្វើការណាមួយក្នុងព្រះពុទ្ធសាសនា មានការកាត់ដៃ ខ្លួនឯង, យកដៃទៅជុតក្នុងក្អើង យកចង្កៀងនេះទៅចងភ្ជាប់នឹងសាច់

ជាដើម ។ នេះបញ្ជាក់ឲ្យឃើញថាលទ្ធិពោធិធម៌ ប្រែក្លែកព្រះពុទ្ធសាសនិកជន ឲ្យប្រព្រឹត្តធម៌ក្លាយទៅជាធម៌តាបសខាងព្រហ្មញ្ញសាសនា (អត្តកិលមជ្ជានុយោគ) ។

ព្រះពុទ្ធឃោសនៃសន្តតិវង្ស តៀន ខាងក្រោយតមកអនុគ្រោះលទ្ធិតាវនិងពុទ្ធសាសនា ។

ព្រះអភិរាជក្នុងសន្តតិវង្ស ស៊ុង ពេញព្រះទ័យនិយមកាន់ខាងលទ្ធិពួកបណ្ឌិត ។ ព្រះភ្ញាក់ហ៊ីព្រះអភិរាជដំបូង (៨៦៤) ជ្រានចាត់ពលទូតទៅព្រះអភិរាជខាងសន្តតិវង្ស តឹង កុំឲ្យរាប់អានព្រះពុទ្ធសាសនា ។ ព្រះអភិរាជនេះទ្រង់កំយល់ព្រមតាម ។ តែមានព្រះពុទ្ធឃោសតមកដំបូងមានព្រះចរិយាមិនសូវពេញចិត្ត ខាងព្រះពុទ្ធសាសនា តែដល់ចុងក្រោយ ស្រាប់តែប្រឹងសាងវត្តមួយកំពស់ ៣៦០ (pieds) ។

ដល់មកចុងសតវត្សស៊ុង, គេបានស្គាបនាទូវិព្រះវិហារនឹងវត្តអារាមនៃព្រះពុទ្ធសាសនាជាច្រើន ។

វត្តដែលល្បីល្បាញក្នុងពេលនោះ គឺវត្តដែលសាងនៅកោះពុតូ, ខាងកើតទីក្រុង ជូសាន (គ. ស. ៧១៩) ។ ក្រៅពីនេះមានវត្ត តៀន-តៃដែលមានសាលាមួយ សម្រាប់លោកសង្ឃរៀនបកប្រែគម្ពីរភាសាសំស្ក្រឹតមកជាភាសាចិន ។

(មានត)

ព្រះមហាយ៉ឺត-ទ្រលង់ វត្តលង្កា ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥កើត ខែកត្តិក ឆ្នាំជូតសំរឹទ្ធិស័ក ព. ស. ២៤៩១ (១ - ១២ — ៤៨)

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្សការថ្វាយបង្គំ ទូវព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ ព្រមទាំងព្រះធម៌ នឹងព្រះអរិយសង្ឃ ។ ដោយអានុភាពនៃកិរិយានមស្សការសូមឲ្យទុបទ្រូតអន្តរាយទាំងឡាយ វិនាសខ្ចាត់ខ្ចាយចេញទៅដោយឆាប់រហ័ស ។

តាមលំដាប់ពីពេលមុន ។ មក រហៀបនៃការសំដែងទូវធម្មទេសនានេះ ក៏តែងមានរៀងមកដល់ឥឡូវនេះឯង ។ ក្នុងពេលនេះត្រូវលើវេនអាត្មាភាពសំដែងតាមសមគួរដល់កាលវេលា ។

ធម៌ដែលនឹងលើកយកមកសំដែងក្នុងវេលានេះ គឺពលធម៌ "ធម៌ជាកំលាំង" ដោយព្រះពុទ្ធភាសិតថា:

បញ្ចិមានិ ភិក្ខវេ ពលានិ, កតមានិ បញ្ច?
សទ្ធាពលំ វីរិយពលំ សតិពលំ សមាធិពលំ
បញ្ញាពលន្តិ ។

សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ! កំឡាំងទាំងឡាយ ៥ នេះ, កម្លាំង ៥ នោះដូចម្តេចខ្លះ? កំឡាំងទាំង ៥ នោះ គឺ:

๑ - សទ្ធាពលំ = កំឡាំងគឺសទ្ធា

๒ - វីរិយពលំ = កំឡាំងគឺសេចក្តីព្យាយាម

๓ - សតិពលំ = កំឡាំងគឺសេចក្តីរឭកបាន

๔ - សមាធិពលំ = កំឡាំងគឺសេចក្តីតាំងចិត្តមាំ

๕ - បញ្ញាពលំ = កំឡាំងគឺសេចក្តីដឹងច្បាស់ផ្លូវធ្លាត ។

ធម៌ទាំង ៥ ប្រការនេះ ហៅថា ឥន្ទ្រិយដូច្នេះក៏បាន ព្រោះជាធំក្នុងកិច្ចរបស់ខ្លួនទាំងអស់ ។

អធិប្បាយថា: ធម៌ទាំង ៥ ប្រការនេះ ហៅថា ពលៈ គឺជាកំលាំង សំដៅសេចក្តីថា អ្នកបរិបូណ៌ដោយធម៌ ៥ ប្រការនេះហើយ ឈ្មោះថាជាអ្នកមានកំលាំងដ៏ក្រៃលែងជាងកំលាំងទាំងអស់ អាចប្រកបការងារហួសវិស័យដែលមនុស្សគប្បីធ្វើបាន ឲ្យសម្រេចត្រង់ប៉ងតាមសេចក្តីប្រាថ្នា ឧបមាដូចជាបុរសមានកំលាំងច្រើន អាចលើកួសែងវត្ថុត្រង់ប៉ងបាន ។ សេចក្តីនេះ គួរជ្រាបអធិប្បាយដោយលើកការងារផ្លូវគតិលោកឡើងសំដែងដូចតទៅនេះ ។

បុគ្គលដែលនឹងប្រកបការងារណាមួយក្តី ងាយក្តី ត្រូវអាស្រ័យសទ្ធា គឺសេចក្តីជឿជាមុន គឺជឿក្នុងការងារនោះ ថាជាការដែលមាន

ប្រយោជន៍ពិត ។ ជាការងារអាចនឹងហុចប្រយោជន៍ឲ្យដល់ខ្លួន សមនឹងដើមទុនធនធាន ព្រមទាំងផ្សឹចិត្តខ្លួនក្នុងការងារដែលធ្វើថា: អាចនឹងធ្វើបាន ឯការងារដែលធ្វើទាំងអម្បាលម៉ាន តែងនាំទៅឲ្យសំរេចប្រយោជន៍ ទាំងផលដែលខ្លួនប្ចាថ្នានោះ ខ្លួននឹងបានក៏ព្រោះការងារដែលធ្វើហ្នឹងឯង មិនមែនបានដោយផ្លូវដទៃឡើយ យ៉ាងនេះកំលាំងចិត្តដែលធ្វើនោះ ក៏រមែងកើតឡើង កាលបើកំលាំងចិត្តកើតឡើងហើយ តែងដឹកនាំឲ្យប្រកបការងារនោះ ។ ដោយឥតមានបង្អែបង្អង់ តែគង់រួញរាបានដោយអំណាចនៃសេចក្តីឱ្យលែងអូស ដែលចាំស្អាក់ដំណើរឲ្យយឺតយូរ ធ្វើខ្លះ មិនធ្វើខ្លះ ដោយអាងចាំវេលានេះ វេលានោះ ការងារនោះនឹងសំរេចមិនបានឡើយ ។

ព្រោះហេតុនេះឯងធម្មិកជនលំដាប់ទីពីរបន្ទាប់អំពីសត្វាមក គឺសេចក្តីព្យាយាម ទើបជាគុណដែលត្រូវប្ចាថ្នាមួយទៀត ព្រោះជាគុណធម៌ដែលជំរុញគាញនាំចិត្តឲ្យប្រកបកិច្ចការ មិនឲ្យរួញរា អាចជួយទំនុកបំរុងតាំងចិត្តធ្វើដោយសេចក្តីក្លាហានប្រឹងប្រែង ។ ធម្មតាបុគ្គលតាំងព្យាយាម ប្រឹងក្នុងការងារនោះ ។ ហើយ តែងជួបប្រទះ នឹងសេចក្តីដំពាក់ពាក់ពាមក្នុងចន្លោះ ។ ដែលជាធម្មតារបស់ការងារគ្រប់លោក កាលបើជួបប្រទះនឹងសេចក្តីពាក់ពាមបែបនោះហើយ បើមិនមានសតិគ្រប់គ្រងរក្សាចិត្តទេ ចិត្តក៏មិនគួរដល់ការងារ គឺតែងលះចោលការងារនោះ

ចានដោយងាយ មិនត្រិះរិះរក។ចាយ មិនគិតរកផ្លូវដែលបន្ថោចង់ កែកុន
ឲ្យឃ្លាតផុតចាកសេចក្តីជំពាក់ខាក់ខាមនោះ។ ចេញឡើយ កាលបើដូច្នេះ
ការងារនោះ ក៏មិនសម្រេច ។

ដោយហេតុនេះ ក្នុងលំដាប់ទី ៣ បន្ទាប់អំពីសេចក្តីព្យាយាមមក
ទើបត្រូវអាស្រ័យសតិផង ព្រោះសតិជាគុណធម៌គ្រប់គ្រងរក្សាចិត្ត
ឲ្យប្រព្រឹត្តទៅតែក្នុងការងារនោះ។ ជាស់គ្មឹងចិត្តមិនឲ្យរួញរា ក្នុងកាល
ដែលជួបប្រទះសេចក្តីជំពាក់ខាក់ខាម អាចជំរុញពុះពារឲ្យអង់អាច
ក្នុងការងារដែលត្រូវធ្វើរក។ចាយក្នុងវិធីកែកុន មិនតែប៉ុណ្ណោះ សតិនេះជា
គ្រឿងការពារឲ្យធ្វើការងារនោះ។ មិនឲ្យភ្លំងភ្លាត់ទៅបាន ពាំងជាហេតុ
ឲ្យកត់ចំណាំនឹងឲ្យព្រមបានន្ទូវការងារ ដែលធ្វើតទៅខាងមុខផង
រួមសេចក្តីថា "សតិជាគ្រឿងធ្វើចិត្តឲ្យគួរដល់ការងារ" ។

ធម្មតាចិត្ត សូម្បីតាំងនៅក្នុងសេចក្តីគ្រប់គ្រងរក្សានឹងសេចក្តីខំនុក
បំរុងគាំទ្រយ៉ាងណាក៏ពិតមែនហើយ តែជួនកាលសតិមិនអាចរក្សាចិត្ត
បាន ព្រោះចិត្តមានអំណាចច្រើនជាង ដល់វេលាល្អក៏ល្អ ដល់វេលា
អាក្រក់កើតឡើងហើយ សតិក៏នៅជាសតិ មិនអាចរក្សាការពារចិត្តបាន
បើមិនដូច្នោះ សតិដែលជាអ្នកគ្រប់គ្រងហ្នឹងឯង មានវេលាភ្លាត់ភ្លំងខ្លួច
ខាតដូចគ្នា កាលបើសតិភ្លាត់ភ្លំងហើយ ចិត្តក៏តែងវាយមាយ មានសេចក្តី
ប្រែប្រួលទៅជាច្រើនផ្លូវ មិនអាចត្រិះរិះដល់ការងារ ដែលខ្លួនធ្វើសោះ
ឡើយ; ការងារនោះក៏ខានសំរេច ។

ព្រោះហេតុនោះ ក្នុងលំដាប់ទី ៤ បន្ទាប់អំពីសតិមក ត្រូវប្រើសមាធិមួយទៀត ព្រោះសមាធិជាគុណធម៌គ្រប់គ្រងចិត្ត មិនឲ្យរាយមាយ ឲ្យប្រព្រឹត្តស្មោះស្មើដោយអាការដ៏មាំមួន មិនឲ្យចិត្តប្រែប្រួលទៅក្នុងអារម្មណ៍ដទៃគ្រប់យ៉ាង ឲ្យស្ថិតនៅតែក្នុងការងារនោះ ។

កាលបើដូច្នោះ ការងារដែលខ្លួនធ្វើនោះ ពាក់ថាបានចូលទៅកាន់សេចក្តីសំរេច តែដែលមិនបានសំរេចនោះ ព្រោះខ្វះបញ្ញាដែលជាកំលាំងសំខាន់បំផុតក្នុងកំលាំងទាំង ៥ នោះ ។

ព្រោះហេតុនោះ ក្នុងលំដាប់ទី ៥ បន្ទាប់អំពីសមាធិនោះ ត្រូវប្រកបដោយបញ្ញាមួយទៀត ព្រោះបញ្ញាជាគុណធម៌ ធ្វើឲ្យឈ្លាសវៃអង់អាចតាមធម្មតានិយម បើបុគ្គលមានបញ្ញា ដឹងហេតុនៃសេចក្តីវិនាសនឹងសេចក្តីចំរើន ឲ្យដំណើរការងារបស់ខ្លួននោះឃ្លាតចាកសេចក្តីអាក្រក់ចេញ ឲ្យប្រព្រឹត្តទៅ តែក្នុងផ្លូវល្អ ផ្លូវប្រពៃ; កាលបើដូច្នោះ ការងារបស់ខ្លួនដែលប្រកបនោះ តែងបានសំរេចដោយងាយ ប្រយោជន៍ដែលប្រាថ្នា ផលដែលខ្លួនប៉ុនប៉ង តែងកើតឡើងតាមសេចក្តីប្រាថ្នា ។

ធម៌ ៥ ប្រការនេះ សុទ្ធតែជាកំលាំងដ៏ក្រៃលែង ក្នុងការប្រកបការងារដូចសំដែងមកនេះ ទើបមានឈ្មោះថាពល: ។ មួយទៀតធម៌ទាំង ៥ ប្រការនេះ មានឈ្មោះថាឥន្ទ្រិយ: ដោយអធិប្បាយថា: ជាធំក្នុងកិច្ចរបស់ខ្លួន គឺសទ្ធាក៏ជាធំខាងចំណែកសទ្ធា; វិរិយ: ក៏ជាធំខាង

វីរិយ: ; សតិក៏ជាធំខាងចំណែកសតិ ; សមាធិក៏ជាធំខាងចំណែកសមាធិ ; បញ្ញាក៏ជាធំខាងចំណែកបញ្ញា ; ជាធំផ្សេង ៗ គ្នា មិនបាច់អាស្រ័យគ្នា ដូចពលៈទេ ; ព្រោះហេតុនោះ ទើបមានឈ្មោះថាឥន្ទ្រិយ ៗ

ហេតុដូចម្តេចបានជា សទ្ធា, វីរិយ, សតិ, សមាធិ, បញ្ញា, ទើបមានឈ្មោះថាធម្មជាកំលាំង ឬជាធំក្នុងកិច្ចរបស់ខ្លួន?

កំលាំងជាគ្រឿងទំនុកបំរុងឲ្យកិច្ចការដែលខ្លួនប្រាថ្នាប៉ុនប៉ងបានដល់សេចក្តីសំរេច ដូចយ៉ាងស្រុកនគរ នឹងមានជ័យជំនះ ឈ្នះសត្រូវខាងក្រៅបាន ក៏ត្រូវអាស្រ័យកំលាំងទាហាន នឹងកំលាំងទ្រព្យ ដែលជាគ្រឿងចិញ្ចឹមគ្នា ដែលហៅថាកំលាំងកាយកំលាំងទ្រព្យ មួយទៀត ការដែលឈ្នះសត្រូវខាងក្នុង ក៏ត្រូវអាស្រ័យកំលាំងការធ្វើវិធ្វាស ដែលប្រព្រឹត្តទៅដោយប្រពៃ បើមិនមានកំលាំងទាំងអម្បាលនេះទេ កិច្ចដែលខ្លួនប៉ុនប៉ងនោះ ក៏មិនបានសម្រេច, សេចក្តីនេះ មានឧបមាយ៉ាងណា ; កិច្ចខាងដើមដែលបុគ្គលគប្បីធ្វើ ក៏ដូច្នោះដែរ ។

បណ្តាកិច្ចការទាំងពួង ដែលត្រូវធ្វើដោយកាយតែងអាស្រ័យចិត្ត ព្រោះចិត្តជាធំក្នុងកិច្ចការ ដែលបង្អាប់អវយវៈទាំងអស់, កាយប្រៀបដូចរូបតុក្កតា ចិត្តដូចមនុស្សអ្នកទាញ រូបតុក្កតានឹងប្រព្រឹត្តទៅយ៉ាងណា ក៏ព្រោះមនុស្សទាញ ព្រោះហេតុនេះចិត្តមានកំលាំង ទើបញុំាងកាយឲ្យក្លាហាន ប្រកបកិច្ចការសំរេចតាមសេចក្តីប្រាថ្នាបាន បើមិនមាន

កំលាំងចិត្តទេ ក៏ទឹងធ្វើកិច្ចការអ្វីមិនកើត ដូចបុគ្គលដែលមានកំលាំងខ្លាំង ល្មមទឹងធ្វើកិច្ចការទាំងពួងបានពិត, តែបើខ្វះសទ្ធាគឺសេចក្តីជឿថា អំពើដែលត្រូវធ្វើទឹងបានផលយ៉ាងនេះហើយ កាយក៏មិនច្បាស់ថ្នាក់ធ្វើ សូម្បីមានសទ្ធាជាគ្រឿងបត្តម្ភហើយ ចិត្តក៏មិនងាយនឹងធ្វើអ្វីកើត បើមិនមានសេចក្តីភ្យាយាមកាយជួយជាកំលាំងផងទេ ក៏មិនអាចនឹងធ្វើអ្វីបាន គ្រាន់តែនឹកចង់មិនចេះអស់មិនចេះហើយប៉ុណ្ណោះ ។ ឯប្រយោជន៍ដែលត្រូវបាន ក៏មិនបានដូចបំណង; ព្រោះហេតុនោះ ទើបត្រូវអាស្រ័យសេចក្តីព្យាយាម ។ សេចក្តីព្យាយាមនេះឯង អាចឲ្យបានសំរេចប្រយោជន៍គ្រប់យ៉ាងដល់បុគ្គល ដែលប្រឹងប្រែងឧស្សាហ៍ព្យាយាមសឲ្យំ ធ្វើមូវកិច្ចការសព្វសារពើ ដោយមិនទំនង់អាងដល់ពេលខ្ជិលទាំង ៦ យ៉ាង មានមិនធ្វើការងារដោយអាងថាត្រជាក់ណាស់ ងារណាស់ដាដើម កាលបើបុគ្គលមិនទំនង់អាងដល់ខ្ជិលហើយ មានសេចក្តីឧស្សាហ៍ព្យាយាមប្រកបការងារទាំងពួង ទ្រព្យសម្បត្តិទឹងសម្បូណ៌ពោរពាសដល់បុគ្គលនោះដោយឆាប់រហ័ស ព្រោះតែបុគ្គលនោះមិនមានសេចក្តីរួញរាចំពោះក្តៅទឹងត្រជាក់ ដូចជាស្មៅមិនអើពើទឹងកំដៅថ្ងៃទឹងត្រជាក់ បើទុកជាក្តៅត្រជាក់យ៉ាងណា ក៏ស្មៅមិនរួញតឿបបុះពៅឡើយ សេចក្តីនេះសមដូចព្រះគាសិតថា:

យោ ច សីតញ្ច ឧណ្ហញ្ច តិណាភិយ្យោ ន មញ្ញតិ
ករំ បុរិសកិច្ចានិ សោ សុខា ន វិហាយតិ ។

សេចក្តីថា: "ជនណាមួយ កាលបើកំពុងធ្វើការងារដែលបុរសត្រូវធ្វើនោះ មិនសំគាល់នូវត្រជាក់ទឹងក្តៅ ដោយកៃលែងជាងស្មៅ គឺថាមិនអើពើក្នុងត្រជាក់ទឹងក្តៅ ដូចជាស្មៅ ជននោះឯងទឹងមិនសាបសូន្យ មិនឃ្លាតចេញពីសេចក្តីសុខឡើយ" ។

ម្យ៉ាងទៀត ជនណាដែលខ្ជិលប្រអូសមិនគិតប្រឹងប្រែងរកទ្រព្យសម្បត្តិ គិតតែដេរលេងស៊ីផឹក សេពគប់នឹងមិត្តអាក្រក់ ជាមនុស្សគ្មានកតា រកតែរឿងទាស់ខែង មនុស្សប្រែបនេះ មិនដាយនឹងធ្វើខ្លួនឲ្យបានសេចក្តីសុខ-ចំរើនទេមានតែសេចក្តីវិនាសម្យ៉ាង កាលដែលខ្លួននៅមានកំលាំងកំហែងមាំមួនឆើបុងៗ មិនប្រឹងរកទ្រព្យសម្បត្តិមកទុកជាក់ឲ្យគ្រន់វង្សនៅស្ថិតស្ថេរចិរកាលតទៅទេ ព្រោះតែសេចក្តីប្រមាទខ្ជិលប្រអូសចូលមកលុកលុយម្ល៉ោះហើយទ្រព្យសម្បត្តិពីណានឹងកើតមាន ? កាលបើមិនមានទ្រព្យសម្បត្តិហើយ សេចក្តីសុខក៏មិនមានឡើយ, លុះដល់យូរទៅសំលៀកបំពាក់ ក៏រហែកអស់ ដេរអាក៏សែ អនាថាតទឹងដេរដោយម្ជុលឈើ ចិញ្ចើមថ្ពល់ធ្លុះក្លែកក្លឹះ ។ ពាំងបាយអាហារសោតទៀត ស្ទើរតែរកបំពេញពោះមិនបាន បើបានក៏បានដោយថោកគាបមនុស្សដែលគ្មានកន្លែងទៅកាន់ហាន: ដ៏ថោកគាបយ៉ាងនេះឯង ព្រោះតែមិន

មានសេចក្តីទុស្សាហ៍ព្យាយាមប្រឹងប្រែងរកទ្រព្យសម្បត្តិ ជាមនុស្សឆ្លៀវឆ្លាស បានជាភ្ជាក់ខ្លួនទៅកាន់ហាន:ដ៏ថោកទាបយ៉ាងនេះ ។

ព្រោះហេតុនេះ គួរយើងខំប្រឹង ប្រកបការងារឲ្យមុឺងមាត់ឡើង ត្រូវកំចាត់បង់សេចក្តីខ្ជិលច្រអូសចេញពីខ្លួនសន្តាន ហើយញុំាងវីរិយៈសេចក្តីព្យាយាមប្រឹងប្រែងឲ្យកើតមានឡើង, កាលណាបើមានវីរិយៈហើយ ទ្រព្យសម្បត្តិគង់តែកើតមានពិតប្រាកដ ។

មួយទៀត មានជនពួកខ្លះច្រើនប្រកាន់លទ្ធិយថាកម្ម គឺលទ្ធិដែលធ្វើអ្វីហើយមិនប្រឹងប្រែងធ្វើឲ្យមែនទែនទេ ធ្វើទៅតាមបុណ្យតាមកម្ម ដោយជឿថា បើបុណ្យយើងមានចាំបាច់ទៅធ្វើប៉ុន្មាន យើងគង់តែនឹងបានជាសេដ្ឋី ជាអ្នកមាន ជាដើមមិនខាន ដល់គិតដូច្នេះហើយ ធ្វើអ្វីក៏សុទ្ធតែសោះអង្គើយខាងអស់ រៀនសូត្រក៏មិនពិតប្រាកដធ្វើជំនួញដួញប្រែអ្វីក៏មិនប្រឹងប្រែង ធ្វើស្រែការចម្ការដំណាំក៏មិនខ្នះខ្នែង អាងឡើងតែស្រែកបន់ស្រន់អំពាវនាវរកខ្មោច ឲ្យលោកចុះមកជួយ ។ ពុំគួរឲ្យខ្មោចជួយទេនូវ ឲ្យជួយលក់ដូរឲ្យបានជាធំធាប់ ឲ្យបានចំណេញមានកំរៃច្រើនដូច្នោះទេ បន់ស្រន់ឲ្យខ្មោចជួយយកទឹកនឹងដីមកចាក់ស្រែចំការចម្ការដំណាំឲ្យ ដើម្បីឲ្យលូតលាស់មានផ្លែផ្កាសម្បូណ៌ឡើង មិនគិតខំប្រឹងរៀនសូត្រ ឲ្យមែនទែនឡើង តស៊ូនឹងសេចក្តីលំបាកគ្រប់យ៉ាង មិនខំប្រឹងប្រែងធ្វើជំនួញដួញប្រែដោយយកចិត្តទុកដាក់ អត់ធន់

ន៍ឯបស់គ្គគ្រប់ផ្លូវ ស៊ូត្រាំនឹងសេចក្តីលំបាកខ្លាំយហត់គ្រប់ប្រការ មិនខំក្លាវាស់កាប់ឆ្ការឲ្យម៉ឺងម៉ាត់ ជាបឋមបញ្ចូល ឬដឹកប្រឡាយបង្ហូតទឹកវាកដ៏ចាក់ដោយសេចក្តីខ្ជិលច្រអូសនោះឡើយ គិតតែបន់ស្រន់ខ្ពាតែមប៉ាងកាលបើមានសេចក្តីសង្ឃឹម នៅលើខ្ពាដូច្នោះហើយ សេចក្តីប្រឹងប្រែងគ្រប់ផ្លូវ ក៏បន្ទរបន្ទុយចេញទៅអស់ដេកចាំមើលផ្លូវខ្ពាចុះមកជួយ មិនដឹងខ្ពាណា ក៏នឹងចាំតែចុះមកជួយអ្នកនោះ; បើទៅកើតជាខ្ពាហើយ នៅតែត្រូវនៃចុះមកជួយរឿនសូត្រសិក្សាជួយលក់ជួយដូរ ជួយក្លែវែសាកាប់ចំការ ឲ្យមនុស្សឲ្យលាំបាកដូច្នោះទៀត តើចាំបាច់ទៅកើតជាខ្ពាធ្វើអ្វី? នៅជាមនុស្សលោកវិញស្រួលជាងទៅកើតជាខ្ពា បើនៅតែមកជួយធ្វើការដដែលដូច្នោះ ។

បើបន់ស្រន់ទៅ លោជួនជាថ្ងៃណា ខែណា ឆ្នាំណា បានប្រទះត្រូវបំណន់របស់ខ្លួន ក៏តាំងសរសើរកត់ឮសំណាង ថាខ្ពាជួយខ្លួនខ្ពាមានឫទ្ធិ មានអំណាច អាចបណ្តាលឲ្យបំណន់របស់ខ្លួនបានសំរេចប្រសិនណាជួនជារឿនមិនចេះ លក់មិនជាច់ខាតពុន ធ្វើស្រែចំការមិនបានផល ក៏គោងដេរប្រទេចផ្តាសាដល់ពួកខ្ពា ដោយពាក្យទ្រគោះបោះបោកផ្សេង ។ កាលបើមានសេចក្តីប្រមាថបួលមកលុកលុយក្នុងខ្លួនធ្វើឲ្យចិត្តកករលក់សៅហ្មងដូច្នោះហើយ ម្ល៉ោះហើយក៏ចេះតែហ៊ានហោចចុះឥតមានសេចក្តីចំរើនលូតលាស់ដុះដាលទៅមុខឡើយ លុទ្ធិបែបនេះ

ហើយ ដែលហៅថា លទ្ធិយថាកម្ម គឺធ្វើកិច្ចការអ្វីដែលខាំងពួន សុទ្ធតែឲ្យខ្មោចព្រាយចុះមកជួយសំរេចឲ្យខាំងអស់ មិនប្រើឲ្យបានសំរេចដោយខ្លួនឯងនេះ លទ្ធិយថាកម្មនេះ បើមាននៅលើរូបបុគ្គលណាហើយ ត្រូវលះចោលចេញកុំឲ្យអត្មាមន្តលនេះនៅបានឡើយ ។

ព្រោះហេតុនោះ ជនដែលប្រាថ្នាខ្លួនសេចក្តីចំរើនដល់ខ្លួន ត្រូវប្រើឲ្យពេញដៃពេញជើងឡើង ប្រើឲ្យអស់ពីចិត្តឡើង កុំធ្វើអ្វី ។ ដោយផ្សែងសំណាងថា: មើ ! បើសំណាងយើងមាន យើងបានសាងទុកពីមុនមក កិច្ចការរបស់យើងនោះ គង់តែនឹងបានសំរេចដល់យើងជាមិនខានទេ ។

ការដែលជនធ្វើអ្វី ។ ហើយគិតដូច្នេះនេះពុំប្រពៃឡើយ សំណាងដែលយើងបានសាងមកនោះ ក៏គឺបានចាត់ឲ្យយើងមកកើត ជាមនុស្សចាត់ឲ្យយើងមានអាយុវែងគ្រប់គ្រាន់មិនខ្លះខាត មិនវិកលវិការដៃជើងចាក់ក្អែកខ្វាក់ត្រចៀកថ្លង់នោះហើយ គង់ដែលធ្វើបាបអ្វីដែលខាំងពួងនោះ ក៏ស្រេចតែនឹងយើងត្រូវធ្វើខ្លួនឯង សំណាងក៏មិនអាចនឹងបង្ហូរទ្រព្យសម្បត្តិ ឬកិច្ចការសព្វជំពូកមកឲ្យយើងបាន ក្នុងពេលដែលយើងមិនធ្វើអ្វីសោះនោះទេ សំណាងក៏មិនលះបង់ចោលយើងស្មោះ គង់តែនឹងជួយយើងតទៅ បើយើងខំប្រឹងធ្វើកិច្ចការខាំងពួង ដោយយកចិត្តទុកដាក់តែសំណាងនឹងលះបង់ចោលយើងនោះ នឹងមិនជួយយើងក្នុងកាលដែល

យើងដេកនៅស្ងៀមមិនធ្វើអ្វី ។ ទំតែស្រែកហៅព្រៃងសំណាងទេ ។ នោះហើយទន្ទឹងមិនជួយយើងកងវេលាដែលធ្វើការងារ បៃបសោះអង្គុយដោយមិនយកចិត្តទុកដាក់ ? . ហើយត្រូវទំធ្វើកិច្ចការឲ្យពេញកំលាំងតែម្យ៉ាង បើមានឧស្សាហ៍ព្យាយាមយកចិត្តទុកដាក់ ដោយម៉ឺងម៉ាត់ចំពោះកិច្ចការដែលខ្លួនត្រូវធ្វើនោះ ទ្រព្យសម្បត្តិនឹងកើតច្រាកដ កាលបើមានទ្រព្យសម្បត្តិហើយសេចក្តីសុខ-ចំរើន តែងតែហុចឲ្យកាលកាលវេលា កងបច្ចុប្បន្ននេះ រហូតទៅដល់បរលោកនាយ ។

ឯីយ:សេចក្តីព្យាយាមនេះ ជាហេតុឲ្យបានសំរេចសេចក្តីច្បាច្បាគ្រប់យ៉ាង ព្រោះហេតុនោះ បានជាចាត់ថាមានកំលាំង ទើបអាចធ្វើការងាំងពួងពេញកំលាំង ដែលគួរធ្វើទៅបាន ព្រោះហេតុនោះត្រូវប្រើកំលាំងសតិ បំពេញឡើងទៀត ដើម្បីជាជំនួយចិត្ត ឲ្យមានកំលាំងហើយបង្គាប់កាយឲ្យធ្វើការងាំងពួង ដែលខ្លួនយើងត្រូវការពិត ។ តែការដែលសតិជាគ្រឿងត្រួតត្រាកំលាំងដទៃ ។ បាននោះ ក៏ត្រូវអាស្រ័យការធ្វើចិត្តឲ្យជាសមាធិ ឲ្យមានកំលាំងក្លាហានទន្ទឹងនៅកងអារម្មណ៍តែមួយ ។ ដោយហេតុនេះត្រូវអាស្រ័យកំលាំងគឺសមាធិទៀត ទើបរឹតតែមានកំលាំងច្រើនឡើង ។ ក៏កំលាំងត្រឹមតែប៉ុណ្ណោះ មិនសូវពូកែណាស់នៅឡើយទេ បើការធំ ។ ក៏ល្មមសំរេចបានដូចច្បាច្បា បើកិច្ចណាដែលល្អិតជ្រាលជ្រៅ ជារបស់កំចាំងដូចជាកិលេស ដែលដេកគ្រាំនៅកងសន្តាន

ហើយប្រើត្រឹមតែកំលាំងប៉ុណ្ណោះ ក៏មិនអាចនឹងកំចាត់ទៅបានឡើយ ។ លុះតែអាស្រ័យបញ្ញារកហេតុផល ឲ្យដឹងតាមពិតជាគ្រឿងយឺតយោងផង ទើបអាចឲ្យកិច្ចការនោះសម្រេចទៅបាន ។

អធិប្បាយមកត្រឹមតែប៉ុណ្ណោះ ក៏អាចនឹងបានជាគ្រឿងសំគាល់កំលាំងចិត្តប្រការ ๑ សមដូចជាពុទ្ធភាសិត ដែលសំដែងចំពោះព្រះបាទបសេនទិកោសលថា អាបទាសុ ខោ មហារាជ ปาโม ฌายิตพฺโพ សេចក្តីថា "បពិត្រមហារាជ ! កុងអន្តពយទាំងឡាយ កំលាំងចិត្តបណ្ឌិតគប្បីដឹងបាន" ។

កំលាំងចិត្តបែបនេះ អាចធ្វើបុគ្គលឲ្យជាឥស្សរជនបាន ឥស្សរជនដែលប្រកបដោយកំលាំងចិត្តបែបនេះហើយ រមែងរក្សាសេចក្តីសុខសំពន្ធរបស់ខ្លួន នឹងបុគ្គលដទៃឲ្យស្ថិតស្ថេរនៅបានដូច្នេះជាដើម ទើបជាគុណគួរអស់សាធុជនទាំងឡាយប្រាថ្នាណាស់ ព្រោះថាមនុស្សទាំងឡាយជាច្រើន ដែលទៅជាមនុស្សឥតប្រយោជន៍ប្រើការមិនកើតនោះ ព្រោះខ្វះធម៌ ๕ ប្រការនេះ ជាគ្រឿងដួយកំលាំងចិត្ត, ធម៌ទាំង ๕ ប្រការនេះ មានអធិប្បាយថាជាកំលាំងដូច្នេះឯង ។

អាត្មាភាពសំដែងមកដោយសេចក្តីសង្ខេប សូមសន្មតថាចប់តាមសមគួរដល់ពេលវេលា ឯវំ ។

จบ

រឿងកុណ្ឌាលកេសីជើរ

ពាក្យកាព្យ

ព្រះមហា សុខុមាលី-សេន ពិន្ទប្បញ្ញោ

អាចារ្យសាលាបាលីវគ្គវត្តផ្អោរកា ខេត្តឃ្លាំង (កម្ពុជាក្រោម)

រៀបរៀង

ព. ស. ២៤៩៤ គ. ស.១៩៥១

អារម្ភកថា

ហត្ថទាំងទ្វី ចាប់គម្ពីរ បើកពិនិត្យ
អានប្រយោគ រកប្រធាន បានរិះគិត
ចាប់ប្រឌិត គិតប្រដៅ ចាកបាលី ។
អាទិភ្ញុ សូមបង្គំ ផ្គុំអញ្ជលី
ក្រាបវន្ទី ទីរំលឹក គុណកែវបី
សូមចំរើន ជោគមង្គល ផ្តល់សួស្តី
សព្វកត្តិ កុំបីឃ្លាត រាត្តខាន ។
រាត្តខុស ព្រោះខ្ញុំទំ រិះប្រឹងប្រែត
រិះប្រឹងប្រែ កែលំអិត កាព្យលំអាន
កាព្យលំអ ឲ្យបវរ តាមដោយជាន
តាមដោយដើម រឿងដែលមាន កូនបាលី ។

គ្នាវៃឆ៍លើក យកឧបមា ណាដែលសម
ណាដែលសុទ្ធ តែឧត្តម យ៉ាងខ្លី ។
យ៉ាងខ្លីខ្លះ មិនតែងតាម តែបាលី
តែបានលើក យកពាក្យថ្មី ថ្លៃដំនួស ។
ថ្លៃដំនួយ ជួយឲ្យបាន រឿងសោកា
រឿងសោកាណា ប្រសិនជា មានខុសហួស
មានខុសហើយ សូមបណ្ឌិត អាណិតជួស
អាណិតជួយ កុំឲ្យជ្រួស ខុសកាព្យគិត ។
ខុសកាព្យកៃ ជួយផ្សះផ្សំ ទំតម្រង់
ទំតម្រូវ ឲ្យត្រូវត្រង់ ខ្ញុំវិចិត្រ
ខ្ញុំក៏ថា កាព្យសង្ហា យ៉ាងប្រណិត
យើងប្រណម្យ ចំបណ្ឌិត អរគុណខ្លុក ។
អរគុណចាំង អស់លោកអ្នក បានអានស្តាប់
បានអានស្តី ដំណាលច្បាប់ ដល់ប្រមុខ
ដល់ប្រមាណ ជនជាតិខ្មែរ ពីទំនុក
ពីទំនង កាព្យនេះខ្លុក ជាច្បាប់ស្រែ ។
ជាច្បាប់ស្រាប់ កុំឲ្យស្រែប ស្រាលឈ្នានពាន
ស្រែបខ្លាំងពេក ខ្មាសមិនមាន ហ៊ានមេត្រី

ហ៊ានមាតុច្ឆេស្តេ ឧុសសណ្ហាប់ ច្បាប់លោកិយ
ច្បាប់លក់កើរ៍ កើតអប្រិយ ដូចរឿងនេះ ។
ដូចរឿងហ្នឹង ត្រូវតែដឹង ថាកាមា
ថាកាមមិន មានសុខា ត្រង់ណាអេះ
ត្រង់នេះឲ្យ ស្រីជាន់ក្រោយ យកតម្រេះ
យកតម្រាប់ កុំឆាប់ចេះ តែសមាគម ។
តែស្នានគង់ មាននារី ជាតិពិសី
ជាតិពិសុទ្ធ ព្រហ្មចារិនី ថ្លៃទុត្តម
ថ្លៃទុត្តង្គ ពង្សចរិយា ថាសក្តិសម
ថ្លៃសោតសឹង ពោលថាខ្ញុំ តែងបន្ទាប ។
តែងបន្ទោស ព្រោះហេតុនោះ សូមពិនិត្យ
សូមពណិនា កាព្យវិចិត្រ ចប់ទើបជ្រាប
ចប់ល្អល់ច្រើន ទើបចំរើន ដូចបានលាភ
ដូចបានលេប ត្រៃបសភាព សុភាសិត ។
សុភាសោ សប្បញ្ញោ កោសល្យំ
កុសលោ ហោមិ, ហំ តាំងប្រណិត
តាំងប្រណិធាន មានសច្ចា ច្បាថ្នាពិត
ច្បាថ្នាពេញ ទៅដោយចិត្ត ចង់ឲ្យចេះ ។

ចង់ឲ្យជន គ្រប់តម្បន់ ខេមរជាតិ
ខេមរជន ចំពីឃ្នាត រៀនតម្រែះ
រៀនតម្រាប់ កាព្យបុរាណ ឲ្យបានចេះ
ឲ្យបានជឿន ដោយចំណេះ កាព្យាអើយ ។

កាមរិគ្គ

រឿងកុណ្ឌលកេសីថេរី — មានក្នុងជាលីជម្ពុបទ
សហស្សវគ្គកាគបួនក្បួនកំណត់ — ចង់ដឹងជ្រាកដូចម្តេចសូន្យនា ។
កិរៈដំណាលកាលអតីត — ជំនាន់ព្រៃឆ្ងាយព្រឹទ្ធិបុរាណា
ភជគ្គីនបុរីមហិសីមា — មែនមានធីតាមហាសេដ្ឋី ។
អាយុគ្រប់ដប់ប្រាំមួយឆ្នាំ — មានរូបលំនាំគ្រាលស្រី
ឃើញគួរស្នេហាគួរមេត្រី — ស្រស់ភ័ក្ត្រចិមចិយកបកល្យាណ ។
បណ្តាបុរសក្នុងបុរី — មានចិត្តបេតីតែគ្រប់ជ្រាណ
ឃើញសែនស្នេហាពន់ប្រមាណ — ប៉ុន្តែមិនបានបំពានសោះ ។
ទំនៀមស្រី ។ វ័យនេះឯង — ច្រើនតែសំដែងបុកឡេះឡោះ
គ្មានស្រីណាមួយរួចដល់សោះ — ចូលចិត្តញោះញោះប្រុសទាំងឡាយ ។
គួយ៉ាងដូចសេដ្ឋីធីតា — រូបពងសង្ឃាស្រស់ឆើតឆាយ
ចូលចិត្តបន្ទែងលេងលែបខាយ — ញោះញោះសប្បាយនឹងបុរស ។

សេដ្ឋីជាមាតាបិតា ឃានឃើញធីតារូបស្រស់បស់
ចូលចិត្តចរចានឹងបុរស ឥតស់អស់ឥរិយាមិនបវរ ។
គិតថាធម្មតាកាពស្ត្រី សំក្តីសមប្រិមប្រិយគួរស្មោះសរ
ប្រុសតែងមនារមចោមអបអរ សាទរក្នុងចិត្តតែគ្រប់ឃ្លាណ ។
គិតហើយឲ្យជាងសង់ឃ្លាសាទ ប្រាំពីរជាន់ស្អាតជាគ្រឹស្ថាន
សម្រាប់ធីតានោមកល្យាណ មានហ៊ានអភិរម្យបន្ទំស្ងាត់ ។
ឲ្យនៅតែស្រី ។ ការពារ ព្យាឃាលថែទាំយ៉ាងមធ្យត
ឃប់ថ្ងៃក្បាជាម៉ឺងម៉ាត់ ប្រយ័ត្នរវាងអគ្គធីតា ។
ថ្ងៃឯពីបុរសកំឡោះម្នាក់ រូបពងសមសំក្តីធើតធាយ
រកស៊ីលួចចូនពាស្ត្រជ្ងា កាជការចាប់ចងសំពងវាយ ។
បណ្តើរគោក្រៃសសព្វផ្សារផ្សារ មនុស្សម្នាគោឡាឈូនិយាយ
ផ្តន្ទាបុរសដែលគេវាយ ប្រមាថមើលងាយព្រោះវាចោរ ។
គ្រានោះធីតាមហាសេដ្ឋី ឃានឮសំដីពាសផ្សារផ្សារ
គិតថាសួរអ្វីឮចោរ ។ រំពងនោឡោទើបមើលជាក់ ។
ឃើញប្រុសកំឡោះជាប់ចោរ ក្តួចកើតស្នេហាព្រឺញ៉ាញាក់
ញ័រកាយដូចគេចាប់កន្ត្រាក់ ហេតុតែកាមចាក់ដោតពេលខ្លួន ។
គួរនាដួចជាសត្វក្រៃបី ជាប់អន់ចំណីយូរចំនួន
ឃើញដុំចាប់ស្មៅឃានញ័រខ្លួន ។ ឧបមេយ្យដូចខ្លួនកូនសេដ្ឋី ។

ជាប់លើច្រាសខ្ចាំពីរជាន់ បរិពារពេបជាន់សុទ្ធស្រី ។
មិនដែលបានដើរនិយាយស្តី ទឹងច្រឡុសសូម្បីម្នាក់ក៏គ្មាន ។
ហេតុតែកាមភាគជុតពេលវាល នាំឲ្យត្រេះបស្រាលស្រែវស្រែកឃ្នាន
ចិត្តចើតចង់ណាស់ខ្លាសមិនមាន ទឹកថាមិនបានស៊ូតែស្លាប់ ។
ប្រែច្រាណប្រះដេកលើសយនា ក្តួលក្តៅខ្លាចផ្សារប្រែផ្សារផ្តាប់
បែរក្អែងរឹងតែឥតសុខសាប់ ក្តងចិត្តតែចាប់សន្ធឹកមួន ។
នត្តិ ភគសមោគ្គិ ក្តៅងភគអាទិក្តៅញ៉ាខ្លួន
ពេលចិត្តជុតកាយគ្រប់ចំនួន ជុតខ្លួនចិត្តសត្វសព្វកាយា ។
គ្រាន់តែយើញគេមួយក្រៃឡែក ចិត្តនាងឃ្នានស្រែកស្រែបស្នេហា
ប្រះច្រាណនឿលលើសយនា ខ្ចោចផ្សាអាល័យស្រមៃនឹក ។
អស់ពួកទាសីស្រីបរិវារ ដែលនៅព្យាបាលក័យពន្ធឹក
ព្រោះយើញធីតាដេកសន្ធឹក សន្ធែវពុកហាក់ឈឺធ្ងន់ ។
រត់ទៅជម្រាបមហាសេដ្ឋី ព្រមទាំងលោកស្រីជាប្រពន្ធ
ថាជ្រួតកញ្ញាផ្សាខ្លួនខ្លាន់ ឈឺធ្ងន់ពេកណាស់ម្ចាស់ថ្លៃអើយ ។
សេដ្ឋីលោកស្រីក៏មីម្នា ទៅដល់គ្រឹហាកូនស្រីហ៊ាយ
ដៃស្ទាបមាត់សួរថាកូនអើយ ឈឺអ្វីថ្លៃអើយបានស្រីដេក? ។
ធីតាសេដ្ឋីឮស្តីភ្លាម ក្រែកឡើងទីមាមពីដំណេក
លើកដៃប្រណម្យទំយំយេក ខ្លាសពេកនាងមិនហ៊ានបរាថា ។

លោកស្រីស្រដីសួរប្រញាប់ កូនអើយចូរប្រាប់ម្តាយឆាប់ៗ
ម្តាយនឹងរកគេទៀមកវក្សា ជាក់ច្បាំកញ្ចាវក្សាស្រី? ។
– អម្ចាស់បពិត្រលោកម្តាយអើយ ម្ចាស់អើយកូនមិនមានឈឺអី!
– អើចុះធីតាផ្សារព្រោះអ្វី ចូរស្រីប្រាប់ម្តាយតាមត្រង់ស្មោះ! ។
– កូនគ្មានជម្ងឺឈឺអ្វីទេ ឈឺព្រោះចិត្តស្នេហ៍នឹងគេនោះ
ដែលត្រូវបណ្តើរឃុំឯណោះ ព្រោយដំអាក្រៃសល់ពួនធ្លោឡា ។
កូនបានឃើញក្លាមមានចិត្តស្ម័គ្រ អនេកអនន្តប្បដិពន្ធ
ប្រសិនមិនបានសន្ទិវាសោ នឹងចោរពេញជាស្លាប់មិនខ្លះ ។
ប្រហែលជីវិតកូនមិនបាន រស់នៅនាស្ថានមនុស្សនឹងគេ
លុះតែបានរួមរសសិង្គសេ្នហ៍ ទើបរស់នឹងគេណាម្ចាស់អើយ ។
លោកស្រីស្តាប់ស្តីខ្វិឃ្លាតថា កុំ! កុំ! ស្នេហាអានោះឡើយ
អាប់យសសក្តាណាកូនអើយ កុំឡើយយកមនុស្សថោកតែកូល ។
ត្រូវយកតែអ្នកមានជាតិស្មើ មានទ្រព្យប្រសើរជាកំពូល
រកស៊ីមានបានក្សាន្តមិត្តមូល ព្រោះមានតែកូលប្រហែលគ្នា ។
អាមនុស្សពូជទាបប្រមាត់ដី អាប់ឥតសិរីដូចសត្វទា
កុំបីស្រីគប់រាប់រកវា នាំថោកបុកតាពាសីយើង ។
កូនអើយធម្មតាចោរសាមឲ្យ តែកូនកល្យាណាលើកដំកើង
ឡើងចាន់ក្រអើតដើតម៉ឺតឡើង ឫកធ្វើងឡើងដូចឆ្កែជិះឡាន ។

— អម្ចៈបពិត្រលោកម្ដាយអើយ
ប្រសិនណាជាកូនមិនបាន
កូនក៏មិនបានគង់ជីវិត
លុះតែបាន់រួមសេស្ដេហា
លោកស្រីស្ដាប់ហើយឆ្លើយប្រែតថា
ចូរទំកាត់ចិត្តសិទ្ធសិនទៅ
ខ្លះអ្វីបុរសរូបស្រស់ល្អ
ឫកពារុងរឿងពេចន៍រូបពង
ម្ដាយកេឲ្យបានគល្យាណប្រុស
ជាបុត្រសេដ្ឋដ៏ស្រីតអាយ
ធីតាបានស្ដាប់ជម្រាបថា
កូនមិនស្រឡាញ់អ្នកមានទ្រព្យ
នេះគឺហេតុកម្មប្រចាំកាយ
បើមានមេត្តាដល់កូនហើយ
ជីវិតកូនពេញអាស្រួវគ្រាស
ប្រសិនលោកម្ដាយមិនមេត្តា
លោកស្រីទំស្ដីពន្យល់សព្វ
ប្រែប្រាប់ស្វាមីថាលោកអើយ
ម្ចាស់អើយចិត្តកូនសូន្យរំខាន
រួមស្ថានតាមចិត្តស្ដេហា ។
ឃើញពិតជាស្លាប់ធាប់ហើយណា
ដូចក្ដីប្រាថ្នាទើបរស់ទៅ ។
ធីតាកូនអើយកូនស្រីពោ
រង៌ទៅចាំម្ដាយខ្ញុកជាក់នាង៏ ។
សាច់សស័ក្ដិសមសព្វសព្រាំង្គ
ចូរនាង៏ពិសំស្រីតាមម្ដាយ ។
ប្រាជ្ញប្រាយសព្វសុសន្ទុះបរិយាយ
ខ្លះអ្វីស្រីម្ដាយគេមានទ្រព្យ ។
"សូមមានមេត្តាកូនឥតភ័ព្វ
អភ័ព្វជាប់ចិត្តស្រឡាញ់ហើយ ។
ព្រៃឆ៍នាយផង៏កូនម្ចាស់កូនអើយ
កុំឡើយឲ្យកូនសូន្យជីវ៉ា ។
មុខជាវិនាសព្រោះស្ដេហា
ធីតាកូនខ្ញុំសុំលាហើយ . . . ។ ។
បញ្ចប់ប្រាប់កូនមិនព្រមឡើយ
ម្ចាស់អើយធ្វើម្ដេចអាណិត៍កូន ។

សេដ្ឋីទុំស្តីអស់តម្រិះ អង្គុយក្រែអេះគំនិតសូន្យ
ហេតុតែចិត្តគាត់ស្រឡាញ់កូន ក្រែងសូន្យជីវិតព្រោះតណ្ហា ។
ហេតុនេះបានអង្គព្រះកតញ្ញូ ស្តេចទ្រង់និព្វន្ធធម៌ទេសនា
ថាដូនហាប្ញទ័យនៃមេម្ដា ករុណាទន់ទោរអាសូរមួន ។
មេត្តាដល់បុត្រជុតពណិនា ទុបេក្ខាព្រហ្មវិហារធម៌ពាំងបួន
មាតាបិតាមានសព្វខ្លួន ចំពោះរូបកូនមហិមា ។
លោកមហាសេដ្ឋីប្រណីស្មោះ ចំពោះបុត្រីក្រែងមរណា
ភ្លេចថោកអាប់ស័ក្តិពាក្យនិន្ទា ព្រោះព្រហ្មវិហារគឺមេត្តា ។
ទើបប្រើចំរើឲ្យរួសរាន យកថ្ងាក់មួយពាន់កហាបណា
ទៅសូកសុំលោះដោះទោសា នាំចោរយាត្រាមកគ្រឹហា ។
រៀបការធ្វើផ្ទុំឲ្យនារី រួមប្រពៃណីជាមួយគ្នា
ការៈនេះមិនបាច់ទុំពណិនា លោកអ្នកគ្រប់គ្នាជ្រាបស្រាប់ហើយ ។
ធីតាសេដ្ឋីវែងស្នេហ៍ស្ងិទ្ធ ផ្គាប់ប្តីពេកពិតឥតកន្តើយ
រៀបគ្រែទូតុកទូលខ្នើយ ផ្កែកកើយគង់កល់ពេលនិទ្រា ។
សូម្បីបាឃទឹកម្ហូបចំណី សព្វទិនភត្តិគ្រប់វេលា
នាងចេញចាត់ចែងសព្វ ។ គ្រា ពាំងាប់រើមិនឲ្យហ្មង ។
ត្រឹមតែសំដីនាងចរចា ធីតាមិនពោលឲ្យឃើញឆ្គង
ម៉ោប្តីទៅណានាងទៅផង ក្រែយខ្នងដូចរូបនឹងស្រមោល ។

នារីបំរើយ៉ាងមធ្យ័ត ប្រយ័ត្នខ្ជាប់ប្តីលបត់ចោល
រក្សាដូចគោនៅក្នុងគ្រោល ក្រែងវក់រួចចោលបង្កាតធំ ។
សត្វទាពួជពាបដេកពាបដី សូម្បីមានគេធ្លៃខ្ទេចខ្ទំ
មិនដែលសត្វទាណាឡើងចំ ដេកលើខ្ទេចខ្ទំឲ្យថ្កុំថ្កើង ។
ពុំនោះដូចជាតិប្រមាត់ដី សូម្បីនរណាមួយធ្លើខ្វើង
បំពាក់ប្រមាត់ដីឲ្យឡើង លើខ្វើងមិនបាននោះយ៉ាងណា ។
អាចារវិលរូចធ្លាប់លួចប្លន់ ទុកជាប្រពន្ធគ្គាប់ម្ល៉ះម្ល៉ា
វាគ្មានសប្បាយចិត្តត្រង់ណា មានឧបមេយ្យថាយ៉ាងនោះឯង ។
ព្រោះវាធ្លាប់ស៊ីងឹកហ៊ីហា នៅផ្ទះសុភសព្វកន្ទែង
ដួបដុំម៉ាកមិត្តសុទ្ធអកល្បែង ដល់ស៊ីម្នាក់ឯងមិនសប្បាយ ។
អ្នកអើយសម្បត្តិមហាសេដ្ឋី មិនមានខ្វះអ្វីតាមចិត្តចាយ
ប៉ុន្តែអាចារមិនសប្បាយ ព្រោះក្តៅក្រហាយដោយទុជ្ជិន ។
បានកូនសេដ្ឋីប៉ិយបួនថ្ងៃ អាចារចង្រៃពាលមោហន្ធ
សប្បាយមិនធ្លុនខ្លួនទុជ្ជិន ទើបគិតរិះគន់ក្នុងចិត្តថា: ។
“អញគិតសម្លាប់កូនសេដ្ឋី ដោយគ្មានបាយអ្វីទើបបាន?
ហើយអញនឹងយកអាករណា លក់ទិញសុភស៊ីសប្បាយ ។
ចុះអញសម្លាប់ដោយរឿងអី ឲ្យជិតសេចក្តីកុំឲ្យសាយ
មានតែនាំវាទៅឲ្យឆ្ងាយ ពីឪពុកម្តាយសឹមសម្លាប់” ។

តែតហើយប្រុះដេកលើសយនា ដេកអត់អាហារហាក់ឈឺចាប់
ប្រពន្ធឃើញភ្លាមសួរប្រញាប់ ថាអ្នកបុកចាប់ឈឺរោគអ្វី ? ។
— កន្ធេមាសមេស់ម្ចាញ់អើយ គ្មានឈឺអ្វីឡើយទេអូនស្រី !
— សាមិបពិត្រអ្នកស្វាមី ចុះមានទាស់អ្វីនឹងអ្នកណា ? ។
ឬមួយលោកម្ដាយលោកឪពុក គាត់មានរំអុកដេរស្ដីថា
ឲ្យអ្នកម្ដេចដឹងឬអ្នកណា គេថាឲ្យអ្នកអាក់អន់អ្វី ? ។
— នុតែវាដីរ៉ាសួនសម្ងាញ់ គាត់គ្មានឱនក្បាញ់នឹងរឿងអី
ចាំងឱ្យកំដរហួងឪាសី គេគ្មានទាស់អ្វីនឹងអញឡើយ ។
— សាមិបពិត្រអ្នកស្វាមី ចុះមានហេតុអ្វីព្រលឹងអើយ
ចូរអ្នកប្រាប់ប្អូនកុំកន្ដើយ ការណ៍អ្វីថ្ងៃអើយប្អូនធានា ។
អាចារប្រាប់ថាដីរ៉ាថ្ងៃ អូនអើយកាលថ្ងៃពួកក្នាក់ងារ
ចាប់ចងរូបចងវ៉ាយផ្ដន្ទា បងស្ដាយដន្ទាពន់ប្រមាណ ។
បងបានបួងសួងបន់ទេពតា ដែលនៅរក្សាគីរីស្វាន
សុំលោកឲ្យជួយរស់រួចប្រាណ នឹងបានបូជាពលីកម្ម ។
បងក៏បានរស់រួចដីរ៉ា ដោយបុទ្ធិទេវតាជួយទុបត្ថម្ភ
ថែមទាំងបានមាសមេទុត្តម៍ រួមរស់សមាគមស្នេដីរ៉ា ។
ជីវិតរៀមរស់រួចនេះក្ដី. ទាំងបានប្អូនស្រីមកស្នេហា
នេះសុទ្ធដោយបុទ្ធិលោកទេពតា មេត្តាមកជួយប្រសិទ្ធី ។

ចានជារៀមត្រួយពេកណាស់ណា ព្រោះគ្មានបណ្ណាការពលី-
កម្មដល់ទេពតាមានបុគ្គី ដែលជួយដីរបងទីនោះ" ។
ធីតាឮហើយឆ្ងើយតបថ្លី អ្នកកុំព្រួយអីការប៉ុណ្ណោះ
អ្វីខ្លះចូរប្រាប់ខ្ញុំដោយស្មោះ ជានារឿងនោះអ្នកកុំព្រួយ ។
ចោរប្តីស្តាប់ស្តីខ្ចីតបថា "ឲ្យតែដីក៏មេត្តាជួយ
បងអារ្ខាំងហើយលែងថប់ព្រួយ ចូរដាំឲ្យស្រួយមធុផ្យាស ។
ខៀនធូបណាជផ្កាស្វាផ្ការី គ្រឿងទេសពិសីប្រើនឲ្យណាស់
ហើយចូររៀបចំឲ្យរហ័ស កុំបីឲ្យខ្លះស្បែកចេញទៅ" ។
ធីតាបានស្តាប់ប្តីប្រាប់ហើយ នាងពុកខ្ទើយរេរាំទៅ
ចាត់ចែងស្ករគ្រាមស្ករអំពៅ សណ្តែកសខ្មៅកដមាស ។
ទឹកដោះស្រស់ជូរល្ហុងចន្ទន៍ ផ្សំបានគ្រប់គ្រាន់មធុផ្យាស
រៀបចំដាក់ចុះក្នុងឆ្នាំងសមាស ពោរពាសបណ្ណាការពលី ។
លង់លុះព្រឹកព្រាងស្វាងសូរ្យា សេដ្ឋីធីតាចមនារី
ឲ្យរៀបរាខេះទឹមពាជី ដឹកនាំពលីទៅបពូតា ។
ស្រែចទៅដម្រាបប្រាប់ចោរប្តី ល្ងួមហើយស្វាមីយើងយាត្រា
មានសព្វគ្រប់ហើយគ្រឿងបណ្ណា- ការគួរយាត្រាទៅណាអ្នក! ។

(មានត)

ព្រះមហាឧត្តមវរិដ្ឋា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីវេន វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌាធុរកិច្ច ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

អ្នកមានទាំងពីកក្តីរក្សាទ្រព្យសម្បត្តិឬស្ងៀវភៅណាមួយ ដែលខ្លួនគ្មានអំណាចនឹងយកឬកែបាន ក៏លបយក លបបំផ្លាញទ្រព្យសម្បត្តិ ឬលបកែ លបបំផ្លាញស្ងៀវភៅនោះៗចេញ ឬក៏ធ្វើឲ្យវិបល្លាសប្រែប្រួលទៅ ពុំនោះបណ្តាយឲ្យអ្នកដទៃធ្វើដូច្នោះ ដោយខ្លួនបានដឹងបានឃើញនឹងភ្នែកដែរ ឬម្យ៉ាងទៀត ទ្រព្យសម្បត្តិឬស្ងៀវភៅណាមួយ ដែលមានចោរគ្រាជការខ្មុកសំគាល់ ដែលខ្លួនមានទាំងពីកក្តីរក្សា តែគ្មានអំណាចនឹងយកបាន ក៏លបកោសលុបគ្រានោះចេញ ឬធ្វើឲ្យគ្រានោះវិបល្លាសទៅដោយឧបាយណាមួយ ដើម្បីនឹងយកទ្រព្យសម្បត្តិឬស្ងៀវភៅនោះទៅធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ឬក៏បណ្តាយឲ្យអ្នកដទៃធ្វើដោយខ្លួនបានដឹងបានឃើញនឹងភ្នែកផងក្តី ។

អ្នកមានទាំងពីចាត់ចែងទិញឬធ្វើ ឬក៏គ្រប់គ្រងរក្សាទ្រព្យសម្បត្តិណាមួយ ដែលខ្លួនគ្មានអំណាចនឹងយកធ្វើជាប្រយោជន៍ផ្ទាល់ខ្លួនបាន ក៏លបបំបាត់លួចយកទ្រព្យសម្បត្តិនោះៗទៅ ឬបណ្តាយឲ្យអ្នកដទៃធ្វើ

ដូច្នោះដោយខ្លួនបានដឹងបានឃើញផង ឬក៏ប្រើអំណាចក្នុងដំណែងនាំ
រកប្រយោជន៍ដែលមិនគួរបាន យកមកគុកជាអាណាប្រយោជន៍របស់ខ្លួន
ដែលជាហេតុធ្វើឲ្យវិនាសប្រយោជន៍របស់រដ្ឋាភិបាល ឬរបស់អ្នកដែល
ជាម្ចាស់ទ្រព្យនោះក្តី ។

- អ្នកមាននាទីចាត់ការ ឬត្រួតត្រាមើលកិច្ចការណាមួយ ក៏ភ្លេចរក
កំរៃនឹងផលប្រយោជន៍ផ្ទាល់ខ្លួន ក្នុងកិច្ចការនោះ។ ឬមិនប្រាប់តាមត្រង់
ឬក៏ភ្លេចប្រាប់ដោយៗបាយណាមួយ ដូចជា ចំណាយតិច ភ្លេចពោល
ថាច្រើន ចំណូលច្រើន ភ្លេចពោលថាតិច ជាដើម ដើម្បីបន្ទុំយក
ធ្វើជារបស់ខ្លួនក្តី ។

អ្នកមាននាទីដកហូតកាស៊ី ពន្ធ អាករ ឬ ទ្រព្យសម្បត្តិដែលត្រូវ
បញ្ជូនទៅឲ្យរដ្ឋាភិបាល ឬឲ្យសាធារណសកាណាមួយ ក៏ទៅហូតប្រាក់
ឬទ្រព្យដែលមិនគួរហូត ឬដកហូតហួសចំនួនដែលគួរហូត នឹងមិនបញ្ជូន
ឲ្យដល់រដ្ឋាភិបាល ឬសាធារណសកានោះ។ ជាដើម ឬក៏ប្រើអំណាច
ក្នុងដំណែងនាទីដោយផ្តរមិនត្រឹមត្រូវ ដូចយ៉ាង មិនដាក់ទោសអ្នកនេះ
ដាក់ទោសតែអ្នកនោះ ឬហូតពីអ្នកនេះ មិនហូតពីអ្នកនោះជាដើម ពុំ
នោះបង្គាប់ឲ្យគេឲ្យ ឬឲ្យគេកេទ្រព្យ ឬផលប្រយោជន៍ ដែលមិនគួរ
បានមកឲ្យខ្លួន ឬអ្នកដទៃ ពុំនោះទេ អ្នកមាននាទីខ្ពង់ខ្ពស់ ដឹងរឿង
កំបាំងក្នុងការផែនដី តែខ្លួនមិនមានអំណាចនឹងបញ្ចេញរឿងកំបាំងនោះ

ចាន កំយកវឿងកំប៉ាំងនោះទៅផ្សាយ ឬ គិតអាក្រែក់ចំពោះអ្នកដទៃ ហើយធ្វើការដែលមិនគួរធ្វើ លះវៀរការដែលមិនគួរលះវៀរក្នុងដំណែងនាទីរបស់ខ្លួន ដោយចេតនាបំណងនឹងឲ្យកើតសេចក្តីវិនាសដល់គេ ឬពុំនោះសោតទេ អ្នកមាននាទីចាត់ការឲ្យប្រព្រឹត្តទៅតាមគោលការ ខបង្គាប់ពាក្យពិភាក្សា ឬ ពាក្យបញ្ជូនរបស់អ្នកធំ ក៏ត្រឡប់ជាការពារ ឬ ឃាំងឃាត់មិនឲ្យការនោះប្រព្រឹត្តទៅតាមគោលការ ខបង្គាប់ពាក្យពិភាក្សា ឬ ពាក្យបញ្ជូននោះវិញ យ៉ាងនេះក្តី ។

ក្នាក់ងារដែលធ្វើការមិនគប្បីដល់នាទីរបស់ខ្លួន ដូចពោលមកហើយ តាំង ៤ ខាងដើមនេះ ចាត់ថាជាក្នាក់ងារទុច្ចរិត ។ មនុស្សទុច្ចរិតក្នុងនាទីនោះ កាលបានទទួលអំណាចហើយ ក៏ប៉ុនគ្មានឹងបានទទួលសុភ-វុឌ្ឍកុសម្រាប់កាត់ខ្លួនឯង ។ បុរាណទើបពោលថា "អំណាចដូចអាវុធមានមុខដ៏មុតថា បើឲ្យទៅមនុស្សមិនចេះប្រើ ក៏ប្រហែលគ្នានឹងឲ្យទៅដើម្បីបង្កឲ្យកើតវឿងកាប់ចាក់ខ្លួនឯង ព្រោះមនុស្សទុច្ចរិតនោះ ចូលចិត្តប្រើអំណាចរកស៊ីលើខ្លួនមនុស្ស លើជីវិតដ៏បរិសុទ្ធ លើចិត្តដ៏សុភាពរបស់ប្រជាពលស្ត្រី នឹងលើកញ្ជើងក របស់ញាតិសន្តានបងប្អូនមិត្តសំឡាញ់ ។ មនុស្សបែបនេះ នឹងត្រូវអប្រិយក្នុងកាលមានអំណាច នឹងត្រូវអាប់យសក្នុងកាលមានយស នឹងត្រូវលិចលង់ក្នុងកាលដែលសុកស្តម្ភ នឹងត្រូវអាប់ឧនក្នុងកាលដែលបានទទួលលើកដំកើង ហើយនឹងត្រូវធ្លាក់បុណ្យក្នុងកាលដែលមានដំណែងនាទី" ។

តាមពិត ការមានអំណាចនោះ សូម្បីនឹងមានឡើងដោយកវណីណា ។ ក៏ដោយ ក៏មិនសំខាន់ដែរ ។ សេចក្តីសំខាន់នោះ នៅត្រង់ការចេះប្រើអំណាច ។ បើអំណាចនៅកន្លែងណាប៉ះដៃនៃមនុស្សសុចរិត ក៏អាចនាំយកប្រយោជន៍ខ្លួន ប្រយោជន៍គេនឹងប្រយោជន៍រួមគ្នាមកដោយត្រជាក់ត្រជុំបាន ធ្វើឲ្យអ្នកប្រើបានទទួលសេចក្តីនិយមរីករាយ ។ ព្រោះអ្នកសុចរិតក្នុងនាទី កាលបានអំណាចមកកន្លែងណាប៉ះដៃហើយ ក៏ធ្វើតែការណា ដែលពួកមនុស្សច្បាស់ច្បាច ។ តែបើអំណាចនោះនៅកន្លែងណាប៉ះដៃនៃមនុស្សទុច្ចរិត ដែលប្រឡាក់ទៅដោយលោភ គ្រោធវង្វេងវិញ ក៏មានតែនាំមកនូវប្រយោជន៍ផ្ទាល់ខ្លួន ដោយបង្អិនបង្អើចប្រយោជន៍របស់បុគ្គល ទឹងរបស់ប្រទេសជាតិមិ៉ងៗ ធ្វើឲ្យអ្នកប្រើត្រូវពាក្យប្រទេចផ្តាសា សូម្បីអ្នកនោះ ធ្វើការងារបានផលសមបំណងក៏ដោយ ក៏ទឹងត្រូវទៅដេកនៅក្នុងបន្ទប់ឃុំឃាំង ។ ដូច្នេះ យើងទើបត្រូវតែប្រមូលយកអំណាចសុចរិតមកទុកឲ្យខ្ជាប់ខ្ជួន ។

កាលក្រឡត់ ស្ងួតត្ងត់ ស៊ីអំបិល
កុំខ្ជូចខិល ដើរស៊ីសាច់ មនុស្សផងគ្នា
កុំត្រាប់ខ្វា ឃ្វានកោក្តា លែងរួញរា
ចាប់ម្រីគា បរិភោគ គ្មានអាណិត ។

កាលពួកជនក្នុងប្រទេស ធ្វើដំណើរចូលទៅកាន់ផ្លូវសុចរិត មាន
និស្ស័យសុចរិតច្រើនគ្នា ទុំពាជការសុចរិត អ្នកកសិការសុចរិត អ្នក១ស្ស-
ហការសុចរិត អ្នកជំនួញសុចរិត ពលរដ្ឋសុចរិត អ្នកធំសុចរិត អ្នកតូច
សុចរិត ទើងអ្នកប្រព្រឹត្តវត្តសុចរិត គឺសុចរិតកើងធម្មចរិយា សុចរិតកើង
បុគ្គល សុចរិតកើងការអាជីវៈ សុចរិតកើងការងារ ទើងសុចរិតកើងនាទី
ដូចពោលមកហើយ គប្បីជ្រាបថា ពួកជនសុចរិតអម្បាលនេះឯង ទើង
ជាបេះដូងនៃសេចក្តីចំរើនរបស់ប្រទេសជាតិ ។

តែកាលបើប្រជាជន ធ្វើដំណើរចូលទៅកាន់ផ្លូវនៃទុច្ចរិត ច្រើតែ
ប្រយោជន៍ផ្ទាល់ខ្លួន ក៏យដំម្បីជីវិតខ្លួនខ្ពស់ជាងជីវិតអ្នកដទៃ ដំកល់
ជីវិតខ្លួនទុកសម្រាប់ទំលួលសុខ ដំកល់ជីវិតអ្នកដទៃទុកសម្រាប់ទំលួលទុក្ខ
ហើយព្យាយាមបៃងទុក្ខកើងជីវិតខ្លួន ជាក់កើងជីវិតអ្នកដទៃ បៃងសេចក្តី
លំបាករបស់ខ្លួនឲ្យមនុស្សដទៃ ដោយវិធីដណ្តើមយកការស្តុកស្តម្ភរបស់
គេមកជំនួសការក្រលំបាករបស់ខ្លួន ដណ្តើមយកសុខកើងជីវិតគេ មកទុក
កើងជីវិតខ្លួនវិញ គប្បីជ្រាបថា នេះឯងជាវិធីហិនហោចនៃប្រទេសជាតិ ។

ព្រោះថាមនុស្សទុច្ចរិត ទុកណាជាបានស្តុកស្តម្ភក៏មិនល្មមចិត្តកើង
ហានៈរបស់ខ្លួននោះដែរ តែងតែមានបំណងនឹងប្រមូលយកសិទ្ធិរបស់អ្នក
ដទៃ ដោយសេចក្តីលោភ ក្រោធ វង្វេង ជាកំឡាំង, កាលបើខ្លួន
ក្រវិញ ក៏គិតធ្វើម្តេចឲ្យតែបានពេញផ្ទៃរបស់ខ្លួនទាំបក្សពួកពាំងអ្នក

ស្តុកស្តម្ភពាំងអ្នកខាល់ក្រ ដើរបំផ្លាញសម្បត្តិរបស់ជាតិឲ្យវិនាសដើម្បីផ្លែរបស់ខ្លួន ទំលាយប្រទេសជាតិឲ្យវិនាសលិចលង់ ដើម្បីហោប៉ៅរបស់ខ្លួនពិតៗ ។ បើគេជាសត្រូវរបស់សង្គមដូច្នេះហើយ ក៏គប្បីជ្រាបថាជាមនុស្សច្រេះឆ្កែតលោក រកតែលំនៅបានដោយលំបាក សូម្បីនឹងឈរនៅលើប្រឹថពីដ៏ធំទូលាយ ក៏ប្រៀបដូចជាឈរក្នុងទីចង្អៀត ឬលើមាត់ជ្រោះដែលងងឹតសូន្យ បានទទួលតែទុក្ខលំបាកតែជាបត្តដួសឬក៏ឈរក្រោមកំពែងរៀចរៅរបែរបោរខ្វេតខ្វោត ដែលនឹងរលំដួលសង្កត់យកជីវិតទៅពេលណាមួយ ។ ! គួរឲ្យស្អប់ខ្ពើមណាស់ហ្ន៎ ! ពួកមនុស្សទុច្ចរិត !

ប្រទេសដែលមានកំពែងរឹងប៉ឹងមាំមួននោះ បានដល់ប្រទេសដែលមានពួកជន ជាមនុស្សសុចរិត ។ ប្រទេសមានកំពែងដែលធ្វើដោយមនុស្សសុចរិត មាំល្អជាងកំពែងដែលធ្វើដោយឥដ្ឋជាអនេក ។ សូម្បីគ្រឹហាដែលចាត់ថាមានគ្រឿងប្រដាប់ដ៏ល្អនោះ ក៏ព្រោះអាស្រ័យអ្នកផ្ទះនោះជាមនុស្សសុចរិតដែរ ។ ដូច្នេះយើងចូរកាន់ឲ្យខ្ជាប់ខ្ជួនក្នុងសុចរិតដែលចាត់ថាជាកំពែងដ៏មាំរបស់ប្រទេសជាតិ ទើងជាគ្រឿងប្រដាប់ដ៏ល្អសមរម្យរឹងរឿងរបស់គ្រឹហា កុំអប្រិយព្រោះការស្តុកស្តម្ភនឹងកិត្តិយស កុំប្រែប្រួលអំពីការគ្រប់គ្រងដោយសុចរិត សូម្បីទីខាល់ក្រក៏ដោយ ក៏កុំញាប់ញ័រអណ្តែតតាមអំណាចនៃសេចក្តីទុច្ចរិតរបស់មនុស្សដទៃ ចូរស-

ឡាញ់សុចរិតឲ្យជានិស្ស័យរបស់ខ្លួនចុះ ដើម្បីឲ្យចុងទទួលសេចក្តីសរ-
សើរថា "ប្រជាជនកម្ពុជា ស្រឡាញ់សុចរិតប៉ុនគ្នាទឹងជីវិតរបស់ខ្លួន" ។

ទឹកក្នងស្រះ ម្ជុលដើមស្រែ អាគារដែលកដោយឥដ្ឋ អម្បាលនេះ
ក្នងរដូវរងា អាចឲ្យកក់ក្តៅ, ក្នងរដូវក្តៅអាចឲ្យត្រជាក់ស្រួល ។
ឯសុចរិតគ្រប់ត្រកូល អាចឲ្យសេចក្តីសុខសម្រាន្តដល់អ្នកប្រព្រឹត្តបាន
គ្រប់ដូរ ។ សេចក្តីសុចរិតជាទឹកថ្លាត្រជាក់, សេចក្តីមិនប្រមាទ
ទុកជាទន្លេ, សេចក្តីសំរុមខ្លួនទុកជាកំពង់ទឹក, សីលជាច្រាំងទន្លេ,
ឯមេត្តាករុណាទុកជារលកទឹក ។ អញ្ជើញលោក-អ្នកទាំងឡាយមក
ស្រោចទឹកគឺសុចរិត ដើម្បីសេចក្តីចំរើនក្នងទីនេះចុះ ។

សុចរិត ជាកំពូល សព្វមង្គល
មិនប្រែប្រួល ចលាចល ទៅឡើយណា
មានដំហរ ឈរឆ្ងំឆ្ងឹង ជាងសិលា
បើមិនដឿ ពិចារណា គង់ឃើញបាន ។

កាលបើចិត្ត សុចរិត ស្អាតជ្រះថ្លា
កិច្ចណា ។ ដែលយើងធ្វើ ទាំងប៉ុន្មាន
គង់សុចរិត ទៅតាមគ្នា ជាពុំខាន
ផលសុចរិត នោះតាមថ្លា ដូចស្រមោល ។

កណ្ឌទី ១៩

ឧកញ៉ាវិបុលរាជសេនា ន្ង-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងរៃឆ្លាសបើបានអាន
ធំងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ចូរឆ្លុះភ័យស្ងុត តែមិនខាន់ថាប្រការដូចម្តេច ក៏ឃើញហៃហ្ឍុន, ខៅធូ, លីតៀន, ដាក់ជិន ចូលមកប្រាប់ថា អ៊ីកឹមលើកទាហាន ដេញកាប់សម្លាប់ពួកទាហានយើងខ្ញុំ សមនឹងប្រែចិត្តក្បត់ធំឆ្លោកមែន ហើយបានជាធ្វើដូច្នេះ សុំឲ្យលោកត្រៀមបុរាំងសេនាទាហានទុកនៅទីនេះឲ្យស្រេច ដើម្បីនឹងបានលើកទៅចាប់ខ្លួនអ៊ីកឹមឲ្យបាន ។

ចូរឆ្លុះភ័យល់តាម ទើបប្រាប់ប្រៀបរៀបកងទ័ពបុរាំងទុកជាស្រេច ។ ឯអ៊ីកឹមក៏ឲ្យរៀបតាំងបន្ទាយប្រាថ្នានឹងបុរាំងទុកទទួលចូរឆ្លុះ ដើម្បីនឹងការពារកងទ័ពគៀវស៊ុយ ។ លុះអ៊ីកឹមដឹងថា ទាហានចូរឆ្លុះបែកទ័ពលើកមកដិត

ហើយ កំឲ្យទាហានទាំងពួងកាន់គ្រឿងសស្ត្រាវុធគ្រប់ដៃ ដើម្បីនឹងរក្សាបន្ទាយឲ្យមាំមួន ។ ទាហានអ័កឹមពុកតិត្តសព្ទថា "ហៃហ្ន្ទុននឹងទាហានបែកខាងណោះនាំសេចក្តីទៅញុះញង់ចូឆួថា អ័កឹមប្រែចិត្តក្បត់" កំនាំយករឿងនោះមកប្រាប់អ័កឹមហើយសួរថា បើគេពោលទោសលោកយ៉ាងនេះ ហេតុម្តេចលោកមកតាំងបន្ទាយត្រៀមបំរុងសេនាទាហានទុកដូច្នេះទៀត វេលានេះបើលោកមិនចេញទៅដួចនឹងចូឆួទេចូឆួកំគង់នឹងដឿតាមពាក្យគេថាពុំខាន ។

អ័កឹមតបថា ដែលគេពោលទោសដល់យើងនោះជាសេចក្តីប្លុសគ្នា ហេតុដែលយើងប្រុងប្រៀបរៀបធ្វើបន្ទាយទុកយ៉ាងនេះ ព្រោះដឹងថាចូឆួចាញ់ទ័ពគេរត់មក ត្រូវយកបន្ទាយនេះពឹងពាក់អាស្រ័យឲ្យរួចភ័យអន្តរាយ ដើម្បីតស៊ូនឹងសត្រូវទៅវិញ ឯការដែលត្រូវនឹងខុសនោះត្រូវតែចាំរិះគិតទៅជាក្រោយ ។

ខណៈនោះកងទ័ពគ្រឿងស៊ីវក៏លើកមកស្កាត់ពីមុខជា ២ ប៉ែក លុះឃើញបន្ទាយអ័កឹមមាំមួននៅពីនោះ គ្រឿងស៊ីវក៏ឈប់ទ័ពឈប់ ។ អ័កឹមក៏លើកទាហានបរសេះគ្រីទ្ធូនចេញទៅតយុទ្ធនឹងគ្រឿងស៊ីវជាមាំមួន ។ គ្រឿងស៊ីវយល់ថានឹងតទល់មិនបាន ក៏នាំទាហានថយត្រឡប់ទៅវិញតាមទន្លេយ៉ុកស៊ុយ ។ អ័កឹមក៏បរពលដេញតាមចាក់កាប់សម្លាប់ទាហានគ្រឿងស៊ីវទៅត្រាតែដល់ច្រកនឹងចូឆួ ។ ទាហានចូឆួក៏លើកគ្នាដេញកាប់សម្លាប់ទាហានគ្រឿងស៊ីវ បែកខ្ចាត់ខ្ចាយអន្តរាយស្ងាប់ភ្លាត់ជាច្រើន ។

ឯតៀវស៊ីវនឹងតាហានដែលសល់នៅប៉ុន្មាន កំរត់កាត់ធ្លងសំដៅទៅរកខ្លាតៀវចៅហ្វាយស្រុកកេងដីវ, ចូធ្លូក៏មិនបានដេញតាម បានត្រួតត្រាប្រមូលសេនាតាហានឲ្យមកប្រជុំគ្នា ។ អ៊ីតឹមក៏ចូលទៅជួបនឹងចូធ្លូ ហើយយកសេចក្តីដំរាបចូធ្លូថា តាហានហែហួមុនគប់គិតគ្នា ទៅវាយឆក់ដណ្តើមយកទ្រព្យរបស់អស់បណ្តាពស្តុអ្នកស្រុក ខ្ញុំបាទឃើញមិនត្រូវ ក៏ឲ្យដេញកាប់សម្លាប់ពួកនោះចេញជាច្រើនអ្នក ។ ចូធ្លូតបថា យើងនឹងអ្នកទាំងអស់គ្នាបែកទ័ពត្រឡប់ទៅតែស្ងួនឯង ហេតុម្តេចឯងមិនមករកយើងឲ្យជួបជាមុន បានជាទៅតាំងបន្ទាយនៅកណ្តាលផ្លូវនោះ តើនឹងធ្វើអ្វី? ។

អ៊ីតឹមបានជំរាបចូធ្លូតាមគំនិតដែលគិតទុកគ្រប់ប្រការថា ខ្ញុំបាទធ្វើនឹងការពារសឹកសត្រូវដែលវាលើកតាមលោកមក ប្រយោជន៍ដើម្បីឲ្យលោកបានជារបាំងពំនឹងការខ្លួន ខ្ញុំបាទក៏បានចាំងនឹងតៀវស៊ីវទាល់តែបែកទ័ព ហើយខ្ញុំស្មងរកលោកក៏មិនជួបប្រទះ ទោសខ្ញុំបាទក៏ខុសណាស់ទៅហើយ ស្រែចតែលោកនឹងមេត្តា ។

ចូធ្លូបានស្តាប់សព្វគ្រប់ ក៏មានសេចក្តីត្រេកអរសើរអ៊ីតឹមថា "ដែលអ្នកគិតធ្វើបានយ៉ាងនេះទើបបានជ័យជំនះមែន រំគិនដែលអ្នកចេះគិតដូច្នេះ ទោះបីតាហានដែលមានកំណ្តាច់ឈ្មោះមកពីជើម ក៏មិនស្មើនឹងអ្នក" លុះសរសើរសេពគ្រប់ទើបយកទ្រព្យមាសប្រាក់ឲ្យអ៊ីតឹម ១ ប្រដាប់

សម្រាប់ជាបំណាច់ ហើយតាំងអ័ក្ខឹមជា "ឥតស៊ីវតែងហៅ" គឺ
នាហ្នឹងចំរើនអាយុ ។ ឯហែហ្មុងដែលមិនបានកំជាប់ខាហានបណ្តាយឲ្យ
ធ្វើទុក្ខបុកម្នេញអស់បណ្តាកស្ត្រ ក៏ឲ្យកាត់សេចក្តីធ្វើទោសជាក់គុត ។

ចូធូឲ្យរៀបតុះសែនចាក់ស្រាឲ្យតៀនអ៊ុយ ហើយនិយាយច្រាប់
សេនាខាហានតាំងពួងថា "ទោះបីកូនចៅរបស់យើងស្លាប់អន្តរាយ យើង
ក៏មិនសូវសោកស្តាយស្មើនឹងតៀនអ៊ុយនោះឡើយ" និយាយហើយ
ក៏យំសោកាល័យស្តាយតៀនអ៊ុយដោយបរិវេនាការ ។ បណ្តាសេនា
ខាហានឃើញដូច្នោះ ក៏មានចិត្តអាណិតអាណាតចូធូពន់ប្រមាណ ក៏
ប្រែច្បាណូញយំតាំងអស់គ្នា ។ លុះចូធូស្វាងទុក្ខសោកវេលាណា
ក៏រៀបចំផ្ទុំពលយោធាលើកត្រឡប់ទៅក្រុងហ៊ូគោវិញ ។

ឯអង់ចិកដែលចូធូប្រើឲ្យនាំសំបុត្រទៅឲ្យលីចោ" លុះទៅដល់ស្រុក
ឈើដីវហើយ លីចោ"ដឹងក៏ចេញទៅទទួលហើយអញ្ជើញចូលទៅក្នុង
ស្រុក ។ អង់ចិកក៏ជូនសំបុត្រព្រះដម្រាស់ឲ្យលីចោ"។ ទទួលមើលឃើញ
សេចក្តីថា ទ្រង់ច្រាសព្រះរាជទានឲ្យលីចោ"ជាទីប៉ែងតង់ចុងគុន គឺ
ជានាហ្នឹងធំសម្រាប់បង្ក្រាបពួកចោរខាងបូពិទិស ។ មានសំបុត្រចូធូ
១ ច្បាប់ទៀតថា ឲ្យលីចោ"ស្តុតសមាគមនឹងទ្បៅពីកុំឲ្យមានសេចក្តី
អាឃាដញាចាទគ្នាតទៅ, ហើយអង់ចិកដំរាបលីចោ"ថា សព្វថ្ងៃនេះមហា
ទេវរាជមានសេចក្តីមេត្តាលោកច្រើន ជានាយកសេចក្តីក្រាបទូលព្រះ

ចៅហ្វាយតេសរសើរគុណចំណាច់លោកសុំឲ្យបានជានាហ្នឹងធំ ។ លីចោ"
បានស្តាប់ដូច្នោះ ក៏មានសេចក្តីសោមនស្សត្រេកអរណាស់ ។

ខណៈនោះ មានបំរើចូលទៅដំណឹងលីចោ"ថា ឥឡូវអ្នឹងសុតត្រៃ
ភាហានមកវគលោក ។ លីចោ"ក៏ឲ្យហៅចូលទៅហើយសួរថា អ្នឹងសុត
ត្រៃឲ្យមកដោយហេតុអ្វី? ។ ភាហាននោះដំណឹងថា អ្នឹងសុតត្រៃខ្ញុំបាទ
មកដំណឹងលោកថា វេលានេះអ្នឹងសុតកំពុងរៀបចំទឹងតាំងខ្លួនធ្វើស្តេច
ម្ចាស់ផែនដី ហើយទឹងតាំងកូនប្រុសជាតុងកុង គឺជាទីតំណាងខាងមុខ
ឲ្យលោកស្រួតរូតបញ្ជូនបុត្រីរបស់លោកទៅជាប្រពន្ធាប់ ទឹងបានរៀបការ
ឲ្យនៅជាមួយគ្នាតែម្តង ។

លីចោ"បានស្តាប់ក៏ទឹកចិត្តឈាស់ដេរអ្នឹងសុតថា "អានេះវាគិត
ប្រទូសា"យកក្បាត់ផែនដី" ហើយក៏ឲ្យចាប់ភាហានជាំបំរើអ្នឹងសុតនោះទៅ
សម្លាប់ចេញ; ឯហាន់អ៊ីនដែលនៅក្នុងគុកនោះ ក៏ឲ្យដាក់ច្រវាក់ដៃក
ជុកឲ្យខ្លាច់ខ្លួន ហើយធ្វើសំបុត្រប្រកាន់តេងលើកភាហានឃុំនាំខ្លួន
ហាន់អ៊ីន ចូលទៅជូនចូរួងស្រុកគ្រុង ។

ចូរួងទទួលសំបុត្រក៏យកមកមើលឃើញសេចក្តីថា "ខ្ញុំបាទលីចោ"គំ
នាប់មក ព្រោះមហាឧបរាជមានសេចក្តីមេត្តាខ្ញុំបាទ បានជួយយកសេចក្តី
ក្រាបបង្គំទូលព្រះចៅហ្វាយតេ ឲ្យខ្ញុំបាទបានពេញទីជាចៅហ្វាយស្រុក
ឈើដីវ ខ្ញុំបាទក៏ទឹងបានធ្វើការតបស្នងគុណព្រះតេជព្រះគុណតទៅ ។

ចូឆួយល់តាមសេចក្តីសំបុត្រនោះក៏នឹកគិតថា "គ្រានេះលីប៉ោនឹងអ្ជិនសុត មានសេចក្តីទាស់ខែងគ្នា មុខជានឹងជាប់ពីដន្ទុងនឹងគ្នាហើយ ប្រាជាធ្វើដូច្នេះ" ហើយក៏ឲ្យយកខ្លួនហាន់អ៊ីនទៅសម្ងាប់ ។

គាន់តេងចូលទៅខ្សឹបដំរាចូឆួថា លីប៉ោនោះជាមនុស្សខ្លុចតែអាក្រក់ ហាក់ដូចជាសត្វតិរច្ឆាន មានតែកម្លាំងគ្មានសតិបញ្ញាអ្វីសោះ ដែលមហាឧបរាជនឹងចិញ្ចឹមមនុស្សនោះឲ្យជាធំ យូរទៅក៏គង់ប្រែជាសត្រូវនឹងលោកវិញ ។

ចូឆួធ្វើយថា យើងដឹងណាស់ហើយ យើងប្រុងតែនឹងកំចាត់រាបេញអ្នកឯង ២ នាក់អាពុកនឹងកូននៅក្នុងស្រុកឈីដាវស្រាប់ រាមេងដឹងគំនិតមារយោងរាល់ច្បាស់លាស់ហើយ បើកាលណាយើងលើកទ័ពទៅស្រុកឈីដាវហើយ ទោះមីខ្លះខាតរបស់អ្វីអ្នកត្រូវតែជួយគិតគូរឲ្យកើតការផងចុះ ។

គាន់តេងដំរាបថា ប្រសិនមហាឧបរាជនឹងត្រូវលើកទ័ពទៅគ្រាណាខ្លួនខ្ញុំបាទនឹងបិតាបំរុងនឹងចាំធ្វើកល់សឹកខាងក្នុងឲ្យបានសម្រេច ។ ចូឆួក៏តាំងគាន់តេងជាចៅហ្វាយស្រុកកងឡែង ត្រូវឡើងស្តាប់បង្គាប់ស្រុកឈីដាវ ហើយឲ្យមានគ្រាព្រះដម្រាស់ព្រះចៅហៀនតេ ទៅដល់លីប៉ោចៅហ្វាយស្រុកឈីដាវ ឲ្យបំពេញសួយសារអាករដល់គាន់គុយជាបិតាគាន់តេងឲ្យច្រើន គាន់តេងក៏គំនាប់លាចូឆួ ។ ក៏ចាប់ដៃបញ្ជប់ហើយ

និយាយថា ការដែលយើងបានគិតទុកគ្រានេះ យើងសុំទុកចិត្តចំពោះបូ
អ្នក ចូរអ្នកចំរើនគិតធ្វើការឲ្យសម្រេចប្រយោជន៍កុំឲ្យខាន ។ តាន់តេង
ទទួលពាក្យចូលួ ហើយក៏លាចេញទៅដល់លីចោ"ឯស្រុកឈើដីវ ។

លីចោ"សួរតាន់តេងថា អ្នកបានទៅដូចនឹងចូលួ។ និយាយការដូចម្តេច
ខ្លះ? ។ តាន់តេងក៏ស្រាយយកគ្រាតាំងសម្រាប់ខ្លួន នឹងគ្រាច្រែកសព្រះ
ពជ្ជានសួយបិតារបស់ខ្លួនបង្ហាញឲ្យលីចោ"មើល ។ លីចោ"ឃើញដូច្នោះ
ក៏ទឹងណាស់ថា "យើងចាត់ច្រើខ្លួនទៅចំពោះការងាររបស់យើង ហេតុ
ម្តេចខ្លួនទៅរិះគិតយកប្រយោជន៍ខ្លួននឹងអាពុកខ្លួនវិញ; ម្យ"ងទៀត កាល
យើងលើកកូនក្រមុំយើងឲ្យអ្នូនសុត តាន់គុយអាពុកខ្លួនមកនិយាយយាំង
ឃាត់យើង ហើយក្លែងឲ្យយើងទៅចូលខាងចូលួ ឥឡូវយើងច្រើខ្លួនទៅ
ក៏មិនឃើញបានការអ្វីដល់តិចសោះ" និយាយហើយក៏ហូតក្រមីកាន់បំរុង
នឹងសម្លាប់តាន់តេង ។

តាន់តេងឃើញដូច្នោះក៏ធ្វើជាអស់សំណើចហើយថា លោកស្តាប់
សេចក្តីមិនទាន់អស់ ប្រញាប់តែទឹងនឹងខ្ញុំបាទ ។ លីចោ"តបថា នៅ
មានសេចក្តីអ្វីតទៀតដែលខ្លួនថា យើងស្តាប់មិនបាននោះ ។ តាន់តេង
ជំរាបថា កាលខ្ញុំទៅរកចូលួនោះ ខ្ញុំបាទក៏បានជំរាបចូលួថា សុំឲ្យចូលួ
ចិញ្ចឹមលោកឲ្យធំដល់ខ្នាតទុបមាដូចយើងចិញ្ចឹមខ្លា បើបានអាហារបរិ-
ភោគឆ្អែតក៏ជាប្រក្រតី បើមិនឆ្អែតហើយវាមែងបៀតបៀនសត្វទាំងពួងជា

អាហារ; ចូរឆ្កួតខ្ញុំបាទថាដូច្នោះអស់សំណើចហើយថា ដែលនឹងចិញ្ចឹមលោកឲ្យពេញយសដូចខ្ញុំបាទនោះមិនចំបាន ព្រោះសព្វថ្ងៃនេះ លោកនៅមានសេចក្តីលំអុតលំនុនទៅរកចូរួ ដោយសារតែលោកនៅពុញវាល់ទេ បើច្រែសិនជាលោកមានឥណាការមាំមួនឡើងវេលាណា លោកគង់ប្រែចិត្តចេញអំពីចូរួ មានឧបមាដូចខ្វែងចង់បរិភោគអាហារ ត្រូវចាំឃ្លាំមើលកូនមាន់ដែលឃ្លាតចេញពីមេវេលាណា ក៏នឹងធ្វើវិធាបចាប់យកកូនមាន់នោះឲ្យបាន បើមានមេរ៉ាវនៅការពារក៏ចាំតែធ្វើសេចក្តីព្យាយាមត្រាតែចាប់យកកូនមាន់នោះឲ្យបានសម្រេចដូចចិត្តប្រាថ្នា; ខ្ញុំបាទក៏បានសួរថា ដែលលោកឧបមាថាខ្វែងនោះគឺខ្លួនលីចាំហើយ ចុះកូនមាន់នោះនឹងប្រៀបដូចនរណាវិញ? ។ ចូរួតបថា កូនមាន់នោះគឺអ្នកសុតចៅហ្វាយស្រុកឡាំយ៉ុង, ស៊ុនសឹកចៅហ្វាយស្រុកតាំងតាំង, អ្នកសៀវចៅហ្វាយស្រុកគីដីវ, ឡៅពៀវចៅហ្វាយស្រុកកេងជីវ, ឡៅជៀងចៅហ្វាយស្រុកសែឈួន, តៀវឡូចៅហ្វាយស្រុកហាន់តុង ។ លីប៉ោបានឮដូច្នោះក៏ពេញចិត្តណាស់សំគាល់ថាពាក្យពិត ទើបទម្លាក់គ្រប៉ៃចេញពីដៃហើយថា ចូរួនោះមានសតិបញ្ញាអាចប្រមាណចិត្តយើងត្រូវមិនខុសសោះ ។

ឯអ្នកសុតនោះ តាំងពីបានគ្រាចម្លាក់រូបស៊ុនសឹកពុក ក៏គិតតែនឹងតាំងខ្លួនជាស្តេច ហើយប្រឹក្សានឹងសេនាឥហានពាំងពួនថា យើងបានឮពាក្យបុរាណតៗ មកថា កាលគ្រាព្រះចៅហាន់កោចោះនៅមិន

ពាន់ទទួលពរជសម្បត្តិ កំដាមនុស្សអនាថាឧបមាដូចនៅក្នុងផ្ទៃសមុទ្រ ឧស្សាហ៍ធ្វើសេចក្តីព្យាយាមមកជាច្រើន ទើបបានតាំងខ្លួនឡើងសោយពរជសម្បត្តិ ទ្រង់ព្រះនាមព្រះចៅហាន់គោចោ លុះដាលំដាប់មកក៏មានព្រះពរជវង្ស បានសោយពរជ្យតៗ មកទៀតដល់ ៤០០ ឆ្នាំដរាបដល់ព្រះចៅហៀនតេសព្វថ្ងៃនេះ ឥឡូវនេះព្រះចៅហៀនតេទទួលពរជសម្បត្តិហើយស្រុកទេសក៏កើតចលាចលអន្តរាយផ្សេងៗ បើតាមសង្កេតទៅក៏ឃើញថាវាសនាបារមីព្រះចៅហៀនតេ ទំនងជៀរភេយសាបសូន្យអស់ហើយ ខ្លួនយើងក៏ជាពូជនាហ្មឹនមកពីដើម បណ្តាកស្តេចាំងឡាយក៏មានសេចក្តីស្រឡាញ់យើងច្រើន ហេតុនេះត្រូវតែយើងនឹងតាំងខ្លួនធ្វើម្ចាស់ផែនដី តើអ្នកគាំងឡាយនឹងយល់ឃើញដូចម្តេច? ។

អៀមសៀងពីប្រក្សាក៏ហាមឃាត់អ៊ួនសុតថា កាលគ្រាព្រះចៅទីវអង់បានសោយពរជសម្បត្តិនៅក្នុងស្រុកក្រុង រមែងបៀតបៀនឲ្យបណ្តាកស្តេបានសេចក្តីក្តៅក្រហាយ ។ណៈនោះជីវប៊ុនអង់ដែលជានាហ្មឹនធំនៅស្រុកកីសាន់ លោកធ្វើវាត្រាតក្នុងការពិជ័យសង្គ្រាម អាណាខែត្រក្នុងប្រទេសចិនក៏នៅក្នុងអំណាចជីវប៊ុនអង់ដល់ ២ ភាគ នៅក្នុងអំណាចព្រះចៅទីវអង់តែ ១ ភាគ ជីវប៊ុនអង់ជាមនុស្សសុចរិតពិតត្រង់នឹងផែនដី មិនបានតាំងខ្លួនធ្វើស្តេចទេ, ចុះឥឡូវនេះព្រះចៅហៀនតេនៅមានព្រះជន្មាយុគង់ជាម្ចាស់ផែនដី ហើយមិនបានបៀតបៀនធ្វើអន្តរាយដល់បណ្តាកស្តេឯណា

សោះ ដែលលោកមកពិគ្រោះនឹងលើកខ្លួនធ្វើស្តេចនោះ ខ្ញុំបាទមិនយល់ព្រមផងទេ ។

អ៊ីនសុតបានឮដូច្នោះក៏ធ្វើយថា គ្រាចម្លាក់សម្រាប់មហាក្សត្រដែនដីនៅកងកណ្តាប់ដៃអញ បើដូចជាទេពតាមកប្រសិទ្ធិឲ្យអញបានធ្វើស្តេចហើយ បើនរណាមិនយល់ព្រមតាមចិត្តអញទេ នឹងឲ្យកាត់ក្បាលចេញ ។ ខ្ញុំជាការចាំងអស់គ្នាក៏នៅស្ងៀម មិនមាននរណាធ្វើយដូចម្តេច ។ អ៊ីនសុតតាំងតែឲ្យរៀបចាត់ចែងរាំងកំពែងក្នុងស្រុក ហើយក៏សន្មតខ្លួនជាម្ចាស់ដែនដី ឈ្មោះតងស៊ី គឺជាពូជព្រះចៅឡិស៊ុនមកពីដើម ។

លំដាប់តមកអ៊ីនសុតដឹងថា លីចោ"គិតប្រែប្រួលចាប់ខ្លួនហាន់អ៊ីនជាក់ក្តីហើយបញ្ជូនចូលទៅឲ្យចូវ ហើយសម្លាប់ចាំងបំរើដែលកាន់សំបុត្រគឿនយកកូនក្រមុំនោះចេញផង អ៊ីនសុតឯងណាស់ក៏គិតលើកទ័ពទៅច្បាំងនឹងលីចោ" ទើបចាត់តៀវហ៊ុនជាមេទ័ពធំលើកទាហាន ២០ ម៉ឺន ឲ្យតៀវសេងនឹងតាន់គីជាមេទ័ពមុខ ឲ្យតាន់ឡានជាមេទ័ពស្តាំ ឲ្យលុយប៊ុកជាមេទ័ពឆ្វេង ឲ្យអៀវហង់នឹងហាន់សៀមជាមេទ័ពគ្រាយ លើកទៅវាយស្រុកឈីដីវ ហើយឲ្យមានសំបុត្រទៅដល់គិមសៀង ចៅហ្វាយស្រុកយួនដីវ ដែលត្រូវឡើងខែត្រអ៊ីនសុតថា ឲ្យគំមសៀងចាត់ស្បៀងអាហារប្រគល់ឲ្យកងទ័ពដែលលើកទៅវាយស្រុកឈីដីវកុំឲ្យខ្វះខាត បើកងទ័ពខ្វះខាតដោយស្បៀងអាហារវេលាណា យើងត្រូវកាត់ក្បាលគិម

សៀងវៀលនោះ រួចចាត់ប្រៃតីឡែងលើកទំពាណូនតាមទៅទៀត កំទៅមិនទាន់ទុកចិត្តក៏ប្រើលោហង, លៀងកង នឹងជាក់ជីវ លើកតាមទៅត្រួតត្រាកងទំពាំងពួង ឲ្យស្រុតរួចូលធ្វើការឲ្យត្រមគ្នា ខ្លួនអ្នួនសុតកំលើកថាហាន ៣ ម៉ឺនទៅជាក្រោយ ។

កាលតៀវហ៊ុនលើកទ័ពទៅជិតនឹងដល់ស្រុកឈីជីវ ក៏ឲ្យបំបែកកងទ័ពញែកជា ៧កង ឲ្យតៀវសេងលើកទៅវាយស្រុកសៀវផាយ, ឲ្យតាន់គីលើកទៅវាយស្រុកគិនគោ ឲ្យលុយប៉ុកលើកទៅវាយស្រុកឡងអៀ ឲ្យតាន់ឡាន់លើកទៅវាយស្រុកកៀតសិក, ឲ្យហាន់សៀមលើកទៅវាយស្រុកហៃហ្ងឺ, ឲ្យអៀវហង់លើកទៅវាយស្រុកជុនស៊ូ. ខ្លួនតៀវហ៊ុននោះលើកទ័ពធំទៅវាយស្រុកឈីជីវ ហើយក៏ញែកគ្នាចេញជា ៧ផ្លូវ ដើរផ្លូវ ១ថ្ងៃ ចម្ងាយ ៥០០ សិន (២០ គីឡូម៉ែត្រ) ។

(មានត)

រឿងអាស័ក្សថ្ងៃនរឿងម្លៃថ្មា

លោក រ៉ាយ-ប៊ុក ក្រមការ ក្រុមពុទ្ធសាសនបណ្ឌិត្យ

ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

មានកាលមួយថ្ងៃ ព្រះមហាក្សត្រខ្មែរយាង ៗ កាន់ទីវាលហមគ្គលការ ឯគេហដ្ឋានរដ្ឋមន្ត្រី ជាមួយនឹងព្រះពរជ័យនូវឆ្នាំត្រមាំឆស័ក ។ ឯបុត្រនៃរដ្ឋមន្ត្រីនោះ បានឃើញមាណពមនុស្សដែលក្លាយកេទជាស្ត្រី ក៏មានចិត្តប្រដិព័ទ្ធពន់ប្រមាណ ហើយក៏ប្រាប់ទៅមិត្តខ្លួនម្នាក់ថា "បើខ្ញុំមិនបានស្ត្រីនោះមកធ្វើជាភរិយាទេ មុខជារលត់ជីវិត ក្នុងពេលនេះមិនខាន" ។

លុះព្រះមហាក្សត្រខ្មែរគ្រាលួច ត្រង់ក៏យាងវិលត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ។ ឯបុត្ររដ្ឋមន្ត្រីនោះកាលឃ្លាតពីមនុស្សី កាលណា ក៏កើតទុក្ខព្រួយចិត្តលែងអាស្រ័យនឹកលែងបរិភោគអាហារ ។ មានមិត្តភក្តិនៃកូនរដ្ឋមន្ត្រីម្នាក់ បានដំណឹងរឿងរ៉ាវសព្វគ្រប់របស់កូនលោករដ្ឋមន្ត្រី ក៏ទៅគាល់ព្រះមហាក្សត្រក្រាបបង្គំទូលថា "សូមត្រង់ព្រះមេត្តាប្រោស! កូនប្រុសទូលបង្គំមានសេចក្តីស្នេហាដ៏ខ្លាំងក្លាចំពោះកញ្ញាជាបុត្រីតាព្រាហ្មណ៍ ជាហេតុឲ្យទូលបង្គំព្រួយចិត្តពន់ពេក, កូនប្រុសទូលបង្គំលែងអាស្រ័យចង្ហាយនឹកសោះ, បើត្រង់អាណិតអាសូរដល់កូនទូលបង្គំ សូមត្រង់ព្រះមេត្តាប្រោស ធ្វើ

ព្រះពជអំណោយនូវកញ្ញានោះមកជាភរិយា, ហើយកូនប្រុសទួលបង្កើនធំ
ឋានសក្តិមានជីវិត តទៅអនាគត" ។

ព្រះមហាក្សត្រែធំព្រះគ្រោធជាខ្លាំង មានព្រះបន្ទូលថា "មិន
ត្រូវធ្វើដូចនេះទេ, មហាក្សត្រមិនត្រូវប្រព្រឹត្តទុច្ចរិតបែបនេះឡើយ, តើ
អ្នកឯងហ៊ានស្នើមកកាន់ខ្ញុំ ឲ្យខ្ញុំធ្វើយ៉ាងនេះឬ" ។

លោករដ្ឋមន្ត្រីបានស្តាប់នូវព្រះបន្ទូលព្រះមហាក្សត្រែក៏អស់សង្ឃឹមរួច
ត្រឡប់ទៅគេហដ្ឋានវិញ, ដល់ឃើញនូវសេចក្តីទុក្ខព្រួយនៃបុត្រាបស់
លោក។ ក៏កើតទុក្ខតាមកូន ក្រែចគិតបរិភោគអាហារតាំងពីពេលនោះមក។

លុះដល់លោករដ្ឋមន្ត្រីលែងបរិភោគអាហារអស់រយៈវេលា ៣ ថ្ងៃ
ពួកក្មាក់ជារខាងកិច្ចការទាំងឡាយ ក៏ប្រមូលគ្នាជាពួកធ្វើចុតហ្វាយថ្វាយ
ព្រះមហាក្សត្រែយ៉ាថា "សូមព្រះមេត្តាជ្រាប! បុត្រនៃលោករដ្ឋមន្ត្រី
ជិតមរណៈហើយ បើបុត្រនោះលះបង់អាយុសង្ខារទៅ មុខជាបិតានៃ
បុត្រនេះមិនរស់នៅយូរប៉ុន្មាន បើលោករដ្ឋមន្ត្រីអនិច្ចកម្មទៅ កិច្ចការ
ក្នុងព្រះពជអាណាចក្រក៏ធ្វើដំណើរទៅមិនបានស្រួលទេ គួរណាសំតែ
ព្រះអគ្គមែធំព្រះពជានុញ្ញាតទទួលតាមសេចក្តីសុំនៃលោករដ្ឋមន្ត្រី" ។
ព្រះមហាក្សត្រែយ៉ាមានព្រះបន្ទូលថា "ចូរអ្នកនោលមក យើងនឹង
ស្តាប់តទៅទៀត" ។

ក្នុងពេលនោះ មានក្មាកង៉ាម្នាក់ក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តាជ្រាស! ជាយូរថ្ងៃមកហើយដែលតាព្រាហ្មណ៍ចេញពីក្រុងនេះទៅ ហើយគាត់មិនទាន់វិលត្រឡប់មកវិញទេ មានតែព្រះអាទិទេពទេដែលអាចជ្រាបបានថា តាព្រាហ្មណ៍នោះរស់ឬស្លាប់; ព្រោះហេតុនេះគួរតែទ្រង់ជ្រាសព្រះរាជទានទូរកញ្ញាជាបុត្រីតាព្រាហ្មណ៍នោះ ទៅបុត្រលោករដ្ឋមន្ត្រី, ទ្រង់នឹងបានធ្វើឲ្យព្រះរាជរដ្ឋាភិបាលឲ្យមានសភាពរឹងប៉ឹងឡើង; បើសិនណាជាតាព្រាហ្មណ៍ចាស់វិលត្រឡប់មកវិញ សូមទ្រង់ព្រះរាជទានទូរកូមិឬព្រះរាជទ្រព្យ, បើតាព្រាហ្មណ៍នោះមិនត្រឡប់មកទេ សូមទ្រង់ព្រះរាជទានស្ត្រីម្នាក់ទៅជាភរិយាតាព្រាហ្មណ៍។ មុខជាមានអំណរខ្លាំងពុំខាន" ។

ព្រះមហាក្សត្រ ទ្រង់ព្រះសណ្តាប់ទូរសេចក្តីស្នើនៃពួកក្មាកង៉ាទាំងនោះ ហើយត្រាសបង្គាប់ឲ្យហៅនាងកញ្ញានៃតាព្រាហ្មណ៍នោះមក ទើបមានព្រះបន្ទូលថា "ចូរនាងអញ្ជើញទៅឯគេហដ្ឋានៃបុត្រលោករដ្ឋមន្ត្រីចុះ" ។ នាងកញ្ញាក្រាបបង្គំទូលព្រះមហាក្សត្រថា "គុណសម្បត្តិនៃស្ត្រីនឹងវិនាសទៅ ដោយសារលំអរបស់ស្ត្រីនោះ, ព្រាហ្មណ៍ធ្វើឲ្យអន្តរាយទូរគុណធម៌របស់ខ្លួនដោយធ្វើការព្រះមហាក្សត្រ, គោញីវង្វែងផ្លូវដោយវាលស្មៅនៅឆ្ងាយ, គេធ្វើឲ្យរលាយកេរគ្រឿងរបស់ខ្លួនដោយក្តេចប្រព្រឹត្តទូរកេរណ៍យកិច្ចរបស់ខ្លួន" ហើយនាងបានក្រាបទូល

បំពេញថា "បពិត្រមហារាជ! ព្រះរាជបំណងព្រះអង្គគឺចង់ឲ្យខ្ញុំម្ចាស់ទៅជាកំរៀយបុត្រលោករដ្ឋមន្ត្រី ខ្ញុំម្ចាស់សូមព្រះរាជានុញ្ញាតឲ្យបុរសនោះធ្វើតាមបង្គាប់ខ្ញុំម្ចាស់។ នឹងទៅឯគេហដ្ឋាននៃបុរសនោះជាមិនខាន ក្រោយ"។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលសួរថា "តើត្រូវឲ្យបុរសនោះធ្វើយ៉ាងណា?"។ នាងព្រាហ្មណីក្រាបទូលព្រះមហាក្សត្រថា "សូមទ្រង់ព្រះមេត្តាប្រោស! ខ្ញុំម្ចាស់មានវណ្ណៈជាព្រាហ្មណ៍ បុរសនោះមានវណ្ណៈជាក្សត្រ, ត្រូវតែបុរសនោះទៅធុតង្គឯបូជនីយដ្ឋាន រួចវិលត្រឡប់មកវិញ ទើបខ្ញុំម្ចាស់ព្រមរៀបវិវាហមង្គលជាមួយនឹងបុរសនោះ"។ ព្រះមហាក្សត្រទ្រង់ព្រះសណ្តាប់ន្ធូវាក្យមនស្ស៊ី រួចទ្រង់មានព្រះបញ្ជាឲ្យហៅបុត្រលោករដ្ឋមន្ត្រីមកហើយ មានបន្ទូលថា "ត្រូវឯងទៅធុតង្គសិនរួចយើងនឹងឲ្យនាងព្រាហ្មណីនេះជាកំរៀយ ក្នុងកាលឯងវិលត្រឡប់មកវិញ"។ បុត្រលោករដ្ឋមន្ត្រីបានស្តាប់ន្ធូវព្រះបន្ទូលព្រះមហាក្សត្រហើយ ក្រាបបង្គំទូលតបថា "សូមទ្រង់ព្រះមេត្តាប្រោស! សូមឲ្យតែនាងមកនៅគេហដ្ឋានទូលបង្គំជាដំបូងចុះ ទូលបង្គំនឹងទៅធុតង្គជាក្រោយ"។ ព្រះមហាក្សត្រទ្រង់មានបន្ទូលឲ្យមនស្ស៊ីទៅនៅឯគេហដ្ឋាននៃបុត្រលោករដ្ឋមន្ត្រី។ ដោយព្រះមហាក្សត្រត្រាស់បង្គាប់ដូច្នោះ មនស្ស៊ីក៏ត្រូវតែតាមព្រះរាជឫទ្ធានុភាព។ រួចបុត្រលោករដ្ឋមន្ត្រីក៏ឲ្យឱវាទនាងព្រាហ្មណីថា "បួរនាងតាំងពីរនៅជាសុខជាមួយគ្នាចុះ, បួរនាងស្រឡាញ់

គ្នាទៅវិញទៅមក ហើយកុំឈ្លោះប្រកែកគ្នាកុំព្យាបាទគំនុំគ្នា កុំទៅលេងនៅផ្ទះអ្នកដទៃ " ។

លុះបុត្រលោកវដ្ដមន្ត្រីឲ្យនុវាទយ៉ាងនេះរួចហើយ ក៏ទៅធុតង្គបាត់ទៅ ។ ភរិយារបស់លោកឈ្មោះនាង សម្ភាគ្យសុន្ទរី (Sambhagya Sundari) បាននាំនាងកញ្ញាជាបុត្រីនៃតាព្រាហ្មណ៍ចូលទៅក្នុងផ្ទះ ហើយពិសាយប៉ែនាងទាំងពីរនៅលើគ្រែជាមួយគ្នា ដាច់ដាគ្នាពីរឿងនេះរឿងនោះ ។ ដល់យូរបន្តិចមក នាងសម្ភាគ្យសុន្ទរីនិយាយទៅនឹងមនស្ស៊ីថា " នាង ! ឥឡូវនេះ កាមរាគជុតពេលវាលសត្វសព្វាង្គកាយខ្ញុំជាភ្ញាំងតើធ្វើដូចម្តេចនឹងបំពេញបំណងនោះបាន ? " ។ មនស្ស៊ីតបថា " បើខ្ញុំរិះរកមធ្យោបាយបាន តើនាងឲ្យអ្វីមកខ្ញុំ ? " ។ នាងសម្ភាគ្យសុន្ទរីពោលតបថា " តាំងពីថ្ងៃនេះទៅ ខ្ញុំនឹងសំពះនាងជានិរន្តរ៍ ហើយធ្វើតាមបង្គាប់នាងទាំងអស់ " ។ មនស្ស៊ីដកយកថ្នាំគុលិកាពីក្នុងមាត់ប្រែកេះទៅជាប្រុសហើយតាំងពីថ្ងៃនោះមកមនស្ស៊ីទៅជាប្រុសក្នុងពេលយប់ ទៅជាស្រីក្នុងពេលថ្ងៃ ។ នាងទាំងពីរនេះស្រឡាញ់គ្នា ឥតមានរលកជង្គិនទេ ។

លុះដល់កន្ទុងទៅបាន ៦ ខែ បុត្រលោកវដ្ដមន្ត្រីក៏វិលត្រឡប់ពីធុតង្គមកវិញ ។ ប្រជារាស្ត្រទាំងអស់គាលបានដំណឹងថាបុត្រលោកវដ្ដមន្ត្រីវិលត្រឡប់មកគេហដ្ឋានវិញ ក៏នាំគ្នារៀបពិធីបុណ្យទទួលជារឿយៗ ។ ក្នុងពេលនោះ មនស្ស៊ីបានដកថ្នាំគុលិកាចេញពីមាត់ ប្រែកេះទៅជាប្រុស

ហោះតាមបង្ហួចនៃឥដ្ឋាគារ ។ បន្តិចមក មនស្សីកំសៅដល់គេហដ្ឋានតា
ព្រាហ្មណ៍មុលទេព ដែលបានឲ្យថ្នាំគុលិកានោះ ហើយពណ៌នាទូរវឿន
ពីរដំណតាព្រាហ្មណ៍សព្វគ្រប់ ។ តាព្រាហ្មណ៍មុលទេពបានស្តាប់
ហើយ ក៏យកថ្នាំគុលិកាពីមនស្សីមកវិញ រួចប្រគល់ទៅឲ្យសហជីវិនរបស់
គាត់ គឺព្រាហ្មណ៍សសី ។ ព្រាហ្មណ៍ចាំងពីរនាក់បានបៀមថ្នាំគុលិកា
រៀងខ្លួន ព្រាហ្មណ៍មួយទៅជាតាចាស់ ព្រាហ្មណ៍មួយទៀតទៅជា
ប្រុសកំឡោះអាយុម្ភៃឆ្នាំ ។ ព្រាហ្មណ៍ចាំងពីរនេះបាននាំគ្នាទៅគាល់
ព្រះមហាក្សត្រ ។ លុះទ្រង់ទតឃើញព្រាហ្មណ៍ចាំង ២ នាក់មកដល់ក៏
សំដែងគារវភាព ត្រាស់បង្គាប់ឲ្យយកកៅអីមកឲ្យព្រាហ្មណ៍អង្គុយ ។
ព្រាហ្មណ៍ចាំង ២ នាក់ក៏សូត្រធម៌ថ្វាយពរជយមង្គល ចំពោះព្រះមហា
ក្សត្រ ។ មានបន្ទូលសួរអំពីសុខភាពនឹងសុកមង្គល នៃព្រាហ្មណ៍ចាំងពីរ
រួចទ្រង់ត្រាស់សួរតាមុលទេពថា "ចុះលោកតាធ្វើអ្វីខ្លះ ក្នុងរយៈវេលា
ពីនោះមកដល់ឥឡូវនេះ ? " ។

ព្រាហ្មណ៍ក្រាបបង្គំទូលព្រះមហាក្សត្រថា "បពិត្រព្រះមហារាជ!
ទូលបង្គំបានទៅរកកូនប្រុសនោះឃើញហើយ ។ ទូលបង្គំបាននាំបុត្រនោះ
មកថ្វាយព្រះអង្គ សូមព្រះអង្គប្រគល់នាងជាភរិយានោះមកឲ្យបុត្រទូល
បង្គំ ។ នឹងនាំទៅគេហដ្ឋានទូលបង្គំវិញ " ។ ព្រះមហាក្សត្រទ្រង់
បានពណ៌នាទូរវឿនពីរដំណតាព្រាហ្មណ៍ ។ ក៏ច្រឡោតទឹងជាខ្លាំង

ហើយក្រាបទូលថា "ម្តេចក៏ព្រះអង្គផ្ទាស់ប្តូរយ៉ាងនេះ, ព្រះអង្គហ៊ាន យកធីតាដែលជាភរិយាបុត្រទូលបង្គំទៅឱ្យអ្នកឯទៀត, ល្អហើយ, ទ្រង់ ធ្វើតាមតែព្រះទ័យទ្រង់, ទ្រង់នឹងត្រូវបណ្តាសាយើងមួយជាតិ" ។ ព្រះ មហាក្សត្រទ្រង់បួងសួងព្រះអាទិទេពថា "សូមកុំឱ្យតាព្រាហ្មណ៍ឯងទទឹង សម្បារអ្វីនឹងយើង។ នឹងធ្វើតាមបង្គាប់តាព្រាហ្មណ៍ឯងទាំងអស់" ។ តាព្រាហ្មណ៍ក្រាបបង្គំទូលសួរថា "បើទ្រង់ខ្ជាបបណ្តាសាយើងខ្ញុំ ត្រូវ ទ្រង់ធ្វើតាមបង្គាប់យើងខ្ញុំ ចូរទ្រង់ចាត់រៀបវិវាហមង្គលការបុត្រយើងខ្ញុំ នឹងបុត្រីរបស់ទ្រង់ឱ្យឆាប់" ។

ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ឱ្យ·ហៅហោរ មកកំណត់ពេល ជយមង្គលនឹងរៀបការនោះ ឯព្រះពជទានព្រះពជបុត្រីនឹងចំណងដៃ ទៅបុត្រនៃព្រាហ្មណ៍។ ក៏ក្រាបថ្វាយបង្គំលាព្រះមហាក្សត្រវិលត្រឡប់ ទៅកាន់ភូមិលំនៅវិញ នាំតាំងព្រះពជបុត្រីទៅផង ។

ព្រាហ្មណ៍មនស្ស ដល់ឯដំណឹងនោះហើយ ក៏មករកឰនហេតុ ប្រឈ្មោះគ្នានឹងព្រាហ្មណ៍សសីថា "ត្រូវប្រគល់ព្រះពជបុត្រីជាភរិយា មកឱ្យខ្ញុំនេះវិញ" ។ ព្រាហ្មណ៍សសីបាននោលតបទៅព្រាហ្មណ៍មនស្ស វិញថា "ព្រះពជធីតានេះជាប្រពន្ធរបស់ខ្ញុំ។ ឯានរៀបមង្គលការជាមួយ នាងនេះ ចំពោះមុខជប់នាក់" ។ មនស្សឹតបថា "ម្តេចក៏ឯងថានាង នេះជាភរិយារបស់ឯង, បើអញឯានៅរួមជាមួយព្រះនាងនេះ រហូតដល់ ទៅមានគតិផង" ។

លោកតាមុលទេពបានឃើញព្រាហ្មណ៍ចាំង ២ នាក់ ឈ្លោះទាស់ទែងគ្នា
ខំព្យាយាមផ្សះផ្សាមិនព្រមជានឹងគ្នាសោះ គ្មានអ្នកណាព្រមស្តាប់តាត់ ។

អារក្សលុះដល់បានពាណិនារឿងក៏វានេះចប់ហើយ ក៏ក្រាបទូលសួរ
ព្រះបាទពិក្រម៉ាថា "សូមទ្រង់ព្រះមេត្តាជ្រាស! សូមទ្រង់ជ្រោះសា
មកមើល តើនាងនោះត្រូវបានជាកំរិយាអ្នកណា ?" ។ ព្រះបាទពិក្រម
ទ្រង់មានព្រះបន្ទូលថា "នាងនេះត្រូវបានជាកំរិយានៃព្រាហ្មណ៍សសី" ។
អារក្សក្រាបទូលសួរថា "សូមទ្រង់ព្រះមេត្តាជ្រាស! ម្តេចក៏ព្រះ
អង្គមានបន្ទូលថានាងនេះត្រូវបានជាកំរិយារបស់ព្រាហ្មណ៍សសី បើ
នាងនេះមានគតិនឹងមនស្ស ?" ។ ព្រះមហាក្សត្រទ្រង់មានបន្ទូលថា
"គ្មានអ្នកណាដឹងជាព្រាហ្មណ៍មនស្សធ្វើឲ្យព្រះនាងទ្រង់គតិទេ ចំណែក
ព្រាហ្មណ៍សសីបានរៀបរាប់ហាមឆ្កួលការនឹងព្រះនាងនេះ សឹងមានគេដឹង
ជាច្រើននាក់ សឲ្យឃើញថានាងនេះជាកំរិយារបស់ព្រាហ្មណ៍សសីពិត
មែន, ឯបុត្រដែលបដិសន្ធិកន្លះព្រះនាងនេះ មានសិទ្ធិបំពេញការណីយ-
កិច្ចចំពោះអ្នកដែលធ្វើមរណភាពពីអតីតកាល ចាំង ២ ខាង ។

អារក្សបានស្តាប់ខ្លួវព្រះបន្ទូលព្រះមហាក្សត្រហើយ រួលត្រឡប់ទៅ
ព្យរខ្លួនឯងរុក្ខជាតិ សិរិស (Siris) ដូចមុន ។ ព្រះមហាក្សត្រទ្រង់
ស្រោចស្រង់ខ្លួវអារក្សនោះនាំយកទៅ ។

សន្ទិសិនព្រះពោធិវង្ស ហ្គួត - តាត

ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ជាប្រធាននៃគណៈប្រតិភូខ្មែរ

សំដែងអំពីសមាជសាកលលើកទី៧នៃពុទ្ធសាសនា

នៅទីក្រុងតូក្យូ (ប្រទេសជប៉ុន)

ពុទ្ធសាសនបណ្ឌិត្យ

ព្រះតេជព្រះគុណអគ្គនេះបានធ្វើសន្ទិសិទអំពីរឿងនេះ

១ — នៅវត្តព្រះកែវមរកតពីថ្ងៃអាទិត្យទី ១៦ វិច្ឆិកា ១៩៥២ ពេលម៉ោង ៤ រសៀល ដោយសេចក្តីនិមន្តនៃពុទ្ធិកសមាគមមជ្ឈិមណ្ឌលកម្ពុជវង្ស ទីដ៏សមាគមមិត្តសាលាបាលី ។

២ — នៅវត្តលង្កាពីថ្ងៃទី ១ ធ្នូ ១៩៥២ ដោយសេចក្តីនិមន្តនៃលោកយោគ្យាត្រជាន់ អ្នកស្រីម៉ាលីយ៉ង់ ព្រមទាំងគ្រួសារក្នុងឱកាសបុណ្យផ្កាដួសដុលព្រះវិហារវត្តលង្កា ។

ម៉ោង ២១ ក្រោយដែលបានចំរើនព្រះបរិត្តរួចស្រេច, ព្រះតេជព្រះគុណព្រះពោធិវង្ស ហ្គួត - តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់ កំបានទិមន្តទៅដឹកនាំលើគ្រែធម្មាសនៈ ទេសនាអំពីលោកដែលបានធ្វើដំណើរចេញពីប្រទេសកម្ពុជា ទិមន្តទៅប្រទេសជប៉ុន ដូចតទៅនេះ :-

ពីថ្ងៃសុក្រទី ៩ កញ្ញា ១៩៥២ ពេលម៉ោង ៧ ខ្ញុំព្រះករុណាអាត្មាភាព ឃានចេញពីព្រះពជ្ជាន៍ក្តុំតេញ ដោយអាកាសយាន

តម្រង់ទៅកាន់ទីក្រុងវៀនតរ ។ អ្នកដែលបានធ្វើដំណើរទៅជាមួយ
អាត្មាផង គឺលោកមហាថៃ - សុខ, លោកក្រូម៉ង់ - ប៉ាន់ ជាសមាជិក,
លោក បេ - យាន អញ្ជើញទៅជាអ្នកសង្កេតការដោយខ្លួនឯង ។

នៅទីក្រុងវៀនតរ ខ្ញុំព្រះករុណា, អាត្មាភាព បានទៅសំណាក់
នៅព្រះពុទ្ធប្រតិកូស្ថានអមទុត្តមស្ថង ការដ្ឋានឥណ្ឌូចិន មានឯកទុត្តម
ស៊ុំ - ហៀង ជាអ្នកតំណាងព្រះករុណាជាអម្ចាស់ជីវិតនៅទីនោះ ។ អាត្មា
ស្ថិតនៅពីថ្ងៃទី ៩ កញ្ញា ទៅដល់ថ្ងៃទី ១៤ កញ្ញា, ពេលមោង ៤
កន្លះបានធ្វើដំណើរទៅទីក្រុងម៉ានិល ជារាជធានីប្រទេសហ្វីលីពីនតាម
នាវា "ម៉ាស៊ីយ៉ែស" នៅទីក្រុងនោះ ប្រជាជនកាន់គ្រិស្តសាសនា
និងពុទ្ធសាសនាខាងមហាយាន ។ ព្រះសង្ឃខាងពុទ្ធសាសនាមហាយាន
បានទិមន្តមកធ្វើបដិសណ្ឋារៈដោយស្មោះស្ម័គ្រ ខ្ញុំព្រះករុណា អាត្មា
ភាពគិតថា: "កាលនៅប្រទេសកម្ពុជា, ព្រះសង្ឃខាងមហាយាន
មិនដែលចូលគ្នាចុះសោះឡើយ ព្រោះកាន់លទ្ធិខុសគ្នា លោកសង្ឃខាង
លទ្ធិមហាយានធាន់ជាយល់ច, ស្រឡាំកាំអាវ ។ តែដោយសេចក្តី
សាមគ្គីនៃព្រះសង្ឃមហាយាន ចំពោះមកខាងព្រះសង្ឃហីនយាន ខ្ញុំព្រះ
ករុណាអាត្មាភាពក៏គិតថា គួរតែប្រែគំនិតមុនចោលចេញ យកគំនិតថ្មីនេះ
វិញគឺជាមិសាមគ្គីនោះឯង សមដូចឆន្ទៈពុទ្ធិកសមាគមពិភពលោកដែល
ព្យាយាមធ្វើសមាជលើកទី ១ នៅក្រុងកូលម្ប៊ូ (កោះសីឡង់), លើក

ទី ២ នៅទីក្រុងតូក្យូ (ប្រទេសជប៉ុន) ដើម្បីរួបរួមប្រទេសចាំងឡាយ
ក្នុងសាកលលោក (ប្រវែលជាងសាមសិបប្រទេស) ឲ្យស្គាបនាខ្លួ
ពុទ្ធិកសមាគមមជ្ឈមមណ្ឌលគ្រប់ ។ គ្នា ផ្សាយព្រះពុទ្ធសាសនាឲ្យជ្រួត
ជ្រាបទៅក្នុងសន្តានៃប្រជាពស្ត្រ ជាហេតុឲ្យមនុស្សធ្វើសាមគ្គីធម៌ ដែល
ដឹកនាំលោកទៅកាន់សន្តិភាព ព្រោះហេតុដូចនេះ ពិតមែនតែព្រះសង្ឃ
ចាំងនេះ កាន់លទ្ធិខុសគ្នា ស្លៀកពាក់ខុសគ្នា មានគំនិតយោបល់ខុសគ្នា
តែគង់មានប្រាថ្នាទៅកាន់វត្ថុបំណងតែមួយដូចគ្នា គឺអមតមហានិព្វាន ។
ប្រៀបដូចជាក្មេងតូវតន្ត្រីមួយមានស្គរវរនាត, គង, ចាប៉ី, ខ្លុយ, ចម្រៀង
ទៅដោយឡែក ។ ពីគ្នា តែសូរសព្ទចាំងនេះ គង់រួបរួមគ្នាចូលទៅជា
សំឡេងមួយហៅថាពីរោះពីសាតែម្យ៉ាង ។ នេះជាទុតិយគតិមួយ គួរយក
មកខ្ទុកជាច្បាប់ប្រាណសម្រាប់ជាស់តឿនពួកព្រះសង្ឃទីងពួកពុទ្ធបរិស័ទ
នៅប្រទេសយើងឲ្យមានសាមគ្គីត្រមត្រៀងគ្នា លះបង់ខ្លួវសេចក្តីប្រកាន់
គ្នាទៅវិញទៅមក ។

ខ្ញុំព្រះករុណា អាត្មាភាពបានចេញពីទីក្រុងម៉ានីលពីព្រឹក ធ្វើ
ដំណើរទៅដល់ទីក្រុងហុងកុងម៉ោង ២ ។ នៅទីនេះក៏មានអ្នកកាន់ព្រះ
ពុទ្ធសាសនាខាងមហាយានដែរ គេក៏ពាប់អានយើងដូចព្រះសង្ឃខាង
ទីក្រុងម៉ានីល ។

ខ្ញុំព្រះករុណាអាត្មាភាព បានចេញពីទីក្រុងនេះទៅកាន់ទីក្រុងយូកូហាម៉ា ប្រទេសជប៉ុនចំនួន ៤ ថ្ងៃ ៤ យប់ទើបដល់ ។ កន្លងពេលដែលនៅលើនាវា មានលោកដុកទ័រគុណបណ្ឌិតឈ្មោះ:ម៉ាលាល៉ះ:សេកេរៈ ប្រធានពុទ្ធិកសមាគមពិភពលោក ព្រមទាំងគណៈប្រតិភូប្រទេសកម្ពុជា, ឥណ្ឌា, ប្រទេសថៃ, យៀកណាម, ភូមាជាដើម បានទៅប្រជុំគ្នានៅទីនោះ ។ លោកប្រធានពុទ្ធិកសមាគមពិភពលោកបានឲ្យដំណឹងអាត្មាថា: លោកសង្ឃនៅប្រទេសជប៉ុនគ្មានធាន់សាច់ ធាន់តែបន្លែឬមើមឈើ, ប្រហែលជាលោកចំាទ្រនឹងចង្ហាន់បែបនេះមិនបានទេដឹង ។ អាត្មាភាពតបទៅលោកប្រធានវិញថា: លោកកុំព្រួយអំពីរឿងចង្ហាន់នេះឲ្យសោះ បើគេធាន់យ៉ាងណា អាត្មាក៏ធាន់យ៉ាងនោះបានដូចគ្នា ។

រួចបាននាវាទៅដល់ទីក្រុងយូកូហាម៉ា ជាកំពង់នាវានៃប្រទេសជប៉ុន ទើបមានរថយន្តមួយមកទទួលអាត្មាឲ្យទៅកាន់ព្រះពជធានីតូក្យូ ។ ទីកន្លែងសមាជនោះគឺវត្តហុង្គាយិ ។ ឯអាត្មាភាពទទឹងសមាជិកគណៈប្រតិភូបានទៅសំណាក់នៅវត្តសុដី-ដិ ចម្ងាយសាមសិបគីឡូម៉ែត្រពីទីក្រុងតូក្យូ, ដល់ពេលមហាសន្និបាត ទើបមានរថយន្តទៅទទួល ។

វត្តនេះមានសភាពស្អាតជាទិច្ច; ខាងយ៉, កន្លងបន្ទប់ទាំងអស់ក៏ស្អាត នៅខាងដីគ្រែកាមសាលា, កុដិ ជាដើម គ្មានសល់មាមេសូម្បីតែបន្តិចក៏ស្អាត ។ អាត្មាបានទៅមើលវត្តឯទៀតក៏ស្អាតដូចគ្នា, តាម

វិថីក្រែងក៏ស្អាតដែរ, ខុសពីសភាពវត្តខាងប្រទេសកម្ពុជាយើង បើវត្តខាងយើង កិក្ខុសាមណេរផ្ទាស់វេនគ្នាបោសសំអាតកុដិអាវាស ព្រះវិហារជាដើម មុខជានឹងបានស្អាតមិនខាន, បើមិនស្អាតដូចវត្តនៅប្រទេសជប៉ុនក៏សមគួរនឹងក្អែកខ្លះ ។ នេះមិនដូចនោះ គឺប្រទេសយើងទម្លាប់ស្មោកគ្រោក, ចោលវត្ថុឥតរបបត្រង់ណាក៏ចោលៗ, មិនបានគិតថា ទីនេះគួរចោលសម្រាមចាំងនេះបាន, ទីនេះមិនគួរចោល, សូម្បីតែកាកអំពៅ ក៏ចោលពាសពេញដី ព្រោះទម្លាប់ជាធំ ធ្លាប់ស្មោកគ្រោក ទៅតែស្មោកគ្រោក, ធ្លាប់ស្អាតនៅតែស្អាត បើយើងដាក់វិន័យឲ្យតឹងរ៉ឹងបន្តិច ចំពោះលោកសង្ឃប្រទេសយើង ក្នុងការបោសឆាសនូវកុដិ, អាវាស, សាលា, មុខជាទម្លាប់ស្អាតនោះ ទឹងដិតជាមៅកងហទយវត្ថុព្រះសង្ឃចាំងនោះ ទឹងក្លាយទៅជាចរិយាល្អគឺចិត្តស្អាត នាំឲ្យសភាពខាងក្រៅស្អាត ។

លំជាប់តពីនេះ. អាត្មាបានទៅពិនិត្យមើលទីក្រែង, ចូលទៅកងគេហដ្ឋាននៃគ្រួសារជប៉ុនខ្លះ ឃើញស្ត្រីជប៉ុនគោរពស្វាមី ប្លែកពីស្ត្រីប្រទេសយើង គឺថាបើស្វាមីមកដល់មុខផ្ទះភ្លាម ភរិយាសួរទៅសំពះស្វាមី កាន់ដៃឡើងមកលើគេហដ្ឋាន, សូម្បីតែហុចវត្ថុអ្វី ។ ទៅស្វាមីក៏ត្រូវសំពះជាមុនសិន, ពេលដេក, ដើរ, ង្គុតទឹក, ត្រូវគោរពជានិរន្តរ៍ : បានជាលោក បេ - យាន ជាអ្នកសង្កេតការដែលទៅជាមួយអាត្មា ទៅជាលាន់មាត់ថា ចង់បានស្រីជប៉ុនមួយនាក់ធ្វើជាកូនប្រសា ។

ទីក្រុងតូក្យូមានចំនួនមនុស្សប្រមាណកន្លះ ជាព្រះរាជធានីប្រទេសជប៉ុនតាំងពី គ. ស. ១៨៦៨ ។ ទីក្រុងនេះសម្បូណ៌ទាំងពាណិជ្ជកម្ម, ទស្សាហកម្ម ហើយរចនាតាមសភាពអឺរ៉ុប ។

ប្រជារស្ត្រជប៉ុន នៅក្នុងសិលាគឺនគ្មានថ្នាក់ មានទ្យានដាំបុប្ផាគ្រីសង់ថែមទឹងបុប្ផាឯទៀតក្រអូបឈ្ងុយឈ្ងប់ពាសពេញ ។ បុរសទាបតែធ្វើការមុតមាំចិត្តក្លាហាន ។ ប្រទេសនោះត្រជាក់ ។ អាត្មាគេបានឲ្យខោ អាវធ្វើពីរណ្តាម័យ ដោយគេឃើញថាស្បង់នេះស្តើង មិនអាចធន់ទឹងរងាបាន ។ មានការមួយថ្ងៃរៀបឡើងរថយន្ត គេបានយកផ្ទៃសីរសេមកប្រគេន, អាត្មាព្រមទាំងព្រះមហាថៃ-សុខ៣នាក់រួច ក៏ឡើងរថយន្តយកទាំងសំបកផ្ទៃសីរសេនោះទៅផង ដោយមិនហ៊ានចោលព្រោះសាលាវត្តនោះស្អាតណាស់, អាត្មាគិតថាចាំឡើងរថយន្តមក ក្រែងមានកន្ទែងណាល្មមចោលសំបកនេះ, ចប់តាមវិថីរហូតមក មិនឃើញមានទីល្មមនឹងចោះសំបកនោះចោល, សំបកនៅកាំខ្ចប់ទឹងកន្ទែងស្អាត; តាមចិញ្ចើមវិថីគ្មានសម្រាមបន្តិចសោះ, កណ្តាលវិថីក៏គ្មាន ។ លុះទៅដល់ទីកន្ទែងធ្វើសមាជ អ្នកប្រតិកូលប់ប្រទេសពោលសុទ្ធតែភាសាអង់គ្លេស ។ អាត្មាប្រសើយគ្មានទឹងអ្នកប្រតិកូលត់ណៀងដោយប្រើភាសាជាលីសួរធ្វើឲ្យខើបស្តាប់បានខ្លះ ។ អាត្មាសូមដំរាបពួកពុទ្ធបរិស័ទទាំងឡាយ, សូមអប់រំចាស់ក្មេងឲ្យរៀនសូត្រភាសាអង់គ្លេសឲ្យមាំមួន ព្រោះចេញតែពីព្រៃនគរទៅ ប្រទេសណាក៏គេប្រើភាសាអង់គ្លេសទាំងអស់ ។

ភាសានេះជាភាសាសាកល, ភាសាការទូតំ, ភាសាដែលជនជាតិទាំងអស់
និយមពោលច្រើនជាងភាសាឯទៀត ។

អាត្មាលំបាកក្នុងចិត្តពន់ពេក ដោយមិនចេះភាសាអង់គ្លេសច្បាស់ត្រឹម
ការមិនបានចំរើនសព្វគ្រប់ ។ មានមួយថ្ងៃ អាត្មាតំយុជាខ្លាំងដោយ
ច្បាស់ក្បែរទេសទាំងអស់ គេបានយកអំណោយដ៏ថ្លៃថ្លាពីច្បែរទេសសព្វ ។
ខ្លួន ។ ឯអាត្មាគិតថា: មានព្រះពាជបុត្រហ្នាយព្រះករុណាជាអម្ចាស់ដ៏វិត
លើត្បូង, ព្រះសង្ឃដីកាសម្តេចព្រះសង្ឃនាយកគណៈមហានិកាយ នឹង
សុន្ទរកថាអាត្មាហើយជាភាសាខ្មែរផង តួចចិត្តពន់ពេក, មិនដឹងគិតយ៉ាង
ណា, ដល់ស្អែកឡើង អាត្មាឲ្យដំណឹងគេថាមិនបានទៅច្រជុំសមាជនោះ
ទេ ។ អាត្មាក៏ធ្វើតនុកាសពេលនោះ ឲ្យលោកគ្រូម៉ង់ ប៉ាន់ច្រែជាភាសា
អង់គ្លេស នូវព្រះពាជសុន្ទរកថា ព្រះសង្ឃដីកា នឹងសុន្ទរកថាអាត្មា,
ហើយយកទៅឲ្យពោធិ៍ពុម្ពគេបោះពុម្ព ២.០០០ ក្បាល, អាត្មាបានជាប់
ទៅជាមួយសៀវភៅធម៌ខ្លះច្រមូលទាំងអស់ទៅជាអំណោយលួមសមគួរ ។
អាត្មាមិនដឹងសោះរឿងនេះ, បើដឹងនឹងគេលួមយកព្រះពុទ្ធរូបកែវឬជ្រើបក់ប្ត
ជាគ្រឿងរតនៈផ្សេង ។ ឲ្យសមជាតំណាងច្បែរទេសខ្មែរ ព្រោះថាបើគ្មាន
អំណោយធ្វើក្នុងពេលនោះ មិនអាប់តែអាត្មាទេនឹងអាប់ដល់ច្បែរទេសកម្ពុជា
ទាំងមូល ។ ព្រោះហេតុដូចនេះបានជាអាត្មាខំព្យាយាមលៃលក បើមិន
បានស្មើនឹងគេឲ្យតែសមគួរកុំឲ្យខ្ពស់ពេកទាបពេក ។

(មានត)

សម្តែបសង្ឃរាយកគណៈអមរៈបុរៈមហាធិកាយ

ទៅប្រទេសស៊ីឡង់ថ្ងៃកន្លងសមាជសាកលលើកទី ២ នៃព្រះពុទ្ធសាសនា

(តូក្យូ ២៥ កញ្ញា, ១៣ តុលា ១៩៥២)

ព្រះពុទ្ធសាសនបណ្ឌិត្យ

លោកប្រធាន! ព្រះភិក្ខុសង្ឃគាំងឡាយ!

លោកស្រី! លោក-អ្នកគាំងឡាយ!

ក្នុងចំណោមនៃព្រះមហាគរុ ដែលមានព្រះទ័យអាណិតអាសូរដល់សត្វលោក ដែលគេឃើញកើតមាននៅក្នុងលោក មានតែព្រះសម្មាសម្ពុទ្ធជាបរមគ្រូ ព្រះអង្គទ្រង់មានព្រះទ័យប្រកបដោយមហាករុណាគុណជាយ៉ាងក្រៃលែង ។ កន្លងកាលជាយូរណាស់មកហើយ ព្រះអង្គទ្រង់បានសោយទុក្ខលំបាកជាអនេកប្បការ ដើម្បីនឹងទ្រង់ដឹកនាំសត្វឥតមានរើសមុខ ទៅកាន់ស្ថានដ៏បរមសុខគឺព្រះនិព្វាន ។ ការដែលព្រះអង្គទ្រង់ខ្នួលទុក្ខជាខ្លាំង ដោយសេចក្តីអាណិតអាសូរដល់សត្វលោកដែលមានទុក្ខចំពោះខ្លួន, ព្រះអង្គក៏បានសម្រែចនូវសម្មាសម្ពោធិញ្ញាណត្រាស់ដឹងនូវបតុភវៃយសច្ចជាអវសាន ។

ក្រួច កន្លងយ:វេលាសែសិបប្រាំឆ្នាំ ព្រះអង្គទ្រង់ធ្វើព្រះកដំណើរទៅតាមស្រុកនិគមជនបទកន្លងប្រទេសឥណ្ឌៀនឹងស៊ីឡង់ ទ្រង់បាន

ទេសនាព្រះធម៌និងព្រះវិន័យព្រះពុទ្ធជាន់ផ្លូវសុខឲ្យគ្រប់ៗគ្នា ។ គឺគ្មាន
មានទឹកដីថ្លាត្រជាក់ ប្រកបដោយអមតភាពនៃព្រះធម៌ដែលព្រះអង្គទ្រង់
ទេសនាទូន្មាននោះ ឋានចូលទៅស្រោចស្រង់នូវដួងហទយវត្ថុនៃជីវសត្វ
ដែលមានទុក្ខភ័យលិចលង់ទៅក្នុងវដ្តសង្សារ ។ សារភ័ព្រះអង្គ
ដែលមានបំណងរចនាខ្លួនលោកទៅកាន់សត្តិតភាព ទើងទេសនាទូន្មាន
ប្រដៅអ្នកឯទៀតឲ្យបានទៅកាន់វិឈ្នានភាព ដោយការប្រតិបត្តិតាមព្រះ
បរមគ្រូសម្ពុទ្ធជាម្ចាស់ ក៏បានត្រាច់ទៅពីប្រទេសមួយទៅប្រទេសមួយ ពី
នគរមួយទៅនគរមួយ ផ្សាយនូវរស្មីព្រះធម៌នៃព្រះអង្គឲ្យភ្លឺស្វាងរុងរឿង ។

ក្នុងសម័យបច្ចុប្បន្ននេះ ពិភពលោកមានដំណើរលឿនទៅកាន់
វិនាសកម្ម ។ ការសង្ស័យនឹងសេចក្តីខ្វាចតែងគ្របសង្កត់នូវសត្វលោក
នីមួយៗ តែសេចក្តីខ្វាចនេះមិនអាចស្ងប់រម្ងាប់ទៅបាន, ហើយសន្តិភាព
នឹងអាចមានឡើងបាន ដោយសារការផ្សាយនូវលទ្ធិព្រះពុទ្ធសាសនា
ដ៏ពិតនេះ ដោយការព្យាយាមរួបរួមនូវពួកពុទ្ធសាសនិកជនទាំងគណៈ
ថេរវាទ និងគណៈមហាយាន ។ កិច្ចពិសោធន៍នេះអាត្មាភាពយល់ថា
ជាកិច្ចបង្ហាញឲ្យមនុស្សជាតិព្យាយាមធ្វើដំណើរឲ្យបានដល់សុភមង្គល
មានសភាពជាសម្ភារម្យ៉ាង, ហើយម្យ៉ាងទៀត មានបំណងឲ្យបានទៅ
ដល់ច្បាប់ដ៏វិសេស ដែលនាំមនុស្សឲ្យរួចចាកទុក្ខទាំងពួង ។

អាត្មាភាពមានចិត្តសោមនស្សពន់ពេក ដោយអាត្មាភាពយល់ថា
យើងជាសមាជិកគណៈអមរបុរៈ បានដឹងជាក់ថា ពុទ្ធិកសមាគមពិភព-

លោក ដែលស្ថាបនាឡើងកាលពីពីរឆ្នាំមុន នៅមហាវិហារព្រះចន្ទមង្គៃ នៅទីក្រុងកន្ឌី ក្នុងកោះស៊ីឡង់ (លង្កា) មុខជានឹងបានសម្រេចទៅតាមវត្ថុបំណងដ៏ខ្ពង់ខ្ពស់ដែលបានតំរិតទុកមក ។ ដល់យើងដឹងថាសន្និសិទទីពីរនៃសមាគមនេះ ស្ថាបនានៅប្រទេសជប៉ុនជាអធិបតីប្រទេសមិនមែនជាមានសភាពល្បីល្បាញ នៅឆ្ងាយទីបណាស់ណាក៏ដោយ យើងក៏បានព្រមព្រៀងតែងតាំងបណ្ឌិត រលៈភេទរៈសូមា លោកៈទិស្សៈនាយកថេរៈថៅអធិការបរិវេណមហាសេត្យៈ មានឋានន្តរសក្តិជាអគ្គលេខាធិការនឹងនាយកថេរសភា នៃគណៈពុទ្ធសាសនារបស់យើង ជានាយកគណៈប្រតិភូយើងហើយជាមគ្គុទ្ទេសខាងផ្លូវ នៃគណៈប្រតិភូប្រទេសស៊ីឡង់ ។ អាត្មាភាពយល់ថា ព្រះតិកុអង្គនេះ មុខជានឹងបំពេញការណ៍យកចិត្តគប់ប្រើង ក្នុងព្រះបរមនាមនៃគណៈពុទ្ធសាសនារបស់យើងមិនខាន ។

អាត្មាភាពសូមជាស់តឿនពួកពុទ្ធបរិស័ទថា ជាការណ៍យកចិត្តដ៏សំខាន់ដែលត្រូវជួយឧបត្ថម្ភគាំទៅវិញទៅមក ដើម្បីនឹងទ្រទ្រង់នូវពុទ្ធិកសមាគមពិភពលោក ជួយបេសាសមាគមនេះ ឲ្យបានសម្រេចតាមវត្ថុបំណងគប់ប្រើង អាត្មាភាពសូមបញ្ជាក់ថាសន្និសិទនេះអាចជួយសម្រួលសម្រួលឲ្យបានសេចក្តីសុខ ព្រមទាំងឯកភាពក្នុងសង្គមចំពោះសាវ័កទាំងអស់តាមតែគណៈណាក៏ដោយ គណៈថេរវាទឬគណៈមហាយាន ។ នេះជាហេតុឲ្យបានផ្សាយនូវសច្ចធម៌ដ៏ពិត ហើយជាយុថ្កាមួយប្រើងសម្រាប់នឹងស្ថាបនានូវសន្តិភាពលោកនឹងសុភមង្គលមនុស្សជាតិ តទៅអនាគត ។

សកម្មភាព នៃពុទ្ធសាសនបណ្ឌិត្យ ទឹងសាលាបាលីជាន់ខ្ពស់

លោក ចាប - ពិន ថ្លែងដាក់វិទ្យុប្រទេសកម្ពុជា ពីថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ១៩៥២

ផ្សាយចេញពីពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

មន្ទីរពុទ្ធសាសនបណ្ឌិត្យ ទឹងសាលាបាលីជាន់ខ្ពស់ ជាវិជ្ជាហានរបស់ប្រទេសកម្ពុជា ឋិតនៅចំកណ្តាលព្រះរាជធានីភ្នំពេញ សម្រាប់ឧបត្ថម្ភការសិក្សាវិជ្ជាខាងសាសនានិងអក្សរសាស្ត្រ ។

តាំងពីជាង ២០ ឆ្នាំមកហើយ ដែលព្រះរាជរដ្ឋាភិបាលបានបង្កើតពុទ្ធសាសនបណ្ឌិត្យ ទឹងសាលាបាលីជាន់ខ្ពស់នេះឡើង, វិជ្ជាហានតាំងពីរនេះបានបង្ហាត់បង្រៀន ទឹងដឹកនាំបណ្តាជនជាតិខ្មែរតាំងគ្រហស្ថចាំឯបព្វជិតឲ្យដើរទៅកាន់អារ្យធម៌ដ៏ប្រសើរខាងផ្នែកសាសនា ទឹងផ្នែកអក្សរសាស្ត្រ ចម្រើនឡើងតាមលំដាប់ ឲ្យយើងបានឃើញលទ្ធផលជាក់ស្តែង ដូចរៀបរាប់ជាគោល ។ ឥឡូវនេះ :—

មន្ទីរពុទ្ធសាសនបណ្ឌិត្យ មានការងារខាងផ្សាយព្រះពុទ្ធសាសនា ទឹងអក្សរសាស្ត្រ ដោយការរៀបរៀងតែងទឹងរៀបចំបោះពុម្ពផ្សាយនូវសៀវភៅផ្លូវលោកផ្លូវធម៌ផ្សេង ។ ច្រើនមុខ ជាវិជ្ជាអក្សរសាស្ត្រ, សិល្បៈ, បុរាណវត្ថុ, ពុទ្ធប្រវត្តិ, កូមិសាស្ត្រ, សាសនប្រវត្តិជាដើម; ខាងព្រះពុទ្ធសាសនាមានសៀវភៅព្រះវិន័យបិដកជាដើម ដែលប្រជុំចុះនូវឫសគល់នៃព្រះពុទ្ធវចនៈសព្វគ្រប់សម្រាប់ឲ្យពុទ្ធបរិស័ទប្រតិបត្តិតាម, ខាង

អក្សរសាស្ត្រខ្មែរ មានសៀវភៅវចនានុក្រមខ្មែរជាដើម ដែលប្រដុំចុះនូវ
ពាក្យសំដីខ្មែរយើងទាំងមូល សម្រាប់ឲ្យប្រជាជនសរសេរអក្សរខ្មែរជាក់
ពាក្យត្រឹមត្រូវ ព្រមទាំងបានផ្សាយទស្សនាវដ្តី ១ ហៅថា "កម្ពុជសុរិយា"
ចេញរៀងរាល់ខែរាល់ឆ្នាំ ។

តាំងពីកើតវិជ្ជាហានពុទ្ធសាសនបណ្ឌិត្យនេះឡើង ប្រជាជនទាំង
គ្រហស្ថ ទាំងបព្វជិតតែងចេញ-ចូលសិក្សា សាកសួរ ពិគ្រោះរិះរក
ក្បួនច្បាប់ក្នុងមន្ទីរនេះជាហូរហែរាល់ថ្ងៃធ្វើការ ។ អាស្រ័យហេតុនេះ
បានជានៅប្រទេសខ្មែរយើងសព្វថ្ងៃ មានបព្វជិតនឹងគ្រហស្ថចេះក្បួន
ច្បាប់ធម៌វិន័យព្រះពុទ្ធសាសនាជាំងការខុសត្រូវកាន់តែច្រើនឡើង។ ។

សាលាបាលីជាន់ខ្ពស់ មានការៈទាងបង្ហាត់បង្រៀនបព្វជិតទាំងផ្លូវ
លោកផ្លូវធម៌ជាភាសាបាលី ភាសាខ្មែរ ភាសាសំស្ក្រឹត នឹងភាសាបរទេស
មានភាសាបារាំង-សៀម-លាវជាដើម ។ ទាងផ្លូវធម៌មានកម្មវិធីបង្រៀន
ធម៌វិន័យព្រះពុទ្ធសាសនានឹងប្រវត្តិពុទ្ធសាសនាជាដើម, ទាងផ្លូវលោក
មានកម្មវិធីបង្រៀនពង្សាវតារ, ប្រវត្តិសាស្ត្រ, ភូមិសាស្ត្រ, ក្បួនពុទ្ធ
នឹងវិទ្យាសាស្ត្រជាដើម ។

អាស្រ័យដោយវិជ្ជាហានពុទ្ធសាសនបណ្ឌិត្យ នឹងសាលាបាលី
ជាន់ខ្ពស់បានពង្រីកសកម្មភាព គឺបង្ហាត់បង្រៀនទាំងផ្លូវពុទ្ធសាសនា ទាំង
ផ្លូវអក្សរសាស្ត្រខ្មែរនេះហើយ បានជានៅប្រទេសខ្មែរយើងសព្វថ្ងៃ សូម្បី

ស្រុកចុងគាត់មាត់ញ្ជាកកំមានអ្នកចេះដឹងខាងភាសាបាលី, ភាសាខ្មែរ នឹងសម្បូណាអ្នកចេះសរសេរអក្សរខ្មែរជាក់ពាក្យត្រឹមត្រូវខ្ជួរខ្ជៅតាំងប្រទេស ។

សាលាបាលីជាន់ខ្ពស់ នៅចំកណ្តាលក្រុងកុំពេញ ជាគោលរបស់សាលាបាលីរងតាំងក្នុងក្រុង តាំងពីខែត្រក្រៅ ដែលខ្វះចំនួនច្រើនឡើង។ ពាសពេញប្រទេសកម្ពុជា តាំងជាគោលសាលាធម្មវិន័យគ្រប់វត្តមេគណអនុគណក្នុងប្រទេស ដោយគណៈកម្មការរៀបរៀងនឹងរៀបចំបោះពុម្ពសៀវភៅបែបរៀនផ្សេង ។ ផ្សាយទៅឲ្យរៀន, ឯចំនួនសាលានឹងកម្មវិធីប៉ង្រៀនក្នុងសាលាតាំងនោះក៏ចេះតែបង្កើនឡើងជាជាបៗ ដើម្បីតម្រូវតាមបច្ចុប្បន្នកាល ។ ក្នុងមួយឆ្នាំ ។ មានបព្វជិតជានិស្សិតច្រើនរូបបានប្រឡងជាប់សញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់, សាលាបាលីរងនឹងសាលាធម្មវិន័យ ។ បណ្តានិស្សិតមានសញ្ញាប័ត្រតាំងនេះ, និស្សិតច្រើនរូបបាននៅជាគេចបព្វជិត ធ្វើជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ខ្លះ, សាលាបាលីរងខ្លះ នឹងសាលាធម្មវិន័យនានា ក្នុងកម្ពុជរដ្ឋតាំងមួល, និស្សិតច្រើនរូបទៀតដែលចាកសិក្ខាបទទៅជាគ្រហស្ថបានធ្វើការរកជការក្នុងក្រសួងនានាក៏មាន, ឬបានប្រកបការរបរចិញ្ចឹមជីវិត មានកសិកម្ម ពាណិជ្ជកម្មជាដើមក៏មាន ។ ចំណែកនិស្សិតជាបព្វជិតដែលបានធ្វើជាគ្រូឬអាចារ្យក៏ខំបង្ហាត់បង្រៀនប្រជាជនជាតិខ្មែរ ខ្ជួរខ្ជៅតាំងប្រទេសតាមរបៀបដែលបានរៀនមកនោះ ឲ្យបានចេះធម្មវិន័យព្រះពុទ្ធសាសនានឹងអក្សរសាស្ត្រខ្មែរ តទៅទៀត ។

ព្រោះតែមានអ្នកចេះដឹងខាងសាសនា នឹងអក្សរសាស្ត្រជាច្រើន ដូចពណ៌នាមកនេះហើយ ចានជាសត្វថ្លៃយើងឃើញកើតមានសៀវភៅផ្សេងៗលោកផ្សេងមិ ចោះពុម្ពជាអក្សរខ្មែរដាក់ជាវោសតេញប្រទេសយើងមិនទន់ខ្សោយជាងសៀវភៅភាសាដទៃដូចពីមុនទេ ដែលជាហេតុឲ្យសំគាល់បានថា ជនជាតិខ្មែរមិនខ្វះបណ្ឌិតអ្នកនិពន្ធទេសព្វថ្ងៃនេះ ។

ម្យ៉ាងទៀត ចំណែកបព្វជិតដែលកាលពីដើម ច្រើនតែចេញទៅសិក្សាភាសាបាលីព្រះត្រៃបិដកនៅប្រទេសគ្រៃ ឬទិញសៀវភៅបែបសិក្សាភាសាបាលីនឹងធម៌វិន័យផ្សេង ។ ពីប្រទេសគ្រៃមានប្រទេសថៃជាដើមមករៀននោះ ឥឡូវនេះមិនបាច់ទៅរៀនទៅទិញពីគេដូចមុនទៀតទេ ព្រោះវិជ្ជានឹងគ្រឿងប្រដាប់សម្រាប់សិក្សាវិជ្ជាទាំងនោះមានគ្រប់គ្រាន់ក្នុងប្រទេសយើងល្មមសិក្សាហើយ ឥតខ្វះកន្លះទេ ។

ដោយការចំប្រឹងរកតសកម្មភាពនៃពុទ្ធសាសនបណ្ឌិត្យ នឹងសាលាបាលីជាន់ខ្ពស់ គឺចំរើនរុងរឿងតាមរៀនធម៌វិន័យច្បាប់ព្រះពុទ្ធសាសនាយ៉ាងម៉ឺងម៉ាត់ ដូចពណ៌នាមកនេះហើយ ចានជាព្រះសង្ឃដែលជាស្រែបុណ្យរបស់ប្រជាជននៅប្រទេសយើងសព្វថ្ងៃ ចានយល់ច្បាស់នូវធម៌វិន័យល្អត្រឹមត្រូវដឹងការខុសត្រូវច្រើនរូបគ្រប់គ្រងវត្តដែលជាការនាំឲ្យអធិករណ៍ (ការពាស់ទែង) រវាងព្រះសង្ឃនៅប្រទេសយើងស្ងៀមស្ងប់ ថយតិចចុះជាងសម័យមុនៗ ។

ដោយហេតុប្រទេសខ្មែរយើង ជាប្រទេសកាន់ព្រះពុទ្ធសាសនាមុតមាំ, មានការសិក្សាវិជ្ជាចេះដឹងខាងព្រះពុទ្ធសាសនាជ្រៅជ្រះពាំងបពូជតពាំងគ្រហស្ថនេះហើយបានជាកាលពីពុទ្ធសករាជ ២៤៩៣ គ្រិស្តសករាជ ១៩៥០ ប្រទេសខ្មែរយើងបានចូលទៅជាសមាជិកនៃពុទ្ធិកសមាគមពិភពលោក នៅលង្កាទ្វីប ដែលសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ បានទិមន្តជាប្រធានគណៈប្រតិភូខ្មែរ ទៅប្រជុំកសន្និសិទព្រះពុទ្ធសាសនានៅប្រទេសលង្កាជាលើកដំបូង ជាមួយនឹងគណៈប្រតិភូប្រទេសនានា ចំនួន ២៩ ប្រទេស គិតពាំងប្រទេសកម្ពុជាយើងផង ។ ឥឡូវនេះប្រទេសកម្ពុជាយើងបានបង្កើតពុទ្ធិកសមាគមពិភពលោកមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ សម្រាប់ធ្វើការទាក់ទងខាងផ្លូវព្រះពុទ្ធសាសនាជាមួយនឹងពុទ្ធិកសមាគមពិភពលោកនេះហើយ ជាហេតុនាំឲ្យពិភពលោកបានស្គាល់ប្រទេសយើងកាន់តែច្បាស់ឡើង ។

នេះហើយជាផលដែលមានដើមកំណើតដុះដាលមកអំពីវិជ្ជាហានពុទ្ធសាសនបណ្ឌិត្យ នឹងសាលាបាលីជាន់ខ្ពស់ ដែលជាដួងប្រទីបដ៏ធំមួយជួយឆ្លុះបំភ្លឺប្រជាជនខ្មែរឲ្យរុងរឿងដើរទាន់សម័យនឹងគេបាន ។

សេចក្តីបរិយាយអំពីសកម្មភាពនៃវិជ្ជាហានពុទ្ធសាសនបណ្ឌិត្យ នឹងសាលាបាលីជាន់ខ្ពស់អស់ត្រឹមប៉ុណ្ណេះ ។

តទៅថ្ងៃខាងមុខ យើងនឹងមកបរិយាយ អំពីសកម្មភាពនៃវិជ្ជាហានពាំងនោះជាផ្នែក ។ ដូនលោកអ្នកតទៅទៀត ។

បញ្ជីភ្ជាប់នាមចៅអធិការដែលតាំងថ្មី

របស់គ្រែសួង៩ធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៨៣០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូសុំប-
សួន នាមធាយា សុវណ្ណត្នេរ កើតឆ្នាំកុរ អាយុ២៧វស្សា ៧ជាគ្រូសូត្រ
ធ្វើវត្ត-ឃុំ ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៣១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ឡាយ-ខួន នាមធាយា ធម្មសុវណ្ណ កើតឆ្នាំមមែ អាយុ៥៥វស្សា ៣៥
ជាចៅអធិការវត្តចំរេះ ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៣២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
មួង-មិត្ត នាមធាយា ធម្មជោត កើតឆ្នាំមមែ អាយុ ៣១វស្សា ១១ ជាគ្រូ
សូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៣៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
អ៊ាង-យាង នាមធាយា ឥន្ទជោត កើតឆ្នាំជូត អាយុ ២៦វស្សា ៦ ជា
គ្រូសូត្រធ្វើ វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៣៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
សម-ម៉ែន នាមធាយា និលជោត កើតឆ្នាំកេង អាយុ ៥៨វស្សា ៣៨ ជា
ចៅអធិការវត្តបន្ទាយក្រៅក ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៣៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុក-យស់ នាមធាយា ព្រហ្មសុវ័ណ្ណ កើតឆ្នាំរោង អាយុ ៤៦ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៣៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ច័ន្ទ-កោះ នាមធាយា ចន្ទជោត កើតឆ្នាំវក អាយុ ៤១ វស្សា ២១ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៣៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជ្រាក់-ឃុត នាមធាយា ឥន្ទបញ្ញា កើតឆ្នាំមមែ អាយុ ៤៣ វស្សា ២២ ជាគ្រូសូត្រស្តាំ វត្តក្ងាន ឃុំតាស្នុក ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៣៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឯក-ប៊ុត នាមធាយា ឥន្ទត្ថេរ កើតឆ្នាំមម្សាញ់ អាយុ ៣៣ វស្សា ១៣ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៣៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស៊ី-ឃ្លោក នាមធាយា ព្រហ្មត្ថេរ កើតឆ្នាំវក អាយុ ៦៦ វស្សា ៤៦ ជាចៅអធិការវត្តពោធិ៍កណ្តាលវាល ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៤០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចិក-ព្រំ នាមធាយា ធម្មបញ្ញាតរី កើតឆ្នាំខាល អាយុ ៦០ វស្សា ៤០ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៤១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្រី-ពិន នាមធាយា ជោតត្នោះ កើតឆ្នាំរោង អាយុ ៤៦ វស្សា ២៥ ជាគ្រូសូត្រធ្វើ វត្ត-ឃុំ ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៤២ ចុះថ្ងៃអង្គារ ១ កើតខែបុស្ស ឆ្នាំច្រូវឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ ប៉ុល-ពៅ នាមធាយា សុវណ្ណត្នោះ កើតឆ្នាំមមី អាយុ ៤៤ វស្សា ២៤ ជាចៅអធិការវត្តអង្គរុណ ឃុំត្រពាំងគ្រសាំង ស្រុកជាអី ខែត្រតាកែវ ។

សញ្ញាប័ត្រលេខ ៨៤៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហ៊ុល-ដេត នាមធាយា កេសវេនត្នោះ កើតឆ្នាំមមី អាយុ ៤៤ វស្សា ២៤ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៤៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស៊ុន-កួង នាមធាយា សុបញ្ញា កើតឆ្នាំរោង អាយុ ៣៤ វស្សា ១០ ជាគ្រូសូត្រធ្វើ វត្ត-ឃុំ ស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៤៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គីង-ធោម នាមធាយាឥន្ទត្នោះ កើតឆ្នាំវក អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តខ្ទារ-ឃុំខ្ទារ ស្រុកជ្រាកាន ខែត្រពោធិសាត់ ។

សញ្ញាប័ត្រលេខ ៨៤៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កិម-មាំ នាមធាយា ព្រហ្មត្នោះ កើតឆ្នាំមមី អាយុ ៣២ វស្សា ៨ ជាគ្រូសូត្រធ្វើវត្ត-ឃុំ ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៤៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុម-សម នាមឆាយា ធម្មជោត កើតឆ្នាំកុរ អាយុ ៣៩ វស្សា ១៨ ជាចៅអធិការ វត្តចំបក់មាស ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៤៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សយ-សម នាមឆាយា ធម្មជោត កើតឆ្នាំម្សាញ់ អាយុ ៣៣ វស្សា ១៣ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៤៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គុប-ឌិត នាមឆាយា ធម្មត្តេរ កើតឆ្នាំខាល អាយុ ២៤ វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៥០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អឿ-ហម នាមឆាយា ធម្មស្សរ៉ែន កើតឆ្នាំរកា អាយុ ២៨ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តភូមិអូរ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៥១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឌុម-សែស នាមឆាយា ឥន្ទ្រត្តេរ កើតឆ្នាំវក អាយុ ៥៤ វស្សា ៣៣ ជាចៅអធិការ វត្តបឹងពិតត្រង់ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៥២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ោ-អ៊ី នាមឆាយា ចន្ទសារោ កើតឆ្នាំឆ្លូវ អាយុ ៤៩ វស្សា ១៨ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

(មានត)

ព្រឹត្តិសាស្ត្រ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៥ ខែកុម្ភៈ លេខ ២

ព. ស. ២៤៩៥ — គ. ស. ១៩៥៣



ភ្នំពេញសន្ទនា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— ព្រះពុទ្ធសាសនានៅប្រទេសឥណ្ឌា (តចប់)	លោក វ៉ាយ - ប៊ុក	៨៣
— ប្រភេទសាសនកថា	ព្រះមហា ទេព - ថោ	៩០
— រឿងកុណ្ឌលកេសីថេរី (តចប់)	ព្រះមហាសុខុមាលី - សេន ...	៩៩
ផ្នែកអក្សរសាស្ត្រ		
— ការបណ្តុះនិស្ស័យ (តមក)	ព្រះមហោទត្តមវិង្សា ប៊ុង - ប៉ម ...	១១៣
— រឿងសាមកុក (តមក)	ឧកញ៉ា ឆូ - កន	១១៨
— រឿងអាវ៉ក្សថ្លែងរឿងម្តែប្រាំ (តមក) ...	លោក វ៉ាយ - ប៊ុក	១២៣
— រឿងស្នាប់ព្រោះជាតិ (តមក)	លោក គង់ — លឹម	១៣០
— រឿងប៉ូលនិងវីរ៉ស៊ីនី (តមក)	លោក ផេង - ជ្រឿ	១៣៦
— សកម្មភាពនៃក្រុមដំនុំទំនៀមទម្លាប់ស្រុកខ្មែរ	ពុទ្ធសាសនបណ្ឌិត្យ	១៤១
កំណាត់ធឹងប្រវត្តិការណ៍		
— សន្និសិទព្រះពោធិវង្ស ហួត - ឆាត អំពី សមាជសាកលលើកទី ២ នៃពុទ្ធសាសនា.	ពុទ្ធសាសនបណ្ឌិត្យ	១៤៨
— សុន្ទរកថាបណ្ឌិតម៉ាល៉ាឡះសេកេរៈថ្លែងក្នុង សមាជសាកលលើកទី ២ នៃពុទ្ធសាសនា	ពុទ្ធសាសនបណ្ឌិត្យ.	១៥៣
— បញ្ជីរាយនាមថៅអធិការនៃសាំងថ្មី (តមក)	ក្រសួងធម្មការ	១៥៩

មួយឆ្នាំមាន ១២ លេខ — ដំឡៃដារ ១៩២រ. ០១

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE		Pages
— Le Bouddhisme en Chine (suite et fin)	*M. Ray-Buc*	83
— Sasanakatha	*Brah Maha Tep-Po*	90
— Histoire de Neang "KUNDALA-KESITHERI" (suite et fin)	*Preah Maha SUKHUMALI-SEN*	99

PARTIE LITTERAIRE		
— Education morale (suite)	*Vén. Pœung-Pam*	113
— Histoire de SAMÒK (suite)	*Oknha Nou-Kan*	118
— Les vingt cinq récits du Mauvais Génie (suite)	*M. Ray-Buc*	123
— Mort pour la patrie (suite)	*M. Kong-Lim*	130
— Paul et virginie (suite)	*M. Phéng-Chrieu*	136
— L'activité de la commission des Mœurs et Coutumes	*institut Bouddhique*	141

NOTES ET CHRONIQUES		
— Conférence du Vén. Brah Bodhivangs BUOT-TATH sur le 2e Congrès Mondial Bouddhique	*Institut Bouddhique*	148
— Discours du Dr MALALASEKERA au 2e Congrès Mondial Bouddhique	— —	153
— Nomination des nouveaux Chau-adhikar (suite)	*Ministère des Cultes*	159

Prix d'abonnement annuel (comprenant 12 numéros): 1928°00

ពី)- ប្រទេសចិនតាំងពីលទ្ធិឡាម៉ាចូលមកស្ថិតនៅរហូតមកដល់សព្វថ្ងៃនេះ

ក)- សន្តតិវង្សមុង្គោល "យ៉ែន" ដល់ចុងសតវត្សទី ១៤, ព្រះអធិរាជនៃប្រទេសចិនបានអញ្ជើញព្រះបាទសង់ស៊ីស្ខាន់ នាយពួកមុង្គោលខាងលិច ឲ្យមកជួយធ្វើសង្គ្រាមទឹងពួកមុង្គោលខាងកើត ។ តែព្រះបាទសង់ស៊ីស្ខាន់ ទៅជាទ្រង់ក៏យកប្រទេសចិនទាំងមូលវិញ ហើយបានឥតកម្មកាព ក្នុងវិសាលភាព ៨០០ យោជន៍ ពីខាងកើតទៅខាងលិច ហើយ ១០០០ យោជន៍ ពីខាងជើងទៅខាងត្បូង ។

រជ្ជកិបាលមុង្គោល បានស្ថាបនាទូវកល្បយុគចំពោះទៅលើសិទ្ធិត្រួតត្រាដែលគេហៅថា មជ្ឈមយុគនៃប្រទេសចិន ។ ពួកមុង្គោលជាអ្នកកាន់ព្រះពុទ្ធសាសនាពីមុនមក ស្រាប់ ដល់បានចូលមកស្ថិតនៅប្រទេសចិន កំតាំងផ្សាយព្រះពុទ្ធសាសនាគ្រប់ទិគម, ជនបទ, ស្រុក, ខេត្ត ។

នៅក្នុងរជ្ជកាលព្រះចៅគូប៊ីលៃខ័ន ជាព្រះរដ្ឋាយោធ តាំងពីព្រះបាទសង់ស៊ីស្ខាន់ ទ្រង់បានស្ថាបនាទូវសន្តតិវង្សមុង្គោល "យ៉ែន"

ព្រះវិហារព្រះអធិរាជដែលសាងសម្រាប់ជូនប្រជាជាតិ ទៅជាសម្រាប់ធ្វើព្រះរាជពិធីខាងព្រះពុទ្ធសាសនា ។

ព្រះបាទគូប៊ីលៃខាន ទ្រង់មិនបានចាត់ការទំនាក់ទំនងទៅវាយប្រទេសជប៉ុន ដោយទ្រង់ព្រះតម្រិះថា ប្រទេសជប៉ុនជាប្រទេសកាន់ព្រះពុទ្ធសាសនា ។ ទ្រង់មានព្រះរាជបំណងនឹងយកប្រទេសនេះដោយសន្តិវិធី ហើយទ្រង់បានធ្វើព្រះរាជបុតហ្មាយទៅព្រះមហាក្សត្រនៃប្រទេសជប៉ុនថា: "ពួកសន្តបុគ្គលដែលយើងគោរពពោលថា: មនុស្សទាំងអស់ជាបងប្អូនសាច់ឈាមជាមួយ ហើយថាពិភពលោកគឺជាគ្រួសារតែមួយ: គ្រប់តែប្រជាជនទាំងអស់មានធម៌សាមគ្គី ក្នុងប្រយោជន៍ច្បាប់ល្អមានប្រយោជន៍" ។

ដល់ចុងវស្សាដែលទ្រង់សោយរាជ្យ, ទ្រង់បានចាត់ឲ្យគេធ្វើបញ្ជីចំរើនវត្តនឹងចំនួនព្រះសង្ឃ : ឃើញវត្តមានចំនួន ៤៦.៨១៨ វត្ត, ព្រះសង្ឃមាន ២១៣.១៤៨ អង្គ ។

នៅក្នុងរជ្ជកាលព្រះបាទសង់ស៊ីស្ពាន់ព្រះពុទ្ធរូបធំបំផុត លំដាប់ពីការពេញព្រះទ័យចំពោះប្រាក់ទឹងស្តើ គឺការអនុគ្រោះជាទូទៅក្រឹដ្ឋន្តូវពួកពុទ្ធសាសនិកជន មានការទុបត្ថម្ភពួកឡាម៉ាដោយ ។

ពួកសន្តតិវង្ស "យ៉ែន" មានព្រះរាជបំណងបង្កើតនូវ "អធិប្រទេសនៃពិភពលោក" ប៉ុន្តែទ្រង់មានព្រះទ័យសន្តោស មិនត្រឹមតែ

ព្រះពុទ្ធសាសនា ថែមទាំងទ្រទ្រង់នូវគ្រិស្តសាសនា, ប្រពៃណីនៃប្រ-
ទេសដែលស្ថិតនៅក្នុងអនិស្សរភាពនឹងលទ្ធិឯទៀត។ ហេតុដល់ទៀ្យល័យ
មហាម័តចំពោះពួកគុរុគោដលិច ។ ព្រះសន្តតិវង្សនេះ ជាមេនយោបាយ
យ៉ាងឯក ។

តែសង្គ្រាមពលរដ្ឋ ដោយការតស៊ូនឹងព្រះសង្ឃខាងព្រះពុទ្ធសាសនា
នឹងបណ្ឌិតខាងកុង-ហ្វុង-ស៊ី នាំឲ្យសន្តតិវង្សមុង្គោល ទៅជាថយ
តេជានុភាព ហើយនាំឲ្យវិនាសសាបសូន្យនៅ គ. ស. ១៣៦៨ ។

លំដាប់តមក, នៅសន្តតិវង្ស "មីង" ព្រះអធិរាជទុបតម្ពក្តពួក
"បណ្ឌិត" ហើយស្ថាបនា នូវគណៈសង្ឃមួយហៅថា: "គណៈ
វ៉ូ-វៃ គីយ៉ាវ" ។ គណៈនេះប្រែថា: "គណៈអកម្មភាព" ដែលវចនា
ពីព្រះពុទ្ធសាសនា ជនកបុរសគឺជនជាតិចិនម្នាក់នាមថា: "លូ-ត្សឺ ប្ក
តាបស" "លូ" កើតនៅខេត្តស័ងទុង ។ លោកបានយកទៅថ្វាយ
ព្រះអធិរាជនៃសន្តតិវង្ស "មីង" នឹង "ចង", នូវគម្ពីរប្រាំដែល
ពណ៌នាពីវត្ត ៦ យ៉ាងគឺ:

១ - ញ្ញាយាមឲ្យផុតចាកតណ្ហា

២ - ទូញសោកចំពោះពិភពលោក

៣ - បំបាត់នូវការគាន់ប្រឡំ

៤ - រចនាចិត្តទៅកាន់ធម៌ពិត

៥ - ធ្វើឲ្យដូចក្តុំតែចាំ (សៀវភៅបញ្ជាក់ពីធម៌ផ្សេង។)

៦ - ច្រាជ្រាធម្មជាតិធ្វើឲ្យបរិសុទ្ធស្អាតឲ្យដល់សុខ្ដិភាព ។

ខ) - នៅសន្ដតិវង្ស "ម៉ានជូ", ព្រះអធិរាជ "ស្ហុនជឺ" បានបដ្ឋម្ភព្រះពុទ្ធសាសនា តែព្រះរដ្ឋាយោគខាងគឺ - កុងសោយពាជ្យពី គ.ស. ១.៦៦២ ទៅដល់ ១.៧២២ ទ្រង់បានទំនុកបំរុងតែពួក "បណ្ឌិត" ខាងកុង-ហ្វុង-សឺ ។

ដល់មក គ.ស. ១៨៤៨, មានការបះបោរពួក "តៃពិងថ្ង" "សកវែង" ។ ពួកនេះស្អប់ព្រះពុទ្ធសាសនា ហើយបង្កើតជាសង្គ្រាមពលរដ្ឋជាអធិកអធ័ម, ពិឃាដលោកសង្ឃជាច្រើន តែមិនធ្វើការុណកម្មចំពោះពួកគ្រិស្ដសាសនិកជន ។

ពួកតៃពិងនេះបដិសន្ធិនៅខេត្ដក្វាង-ស៊ី នៅខន្ទេកខ្លាំង, បានចូលទៅលុកលុយខេត្ដឯទៀតខាងត្បូង ហើយបានឆាំកងទ័ពទៅដល់ទីក្រុងជៀង - ស៊ីន ។ ក្នុងមួយឆ្នាំៗ ឥទ្ធិពលពួកតៃពិងកាន់តែខ្លាំងឡើង ហើយចូលទៅលុកលុយខេត្ដឯទៀតជាច្រើនតទៅទៀត, តែចុងក្រោយមានសង្គ្រាមជាកំដរអង់គ្លេសនឹងចិន ពួកតៃពិងក៏ផុតអានុភាព ក្នុងពេលនោះ (គ. ស. ១៨៦២) ។

៨ - ស្ថានភាពបច្ចុប្បន្ននៃព្រះពុទ្ធសាសនា នៅប្រទេសបិន

នៅប្រទេសចិនសព្វថ្ងៃ មានប្រជាពស្ត្រដោយកាគន្ធ្រែនកាន់ព្រះពុទ្ធសាសនា តែវត្តអារាម, ព្រះវិហារ ឬជនិយដ្ឋានទាំងប៉ុន្មានសាងតាំងពីបុរាណកាលមានខ្លះចាក់បែក, បណ្តាប្រជាពស្ត្រដែលជាពុទ្ធសាសនិកជនច្រើនតែស្ត្រី ។

ព្រះពុទ្ធសាសនាសព្វថ្ងៃក្លាយទៅជាលទ្ធិមួយបែបថ្មី គឺព្រហ្មវិហារវចនាទៅជារូបនិមិត្តមេត្តា, ករុណាត្រឡប់ទៅជាមានរូបនិមិត្តដែរ ដូចជារូប "ក្វាន-យីន" ។ នៅសន្តតិវង្សសុង រូប "ក្វាន-យិន" ជារូបបុរស តែប្រហែល ៦០០ ឆ្នាំហើយ រូបព្រះពុទ្ធ "ក្វាន-យិន" គេបានធ្លាក់ជារូបស្ត្រីទៅវិញ គឺព្រះទេវធីតានៃមេត្តា, ករុណាទៅវិញ ។

ការស្រោចស្រង់មនុស្សដោយការសិក្សា មានសារៈសំខាន់ចំពោះព្រះពុទ្ធសាសនាប្រទេសចិន ។ ព្រះពុទ្ធរូបចិន គឺ ពូ សា, ក្វាន-យិន មានប្រតិស្ថានព្រះរូបជាសាមសិបពីររូប ។ មានព្រះពុទ្ធរូបខ្លះ មានព្រះហស្ត ១២ គូ ដែលជាបដិមារូបសម្រាប់ដឹកនាំពួកលង្ឃ ទឹងពួកប្រព្រឹត្តបាបអកុសល ។ ព្រះរូបទាំងសាមសិបពីរនេះ អាចយាងទៅកាន់ព្រះពុទ្ធអាណាចក្រផ្សេង ។ ដើម្បីទឹងសំដែងធម្មទេសនាចំពោះមនុស្សសត្វទៅស្ថានសួគ៌, ស្ថានកាមភព, រូបភព, អរូបភព ។ ស្រេចតែមេត្តា

នៃព្រះរូបសាមសិបពីរនេះ អាចរចនាព្រះមហាកឫត្រ, ចៅហ្វាយខេត្ត, មន្ត្រី, ប្រជាពលរដ្ឋ, ឲ្យបានចរិយាល្អ ហើយមានវិធីស្រោចស្រង់ជាច្រើនបែប យ៉ាង មានអានុភាពទៅជួយអ្នកដទៃបាន, ដោយសុត្តធម៌ព្រមទាំងធ្វើសមាធិ, ការពារនូវគ្រោះកាចបានច្រើនបែប, អាយុវែង, ព្រះនិព្វាន ។

បើតាមពណ៌នាខាងលើ, ព្រះពុទ្ធ "ក្វាន យិន" គឺមានអានុភាពជាងព្រះពុទ្ធទាំងអស់ ព្រះពុទ្ធ ពូ ហៀន, មិនដូច្នេះ ។ ការវែលធ្វើរូបព្រះពុទ្ធ "ក្វាន-យិន" ជារូបស្ត្រីមកពីគំនិតប្រជាមានិត ។

ព្រះពុទ្ធ ពុស្យិន ទឹង វេង ស៊ូ គេធ្លាក់ព្រះរូបជាព្រះពុទ្ធពីបុពណសម្រាប់ជួយព្រះសក្យមុនីពុទ្ធ ។

ព្រះពុទ្ធ វេង-ស៊ូ ព្រះអាទិទេពខាងគតិបណ្ឌិត ចានយកសង្ឃជាបដិមារូបខាងពលភាព ជាព្រះពជយាន, ព្រះពុទ្ធ ពូ-ហៀន, ព្រះអាទិទេពនៃសកម្មភាព ចានយកជំរី ជាបដិមារូបខាងអប្បមាទ, មិនផ្ទេសច្រវៃហេស ។

ព្រះពុទ្ធសាសនាទៅប្រទេសចិន គឺយកគុណធម៌ធឹងមកជាបដិមារូប ហើយរចនាទៅជាព្រះពុទ្ធរូបឲ្យគេគោរព; ចំពោះការហែសព មានពិធីព្រះពុទ្ធសាសនាលាយឡំជាមួយផង, ផ្សាយនូវមេត្តាចំពោះសត្វតិរច្ឆាន, មេត្តាចំពោះមនុស្សជាតិ, ល . . . ។

ចំណែកខាងព្រះសង្ឃកាន់វិន័យមិនសូវត្រឹមត្រូវទេ, មានអាស្រមយាយជីជាច្រើន តែយាយជីទាំងនេះ មិនមានវិន័យរឹងប៉ឹង ចូលចេញដើរលេងតាមអំពើចិត្ត ។

មានពួកឫសីនៅប្រែបវត្តអាភមប្តូរបូជនីយដ្ឋាន; មានខ្លះនៅក្នុងគុហាកំប្តៅនៅក្នុងអាស្រមមួយ ។

គេមានឃើញនៅប្រទេសចិន ពួកឡាម៉ាលឿងខាងក្រមកែទម្រង់ត្បូង-កប: ហើយនឹងពួកឡាម៉ាប្រងេះខាងក្រមបុពណមិនសូវជ្រះថ្លា, កាន់វិន័យមិនសូវតឹងរឹង ហើយចូលទៅរួបរួមជាមួយព្រះសង្ឃ ‹ ហ្គូអីស្ត” ដែលទើបនិមន្តជាបឋមមកកាន់ប្រទេសចិន, មុនសន្តតិវង្សមុង្គោល ។

ប្រកេនសាសនកថា

ព្រះមហា ទេព - ប៉ោ វត្តកែវព្រះភ្លើង ក្រុងភ្នំពេញ

ទេសនាជាកិរិយោសនសព្វនៃប្រទេសកម្ពុជា ក.ស.ពីថ្ងៃ ៨ កើតខែមិគសិរ ឆ្នាំដូតសំរឹទ្ធិស័ក ព. ស. ២៤៩១ (៩ - ១២ - ៤៨)

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមថ្វាយបង្គំចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ (ព្រមទាំងព្រះធម៌នឹងព្រះអរិយសង្ឃ) ។

ឧភាសនេះ អាត្មាភាពសូមសំដែងធម្មទេសនា តាមប្រកេនសាសនាដ៏វិសេសដែលខ្ពស់ថាបជាងគ្នាជាលំដាប់ដូចតទៅនេះ:-

បណ្តាសាសនាដែលមានកង់លោក នឹងរកសាសនាណាដែលអាចបង្អុលបង្ហាញនឹងបង្ហូរទៅទឹកអម្រឹតគឺព្រះនិព្វាន ឲ្យស្រស់ស្រោចលើសន្តានចិត្តសត្វដែលកំពុងឆេះក្តៅដោយភ្លើងទុក្ខភ្លើងកិលេស ឲ្យរលត់យ៉ាងឆាប់រហ័សដូចព្រះពុទ្ធសាសនានេះគ្មានឡើយ ។ ហេតុនេះបានជាព្រះពុទ្ធសាសនា ទទួលកិត្តិយសអំពីសំណាក់អ្នកប្រាជ្ញទាំងឡាយថាជាសាសនាយ៉ាងឯកឥតគូប្រៀប ។

ព្រះបរមគ្រូជាម្ចាស់ទ្រង់ចេញចាកសក្យត្រកូលទៅទ្រង់ព្រះផ្នួសក្នុងវៃ ស្វែងរកធម៌ជាគ្រឿងរំលត់ទុក្ខដោយព្យាយាមយ៉ាងតឹងរ៉ឹង ដរាប

ដល់បានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណ លុះត្រាស់ដឹងហើយ
ទ្រង់មានព្រះទ័យពេញប្រៀបដោយព្រះមហាករុណាគុណ ទ្រង់ប្រ-
ទានធម៌ ដែលព្រះអង្គត្រាស់ដឹងនោះ ដល់ទេវតានឹងមនុស្សទាំងឡាយ
ឲ្យបានសម្រេចប្រយោជន៍ក្នុងប្រកែធម៌ទាំងបីនេះ គឺបរិយត្តិធម៌ ទ្រង់
ចង្អុលបង្ហាញព្រះត្រៃបិដកទាំងបី ១, បដិបត្តិធម៌ ទ្រង់ចង្អុលបង្ហាញ
សីល សមាធិ បញ្ញា ១, បដិវេធធម៌ ទ្រង់ចង្អុលបង្ហាញដល់ការ
ត្រាស់ដឹងនូវមគ្គនឹងផល១ ។ ព្រះបរិយត្តិធម៌ជាមគ្គនាយក នាំមុខធម៌
ទាំងពួង បើមិនរៀនបរិយត្តិជាមុនទេ មិនអាចនឹងធ្វើបដិបត្តិធម៌ឲ្យ
ពេញបរិបូណ៌បានឡើយ ។ ហេតុនេះ កុលបុត្រអ្នកមានសទ្ធា ប្តូរថ្នា
នឹងបំពេញ បដិបត្តិធម៌ឲ្យបានពេញលេញនោះ លុះតែរៀនបរិយត្តិធម៌
ឲ្យដឹងវិធីចំរើនជាមុន ហើយសឹមបំពេញបដិបត្តិធម៌ជាក្រោយ, ព្រោះ
ការរៀនបរិយត្តិធម៌ ពុកដូចជារៀនផែនទីរបស់បដិបត្តិធម៌ ឲ្យដឹងទិស
ដំបន់ នឹងជ្រុងជ្រោយនៃក្រសែធម៌ ការទំអប់រំបដិបត្តិធម៌ ឲ្យរឹងប៉ឹងល្អ
ពុកដូចជាដើរតាមផែនទី ដែលបរិយត្តិធម៌ចង្អុលប្រាប់ស្រេចហើយ, ការ
បានសម្រេចមគ្គផលជាថ្នាក់ៗពុកដូចជាដំណាក់សម្រាប់អ្នកដំណើរ ឈប់
សម្រាកក្នុងរយៈផ្លូវ, ការបានសម្រេចព្រះនិព្វាន ពុកដូចជាបានធ្វើដំណើរ
ទៅដល់ស្រុកដែលសុខសាន្តគ្មានក្តីទុក្ខ ។

ព្រះពុទ្ធបរិសេទ្យអ្នកមានបំណងចង់បំពេញបតិបត្តិធម៌ ដោយពេញបរិបូណ៌នោះ គួរស្តាប់ពាក្យរៀនលុះត្រាតែបានសម្រេចវិជ្ជា ខាងផ្លូវបរិយត្តិធម៌ជាមុន ទើបធ្វើបតិបត្តិធម៌ឲ្យដើរត្រង់ផ្លូវបាន បើមិនធ្វើដូច្នេះទេមុខជាទន្ទឹងដើរខុសផ្លូវរវើរវាយកាន់ច្រឡំ ប្រតិបត្តិពានលើខុសសោះ តែប្រកាន់ថាត្រូវ ។ ដូចមនុស្សពួកខ្លះមានជាតិជាបុថុជ្ជន នៅក្នុងអំណាចកម្មទុនកប្រមែង ដួនបានសុខដួនបានទុក្ខ ក្នុងពេលដែលបានសុខ កុំអាលប្រញាប់សរសើរថាគល់ឈើដុំថ្មឲ្យសុខនោះ ឧកាសណាដែលត្រូវបានទុក្ខវិញ ក៏កុំប្រញាប់ជាក់ខោស ទៅលើខ្មោចបិសាចពេក គួរពិចារណាឲ្យឃើញហេតុផលសិន, សំរិសួស្តីប្អូអពមង្គលមិនមែនបានមកពីគល់ឈើឬដុំថ្មនោះទេ មនុស្សដែលជឿហេតុដទៃ ហើយបដិសេធផលកម្មចោលដូច្នេះ ទន្ទឹងចាត់ថាជាអ្នកកាន់ព្រះពុទ្ធសាសនាឯណាបាន? ជនណាមួយដែលមានគំនិតជឿបែបនេះហើយ មុខជាទន្ទឹងវង្វេងវិលវិលរឹតក្នុងឆ្ងាយណាស់លោកនេះកកោះត្រើយមិនឃើញ ទន្ទឹងជួបប្រទះតែសេចក្តីអន្តរាយក្នុងវេរៈផ្លូវជានិច្ចមិនខាន ។

អ្នកដំណើរដែលទៅតាមផ្លូវ ជើងទឹកជើងគោកក្នុងលោកនេះ រមែងចួបប្រទះប៉ះពាល់ទន្ទឹងសត្រូវមានសត្វសាហាវយង់ឃ្នង ទន្ទឹងចោរកំណាចចាំស្តាត់ក្នុងទីស្ងាត់ក្បែរវេរៈផ្លូវ បៀតបៀនដណ្តើមយកធនធានឲ្យស្មុនដំណើរប្អូអន្តរាយចាំងជីវិតក៏សឹងមាន តែគេគិតប្រទិតតាក់តែង ឲ្យកើត

មានយានដ៏ខ្ពង់ខ្ពស់បវរ មានទ្វារទេះយន្តហោះជាដើម សម្រាប់ប្រើក្នុងផ្លូវទឹក ផ្លូវគោក ទឹងផ្លូវអាកាស ឲ្យលឿនទៅដោយកំលាំងយន្តចក្រនោះ ឲ្យស្ទុះរំលងចាកសេចក្តីអន្តរាយក្នុងផ្លូវ ទៅដល់ទីដែលគេប៉ុនប៉ងដោយសួស្តីបាន យ៉ាងណាមិញ; សត្តនិករទាំងឡាយដែលចរឆ្លាត់កងវដ្តសង្សារ ហើយតើបពះប្រទេះបួនទឹងសត្វគឺកិលេសទាំងឡាយមានតណ្ហា (ចំណង់) មាន: (សេចក្តីប្រកាន់) ទិដ្ឋិ (សេចក្តីឃើញខុស) ជាដើម ចាំកាងកស្កាត់ដំណើរចិត្តរបស់សត្វ ឲ្យទាក់ទាមយឺតយូរដំណើរ មិនឲ្យសម្រេចព្រះនិព្វានឆាប់រហ័សបាន រវល់តែនឹងកើត ចាស់ ឈឺ ស្លាប់ ស្លាប់កើត កើតស្លាប់ វិលចុះវិលឡើង ជួនជាមនុស្ស ជួនជាសត្វមិនឈឺងាត់ច្បាកដ ខ្លួលសោយសុខតិច ទុក្ខច្រើនជានិច្ច ជានិន្នរីរកំនេរគ្មាន តែងងឹតងងុល វិលវល់ វៃលបេងច្វាងកងសមុទ្រប្លឹមចុះប្លឹមឡើង រកគោះត្រើយមិនឃើញ ។

ព្រះបរមសាស្តាជាមហាអ្នកច្បាជ្រយ៉ាងឆ្នើម ទាងផ្លូវសាសនាបានទ្រង់ទំប្រឹងរិះគិតពាក្យធម៌ល្អនឹងអាក្រក់ ដកឲដល់បានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ហើយទ្រង់តែងតាំងធម្មយាន ជាយានយ៉ាងឯកក្នុងផ្លូវធម៌ឡើង ជាយានសម្រាប់ស្រង់ផ្តុកនាំ ចំឡងសត្វទាំងឡាយ ដែលកំពុងលិចលង់ផុងវង្វេងក្នុងមហាសមុទ្រ គឺវដ្តសង្សារដែលជាទី មានគ្រែតើតូមមកពាំនូវ គឺកិលេសដ៏ច្រើន ទ្រង់ចំឡង

រំលងទៅជាក់ដល់ត្រើយខាងនាយគឺព្រះនិព្វាន ជាស្ថានប្រាសចាកទុក្ខ សោកភោគភ័យចង្រៃអពមង្គល មិនឲ្យចូលមកបៀតបៀនបាន ក៏យ៉ាងនោះដែរ ។

មិនតែប៉ុណ្ណោះ ព្រះមហាករុណាគុណធ្ងន់ៗប្រឹងបង្អុលបង្ហាញប្រៀបធៀបផែនទីទុកឲ្យសត្វខាងក្រោយអ្នកបង់ធ្លើដំណើរ ទៅកាន់ព្រះនិព្វានថា: សម្មាទិដ្ឋិ (សេចក្តីយល់ត្រូវ) ដូចជាប្រទីបសម្រាប់បំភ្លឺផ្លូវ; សម្មាសង្កប្បោ (សេចក្តីតំរិះត្រូវ) ដូចជាមគ្គុទ្ទេសក: អ្នកបង្អុលប្រាប់ផ្លូវ; សម្មាវាចា (សំដីត្រូវ) ដូចជាសាលាសំណាក់; សម្មាកម្មន្តោ (ការងារត្រូវ) ដូចជាផ្លូវថ្នល់ដ៏ស្អាតល្អ; សម្មាអាជីវោ (ការចិញ្ចឹមជីវិតត្រូវ) ដូចជាទីពាលំនៅរឥតអ្វីជាប់ជំពាក់; សម្មាវាយាមោ (ការព្យាយាមត្រូវ) ដូចជាជំហានដែលឈានដើរទៅ; សម្មាសតិ (សេចក្តីរលឹកត្រូវ) ដូចជាឲ្យល់ដកដង្ហើមចេញចូល; សម្មាសមាធិ (ការដំកល់ចិត្តឲ្យនឹងក្នុងអារម្មណ៍ដ៏ត្រូវ) ដូចជាសេចក្តីសុខដែលគ្រប់គ្រាន់ជួបប្រទះ ។ ផ្លូវទាំង៨នេះហើយដែលឈ្មោះថា "អរិយមគ្គ" ។ នេះឯងជាឧបាយប្តូរដំរាយផ្លូវដ៏ប្រសើរ ធ្វើដំណើរចិត្តរបស់សត្វអ្នកប្រតិបត្តិធម៌ ឲ្យដល់ទៅព្រះនិព្វានជាទីរំលត់ទុក្ខព្រួយគ្រប់យ៉ាងបាន ។

ព្រះពុទ្ធសាសនាដែលទ្រង់មានសន្តុះលឿនរកទៅកាន់សេចក្តីចំរើនរុងរឿងបាន ដោយអាស្រ័យពួកពុទ្ធបរិស័ទទាំង ៤ គឺ ភិក្ខុ, សាមណេរ,

ឧបាសក, ឧបាសិកា, ទំរ្រឹងស្រវ់ស្រទេញសុះសារព្យាយាម ស្តាប់ធម៌ រៀនធម៌ ប្រតិបត្តិធម៌ ដោយក្តីគោរពយ៉ាងហ្មត់ចត់ តាំងទំរ្រឹងបង្ហាត់បង្រៀនបរិយត្តិធម៌ ឲ្យបានចេះដឹងច្រើនគ្នានឹងមានការប្រតិបត្តិធម្មានុវ័យដោយសេចក្តីព្រមព្រៀងគ្នា; ឯឧបាសកឧបាសិកាបរិស័ទ កំចេះរក្សាសីល ៥ សីល ៨ ព្រមទាំងមានសទ្ធាជ្រះថ្លា ធ្វើទានដោយសេចក្តីស្ទុះស្ទួល អាចធ្វើសប្បាយទាំង ៤ នេះ ឲ្យកើតឡើងគឺ សេនាសនៈសប្បាយ ចេះធ្វើកុដិសាលាវិហារជាដើម ជាទីនៅរៀនសូត្រស្រួលមិនលំបាក ១; បុគ្គលសប្បាយ មានឧបាសកទំនុកបម្រុងព្រមទាំងមានកិច្ចសាមណោរផងគ្នាជាកល្យាណមិត្ត ជាគ្រូបីក្សាធម្មានុវ័យច្រើនរូបមិនខាស់ខែងគ្នា ១; អាហារសប្បាយ បានអាហារគ្រប់គ្រាន់មិនខ្វះខាត ១; ធម្មសប្បាយ បានធម្មានុវ័យ គម្ពីរដីកាក្បួនខ្នាតជាគ្រឿងរៀនសូត្រច្រើន ១ ។ សប្បាយទាំងនេះបើកើតមានព្រមហើយអាចនឹងធ្វើ ឲ្យកិច្ចសាមណោរ ទំរ្រឹងសម្រឹងស្ទឹងស្មាធ៌ធម្មានុវ័យ ឲ្យមានជំរឿនសុះទៅកាន់វឌ្ឍនធម៌ដោយឆាប់រហ័ស នឹងទំរ្រឹងបួសបំពេញកិច្ចក្នុងព្រះពុទ្ធសាសនាជារបជល់អស់ជីវិតបានផង; អស់លោកឧបាសកអ្នកទំនុកបម្រុង ក៏បានសម្រែចផលានិសង្សច្រើនជាអនេក ដូចភាសិតថា:

សុខស្សុ ទាតា មេធាវី សុខំ សោ អធិគច្ឆតិ

អ្នកមានប្រាជ្ញាបានឲ្យសេចក្តីសុខដល់គេ តែងបានសេចក្តីសុខនោះមកខ្លួនវិញ នេះឈ្មោះថាទំនុកបម្រុងក្នុងផ្លូវធម៌ ។

មិនត្រឹមតែផ្លូវធម៌ ទើបត្រូវអាស្រ័យសប្បាយចាំង៤យ៉ាងនោះទេ្តយ សូម្បីផ្លូវលោកក៏ត្រូវអាស្រ័យដូចគ្នា ទើបវិលទៅកាន់សេចក្តីចំរើនបានសម័យបាន ហេតុនេះឃើញថា ការរៀបចំស្រុកទេសជាទីនៅរបស់មនុស្សឲ្យមានផ្ទះសំបែង គ្រឿងប្រដាប់សម្រាប់ប្រើប្រាស់នឹងសំលៀកបំពាក់តាក់តែងពាងកាយឲ្យសប្បាយសម្បូណ៌ហូរហៀរ រៀបរយសមរម្យល្អមើលឲ្យមានអាបរាសម្រាប់បរិភោគ មានយានដំនិះសម្រាប់ទៅមកដោយស្រួលមិនខ្វះខ្ជៃ ឬទំនប់ធ្លុះបណ្តាលបង្កើតក្សួនប្បាប់ ខាងអក្សរសាស្ត្រ ប្រវត្តិសាស្ត្រ ហត្ថកម្ម វេជ្ជកម្ម ផ្លូវគមនាគមន៍ជាដើម ឲ្យសុះទៅកាន់វឌ្ឍនធម៌ដោយពេញបន្ទុក ទើបចុំច្បើនបាន បើប្រទេសមួយៗកន្លងលោកសន្និវាសនេះ មិនទំនប់ធ្លុះជ្រោងស្ងួយបង្កើតបង្កើនទូវសប្បាយចាំងឡាយ មានសាលាសម្រាប់បណ្តុះវិជ្ជាជាដើមឲ្យច្រើនទេ ហើយដេកសង្ឃឹមថា "ល្អើយចុះ អញចាំមើលព្រៃងសំណាង បុណ្យរបស់ងងឹងចុះ បើសំណាងមាន មិនចាប់ប្រឹងរៀនសូត្រឬធ្វើការងារអ្វីប៉ុន្មានទេ គង់តែវិជ្ជាទឹងច្រៀសឲ្យសព្វយ៉ាងកើតឯងមិនខាន" សាមន៍ណា ជែនណាជែលមានគំនិតបែបនេះ មុខជាទឹងធ្លាក់ខ្លួនទៅជាគំនិតទាសៈមិនខាន ។

ប្រទេសណាជែលមិនទំនប់ធ្លុះកសាងសាលារៀនក្សួនខ្នាតទឹងគ្រឿងឧបករណ៍ផ្សេងៗ ទេ ប្រទេសនោះរមែងគ្មានការចេះដឹង បើគ្មានការចេះដឹងហើយ ធ្វើម្តេចទឹងឲ្យប្រទេសជាតិមាតុភូមិនោះ អាចអាច

ក្នុងហានកងចំណោមអ្នកប្រាជ្ញ ដែលមកពីប្រទេសនានាបាន? លុះត្រាតែទំរឹងបង្កើតបង្កើនសាងសង់សាលារៀនក្នុងខ្លួនភ្នាក់សព្វ។ វិជ្ជា ទើបសប្បុរយគាំង ៤ ប្រការនោះ សុះទៅកាន់អាវុធមិនធឹងវឌ្ឍនធម៌ បានពេញបរិបូណ៌ មានគាំងតន្ទុកទ្រុយមែកខ្នែងបញ្ចេញផលាផលឲ្យដល់កុមារកុមារី ដែលកើតខាងក្រោយដោយសួស្តីបាន, នេះឈ្មោះថាតាក់តែងកងផ្លូវលោក ។

ក្នុងប្រទេសជាតិមួយៗ លុះតែមានគាំងផ្លូវលោកនឹងផ្លូវធម៌ ចំរើនកុះករស្មើភាគគ្នាសព្វ។ កាល ទើបបានសេចក្តីសុខសួស្តី ថ្កុំថ្កើងរុងរឿងជានិច្ចបាន, បើមានតែផ្លូវលោកមួយចំណែក មិនមានផ្លូវធម៌ផងទេ លោកនឹងនេះទ្បើងជាក្តើង ដោយហេតុសត្តនិកាយមាន ពាគ: ទោស: មោហ: ខ្វាំងប្រណាំងប្រជែងប្រធាំងឈ្នានីសប្រកួតប្រកាន់ ដំទ្បើងបុគ្គលអំណាចពាលតែឯង ឥតគិតគ្រែងរអែងដល់បុណ្យបាបសោះទ្បើយ ។ បើមានតែផ្លូវធម៌មួយចំណែក មិនមានផ្លូវលោកផងទេ លោកនឹងក្លាយទៅជាវៃព្រៃ ដោយមនុស្សមិនទំរឹងយកចិត្តទុកជាក់ នឹងការរៀបចំស្រុកទេសសោះ ។ ហេតុនេះបានជាព្រះពុជាគាំងឲ្យាយទ្រង់ធ្វើពុជកិច្ចទំនុកបម្រុងផងផ្តើមគាំងផ្លូវលោកនឹងផ្លូវធម៌ ឲ្យចំរើនស្មើភាគគ្នាជាលំដាប់ ដើម្បីឲ្យបានសុខសួស្តីដល់មហាជន ក្នុងព្រះពុជអាណាចក្ររបស់ព្រះអង្គ ។

ព្រះបរមគ្រូរបស់យើង៑ ពេលដែលព្រះអង្គត្រាស់ដឹងហើយ ទ្រង់ប្រតិស្ឋានសាសនាពុកក្នុងបច្ចុប្បន្ននេះ ដែលសម្រេចដោយប្រយោជន៍ពាំងបី ឬប្រែកេរធម៌ពាំងបីនោះ ក៏មានសេចក្តីរមែងចុះកន្លងផុតនឹងផ្លូវធម៌ប៉ុណ្ណោះ ដើម្បីឲ្យបានសេចក្តីសុខ ចំរើនដល់ពុទ្ធបរិស័ទ ក្នុងពុទ្ធសាសនមណ្ឌល ។

ព្រោះហេតុនេះ សាធុជនពុទ្ធបរិស័ទ អ្នកកាន់ព្រះពុទ្ធសាសនាគួរទស្សាហ៍ស្វែងរកសេចក្តីចំរើនពាំងផ្លូវលោកនឹងផ្លូវធម៌ កុំបីអាក់ខានខាងណាមួយឡើយ ទើបសមតាមពុទ្ធាថ្លែង ។

ធម្មទេសនាសន្ធតថាចប់ត្រឹមប៉ុណ្ណោះ

ធម្មទេសនាផុតារេន និទ្ទុក្ខា ហោន្តុ សព្វទា

ដោយអានុភាពនៃធម្មទេសនានេះ សូមពុទ្ធបរិស័ទពាំងឡាយ កុំបីមានទុក្ខសព្វ។ កាល ។

ចប់

ភាសាភាស្យ

ព្រះមហាសុខុមាលី-សេន ឥន្ទ្រប្បញ្ញោ

អាចារ្យសាលាបាលីវត្តដង្កោរកា ខែត្រឃ្លាំង (កម្ពុជាក្រោម,

វៀតណាម

(ត-ចប់)

បឋមវគ្គ

បទភ្ជុជង្គលីលា

ប្រែបទកុជង្គលីលា អាចារ្យមីមា តែងកាយឃ្លាតខ្មី
ស្រែចច្រាប់ធីតាសេដ្ឋី ថាបូរអូនស្រី តែងតួឲ្យខ្ញុំ ។
ធីតាកល្យាណតែងអង្គ មាសពេជ្រចញ្ចង់ ទម្រង់មណីរត្ន
ទំហូរពៃទូរ្យមរកត កណ្ឌលផ្ទេករត្ន និលត្នម្ពក្ខា ។
កងកកងកន់ហត្ថា ចិញ្ចៀនរចនា ក្បូរក្បាច់ភ្ជីសាយ
សង្វារយ៉ាឆើតឆាយ ប្រដាប់តែងកាយ ស្រែចច្រាប់ចេញចរ ។
ញាតិកាបរិវារឈូឆរ សឹងមានអំណរ បើកបរពោជ
សំដៅព្រៃពនាលី ផុតវាលទូរទី ទាល់ទៀបបព្វតា ។
លុះដល់ដើងកុំហើយណា សេដ្ឋីធីតា រឹងរឹតសប្បាយ
ជំនោរវាយោផាត់ផាយ រុក្ខាទាំងឡាយ ផ្លែផ្កាយោនយាន ។

សុគន្ធហាក់ឧន្ទន់ឧឡាន បុជ្ជផលមាន រីករុះស្គុសស្គាយ
ភូមិនុ្ទស្រស់ភ្លឹងពពាយ កេសរុះរាយ ឈ្លុយឈ្លប់សព្វស្ថាន ។
ធ័តាកន្យាថ្កើងថ្កាន សប្បាយហាក់ឋាន បិតហានសួគ៌ស្រី
មើលសព្វត្រីក្សាបក្សី ខិតជិតស្វាមី សំណេះបរបា ។
បងអើយនេះហើយបម្ប៉ា ចម្បីក្តាំងងា ក្រឹស្នាបន្ទូ
លលកលោតលេងតាំងគូ ចាបពួកហូពូ ហើរពាសព្រឹក្សា ។
អ្នកបង+ន្ទុះហោងសារិកា ចោះចិកផលា សិតាខ្ទរណាំង
បងអើយ+ន្ទុះហើយក្រសាំង ក្រសារសំគាំង សំកុលកន្ធុយ ។
អ្នកប្រុសមើលចុះ+ហ្គូយ +ហ្គូកហើរព្រួយ ហើរព្រាត់ពត់រយ
អ្នកបង+ន្ទុះហោងពពាយ ពពេចប្រញាយ ប្រញាប់ខំផ្គាស ។
អ្នកប្រុសមើល+ហ្គូសត្វទាស សត្វទៀវខំជ្រាស ផ្លែរជើមដង់ផ្តែក
ចោរប្តីស្បែតខ្លីធ្លើយរក ប្រែប្រាប់ថាមក ប្រញាប់នឹងទៅ ។
ឲ្យគេរិលទៅលំទៅ ពីរនាក់យើងទៅ ប្អូរាខេតតា
ហ៊ីកាន់អីក៏ន់នេះណា ប្រដាប់ប្អូរា កណ្តៀតទៅផង ។
ធ័តាយាគ្រាញ៉ែងញ៉ង ពោលថាអ្នកបង អញ្ជើញដើរមុខ
ចោរនាំនាងដើរតត្រុក កាត់វាលរំនុក្ខ តត្រុកឡើងភ្នំ ។
លុះដល់កណ្តាលផ្លាធំ ថ្ងៃសង្កត់ៗ ទៀបត្រោះបច្ចាត(១)

---

១ មើលថា ប៉ះ ប៉ាត ។

ទឹកជ្រោះជ្រៅជ្រះថ្លាស្អាត ទីនោះគ្មានជាតិ ត្រីចកឈើស្មៅ ។
មានតែថ្មស្រួចៗនៅ មនុស្សសត្វភ្ញាក់ផ្អើ មុតដូចសស្រ្តា
ដូចកាត់ដូចកាប់ច្នោះណា ខ្លួចខ្លីកាយា បីបួនកំណាត់ ។
គេហៅចោរៈបច្ចាត ព្រោះតែឆន់ពិយាត ចោរនាទីនោះ
ធីតាកន្យាញ៉ែញ៉ែ ដើរដល់ទីនោះ នាងសួរថ្តីថា ៖ ។
"ដល់ហើយអ្នកអើយទីណា ឱងរៀបបូជា អញ្ជើញតាមចិត្ត"
អាចោរមោហៈពុច្ចតែ ស្តាប់ស្តីមិនស្ងៀត មិនខ្លីឆ្ងើយឆ្ងល់ ។
ធីតាសួរថាអ្នកបង ហេតុអ្វីច្នេះហោង អ្នកស្ងៀមព្រងើយ
ឬមួយខ្លះអ្វីនៅឡើយ ទៀនធូបមានហើយ បូជាត្រង់ណា ? ។
ចោរថ្កាប់ថាគ្រឿងបណ្ណា- ការនេះទេតា មិនត្រូវការទេ
អញត្រូវការតែមេ ម៉េចដឹងឬទេ រំលងមិនបាន ។
ប្រដាប់សម្រាប់តែងថ្កាណ មាសពេជ្រប៉ុន្មាន បានអញលក់ចាយ
ធីតាកន្យាឆើតឆាយ បានស្តាប់បរិយាយ ចោរថ្កាប់ដូច្នោះ ។
តក់ស្លុតខ្លាចញ័រពោះ មិនដឹងពិគ្រោះ គិតតែយ៉ាងណា
ទើបសួរចាំងគិតភ័យថា នាងខ្ញុំនេះណា មានទោសដូចម្តេច ? ។
គ្រែងគ្រឿងរបស់មាសពេជ្រ ខ្លួនខ្ញុំនេះស្រេច សម្រាប់អ្នកហើយ
នឹងកាប់សម្លាប់ថ្វាយ ទុកនៅអ្នកអើយ គ្មានបំរើអ្នក ។
គ្មានទុក្ខព្រួយធ្ងន់ ខ្លួនខ្ញុំនេះជាក់ ជាអ្នកបំរើ

គ្រប់កិច្ចគ្រប់ការសោរពើ សម្ងាប់ខ្ញុំតើ មានប្រយោជន៍អ្វី? ។
សូមអ្នកមេត្តាប្រណី ខុកជាខាសី បំរើតទៅ
ចោរថាបើខុកហាន៎នៅ ហើយហាន៎នឹងទៅ ប្រាប់ម្តាយឪពុក ។
មុខជាចាប់អញដាក់គុក អញទឹងមិនខុក ហាន៎ឲ្យអំពល់
ដៀបុះខ្ញែងស្ងាប់កុំឆ្ងល់ កុំសោកសល់រល់ អំពល់ខ្លាំងពេក ។
ខុកជាហាន៎ទ្បាយយំយែក ឈាមចេញពីក្អែក មិនបានរស់ឡើយ
សេដ្ឋីធីតាគ្រាណាត្រើយ ស្តាប់ពាក្យចោរហើយ រងឹតតក្កមា ។
ទើបគិតថារ៉ែប្លាជ្ញ គ្មានអ្នកឯណា ខុកធាងាំស្ងួ
គ្រាមានអាសន្នមន្ទក គេតែងគេយក ប្លាជ្ញាមក៏គិត ។
ឥឡូវត្រែវសូន្យជីវិត មានតែអញគិត ប្រើប្លាជ្ញាម្ត៎ង
គិតហើយឆ្លើយថាអ្នកបង នាង៎ខ្ញុំនេះហោង មុខជានឹងស្ងាប់ ។
សូមអ្នកអនុញ្ញាតឲ្យគ្រាប សំពះលាបាប លាទោសនឹងអ្នក
ក្រែងមានប្រមាថពាធពាក្យ ពុំគួរនឹងអ្នក ម្តេចៗ ពីមុន ។
សូមអ្នករំភ្ញុកដល់គុណ ដល់កាលពីមុន ខ្ញុំឲ្យលោះអ្នក
មកទៅសន្ធិវ៉ាសរួមរ័ក រួមរួបនឹងអ្នក ជាប្តីប្រពន្ធ ។
ឥឡូវខ្ញុំត្រែវសូន្យជន្ម សូន្យដីពជីវិន ជីវិតមរណា . . .
អាចោរមោហាញាណ ញាណលុះលោភា លោភៈមោហន្ធ ។
អង្គុយចុះឲ្យប្រពន្ធ គោរពអតិវន្ធ ក្តៅក្តួចអាត្មា

នារីសោភីប្រាជ្ញា ប្រទក្សិណអា- ចោរប្លន់ទ្រព្យ ។
ទ្រង់ញាសោភអាមៅភមហិមា: "បងអើយអូនលា បងទីបំផុត . . .
ក្រុងក្រាបហាក់ជាបស្រយុត ដង្គង់លង់លុត លំអុតវន្ទា ។
អាចោរធ្លុះផ្ទះអគ្គ៌ា ដោយនាងពុំងា ទុបរតីពីក្រោយ
អង្អែលឆ្នាមកបណ្តោយ ដៃឆ្នេះគូថក្រោយ បណ្តោយចានចោះ ។
ទម្លាក់ចោរចុះកន្លង់ជោះ ចោរធ្លាក់ទៅនោះ ទង្គិចសិលា
តួច ។ មុតដួចស្លាប់ ខ្លួចខ្លីកាយា រអោចរអិត ។
ក្បាលក្បាយប្រល័យជីវិត ព្រោះផលទុច្ចរិត របស់អាត្មា
គ្រានោះអស់ពួកទេព្តា ដែលនៅរក្សា គឺរីបពិត ។
ឃើញចោរនឹងនារីវត្ត សុទ្ធសឹងលាន់មាត់ សរសើរនាងថា:
"ធម្មតារឯប្រាជ្ញ ប្រសើរវិចិត្រ ប្រពៃស្រួចស្រស់ ។
មិនមែនមានតែបុរស ស្រី ។ ពាំងអស់ គង់មានដែរណា
មើលហ្នាសេដ្ឋីធីតា នាងប្រើប្រាជ្ញ សម្លាប់ចោរបាន ។
ប្រាជ្ញានេះមហាចំណាន ដោះទុក្ខភ័យបាន ក្សេមក្សាន្តសុខា
អ្នកប្រាជ្ញតែងសរសើរថា រស់ដោយប្រាជ្ញ ប្រសើរក្រៃលែង ។
ការបានប្រាជ្ញានេះឯង ប្រសើរលើសលែង លើសលើអ្វីៗ
ហេតុនេះនរ:ប្រុសស្រី អ្នកកុំគប្បី មើលងាយប្រាជ្ញ ។
គួរខិតគួរខំទុស្សាហ៍ រិះរកប្រាជ្ញ មកបរិហារប្រាណ
នឹងបានសុខសមក្សេមក្សាន្ត យសសក្តិថ្កើងថ្កាន ប្រពៃពេកអើយ ។

បទព្រហ្មគីត

ប្រែបទព្រហ្មគីតកាល　　ទើងដំណាលចរចាចែង
ពីនាងនាថកណ្តែង　　នាកណ្តាលបព្វតា
ពពកពពូនតាប់　　ហាក់ដូចជាប់ចុងព្រឹក្សា
មេឃមីរដេរដាសដា　　ខ្យល់ផាត់ផាយឆ្ងាយលើសសន់ ។
នាងសែនសោយសោកសព្វ　　សល់សែនថប់ៗពេកពន់
មិនដឹងបើនឹងគន់　　គន់គិតទៅតាមផ្លូវណា
កិតកំយញ៉ាំរំចែប្រប់　　ស្ទើរសន្ធប់សូន្យជីវ៉ា
តែអគ្គិឯងឯកា　　គ្មានអ្នកណានៅជាគ្នា ។
មើលព្រៃស្មាត់ជ្រងំ　　គន់មើលភ្នំធំមហិមា
គន់មើលឥតានា　　នាងពុំដាវែងជាទុក្ខ
គិតសព្វវែងថប់ថា　　"អញ្ញានេះណាឯមាសមុខ
ប្រសិនវិលទៅស្រុក　　សមនុតុកម្លាយផ្តាសា ។
ថាអញ្ញានេះអប្រិយ　　ឲ្យលោះប្តីមកស្នេហា
ស្នេហ៍ហើយនឿយចិត្តា　　ប្រហារះចាលះដោយចិត្តក្រៃឆ
បើទុកជាអញ្ញាប់　　ថាចោរចាប់ៗ កំហែង
សម្លាប់អគ្គិអញ្ញឯង　　ព្រោះចង់បានអាកររណា" ។

ខ្លះណាខឹងដៀលឡើយ ពុទ្ធោអើយកម្មអាត្មា
ច្នេះអញខឹងយាត្រា តាមយថាកម្មអញឯង
គិតហើយដោះសង្ឃា អាករណាគ្រឿងតាក់តែង
ចោលនៅទីនោះឯង ទាំងអស់ហើយទើបយាត្រា ។
ញ៉ាំញោមចំប្រៃបន្តិច ខន់ដង្កឹងដងបន្ទា
ជំពប់ដុំថ្មជា ខ្លះអាត្មាស្ទើរមិនបាន
ចុះចាកកំពូលភ្នំ ដៃខ្លះគេមរហោស្ថាន
ខ្លាចចិត្តអាណិតប្រាណ ព្រោះមកបានទុក្ខវេទនា ។
គិតយើញកាលស្រណុក ស៊ីសោយសុខក្នុងគ្រឹហា
ឥពុកម្តាយមិងមា មូលមិត្តគ្នាជាសុខា
ចិត្តចង់ស្រើបស្រាលត្រេក ឃ្លានខ្លាំងពេកពាគត់ណា
មិនដឿស្តាប់មាតា បិតាផងខ្លួនប្រដៅ ។
ឥពុកម្តាយចង់បាន ឲ្យសុខសាន្តដល់កូនចៅ
ឲ្យថ្កុំថ្កើងពងរ្យផៅ មិនឲ្យសៅសោយសោកា
ខ្លួនរឹងចចេសចង់ តាមចំណង់ផងអាត្មា
ព្រោះយល់ថាតណ្ហា នាំកាយឲ្យស្រួលពិត ។
មិនមែនទេទេពតា កុំយល់ថាការស្នេហ៍ស្និទ្ធ
ខឹងមនុស្សពាលទុច្ចរិត នាំជីវិតឲ្យស្រួលឡើយ

អ្នកអើយនាងស្រី ។ គួរវើសប្តីណានាងអើយ
ខ្ញុំនឹងខ្ញុសជ្រុលហើយ កាលណាឡើយបានសុខា ។
ដូច្នេះនាងនៅគ្រោយ គួរបណ្តោយតាមមេបា
ឲ្យវើសតូចធំឮ វើសចរិយាសឹមមេត្រី
រីខ្ញុំនឹងនេះណា ស្រីបស្នេហាចង់បេតី
ទឹងចោរសោអប្រិយ យកស្វាមីមនុស្សខុចិត្ត ។
ចាបកម្មតាមមកផ្គត់- ខ្ញាចាន់ហាន់ដល់ដូចចិត្ត
កំណាចព្រោះគំនិត តែងតែមតែកតែងតែអាល
ចចេសចើកចោរចង់ តាមចំណង់ឃ្លានស្រីបស្រាល
អកុសលផ្តល់បណ្តាល កម្មផ្តាញ់ផ្តាលឲ្យខ្ចោចផ្សា ។
អស់អ្នកនាងនៅគ្រោយ កុំបណ្តោយតាមតណ្ហា
ខុកជាស្រីបយ៉ាងណា ចំរក្សាខ្លួនឲ្យបាន
នាងអើយការស្រីបស្រាល តាមបណ្តាលគ្មានសុខសាន្ត
នាំឲ្យអាស្រូវប្រាណ បានវេទនាដូចជាខ្ញុំ ។
គួរស្តាយរូបអាត្មា ស្តាយចរិយានាងក្រមុំ
កុំស្រីបស្រាលដូចខ្ញុំ គួរតែកុំប្រសើរជាង
គួរនឿយណាយអាម៉ាស គួរតែខ្មាសគួរណាស់ពាង
គួរគេចគួរចៀសពាង រក្សារូបឲ្យសុខអើយ ! ។

បព្វជ្ជាវគ្គ

បទកាកគតិ

ព្រៃបទកាកា ដំណាលបវរចា ចាប់ចែងសេចក្តី ថ្វាថ្លែងអំពី
នារីប្រិមប្រិយ ទំប្រឹងឃ្លាតខ្ចី ចុះចាកបព្វតា ។ លទ្ធដ៏លន្ទោច
ត្រមង់ត្រមោច កណ្តាលព្រឹក្សា តេជៈកុសល ដួយផ្តល់ធីតា ឲ្យ
ទំយាត្រា តាមវាសនានាង ។ សត្វពាឡម្រឹគា សិង្ហសីហ៍នានា
ភ្ញាភ្ញាចចៀសវាង គោព្រៃក្របី កិតក័យនឹងនាង បរវៀសចៀសវាង
មិនអាចយាយី ។ នាងដើរលុះដល់ តើបពះយង់យល់ អាចមជាទី
បរិព្វាជក: នឹងបរិព្វាជី នោះក៏នារី ចូលទៅវន្ទា ។ ក្រាបថ្វាយបង្គំ
លោកគ្រូជាធំ សូមសុំបព្វជ្ជា សូមទានមេត្តា ករុណាកំព្រា មកសូម
បព្វជ្ជា នឹងព្រះគុណម្ចាស់ ។ បរិព្វាជកា ឃានស្តាប់ធីតា គាប់ចិត្តា
ណាស់ ប្រដុំគ្នាគ្តី មកមើរដេរជាស ដួបដុំរហ័ស បំបួសធីតា ។
ទើបឲ្យនាមេ ហៅថា "ជម្ពុ បរិព្វាជិកា" ព្រោះនាងបួសរួច រៀន
ភ្លូចប្រស្នា ជម្ពុហត្ថា ជាអាថិសេចក្តី ។ គ្រូបង្គាប់ថា ចូរនាងយាត្រា
ទៅសត្វបុរី ស្រុកភ្លូចស្រុកធំ និគមណាក្តី ប្រយោជន៍ដើម្បី
សាកសួរបញ្ហា ។ បើមានគ្រហស្ត ជាតិជាបុរស អាចដោះប្រស្នា
ឃានរួចរួសរាន់ មួយពាន់ប្រការ នោះចូរធីតា ស្នេហាមេត្តី ។
ឧស្សាហ៍សង្វាត គោរពទៀបឃាត សត្វពោលប្រកែត ព្រោះគេជាតិ
ឃាជ្ញ តែងអាចដោះស្តី គួរតែពិសី មេត្រីជាគ្នា ។ បើបព្វជិតណា

អាចដោះបញ្ហា មួយពាន់ភាគ ឆ្លើយរួចទាំងអស់ គ្មានខ្វះមួយឃ្លា នោះចូរពាំងា បួសរៀនតាមចុះ ។ ពីព្រោះបព្វជិត នោះជាបណ្ឌិត វិសិដ្ឋប្រាជ្ញប្រុះ កបដោយញាណញ្ញ្យ ប្រពៃឆ្លៀវឆ្លុះ អាចដឹងសព្វសុះ អស់អាថិប្រស្នា ។ នាងបវរ្ជាដ ឮបានស្តាប់ពាក្យ គ្រូប្រាប់ច្នេះណា លើកហត្ថបង្គំ ដាក់ធ្លុំកេសា រួចរៀបអាត្មា ស្រែចចាប់ចរលើ ។ នាងដើរបិណ្ឌបាត ទិតទំសង្ឃាត សួរសាកវាទី សព្វស្រុកខេត្តឃុំ និគមធានី ដើរសួរសព្វទី ពាជគ្រឹះបុរី ។ សាកសួរលុះដល់ដៃនដីកោសល ក្រុងសាវត្ថី ពុំមានអ្នកប្រាជ្ញ ដែលអាចដោះស្តីប្រស្នាបាលី នៃនាងបានឡើយ ។ មួយថ្ងៃនោះណា បវរ្ជាដិកាវៀបខ្លួនស្រែចហើយ យកមែកព្រីងថ្មី ពូនដីរួចហើយ ធីតាត្រាណត្រៃយ អធិដ្ឋានថា ។ អ្នកណាអាចហ៊ាន ជាន់ដកបំពាន មែកព្រីងនេះណា អ្នកនោះត្រូវឆ្លើយ បើកផើយប្រស្នា ទើបរួចខ្លួនបាន ។ ក្រោយនាងចេញទៅ មានពួកក្មេងនៅ ប្រជុំនាស្ថានទីនោះទៀត តែថាមិនបាន បៀតបៀនដល់ស្ថាន ជម្ពូសាខា ។ អាខ្លះធ្វើហ៊ាន ស៊ុះទៅបំពាន ដៃប្រឹងប្រែង ខ្លះតន់ខ្លះឈរ ខ្លះលាបម្ស្ន ខ្លះស្រែកថាអ លាញរើយប្រយ័ត្ន ។ ខ្លះហ៊ានចូលជិត ខ្លះខ្លាចភ័យតិត សម្ងំស្ងៀមស្ងាត់ ខ្លះលោតប្រឡែង ខ្លះប៉ែងគូចប៉ាត់ ខ្លះតន់ប៉ាត់ញ៉ាត់ ដេញគ្នាប្រញាយ ។ ជួនថ្ងៃនោះណា អគ្គសាវ័កា

សារីបុត្តច្រាជច្រាយ ដល់ទីនោះឯង ឃើញក្មេងទាំងឡាយ ទ្បៀវ
ភ្ញាសច្បាយ ទើបសួរទៅថា: ។ នែរើយពួកក្មេង អស់ឯងនេះលេង
អីនេះអ្ហ៊ីរអា មែកព្រីងផ្កឯ្បាប់ សំបាច់នរណា ថ្លឹកពួកអា មិនហ៊ាន
ទៅជិត ។ ពួកក្មេងទូលថា ពួកខ្ញុំកុណា នេះខ្លាចកំយកិត នាង
ឋរិព្ធាជ៍ នារីបព្វជិត ដេញដោលឲ្យគិត រកអាថ៌ប្រស្នា ។ – បើយ៉ាង
នេះពិត ពួកឯងកុំកិត ភ័យខ្លាចឡើយណា កំទេចឲ្យអស់ ការដោះ
ប្រស្នា ស្រែចលើអាត្មា ជានាឆ្លើយឆ្លង ។ ពួកក្មេងបានច្បាប់
រត់ទៅប្រញាប់ ក៏ញ្ជ្រៀវអីងកង ខ្លះជាន់ខ្លះកាច់ ខ្លះបាចព្រាច់ផង
ទ្រហឹងអឺងកង ក៏ញ្ជ្រៀវស្រៀវស្រែក ។ កំពុងតែជាន់ នារីមកទាន់
ប្រពួនបែកខ្ញែក ខ្លះរត់ទៅឆ្ងាយ ខ្លះប្រាយដោយឡែក នារីក៏ស្រែក
គម្រាមទៅថា: ។ លាកហើយម្ដងនេះ បានពួកឯងចេះ ឆ្លើយអាថ៌
ប្រស្នា ចូរប្រមូលគ្នា កុំអាទៅណា អញសួរសិនព្រ៉ំ បំណាច់ក្លា-
ហាន ។ ពួកក្មេងឆ្លើយថា លេកគ្រូនុ៎ះណា លោកដោះសាបាន
អញ្ជើញសួរចុះ ចុំរុំប៉ុន្មាន ពួកយើងគ្រប់ប្រាណ៎ សឹងបានលោក
ប្រៃ ។ នាងឋរិព្ធាជ៍ ចូលជិតវេទ្ធី បង្គំទូលស្នើ ថាព្រះគុណម្ចាស់
បានត្រាស់ចាត់ប្រៃ ឲ្យពួកក្មេងរើ មែកព្រីងឬអ្វី? ។ អាម:កគិនី
អើបរិព្ធាជ៍ ចុះមានការណ៍អី ឮថាព្រីងព្រីង ហើយនឹងផ្កជ៍ នោះ
ជាឬស៊ើ កើតអាថ៌ប្រស្នា? ។- ខានប្រាសពីតណាស់ ត្រូវព្រះគុណម្ចាស់

ខ្ញុំលោះសោ វាទៈនៃធាន់ មួយពាន់បញ្ហា តើព្រះកុណា ខ្ញុំលះ
ប្តូរម៉េច? ។ - អាមៈភគិនី អើបវិញ្ញាដី អាត្មាមិនគេច រសៀលនេះ
ណា ធីតាកុំក្តៅច ចង់ស្តូរដូចម្តេច ទៅវត្តអាត្មា ។ - ខានច្រើនស
គាប់ណាស់ រសៀលខ្ញុំមាស់ រូតរះយាត្រា ច្នេះសូមព្រះគុណ និមន្ត
ចុះណា រសៀលស្តូរ្យា ខ្ញុំទៅវិហារ ។

បញ្ហាវត្ត

ព្រឫក្តីត

លុងលុះចូលសាយណ្ហ ទាបទោរទន់ព្រះសូរ្យា
សូរ្យសែងលែងក្តៀវក្តា អ័ព្ភស្រទន់ស្រទំចុះ
បញ្ចាំងពណិសុវ័ណ្ណ ហាក់ដូចស្ថានកញ្ចក់ធ្នុះ
ភ្នំផ្ទេកពព្រាតប្រុះ ជាប់ចុងចុះឈើនានា ។
វាយោក៍ផាត់ផាយ សុសសព្វសាយផែនពសុធា
ឲ្យចាន់ដឹងថាជា ចូលវេលាវរសៀលហើយ
នាងបវិញ្ញាដិកា រៀបអាត្មាពុំលង់ឡើយ
លុះរៀបស្រេចចាប់ហើយ ក៏ចេញចរចូលដេតពន ។
មិច្ចាទិដ្ឋិកា នឹងសម្មាទិដ្ឋិជន
ដើរតាមចាំគយគន់ ចូលដេតពនស្តាប់បញ្ហា
មិច្ចាទិដ្ឋិជន រិះគិតគន់ថាប្រសើ

នាងបវិត្រាជិកា សួរមហាសារីបុត្ត ។
ដល់មួយពាន់បញ្ហា មានអត្ថាស្រាវជ្រាវបំផុត
មុខតែសារីបុត្ត ជាប់ពិរុទ្ធិ៍ខ្លះមិនខាន
សម្មាទិដ្ឋិកា រិះគិតថាយើងនឹងបាន
ស្តាប់ធម៌យ៉ាងចំណាន ច្រើបាជ្រពីរច្រើណាចោទធ្វើយគ្នា ។
នាងបវិត្រាជិកា ដល់ហើយណាគុនវន្ទា
អង្គុយសន្ទនា សាពណីយកថា
រួចលើកយកវាគា មកតាំងជាអាថិបស្ថា
ជាមួយពាន់បញ្ហា នាងបុច្ឆាឥតចន្ទោះ ។
ព្រះសារីបុត្តច្រើបាជ្រើបាយ ធ្វើយដោះស្រាយឥតសល់សោះ
ធ្វើយសព្វឥតចន្ទោះ លុះចប់អស់មួយពាន់ឃ្លា
ទើបសួរថាបញ្ហា ដែលអាត្មាវិសជ្ជនា
មកនេះច្រើនមហិមា មួយពាន់ឃ្លាណានាងអើយ ។
ឥឡូវត្រូវអាត្មា ការពុច្ឆានាងវិញហើយ
តើនាងទទួលធ្វើយ ឬឯអាត្មាឬទេអេះ?
— ខានច្រើបាសខ្ញុំគុណា សូមសន្យាថាបើចេះ
ទឹងធ្វើយតាមចំណេះ បើមិនចេះសួរវិញទេ ។
— ធម្មជាតមួយគឺអ្វី? ចូរពិស្តីតិរិះរេ

- នាងគិតមិនយល់ទេ មិនដឹងគ្នេរគ្នើយយ៉ាងណា
ទើបទូលតបថាខ្ញុំ នែរកពុំយល់ច្បាស្នា
នេះទេសូមមេត្តា ធម៌ឯកានុ៎ះគឺអ្វី? ។
- ធម្មជាតិនោះសោភ័ណ គឺពុទ្ធមន្តណាពិសី
បើពោលរួមឲ្យខ្លី ឃានសេចក្តីថានិព្វាន,
- ទានច្រើនសតីពោះផ្ទៃក នេះចំណែកកម្រមាន
សូមច្រើនច្រើនឲ្យទាន ធម៌និព្វានដល់ករុណា ។
- ការរៀនពុទ្ធមន្តនោះ លុះតែបួសបែបអាត្មា
ទើបលោកឲ្យសិក្សា អត្ថគាថាពុទ្ធបាលី,
នាងបរិព្វាជិកា បួសឃានជាព្រះថេរី
នាមកុណ្ឌលកេសី ច្រើនឃ្នាតខ្លីខំបិក្សា ។
មិនជាយូរប៉ុន្មាន សម្រេចបានអរហត្តា
ជាមហាសាវិកា ក្នុងសាសនាព្រះគោតម;
រីរឿងភ័ស្តុនេះឯង ខ្ញុំចាត់ចែងពីដើមចម
តាមបែបតាមដោយគម- ម្ពីរបាលីព្រះធម្មបទ ។
សង្ខេបបែបភ្លេហារ ពុំពិស្តារឃានមត់ចត់
ប៉ុណ្ណេះស្ទុះសន្ធត ថាចប់ចុះអស់ឯវំ ។

ព្រះមហាឧត្តមរដ្ឋិ ធិលញ្ញាណោ ប៊ុង-ប៉ម
អាចារ្យសាលាឆាលីវង្ស វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង
ឃុនបណ្ឌានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តមក)

ឧបាយបណ្តុះធិសប្បុរទី ៥

ធិសប្បុរស្រឡាញ់ភក្តី (ស្វាមីភក្តិ)

ការស្រឡាញ់ភក្តីគឺអ្វី? ការស្រឡាញ់ដោយទឹកចិត្តពប់អានយ៉ាងបរិសុទ្ធពិត។ ឈ្មោះថាស្រឡាញ់ ។ ការគោរពសមល្មម ទន់ ដឿ ដោយទឹកចិត្តសុចរិតស្មោះត្រង់មិនគិតរៀបវេរឧយិស ឈ្មោះថា ភក្តី ។ បើលោក-អ្នកជ្រាបសេចក្តីត្រឹមប៉ុណ្ណេះហើយ ក៏តបបញ្ហានេះបានភ្លាមថា: សេចក្តីស្រឡាញ់ក្នុងវត្ថុឬបុគ្គល ដោយទឹកចិត្តពប់អានយ៉ាងបរិសុទ្ធពិត ។ ទន់ការគោរពសមល្មមដឿស្តាប់ក្នុងវត្ថុឬបុគ្គល ដោយទឹកចិត្តសុចរិតស្មោះត្រង់ មិនគិតរៀបវេរឧយស បង្ហោនខ្លួនដើម្បីជាប្រយោជន៍ដល់វត្ថុឬបុគ្គលដែលខ្លួនគោរពស្រឡាញ់នោះពិត ។ នេះឯងចាត់ថា "សេចក្តីស្រឡាញ់ភក្តី" ។

មនុស្សដែលមានធិសប្បុរស្រឡាញ់ភក្តី រមែងធ្វើទន់ធិយាយដោយចិត្តសុចរិត គោរពស្រឡាញ់ចំពោះវត្ថុឬបុគ្គលដទៃ ដូចជាគោរព

ស្រឡាញ់ចំពោះខ្លួនឯង មានសេចក្តីព្រមព្រៀងគ្នារវាងគ្រួសារញាតិមិត្របង់ប្អូន សុចរិតស្មោះត្រង់ចំពោះមិត្តភក្តិរួមជាតិ ។ អ្នកដែលមានទិស្សយស្រឡាញ់កក្តិនេះបើជាបុត្រធីតាក៏ស្រឡាញ់កតីចំពោះមាតាបិតា, បើជាសិស្ស ក៏ស្រឡាញ់កតីចំពោះគ្រូអាចារ្យ, បើជាអ្នកគួច ក៏ស្រឡាញ់កតីចំពោះអ្នកធំ, បើជាពលរដ្ឋ ក៏ស្រឡាញ់គោរពប្រមុខរបស់ខ្លួន មើលឃើញនូវពាក្យដែលព្រឹទ្ធាចារ្យប្រៀនប្រដៅ ដូចជាឃើញកំណប់ទ្រព្យដ៏ប្រសើរដែលបិតានៅចំពោះមុខ នឹងខ្វល់ខ្វាយអើពើជួយកិច្ចការរបស់ពួកគណៈ ឲ្យឈានទៅកាន់សេចក្តីចំរើន ។

លោក-អ្នកចាំង ឡាយ មានទិស្សយនេះហើយឬនៅ? បើមានហើយទិស្សយរបស់លោក អ្នក ក៏នឹងបង្ហាញឲ្យឃើញច្បាស់ជាថា "លោក-អ្នកមានសេចក្តីស្រឡាញ់កក្តីសុចរិតស្មោះត្រង់ ចំពោះវត្ថុបុគ្គល ដូចជាស្រឡាញ់កក្តីខ្លួនឯង មិនគិតរៀបរៃឧយិស មានទឹកចិត្តស្រឡាញ់កក្តីពិត ។ ធ្វើខ្លួនឲ្យជាកំឡាំងក្នុងកិច្ចការសោរតើ តាំងចិត្តធ្វើការណ៍យ-កិច្ចតាមដែលខ្លួនបានព្រមទទួលមកដោយសុចរិតស្មោះត្រង់ មិនធ្វើតែចំពោះមុខ សូម្បីកំបាំងមុខក៏ធ្វើដូចគ្នា កាលដល់វេលាត្រូវការក៏បង្ហាន់ខ្លួនធ្វើពលីកម្ម ដើម្បីជាប្រយោជន៍ដល់វត្ថុបុគ្គលដែលខ្លួនគោរពស្រឡាញ់នោះបានពិត ។" ។

ការស្រឡាញ់កក្តី ជាសេសរគោលបង្ការឲ្យយើងមានសន្តិសុខ ១ ផ្នែក ។ សូមលោក-អ្នកពិចារណាកន្លះចំណែកសំខាន់នៃសេសរគោលបង្ការ

គឺសេចក្តីស្រឡាញ់កក្តីនោះឲ្យចូលចិត្តជាក់លាក់ដូច្នេះថា មនុស្សយើងនឹងសត្វមានរូប, ជីវិតនឹងចិត្តដូចគ្នា តែការតាំងនៅនៃមនុស្សនឹងសត្វនោះខុសគ្នាឆ្ងាយណាស់ ។ សត្វក្នុងព្រៃ ត្រឹកឯងទឹកចេះតែប្រហារគ្នានឹងស៊ីគ្នាឯងមិនមានឈប់ឈរ ។ សូម្បីមនុស្សត្រូវការប្រហារ ឬចាប់ពាមកធ្វើជាអាហារកាលណាក៏ជាន ។ សភាពតាំងនៅក្នុងការគ្រប់គ្រងជីវិតរបស់សត្វ រមែងជាក្តើងនរកដុតបំផ្លាញ ឲ្យក្តៅក្រហាយយ៉ាងសាហ៊ាស ។

បើលោក-អ្នកពិចារណាឲ្យឃើញច្បាស់ដោយជាក់លាក់ហើយ មុខជានឹងដឹងក្លាមថា សត្វតាំងនោះ មិនមែនមានហាន: ដូចជាលទ្ធិខ្លះដែលយល់ឃើញថា ព្រះម្ចាស់សួគ៌សាងពាមកឲ្យជាដូច្នោះ ឬព្រោះពាជាសត្វមានសភាពតាំងនៅដូច្នោះឡើយ ។ តាមសេចក្តីពិត ដែលពាមានការគ្រប់គ្រងជីវិតជានរកដុតបំផ្លាញគ្រប់វេលានោះ ព្រោះពាខ្លះបង្កើលសំពាប់ការពារ ។ ចំណែកមនុស្សដែលមានលក្ខណៈផ្ទុយគ្នាពីសត្វ ក៏ព្រោះមនុស្សយើងមានសេចក្តីស្រឡាញ់កក្តី ជាបង្កើលសំពាប់ពីធម្មជាតិ គឺស្រឡាញ់កក្តីចំពោះរបស់ឃុំគ្រង ដែលជារបាំងយ៉ាងសំខាន់ ដើម្បីសន្តិសុខដែលកាលពីដើមធ្លាប់មានតែ ៣ ប្រការ គឺជាតិ, សាសនានឹងព្រះមហាក្សត្រ; ដល់មកក្នុងគ្រានេះ បន្ថែមរដ្ឋធម្មនុញ្ញមួយមកទៀត ត្រូវជាសេចក្តីស្រឡាញ់កក្តីមាន ៤ ប្រការគឺ:

១— ស្រឡាញ់កក្តីបំពោះជាតិ — ចំដុំជនដែលតាំងនៅជាពួកជាគណៈ មានកំណើតតូចធំឬ ឬ សញ្ជាតិជាប់តមកអំពីដើមឲ្យជា

មួយគ្នាមានភាសានឹងអក្សរសាស្ត្រជាមួយគ្នា មានកូមិលំនៅទីអាស្រ័យរួមគ្នា គឺនៅក្នុងខែត្រនៃការគ្រប់គ្រងជាមួយគ្នា មានចរិតប្រពៃណី ឬទំនៀមទំលាប់ស្រដៀងគ្នា រាប់អានសាសនាជាមួយគ្នាដោយច្រើន នឹងមានប្រមុខជាអ្នកបង្គាប់បញ្ជាកិច្ចការឲ្យប្រព្រឹត្តទៅជាមួយគ្នា ហៅថា ជាតិដូចយ៉ាងជាតិកម្ពុជា ក៏គឺអ្នកកម្ពុជាទាំងអស់រួមគ្នា ទាំងដែលមានពូជពង្សសៃស្រឡាយជាប់ជាដំណគ្នាមក និយាយភាសាជាមួយគ្នា មានរូបរាងលក្ខណៈនឹងទំនៀមប្រពៃណីដូចគ្នា ទាំងដែលមានសញ្ជាតិជាខ្មែរតាមច្បាប់ទំលាប់ផង រួមសេចក្តីមកថា ជាតិខ្មែរកម្ពុជា ក៏គឺជាតិខ្មែរដោយកំណត់ នឹងដោយសញ្ជាតិរួមគ្នាទាំងអស់ ។

ជាតិ រមែងជាទីអាស្រ័យទ្រទ្រង់ដ៏វិសេស នឹងវង្សត្រកូលនៃពួកជនរបស់ជាតិ ជាទីរួមនៃប្រយោជន៍ចំណែកធំ នឹងជាទីពឹងដ៏ក្សេមក្សាន្តរបស់ប្រជាជននៃជាតិ ។ មនុស្សគ្រប់រូបនៃជាតិ ត្រូវពឹងពាក់អាស្រ័យគ្នានឹងគ្នា ក្នុងការគ្រប់គ្រងជីវិតរួមគ្នា មានទាំងចំណែកបាន ទាំងចំណែកបង់ រួមសុខរួមទុក្ខជាមួយគ្នានឹងជាតិ, ជាតិប្រព្រឹត្តទៅយ៉ាងណា ទោះជាសុខក្តី ជាទុក្ខក្តី ចំរើនក្តី វិនាសក្តី មនុស្សក៏ត្រូវតែប្រព្រឹត្តទៅយ៉ាងនោះដែរ ។ សេចក្តីសុខទុក្ខ ចំរើន ឬវិនាសរបស់ជាតិ ធ្លាក់ទៅជារបស់មនុស្សទាំងអស់ ។ មនុស្ស ជាអ្នកមានចំណែកបាន ចំណែកខ្ជួលស្មើគ្នាខ្ជួទៅ គឺកាលបើជាតិ បានសុខទុក្ខ ចំរើន ឬវិនាស មនុស្សក៏ត្រូវបានសុខទុក្ខ ចំរើនឬវិនាសផងដែរ ។

ជាតិសំខាន់ជាងមនុស្ស ព្រោះបើជាតិនៅគង់វង្សរឹងប៉ឹងដំហរ
មនុស្សរមែងមានសន្តិសុខ ទើងមានសិទ្ធិ ឥស្សរភាព សេរីភាព សម្បូណ៌
ពេញលេញ ។ បើជាតិវិនាសសាបសូន្យទៅហើយ សូម្បីនៅមានសល់
មនុស្សខ្លះក៏ដោយ ក៏អ្នកនោះ ឥតមានសន្តិសុខ ទើងសិទ្ធិ ឥស្សរភាព
សេរីភាពដែរ ដូចយ៉ាងជាតិដែលជាក់ទៅជាទាស:របស់ជាតិដទៃ ត្រូវជាតិ
របស់ជន ដែលជានាយចៅហ្វាយគ្របសង្កត់ ដណ្តើមយកប្រយោជន៍
ដែលខ្លួនគួរមានគួរបានទៅអស់រលីង មិនយល់ព្រមបណ្តោយឲ្យមាន
សិទ្ធិ ឥស្សរភាព សេរីភាព ក្នុងវត្តណាមួយឡើយ ត្រូវបានទទួល
តែសេចក្តីចង្អៀតចង្អល់ទើសទែង ស្រែកថ្ងូរទ្រហោយំ ក្រៃលែងជាង
ទាស:ចំពោះរូប ដែលត្រូវនាយចៅហ្វាយកាត់ផ្តាច់សិទ្ធិ ទើងដណ្តើម
យកប្រយោជន៍នោះទៅទៀត ។ ព្រោះថាជាតិដែលត្រូវគេគ្របសង្កត់
នោះ មិនមែនចំពោះតែមនុស្សមួយរូប។ឡើយ សូម្បីមនុស្សដែលជាទី
ស្រឡាញ់ ជាទីគោរពរាប់អានជាងអស់ ក៏ត្រូវគេគ្របសង្កត់ផងដែរ ទាំង
ត្រូវឆ្លងទុក្ខវេទនាសែនសាហ៊ស រហូតទៅដល់កូន ដល់ចៅ។ ល ។ ផង
ទៀត ឥតមានកំណត់ថាកាលណាទើងផុតឡើយ ។ ចំណែកទាស:
ចំពោះរូបដែលត្រូវគេគ្របសង្កត់នោះ ក៏ចំពោះតែរូបមនុស្សមួយ សូម្បី
ទើងបានទទួលទុក្ខលំបាក ក៏ត្រឹមតែ ១ អាយុខ្លួនឯងប៉ុណ្ណោះ ។

(មានត)

រឿងសាមកុក

កណ្ឌទី ១៥

ឧកញ៉ាវិបុលរាជសេនា ន្ង-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវិឆ្ងាសបើបានអាន
ទឹងបេះឧបាយកលបំណាន
ទាំងមានសន្ធានស្នេហាជាតិ ។

ឯលីចុ៉កាលដឹងថា ទ័ពអ៊ិនសុតលើកមកចាំងដូច្នោះ ក៏ឲ្យហៅតាន់កុង, តាន់គុយ, តាន់តេង ទើងនាយទាហានទាំងពួងមកប្រឹក្សាថា គ្រានេះអ៊ិនសុតលើកទ័ពមកធំយ៉ាងពន្លឹក ហើយញែកគ្នាទៅវាយស្រុកចំណុះរបស់យើងទាំងអស់ តើអ្នកទាំងឡាយនឹងគិតប្រការដូចម្តេច? ។ តាន់កុងឆ្លើយថា ដែលតើតហេតុទាំងនេះ ក៏ព្រោះតាន់គុយនឹងតាន់តេង ២ នាក់អាពុកនឹងកូន ឃាត់មិនឲ្យលោកលើកកូនក្រមុំឲ្យអ៊ិនសុត ហើយឃុបឃិតចូលគំនិតគ្នាទៅនិយាយនឹងចូរ ។ ក៏តាំងតាន់តេងជានាហ៊ុនមានបណ្ណាសក្តិ ហេតុនេះ សុំឲ្យលោកចាប់ខ្លួនតាន់តេងនឹងតាន់គុយ

បញ្ជូនទៅឲ្យអ្នកសុត ហើយសំដែងរឿងការពាំងប៉ុន្មានឲ្យអ្នកសុតអស់សេចក្តីសង្ស័យ ប្រហែលអ្នកសុតនឹងលើកទ័ពត្រឡប់ទៅវិញ ។ លីចោ" យល់ឃើញត្រូវ ក៏បង្គាប់ថាហានឲ្យទៅចាប់ខ្លួនគាន់គុយនឹងគាន់តេង ពាំង២នាក់យកទៅសម្ងាប់ ។

គាន់តេងដឹងថា លីចោ"បង្គាប់ឲ្យចាប់ខ្លួន ក៏ចូលទៅជួបនឹងលីចោ" និយាយហើយសើចចំអកឲ្យលីចោ"ថា ពីដើមខ្ញុំបានឃើញថា លោកជាមនុស្សមានសតិបញ្ញាស្គាល់ការខុសត្រូវមាំមួន ឥឡូវសង្កេតទៅឃើញគំនិតនឹងដំរេះប្រាជ្ញារបស់លោកទន់ខ្សោយពេកណាស់ ចុះលោកទៅញញើតខ្លាចអ្វីនឹងចំនួនកងទ័ពអ្នកសុត ៧ កង៉ប៉ុណ្ណេះ ។បមាដូចជាស្មៅ ៧ ក្តាប់នៅជិតមាត់គោ នឹងំពាសុីក៏អស់ដោយងាយណាស់ ដូចរឿងនេះបើនឹងគិតសុីក៏ឃើញថាកងទ័ពអ្នកសុតនោះ នៅមិនល្មមនឹងគំនិតរបស់ខ្ញុំបានទេ ។ លីចោ"សួរថា អ្នកនឹងគិតធ្វើ។ចុាយដូចម្តេច? ក៏ឲ្យរៃគិតធ្វើឲ្យបានទៅចុះ បើគិតយកអាសាចេញទៅតសុូនឹងអ្នកសុតបាន យើងក៏ព្រមលើកទោសពាំងអាពុកនឹងកូន ។ គាន់គុយជំរាបថា ប្រសិនបើលោកស្តាប់ពាក្យខ្ញុំបាន។ នឹងបានស្រុកឈើជីវិតមិនឲ្យកើតមានសេចក្តីអន្តរាយឡើយ ។ លីចោ"សួរថា គំនិតរបស់អ្នកនឹងគិតធ្វើដូចម្តេច? ។ គាន់គុយជំរាបថា ទាហានអ្នកសុតច្រើនក៏មែនពិតហើយតែថាសុទ្ធតែជាមនុស្សផ្តេសផ្តាសមិនចំណានកងការសឹកសង្គ្រាម ពាំងខ្លួនអ្នកសុតសោត

ក៏មិនសូវទុកចិត្តប៉ុន្មាន, ឯតាហានក្នុងស្រុកយើងសុទ្ធតែជាមនុស្សគួរទុកចិត្តបាន . បើយើងនឹងលើកចេញទៅច្បាំងនឹងអ្នកសុតរលាណាគង់តាហានខាងយើងនឹងមានជ័យជំនះ ឯគំនិតខ្ញុំបាទដែលនឹងគិតរក្សាស្រុកឈើវាដីវានេះត្រូវតែស៊ូនឹងអ្នកសុតមានទុច្ចាយទៅទៀត ។ លោ"សួរថាកល់ទុច្ចាយរបស់អ្នកគិតធ្វើដូចម្តេចខ្លះ? ។

តាន់គុយជំរាបថា ហាន់សៀមនឹងអៀវហង ២ នាក់នេះ ពីដើមនៅធ្វើទ្រឹក្សាការព្រះចៅហៀនតេ លុះបូធូរធ្វើទុក្ខបៀតបៀនគ្នានឹពីនឹពុំនាក់ក៏នាំគ្នារត់មកពឹងបុណ្យអ្នកសុត។ ក៏មិនបានដប់លៀងតាមគុណបំណាច់នឹងដំរេះប្តាជ្ញាឲ្យដល់ខ្នាត ខ្ញុំបានឃើញថា ហាន់សៀមនឹងអៀវហង មិនមែនតាំងចិត្តទៀងត្រង់នឹងអ្នកសុតប៉ុន្មាន សុំឲ្យលោកមានសំបុត្រជាសម្ងាត់ទៅដល់ហាន់សៀមនឹងអៀវហងថា បើវេលាណាខ្លួនលោកនឹងអ្នកសុតចេញច្បាំងនឹងគ្នា ឲ្យហាន់សៀមនឹងអៀវហងគិតធ្វើទុច្ចាយជាកលសឹកខាងក្នុង ហើយឲ្យលោកមានសំបុត្រទៅដល់ទ្លៀតីឲ្យទ្លៀពី, គួនអ៊ូ, តៀវហ៊ុយ លើកទំពមកដួយវាយខ្ទប់ពីក្រោយទ័ពអ្នកសុត មុខជាអ្នកសុតទឹងបរាជ័យមិនខាន ។

លោ"យល់ឃើញត្រូវ ក៏ធ្វើសំបុត្រចាត់ប្រៃតាន់តេងឲ្យលបចេញទៅឲ្យហាន់សៀមនឹងអៀវហង ដែលលើកទ័ពទៅវាយស្រុកហៃហ៊ីនឹងស្រុកជុនសួ ហើយប្រើតាហានឲ្យកាន់សំបុត្រចូលទៅក្រងហ៊ូតោ ជួន

ដំណឹងដល់ចូរ ១ ច្បាប់ទៅដល់ខ្មៅពីនៅស្រុកអ៊ីដាវ ១ ច្បាប់ ។ លុះតាន់
តេងបានសំបុត្រនឹងតាហាន ៣ នាក់ កំលះចេញទៅស្រុកហៃហ្វីមុន,
ទទួលហាន់សៀមលើកទ័ពទៅដល់ស្រុកហៃហ្វី តាំងបន្ទាយនៅក្រៅ
កំពែងស្រុក ។ តាន់តេងក៏ចូលទៅដួបនឹងហាន់សៀមក្នុងបន្ទាយ ហាន់
សៀមក៏សួរតាន់តេងថា អ្នកឯងនេះក្រែងជាពួកម៉ាកលីប៉ោទេ ហេតុម្តេច
ក៏ចូលមកក្នុងបន្ទាយយើងនឹង? ។ តាន់តេងសើចហើយថាខ្ញុំជាខ្ញុំព្រះចៅ
ហៀនតេទេ ហេតុម្តេចអ្នកថាជាពួកម៉ាកលីប៉ោវិញ ខ្លួនខ្ញុំនឹងអ្នកក៏ដូចគ្នា
ព្រោះអ្នកបានទៅធ្វើជាខ្ញុំរាជការព្រះចៅហៀនតេ កាលទ្រង់សោយទុក្ខ
លំបាកនៅទីគយគួនតុង អ្នកក៏បានជួយឲ្យព្រះអង្គរួចពាកទុក្ខ ខ្លួនអ្នកក៏
ទៅមានគុណបំណាច់នឹងផែនដី ដូចជាបក្សីបានសម្បុកនឹងទ្រនំហើយ
ម្តេចឡើយក៏អ្នកមកលះបង់សម្បុកទ្រនំ មកនិយមនៅនឹងអ៊ួនសុតជា
មនុស្សអកតញ្ញូកូតផែនដី ខ្ញុំឃើញការនេះគប្បីដូច្នេះបានជាចូលមក
ដើម្បីនឹងជាសត្រឿនសត្វអ្នក ព្រោះខ្ញុំឃើញថា បើអ្នកនឹងជ្រកនៅក្នុង
ម្ល៉ាអ៊ួនសុតតទៅ អ្នកក៏គង់មានសេចក្តីទុក្ខភ័យលំបាកទៅខាងមុខ បើ
អ្នកចង់ឲ្យរួចពាកទុក្ខជាសុខតទៅត្រូវតែគិតឲ្យហើយជាមុន ទើបផុតរួច
ពាកកណ្តាប់ដៃអ៊ួនសុតបាន ។

ហាន់សៀមបានឮតាន់តេងសំដែងពីរឿងដើមពាំងប៉ុន្មាន ក៏មាន
សេចក្តីរលឹកនឹកឃើញសព្វគ្រប់ ជាក់មុខសូតសប់ហើយដកដង្ហើមធំ

និយាយថា ខ្ញុំសព្វថ្ងៃនេះក៏រិះគិតមិនក្ខេចដែរ តែថាបានជាជ្រុលខ្លួនមក
ទៅនឹងអ្នកសុតហើយ មិនដឹងឡើយដែលនឹងគិតដូចម្តេច ការនេះស្រេច
តែអ្នកជួយគិតខ្ញុំផង ។ គាន់តេង៉យល់អធ្យាស្រ័យហូតយកសំបុត្រលីវ៉ោ"
ហុចឲ្យទៅហាន់សៀម។ មើលដឹងសេចក្តីច្បាស់ក៏ផ្ទាស់ចិត្តខ្លួនប៉ះវង់ថា
ការនោះកុំព្រួយ ចាំខ្ញុំទៅរិះគិតនឹងអៀវហង៉ទៀត អ្នកចូរឆ្ងៀតទៅជំរាបុ
លីវ៉ោ"ចុះថា ការនោះខ្ញុំខ្លួលជាធុរៈហើយ ប្រើកាលណាលីវ៉ោ"ចូល
វាយត្រង់គយនោះ ខ្ញុំនឹងជួយធ្វើការនោះឲ្យសម្រេច ។ គាន់តេង៉មាន
សេចក្តីត្រេកអរជាពន្លឹក ហើយក៏ធ្វើសេចក្តីគារវៈគំនាប់ហាន់សៀម
ហើយលាចេញទៅយកសេចក្តីនោះមកជំរាបលីវ៉ោ"គ្រប់ប្រការ ។

ខណៈនោះ លីវ៉ោ"ប្រមូលសេនាគាហានបានមួយម៉ឺនចូរយ បំបែក
ទ័ពចេញជា ៤ កង ឲ្យកោស៊ុនលើកទ័ពទៅជួយស្រុកសៀវផាយ ចាំង
នឹងកៀរសេង ១ កង, ឲ្យគាន់កុងលើកទ័ពទៅជួយស្រុកគិនតោ ចាំង
នឹងគាន់គី ១ កង, ឲ្យតៀវសៀវលើកទៅជួយស្រុកឡងអៀ ចាំងនឹង
លុយប៉ុក ១ កង, ឲ្យស៊ុនហៀន ឆុយសុកលើកទៅជួយស្រុកកៀតសិក
ចាំងនឹងគាន់ឡាន់ ១ កង ខ្លួនលីវ៉ោ"ប្រមូលសេនាគាហានដែលមានចូរដៃ
លើកចេញទៅតាំងបន្ទាយនៅខាងត្រៀកំពែងស្រុក ចម្ងាយប្រហែល
៣០០ សិន (១២ គី ម.) ។ លុះតៀវហ៊ុនលើកទ័ពមកដល់បន្ទាយលីវ៉ោ"
ក៏ប្រើគាហានឲ្យចូលទៅហៅលីវ៉ោ"ចេញមកចាំងគ្នា ។ (មានត)

រឿងអាវ៉ក្សព្រ៉ែងរឿងម្ភៃក្រាំ

លោករ៉ាយ-ប៊ុក ក្រមការ នៅក្រុមពុទ្ធសាសនបណ្ឌិត្យ

ប្រែពីបាកំងមកជាខ្មែរ

(តមក)

រឿងទីដប់ប្រាំ

អាវ៉ក្សក្រាបទូលថា: បពិត្រមហាកជ! នៅលើគីរីមួយឈ្មោះហិម-ចល: (Himachal) គេបានស្គាបនាទូវព្រះពជធានីមួយជាមណ្ឌល នៃពួកគន្ធ៌ព្វ (ទេវតាបុាំ) ដែលមានព្រះបាទជិមុតកេតុ (Jimutkêtu) សោយរាជសម្បត្តិនៅទីនោះ ។ ដោយទ្រង់មានព្រះរាជដំណាងចង់បានព្រះរាជបុត្រមួយព្រះអង្គ, ព្រះមហាក្សត្រអង្គនេះទ្រង់ក៏បានធ្វើសក្ការបូជាជានិ.ន្តរ៍ចំពោះទេវតានាម កល្បវ្រិក្ស (Kalpa-Prisksh) ។ មានមួយថ្ងៃទេវរូបនេះ មានព្រះទ័យសោមនស្សពន់ពេក, ហើយក៏មានទេវាចាទៅកាន់ព្រះមហាក្សត្រថា: "បពិត្រមហាកជ! យើងខ្ញុំបានយើញប្បាសន៍ទូវករណីយកិច្ច ដែលមហាកជធ្វើចំពោះខ្ញុំ, យើងខ្ញុំអនុញ្ញាត ឲ្យទ្រង់សូមសេចក្តីអនុគ្រោះអ្វីមួយ, យើងខ្ញុំនឹងថ្វាយទ្រង់តាមព្រះរាជបំណង" ។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលថា: "សូមទ្រង់ព្រះមេត្តាធ្វើ-អំណោយនូវព្រះរាជបុត្រមួយអង្គដើម្បីនឹងតសន្ដតិវង្ស សោយរាជសម្បត្តិស្នងយើងខ្ញុំតទៅអនាគត" ។

ទេវរូបនោះក៏មានទេវបញ្ជាថា: "សូមឲ្យបានសម្រេចតាមព្រះរាជចំណង" ។

មិនយូរប៉ុន្មាន ព្រះអគ្គមហេសីព្រះអង្គទ្រង់មានគភ៌ ហើយក៏ប្រសូតព្រះរាជបុត្រ ។ ព្រឹត្តិការណ៍នេះ, ព្រះមហាក្សត្រទ្រង់គ្រាស់បង្គាប់ឲ្យរៀបធ្វើពិធីជាទ្វេភាវិក ហើយទ្រង់មានព្រះរាជហឫទ័យសោមនស្សពន់ពេក ។ ក្នុងពិធីបុណ្យនោះ ទ្រង់ក៏បានគ្រាស់បង្គាប់ឲ្យយកភោគៈក្ងែងជូរ្យតន្ត្រី, ព្រះរាជទានអំណោយជាច្រើនវែបច្រើនយ៉ាង, ព្រមទាំងធ្វើបុណ្យកុសលក្នុងសាសនាថែមទៀតផង ។ ទ្រង់មានព្រះបន្ទូលឲ្យហៅព្រាហ្មណ៍មកដើម្បីនឹងដាក់ព្រះនាមព្រះរាជបុត្រ ហើយព្រាហ្មណ៍ទាំងនោះបានដាក់ព្រះនាមថា: ជិមូតពាហន (Jimutbahan) ។ លុះព្រះរាជបុត្រមានព្រះជន្មាយុដប់ពីរឆ្នាំ ទ្រង់ត្រូវគោរពចំពោះព្រះសិរៈជាមុន ។ ទ្រង់បានមប់នៃវិទ្យាសាស្ត្រទាំងអស់ ហើយមានព្រះប្រាជ្ញាដ៏មុតមាំខាងការពិចារណា, មានព្រះទ័យមុឺងម៉ាត់ក្នុងហាន, ភ្លៀវក្លា ព្រះទ័យខន់ក្នុងខាងសាសនា យល់កិច្ចការពាក់ព្រៀងសព្វយ៉ាង ។ ចំពោះព្រះប្រាជ្ញាគ្មានអ្នកណាអាចប្រៀបធៀបនឹងព្រះអង្គបានឡើយ ហើយប្រជាពលស្ត្រទាំងអស់ក្នុងព្រះរាជអាណាចក្រ ក៏ប្រតិត្តការណ៍យកតិច្ចសព្វ ។ ខ្ញុំ ។

ព្រះអង្គម្ចាស់ទ្រង់ស្ថិតនៅក្នុងយុវនភាព តែទ្រង់គោរពរាប់អានជា

និវត្តន៍ នូវទេវតាឈ្មោះ កល្យាណិកៈ ។ ទេវរូបនេះមានទេវបញ្ញាថា: "ខ្ញុំមានព្រះទ័យប្តូរថ្នាអ្វី សឹងបានតាមប្តូរថ្នា" ។

ព្រះអគ្គមហាសេនាបតីទេវតាវិញថា: "បើខ្ញុំសព្វព្រះពុទ្ធហឫទ័យនឹងខ្ញុំ សូមខ្ញុំធ្វើឲ្យខ្មាំងកំណាចរួចចេញឆ្ងាយពីប្រជាពលស្តេចរបស់ខ្ញុំ ហើយឲ្យប្រជាពលស្តេចរបស់ខ្ញុំមានកាលទេព្យស្មើៗគ្នា" ។

ទេវតាកល្យាណិកៈខ្ញុំអនុគ្រោះព្រះអគ្គមហាសេនាតាមព្រះពុទ្ធបំណង ហើយប្រជាពលស្តេចសុខស្រួលពន់ពេក ទាល់តែគ្មានអ្នកណាចង់ប្រតិបត្តិតាមព្រះបន្ទូលព្រះអង្គ ព្រមទាំងគ្មានធ្វើការអ្វីសោះឡើយ ។ ពួកប្រជាពលស្តេចក្នុងព្រះពុទ្ធអាណាចក្រ តែឮប់ទៅជាមានចរិយាការចសាមន្យដោយព្រះរឿមនឹងព្រះពុទ្ធវង្សានុវង្សបានញុះញង់ គឺថាប្រជាពលស្តេចនោះគិតថា ព្រះបរមពុទ្ធបិតានឹងព្រះពុទ្ធបុត្រទាំងពីរព្រះអង្គ ខ្ញុំកាន់សាសនាជាប្រមុខ, ហើយប្រជាពលស្តេចលែងស្តាប់ធ្វើតាមព្រះពុទ្ធឱវាទ, យើងនឹងព្រះពុទ្ធបុត្រត្រូវតែចាប់ព្រះមហាក្សត្រយកទៅឃុំឃាំង ហើយដណ្តើមយកពុទ្ធសម្បត្តិ ។

ព្រះមហាក្សត្រខ្ញុំមិនបានជ្រាបនូវរឿងនោះ ខ្ញុំក៏មិនបានប្រុងប្រយ័ត្នការពារព្រះអគ្គីឡើយ, ស្រាប់តែពួកឧត្តមចាត់ការងឹងមាំព្រះបរមពុទ្ធាំង ។

កាលទ្រង់ជ្រាបនូវដំណឹងនេះ, ទ្រង់ក៏បានសួរព្រះពជបុត្រថា: "តើយើងគិតយ៉ាងណា?" ។

ព្រះអគ្គមហាសេនាបតីក្រាបបង្គំទូលព្រះវរបិតាថា "សូមព្រះវរបិតាគង់នៅទីនេះហើយ ទ្រង់កុំខ្វាចអ្វីឡើយ, ទូលបង្គំនឹងយកពលកាពនៃគុណសម្បត្តិ ព្រះវរបិតាទៅផ្ចាញ់ពួកខ្មាំងឲ្យបានជោគជ័យ" ។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលទៅព្រះពជបុត្រថា: "ឧកូន! រូបកាយនេះជាអនិច្ចតាធម៌ ហើយកោគទ្រព្យក៏មិនទៀង, បើមានសត្វបដិសន្ធិ ទៀងតែសត្វនោះអនិច្ចកម្ម, ឥឡូវយើងត្រូវទុកដោយឡែក ហើយយើងត្រូវចូលសិប់ទៅកង់សាសនាតែម្តង, យើងមិនត្រូវប្រព្រឹត្តបាបអកុសលធំៗ ព្រោះតែសេចក្តីស្នេហានៃរូបកាយ ហើយទឹងព្រះពជ-អាណាចក្រប៉ុណ្ណោះទេ; ព្រះមហាក្សត្រ យុធិស្ឋិរ: (yûdhishthir) ទ្រង់បានសោកស្តាយជាច្រើនលើកច្រើនគ្រាអំពីសង្គ្រាមដែលសន្ធតិវង្ស "ការវត" ប្លាននូវីអតីតកាលមក" ។

ព្រះពជបុត្រទ្រង់ព្រះសណ្តាប់នូវព្រះបន្ទូលព្រះវរបិតាហើយ ទើបទ្រង់ក្រាបទូលតបវិញថា: "ព្រះឧង្ការនៃព្រះវរបិតាគេញាត្រូវមែន, ត្រូវលះបង់ពជសម្បត្តិឲ្យទៅព្រះពជវង្សានុវង្ស ហើយទ្រង់យាងទៅធ្វើឥសី" ។

លុះបានសម្រេចព្រះពរជបំណងហើយ, ព្រះមហាក្សត្រខ្មែរតែងតាស់បង្គាប់ឲ្យអញ្ជើញព្រះជង្ហានទីព្រះអនុជ ព្រមទាំងព្រះភគិនេយ្យមក, ខ្មែរព្រះពរជទានទូវរជ្ជាភិបាល រួចព្រះវរបិតានឹងព្រះពរជបុត្រខ្មែរចេញពីព្រះបរមពរជវាំងទាំងពីរព្រះអង្គតម្រង់ទៅលើកំពូលមួយឈ្មោះ មលយចល: (Malayachal) ខ្មែរបានឲ្យសាងអាស្រមហើយក៏គង់ទៅទីនោះ ។

ព្រះអង្គម្ចាស់ជិមុតពហ័ន ខ្មែរបានរក្សាមេត្រីភាពនឹងបុត្រឫសីម្នាក់ ។ មានកាលមួយថ្ងៃ, ព្រះអង្គម្ចាស់ខ្មែរបានគ្រាច់ទៅក្រសាលលើកំពូលនោះ ជាមួយនឹងបុត្រឫសី ខ្មែរបានឧតទៅឃើញបូជនីយដ្ឋានមួយដែលគេសាងសម្រាប់ព្រះនាងភវានី (Bhavâni) ។ ទៅកន្លែងបូជនីយដ្ឋាននេះ, មានព្រះពរជបុត្រីព្រះមហាក្សត្រមួយអង្គ ខ្មែរកំពុងថ្វៃងចំពោះព្រះកត្តិនាងទេវធីតា ដោយផ្ការត់ចាប៉ីផង ។ ព្រះចក្ខុព្រះនាងឧតទៅឃល់ព្រះអង្គម្ចាស់ ជិមុតពហ័នហើយ ខ្មែរទាំងពីរក៏កុកកណ្តូលក្នុងព្រះទ័យដោយកាមតណ្ហាពន់ពេក, តែព្រះអង្គម្ចាស់ក្សត្រី ខ្មែរខំទប់ទូរមនោសញ្ចេតនារបស់នាង, ក៏វិលត្រឡប់ទៅកាន់ព្រះបរមពរជវាំងវិញ ។ ចំណែកព្រះអង្គម្ចាស់ជិមុតពហ័នខ្វាសអៀនពន់ពេក ក៏វិលត្រឡប់ទៅកាន់អាស្រមវិញជាមួយនឹងបុត្រឫសី ហើយខ្មែរក៏ផ្ទុលក់ក្នុងយប់នោះត្រមទាំងបុត្រឫសីដោយកង្វល់ក្នុងព្រះទ័យជាខ្លាំង ។ លុះដល់បុព្វណ្ហសម័យ, ព្រះអង្គម្ចាស់ក្សត្រីខ្មែរស្តេចទៅកាន់បូជនីយដ្ឋាន ព្រះអង្គម្ចាស់ជិមុតពហ័នក៏យាង

ទៅទីនោះដែរ ។ ព្រះអគ្គមហេសីទ្រង់ទតឃើញព្រះនាងហើយ ក៏ទ្រង់មានបន្ទូលសួរពីព្រះជន្មព្រះនាង ។

ព្រះនាងក្រាបទូលថា: "ខ្ញុំនាមនាង មលយវតី (malayavati) ជាព្រះរាជបុត្រីព្រះបាទមលយកេតុ (Malayakêtu) ហើយនាងខ្ញុំនៅក្នុងវ័យនៅឡើយ" ។

កាលព្រះនាងក្រាបទូលព្រះអគ្គមហេសីរួចហើយ ក៏មានបន្ទូលសួរទៅព្រះអគ្គមហេសីវិញថា: "អ្នកកម្ងោះមកពីណា? ឈ្មោះអ្វី?" ។

ព្រះអគ្គមហេសីទូលតបទៅព្រះនាងវិញថា: "ខ្ញុំឈ្មោះដំមុតពហ័ន ជាព្រះរាជបុត្រព្រះបាទដំមុតកេតុ មហាក្សត្រ នៅពិទ្យាធរ: (Bidyadharas), ព្រះវរបិតាខ្ញុំបានយាងមកគង់ទីនេះជាមួយនឹងខ្ញុំ ក្រោយដែលគេដណ្តើមយកពាជសម្បត្តិ" ។ នាងកិលេងម្នាក់ក្រាបទូលព្រះនាងឲ្យជ្រាបសព្វគ្រប់ប្រការ នូវព្រះបន្ទូលព្រះអគ្គមហេសី ។ ព្រះនាងទ្រង់ព្រួយព្រះហឫទ័យពន់ពេក, រួចត្រឡប់ទៅព្រះបរមពាជវាំងវិញ ។ ដល់ពេលយប់, ព្រះនាងទ្រង់ព្រះតម្រិះអំពីរឿងនេះ ក៏ទ្រង់ផ្ទំលក់ទៅ ។ នាងសហជាតិនីកាលបានយល់ព្រះនាងព្រួយព្រះទ័យពន់ពេក ក៏ទៅក្រាបបង្គំទូលព្រះបរមពាជមាតា ។ ទ្រង់ក៏ក្រាបបង្គំទូលព្រះមហាក្សត្រថា: 'សូមទ្រង់ព្រះមេត្តាប្រោស! កូនស្រីអាយុល្មមរកស្វាមីឲ្យហើយ, ហេតុម្តេចក៏ព្រះអង្គទ្រង់មិនមានព្រះតម្រិះរកបុរសណាល្មមឲ្យជាស្វាមីកូនស្រីយើង?" ។

ព្រះមហាក្សត្រខ្ញុំព្រះសណ្ដាប់ហើយក៏មានព្រះបន្ទូលបាត់ឲ្យទៅ
ហៅព្រះរាជបុត្រព្រះនាម មិត្រាវសុ (Mitravasu) ហើយខ្ញុំត្រាស់
បង្គាប់ឲ្យទៅរកស្វាមីឲ្យនាង ។

ព្រះអគ្គមហេសីខ្ញុំក្រាបបង្គំទូលព្រះវរបិតាថា: "ទូលព្រះបង្គំបាន
ដំណឹងថា ព្រះបាទដិមុតរកេតុនឹងព្រះរាជបុត្រដិមុតពហ័ន ខ្ញុំស្តេច
យាងមករកនាន់ពីនេះ ក្រោយដែលចេញចោលរាជសម្បត្តិ" ។

ព្រះបាទមលយរកេតុខ្ញុំមានបន្ទូលថា: "បិតានឹងឲ្យកូនស្រីទៅព្រះ
អគ្គមហេសីដិមុតពហ័ន" ។

រួចខ្ញុំត្រាស់បង្គាប់ព្រះរាជបុត្រឲ្យទៅរកព្រះអគ្គមហេសីដិមុតពហ័ន។
ព្រះរាជបុត្រខ្ញុំស្តេចទៅដល់ក្រាបបង្គំទូលព្រះបាទដិមុតរកេតុ នូវព្រះ
រាជបំណងនៃព្រះបាទមលយរកេតុជាព្រះវរបិតា ។

ព្រះបាទដិមុតរកេតុខ្ញុំព្រះសណ្ដាប់ហើយ, ខ្ញុំក៏អនុញ្ញាត ឲ្យ
ព្រះរាជបុត្រស្តេចទៅជាមួយព្រះអគ្គមហេសីមិត្រាវសុ ។ លុះដល់ព្រះអគ្គ
មហេសីទាំងពីរខ្ញុំស្តេចទៅដល់ចំពោះព្រះកន្លែងព្រះបាទមលយរកេតុ ។ ក៏
ខ្ញុំត្រាស់បង្គាប់ឲ្យធ្វើពិធីព្រះរាជសមវាស ព្រះអគ្គមហេសីនឹងព្រះនាង
តាមទំនៀមគន្ធវិ «Gàndharva» ។

(មានត)

មាន ៣ ឈុត

លោកគង់-លឹម ឥស្សរិតសាលាគរុដ្ឋា ភ្នំពេញ តែង

(តពីលេខ ១២ ឆ្នាំ ១៩៥២)

ឆាកទី ៤

ភគា វណ៌នារី ភគី

ភគី

ចា"អង្គុយធ្វើអ្វីហ្នឹង? ចុះប្អូនខ្ញុំថ្លឹកដេកស្ដឹងស្កុកយា"ងនេះ? ។ អូន! អូន! ចា"ចា"! ម្ដេចក៏ចាត់មាត់ចាត់កស្វាត់ស្ងៀមយា"ងដូច្នេះ? (ដើរទៅមើលផ្នូរស្រាប់តែឃើញអក្សរស្លាកថាម្ដាយស្នាប់)

យីចា"! ម៉ា"ក់ខ្ញុំស្នាប់! ស្នាប់ពីថ្ងៃណាចា"? ម៉ា"ក់អើយ! ម៉ា"ក់ទទួលមរណភាពចោលខ្ញុំហើយ! អ្នកម្ដាយពុកឲ្យខ្ញុំកំព្រាវេទនាកង់លោកនេះហើយ, លោកឪពុក! ម្ដេចក៏លោកមិនច្រាបខ្ញុំ? ម្ដេចក៏លោកឪពុកចាំលាក់ធ្វើអ្វី? ។ អ្នកម្ដាយអកតាននឹកអាណិតដល់កូនបន្តិចមេ; អ្នកម្ដាយអើយ! ខ្ញុំលែងបានឃើញមុខអ្នកម្ដាយទៀតហើយ ។ លោកចា"! លោកចា"ជាមនុស្សអាក្រក់ណាស់, ម្ដាយខ្ញុំស្នាប់ ចា"មិនច្រាបខ្ញុំទេ ។ ម៉ា"ក់អើយខ្ញុំមិនចង់នៅរស់ទេ ។

វាគា

ឧត្រែះអើយ! មួយទៀតហើយ! កូនប្រុសមាសឧពុក! ប្អូរកូនអាណិតដល់ចិត្តឧពុកផង ឧពុកតឹងកូនខ្លែងណាស់! ឧពុកទទួលកំហុសទាំងអស់ ឧពុកទទួលទោសទាំងអស់កូន! ប្អូរកូនកុំប្រកាន់ខឹងនឹងឧពុកធ្វើអ្វី ។

វាគី

លោកឧពុកមិនគួរធ្វើយ៉ាងដូច្នេះសោះ! បើទុកជាម្តេចម្តា ក៏គួរតែលោកឧពុកប្រាប់ខ្ញុំជាកូនឲ្យដឹងផងដែរ ។ លោកឧពុកមិនគួរនឹងណាក់យ៉ាងដូច្នេះទេ! ។ បើប្រាប់ខ្ញុំមក ខ្ញុំឥតមានថាអ្វីទេ ធ្វើម្តេចរូបមនុស្សយើង តែងតែមានព្រាត់ប្រាសទាំងសចាកចោលគ្នាយ៉ាងដូច្នេះជាធម្មតារូបណាក៏ដូចជារូបណាដែរ តើតមកជាមនុស្សក្នុងវដ្តសង្សារពិភពលោកសន្ធាប់សយើងនេះ មិនអាចនរណាមួយចៀសឲ្យផុតអំពីសេចក្តីស្លាប់បានទេ! ។ កុំថាតែយើងជាមនុស្សបុថុជ្ជន ទុកជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ក៏ដោយ គង់តែព្រះយាងចូលនិព្វានដែរ ។

វាគា

ឧកូនមាសឧពុក! អ្នកយល់ត្រូវណាស់ ។ រឿងនេះឧពុកមិនបានប្រាប់កូនឲ្យដឹងព្រោះឧពុកអាណិតកូនណាស់ ។ បើគាលណាប៉ាប្រាប់ឯងទៅ មុខជាឯងនឹងកើតទុក្ខ ហើយឯងនឹងប្រកបការរៀនសូត្រមិនបានចម្រើន, ហេតុនេះហើយបានជាប៉ាមិនប្រាប់ឯង ។

រាគី

លោកឧពុក! សេចក្តីទុក្ខសោកកើតមានឡើង ចំពោះរូបមនុស្សណាដែលគ្មានចេះពិចារណាគិតឲ្យឃើញវែងឆ្ងាយទេ ។ បើកាលណាគេគិតពិចារណាឲ្យវែងឆ្ងាយតាមគន្ថ៍ចប្បាប់ព្រះសម្មាសម្ពុទ្ធទៅទុះ ប្រហែលជាគេមិនសូវកើតទុក្ខប៉ុន្មានទេថា"! ។

រាគា

នែកូន! ឯងត្រូវត្រៃឡប់ទៅហៅដីដូនឯងមក ឲ្យជួយមើលនាងវណ្ណានីផង ថាវាយំសន្ធប់ប្តាត់មាត់ប្តាត់កទៅហើយ ឲ្យគាត់ផាប់អញ្ជើញមក ។ កូនខ្ញុំក្មេងតែខ្លួនទេ! តែចេះពិចារណាគិតឃើញវែងឆ្ងាយល្អណាស់, ចេះយកផ្លូវធម៌មកនិយាយពន្យល់ខ្ញុំផង ។ ឯសេចក្តីទុក្ខសោករបស់រាក៏ពុំសូវកើតមានឡើងប៉ុន្មានដល់រូបវាទេ រាមិនកើតទុក្ខប៉ុន្មានទេ ។ គួបតែខ្លួន តែគំនិតចេះគិតទៅវែងឆ្ងាយ ។

កូន! វណ្ណានីកូន! កូនមាសឧពុក! កូនគ្រាកឡើង អាណិតប៉ាទៅកូន! កុំយំកុំសោកច្រើនពេក! នាំឲ្យទៅជាឈឺឆ្អាត់ កុំឲ្យប៉ាព្រួយចិត្តច្រើនពេក ។ ធ្លើម្តេចរូបមនុស្សយើងតែកើតឡើងមកហើយតែងតែវិនាសទៅវិញជាធម្មតា មិនដែលមានរូបណាមានខ្ចីមសារធ៌ស្ថិតថេរទៅវែងឆ្ងាយនោះទេ ។

វិណ្ណាវី

(និយាយទាំងយំ) ខ្ញុំចង់តែវាយបាំងឯងឲ្យស្លាប់ទៅជាមួយនឹងម៉ាក់ឥឡូវហ្នឹង, ស្អប់ណាស់គ្រាន់តែម៉ាក់ខ្ញុំស្លាប់ ចាំងឯងមិនគ្រាប់ខ្ញុំឲ្យដឹងទេ, លាក់ណាស់! លាក់ទុកធ្វើអ្វី? ខ្លាចខ្ញុំស៊ីចាំងឯងឬ?

រាគា

ចាំខ្លាចកូនឯងកើតទុក្ខហើយឈប់លែងរៀន ចានជាចាំមិនគ្រាប់ឲ្យកូនដឹង ។

វិណ្ណាវី

ខ្ញុំលែងរៀនហើយចា! ខ្ញុំលែងទៅផ្ទះហើយ! ។ ខ្ញុំនៅគេងនឹងផ្ទះម៉ាក់ហ្នឹងជាដរាប ចាំឯងទៅផ្ទះចុះ ។

រាគា

កូនឯងមិនខ្លាចខ្មោចទេឬ? នៅហ្នឹងខ្មោចច្រើនណាស់ តែព្រលប់ឡើងសឹងមិនទាន់ទេ វាចេញដើរច្រកត់ច្រវែងពេញផ្លែ ។

វិណ្ណាវី

ខ្មោចឯណានឹងហ៊ានលង បើខ្ញុំនៅជេតជាមួយនឹងម៉ាក់ ។

រាគា

ខុ! ខ្មោចម៉ាក់ឯងលងហួសខ្មោចគេដទៃទាំងអស់, ឯងមិនឃើញទេពីព្រឹកមិញនេះទៅលងឯងនំពុងរៀន ឲ្យឃើញស្រស់ៗនឹងភ្នែក ។

ខ្ញុំចម៉ាក់ឯងហ្នឹងលង់សម្បើមហើយ! កូនវៃហ្នឹងមានតែមួយទេ! ពីព្រោះខ្ញុំចនៅថ្មីៗ លង់សម្បើមណាស់ កុំនៅដេកធ្វើអ្វីកូន! ដេកមិនបានទេ បើកូនឧកណាស់ ចាំពេលល្ងាចត្រជាក់ ប៉ាឲ្យគេធ្វើម្ហូបអាហារចំណីមួយស្រាក់ឲ្យកូនយកមកសែនឲ្យម៉ាក់ឯង ពាល់តែថ្ងៃក៏បានដែរ ។ តែឯងនៅដេកពុំបានទេ ។

រាគី

យី! វណ្ណនារី អូនដឹងខ្លួនហើយ, លោកប៉ា! អូនដឹងខ្លួនហើយឬ?

រាគា

វាទើបតែនឹងដឹងខ្លួនអំបាញ់មិញនេះទេ ។

រាគី

ស្ងាប់ហើយ លោកយាយខំរត់ទៅរកហៅពេទ្យប៉ាត់ទៅហ៊ាយ ។

រាគា

បើដូច្នេះ ឯងរត់ទៅជំរាបលោកយាយឯងឲ្យឆាប់ទៅ! ថានាងវណ្ណនារីដឹងខ្លួនហើយ! កុំឲ្យគាត់ឆ្ងល់ពេក ។

នែកូនស្រីប៉ា! ចូរកូនលុតជង្គង់សំពះសូមទោសនឹងអ្នកម្តាយឯងទៅ កុំឲ្យម៉ាក់ឯងមានទោសទុក្ខអ្វី! លើអំពើណាដែលម៉ាក់ឯងបានប្រព្រឹត្តកន្លងនឹងឯង ។ ហើយឯងក៏យ៉ាងដូច្នេះដែរ ត្រូវតែឯងសូម

ខមាទោសទឹងម៉ាក់ឯងវិញ លើសំដីណាក្រែងឯងបានពោលទ្រគោះចោះ
ចោកឲ្យម៉ាក់ឯងកាលពីពេលមុន សូមកុំឲ្យមានទោសទាំងអស់គ្នា . . .

(នាងវណ្ណនារីក៏លុតជង្គង់ធ្វើតាមពាក្យនុពុក)

កូនស្រីចា៎ ! កូនពុំបានដឹងទេ, មិនត្រានៅតែឯងទាំងពីរនេះទេដែល
ពុំដឹងជាម្តាយឯងស្លាប់នោះ ចំណែកចា៎ក៏យ៉ាងដូច្នេះដែរ ចា៎ឥតបាន
បានដង្ហើមម៉ាក់ឯងទេ ចា៎ឥតបានឃើញមុខម៉ាក់ឯងបន្តិចទេ មិនដឹងជា
ស្រកសាច់ចុះស្គមឬមួយទៅជដែល, ចា៎ឥតបានដឹងទេ ពីព្រោះចា៎មក
មិនបានដែរ ចា៎មកដល់គេយកភ្លោចម្តាយឯងមកបញ្ចុះរួចទៅហើយ ។

កូនមិនបានដឹងទេ, ម្តាយកូនឯងចិត្តស្ងួតណាស់ ហ៊ានឲ្យចា៎ចេញ
ទៅធ្វើសឹកសង្គ្រាម កងពេលដែលកំពុងមានជម្ងឺឈឺទៅហើយ ។ សុខ
ចិត្តស៊ូស្លាប់ដោយសារជាតិ, ឲ្យតែជាតិបានសុខ, មិនសុខចិត្តឲ្យចា៎នៅ
ថែជម្ងឺទេ, ស៊ូទៅដេកថ្កូរម្នាក់ឯង ឲ្យតែចា៎បានទៅធ្វើការបំពេញកិច្ចដល់
មាតុភូមិ ។ ម៉ាក់ឯងស្លាប់យ៉ាងដូច្នេះ ប្រសើរណាស់កូន ! ។

វណ្ណនារី

ខ្ញុំចិត្តដូចម៉ាក់ខ្ញុំដែរចា៎ ! ដល់ខ្ញុំធំឡើង ។

(មានត)

រឿងរ៉ូល ធីង វ៉ីស៊ុនី

លោកផេង - ជ្រឿ សាស្ត្រាចារ្យទៀសាលាគរុជ្ជៃ ភ្នំពេញ

ប្រែរៀបរៀង

(តពីលេខ១១២ ឆ្នាំ ១៩៥២)

ហើយវាបេះដូងខ្ញុំយ៉ាងស្អាតពិរោះផ្ទៃទៅឲ្យផង តែផ្ទៃដំណាំឯទៀតនៅកោះ វាមិនផ្ទើទៅទេ ដោយគិតថាបំណងចង់ឃើញផ្ទៃទាំងនោះនាំឲ្យនាងវិលត្រឡប់ធាប់ ។ វាសុំអង្វរឲ្យនាងត្រឡប់ធាប់តាមពាក្យបន់ស្រន់នៃក្រុមត្រកូល តែខ្លួនវាបន់ជាងគេ ដ្បិតវាគ្មានសប្បាយសោះ នៅឆ្ងាយពីនាង ។

អាប៉ូលយកពូជដំណាំពីអឺរុបទៅសាបព្រោះដោយសេចក្តីមធ្យត តែវាយកចិត្តទុកដាក់ជាងគេ តែផ្កាវិយ៉ូឡែត ធីង ស្តុបប៊្រយើ ព្រោះមានទំនងរឿងប្រហែលគ្នាធីង វ៉ីស៊ុនី ។ តែមិនដឹងជាស្មុយពន្លកតាមផ្លូវឬជាធាតុអាកាសនៅខាងស្រុកអង្គ្លេតមិនសូវល្អ ឬានជាគេឃើញដុះតែបន្តិចបន្តួច មិនបានដុះឲ្យច្រើនដូចចិត្តចង់ ។

កាលពេលនោះ សេចក្តីច្រណែនដែលជាធម៌សម្រាប់ដើរទៅដំទាស់នៅពីមុខសេចក្តីសុខស្រួលនៃមនុស្សទាំងឡាយ ឬានផ្សាយដំណឹងកាលកោះ ជាដំណឹងដែលនាំឲ្យអាប៉ូលព្រួយពេក ។ គឺមនុស្សអ្នកជិះកង់ដែលកាន់សំបុត្រវ៉ីស៊ុនីយកមកឲ្យនិយាយថា វ៉ីស៊ុនី ជិតរៀបការ

ហើយ: ក្រែបាប់ឈ្មោះនាម៉ឺនដែលបំរុងយកវ៉ែស៊ុនីធ្វើជាប្រពន្ធ អ្នកខ្លះនិយាយថា រឿងហ្នឹងប្រាកដណាស់ គេហ៊ានធ្វើជាសាកូដែង ។ ដំបូងអាប៉ូលមិនជឿទេ ព្រោះថាពួកកប៉ាល់ដំនួញចេះតែកុហកនិយាយបន្លោត ។ តែដល់មនុស្សក្រុងគោះបបួលគ្នារត់ទៅប្រាប់អាប៉ូលអំពីរឿងហ្នឹង ហើយនាំគ្នាភ្ញាក់អ្នកអាណិត តែអ្នកអាណិតប្រកបដោយសេចក្តីប្រណែនៅខាងក្នុង ម្ល៉ោះហើយ អាប៉ូលក៏អត់ចំពាជឿមិនបាន ។ ម្យ៉ាងទៀត តាមក្នុងសាស្ត្រខ្លះដែលរ៉ាមើល រ៉ាឃើញមានសេចក្តីក្បត់ចិត្តខ្លះកើតមកពីពាក្យលេងសើច ហើយសាស្ត្រចាំងនោះ មានរឿងទំនៀមទម្លាប់សុចរិតគួរសមរ៉ាយរ៉ាប់ពីប្រទេសអ៊ីរុប រ៉ាខ្ចាចក្រែងកូនខាងឡាតួរខ្ចប់ខ្លួនៗលៅតាមគេ ក្រែចសំដីដើម ។ ការយល់ដូច្នេះនាំឲ្យរ៉ាកើតទុក្ខម្ដងទៀត ។ ដែលនាំឲ្យរ៉ាជឿជាក់ក្នុងចិត្តជាជាច់ស្រេច មកពីមិនបានដំណឹងសោះក្នុងរវាងប្រាំមួយខែ ។

អាប៉ូលដែលបណ្តាយឲ្យសេចក្តីទុក្ខញាំញីដូច្នេះ ក៏ចេះតែមកឯផ្ទះខ្ញុំឲ្យខ្ញុំជួយគិតមើល ជួយពិចារណាមើល តើត្រូវធ្វើដូចម្តេច ព្រោះខ្ញុំជាមនុស្សចាស់ (តាចាស់) យល់ការណ៍ច្រើន ។

ផ្ទះខ្ញុំសង់នៅមាត់ស្ទឹងដែលហូរតាមក្រុងវែង ចម្ងាយមួយគីឡូក្រុងពីផ្ទះអាប៉ូល ។ នៅទីហ្នឹងហើយដែលខ្ញុំរកទួលបានចិញ្ចឹមជីវិត តែម្នាក់ឯង គ្មានប្រពន្ធកូន គ្មានអ្នកបំរើឡើយ ។

ក្រៅពីសេចក្តីសុខស្រួលដែលនៅជាមួយច្រៀងចិត្តស្ងួតត្រង់គួរសម
បើចង់កុំឲ្យសូវមានទុក្ខ ច្បាកដណាស់ ឃើញតែនៅរកស៊ីម្នាក់ឯង
កុំឲ្យអ្នកណាមកជាពីរឡើយ ។ មនុស្សណាដែលរត់រកទីស្ងាត់ មកពី
ធុញច្រាន់ទឹងគ្នាច្រើន ។ មានមនុស្សច្រើនពួកណាស់ គួរលើកយក
មកពន្យល់ ដែលធុញច្រាន់ទឹងយោបល់ មតិច្រើនទឹងទំនៀមទម្លាប់
ទឹងផ្លូវរាជការពេកនាំគ្នាទៅកត្រកូលជាច្រើនដោយឡែក ជាប់ចិត្តនៅក្នុង
ទីស្ងាត់ ប្លុកស៊ីនៅលីវ ។ ដូចពួកអេស៊ីប្តជាន់ខាប ពួកក្រែកខាងស្រុក
ខាប: សព្វថ្ងៃនេះ ដូចពួកឥណ្ឌៀ ពួកចិន ពួកក្រែកសម័យថ្មី ពួកអ៊ីតាលី
ហើយនឹងមនុស្សនៅបុងបុញ្ចាប្រទេស ទឹងសាសនអ៊ីរុបខាងត្បូង ។ ការ
ហួតតែងនាំមកនូវសេចក្តីសុខស្រួលដល់មនុស្សជាតិ ហើយបញ្ចៀស
នូវសេចក្តីទុក្ខដែលកើតមកពីក្រុមពីគណៈ ។ នៅកណ្តាលពួកក្រុម
ទាំងឡាយដែលមានគំនិតបែកពីគ្នាជាច្រើនគណៈ ដួងព្រលឹងយើង
តែងញាប់ញ័រជាធម្មតា ដួងព្រលឹងវិលត្រឡប់ផ្តាប់ផ្សារមិនឈប់-ឈរ
មួយពាន់គំនិត តប់ប្រមល់ឃ្លាំឆ្នេង-ស្តាំ ទាស់គ្នាហើយមានពួកជនខ្វះ
នៃសង្គមចិត្តអភិជ្ឈាហួសប្រមាណ ហើយជាអ្នកក្រីក្រតែងស៊ីឡប់ពីគ្នា
ទៅវិញទៅមក ។ មានតែទីស្ងាត់ទេ ដែលអាចកំចាត់បង់នូវគំនិតអកុសល
ធ្វើដួងព្រលឹងឲ្យថ្លាបាន ។ ដួងចិត្តនេះវិលត្រឡប់ជាចិត្តថ្មី ហើយមាន
ពណ៌រស្មីដូចដើម ។ ឧបមាដូចវ៉ារីជ្រលងដ៏ល្អក់ហូរកាត់ទីវាល ធ្លាក់ចុះ

កន្ត្រែតាំងមួយឆ្ងាយពីផ្លូវទឹក ទឹកនោះមានកក់ភ្លាក់ទៅក្រោម ត្រឡប់ជាទឹកថ្លាដូចដើមគ្មុះមុខបាន ចាំងស្រមោលពៃនៅមាត់ត្រែតាំងតាំងប៉ុន្មាន មើលឃើញតាំងអស់ ។ មិនតែប៉ុណ្ណោះសោត សុញ្ញាដ្ឋានរៀបចំកាយ ភាវក្រៃឲ្យសមរម្យនឹងដួងចិត្តភាវកន្ត្រែផង ។ គឺកន្ត្រែពួកអ្នកស្វែងទីស្ងាត់ ហ្នឹងហើយដែលគេឃើញមានមនុស្សព្រុញការងារ ចោលឆ្ងាយពីខ្លួនជាច្រើន ដូចពួកព្រាហ្មណ៍កន្ត្រែប្រទេសកូឝ្ឝលជាដើម ។ នៅទីបំផុតខ្ញុំយល់ថា ការងារសំខាន់ណាស់ខាងនាំមកនូវសេចក្តីសុខស្រួលកន្ត្រែលោកមែន តែបើតាមយល់ថែមទៀត មើលទៅមិនងាយនឹងសោយសេចក្តីរីករាយកើតឡើងពីការងារបានបរិសុទ្ធឡើយ ទោះបីតាំងចិត្តដូចម្តេចក៏ដោយ ឬមួយក្តៀងកំរិយាមារយាទទៅលើច្បាប់យ៉ាងមិនកំរើកក៏ដោយ បើចិត្តខាងកន្ត្រែមិនស្ងប់ស្ងាត់សោះបណ្តាយឲ្យការយល់ទៅក្រៅ នឹងឲ្យការយល់ឃើញរបស់អ្នកជំទៃមកលុកលុយខាងកន្ត្រែ ។ ខ្ញុំមិនយល់ដោយដាច់ខាតថាមនុស្សត្រែតែរស់នៅកន្ត្រែទីស្ងាត់តែម្នាក់ឯងឡើយ:មនុស្សកើតមកសម្រាប់កិច្ចការតាំងឡាយ ដ្បិតព្រះជាម្ចាស់បង្កើតឲ្យយើងមានអាយតនៈគ្រប់គ្រាន់សមគួរដល់វត្តដែលមាននៅលើផែនដី ដូចជាដើងគួនឹងដី ស្មួតគួនឹងអាកាស ក្អែកគួនឹងពន្លឺ មិនចាំបាច់យើងពឹងការនៃគ្នាណាឲ្យមកជួយហើយបង្កើតចិត្តមួយជាអាយតនៈមួយជាមេលើដ៏ត្រែតាំងមូល ។

មនុស្សកើតឡើងសម្រាប់យើងច្រើន ទើងសម្រាប់ធ្វើបាបយើងផង ដូច្នេះបានជាខ្ញុំស៊ូនៅតែឯងឥតឮយព័មនុស្សទាំងឡាយនោះ ។ ខ្ញុំបានត្រាច់ចរក្នុងប្រទេសអ៊ីរុបអស់សឹងតែពាក់កណ្តាល ប្រទេសអាមេរិកខ្លះ ប្រទេសអាហ្វ្រិកខ្លះ រួចហើយបានខ្ញុំមកដោតសសរនៅក្នុងកោះនេះ ដែលមិនសូវមានមនុស្ស មានជាតុអាកាសស្រួលហើយស្ងាត់ផង ។ ខ្លួមដែលខ្ញុំសង់នៅក្នុងព្រៃ ក្បែរឈើមួយដើម មានចំការមួយតាប់ពានដោយដៃខ្ញុំ ស្មឹងមួយរហូតកាត់ចំពីមុខផ្ទះខ្ញុំ របស់ទាំងនេះល្មមសមគួរដល់សេចក្តីត្រូវការនឹងសេចក្តីរីករាយរបស់ខ្ញុំ ។ មានគម្ពីរយ៉ាងល្អពីរ-បីសម្រាប់ប្រដៅចិត្តគំនិតឲ្យជាមនុស្សស្លូតត្រង់ត្រឹមត្រូវ បន្ថែមលើសេចក្តីរីករាយខាងលើទៀត ។ សេចក្តីសុខស្រួលខ្ញុំកើតមកពីយកមនុស្សទាំងឡាយដែលខ្ញុំរត់ចោលមកជាប្រមាណផង ដោយបានៈមើលគម្ពីរដែលរៀបរាប់ឲ្យឃើញទៅមុខ ពីរឿងតណ្ហាជាជម្ងឺទាំមនុស្សឲ្យលំបាកវេទនាផង ដល់ខ្ញុំយកវាស្មាអ្នកទាំងឡាយនោះមកធៀបនឹងវាស្មាខ្ញុំ ឃើញថាសេចក្តីសុខស្រួលរបស់ខ្ញុំផ្ទួយពីសេចក្តីសុខនៃជនទាំងនោះ ។ ខ្លួនខ្ញុំប្រៀបដូចមនុស្សលង់ទឹកទើបនឹងប្រាថ្នាបានដុំថ្មជាទីពឹងនឹង ខ្ញុំក្រឡេកពីកន្លែងខ្ញុំទៅឃើញព្រះសង្ឃព្រះ កំពុងតែបោកបក់នូវមនុស្សសំណាល់ញាក់ទៅក្នុងលោក ។ សូវសន្ធឹកព្រះពីចម្ងាយ រើងតែតែធ្វើទីសម្រាកនៃខ្ញុំឲ្យរាយ្ងយ ជាខ្លួណាឡើង ។

(មានត)

សេចក្តីកាត់

នៃក្រុមដំណុំទំនៀមទម្លាប់ស្រុកខ្មែរ

ចាប—ពិន ថ្លែងដាក់វិទ្យុប្រទេសកម្ពុជាពីថ្ងៃទី ១៥—១២—៥២

ផ្សាយបេញពីពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

កន្លងវិជ្ជាហានពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ មានក្រុមមួយ ជាក្រុមរក្សាគោលចារិកយ៉ាងសំខាន់របស់ប្រទេសកម្ពុជា គឺក្រុមដំណុំទំនៀមទម្លាប់ស្រុកខ្មែរដែលនឹងបរិយាយដូនជូចតទៅនេះ :—

ទំនៀមទម្លាប់ ជាលក្ខណៈសំខាន់មួយយ៉ាងរបស់មនុស្សជាតិក្នុងសង្គមកន្លងប្រទេស ដែលគ្រប់ប្រទេសក្នុងសកលលោកសព្វថ្ងៃនេះគេកាន់តែត្រូវការចេះដឹងជាច្រើន ទើងគេត្រូវការរក្សាទុក មិនបំភ្លេចចោលទេ ព្រោះគេយល់ថាបើទំនៀមទម្លាប់របស់ជាតិគេសាបសូន្យ ជាតិគេក៏សាបរលាបមិនអាចតស៊ូទ្រទ្រង់ទៅបាន ។

ប្រទេសកម្ពុជាយើង ពិតមែនតែបានកាន់តាមអារ្យធម៌របស់ប្រទេសឥណ្ឌាជាច្រើន តែគង់មានរបៀបជាច្រើន ដែលជារបស់ខ្មែរសុទ្ធពិត។ ហើយជារបៀបចាស់ ដែលខ្មែរយើងធ្លាប់បានប្រតិត្តជាច្រើនសតវត្សមកហើយ, ប៉ុន្តែទោះបីខ្មែរយើងមានអារ្យធម៌ចាស់ដែលគេចង់ចាំពិតប្រាកដជារបស់ខ្លួនយ៉ាងណាក្តី ក៏នានាប្រទេសគេបានស្គាល់ខ្មែរយើងតិចប្រទេសទៅទៀយ, ទាំងនេះមិនពីព្រោះហេតុអ្វី គឺពីព្រោះហេតុអារ្យធម៌ខ្មែរយើងមិនទាន់បានផ្សាយទៅឲ្យគេស្គាល់ ។

ហេតុនេះ ចានជាព្រះពជវជ្ជាគិបាលចានបង្កើតឲ្យមានក្រុមដំនុំមួយឡើងហៅថា "ក្រុមដំនុំទំនៀមទម្លាប់ស្រុកខ្មែរ" ដោយព្រះពជប្រកាសលេខ ១២ ចុះថ្ងៃ ២៩ ១ - ៣៤ ។ មុខងាររបស់ក្រុមដំនុំនេះមិនគ្រាន់តែបង្ហាញបវេណីខ្មែរឲ្យជនបរទេសស្គាល់ប៉ុណ្ណោះទេ គឺមានការៈខាងស្រាវជ្រាវរកគាំងសៀវភៅក្បួនខ្នាតដែលស្តីអំពីទំនៀមទម្លាប់ខ្មែរទៀតផង ព្រមទាំងដំកល់ទុកនូវឯកសារដែលចាក់ទងដោយទំនៀមទម្លាប់ខ្មែរ, រៀបរៀងចុះពុម្ពផ្សាយនូវឯកសាររឿងដែលបង្ហាញឲ្យឃើញផលប្រយោជន៍នៃការដែលចានពិភាក្សាអំពីប្រជាជនទាំងឡាយ នឹងចុះពុម្ពផ្សាយនូវទំនៀមទម្លាប់នានា មានព្រះពជពិធីទ្វាទសមាសជាដើម ដើម្បីរក្សាទុកមិឲ្យបាត់អារ្យធម៌បុរាណរបស់ខ្មែរ ដែលគ្រែនតែបាត់ឫក្ខេចទៅនឹងដើម្បីឲ្យបណ្តាជនជាតិខ្មែរយើង ឬនានាជាតិដែលចង់ចេះដឹងអារ្យធម៌របស់ខ្មែរយើង ដែលមកស្រាវជ្រាវរកនៅក្នុងនូទុកឯកសាររបស់ក្រុមដំនុំនេះឲ្យបានឃើញដោយងាយ នឹងឲ្យបានឃើញថាខ្មែរយើងបានកត់ត្រាអារ្យធម៌របស់ប្រទេសជាតិ តាំងពីបុរាណមកមិនមែនបំភ្លេចចោលទេ ។

ប្រពៃណីខ្មែរដែលក្រុមដំនុំទំនៀមទម្លាប់ត្រូវការស្រាវជ្រាវរកនេះមានដល់ ៩៩ មុខ មានថតនូសម្រាប់ជាឯកសារដល់ទៅ ៩៩ ថត ដូចបានពាយណ្ឌោះខ្លះដោយសង្ខេប គឺ:

ត្រុដិសង្ក្រាន្ត, ចូលឆ្នាំថ្មី, លើកពស់, ពេលា, ហោរាសាស្ត្រ, វេជ្ជ, តិសាទបូជា, មាយបូជា, ចូលវស្សា, ចេញវស្សា, ភ្ជុំបិណ្ឌ, កឋិន, ផ្កា, បញ្ចុះសីមា, បំបួសនាគ, សំពះព្រះខែ, លយប្រទីប, អកអំបុក, អុំទូក, អារាហរិកហាមង្គល, ល្បែង, របាំ, មហោស្រព, ក្បួនព្យុហ៍សឹក, វិធីសមយុទ្ធ (អាវុធគ្រោះ), ប្រវត្តិសាស្ត្រ, កូមិសាស្ត្រ. ពង្សាវតារ ឧដ្ឋទេម ផ្សេងៗ ជាដើម ។ល។

ទំនៀមទម្លាប់ ដូចពន្យល់ឈ្មោះខ្ញុះមកនេះហើយ ដែលក្រុមដំនុំទំនៀមទម្លាប់ខ្មែរ ត្រូវការតត់ត្រាស្រាវជ្រាវប្រមែប្រមូលរក្សាទុកឲ្យគង់នៅតទៅ ។

ឯដំណើរការស្រាវជ្រាវរកនោះមានរបៀបដូច្នេះ គឺ

១ - ចាត់ការស៊ើបសួរយកការតត់ត្រា នូវទំនៀមទម្លាប់ផ្សេងៗ នៅវេលាដែលប្រជាជនក្នុងសង្គមធ្វើពិធីផ្សេងៗ ដែលទាក់ទងដោយទំនៀមទម្លាប់ខ្មែរ;

២ - ចាត់ការចម្លងឯកសារក្បឿងទំនៀមទម្លាប់ តាមសាស្ត្រាគាំងសៀវភៅក្បួនខ្នាតផ្សេងៗ ដែលខ្ចីមកអំពីគ្រហស្ថឬបព្វជិតនៅភូមិស្រុកនិងវត្តអារាមនានា ;

៣ ចាត់ការស៊ើបសួរយកការក្បឿងទំនៀមទម្លាប់អំពីពួកសមាជិកធ្វើយឆ្ងន់នៅភូមិស្រុក - ខែត្រនានា ដែលក្រុមដំនុំបានតាំងប្រចាំការ

សម្រាប់សាកសួរ ដោយបានឲ្យសមាជិកធ្វើយធ្វន់ទាំងនោះសរសេរ ឯកសារឲ្យការមកជារឿយៗ;

៤ - ចាត់ការប្រឡងប្រជែង រវាងបេក្ខជនដែលស្នើតែចិត្តប្រឡងរាល់ឆមាសនីមួយ ៗ គឺ ៦ ខែប្រឡងម្តងរៀងរាល់ឆ្នាំ ដើម្បីឲ្យបេក្ខជនទាំងនោះជួនឯកសារឿងទំនៀមទម្លាប់ខ្មែរ តាមដែលក្រុមដំនុំត្រូវការចំពោះរឿងណាដែលមិនទាន់បានបរិបូណ៌ ។

ជនជាតិខ្មែរណាក៏សឹងតែចេះចាំទំនៀមទម្លាប់ខ្មែរដែរ, ប្លែកតែខ្លះចេះចាំច្រើនខ្លះតិច, រីឯជនខ្លះជាបព្វជិតគ្រីស្តបរិស័ទ ដែលចេះចាំហើយនាំយកមកពណ៌នាពន្យល់ច្បាស់លាស់បាន, អាចធ្វើជាសមាជិកធ្វើយធ្វន់របស់ក្រុមដំនុំបានទាំងអស់ ។ ដោយក្រុមដំនុំយល់ឃើញថា រីឯជនដែលបានទទួលសរសេរតែងរឿងប្រពៃណីខ្មែរឲ្យការទៅក្រុមដំនុំនោះមានអំពល់ច្រើនក្នុងរឿងនេះ បានជារវាង ៦ ខែក្រុមដំនុំបានស្រង់យកម្តង នូវរឿងនានាដែលពួកសមាជិកធ្វើយធ្វន់បានឲ្យការទៅនោះមកប្រជុំពិនិត្យហើយបានជូនវង្វាន់ជាប្រាក់តាមបំណាច់ ដែលសមាជិកធ្វើយធ្វន់នោះ។ បានខំធ្វើដោយនឿយហត់ ។

ពួកសមាជិកធ្វើយធ្វន់ដែលបានឲ្យការទៅក្រុមដំនុំនោះ នឹងបានឃើញឈ្មោះរបស់ខ្លួន នៅពេលដែលក្រុមដំនុំបានផ្សាយអំពីកិច្ចការ

របស់ក្រុមដំនុំ ក្នុងសារពត៌មានកម្ពុជា, ក្នុងទស្សនាវដ្តីកម្ពុជសុរិយា ឬក្នុងសៀវភៅដែលក្រុមដំនុំរៀបរៀងអំពីអារ្យធម៌ខ្មែរ ។

ពួកបេក្ខជនដែលបានសរសេរឯកសារ ធ្វើទៅបែបដែលនោះ ក្រុមដំនុំទទឹងជួនរង្វាន់ក្រោយដែលបានជួបជុំពិនិត្យឃើញថា ឈ្មោះណាបានជាប់រឿងណាថ្នាក់ណាហើយ ត្រមាំងបានប្រកាសលទ្ធផលនៃការប្រឡងនឹងឈ្មោះបេក្ខជនដែលប្រឡងជាប់នោះ ។ ពាល់លើកក្នុងសារពត៌មានកម្ពុជា ឬក្នុងទស្សនាវដ្តីកម្ពុជសុរិយារបស់ពុទ្ធសាសនបណ្ឌិត្យផង ។

កិច្ចការរបស់ក្រុមដំនុំនេះ. មានការៈយ៉ាងធំត្រង់ការស្រាវជ្រាវរកគាំងសៀវភៅក្បួនខ្នាតនានាដែលស្តីពីទំនៀមទម្លាប់ខ្មែរឲ្យបានច្រើនមុខ, មួយមុខ ៗ ឲ្យបានចំនួនច្រើន, ដើម្បីយកឯកសារមួយមុខ ។ ដែលមានច្រើនបែបនោះមកប្រៀបធៀបធ្វើមធ្យើគ្នាមើល ឲ្យដឹងថាត្រូវគ្នា ឬខ្ចែកគ្នាយ៉ាងណាខ្លះ ដល់ពេលដែលទំនងរៀបរៀងជាសៀវភៅចោះពុម្ពឡើង ឲ្យបានមានគោលចារឹកត្រឹមត្រូវល្អ ។

ឯការស្រាវជ្រាវដែលនឹងបានច្រើនមុខហើយក្នុងមួយមុខ ៗ ច្រើនបែបនោះលុះតែអស់លោកវិញ្ញាជនច្រើនរូបជួយឧបត្ថម្ភផង គឺឧបត្ថម្ភដោយសារសេរខ្លួឯកសាររឿងទំនៀមទម្លាប់ផ្សេង ៗ តាមចេះចាំឬបានចម្លងតាមគាំងសៀវភៅក្បួនខ្នាតផ្សេង ៗ ដែលមានតាមវត្តអារាមក្នុងភូមិស្រុក

ដោយជាក់ដើមកំណើតគឺឈ្មោះនឹងទីលំនៅអ្នកម្ចាស់ក្បួន, ព្រមទាំងឈ្មោះនឹងទីលំនៅអ្នកសរសេរចម្លងឯកសារ ឲ្យការទៅនោះយ៉ាងច្បាស់លាស់ ផ្ញើទៅឲ្យក្រុមជំនុំឲ្យបានច្រើន ។ ក្រុមជំនុំសង្ឃឹមទាំលើអស់លោកវិញ្ញាជនទាំងឡាយនូវទៅទាំងប្រទេសកម្ពុជាទាំងមូល, ដែលបានយកចិត្តទុកដាក់កិច្ចការនេះ ។

ដូច្នេះ, អស់លោកអ្នកជាវិញ្ញាជនទាំងឡាយ នោះជាគ្រហស្ថក្តីជាបព្វជិតក្តី ដែលបានចេះចាំនូវទំនៀមទម្លាប់ជាអារ្យធម៌ខ្មែរ, ហើយដែលមានចិត្តថ្នាក់ថ្នមទុកឲ្យគង់នៅ ដើម្បីជាគោលចារិកនឹងជាព្រំដែនរបស់ខ្មែរតទៅ; សូមជួយជ្រោមជ្រែងដោយការឧបត្ថម្ភ ៣ យ៉ាង គឺ

๑) ដោយទទួលធ្វើជាសមាជិកធ្វើយន្តរបស់ក្រុមជំនុំទំនៀមទម្លាប់ហើយសរសេរឯកសារផ្សេង។ ដែលតាក់តែងដោយទំនៀមទម្លាប់ខ្មែរតាមបញ្ជីកយៈឈ្មោះថតចាំង ៩៩ ឬណាមួយដូចបានរៀបរាប់ពីខាងដើមមក ហើយនោះផ្ញើទៅឲ្យក្រុមជំនុំ;

๒) ដោយទទួលធ្វើជាបេក្ខជនសរសេរឯកសាររឿងទំនៀមទម្លាប់ខ្មែរផ្សេងៗ ផ្ញើទៅប្រឡង តាមកាលបរិច្ឆេទដែលក្រុមជំនុំបើកតុការសប្រឡងប្រជែង ដែលជូនដំណឹងតាមប្រកាសការប្រឡងរៀងរាល់ធម្មាសតទៅ;

៣) ដោយមិនខ្វល់ធ្ងីជាសមាជិក ឬបេក្ខជនខ្លះគ្មានតែសរសេរចម្ងល់ក្បួនខ្នាតរឿងទំនៀមទម្លាប់ផ្សេងៗ ផ្ញើទៅឲ្យក្រុមជំនុំ ឬឲ្យក្រុមជំនុំខ្លះក្បួនខ្នាតរឿងទំនៀមទម្លាប់ទៅចម្លង ។

បណ្តាការខុបត្ថម្ភទាំង៣យ៉ាងនេះ លោកអ្នកវិញ្ញាជនណាមួយគោះជួយខុបត្ថម្ភបែបណាក្តីក៏ឈ្មោះថា បានជួយជ្រោមជ្រែងកិច្ចការរបស់ក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ ឲ្យបានរុងរឿងតាំងអស់, ហើយបានឈ្មោះថាជាអ្នកស្នេហាជាតិ ជួយខុបត្ថម្ភអារ្យធម៌របស់ប្រទេសជាតិឲ្យមានគោលចារិកល្អផង ថែមទាំងបានរង្គាន់ជាប្រាក់សមគួរតាមបំណាច់ដែលនឿយហត់ក្នុងការជួយខុបត្ថម្ភនោះផង ។

ក្រុមជំនុំសូមខ្វល់អំណរគុណយ៉ាងខ្លាំងទុកជាមុនចំពោះអស់លោកអ្នកដែលបាន យកចិត្តទុកដាក់ជួយទំនុកបម្រុងកិច្ចការរបស់ក្រុមជំនុំនេះឲ្យបានចម្រើនជាកិរិយាភាព ។

សេចក្តីបរិយាយអំពីសកម្មភាព នៃក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរនៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ អស់ត្រឹមប៉ុណ្ណេះ ។

តទៅខាងមុខ យើងនឹងបរិយាយអំពីសកម្មភាពនៃវិជ្ជាឋាននេះជាផ្នែកៗជូនលោកអ្នកតទៅទៀត ។

សន្ដិសិទ្ធិព្រះពោធិវង្ស ហ្សួត-តាត
ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ជាប្រធាននៃគណៈប្រតិភូខ្មែរ

ថ្លែងអំពីសមាជសាកលលើកទី ២ នៃពុទ្ធសាសនា
នៅទីក្រុងតូក្យូ (ប្រទេសជប៉ុន)

ពុទ្ធសាសនបណ្ដិត្យ

(តមក)

អាត្មាសំដែងមកនេះ មិនបានពណ៌នាឲ្យបានសព្វគ្រប់ទេ គ្រាន់តែពោលគ្រួសៗ អំពីរឿងផ្សេងៗ មិនបានពោលពីផលិតកម្ម ទិដ្ឋភាពក្នុងប្រទេស, វាល, ភ្នំ, មាត់សមុទ្រ, ប្រពៃណីនិយម, ទំនៀមទម្លាប់, ពាណិជ្ជកម្ម, ទេសាភាកម្ម, សង្គម, នយោបាយជាដើម ។ នៅទីក្រុងគេគ្រឡែកទៅឃើញភ្នំភ្លើងមួយឈ្មោះហ្វុតស៊ីយ៉ាម៉ា នៅកណ្ដាលកោះហុងដូ បញ្ចេញផ្សែងខ្មៅទៅលើអាកាស ។ បើតាមពិនិត្យសេដ្ឋកិច្ចឃើញមានស្រែវាំងក្នុងសួន ដោយយកចម្បារនាស់ដែកជ្រួយកាស់ដី គ្មានសត្វច្រៃទេ ឃើញមានដាំដើមថ្ពាល ស្រែវសាល់ តោត ។ ដើមតែមានដាំជាច្រើន, ចានជាមានពិធីបរិភោគតែ ជាទំនៀមជាប់ពីបុពណមក តែឲ្យសុខ តែឲ្យសេរីសួស្ដី តែឲ្យជយមង្គល ។ មានគេចិញ្ចឹមសត្វជាច្រើនមានដៀម, មាន់, គោ, សេះ, មានរបរចាប់ត្រី ។

ក្រៅពីនេះមានលោហធាតុផ្សេងៗ ដែក, ធ្យូងថ្ម, ក្រែងគាត, មាស, ប្រាក់, ស្ពាន់, ស្ពាន់ធ័រជាដើម ។ គេយកកំលាំងទឹកជ្រោះកន្ទឹកគុហាកំពង់កំលាំងសម្រាប់បង្កើលក្រឿងចក្រក្នើងអគ្គិសនី ។ មានការទេស្សាហកម្មខាងគ្រួសារ ចានប៉ូសឺឡែន, ចានដី, ការប៉ាក់ជរសំពត់ត្បែ, កន្ទេល, ក្រជាស, របស់សម្រាប់កូនក្មេងលេង, តុ, ទូ, កៅអីជាដើម ។

មុននឹងបញ្ចប់សេចក្តីនេះ អាត្មាសូមជំរាបសាធុសប្បុរសទាំងឡាយថា អាត្មាចេញពីវត្តដែលសំណាក់ដោយមានរថយន្តទៅទួល, កាលទៅដល់ទីកន្លែងមួយក៏ចុះពីរថយន្ត ស្រាប់តែឃើញក្មេងអាយុ ៦-៧ឆ្នាំ ឈរតម្រៀបគ្នាប្រហែល ២-០០០ នាក់ គំនាប់អាត្មាជាកិត្តិយស ។ អាត្មាបានសួរថា: ក្មេងនេះមកធ្វើអ្វី? គេប្រាប់អាត្មាថា: "ក្មេងទាំងនេះ ស្ថិតនៅក្នុងតំរុវទេសមាគម ហៅថា "សមាគមអប់រំក្មេងខាងព្រះពុទ្ធសាសនា ឬសមាគមយុវពុទ្ធសាសនា" ។ សមាគមនេះមានវត្តុបំណង់ តែងតែការអប់រំក្មេងនេះឲ្យរៀនសូត្រខាងព្រះពុទ្ធសាសនា ព្រោះប្រទេសជប៉ុនខ្លាចក្រែងវិនាសព្រះពុទ្ធសាសនាទៅអនាគត ដោយហេតុណាមួយ, គេភ័យនឹងព្រះពុទ្ធសាសនា, គេរំលេកមជ្ឈាបាយផ្សេងៗ ដើម្បីឲ្យព្រះពុទ្ធសាសនាគង់ធ្លាក់តទៅ ។ សមាគមនេះ មិនមែនមានតែប្រទេសជប៉ុនទេ, ប្រទេសឥណ្ឌា, កូមា, សៀម គេក៏មានហើយ, នៅតែប្រទេសកម្ពុជាមិនទាន់មាននៅឡើយ ឃានជាអាត្មាមកដល់ព្រះរាជធានីភ្នំពេញ

ចូលទៅថ្វាយព្រះពរស្តេចព្រះកុរណាជាអម្ចាស់ជីវិតលើតំបូង អំពីរឿងស្តាប់នាទូវិសមាគមបែបនេះ នៅប្រទេសកម្ពុជា ។ ទ្រង់សព្វព្រះរាជហឫទ័យចង់ឲ្យមានសមាគមនេះដែរ ។

នៅទីនេះ អាត្មាមិនបានពោលអំពីផ្លូវគមនាគមន៍, ថ្នល់, អយស្ទឹយយាន, សម្បុរជាដើម គ្រាន់តែពោលអំពីពុទ្ធសាសនានៅប្រទេសជប៉ុនទឹងសាសនាសង្ឃតូ ។

ព្រះពុទ្ធសាសនានៅប្រទេសជប៉ុនមកពីប្រទេសចិន ផ្សាយតាមប្រទេសកូរេតាំងពីសតវត្សរ៍ទី ៦ គ. ស. ។ ការស្តាប់នាព្រះពុទ្ធសាសនាដំបូងនៅប្រទេសជប៉ុន ប្រាន់ដូចប្រទេសទឹងការដែរ ស្តេចជាតិកងស្តេចជាឧបសម្ព័ន្ធមួយធំ តែការផ្សាយព្រះពុទ្ធសាសនា ក៏ជួបជាបទៅកងសន្ធានចិត្តប្រជាពុស្តេ មានរត្តជាច្រើនគេសាងនៅទីក្រុងនារ, កីយូតូ, កាម៉ាគុរ៉ា ជាដើម ។ មានគណៈជាច្រើន តាំងអស់ ១២ គណៈ គឺ គណៈសង្ឃតុងកើតឡើងដោយជនកបុរសនាមកូប៊ូដៃស្ហ៊ី ពីសតវត្សរ៍ទី ៨ គ ស , គណៈហូណែក សតវត្សរ៍ទី ១២ ។ ក្នុងពេលនោះមានគណៈបួយទៀត កើតឡើងដោយមានលោកនីចីរែនជាជនកបុរស ព្រមទាំងគណៈសែនទៀត ។ អាត្មាមិនបានពណ៌នាព្រះពុទ្ធសាសនានៅប្រទេសជប៉ុន ឲ្យជាវិត្តារពីស្តារទេ លំដាប់តអំពីនេះទឹងពណ៌នាសាសនាសង្ឃតូហើយទឹងបញ្ចប់ ។

ពាក្យជប៉ុនថា សិង្តូ ប្រែថា "ផ្លូវព្រះអាទិទេព" ។ សាសនានេះប្រែហាលជាសាសនាក្រៅពីសាសនា "តៅ" ដែលបណ្ឌិតឡៅសឺនៅប្រទេសចិនបានស្ថាបនាពីមុនមក ព្រោះថា "តៅ" នេះ ក៏ប្រែថា "ផ្លូវ" ដូចគ្នានឹងការសាជប៉ុនថាសិង្តូ ។ សាសនានេះពណ៌នាឲ្យវែងឆ្ងាយទូលាយក៏បាន តែពេលវេលានេះខ្លីណាស់ គ្រាន់តែដំណាលថាសាសនានេះមានយកសត្វតិរច្ឆានមកសូន្យជារូប ថាជារូបដ៏ជូនដ៏តា ហើយក៏នាំគ្នាគោរពបូជា ព្រមទាំងប្រតិស្ថានទ្បូពលភាពជម្ងាតិទៅជាទេវតា, មានឫទ្ធានុភាពចំពោះសត្វតិរច្ឆាន, គេបានឃើញនៅកូមិភាគប្រទេសជប៉ុនខាងជើងមានធ្វើ "ពិធីបុណ្យសត្វខ្លាឃ្មុំ" ដែលគេទុកជាដ៏តា ហើយក៏ទម្លាក់ការថ្វាយបង្គំ ។ មានទីកន្លែងខ្លះ គេកំតាមប្រពៃណីនិយម ដើម្បីធ្វើបដិសណ្ឋារៈចំពោះទេវតា ដែលគេគោរពកប់អាន ។ មានតាមកូមិខ្លះ មានធ្វើពិធីបុណ្យទាក់ក្បែរតាជិការ សែនទេវធ៌តាចំទុកបំរុងស្រូវជាដើម ។ មានទីខ្លះ មានធ្វើពិធីលាងវត្ថុឲ្យជុតពីចង្រៃ ឲ្យទៅជារបស់មានសិរីសួស្តីទៅវិញ ។ សាសនានេះមានសរសេរទុកទៅក្នុងសៀវភៅពិសិដ្ឋគឺ កូដីត ១ នីហុងគី ១ តាំងពីសតវត្សរ៍ទី ៨ គ.ស. ។ សៀវភៅនិទានថា: "ព្រះអាទិទេព (អ៊ីសានគី) នឹងព្រះអាទិទេវី "អ៊ីសាណាមី" បានរួមសមវាសនឹងគ្នាកើតជាកោះ, ភ្នំង, ទឹក, ផ្លូវ, ព្រមទាំងទេវតាទេវធីតាផ្សេងៗ រួច

តមកនាងៈទេវធីតានៃព្រះសូរ្យា នាម "អាម៉ាតេរស៊ុ" នឹងបង្ហែរនាម "ស៊ុសាណូ" ។ ការឈ្លោះទាស់គ្នានៃទេវធីតានឹងបង្ហែរ នាំឲ្យទេវធីតាប្រគល់ឲ្យព្រះពជបុត្រត្រួតត្រាប្រទេសកំលៀងគឺប្រទេសជប៉ុននេះឯង; ព្រះនាងបានធ្វើព្រះពជអំណោយចំពោះព្រះពជបុត្រនូវកញ្ចក់មួយ គឺជាព្រះពជកេតនកណ្ឌជាពិសិដ្ឋ ចំពោះព្រះពជកេតនកណ្ឌទាំងបី តាំងពីនោះក៏ស្ថាបនានូវសន្តតិវង្សព្រះអធិរាជប្រទេសជប៉ុន ។

នៅគ.ស. ១៨៦៨ រដ្ឋាភិបាលព្រះចៅទៃដ៏ បានព្យាយាមប្រកាសសាសនាស៊ិនតូ ជាសាសនារបស់រដ្ឋ ឯកត្យានុភាពនៃព្រះពុទ្ធសាសនាក្នុងពេលនោះមិនអាចធ្វើបាន ។ ព្រះវិហារធំជាងគេនាម៉ថា: "អ៊ីសេ" គ្មានរូបអ្វីជាទីគោរពធ្វើពីឈើ គ្មានរចនាដោយក្បាច់ចំឡាក់អ្វីសោះឡើយ ខុសគ្នាពីព្រះវិហារព្រះពុទ្ធសាសនា ដែលតុបតែងដោយក្បាច់សិល្បៈ ព្រមទាំងតាំងព្រះពុទ្ធរូប ជាទីគោរពជាច្រើន ។

នៅទីនេះ មិនបានពណ៌នាអំពីប្រវត្តិសាស្ត្រប្រទេសជប៉ុន ព្រមទាំងគ្រិស្តសាសនា ។

អាត្មាពណ៌នាសេចក្តីខាងលើនេះ គឺពោលសារុបទាំងសន្និសីទនៅវត្តព្រះកែវមរកតនឹងវត្តលង្កា ត្រង់កន្លែងដែលចាំ មានកន្លែងខ្លះមិនបានចាំមិនបានយកមកអធិប្បាយទេ ។

(មានត)

សុន្ទរកថា

លោកជុំកទ័រគុណបល:បិយសេន:ម៉ាលាំល:សេកេរ:

ជាប្រធានពុទ្ធិកសមាគមពិភពលោក ថ្លែងក្នុងពេលសមាជសាកល
លើកទី ៦ នៃពុទ្ធសាសនា នៅក្រុងតូក្យូ (ប្រទេសជប៉ុន)
(តូក្យូ ២៥ កញ្ញា, ១៣ តុលា ១៩៥២)

ពុទ្ធសាសនបណ្ឌិត្យ

ជមោ ពុទ្ធាយ

ព្រះគិក្ខុសង្ឃទាំងឡាយ! ញាតិទាំងបុរស-ស្ត្រីទាំងឡាយ!
សហជីវិននៃបុព្វហេតុពិសិដ្ឋពុទ្ធសាសនាទាំងឡាយ!
កល្យាណមិត្តទាំងអស់!

ខ្ញុំសូមនមស្សការ ក្នុងនាមនៃពុទ្ធិកសមាគមពិភពលោក ចំពោះ
ព្រះសម្មាសម្ពុទ្ធ ដែលមានព្រះគុណាទិគុណ, ពុទ្ធោវាទ គឺព្រះធម៌និង
ព្រះសង្ឃ ដែលជាអ្នករក្សាក្តើមរតកព្រះបរមគ្រូជាម្ចាស់ ។

យើងសូមថ្លែងនូវអំណរជាយ៉ាងក្រៃលែង ដោយយើងទាំងអស់គ្នា
បានមកជួបជុំគ្នាដើ "បុប្ផាសិរិស ប្រទេសជប៉ុន" នេះ ដែលមានកិច្ចការ
ដ៏ប្រសើរតាំងពីបុពណាកាលមក ហើយមនោសញ្ចេតនាជាបឋមរបស់
យើងគឺការសំដែងនូវគតញ្ញូដ៏ពន្លឹក ចំពោះក្រុមប្រឹក្សាពុទ្ធសាសនា នៃ
ប្រទេសជប៉ុន ដែលជាអ្នកស្នើចំពោះការធ្វើមហាសន្និបាតនេះ ដែលមាន

គណៈប្រតិភូទាំងបុរស - ស្ត្រី ។ គណៈប្រតិភូនេះ មានសញ្ជាតិផ្សេងៗគ្នា អញ្ជើញមកពីប្រទេសផ្សេងៗគ្នា មានខ្លះចម្ងាយជាច្រើនពាន់ម៉ែល មករួបរួមនឹងយើង ដើម្បីវិនិច្ឆ័យអំពីរឿងនេះ ព្រមទាំងទទួលសេចក្តីសប្បាយ នឹងការផ្ញាស់ប្តូរយោបល់គ្នាទៅវិញទៅមក ។ យើងសូមថ្វាយនូវសេចក្តីអរគុណ ជាយ៉ាងក្រៃលែងចំពោះលោកដុកទ័រ ម៉ាកូតូណា - តៃ ប្រធាននៃក្រុមប្រឹក្សាពុទ្ធសាសនា. នៅប្រទេសជប៉ុន ដែលមានល្បីល្បាញជាអ្នកវិញ្ញាបុគ្គលទៅកងពិភពលោក ។

ចំពោះភ្ញៀវអ្នកដំណើរសាមញ្ញ ប្រទេសជប៉ុន គេបានចុះនាមថា ប្រទេសបុប្ផាគ្រិស្ត ថែមទាំងព្រះសុរិយោះ ចំណែកយើង ប្រទេសជប៉ុន ជាប្រទេសមានទំដ្ឋកាព ដូចខាងលើ តែប្រទេសនេះជាប្រទេសដែលសមាគម នឹងព្រះសម្មាសម្ពុទ្ធអមិទ: ហើយនឹងព្រះពុទ្ធក្លាង - យិន ជាប្រទេសគឺរីហ្គង់សីយ៉ាម៉ាពិសិដ្ឋ ដែលអ្នកគរីចំណានម្នាក់ ឈ្មោះម្យាមួនបានយកទៅទិពន្ធជាយ៉ាងពីរោះ ជាព្រះពាជអាណាចក្រនរ: នឹងកមករ: ជាដីគរីហាយ ប្តូបុរាតដែលមាននាមថា ហ្វូរិយុដ ហើយនឹងកូយ៉ាសានជាស្ថានទីពិសិដ្ឋសម្រាប់បូជនិយេសន៍ ចំពោះពុទ្ធសាសនិកជនពិភពលោក ជាប្រទេសនៃរឿងរបាំណូ ហើយនឹងស្នាដៃសិល្បកម្មព្រមទាំងអក្សរសាស្ត្រខាងបព្វជិត នឹងគ្រហស្ថ ជាមាតុភូមិនៃលោកស្ងួតូ ហើយនឹងរីតិយុ. ព្រមទាំងប្រទេសដែលគេនិយមការបូជានូវតែ

ជាបដិមារូបបញ្ជាក់ឲ្យឃើញ អំពីគុណសម្បត្តិសំខាន់ៗ ទាំងពុទ្ធសាសនា មានការរៀបរយ នឹងការគោរព មានវិសុទ្ធិចិត្ត នឹងការស្ងប់ស្ងាត; ចរិយោសានជាដីដែលពួកបណ្ឌិតតែងម្រង់សាសនា នឹងពួកសន្តបុរស ដូចជាស្តូតគ្គ តែស្គី. ដង់សីយូ - ដៃស្គី, កូប៊ូដៃស្គី ជូនសេន សង់ជី. ហូណាង់ សិនវ័ន នឹងនិចីរេន ។

ប្រទេសជប៉ុនកាន់ពុទ្ធសាសនា

ចំពោះពុទ្ធសាសនិកជន ប្រទេសជប៉ុនចាត់ថ្នមូល នូវលទ្ធផល ដែលកើតមកពីផែនការណ៍ជាច្រើន ។ ប្រជាជាតិនេះបានទទួលនូវការ សិក្សា ដែលជាឫកនៃព្រះសម្មាសម្ពុទ្ធ ព្រមទាំងលំនាំរស់ទៅតាម ពុទ្ធានុញ្ញាត ។ កន្លងមកជាច្រើនសតវត្សមកហើយ ការគមនាគមនៃ ព្រះពុទ្ធសាសនា នឹងប្រវត្តិនយោបាយនៃប្រទេសជប៉ុន កាន់តែជិត ស្និទ្ធ ។ ព្រះពុទ្ធសាសនាទៅជាសាសនារបស់រដ្ឋជប៉ុន យើងអាច វិនិច្ឆ័យបាន នូវលទ្ធផលល្អប្រសើរក្នុងសម្ពន្ធកិច្ចនេះ ។ បឋម, ចរិត និស្ស័យខាងបុព្វណាវត្តុ ប្រកបដោយវីរភាពនៃប្រទេសជប៉ុនបានស្វែង រកយើញនូវសភាពមួយ ជាសាមញ្ញលក្ខណៈ ហើយត្រង់ចំពោះ សាសនាជាដំបូង គឺព្រះពុទ្ធសាសនានេះឯង ដែលបានឲ្យប្រជាជនឹងគំនិត ធ្វើឲ្យប្រជាពលរដ្ឋបញ្ចេញនូវមេត្តាបានពេញលេញ, សាសនានេះធ្វើឲ្យ ប្រទេសជប៉ុន មានអារ្យធម៌ប្រកបដោយមនុស្សជាតិ នឹងមានសភាព

ស្តង់ស្តែលត្រមាំងជ្រាជ្ញ គឺគុណធម៌ទាំងពីរនៃកុណាបញ្ចូលទៅនឹងជ្រាជ្ញ ដែលជាកូនសោសម្រាប់បង្ហាញ ឲ្យយល់ច្បាស់នូវលទ្ធិនៃព្រះសម្មាសម្ពុទ្ធ ។ សាសនាចនាប្រទេសជប៉ុន ឲ្យមានការបដិវត្តន៍មួយចំពោះទឹកចិត្ត អក្សរសាស្ត្រ នឹងសិល្បសាស្ត្រ ។ ប្រវត្តិសាស្ត្របានបង្ហាញ នូវចរិយាជនជាតិជប៉ុន គឺរីកសម្បើមត្រមាំងធ្វើទឹកមុខឲ្យស្នេហាពេញទាំងពីរយ៉ាង ដែលកើតឡើងពីកំសួលពុទ្ធសាសនាផ្សាយចូលជ្រួតជ្រាបទៅក្នុងចរិតនិស្ស័យជនជាតិនេះ ។ កំសួលនេះធ្វើឲ្យជនជាតិជប៉ុនមានចិត្តមេត្តាចំពោះសត្វតិរច្ឆាន ពិតមែនតែជនជាតិខ្លះមិនបានបរិភោគផ្លែឬមើមឈើ ។ ការជាប់ជំពាក់នៃសិល្បកម្មជប៉ុន ចំពោះព្រះពុទ្ធសាសនានេះ ហើយមានសារៈសំខាន់ ព្រោះថាមកពីព្រះពុទ្ធសាសនា បានជាវិចិត្រសិល្បៈក្បាច់រចនា, ក្បួនតុបតែងគេហដ្ឋាន, ការធ្វាក់ដោយស្ពាន់សំណ; ការចុះពុម្ពទឹងអក្សរជាតិ បានចូលមកប្រតិស្ឋាននៅប្រទេសជប៉ុន ។ គឺមកពីសាលាវត្តដែលមានចំពោះភូមិនិមួយៗ ដែលបានទទួលការសិក្សាយកមកអប់រំពួកប្រជាពស្ត្រគ្រប់សង្គម ។ ពិតមែនតែពួកមហាន ត្រូវទុកឲ្យនៅក្រៅកំសួលនេះ ពួកនេះក៏ត្រូវការបំពេញវិន្យាក្រៅពីតិកនិក គឺវិន្យាមានលំនាំទូទៅ ដោយយកព្រះសង្ឃមកបង្ហាត់បង្រៀនដែរ ។

ព្រោះហេតុដូច្នោះ បានជាកំសួលព្រះពុទ្ធសាសនានៅប្រទេសជប៉ុនមានសក្តានុពលសម្បើមអស្ចារ្យ មិនត្រឹមតែផ្នែកការណ៍ខាងសាសនាទេ

ថែមទាំងមានខាងនយោបាយ ការសិក្សាទឹងសិល្បសាស្ត្រ ។ ព្រះពុទ្ធ-
សាសនាបានអប់រំ ដុសខាត់ធ្វើឲ្យមានទម្រង់ល្អឡើង នៃបរិតនិស្ស័យ
ជនជាតិដប៉ុនត្រមទាំងឧបត្ថម្ភត្រង់ការពង្រីកនូវប្រជាប្រជាជាតិ ឲ្យដុះ
ដាលច្រើនឡើង ។ សភាពដ៏ឧត្តមនៃព្រះពុទ្ធសាសនានេះ កើតឡើង
ក្នុងសម័យ ដែលប្រទេសជប៉ុនបានបំពេញកិច្ចការ ឲ្យបានពិតប្រាកដ
តែតមកក៏ចុះអន់ខន់ថាបទៅវិញ ដោយគេទុកព្រះពុទ្ធសាសនាជាថ្នាក់ទី
ពីរ ហើយមិនសូវគោរពប្រតិបត្តិ ហើយដោយពួកអ្នកណែនាំប្រជាជាតិ
ពេញចិត្តខាងគតិ ជាសម្ភារៈប្រយោជន៍ ។ តិតមែនតែប្រទេសនេះ
នៅមានកោតទ្រព្យប្រកបដោយសម្ភារៈតែវត្តុទាំងនេះបានមកពីការស្វែង
ទៅខាងផ្លូវទុស ។ ពេលទុក្ខលំបាកនេះ រចនាបរិតនិស្ស័យនៃប្រជា-
ជាតិ ហើយដឹកនាំប្រជាជាតិនេះឲ្យឈរច្បាស់នូវតម្លៃជាតិ ។ ក្រៅយ
ព្យុះសង្ឃរា, ការខាតបង់ នៃមហាសង្គ្រាម ទឹងផលដ៏អាក្រក់,
មហាប្រទេសជប៉ុន បានមានជីវិតរស់ចេញពីផេះ (ស្ងាប់ហើយរស់ឡើង
វិញ) ការសំគាល់ចំពោះកិច្ចនេះ មានលំនាំស្រួលហើយបរិតនិស្ស័យ
ដែលជ្រលក់ទៅក្នុងទុក្ខលំបាកនៃប្រជាជាតិនោះ បានបញ្ចេញនូវសីតង
ពេលសន្តិភាពនេះ ។ ជីវភាពដែលរស់នៅជាថ្មីនេះ បម្រុងនឹងយក
ទៅអនុវត្តន៍ ចំពោះការស្វែងនូវឧត្តមគតិទៅតាមពុទ្ធោវាទនេះ ជាភារ
មួយដ៏ប្រសើរ ដែលយើងមកជួបជុំគ្នា ជាគណៈប្រតិកូនៃពុទ្ធបរិស័ទ

កងទ័ពចាំដួងនៃសាកលលោក យើងសូមគោរពចំពោះប្រទេសជប៉ុន ដែលទើបចាប់បដិសន្ធិថ្មី ហើយសូមជូនពរប្រជារាស្ត្រ ឲ្យសមានចិត្តជាថ្មីថ្លា នឹងសហការជំរុញសេរីរបស់យើង ។

ពុទ្ធិកសមាគមពិភពលោក

ប្រហែលជាង៣ទសវត្សមកហើយ គឺនៅក្នុងខែឧសភា ១៩៥០ ដែលពុទ្ធិកសមាគមពិភពលោកឋានស្ថាបនា នៅកោះស៊ីឡង់នៅបន្ទប់ធំនៃមហាវិហារ ព្រះចន្ទមកៃរដ៏ត្រជាកខ្លី ជាអតីតព្រះពាជនានៅកោះលង្កា ។ ការផ្តើមបង្កើតនៅសមាគមនេះ មកពីមានបំណងដ៏ជ្រាលជ្រៅត្រង់ប្រមូលព្រមទាំងរួបរួមនូវពួកពុទ្ធបរិស័ទនៃពិភពលោក ដោយមានវត្ថុបំណងជាធំត្រង់ការរស់នៅ នៅតាមពុទ្ធោវាទ ហើយនឹងផ្សាយនូវលទ្ធិដ៏ប្រសើរនេះឲ្យជ្រួតជ្រាបគ្រប់ៗ គ្នា ដើម្បីឲ្យសន្តិភាព នឹងសុភមង្គលស្ថិតនៅពាសពេញផែនដីទាំងអស់ ។ ពួជដែលដុះឡើងមានបំណង ឲ្យប្រែទៅជារុក្ខជាតិ មានពណ៌ភាពដ៏អស្ចារ្យ ។ ពួជនេះស្រស់ស្រោច ដោយធនូដ៏ខ្លាំងក្លានឹងសមានចិត្តបរិគោគនូវរស្មីរយៈភាពនឹងសច្ចធម៌ជាអាហារដ៏វិសេសវិសាល ហើយបក់ដោយវាយោស្រួលត្រជាក់តិចិត្តសន្តោស នឹងសម្ងាត់ដ្ឋិ អាចបំរើន រំយិវឌ្ឍនាការឡើង រីកធំពេញមនុស្សធម៌ ដែលមានម្ចប់គួរឲ្យសុខកាយសប្បាយចិត្ត ។ សេចក្តីសង្ឃឹមហើយនឹងវត្ថុបំណងរបស់យើងត្រូវស្ថិតនៅកងទ័ពនេះ ស្មោះក្តីព្យាយាមរបស់យើង តម្រង់ផ្លោះត្រង់ទៅកងទ័ពនោះ ។ (មានត)

បញ្ជីរាយនាមថៅអធិការដែលតាំងថ្មី

របស់ក្រសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៨៥៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ួង-អុង នាមធាយា ឥន្ទ្រត្ថេរ កើតឆ្នាំរោង អាយុ ៧០ វស្សា ១០ ជាគ្រូសូត្រធ្វើ វត្ត-ឃុំ-ស្រុកខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៥៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ញឹក ង៉ួន នាមធាយា ង៉ួនសភេ កើតឆ្នាំមមី អាយុ ៣២ វស្សា ៩ ជាគ្រូសូត្រស្តាំវត្តកោះកែវមុនីខត្តម ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៥៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឈិម-សេក នាមធាយា និលសរ កើតឆ្នាំខាល អាយុ ៦០ វស្សា ៤១ ជាគ្រូសូត្រស្តាំ វត្តពោធិវង្ស ឃុំជង់ឡង ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៥៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ខែក-ចុ៉ី នាមធាយា ចន្ទសរ កើតឆ្នាំម្សាញ់អាយុ ៤៥ វស្សា ២៦ ជាគ្រូសូត្រធ្វើ វត្ត-ឃុំស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៥៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស-ឃឹម នាមធាយា សុវណ្ណត្ថេរ កើតឆ្នាំកុរ អាយុ ២៧ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្តកោះធំ ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៥៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ម៉ុក-ហែម នាមឆាយា ព្រហ្មបញ្ញា កើតឆ្នាំមមី អាយុ ៥៦ វស្សា
៣៧ ជាចៅអធិការ វត្តពោធិសុទស្ស ឃុំ-ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៥៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ព្រំ-ប៊ុន នាមឆាយា ប៊ុនត្ថេរ កើតឆ្នាំជូត អាយុ ៣៨ វស្សា ១៨ ជាគ្រូ
សូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៦០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ចាប់-ឈួន នាមឆាយា និលសរ កើតឆ្នាំជូត អាយុ ៣៤ វស្សា ១៦
ជាចៅអធិការវត្តពោធិ៍មានបុណ្យ ឃុំចាក់ទឹម ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៦១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
កុយ-ឡាញ់ នាមឆាយា លញ្ញត្ថេរ កើតឆ្នាំមមី អាយុ ៤៤ វស្សា ២១
ជាចៅអធិការវត្តចាកាន ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៦២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ម៉ម ទុក នាមឆាយា សុវណ្ណបញ្ញា កើតឆ្នាំមមី អាយុ ៦៨ វស្សា ៦
ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៦៣ ចុះកាលបរិច្ឆេទដដែល តាំងលោងគ្រូ
អ៊ុក-ខ្វា នាមឆាយា កលន្ទត្ថេរ កើតឆ្នាំម្សាញ់ អាយុ ៣៣ វស្សា ៣
ជាចៅអធិការវត្តកំចាង ឃុំព្រះម្លូ ស្រុក-ខេត្តដដែល ។ (មានត)

ភ្នំពេញសុទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៥ ខែមីនា លេខ ៣

ព. ស. ២៤៨៥ — គ. ស. ១៩៤៣

ពុទ្ធសាសនបណ្ឌិត្យ សូមប្រគេនធំងដូនជំណាំង

សៀវភៅព្រះត្រៃបិដក កំពុងតែចាត់ការចុះពុម្ពសព្វថ្ងៃ ដោយបំរុងនឹងចុះឲ្យហើយក្នុងពេលឆាប់ៗ នេះ។ ចំពោះសៀវភៅភាគ ៣៧ ដល់ ៤៤ នឹងចុះឲ្យបើយើងស្រេចក្នុងឆ្នាំ ១៩៥៣។ ឯសៀវភៅភាគ ៣៦ វិញ ដែលបានចុះពុម្ពរួចហើយ តាំងពីចុងឆ្នាំ ១៩៥១ (តម្លៃ ១ ក្បាល ៧៨រ,០០) សព្វថ្ងៃនេះកំពុងចែកនឹងជាវដូនអស់លោក-អ្នកតាមរបៀប។

ដូច្នេះ,អស់លោក-អ្នកឯណា (អ្នកជាវជាន់មុនក្តី អ្នកជាវជាន់ក្រោយក្តី) ដែលមិនទាន់បានសៀវភៅភាគ ៣៦ នេះ សូមអញ្ជើញចូលទៅបើកនឹងជាយកនៅមន្ទីរពុទ្ធសាសនបណ្ឌិត្យដោយរួសរាន់ ឲ្យទាន់មុនថ្ងៃ ៣១ ខែឧសភា (ម៉ែ) ឆ្នាំនេះ, ក្រោយពីពេលនេះទៅ មន្ទីរពុទ្ធសាសនបណ្ឌិត្យនឹងចាត់ចែងចំណាយសៀវភៅដែលខុតដូននោះ ទៅឲ្យអ្នកឯទៀតហើយ បើលោកអ្នកណាដែលចូលមកពុំរួច ក៏សូមឲ្យដំណឹងតាមសំបុត្រទៅមន្ទីរពុទ្ធសាសនបណ្ឌិត្យ ឲ្យទាន់ពេលខាងលើនេះដែរ ដោយសុំឲ្យជាក់ទីលំនៅផ្ទះក្នុងសំបុត្រនោះឲ្យបានច្បាស់លាស់ផង។

សូមអស់លោក-អ្នកជ្រាបថា ការចុះពុម្ពសៀវភៅព្រះត្រៃបិដកនោះ ជាការពិបាកណាស់ ហើយមិនងាយនឹងរើចុះឡើងវិញទេ។

ដូច្នេះ សូមអស់លោក-អ្នករៀសរៀវទៅបើកនឹងជាវសៀវភៅនោះកុំបណ្តែតបណ្តោយឲ្យយឺតយូរហួសកំរិតថ្ងៃខាងលើនេះឡើយ។

ភ្នំពេញថ្ងៃ ២០ កុម្ភៈ ឆ្នាំ ១៩៥៣



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជើរឿង	ទំព័រ
— វិជ្ជាទិកថា	ព្រះមហា ជាប — ប៊ិន	១៦៣
— សង្គាយនាព្រះត្រៃបិដកប្រទេសកម្ពុជា ..	ពុទ្ធសាសនបណ្ឌិត្យ	១៧៩
— កថិនកថា	ព្រះមហាឧត្តមវិជ្ជា កែ — ឿន ..	១៩២
ផ្នែកអក្សរសាស្ត្រ		
— ការបណ្តុះនិស្ស័យ (តមក)	ព្រះមាកឧត្តមវិជ្ជា ប៊ុង - ប៊ម	១៩៦
— រឿងសាមកុក (តមក)	ឧកញ៉ា នូ - កន	២០៣
— រឿងអារ័ក្សថ្លែងរឿងម្តែជ្រាំ (តមក) ...	លោក ភ័យ - ប៊ុត	២១០
— រឿងស្នាប់ព្រោះជាតិ (តមក)	ពេញ គង់ — លឹម	២១៧
— រឿងប៉ូលនឹងវីរ៍ស៊ីនី (តមក)	លោក ឆេង - ជ្រឿ	២២៤
កំណត់ទឹងប្រវត្តិការណ៍		
— សន្និសិទព្រះពោធិវង្ស ហួត - ងាត អំពី សមាជសាកលលើកទី ២ នៃពុទ្ធសាសនា	(តមក) ពុទ្ធសាសនបណ្ឌិត្យ ...	២២៩
— សុន្ទរកថាបណ្ឌិតម៉ាល៉ាឡ៊ះសេកេរៈថ្លែងក្នុង សមាជសាកលលើកទី ២ នៃពុទ្ធសាសនា	(តមក) ពុទ្ធសាសនបណ្ឌិត្យ	២៣៤
— បញ្ជីរាយនាមភៅអធិការដែលតាំងឡើ(តមក)	ក្រសួងធម្មការ	២៣៩

មួយឆ្នាំមាន ១២ សៀវភៅ — ជំរៀងដារ ១៩២៣. ០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE

		Pages
— Vijjadikatha.....	*Brah maha Chap-Bin*	163
— Notice sur le Tripitaka Cambodgien	*Institut Bouddhique*	179
Kathinakatha.....	*Brah Maha Ker-œurn*	192

PARTIE LITTERAIRE

— Education morale (suite)....	*Vén. Pœung-Pam*	196
— Histoire de SAMŒK (suite)..	*Oknha Nou-Kan*	203
— Les vingt cinq récits du Mauvais Génie (suite)	*M. Ray Buc*	210
— Mort pour la patrie (suite) ...	*M. Kong-Lim*	217
— Paul et virginie (suite)	*M. Phéng-Chrieu*	224

NOTES ET CHRONIQUES

— Conférence du Vén. Brah Bodhivangs HUOT-TATH sur le 2e Congrés Mondial Bouddhique (suite)	*Institut Bouddhique*	229
— Discours du Dr. MALALASEKERA au 2e Congrés Mondial Bouddhique	— —	234
— Nomination des nouveaux Chau-adhikar suite	*Ministère des Cultes*	239

Prix d'abonnement annuel comprenant 12 numéros : 1928$00

វិជ្ជាធិកថា

ព្រះមហា ចាប-បិន មេធង្គ វត្តបទុមវតី ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ កើត ខែមិគសិរ ឆ្នាំជូតសំរឹទ្ធិស័ក ព.ស. ២៤៩១ (១៦ – ១២ – ៤៨)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការបំពោះព្រះរតនត្រ័យគឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយសេចក្តីគោរព ។

ពេលនេះ អាត្មាភាពនឹងសំដែងព្រះសទ្ធម្មទេសនា អំពី "វិជ្ជាធិកថា" ផ្សាយតាមវិទ្យុកម្ពុជា ថ្វាយខ្ញុំ នឹងបែកជូនអស់លោក-អ្នក ឲ្យបានស្តាប់ដូចតទៅនេះ :-

ធម្មំ វិជ្ជាសមំ ឯវំ ធម្មំ ព្យាធិសមារិយោ
ធម្មំ អត្ថសមំ បេមំ ធម្មំ កម្មសមំ ពលំ

ព្រះធម្មកថានេះ បែកជា ៤ បទ គឺ :

១ – មានទ្រព្យមិនស្មើនឹងមានវិជ្ជា

២ – សត្រូវអ្វីមិនស្មើនឹងព្យាធិ

៣ – ស្រឡាញ់អ្វីមិនស្មើនឹងស្រឡាញ់ខ្លួន

៤ – កម្លាំងអ្វីមិនស្មើនឹងកម្លាំងកម្ម ។

មានទ្រព្យមិនស្មើនឹងមានវិជ្ជា ... បណ្តាទ្រព្យទាំងឡាយដែលមានវិញ្ញាណក្តី គ្មានវិញ្ញាណក្តី សុទ្ធតែជារបស់ដែលមហាជនគ្រប់គ្នាត្រូវការចូលចិត្តបាន ។ ក៏ឯទ្រព្យទាំងនេះ ដែលគេនឹងបានមកក៏ដោយ ឈរតែទស្សាហ៍ប្រកបការងារ មានពាណិជ្ជកម្ម កសិកម្ម ធ្វើការក្នុងក្រសួងណាមួយឬស៊ីឈ្នួលធ្វើការឲ្យគេជាដើម ទើបកើតឡើងបាន មិនមែនកើតមានឯង ។ នោះទេ លុះកើតមានហើយតោងបីបាច់ថែរក្សាទុកជាក់ផង ទើបគង់នៅបាន ព្រោះថាទ្រព្យទាំងនោះតែងប្រកបដោយអន្តរាយ ៤ យ៉ាង គឺ ភាជនន្តរាយ = វិនាសដោយព្រះរាជាវបជាន់ អូសយកព្រោះខ្លួនប្រព្រឹត្តទុស្សច្បាប់សម្រាប់នគរ ១, ចោរន្តរាយ = វិនាសដោយចោរលួចប្លន់ដណ្តើមយក ១, ទេយ្យន្តរាយ = វិនាសដោយទឹកលិចឬភ្លើងឆាបឆេះក្នុងទីតំ ១ អគ្យន្តរាយ = វិនាសដោយភ្លើងនេះ ១, ឬក៏ត្រូវអន្តរាយឯទៀតមានកណ្តៀរកោរ កណ្តុរកាត់ពុកផុយស្អុយរលួយទៅក៏សឹងមាន ។ ទ្រព្យនោះបុគ្គលស្វែងរកដោយលំបាក ដួងណាបាន ដួងណាមិនបាន ហើយលំបាកថែរក្សាឲ្យគង់ទៀត ព្រោះហេតុនោះបានជាព្រះគន្ថមុនីត្រាស់ថា: ធនំ វិជ្ជាសមំ ធនំ ទ្រព្យអ្វីមិនស្មើទ្រព្យគឺវិជ្ជា ។

វិជ្ជានេះប្រែថា ចេះច្បាស់ ចេះសព្វ ។ ចេះច្បាស់,ចេះសព្វយ៉ាងណា ហៅថាវិជ្ជា ? ។ បុគ្គលណាមួយចេះធ្វើកិច្চការគ្រប់ពួកមាន ចេះអក្សរសាស្ត្រ, លេខនព្វង្គ, ចេះគាសា, ចេះសរសេរ, ចេះនិយាយ

ចេះធ្វើការជាងឥដ្ឋ, ជាងកំបោរ, ជាងឈើ, ជាងដែក, - ជាងច្រាក់, ជាងមាស ប៉ុណ្ណេះជាដើម ហៅថា មនុស្សមានវិជ្ជា ។

វិជ្ជានេះដែលនឹងកើតឡើង ក៏ដោយសារសេចក្តីព្យាយាមរៀនសូត្រប្រឹងខំត្រិះរិះពិចារណាយកចិត្តទុកដាក់ឲ្យចេះចាំស្ទាត់ ទើបជាហេតុឲ្យកើតកោតទ្រព្យ ព្រោះថាកោតទ្រព្យទាំងពួងដូចសំពត់អាវ, តុតាំង, ផ្ទះសម្បាប់នៅ ព្រមទាំងរបស់ប្រើប្រាស់គ្រប់មុខ រហូតដល់ត្រយ៉ាងថ្លៃថ្លាមានមាសពេជ្រដែលគេនិយមថា មានដំឡៃគួរច្រាថ្មាច់ធំបាននោះ ដែលនឹងល្អរិសេសបាន ក៏ដោយស្មាដៃក្មេងមានវិជ្ជារចនាឡើងទើបល្អទៅកើត ។ មាសពេជ្រនៅទាំងដុំ ។ យកមកធ្វើជាគ្រឿងស្អិតស្អាងឯណាកើត លុះណាតែអ្នកចេះធ្វើខាងគ្រឿងមាសពេជ្ររចនាឡើង ទើបយកមកប្រើប្រាស់សមសម័យបាន ។ របស់ដែលប្រើប្រាស់ក្នុងលោកទាំងមូល សុទ្ធតែកើតពីជាតុទាំងអស់ ជាតុ ៤ មានអស់ទៅឯណា ស្រុកទេសណាគេចេះត្រៃឡែយកប្រយោជន៍ពីជាតុ ៤ គេក៏បានរបស់សម្រាប់ប្រើបរិបូណ៌ឥតខ្វះ តែបើខ្វះមនុស្សចេះហើយ មុខជារស់តែនឹងប្រើដោយសារគេមិនខាន ។ ទឹកពេញទាំងទន្លេស្ទឹងបឹងបួរ ប៉ុន្តែបើខ្វះវិជ្ជាខាងមាស៊ុនទឹកហើយ មុខជាផឹកទឹកទាំងល្អក់មិនខាន ។ ព្រោះហេតុនោះហើយទើបពោលថា: "វិជ្ជាជាទ្រព្យប្រសើរលើសទ្រព្យគ្រប់យ៉ាង" ។ អ្នកដែលតាំងខ្លួនជាអ្នកមាន, សេដ្ឋី, គហបតី, នាម៉ឺនសព្វ

មុខមន្ត្រី រហូតដល់ទៅជាស្តេចផែនដីបាន ដោយសារតែអ្នកនោះមានសេចក្តីចេះដឹងនៅក្នុងខ្លួន ទើបគេលើកឲ្យធ្វើធំបាន គួរជាបច្ចុះ គ្រប់ក្រសួងតាំងអស់ គ្មានមនុស្សល្ងង់ណាធ្វើការបានទេ ទុកណាជាមានសម្បត្តិច្រើនយ៉ាងណាក៏ដោយ ក៏ឲ្យធ្វើធំពុំកើត ព្រោះមិនអាចសម្រេចកិច្ចការក្នុងក្រសួងនោះដោយសិរីបាន គេត្រូវការតែមនុស្សមានវិជ្ជាប៉ុណ្ណោះ សម្រាប់ឲ្យធ្វើធំតែម្យ៉ាង ។ ម្យ៉ាងទៀតស្រុកណាមានគេចេះច្រើន លោកធ្វើធម៌ច្រើន ស្រុកនោះបំពេរុងរឿងលើសស្រុកដែលល្ងង់ខ្លៅ ។ ធម្មតាអ្នកមានវិជ្ជាអាចពន្យល់អ្នកឯទៀត ឲ្យចេះដឹងឲ្យអាចហ៊ានឲ្យបានលូតលាស់ ដូចប្រទីបធំតែមួយអាចកំចាត់ងងឹតចំនួនច្រើនឲ្យក្លាំព្រោងព្រាតបាន ។ អ្នកមានវិជ្ជា អាចញុំាងវង្សត្រកូលឲ្យមានដំណែកអូបសុះសាយត្រមាំងដួយការពារមិនឲ្យសត្រូវបៀតបៀន មានតែគេគោរពគោតខ្លាចជានិច្ច ។ ឈើផ្កាត្រកអូបដុះកន្លងព្រៃណា អាចផ្សាយក្លិនឲ្យដឹតជាប់ដល់ឈើក្បែរខាងឆង មានគេត្រូវការចេះទៅស្តិតស្អាងជាហូរហែ សូម្បីសត្វកន្ទុំសត្វយុំ ក៏ចូលចិត្តចោមរោម ត្រែបយកវាសជាតិដែរ សេចក្តីនេះដូចកង្កែកូលណាដែលមានដំរេវិជ្ជា ក៏អាចធ្វើឲ្យរុងរឿងដូច្នោះ ។

មនុស្សល្ងង់ប៉ើទុកណាជាទំស្តិតស្អាងខ្លួនឲ្យបានល្អល្អះយ៉ាងណាដើម្បីឲ្យគេកាន់គំនិតយល់ថាជាមនុស្សមានដំរេក្តាជ្ញា ក៏គង់តែបញ្ចេញសេចក្តីល្ងង់ខ្លៅឲ្យគេដឹងបានកន្លងពេលចាត់ការ ឬពេលនិយាយការមិនខាន សេចក្តីនេះសមដូចគាថាលោកសំដែងថា:

មួយទៀបិ គោភតេ តារិតំ សភាយំ
វិស្សេវេស្តិតៈ តារិប្ប គោភតេ មួយទៅ
យារិតំ កិចិន្ត ភាចតេ

មនុស្សល្ងង់ចូលកន្លែងទីប្រជុំ ល្អបានដោយសារតែមានគ្រឿងសម្លៀកបំពាក់ត្រឹមត្រូវតាមសម័យប៉ុណ្ណោះ ម្យ៉ាងទៀតមនុស្សល្ងង់បើមិនចាន់ហានិយាយការទេ ក៏នៅជាល្អស្រស់បស់បាន ពេលណាតែហានិយាយឡើងក៏បញ្ចេញសេចក្តីល្ងង់ ឲ្យគេដឹងថាជាមនុស្សមិនបានការក្លាម ។

អជាតមួតមួទិនំ វិរមាទ្បៅ ន បាតិមៈ
សក្ខុនះខតរាវិទ្យា វិត្តិមន្ត បទេ បទេ

បណ្តាកូនមិនចាន់តើត ទីឯកូនតើតហើយស្លាប់ទៅវិញ កូនទាំងពីរខាងដើមនេះប្រសើរជាង ព្រោះឲ្យទុក្ខដល់ម្តាយឪពុកម្តងមួយគ្រា តែកន្លងតើតទីឯស្លាប់ប៉ុណ្ណោះ កូនដែលល្ងង់ខ្លៅឲ្យទុក្ខម្តាយឪពុកកាល់ ។ ដំហាន ព្រោះកូនល្ងង់ទៅណាឆ្ងាយច្រើនមានគ្រោះថ្នាក់ ហើយមិនអាចរកសម្បត្តិទ្រព្យ ចិញ្ចឹមជីវិតឲ្យបានស្រួលទេ ច្រើនតែជួបប្រទះនឹងសេចក្តីទុក្ខវេទនា ។

វិជ្ជាជាទ្រព្យវិសេស ប្រើមិនអស់ មិនចេះវិនាសដោយហេតុដទៃ ចោរលួចមិនបាន មានគាថាជាគ្រឿងអាងថា :

សិប្បសមំ ធនំ នត្ថិ សិប្បំ ចោរេ ន គណ្ហតេ
ឥធ លោកេ សុខំ មិត្តំ បរលោកេ សុខាវហំ

ទ្រព្យអ្វីស្មើនឹងវិជ្ជាសាស្ត្រមិនមាន វិជ្ជាចោរលួចមិនបានក្នុងលោកនេះ ជួចមិត្តសម្រាប់ឲ្យសេចក្តីសុខ លុះទៅលោកឯមុខក៏នាំឲ្យបានសុខទៀត ។

ទ្រព្យសម្បត្តិដទៃ ចោរលួច ភ្លើងឆេះ ឬវិនាសដោយហេតុផ្សេង ។ បាន ទ្រព្យគឺវិជ្ជានេះ ចោរលួចមិនបាន ភ្លើងមិនឆេះ ទឹកមិនលិចប្រើណាសឹងតែតិចថ្មី កាត់ថ្លៃមិនបាន ដោយហេតុនេះហើយទើបថាជារបស់ប្រសើរយ៉ាងឯក ។ វិជ្ជាសូម្បីបន្តិចបន្តួចក៏ដោយចុះឲ្យតែចេះចាំស្ទាត់ពិតប្រាកដ ក៏គង់ចិញ្ចឹមប្រាណបាន ដូចជាបុរសម្នាក់កំព្រាអនាថាខ្វិនខ្វល់ដៃដើង ប៉ុន្តែចេះឆ្លាក់គ្រាប់ក្រសែឲ្យខ្ទុះស្វឹកឈើនៅលើដើមធ្វើជាក្បាច់រចនារូបសត្វផ្សេង ។ ព្រះរាជាទ្រង់ទតឃើញសត្វព្រះរាជហឫទ័យដោយស្នាដៃបុរសនោះ ក៏យកទៅចិញ្ចឹមចែកក្បាប្រចានរបស់គ្រប់មុខសម្រាប់ប្រើប្រាស់ ព្រមទាំងស្រូកសម្រាប់ឡើងសួយសារអាករទាំងបួនទៀត ឡើងថ្នាក់ជាអ្នកមានស្តុកស្តម្ភ ពេលនោះព្រះពោធិសត្វឃើញហេតុអស្ចារ្យដូច្នោះ ពោលសរសើរដោយសេចក្តីពេញចិត្តថា:

សាធុខោ សិប្បកំ នាម អបិ យាទិសី កីទិសំ
បស្ស អដ្ឋិប្បហារេន លទ្ធា គាមា បតុទ្ធិសា

គួរឲ្យស្ញើចដែរ ! សិល្បវិជ្ជាបន្តិចបន្តួចសោះ តែឲ្យបានជាមានផល គ្រាន់បើ (បពិត្រព្រះអង្គ) សូមទ្រង់ទតមើលស្រុកស្ងួយក្នុងទិសទាំងបួន បុរសខ្វិនបានដោយសារតែវិជ្ជាចេះបាញ់គ្រាប់គ្រួសប៉ុណ្ណោះ ។

ឯព្រះពុទ្ធសាសនាទាំងមូល ព្រះពុទ្ធជាម្ចាស់ទ្រង់លើកវិជ្ជាសេចក្តីចេះដឹងនេះជាកំពូលលើធម៌ទាំងអស់ ដូចជាឧបាសក ឧបាសិកាដែលធ្វើបុណ្យកុសលឲ្យបានត្រឹមត្រូវពេញលក្ខណៈ តំណាយសារការយល់ផ្លូវព្រះពុទ្ធសាសនាជាមុន ទើបជាកិច្ចដ៏ឃើញនឹងប្រតិបត្តិតាម ឬមួយដូចជាភិក្ខុសាមណេរ បើមិនចេះរៀនសិក្ខាសម្រាប់ខ្លួនទេ ក៏ធ្វើជាភិក្ខុសាមណេរពុំកើត ។ សីល សមាធិ បញ្ញា ជាកិច្ចដែលភិក្ខុត្រូវបំពេញ ក៏ព្រះអង្គលើកយកបញ្ញាគឺវិជ្ជាជាប្រធាន អាចកំចាត់សត្រូវគឺលេសយ៉ាងល្អិតសុខុមជាការគ្រលំបាកបាន ។

ព្រះអរិយម្ចាស់ទាំងឡាយ ដែលបានឡើងថ្នាក់ជាមនុស្សយ៉ាងពិសេសនោះក៏ដោយសារគុណគឺវិជ្ជា ៣ វិជ្ជា ៨ នោះឯង ព្រះពុទ្ធជាម្ចាស់ ទំស្ងួរស្វែងកសាង ៤ អសំខេយ្យ នឹង ១ សែនកប្ប ខឿយព្រួយលំបាកព្រះអង្គកាយវាចាចិត្តកិរិយា ព្រមទាំងជីវិតឲ្យទៅជាទាន ក៏ព្រោះតែបុព្វចរិយាបានពោធិញ្ញាណគឺវិជ្ជាហ្នឹងឯង ។

សាធុជនទាំងឡាយ ! បើបានជ្រាបវិជ្ជាផ្លូវលោកផ្លូវធម៌ជាគុណជាតមានដំឡៃយ៉ាងនេះហើយ គួរណាស់តែទំស្ងួរស្វែងរករៀនវិទ្យាសាស្ត្រដែលជាប្រយោជន៍សំខាន់សម្រាប់បណ្តុះបណ្តាល ឲ្យកើតទ្រព្យសម្បត្តិ

ផងដើម្បីជាសេចក្តីថ្លៃថ្នូរកងខ្លួនផង ដើម្បីជាគ្រឿងការពារសេចក្តីអន្តរាយគ្រប់យ៉ាងផង ។ ឯការស្វះស្វែងរកដំរេះវិជ្ជានេះ លុះណាតែសេពគប់មិត្តកល្យាណមានប្រាជ្ញាជាមុនសិន ទើបនឹងបានជាជំនួយខ្លួនឲ្យ**ឈ្លាស**មនុស្សបេះដឹង បើសេពគប់មនុស្សល្ងីវិញ មុខជាបានតែសេចក្តីល្ងង់ខ្លៅប៉ុណ្ណោះ ដូចជាកាសិតរបស់សេដ្ឋីម្នាក់ប្រដៅកូនរបស់ខ្លួនថា:

ហីយតេ ហិ មតិស្តាត ហីនេ សហសមាគមាត
សមែប្ប សមគាមេតិ វិតិថ្លែប្ប វិតិប្តតាម

នែកូន! សេចក្តីពិតថា គំនិតរបស់មនុស្សបើសេពគប់មនុស្សថោកទាប ក៏ថោកទាបទៅតាម បើសេពគប់មនុស្សថ្នាក់កណ្តាល គំនិតក៏នៅជាកណ្តាល បើសេពគប់មនុស្សខ្ពង់ខ្ពស់ គំនិតនោះក៏ខ្ពស់ទៅតាមដែរ ។

មនុស្សខ្លិលច្រអូសមិនចំរើនសូត្រមុខតែគ្មានវិជ្ជា បើគ្មានវិជ្ជាហើយកុំសង្ឃឹមឡើយ មុខជាឃ្លាត់ឆ្ងាយអំពីសេចក្តីល្អគ្រប់យ៉ាងដែលខ្លួនត្រូវចង់បាន តាំងពីជាតិនេះរហូតដល់ព្រះនិព្វានជាទីបំផុត ព្រោះមានគាថាកង់គម្ពីរលោកនីតិប្រដៅថា:

អលសស្ស កុតោ សិប្បំ មនុស្សខ្លិលគ្មានវិជ្ជា
អសិប្បស្ស កុតោ ធនំ បើគ្មានវិជ្ជា ទ្រព្យក៏គ្មាន
អធនស្ស កុតោ មិត្តំ តែគ្មានទ្រព្យហើយ មិត្តក៏គ្មាន

អរិត្តសុ្ស កុតោ សុខិ តែគ្មានមិត្តហើយ សុខក៏គ្មាន
អសុខសុ្ស កុតោ បុញ្ញំ តែគ្មានសុខហើយ បុណ្យធ្វើមិនកើត
អបុញ្ញសុ្ស កុតោ និព្វានំ តែគ្មានបុណ្យហើយ និព្វានក៏គ្មាន ។
ការដែលសូន្យសេចក្តីល្អមកអំពីមិនរៀន ដូចបានអធិប្បាយមកនេះ ។

សត្រូវអ្វីមិនស្មើនឹងព្យាធិ ... ពាក្យថា "សត្រូវ" គឺជាតួឧបសគ្គចូលមកកំចាត បៀតបៀនបំផ្លិចបំផ្លាញ ក្នុងរូបមនុស្សម្នាក់ ។ ធ្វើឲ្យទទួលគ្រោះថ្នាក់ជាទម្ងន់ ឬឲ្យដល់នូវសេចក្តីស្លាប់ក៏មាន ដូចជាសត្វសាហាវ ចោរកំណាចមកធ្វើឲ្យកើតទុក្ខដល់ខ្លួន ទើងវិនាសទ្រព្យសម្បត្តិ ជាដើមហៅថា "សត្រូវ" ។ ប៉ុន្តែសត្រូវខាងក្រៅដូចបានរៀបរាប់មកនេះ បើកាលណាបានជួបប្រទះហើយ គេអាចតតាំងកាំងការឲ្យឈ្នះដៃ ឲ្យវិនាសទៅ ដោយកំឡាំងកាយ ដោយទ្រព្យដោយសេនាពល ដោយឧបាយកលជាដើម ប៉ុន្តែការទៅក៏បានខ្លះ ហើយសត្រូវខាងនេះ មិនមែនបៀតបៀនពាល់រូបមនុស្ស គ្រប់ពេលវេលានោះឡើយ ជួនកាលជួបប្រទះ ជួនកាលមិនជួបប្រទះ បើទុកណាជាមានខ្លះ ក៏មិនញឹកញាយប៉ុន្មាន ចំណែកសត្រូវ គឺព្យាធិតែងរុកពន់ទន្ទ្រានក្នុងរូបកាយសត្វច្រើនលើសលុបសត្រូវឯទៀតៗ ។

ព្យាធិ ប្រែថា "ជម្ងឺ, ពេគា" ដែលធ្វើសត្វឲ្យក្តៅផ្សុះច្រើនបែប ច្រើនសណ្ឋានដូចមានសំដែងដោយពិស្តារក្នុងគីរីមានន្ទសូត្រ ។. សត្រូវនេះ

ធ្វើឲ្យកើតទុក្ខដល់រូបមនុស្សមិនរើសថា ធំ-តូច មានគ្រែទេ ឲ្យតែមានជាតិហើយគង់តែមានជរាពាធិ ប្រចាំសង្ខារជានិច្ច ចូលមកញាំញីគេចរៀសទៅណាមិនផុត ពឹងឲ្យគេជួយមិនបាន ដំរេរដ្ឋាប្រាជ្ញាសម្បត្តិការពារសត្រូវមៃរនេះពុំបាន សូម្បីគ្រែពេទ្យយ៉ាងចំណានទាន់រំពេលំ្ងាំបំបាត់ពេត ក៏គង់ដំមិនរួចតែកណ្តាប់ដៃភ្យាធិដែរ មិនតែមនុស្សហាមញ្ញាទេ សូម្បីតែព្រះមុខីសាស្តាលើកែតពកំទ្រេងព្រះឈ្មួនដែរ ដូចគាលសោយចង្ហាន់ខ.យក្ខុន ។

អធិប្បាយមកនេះ យើញថាភ្យាធិជាសត្រូវយ៉ាងសម្បើម គ្មាននរណាគេចរួចខ្លួនមែនហើយ រូបកាយយើងពុំគ្រា ជាទីអាស្រ័យនៃពេតផ្សេង ។ ពិតមែន បើខុកណាជាដូច្នោះ ក៏មិនត្រូវបណ្តាយឲ្យដាច់ស្រេចលើសង្ខារនោះមិនបានសុខទេ ត្រូវយើងថាក់ថ្នមរូបកាយ កុំឲ្យត្រូវគ្រោះថ្នាក់ ប្រយ័ត្នខាងពេតានាម័យឲ្យមិនត់ចត់ អាហារចំណីឯណានាំបណ្តាលឲ្យខាស់ ត្រូវរៀងគុំបរិភោគ ពេតឯណានាំឲ្យឆ្អែតពីមួយទៅមួយត្រូវយើងបៀសឲ្យឆ្ងាយ ហើយត្រូវទុស្សាហ៍ចោសសំអាតទីលំនៅនឹងដុសលាងត្រឹងស្អុកតាក់ខ្លួនប្រាណឲ្យស្អាតបាត ព្រមទាំងទុស្សាហ៍ប្រកបរំដំហាត់ប្រាណ ដើបជាហេតុបៀសវាងជំងឺមិនឲ្យបានខ្លះ ។ រូបយើងដូចជារត្រឹងចក្រ ។ នោះ បើប្រើមិនថ្នាក់ថ្នមក៏ធ្លាប់រំនាសអន្តរាយរូបកាយយើង បើមិនបានថែទាំ ក៏ដូច្នោះដែរ ។

ព្យាធិនេះយើងចៀសវាងមិនផុតមែន ប៉ុន្តែត្រូវយើងរកឧបាយសម្រាប់ការពារខ្លះ កុំឲ្យវាមានអំណាចញាំញីខ្លាំងពេក បើបណ្តោយស្រែចលើសង្ឃាតាក់តែងហើយ មុខជាលំបាកវេទនា ដោយសារពេតបៀតបៀនពេញបន្ទុកមិនខាន ។

ស្រឡាញ់អ្វីមិនស្មើនឹងស្រឡាញ់ខ្លួន.— ពាក្យថា "ខ្លួន" នេះ ក្នុងគម្ពីរអភិធានទីបីតាសូចិ លោកសំដែងបញ្ជាក់ថា: ស្ពុ ខ្ទុ ក្ខ្ពុ អ្នទ្ធ: ខាទ្ធពីតិ > អ្នត្តា សភាវៈដែលទំនាស់ប្លុងឲ្យដឹងសុខទុក្ខ ហៅថា អ្នត្តា គឺ "ចិត្ត" ។ អាយវៈធំ - តូច មានដៃជើងជាដើម ហៅថា "កាយ" ប្រែថា ប្រដុំ ។ រួមកាយនឹងចិត្តទាំងពីរ ហៅថា "អ្នត្តា គឺខ្លួន" ឬឯហៅថា "ជីវិត" ក៏បាន ។ មនុស្សសត្វទាំងអស់ស្រឡាញ់ខ្លួនលើសជាងវត្ថុគ្រប់យ៉ាង បានជាមានមនុស្សដេរដាសទាំងប្រពៃគ្រប់សាសន៍ ខំធ្វើការ មិនគិតខ្សោយហត់ក៏ដើម្បីយកទៅចិញ្ចឹមខ្លួន ខំនុកបម្រុងឲ្យបានសេចក្តីសុខ ទើបខំនុកបម្រុងអ្នកជិតខាងឯក្រៅ ។ ការស្រឡាញ់ខ្លួននេះ កុំថាឡើយតែមនុស្សមានរូបកាយសមរម្យសសត្តិខ្ពស់នោះទេ, សូម្បីតែមនុស្សកំចាត់កំបែកខ្វាក់ខ្វិនយ៉ាងណាក៏ដោយ ក៏គង់តែស្រឡាញ់ខ្លួនរបស់គេជាជាងអ្នកជិតខាងទើបខំប្រឹងដើរសុំទានគេស៊ី ធ្វើការឈ្លួលឲ្យគេដើម្បីតែចិញ្ចឹមខ្លួន ។ បុត្តកវិយា ស្វាមី មាតា បិតា ពាប់ថាជាទីស្រឡាញ់ពេញចិត្តណាស់ហើយ

តង់តែនៅបន្ទាប់ពី ២ អំពីខ្លួនទោះទៀត ។ មានអ្នកខ្លះអួតថាខ្ញុំសព្វថ្ងៃ
ស្រឡាញ់មាតាបិតាបុត្តភរិយាលើសជាងខ្លួន ខំធ្វើការរកស៊ីទាំងប៉ុន្មាន
ក៏ដើម្បីចំណុកបម្រុងអ្នកទាំងនោះប៉ុណ្ណោះ ពាក្យនេះបើពិនិត្យឲ្យល្អិតទៅ
ឃើញថាជាការមិនពិត បើថាស្រឡាញ់លើសខ្លួនមែន ចុះហេតុអ្វីក្នុង
ពេលមានអាសន្នម្តង ។ ឥពុកម្តាយ កូនប្រពន្ធរត់យកតែអាយុរៀង ។ ខ្លួន
ក្លែចគិតគឺគ្មានឃើញនរណាស៊ូប្តូរ ស្ទាប់ដួសរូបគេសោះ លុះចាត់
ក័យទើបគិតរកគ្នាវិញ ដួនកាលទុំក្បែរអត់ឃ្លានពេកណាស់ទៅ ក៏ក្លែច
គ្នាដូចជាពេលមានក័យដែរ មានរឿងមួយក្នុងគម្ពីរធម្មបទថា គោតុហលិក
បុរសខ្វាចអហិរិកពេក នាំភរិយាមានកូនតូចមួយ រត់គៀសខ្លួនអំពី
អលួកប្បរដ្ឋទៅទៅក្រុងកោសម្ពីក៍ ពេលទៅនោះ អស់ស្បៀងអាហារ
កណ្តាលផ្លូវ មានសេចក្តីស្រេកឃ្លានណាស់ ចោះកូនចោលក្នុងព្រៃ
លុះដល់ក្រុងកោសម្ពីក៍ គេឲ្យអាហារពីរចំណែកមក បរិភោគម្នាក់ឯង
មិនចែកប្រពន្ធទៀត បើយ៉ាងហ្នឹងតើឲ្យឈ្មោះថាស្រឡាញ់អ្នកដទៃ ទឹង
ឲ្យសម្បត្តិលើសជាងខ្លួនឯណាបាន ។ ការស្រឡាញ់ខ្លួនឃើញជា
ការពិតដូច្នោះមែន ប៉ុន្តែបើស្រឡាញ់ហើយ គ្មានតែស្ងៀតពាក់ឲ្យ
តែខាងល្អ បរិភោគស្រេកតែឆ្ងាញ ចាយឲ្យតែហ៊ុំហា ប្តូកំតួនសម្
បំប្រែសំពំប្រែងម្សៅតួនទៅតែក្តីធ្លុះ មិនហ៊ានធ្វើការខ្វាចខ្មីយហត់
បែបនេះឲ្យឈ្មោះថាស្រឡាញ់មិនបាន ហៅថាបំផ្លិចបំផ្លាញខ្លួនទៅវិញ

ឯការស្រឡាញ់ខ្លួនត្រឹមត្រូវនោះ លុះណាតែលែងពេលវេលាកប្រយោជន៍សម្រាប់ខ្លួន គឺនៅពីរយ៉ែងក្នុងត្រូវរៀនដំរេះវិជ្ជាឲ្យបានចំណាន រួយកណ្តាលត្រូវចំរេកឲ្យសន្សំទុកឲ្យបានច្រើន រួយចាស់ជាត្រូវកសាងសេចក្តីល្អគឺធ្វើទានរក្សាសីល សម្រាប់បន្តព្រេងសំណាងទៅតមុខទៀត មិនត្រូវបណ្តោយខ្លួនឲ្យពុកផុយរលួយមិនបានថ្លៃថ្នាមោះឡើយ ព្រោះថារូបយើងដូចគ្នានឹងរថយន្ត ធម្មតារថយន្ត បើទិញមកហើយមិនចេញដួញជាក់តែចោល យើញវាអស់តម្លៃទេ លុះណាតែផ្តុកទំនិញចេញដួញទើបមានប្រយោជន៍ រថគឺរូបកាយយើងត្រូវដួញគឺរៀនសូត្រវិជ្ជា ស្មើនរកសម្បត្តិនឹងធ្វើសេចក្តីល្អ ទើបមានកម្រៃអំពីខ្លួនវិញបាន ។

កំឡុងអ្វីមិនស្មើនឹងកម្លាំងកម្ម — កម្ម: ប្រែថា "អំពើប្រការ" គឺកិច្ចដែលគេត្រូវធ្វើ ។ អំពើនោះចែកជាពីរចំណែក គឺអំពើអាក្រក់ ១, អំពើល្អ ១; អំពើណាធ្វើទៅហើយមានការបៀតបៀនបំផ្ទិចបំផ្ទាញឲ្យគេក្តៅក្រហាយ អំពើនោះហៅថាអំពើអាក្រក់ អំពើណាធ្វើទៅហើយបានផលជាសុខមានតែកម្រៃប្រយោជន៍ ដល់ខ្លួនទឹងអ្នកដទៃមិនមែនជាអំពើសម្រាប់បៀតបៀនគ្នាឲ្យក្តៅក្រហាយវិនាសទ្រព្យសម្បត្តិ ហៅថាអំពើល្អ ។ កម្មទាំង ២ នេះមានកម្លាំងធ្ងន់លើសជាងកម្លាំងឯទៀត គោ ក្របី ដំរី សេះ គ្រឿងចក្រគ្រប់មុខ ពាប់ថាមានកម្លាំងខ្លាំងមែន អាចដឹកនាំវត្ថុធ្ងន់ៗទៅបានដោយងាយ ប៉ុន្តែគេអាចបន្ទរបន្ទាយ បញ្ឈប់

តាមសេចក្តីប្រាថ្នារបស់គេ មិនជាការគ្រលំបាកប៉ុន្មាន ចំណែកកម្ចាំង
កម្មតាំងពីខ្លាំងលើសលុបជាងអ្វីតាំងអស់ គ្មានអំណាចអ្វីមកពាំងពាត្បែរ
ជាអាក់ខានឲ្យផលទៅវិញនោះគ្មាន ធ្វើល្អទៀតតែបានល្អ ធ្វើអាក្រក់
ទៀតតែបានអាក្រក់ពិតប្រាកដ ។ នរណាមានចិត្តធ្ងរខ្វល់ឃើញជួយទំនុក
បម្រុងធ្វើមធ្វើសាធារណប្រយោជន៍ ដល់មហាជនដោយមេត្តចិត្ត
អ្នកនោះគង់បានទទួលសេចក្តីសុខ សេចក្តីពាក់អាន ឃ៉ាងប្រសើរអំពី
មនុស្សទើរខ្ពើ នរណាមានចិត្តអាក្រក់គិតប្រទូសរ៉ាយធ្វើឲ្យគេក្តៅ
ក្រហាយ គ្មានអាណិតអាសូរអ្នកដទៃ អ្នកនោះឯងតែងទទួលសេចក្តី
ទុក្ខលំបាកវេទនា ព្រោះគ្មានគេជួយទំនុកបម្រុង ឬពេលមានៈគ្រោះថ្នាក
គ្មានអ្នកណាជួយសង្គ្រោះ ។

អំពើល្អក្តី អាក្រក់ក្តី បុគ្គលណាធ្វើហើយ ទឹងគេចទៅពួនសម្ងំ
ឯណាក៏គង់មិនផុត ត្រូវតែទទួលទុក្ខទោសក្នុងជាតិនេះទឹងជាតិមុខមិនខាន
សមដូចជាគាថាដែលព្រះលោកនាថម្ចាស់ត្រាស់ថា:

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ ន បព្វតានំ វិវរំ បវិសុ
ន វិជ្ជតេ សោ ជគតិប្បទេសោ យត្រដ្ឋិតោ មុញ្ចេយ្យ បាបកម្ម

"បុគ្គលធ្វើអំពើអាក្រក់ ហើយចង់គេចឲ្យផុតរត់ទៅពួនលើអាកាស
កណ្តាលបាតសមុទ្រក្តី រូងភ្នំក្តី គង់ចាបកម្មតាមទាន់, បុគ្គលស្ថិតនៅកន
ណាដែលថាឲ្យផុតពីកចាបកម្ម ទីនោះសូម្បីប៉ុនសរសៃសក់ក៏គ្មាន"

ព្រះចាន់សុប្បពុទ្ធ ច្រៀងសរសើរព្រះពុទ្ធម្ចាស់ហើយ ខ្លាចព្រះឆវណីស្រែបរត់ទៅពួនលើច្រាសាទ ៧ជាន់ បិទទ្វារបង្អួចដិតឲ្យពួកចំបាប់នៅចាំគ្រប់មាត់ទ្វារ គង់តែមិនរួចអំពីព្រះឆវណីស្រែប ។ មិត្តវិន្ទុក:ច្រមាថមើលងាយទេតប់ម្តាយហើយទៅដួញតាមសំពៅជាមួយឈ្មួញឯទៀត តាមធម្មតាសំពៅនោះធ្លាប់ផុតមនុស្សព្រប់រយ - ពាន់ ទំនិញមិនដឹងជាប៉ុន្មានគោនដឹកនាំទៅមករួចដោយស្រួល គាន់តែមិត្តវិន្ទុក:ដែលច្រពឹត្តធ្វើអំពើលាមកម្នាក់ឡើងជិះត្រឡប់ជាកៀនទៅណាមិនរួច ធ្ងន់អ្វីម្ល៉ះមនុស្សអាក្រក់, នេះជាកំឡាំងខាងអកុសល ។ អង្គុលិមាលចោរសម្លាប់មនុស្សចោលត្រៀបត្រា រួចអំពីចោរជាតិនេះផង ចានសម្រេចអរហត្តផង ដោយសារបានជួបព្រះបរមសាស្តាហើយខំធ្វើសេចក្តីល្អ ត្រង់ហ្នឹងហើយគ្មានអ្វីស្មើនឹងកំឡាំងកម្ម ។

លោក - អ្នកខាំងឡាយកម្លាំងកម្មធ្ងន់ណាស់ គ្មានអ្វីជួយរាំងរាបានទេ បើដូច្នោះត្រូវធ្វើតែអំពើល្អច្រពៃ ការច្រកបអាជីវកិច្ចប្តូរធ្វើអ្វីក៏ដោយត្រូវចៀសវាងឲ្យផុតអំពីទុច្ចរិតឲ្យស្រឡះ កុំឲ្យដិតជាមជាហេតុបង្កឲ្យកើតទុក្ខទោសដល់ខ្លួនឡើយ ។

ពេជសា យសសោ ចាបិ វឌ្ឍយន្តោ នរុត្តមោ
សទា ភទ្រានិ សម្បស្សំ ចិរំ រជ្ជេ បតិដ្ឋតុ

(ដោយអំណាចគុណត្រៃរតនត្រ័យ) សូមព្រះប្រិយមហាក្សត្រិយ៍
របស់យើងតាំងឡាយ ដែលជាធំជាងនរជន ចានចំរើនដោយតេជៈ
ដោយយស! ហើយសូមឲ្យទ្រង់កប់ប្រសប់តែនឹងសេចក្តីចំរើនគ្រប់កាល
តាំងពួង! សូមឲ្យស្ថិតនៅក្នុងពជសម្បត្តិអស់កាលជាយូរអង្វែងតទៅ! ។

សព្វំ រដ្ឋំ សុខំ សេតិ រាជា បេ ហោតិ ធម្មិកោ

ដោយអំណាចព្រះពជាជាម្ចាស់ទ្រង់ប្រកបដោយធម៌ សូមឲ្យពលរដ្ឋតាំងអស់នៅជាសុខសប្បាយ កុំបីឃ្លាតក្លាយទៅប្រការដទៃឡើយ! ។

អាត្មាភាពសំដែងមកគង់វិស្សាទិកថាក៏អស់សេចក្តីតែប៉ុណ្ណេះ ឯវំ ។

ចប់

សុភាសិត

ធនជានអ្វី ពុំប្រពៃ ស្មើរិដ្ឋា,
ព្យាធិរោគា ឧរ្យាសា ជាងសត្រូវ,
ស្រឡាញ់ខ្លួន ជាងស្រឡាញ់ ជនខាងក្រៅ,
កម្មសព្វ មានកម្លាំង ខ្លាំងក្រៃលែង។

សន្ទនាព្រះត្រៃបិដកប្រទេសកម្ពុជា

ចាប-ពិន ថ្លែងជាកំរិតប្រទេសកម្ពុជាពីថ្ងៃទី ២-១-៥៣ ព.ស. ២៤៩៥

ផ្សាយបែញពីពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

អស់លោកអ្នកគាំងឡាយ !

ខ្ញុំបាទមានកិត្តិយស បានមកប្រស្រ័យជាមួយអស់លោកអ្នកគាំង-ឡាយ ដោយសំឡេងវិទ្យុប្រទេសកម្ពុជាក្នុងនាមនៃពុទ្ធសាសនបណ្ឌិត្យ ដើម្បីរៀបរាប់ពីសន្ទនាព្រះត្រៃបិដកប្រទេសកម្ពុជា ចែកជូនជាសណ្តាប់ដល់អស់លោក-អ្នកគាំងឡាយ ឲ្យបានជ្រាបពីដំណើរការចោះពុម្ពព្រះត្រៃបិដកនៅប្រទេសយើង ដែលអស់លោកគាំងឡាយខ្លះចាំមើលផ្លូវមកអស់កាលយូរហើយ ទុកជាប្រជាប់ការចេះដឹងនៅដុំវិញខ្លួន ។

អស់លោក-អ្នកគាំងឡាយបានជ្រាបហើយថា ពុទ្ធសាសនបណ្ឌិត្យជាមន្ទីរក្សាតម្ពីរដ៏សំខាន់ណែនវិជ្ជាផ្សេង ។ ឥឡូវជាមន្ទីរចោះពុម្ពផ្សាយនូវវិជ្ជាគាំងឡាយ គាំងផ្លូវលោកផ្លូវធម៌ ជាប្រយោជន៍ដល់ប្រទេសជាតិ ។

ព្រះពុទ្ធសាសនានៅប្រទេសយើង បើតាមការដែលយើងមើល យើញថាកើតទៅជាទំនៀមទម្លាប់ប្រទេស រាយយូរសាច់ជាឈាមប្រជាជនគាំងមូលទៅហើយ ឥតមានសាសនាណាមួយអាចចូលមកវាលាងប្លុកកន់កកាយគាស់រំលើងឲ្យចេញបានសោះឡើយ ឯការដែលយើងយកពុទ្ធ-សាសនាមកជាប្រវៃណីប្រទេសនេះជាការប្រពៃហើយ ព្រោះបានពុទ្ធ-

សាសនាដែលជាសាសនាឯក ឥតប្រែកែកបាន មកជាគោលការប្រតិបត្តិ
របស់ប្រទេសជាតិ តែយើងត្រូវដឹងទៀតថា ព្រះពុទ្ធសាសនាដែលមក
ប្រតិស្ឋាននៅប្រទេសយើងនេះអស់កាលយូរយារហើយ, ធម្មតារបស់អ្វី
មួយដែលចាស់យូរយារ តែងមានជុះជាច្រែះស្នឹមនាំឲ្យស្រអាប់ព័ណ៌ប្លែ
ឃ្លឹងឃ្លាតតក់សេចក្តីដោយអន្ទើជាជពមិនខាន ឯតួពុទ្ធសាសនា
របស់យើងក៏មានសភាពដូច្នោះដែរ អាស្រ័យដោយការមកប្រតិស្ឋាននៅ
ប្រទេសយើងយូរយារពេក ដូច្នេះគប្បីយើងខំរៀបចំតម្រឹមតម្រូវឲ្យបាន
ត្រឹមត្រូវតាមច្បាប់ដើមវិញ ដូចនាឥតាំងឡាយដែលយើងប្រើយូរឆ្នាំ
ហើយចាស់គ្រាំគ្រា ត្រូវតែយើងរៀបចំជួសជុលហើយលាបលនឲ្យបាន
ល្អដូចដើមវិញ ទុកប្រើជាប្រយោជន៍តរៀងទៅ ។

អាស្រ័យដោយហេតុដូចខ្ញុំបានពណ៌នាមកដោយសង្ខេបនេះ ទើប
ព្រះពជរដ្ឋាភិបាលបានបង្កើតពុទ្ធសាសនបណ្ឌិត្យនេះឡើង កាលពីថ្ងៃទី
២៥ មករាឆ្នាំ ១៩៣០ ដោយមានគោលបំណង៤ប្រការ គឺ:

១ - ដើម្បីស្រាវជ្រាវរកគម្ពីរដីកាក្នុងខ្មែរបុរាណមករក្សាទុកកុំ
ឲ្យវិនាសបាត់បង់ទៅ;

២ - ដើម្បីរកគម្ពីរក្នុងខ្មែរបរទេសយកមកបំពេញសេចក្តីត្រូវការ
យើងដែលខ្វះខាត;

៣ - ដើម្បីបោះពុម្ពផ្សាយទូរទៅឥតាំងឡាយ ដោយផ្លូវលោកប៊ុន
ធម៌ ជាប្រយោជន៍ឲ្យប្រជារាស្ត្រយើងមានការចេះដឹងទូលាយបរិបូណ៌ឡើង;

๔ – ដើម្បីរៀបចំលើកពុទ្ធសាសនាឲ្យបានរុងរឿងឡើង ដោយការពង្រីកការសិក្សាព្រះបរិយត្តិធម៌ មានបង្កើតសាលាបាលីជាដើមឲ្យបានផ្សាយទូលាយនៅគ្រប់ខែត្តក្នុងព្រះពាជអាណាចក្រ ;

๕ – ដើម្បីបោះពុម្ពព្រះត្រៃបិដក ឲ្យកើតមានឡើងក្នុងប្រទេសយើង ។

ពុទ្ធសាសនបណ្ឌិត្យនេះ តាំងពីបានបង្កើតមក បានបោះពុម្ពផ្សាយគម្ពីរជាធម៌អាចបំពេញសេចក្តីត្រូវការប្រជាជនខ្មែរ ជួនល្មមដល់សេចក្តីត្រូវការហើយ ខ្ញុំបាទជឿជាក់ថាតទៅអនាគតមិនយូរប៉ុន្មាន មន្ទីរនេះនឹងធ្វើការឲ្យបានសម្រេចលទ្ធផលគួរជាទីពេញចិត្តមិនខាន ។ កិច្ចការដ៏ប្រសើររបស់មន្ទីរនេះ ខ្ញុំបាទមិនបានពណ៌នាតាំងអស់ជូនជាសណ្តាប់ក្នុងពេលនេះទេ ខ្ញុំបាទសូមលើកយកតែការងារសង្គាយនាព្រះត្រៃបិដកខ្មែរយើងតែមួយមុខមកអធិប្បាយជូនដូចសេចក្តីតទៅនេះ : –

មុននឹងពណ៌នាពីសង្គាយនាព្រះត្រៃបិដករបស់យើង ខ្ញុំបាទយល់ថាគួរលើកយកការប្រៀបសង្គាយនាតាំងឡាយពីបុរាណ តាំងពីបឋមរហូតមកដល់សង្គាយនាទី ៥ ដែលរាប់ជាសង្គាយនាធំៗ មកពិចារណាប្រៀបធៀបគ្នាមើលសិន ដើម្បីឲ្យឃើញតម្លៃសង្គាយនាព្រះត្រៃបិដកយើង ។ តាមប្រវត្តិពុទ្ធសាសនា ដែលនិយាយទាក់ទងដោយសង្គាយនាមានសេចក្តីដំណាលជាក្រោយព្រះពុទ្ធអគ្គបរិនិព្វានទៅមិនយូរប៉ុន្មាន ព្រះ

មហាកស្សបត្ថេរជាប្រធានសង្ឃប្រជុំអរហន្ត ៥០០ អង្គ៖ធ្វើបឋមសង្គាយនា
អង្គលោកជាអ្នកចោទដណ្តឹងសួរព្រះវិន័យបិដកទាំង ៣, ព្រះឧបាលិត្ថេរ
ជាអ្នកឆ្លើយវិនយបិដក, ព្រះអានន្ទត្ថេរជាអ្នកឆ្លើយសុត្តន្តបិដកនិងអភិធម្ម-
បិដក ។ ក្នុងការប្រជុំការកសង្ឃជាសង្គីតិកាចារ្យនោះ មានវគ្គ ២
វគ្គមួយហៅថា ថេរាសនៈ សម្រាប់ព្រះមហាកស្សបត្ថេរជាអ្នកសួរ, វគ្គ
មួយទៀតហៅថា ធម្មាសនៈ សម្រាប់ព្រះថេរៈជាអ្នកឆ្លើយ អរហន្តទាំង
អស់អង្គគង់ចាំស្តាប់នៅក្នុងទីប្រជុំទាំងអស់ ហើយមានការឃាត់ហាមភិក្ខុ
សង្ឃដទៃមិនឲ្យចូលទៅកាន់ទីប្រជុំនោះឡើយ ។ លុះចប់ព្រះវិនយ-
បិដកហើយ ព្រះសង្ឃមូលមតិព្រមគ្នាសូត្រស្វាធ្យាយបញ្ចុះត្រូវគ្នាទាំង
អស់អង្គ ។ កាលព្រះឧបាលិត្ថេរចុះចេញពីវគ្គ ព្រះមហាអានន្ទត្ថេរ
ឡើងកាន់វគ្គនោះឆ្លើយសុត្តន្តបិដក លុះចប់សុត្តន្តបិដកហើយព្រះសង្ឃ
ស្វាធ្យាយបញ្ចុះគ្នាទៀត ។ គឺទៅព្រះមហាអានន្ទត្ថេរឆ្លើយអភិធម្មបិដក
ទៀត ចប់អភិធម្មបិដកព្រះសង្ឃស្វាធ្យាយទៀត ឈ្មោះហៅចប់បឋម
សង្គាយនាព្រះពុទ្ធវចនៈ គឺព្រះវិន័យបិដកតែប៉ុណ្ណោះ ។ បើយើងពិចារណា
តាមសង្គាយនានេះ យើងឃើញថាកាលនោះព្រះអរហន្តលោកចង់ក្រង
ព្រះពុទ្ធវចនៈដោយ ព្រះតស្មិនបានចារឹក ព្រះពុទ្ធវចនៈជាលាយលក្ខណ៍
អក្សរទេ គឺលោកគ្រាន់តែទន្ទេញឲ្យចាំមាត់ពាល់អង្គ បានសេចក្តីថាកាល
នោះព្រះវិន័យបិដកមិនទាន់ចារឹកជាក់ស្តឹកឬតប្តៀវតៅទេ សង្គាយនាទី ២

ទី ๓ នឹងទី ๔ ក៏មានទំនងដូចគ្នាទៀតនឹងបឋមសង្គាយនានេះដែរមិនប្លែកគ្នាទេ មានប្លែកខ្លះតែហេតុនាំឲ្យកើតសង្គាយនាប៉ុណ្ណោះ ព្រោះគោលបំណងតែមតែឲ្យព្រះសង្ឃតិកាចារ្យចងចាំព្រះពុទ្ធវចនៈវត់មាត់ស្មាត់ដូចគ្នាទាំងអស់អង្គប៉ុណ្ណោះ ។ ដល់មកបញ្ចមសង្គាយនាគឺសង្គាយនាទី ៥ ទើបមានការប្លែកពីកាលមុនៗ គឺការប្រជុំការកសង្ឃជាសង្ឃតិកាចារ្យមកសង្គាយនាហើយចារកព្រះពុទ្ធវចនៈគ្រប់បិដកទាំង ៣ ចុះកាន់ស្លឹករឹត ។ ហេតុដែលនាំឲ្យចារកជាលាយលក្ខណ៍អក្សរដូច្នេះ មកពីអស់លោកដែលចេះចាំព្រះពុទ្ធវចនៈវត់មាត់ស្មាត់នោះកាន់តែក្រខ្លាំទៅមិនសូវមានច្រើនទេ ។ ហេតុនេះជាដើមហើយក៏លើកការចារកព្រះវចនៈជាលាយលក្ខណ៍អក្សរឡើង ហូតជាព្រះពុទ្ធវចនៈបិតថេរេហូតមកដល់បច្ចុប្បន្នកាលនេះ ។ គំនិតអស់លោកទាំងឡាយនោះដែលចារក ព្រះពុទ្ធវចនៈទុកជាការសំខាន់បំផុត បើប្រសិនជាមិនចារកទុកទេ គ្រាន់តែធ្វើសង្គាយនាហើយទន្ទេញឲ្យចាំមាត់ដូចសង្គាយនាកាលមុនៗមក ព្រះពុទ្ធសាសនានឹងអន្តរធានបាត់បង់ទៅហើយ ។ បើយើងយកសង្គាយនាទាំង ៥ លើកនោះ មកពិចារណាមើលតទៅទៀត យើងនឹងឃើញមានការសំខាន់ ២ ផ្នែក គឺ :-

๑ - ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកដែលបិតថេរេហូតមក; ដោយអាស្រ័យព្រះថេរានុត្ថេរៈទាំងឡាយចេះចាំមាត់ស្មាត់ច្រើនអង្គ, នេះទុកជាលើកទី ๑ ;

២ - កាលព្រះថេរៈតែងតាំងឲ្យដែលចេះចាំមាត់ស្ទាត់ឱ្យត់មិនមានច្រើនអង្គ កំពើតមានការចារកែព្រះពុទ្ធវចនៈជាំអស់នោះចុះកាន់ស្នឹកតែតុកតមកទៀត, នេះតុកជាលើកទី ២ ។

ការសង្គាយនាតួចៗតា មកគ្រប់ប្រទេសកាន់ពុទ្ធសាសនា ដូចលង្កា - ភូមា - សៀម ឬ ឥណ្ឌ (Pali Text Society) ក៏មិនមានការប្លែកពីសង្គាយនាទី ៥ គ្រាន់តែមានសង្គាយនាហើយចារកែចុះកាន់ស្នឹកតែ ឬបោះពុម្ពសៀវភៅតុកតូចដែលៗប៉ុណ្ណោះ នៅខ្លះការសំខាន់មួយលើកទៀតជាលើកទី ៣ គឺការប្រែព្រះពុទ្ធវចនៈជាភាសារៀងខ្លួន ។

ការប្រែព្រះពុទ្ធវចនៈជាភាសារបស់ខ្លួនគ្រប់ប្រទេសនេះ កើតជាប្រស្នាមួយធំណាស់ មកពីមានសេចក្តីយល់ឆ្គងគ្នា អ្នកខ្លះយល់ថាត្រូវប្រែចេញជាភាសារបស់ខ្លួន អ្នកខ្លះយល់ថាមិនត្រូវប្រែចេញជាភាសារបស់ខ្លួនទេ, ព្រះពុទ្ធវចនៈគឺព្រះត្រៃបិដកនេះ ត្រូវនៅជាបាលីដដែល អ្នកណាប្រែចេញជាភាសារបស់ខ្លួនមិនសមគួរទេ ; ម្ល៉ោះហើយប្រទេសណាក៏ដោយ ក៏បណ្តែតបណ្តោយមិនបានប្រែជាភាសារបស់ខ្លួនរហូតមក បើតុកជាមានប្រែខ្លះ ក៏ចំពោះតែសេចក្តីខ្លះឬសូត្រខ្លះៗបន្តិចបន្តួចប៉ុណ្ណោះ ។ កាលប្រទេសយើងបង្កើតពុទ្ធសាសនបណ្ឌិត្យនេះឡើងទើបយើងផ្តើមចាត់ការប្រែព្រះពុទ្ធវចនៈ ជាភាសាខ្មែរយើង មុនគេបង្អស់ ។ ការដ៏ធំហើយប្រកៃនេះ ក៏ចាប់កំណើតកើតឡើង នៅក្នុង

លោកដោយផ្សាយខ្លួនឯង ។ ការចោះពុម្ពព្រះត្រៃបិដកយើងនេះ យើងតែងដាក់ថាជាសង្គាយនាដែរ ជាឧទ្ទេសឈ្មោះថា "ឧត្តមសង្គាយនា" ដោយការរបស់យើងប្លែកវិសេសជាងសង្គាយនាមុនៗ ទាំងអស់ គឺយើងបានប្រែជាភាសារបស់យើង ហើយចោះពុម្ពជាសៀវភៅ មានចាលីទំព័រម្ខាង សំពាយខ្មែរយើងទំព័រម្ខាង តែយើងមិនបានដាក់ថាជាសង្គាយនាទីប៉ុន្មានទេ ។

ដល់មកត្រង់នេះ ខ្ញុំបានសូមរំលឹកអស់លោកទាំងឡាយឲ្យបានជ្រាបពីរបៀបចាត់ការសង្គាយនាព្រះត្រៃបិដក នៅប្រទេសយើងដោយល្អិតល្អន់អស់ជើង ។ ឯរបៀបចាត់ការនោះ ដូចខ្នះ ៖

ព្រះពជរដ្ឋកិបាលរបស់យើង បានធ្វើក្រឹត្យមួយលេខ ១០៦ ចុះថ្ងៃ ១៤ ខែធ្នូ ឆ្នាំ ១៩២៩ តាំងអធិបតីមួយរូបនឹងក្រុមជំនុំប្រចាំនរូប តមកតែប្រែក្រឹត្យថ្មី តាំងអធិបតី ១ រូប អធិបតីរង ២ រូប ក្រុមជំនុំ ៤០ រូប រួមហៅថាព្រះសង្ឃនីតិកាចារ្យ ។ ព្រះសង្ឃនីតិកាចារ្យទាំង ៤០ រូបនេះ ចែកជា ៥ ក្រុម គឺ:

១ –	លោកសរសេរចម្លង	១ ក្រុម;
២ –	លោកធ្វើឥណ្ឌាលី	១ ក្រុម;
៣ –	លោកប្រែជាភាសាខ្មែរ	១ ក្រុម;
៤ –	លោកពិនិត្យសេចក្តីប្រែជាភាសាខ្មែរ	១ ក្រុម;

៥ - លោកពិនិត្យសេចក្តីប្រែភាសាខ្មែរសម្រេច ១ ក្រុមទៀត ។
ព្រះសង្ឃគីតិកាចារ្យចាំង ៥ ក្រុមនេះ ត្រូវមកធ្វើការនៅក្នុងពុទ្ធសាសន-
បណ្ឌិត្យ មានទីកន្លែងមួយពិសេសហៅថា "ក្រុមជំនុំប្រែព្រះត្រៃបិដក" ។
កាលប្រជុំលើកដំបូង ក្រុមជំនុំបានសម្រេចថា ក្នុងការសង្គាយនានេះ
ត្រូវយកព្រះត្រៃបិដកស្ទឹកវត្តខ្មែរយើងជាគោល ។ លុះបានជំនុំព្រមព្រៀង
គ្នាហើយ ក្រុមជំនុំអ្នកចំឡងបានចម្លងចេញពីគម្ពីរស្ទឹកវត្តខ្មែរ ចម្លង
ហើយបញ្ជូនទៅក្រុមជំនុំផ្ទៀងផ្ទាត់ ។ ក្រុមជំនុំផ្ទៀងផ្ទាត់បានយកព្រះត្រៃបិដក-ភូមា-លង្កា-សៀម ឧរោបគឺ (Pali text sociéty)
មកផ្ទៀងគ្នាមើល កាលផ្ទៀងបើឃើញមានការប្លែកគ្នាខ្លះដោយអន្ទឹះ
មិនហ៊ានកែប្រែលុបបាំងចោលទេ បានធ្វើជាលេខយោងហៅថា នយ-
លក្ខណៈ មកដាក់នៅខាងក្រោមទំព័រហើយដឹកបន្ទាត់ខ័ណ្ឌដាក់អក្សរ
អាទិសង្កេតថា "ម" មើលថា មរមញ្ញ គឺព្រះត្រៃបិដកភូមា "សី"
មើលថាសីហឡៈ គឺព្រះត្រៃបិដកកោះលង្កា "ឧ" មើលថា ឧរោប គឺ
ព្រះត្រៃបិដក (Pali Text Sociéty ក្រុមជំនុំផ្ទៀងផ្ទាត់បានពិនិត្យមើល
ហើយ បញ្ជូនទៅក្រុមជំនុំប្រែភាសាខ្មែរ ។ ក្រុមជំនុំប្រែចាត់ការប្រែជា
ភាសាខ្មែរតទៅ លុះប្រែហើយ បញ្ជូនទៅក្រុមជំនុំពិនិត្យសេចក្តីប្រែ ។
ក្រុមជំនុំនេះ កាលពិនិត្យសេចក្តីប្រែនីមួយៗ បានយកអដ្ឋកថាដីកា
យោជនា មកធ្វើជាគោល មិនមែនប្រែតាមទំនើងខ្លួនទេ ។ លុះ

ពិនិត្យសេចក្តីប្រែនេះហើយបញ្ជូនត្រឡប់ទៅឲ្យក្រុមដំទុំអ្នកសរសេរចម្លង ឲ្យសរសេរចម្លងសំអាត, ចម្លងសំអាតហើយ បញ្ជូនទៅក្រុមដំទុំពិនិត្យសេចក្តីប្រែវិញ ។ ក្រុមដំទុំពិនិត្យសេចក្តីប្រែពិនិត្យមើលម្តងទៀតឃើញថាត្រឹមត្រូវហើយ ទើបបញ្ជូនទៅក្រុមដំទុំពិនិត្យសេចក្តីប្រែសម្រេច ។ ក្រុមដំទុំពិនិត្យសេចក្តីប្រែសម្រេចនេះ ពិនិត្យផ្ទៀងផ្ទាត់មើលតាមអដ្ឋកថាដីកា យោជនាដដែលទៀត ដើម្បីបញ្ជាក់ឲ្យឃើញជាត្រឹមត្រូវពិតប្រាកដ លុះពិនិត្យ"តចត់ហើយ ទើបបញ្ជូនទៅសុំសេចក្តីយល់ព្រមពីព្រះសង្ឃនាយកទាំង ២ គណៈតពីព្រះសង្ឃនាយកទាំង ២ គណៈ បញ្ជូនសំណៅនេះទៅកាន់ការដំទុំរដ្ឋមន្ត្រីជាទីបំផុត ។ កាលចេញពីការដំទុំរដ្ឋមន្ត្រីហើយ ទើបអាចផ្ញើសំណៅនេះទៅពេញពុម្ពឲ្យចាត់ការបោះពុម្ពបាន ។

តាំងពីកើតការសង្គាយនាព្រះត្រៃបិដកយើងកាលពីឆ្នាំ ១៩២៩ មកដល់ឆ្នាំ ១៩៥២ គិតទៅ ២៣ ឆ្នាំហើយ ព្រះសង្ឃីតិកាចារ្យប្តូដែលហៅថាក្រុមដំទុំប្រែព្រះត្រៃបិដក បានប្រែព្រះត្រៃបិដកទាំង ៣ ជាភាសាខ្មែរយើងចប់សព្វគ្រប់អស់ហើយ បានបោះពុម្ពជាសៀវភៅស្រេចចំនួន ៣៧ សៀវភៅហើយ គឺវិនយបិដក ១៣ សៀវភៅ សុត្តន្តបិដក ២៤ សៀវភៅ នៅសល់ខានមិនទាន់ឡើងកាន់ពុម្ពទៀតចំនួន ៦៣ សៀវភៅគឺសុត្តន្តបិដក ខ្លះនឹងអភិធម្មបិដកទាំងអស់ ។ ចំនួន ២៣ ឆ្នាំនេះឃើញថាការយើងនេះគឺយូរពិតមែន តែហេតុដែលយឺតយូរប៉ុណ្ណោះ មិនមែនមកពីហេតុការណ៍

អ្វីខ្លះ គឺមកពីប្រទេសកើតសង្គ្រាម, សង្គ្រាមនេះហើយដែលបំផ្លិចបំផ្លាញ
ឱ្យខ្ទេចខ្ទាតគ្រឹងគ្រេងបាក់បែកអាណាធ្វើឱ្យកកាន់តែចោះពុតមកដល់ពេលនេះ ។

តាមសេចក្តីពណ៌នាមកប៉ុណ្ណេះ យើងឃើញថាព្រះត្រៃបិដកយើង
ខ្ពស់ជាងព្រះត្រៃបិដកប្រទេសណាៗ ទាំងអស់ សមឈ្មោះថា
ឧត្តមសង្គាយនា ពិតប្រាកដមែន ដោយហេតុ ២ ប្រការ គឺ :

๑ - យើងបានធ្វើនយលក្ខណៈ ក្នុងព្រះត្រៃបិដកយើងប្រាប់
សេចក្តីច្បែកគ្នាដោយអន្លើៗ ដែលមានទៅក្នុងព្រះត្រៃបិដកនានាប្រទេស
ទាំងអស់ថា ត្រង់នេះព្រះត្រៃបិដកភូមាថាដូច្នេះ លង្កាថាដូច្នេះ ខ្មែរ
ថាដូច្នោះទៀត បើយើងបានមើលត្រឹមតែព្រះត្រៃបិដកយើងមួយប៉ុណ្ណោះ
យើងអាចដឹងសេចក្តីច្បែកគ្នាគ្រប់ព្រះត្រៃបិដក ហាក់ដូចជាយើងបានមើល
ព្រះត្រៃបិដកគ្រប់ប្រទេសទាំងអស់ ។

๒ - យើងបានប្រែជាសំពាយភាសាខ្មែរយើង មុនគេបង្អស់ក្នុង
លោក ហើយចោះពុតជាសៀវភៅ ទំព័រម្ខាងជាបាលី ទំព័រម្ខាងទៀត
ជាសំពាយភាសាខ្មែរ ។ ការធ្វើដូច្នេះប្រទេសណាៗ ក៏មិនទាន់បានធ្វើទេ
មានតែប្រទេសយើងមួយទេ ដែលអាចធ្វើការនេះមុនគេបង្អស់ ទុកជា
ការប្រសើរបំផុត បំពេញសេចក្តីត្រូវការដែលលោកអ្នកកាន់ព្រះពុទ្ធសា-
សនាត្រូវការ ព្រោះមើលតាមប្រវត្តិឃើញថាលើកទី ๑ ព្រះសង្គីតិកា-
ចារ្យសង្គាយនាមក ๔ លើក ក៏នៅតែចងចាំព្រះត្រៃបិដកទុកមក

ដោយចាំមាត់ស្ទាត់ លើកទី ២ តាំងពីសង្គាយនាទី ៥ មក ព្រះសង្ឃតិការចារ្យ បានគ្រាន់តែចារឹកព្រះត្រៃបិដកជាលាយលក្ខណ៍អក្សរកាសាបាលីមិនទាន់បានប្រែជាសំពាយទេ លើកទី ៣ ប្រទេសខ្មែរយើង បានប្រែជាសំពាយភាសាខ្មែរបំពេញសេចក្តីត្រូវការគ្រប់គាំង ៣ លើក ។

ដោយការយើងប្រសើរជួចពោលមកនេះ ព្រះត្រៃបិដកយើងត្រូវបានពាក្យសរសើរនានាប្រការ ពីប្រទេសកាន់ពុទ្ធសាសនាគាំងឡាយនឹងប្រទេសដទៃខ្លះ ។ បច្ចុប្បន្នកាលនេះ ព្រះត្រៃបិដកយើងមានកេរ្តិ៍ឈ្មោះ លេចឮសុះសាយគេញសាកលលោកគាំងអាស៊ីនឹងឧរោប គេកោតស្ងើចការងារយើងជាបំផុត ។ កាលពីឆ្នាំ ១៩៣១ មានអ្នកជ្រាបលង្កាមួយរូបជាតិកុនាម នារេ: បានមកកាន់ប្រទេសយើង បានដឹងការងារនេះជាក់ច្បាស់ កាលត្រឡប់ទៅទ្វីបលង្កាវិញ បានព្រះត្រៃបិដកយើងមួយភាគ គឺនិយបិដកភាគទី ១ យកទៅជាមួយខ្លួនផង អ្នកជ្រាបនេះ បានសរសេរផ្សាយតាមសារពត៌មានក្នុងលង្កាទ្វីបថា ប្រទេសខ្មែរជាប្រទេសតូច ស្ទើរតែគេមិនដែលឮឈ្មោះសោះ អ្នកជ្រាបក៏មានតិចហ៊ានធ្វើការធំណាស់ គឺហ៊ានសង្គាយនាព្រះត្រៃបិដកហើយប្រែជាភាសារបស់ខ្លួន ជាក់ទំព័រម្ខាងបាលី ទំព័រម្ខាងជាភាសារបស់ខ្លួន ការងារនេះថ្មីកប្រសើរណាស់ មិនមានប្រទេសណាក្នុងលោកអាចធ្វើបានទេ ហើយប្រទេសនេះមិនចេះអួតខ្លួនផង ។ ក្នុងសារពត៌មាននោះគេបានគូសរូប

ភាពព្រះវិតែបិដកយើងភាគទី ១ នោះជាក់ជង ។ ក្នុងឆ្នាំ ១៩៤៨ អ្នក
ប្រាជ្ញឫរាំងម្នាក់ឈ្មោះ (Jean Filliozat) បានមកកាន់មន្ទីរក្រុមដំទុំព្រះ
វិតែបិដកយើងបានពិនិត្យមើលការងារយើងហើយ ពោលសរសើរជា
បំផុត, ទីបំផុតលោកមានប្រ ហាន់ថា « ប្រទេសឫរាំងនឹងយកតម្រាប់តាម
ព្រះវិតែបិដកខ្មែរនេះ ហើយចោះពុម្ពជាព្រះវិតែបិដកឫរាំងតមកមិនយូរ
ប៉ុន្មាន ប្រទេសឫរាំងបានចេញព្រះវិតែបិដកមួយភាគ ទំព័រម្ខាងជា
ឫលីអក្សរភេម៉ាំង ទំព័រម្ខាងសេចក្តីប្រែជាភាសាឫរាំង ក្នុងអារម្ភកថា
ជាក់ថាយកតម្រាប់តាមព្រះវិតែបិដកកុំពេញប្រទេសកម្ពុជា ។ ក្នុង
ពេលថ្មីៗ នេះ ប្រទេសយើងបានផ្ញើព្រះវិតែបិដកយើងមួយចប់ទៅដម្កល់
ទុកនៅប្រទេសឥណ្ឌា ។ រីឯលោកលាល់ព្រះវិតែបិដកនេះគេបានរៀបពិធី
មួយ ជាហេតុនាំឲ្យមានឮដំណឹងខ្ចរខ្ចាយដោយពួកសារព័ត៌មានចាំង-
ឡាយផ្សាយតៗគ្នា ។ តមក ប្រទេសឥណ្ឌាបានធ្វើចុតហ្វាយមួយចប់ប
ថ្វាយចំពោះព្រះករុណាម្ចាស់ជីវិតលើត្បូង ដូចមានសេចក្តីនៅកង្ខសារ-
ពត៌មាន Cambodge លេខ ២.១៧៤ ចុះថ្ងៃទី ១៩-១១-៥២ នេះស្រាប់ ។
មិនតែប៉ុណ្ណោះទេ ប្រទេសខ្មែរយើងបានឲ្យព្រះវិតែបិដកយើងទៅដម្កល់
ទុកនៅលង្កាទ្វីប ១ ចប់ នៅប្រទេសកូមា ១ ចប់ទៀត ។ នៅប្រទេស
ទាំងពីរមានអ្នកជ្រះថ្លាជាវិយកទៅទុកជាសម្បត្តិរបស់ខ្លួន តាំងច្រើនគ្នា ។
ក្នុងពេលនេះបានដំណឹងថា ប្រទេសកូមានទឹងធ្វើសង្គាយនាពាក់កណ្តាល

សាសនា គឺ ព ស. ២៥០០ ឆ្នាំ ហើយគេហ៊ានឲ្យឈ្មោះសង្គាយនាគេ ថា សង្គាយនាទី ៦ តពីសង្គាយនាទី ៥ នោះមក គេបានសូមយកព្រះ ត្រៃបិដកយើងធ្វើជាគោលក្នុងការសង្គាយនារបស់គេផង គេបានឲ្យ យើងខំប្រឹងចោះពុម្ពព្រះត្រៃបិដកយើងឲ្យធាប់ចប់ទៅ ឲ្យគាន់ការគេ កុំខាន ។ ពាក្យសរសើរទាំងអស់នេះជាហេតុនាំឲ្យប្រទេសនានា ដែល កាន់លទ្ធិសាសនាជួចគ្នាក្នុងលោកស្គាល់ប្រទេសកម្ពុជាយើងកាន់តែច្រើន ទុកជាកេរ្តិ៍ឈ្មោះប្រទេសកម្ពុជាយើង ។

ទីបំផុត ពុទ្ធសាសនបណ្ឌិត្យមិនធ្លុះប្រហែសសោះឡើយក្នុងការ ចោះពុម្ពព្រះត្រៃបិដកនេះ ទំហើយទំទៃតគិតដូចម្តេចឲ្យខាងតែបាន សម្រេចសមតាមគោលបំណងមិនខាន ការខកខានយឺតយូរមកដល់នេះ ជាការផុតវិស័យដែលឥតកែទៀបាន តែពុទ្ធសាសនបណ្ឌិត្យមិនអស់សង្ឃឹម ទេ ដោយការខ្វះខែងរបស់មន្ទីរនេះទើបបានអនុញ្ញាតពីព្រះរាជរដ្ឋាភិបាល បច្ចុប្បន្ន គឺព្រះរាជរដ្ឋាភិបាលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានទ្រង់ ព្រះមេត្តាប្រោសព្រម ឲ្យចំណាយថវិកាជាតិ ២ លានរៀលក្នុងមួយឆ្នាំ។ គិតពីឆ្នាំ ១៩៥៣ តទៅ សម្រាប់ជាជំនួយក្នុងការចោះពុម្ពព្រះត្រៃបិដក នោះតាល់តែបានចប់សព្វគ្រប់បរិបូណ៌ ដើម្បីទុកជាវដល់ពុទ្ធសាសនិក-ជន ។ អាស្រ័យហេតុនេះ យើងសង្ឃឹមថាតទៅមុខមិនយូរប៉ុន្មានព្រះត្រៃ-បិដកយើងនឹងបានសម្រេចសមតាមគោលបំណងយើងមិនខាន សូមអស់ លោកចាំងឮាយរង់ចាំទទួលអនុមោទនាត្រៃកអរចំពោះកុសលនេះចុះ ។

កបិនកថា

របៀបទេសនាបុច្ឆា - វិសជ្ជនា

ព្រះមហាឧត្តមវិជ្ជា កែ-អឿន (វិរិយបញ្ញោ)

វត្តព្រះពហ្មវតន៍ ខែត្រសៀមរាប រៀបរៀង

ព្រះទេពសត្ថា សូរ-ហាយ ពិនិត្យកែសម្រួល

អារម្ភកថា

ហេតុដែលនាំឲ្យកើតជាសៀវភៅ កបិនកថា បុច្ឆា - វិសជ្ជនានេះ ឡើង គឺកើតឡើងដោយលោកឡែម - រឿន ជាអតីតមេឃុំសៀមរាប ទទឹង ឧបាសិកា ខូច ជាកិរិយា មានសទ្ធាជ្រះថ្លាធ្វើកបិនទានដង្ហែទៅវេរប្រគេន ព្រះសង្ឃវត្តពោធិលង្កា ខែត្រសៀមរាប ក្នុងឆ្នាំជូតនក្សត្រសំរឹទ្ធិស័ក ព.ស. ២៤៩១, គ.ស. ១៩៤៨ មានប្រាថ្នាចង់បានសៀវភៅកបិនទាន ដើម្បីសំដែងក្នុងកាសបុណ្យនោះ រួចហើយទទឹងហែយកទៅជាមួយអង្គកបិន ដំកល់ទុកជាធម្មទានក្នុងវត្តនោះផង បានទៅទិមន្តខ្ញុំឲ្យរៀបរៀងកបិន ទទឹងអានិសង្សក្រៃបិនទានផងរៀបបុច្ឆា - វិសជ្ជនា ទំនងដូចជាធម្មកថិកទេសនាត្រៃគតីវារ ។ ខ្ញុំក៏ពេញចិត្តក្នុងការនេះដែរ ទំរឹងរៀបរៀងត្រាតែបានសម្រេច ។ កាលទទឹងរៀបរៀងខ្ញុំបានយកគម្ពីរទទឹងច្បាប់ជាច្រើន ដែលលោកអ្នកប្រាជ្ញបានរៀបរៀងទុកមកពីមុនខ្លះ ទាំងបាន

យើញសាស្ត្រាអនិសង្សកបិនស្ងឹកតែ ១ ខ្សែ ចំណងដើងថា ជាស្នាដៃ
របស់លោកទុកញ៉ាំសុត្តន្តច្រើជាឥន្ធតែង, ឲ្យានពិនិត្យមើលសព្វគ្រប់ មាន
សេចក្តីពីរោះប្លែកជាទីចាប់ចិត្តដែលមិនដែលមានក្នុងច្បាប់នានា ក៏ឲ្យាន
ដកស្រង់យកមករៀបរៀងឲ្យកើតឲ្យានជាច្បាប់នេះ ។ លុះរៀបរៀងរួច
ហើយ ខ្ញុំឲ្យានយកសំណៅនោះទៅឲ្យលោកមហាជាច្រើនអគ្គ ឲ្យជួយ
ពិនិត្យកែសម្រួលសេចក្តី ។ លោកទាំងនោះក៏ជួយពិនិត្យដោយម៉ត់ចត់,
ពិនិត្យរួចហើយ លោកឡែម រឿនឲ្យានជួលអ្នកចារសាស្ត្រាឲ្យចារជាក់
ស្ងឹកតែបំបែកជាពីរខ្សែ គឺមហាវេរ អ្នកសូរ ១ ខ្សែ អនុត្តរ អ្នកឆ្លើយ
១ ខ្សែ ។

ដល់ពេលកំណត់បុណ្យកបិននោះ លោកឡែម-រឿនឲ្យានទិមន្តភិក្ខុ
ពីរូបទៅសំដែងតាមសេចក្តីដែលរៀបរៀង, ពុទ្ធបរិស័ទឲ្យានជួបជុំស្តាប់
ធម៌នេះជាច្រើន សឹងសរសើរថាពីរោះពាល់គ្នា ហើយក៏សូមយកច្បាប់
នោះទៅចារចម្លងតៗទៅចំនួន ២០ ច្បាប់ទៀត ។

ច្បាប់នេះ ខ្ញុំមានបំណងនឹងចោះត្មុតជាសៀវភៅយូរហើយ តែមិន
មានពេលទុកាសនឹងធ្វើឲ្យាន ទើបតែពេលនេះទំនៀតពេលដកស្រង់ជាថ្មី
ឲ្យានកែសម្រួលសេចក្តីថែមទៀត ។

លុះកែសម្រួលសេចក្តីរួចហើយ ឲ្យលោកមហាជាដៃជួយកែសម្រួល

ទៀត ហើយឲ្យកិត្តិយ៉ាន យ៉ុន ធម្មកោសលត្រៃទីធ៌ជម្មកោសលទោ ឲ្យជួយសរសេរចម្លងយកមកចុះពុម្ពជាសៀវភៅឡើង ។

សៀវភៅ កបិនកថា បុព្វា - វិសជ្ជនានេះ មានប្រយោជន៍ខ្លួនឯ ពាំងគ្រហស្ថ បព្វជិត, ខាងចុងសៀវភៅនេះមានចារលើវេរកបិនទីធ៌ពិធី ក្រាលគ្រងកបិនជាដើមដោយសព្វគ្រប់ ។

ដោយអំណាចវិរិយភាព ដែលខ្ញុំបានរៀបរៀងកបិនកថា បុព្វា-វិសជ្ជនានេះ សូមឲ្យសាសនមណ្ឌលនៃព្រះទសពលញ្ញាណប្រតិស្ឋានគ្រប់ ៥ ពាន់ព្រះវស្សា !

ម្យ៉ាងទៀតសូមឲ្យលោកអ្នកសិក្សាទាំងឡាយបានសម្រេចសមតាមវត្ថុបំណងកុំបីឃ្លៀងឃ្លាតឡើយ !

សូមអភ័យទោសអំពីសំណាក់បណ្ឌិតទាំងឡាយ បើឃើញមានសេចក្តីភ្លាំងភ្លាត់ឆ្គាំឆ្គងត្រង់ក៏ន្ទៃងណាមួយ មេត្តាជួយកែតម្រង់ឲ្យបាន ដើម្បីជាប្រយោជន៍ដល់ពុទ្ធសាសនា ។

វត្តព្រះព្រហ្មរតន៍ ថ្ងៃចន្ទ ១ កើតខែមិគសិរ ឆ្នាំរោងចត្វាស័ក ព. ស. ២៤៩៥ ត្រូវនឹងថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ១៩៥២ ។

ព្រះមហាឧត្តមវិជ្ជា

កែ - អឿន

ក្រមិនកថា

បុច្ឆា - វិសជ្ជនា

អាត្មាភាពទាំងពីរបូប សូមចំរើនពរ ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ។ ពរទាំង ៤ ប្រការនេះ ចូរវឌ្ឍនាការចំរើនដល់ពុទ្ធបរិស័ទទាំងឡាយ ដែលមានចិត្តសោមនស្សស្មោះសរ ត្រេកអរក្នុងការកុសលផលសីលទាន ជាញាណសម្បយុត្តខ្លះ ជាញាណវិប្បយុត្តខ្លះ ដោយសទ្ធាជ្រះថ្លាក្នុងព្រះរតនត្រ័យគុណជាបុញ្ញខេត្ត, មានបច្ច័យជួយឧបត្ថម្ភទាំងឲ្យកើតបុញ្ញកម្ម ទើបមកសន្និបាតប្រជុំគ្នាក្នុងទីនេះ ដើម្បីនឹងស្តាប់ព្រះសទ្ធម្មវិសេសទេសនា បានអាងធនាទិមន្តអាត្មាភាពទាំងពីរបូបមកសំដែងថ្វែងព្រះសទ្ធម្មទេសនាបុច្ឆា - វិសជ្ជនា ជាបដិការៈតបស្នងគុណសទ្ធា គោះបីបើអាត្មាភាពទាំងពីរបូប សំដែងទៅហើយត្រែងមានភ្លាំងភ្លាត់ខាតខុសលើសលោះ ដោយបទបាទអក្ខរៈព្យញ្ជនៈចាលីឬសេចក្តីអធិប្បាយត្រង់ណាមួយ ដោយឥតមានចេតនាក្រែងក្លាយ សូមលោកអ្នកទាំងឡាយខន្តីអភ័យទោស ដល់អាត្មាភាពទាំងពីរបូប ទើបបានសំដែងតាមដោយខ្ទរដម្រិះជ្រាបអនុថយ

សូមចំរើនពរ ។

ព្រះមហាឧត្តមវិជ្ជា ធីលញ្ញាណោ ប៊ុំង-ប៉ាម
អាចារ្យសាលាជាតិវេន វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង
ឃុនបណ្ឌាន្តរ៉ក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តមក)

ហេតុដូច្នេះ អ្នកដែលស្រឡាញ់កក្តីចំពោះជាតិ ត្រូវតែស្រឡាញ់ជាតិ ស្រឡាញ់ផែនដីដែលខ្លួននៅ ទើង ស្រឡាញ់មិត្តភក្តិរួមជាតិឲ្យមែនទែន កុំស្រឡាញ់តែខ្លួនឯងមួយប៉ុណ្ណោះ ត្រូវតែបញ្ជូនសេចក្តីស្រឡាញ់កក្តី អំពីខ្លួនឯងទៅកាន់គ្រួសារ អំពីគ្រួសារទៅកាន់ស្រុកភូមិ អំពីស្រុកភូមិទៅកាន់ប្រទេស អំពីប្រទេសទៅកាន់ជាតិ ទើង កុំស្រឡាញ់តែមាត់ក្រៅ ត្រូវស្រឡាញ់ព្រមទាំងកាយទាំងចិត្ត ត្រូវនឹកវង្វេកដល់បុព្វបុរសដែលបានខំប្រឹងប្រែង ខំនុកបំរុងជាតិរបស់យើងឲ្យគង់វង្សរហូតមក កាលទើងធ្វើការណា ។ ត្រូវនឹកដល់ប្រយោជន៍ ដែលទើងមានដល់ជាតិជាទីតាំង ហើយព្យាយាមធ្វើការនោះ ។ ឲ្យជាគុណប្រយោជន៍ដល់ជាតិពេញទី សូម្បីទើងត្រូវលះបង់សេចក្តីសុខផ្ទាល់ខ្លួន ដើម្បីប្រយោជន៍ដល់ជាតិ ក៏ត្រូវតែលះបង់ដោយសេចក្តីពេញចិត្ត ហើយខំប្រឹងធ្វើខ្លួនឲ្យទៅជាមនុស្សល្អតាមខ្នាតទៅនេះ :-

ក)- ប្រព្រឹត្តធ្វើខ្លួនឲ្យទៅជាពលរដ្ឋដ៏ល្អ.- គឺត្រូវយកចិត្តទុកដាក់អប់រំខ្លួនឲ្យជាមនុស្សឆ្លៀវឆ្លាស ស្គាល់របស់ដែលជាគុណប្រយោជន៍ទីដ៏ជាទោសដល់ខ្លួន ដល់ជាតិ, គោរពចំពោះព្រះរាជប្បញ្ញត្តិច្បាប់ទំលាប់របស់ប្រទេសជាតិ លះវៀរសេចក្តីអាក្រក់ បំពេញសេចក្តីល្អចំពោះសាធារណជន ប្រព្រឹត្តឲ្យត្រូវតាមគន្ធធម៌ ទីដ៏ព្រះរាជប្បញ្ញត្តិច្បាប់ទំលាប់ប្រពៃណីស្រុកទេស មិនរបៀតបៀនបំផ្លាញប្រយោជន៍ ទីដ៏សេចក្តីសុខរបស់គ្នាទីដ៏គ្នា វៀរចាកអំពើដែលបង្កគ្រោះភ័យអន្តរាយដល់ជាតិ ខំបំពេញប្រយោជន៍ចំណែកខ្លួនគ្នា ទីដ៏ ខំទុកបំរុងវត្ថុដែលជាប្រយោជន៍ដល់ជាតិ កាលបើឃ្លាតឃើញនរណាមួយ ធ្វើការអ្វីដែលជាហេតុបំផ្លាញប្រទេសជាតិ ត្រូវឃាំងឃាត់ ទីដ៏ កំចាត់កិច្ចការនោះចេញ ឬស្រែកអំពាវនាវឲ្យគេជួយការពារតទៅ លុះត្រាតែសម្រេច ។

ខ)- ប្រកបការអាជីវៈត្រឹមត្រូវ.- គឺត្រូវព្យាយាមធ្វើកិច្ចដែលខ្លួនផ្តើមប្រកបឡើងដោយខ្លួនឯង ឬដែលខ្លួនទទួលមកអំពីអ្នកដទៃឲ្យប្រព្រឹត្តទៅដោយត្រូវធម៌ (ច្បាប់) ។ នាយក្រសួងគ្រប់ផ្នែក ត្រូវតែតាំងព្យាយាមធ្វើកិច្ចដុះតាមនាទីរបស់ខ្លួន ដោយសុចរិត (ទៀងត្រង់) ទីដ៏ យកចិត្តទុកដាក់ដោយមិនខ្ជិលច្រអូសដល់សេចក្តីសុខ ឬប្រយោជន៍ផ្ទាល់ខ្លួន ឬក៏របស់ញាតិសន្តានឲ្យលើសលុបជាងកិច្ចការដែលជាប្រយោជន៍របស់ជាតិ ។ អ្នកបួសត្រូវតែព្យាយាមប្រតិបត្តិតាមធម៌វិន័យឲ្យបរិសុទ្ធ ។

ឈ្មួញគហបតីត្រូវតែខ្វល់ខ្វាយរកផ្លូវធ្វើឲ្យការងាររបស់ខ្លួន ចាន់ជាចាប់ជាផ្តាំដ៏កំណួន ។ ប្រជាជនមិនត្រូវអង្គុយជំពាស់ដៃជំពាស់ជើង ត្រូវតែតាំងព្យាយាមធ្វើរបរកេទ្ធលាភដោយសេចក្តីមានៈអត់ធន់ មិនត្រូវបណ្តោយខ្លួនឲ្យទៅជាមនុស្សសូមទានគេបរិភោគ ក្នុងកាលដែលខ្លួនមានកំឡាំងនៅឡើយ ។ អ្នកស្រែ ត្រូវតែខំធ្វើស្រែ, អ្នកចំការ ត្រូវតែខំធ្វើចំការ, ជាងឈើ ត្រូវតែខំធ្វើគ្រឿងឈើ, ជាងដែក ត្រូវតែខំធ្វើគ្រឿងដែក ដោយសេចក្តីប្រឹងប្រែងមែនទែន ដើម្បីឲ្យកើតផលប្រយោជន៍ ជាគិយ្យាភាពដល់ខ្លួនទឹងដល់ប្រទេសជាតិ ។

គ)— តាំងខ្លួនឲ្យមានគោលបាំភ្លឺ.— គឺត្រូវព្យាយាមកសាងខ្លួនឲ្យជាមនុស្សស្តុកស្តម្ភសម្បូរ មានគេហដ្ឋាន ផ្ទះសំបែង ខុកជាទីសំណាក់យ៉ាងមាំមួន មានគ្រួសារដ៏ប៉ិនគួរគក់ក្តៅ មានការអាជីវៈត្រឹមត្រូវជាមុខជាមាត់ មានទីដីជារបស់ខ្លួន មានផ្ទះជារបស់ខ្លួន មានចំការជារបស់ខ្លួន មានស្រែជារបស់ខ្លួន មានការងារជារបស់ខ្លួនឯង ធ្វើខ្លួនឲ្យមានហានៈមាំមួន ទឹង សម្បូរសប្បាយដោយភោគទ្រព្យ តាំងខ្លួនឲ្យជាទីពំនាក់អាស្រ័យ ដើម្បីបានជាកំឡាំងរបស់ជាតិក្នុងផ្លូវទ្រព្យសម្បត្តិ ដូចយ៉ាងជួយក្នុងផ្លូវកាសី ពន្ធអាករឲ្យកៃលែងឡើងទៅ ឬ ជួយក្នុងការកសាងវត្ថុដែលជាប្រយោជន៍ដល់ជាតិ ។

ឃ)— តាំងចិត្តជួយជាតិ.— គឺត្រូវប្រព្រឹត្តឲ្យល្អ ចាប់ដើម
ពីការតាំងចិត្តហ្វឹកហ្វឺនអប់រំខ្លួន នឹងចូលរួមកសាងឲ្យជាមនុស្សល្អ មាន
សីលធម៌ នឹងមានសេចក្តីចេះដឹង សេចក្តីអង់អាចក្នុងកិច្ចការ ដើម្បីបានជា
កំឡាំងជួយជាតិ នឹងជួយអនុគ្រោះមិត្តរួមជាតិ ឲ្យមានសេចក្តីសុខ សេចក្តី
ចំរើន ឲ្យផុតពីសេចក្តីទុក្ខ សេចក្តីវិនាស ជួយទប់ទល់ផ្តើមកិច្ចការ
ដែលជាគ្រឿងធ្វើឲ្យជាតិបានចំរើនរុងរឿង មាំមួន មិនធ្វើការដែលជា
គ្រឿងយាត់យាំងកំងក ស្គាល់ដំណើរនៃសេចក្តីចំរើនរុងរឿងពេញលេញ
របស់ជាតិ ប្រាថ្នាតែប្រយោជន៍ចំពោះជាតិជាទីតាំង មិនប្រាថ្នាប្រ-
យោជន៍ផ្ទាល់ខ្លួន ដើម្បីសេចក្តីរុងរឿងនឹងការផុតភ័យនៃជាតិ ត្រៃកអាកង
ការបង់ពន្ធការ ពន្ធអាករគ្រប់យ៉ាងមិនគេចវេះ ជួយជាតិដោយកំឡាំង
ទ្រព្យ, កំឡាំងកាយ នឹងកំឡាំងចិត្ត ខំទុកបំរុងនឹងការពារប្រទេសជាតិ
ឲ្យមានកំឡាំងខ្លាំងរឹងមាំមួន ចំរើនរុងរឿង នឹង ប្រាសចាកភ័យ ។

ង)— បេះក្បាលសម្បត្តិរបស់ជាតិ.— គឺត្រូវបេះរក្សាទំនៀម
ទំលាប់ប្រពៃណីដែលល្អនឹងសាសនា ភាសា អក្សរសាស្ត្ររបស់ជាតិឲ្យ
ចំរើនរុងរឿងបិតបៀស្គាល់ មិនត្រូវបណ្តោយឲ្យសាបសូន្យ ឬអន់ថយ
ខ្សោយទៅឡើយ ។ ចរិតប្រពៃណីឯណា របស់ជាតិ ទាំងចាស់ទាំងថ្មី
ដែលឃើញថាជារបស់ល្អ ក៏ព្យាយាមប្រតិបត្តិនឹងរក្សាទ្បូវចរិតប្រពៃណី
នោះទុកដើម្បីឲ្យជាគ្រឿងសំគាល់ នៃការតាំងនៅយឺនយូរ នឹងការសម្បូរ

នៃជាតិ មិនត្រូវគិតលុបលាង់ចោល ត្រូវប្រកាន់គតិថា ជាតិណា គ្មាន
ចរិតប្រពៃណីរបស់ជាតិទុកដាស់តឹមខ្ពស់ទេ ជាតិនោះ មិនគួរនឹងតាំងនៅ
ជាជាតិឯករឿយ តែថាបើចរិតប្រពៃណីចាស់ខ្លះថ្មីណា ។ ដែលប្លែកដ
ថារើមិនទាន់សម័យ ឬមិនសមគួរពេលសម័យ ខ្លះដែលយល់ឃើញថា
គ្មានប្រយោជន៍ដល់ជាតិក្នុងកាលជាខាងក្រោយទេ ក៏មិនត្រូវព្យាយាម
ចែងតែវែរ ត្រូវតែបណ្តោយឲ្យសាបសូន្យទៅឯង ។ ចុះ តាំងត្រូវចេះថែ
រក្សាទីសំខាន់របស់ជាតិ ដូចយ៉ាងបុព្វណស្ថានជាដើម មិនឲ្យ
វិនាស ដូចជាមិនគាស់រំលើង ឥឡូវចោល មិនរំលាយរបស់ដែលជា
សាធារណៈប្រយោជន៍ ដូចជាមិនលបគាត់ខ្សែខ្សួរសព្ទ ខ្សែទូរលេខ ឬដក
បង្គោលខ្សែភ្លើង ឬក៏ខ្សែភ្លើងជាដើមដែលសម្រាប់ឲ្យតំណឹងនឹងស្ទើរ
រឿងដល់ប្រជាជន ។

លោកអ្នកប្រុស - ស្រី ដែលប្លែកថាសេចក្តីចំរើនដល់ជាតិតាំងឡាយ
ចូរព្យាយាមធ្វើខ្លួនឲ្យជាប្រយោជន៍ដល់ជាតិ ដោយប្រែមុខរឹតតែ ជាអ្នក
សាមគ្គី សេចក្តីព្រមព្រៀងគ្នា ចូរជួយអនុគ្រោះ ចូរជួយទាំគ្នាទំនុក
បំរុងទូលជាតិឲ្យបានចំរើនរុងរឿងមាំមួន ដោយកំម្លាំងទ្រព្យ កម្លាំងកាយ
និងកម្លាំងគំនិត ចូរទាំគ្នាថ្នមពិកក្តីរក្សាជាតិ ឲ្យទ្រទ្រង់ឥស្សរភាពមាំតាំ
បិតរៀង មិនត្រូវបណ្តែតបណ្តោយឲ្យវិនាសអន្តរាយលិចលង់ឡើយ ត្រូវ
យកចិត្តទុកដាក់ធ្វើការដែលជាគុណប្រយោជន៍ដល់ជាតិ ប្រយត្នខ្លួន មិន

ធ្វើការណាដែលជាហេតុឲ្យកើតភ័យដល់ជាតិ, ត្រូវសង្កេតក្នុងផ្លូវមហាសម្ដុទ្រ រមែងមានវេលាហួតហែង ឬលេចចាំងឡាយរមែងមានចៃប្លែកឆ្ងាយៗទៀតបាន ឯនិស្ស័យស្រឡាញ់ក្តីចំពោះជាតិ របស់លោក-អ្នកនោះ ចូរកុំឲ្យមានវេលាហួតហែង ឬប្លែកឆ្ងាយទៅឯណាឡើយ សូមឲ្យឃើញដូចទៅជាផ្លូងវិញ្ញាណប្រចាំជីវិតរបស់លោក-អ្នកគ្រប់ទិវាពត្រីកាលតទៅ ។

๒—ប្លែងស្រឡាញ់ភក្តីចំពោះសាសនា.- សាសនា គឺពាក្យប្រៀនប្រដៅក្នុងផ្លូវដែលល្អ ជាគោលចរិយារបស់ប្រទេស ជាសិរីមង្គលរបស់ជាតិ ជាអណ្តូងកើតនៃសេចក្តីចំរើនវុឌ្ឍិ នឹងសន្តិសុខចំពោះជាតិ ជាផ្លូងប្រទីបដ៏ភ្លឺចិញ្ចាចសម្រាប់ចំភ្លឺផ្លូវឲ្យជាតិដំណើរទៅតាមវិថីដ៏ត្រង់ឲ្យដល់ទីវាសជាអារ្យជាតិ នឹងជាទីអាស្រ័យនៃការប្រតិត្តដ៏ល្អត្រឹមត្រូវរបស់ប្រជាជនក្នុងជាតិ ដើម្បីឲ្យបានសម្រេចនូវសេចក្តីសុខនឹងឲ្យបានធុតទុក្ខ ។ តួបុរេផ្លូងនៃសាសនានោះនៅត្រង់ការតាំងចិត្តប្រតិត្តតែក្នុងផ្លូវដែលត្រូវ ដែលខ្លួនឃើញថាត្រូវ សូម្បីកាលប្រតិត្តដូច្នោះហើយគ្មានកើតជលល្អខាងក្រោយ ឬប្រែត្រឡប់ជាឲ្យបានទុក្ខក្តៅក្រហាយខាងក្រោយវិញ ក៏នៅតែកូរហានស៊ូប្រតិត្តលុះត្រាតែបានសម្រេច នឹងនៅត្រង់ការមិនពេញចិត្តប្រតិត្តក្នុងផ្លូវខុសដែលមិនត្រូវទំនងតាមសេចក្តីចេះដឹងរបស់ខ្លួន សូម្បីបើមិនធ្វើដូច្នោះ ភ័យអន្តរាយមុខជានឹងមានដល់ខ្លួន ក៏ស៊ូតែព្រាងទុលទុក្ខដែរមិនសុខចិត្តប្រតិត្តឲ្យ

ខុសៗគ្នាយ ។ ទឹកចិត្តដ៏អាចហ៊ានដូច្នេះ រមែងធ្វើមនុស្សអ្នកប្រព្រឹត្ត
ឲ្យស្ម័គ្រចិត្តប្រព្រឹត្តសេចក្តីល្អថ្មាន់ឯនយូរតទៅ ។

ជាតិនិងសាសនា ជារបស់គួគ្នា អាស្រ័យគ្នាទៅវិញទៅមក មាន
ខ្សែសម្ពន្ធជាប់ជាក់ខ្ជាប់គ្នា បើជាតិអន្តរាយទៅដោយប្រការណា ។
សាសនារបស់ជាតិក៏និងអន្តរាយទៅដោយប្រការនោះ ។ ដែរ ។ សាសនា
និងតាំងនៅមាំមួនបាន ត្រូវអាស្រ័យការរឹងប៉ឹងរបស់ជាតិ សូម្បីជាតិនឹង
តាំងនៅមាំមួន ថ្មានសន្តិសុខ ក៏អាស្រ័យសាសនាឃុំគ្រងដែរ ។ ជាតិ
ដែលបរិបូណ៌ដោយគុណធម៌ រមែងថ្មានចំរើនរុងរឿង ។ គុណធម៌ដែល
មានប្រចាំជាតិនោះ គឺសាសនា ដែលចាត់ថាជាសិរីដ៏ប្រសើរវែកលែង
ជាងគ្រឿងប្រដាប់ណា ។ ទាំងអស់ ព្រោះអាចការពារពួកជនមិនឲ្យ
ប្រទូសរ៉ាយដល់គ្នានឹងគ្នា ឲ្យលះវៀរការប្រព្រឹត្តដែលនាំឲ្យកើតសេចក្តី
គ្រោធតូចចិត្តនឹងគ្នា ឬឲ្យលះវៀរវត្ថុដែលធ្វើសេចក្តីក្តៅក្រហាយឲ្យកើត
ដល់មិត្តភក្តិរួមគ្នា ។

(មានត)

កណ្ដាល ១៩

ឧកញ៉ាវិបុលរាជសេនា ង្ហួ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លៀសបើបានអាន
ធឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

លីចោ"គិតថាវម្ភថា កងទ័ពដែលលើកទៅជួយកាន់ស្រុកចាំង ៤ តំបន់នោះ ត្រែងទៅមិនទាន់ដល់ ខ្លាចតាហានតៀវហ៊ុនលើកមកប្រទល់ជួយគ្នាទាន់ ហើយក៏ទៅមិនទាន់ឃើញសំទាន់ត្រង់ហាន់សៀមទឹងអៀវហានសញ្ញានោះទៀត លីចោ"ឲ្យកំលាំងកងទ័ពទៅតាំងជិតកំពែងស្រុក ចម្ងាយប្រហែល ៣០០ សិន (១២ គ. ម.) ។ តៀវហ៊ុនក៏លើកទ័ពតាមមកតាំងបន្ទាយជាប់ជិតគ្នានឹងបន្ទាយលីចោ" ។

ឯហាន់សៀមទទួលពាក្យតាន់តេងហើយ ក៏បានទៅប្រឹក្សានឹងអៀវហាង ហើយបបួលគ្នាទៅរកតៀវហ៊ុនក្នុងបន្ទាយ លុះដល់ពេល

យាម ៣ ហាន់សៀមនឹងអៀវហាង កំចាត់ភាហានឲ្យយកក្តីងដុតបន្ទាយ
នេះឡើង ។ លីហ្ចាំយើញសំខាន់ដូច្នោះ លើកភាហានចូលបន្ទប់បន្ទាយ
តៀវហ៊ុនបែកសម្លាប់ភាហានស្លាប់ជាច្រើន ។ តៀវហ៊ុនកំបវតលំលុះ
ចំណាយកងទ័ពរត់ចេញពីបន្ទាយទៅ លីហ្ចាំក៏លើកភាហានដេញតាម
តៀវហ៊ុនទៅទៀត ទទួលដួបទឹងគីឡង ដែលជាទ័ពណ្តូនខាងតៀវហ៊ុន
នោះលើកមកខាន់ កំបវរសេះចូលច្បាំងនឹងលីហ្ចាំមិនខាន់បានចាញ់ឈ្នះ
គ្នា ទទួលហាន់សៀមនឹងអៀវហាងលើកតាមមកខាន់ កំខ្ចប់វាយទ័ពគ
ឡើងពីក្រោយ គីឡើងកំបំផ្លាយសេះរត់ចេញទៅ លីហ្ចាំក៏លើកភាហាន
ដេញតាមដល់ដើងកុំ ១ អន្ទើ ដែលកងទ័ពអ្ចិនសុតតាំងបន្ទាយនៅនោះ ។

លីហ្ចាំក្រឡេកមើលទៅក្នុងបន្ទាយ ឃើញដោតទង់ម្ភាទនឹងទង់ហង្ស
ជាគ្រឿងសម្គាល់ទ័ពព្រះមហាក្សត្រ ហើយឃើញអ្ចិនសុតពាក់អាវផ្ទៃ
មាស កាន់គ្រឿងដៃទាំង ២ ដិះសេះបញ្ជារ ចុំងសព្ទធនមាសនៅកងក្នុ
បន្ទាយ, លីហ្ចាំកំបំផ្លាយសេះឡើងទៅលើកំពូលកុំម្ខុខបន្ទាយ ។ អ្ចិនសុត
កាន់គ្រឿងចេញមកហើយស្រែកដេរថា ខ្ញុនមឹងជាមនុស្សគាបទេ ហេតុ
ម្តេចកំអង់អាចមកក្បត់នឹងម្ចាស់ផែនដី មឹងធ្វើដូច្នេះមិនគួរទេ ។ លីហ្ចាំ
គាស់ចិត្តណាស់ ទើបដិះសេះពាំខ្ញុនចូលទៅច្បាំងនឹងអ្ចិនសុត។ ឲ្យ
លោហង៍ចេញតស៊ូនឹងលីហ្ចាំបានបីក្លេង លីហ្ចាំយកខ្ញុនចាក់ត្រូវលោហង៍។
កំបំផ្លាយសេះគេចចូលកងបន្ទាយ ។ លីហ្ចាំទើបបង្គាប់ភាហានឲ្យចូល

លុកកង់បន្ទាយ, អ្នកនុតមិនបានតស៊ូ នាំពលគេចរត់ចោលបន្ទាយ នោះទៅ ។

លីប៉ាលើសបានរបស់ទ្រព្យសម្បត្តិគ្រឿងសស្ត្រាវុធកង់បន្ទាយជាច្រើន ហើយក៏លើកតាមអ្នកនុតទៅ ឯអ្នកនុតរត់ទឹងសេះទៅផ្សាយពីបន្ទាយ ច្រហែល ៣០ សិន (១.២០០ ម.) បានជួបទឹងកង់ទ័ពគួនអ៊ូដែលឡៅពីច្រើឲ្យលើកទៅជួយលីប៉ា គួនអ៊ូស្រែកដេរអ្នកនុតថា អាកប្បត់ អាឯង ហានតាំងខ្លួនជាស្តេចហើយម្តេចក៏តែទៅណា? ។ អ្នកនុតខឹងណាស់ក៏ចូលតទឹងគួនអ៊ូ ខ្លួលបានភ្លុំសំឡេងគាហានលីប៉ាហៅឡូនៗ ចូលមកពីក្រោយ អ្នកនុតក៏បង់ាយសេះរត់រួចទៅសំដៅស្រុកឡាំយ៉ុង ។ លីប៉ា, គួនអ៊ូ, ហាន់សៀម, អៀវហង ក៏បបួលគ្នាត្រឡប់មកជួយគាហានដែលច្រើឲ្យលើកទៅវាយស្រុកទាំង ៤ តំបន់ ។

ឯតៀវសេង, តាន់គី, លុយប៉ុក, តាន់ឡាន់ ដែលតៀវហ៊ុនច្រើឲ្យទៅវាយស្រុកទាំង ៤ តំបន់នោះ លុះដឹងថាទ័ពហ្លួងបែកហើយ ក៏លើកទ័ពត្រឡប់ទៅស្រុកឡាំយ៉ុងវិញ ។ លីប៉ា, គួនអ៊ូ, ហាន់សៀម អៀវហង ក៏នាំគ្នាចូលទៅស្រុកឈើដីវ ។ លីប៉ាឲ្យរៀបតុលៀងគោជនា-ហារបណ្តាសេនាគាហានទាំងពួង ហើយចែកវង្វាន់មាសប្រាក់ គ្រឿងសម្លៀកបំពាក់ដល់គាហានគួនអ៊ូ, ហាន់សៀម, អៀវហងជាច្រើន ។ លុះវេលាព្រឹក គួនអ៊ូក៏លាលីប៉ាត្រឡប់ទៅស្រុកអ៊ីដីវវិញ ។

លីចោ"ប្រធ៌ទឹងតាំងហាន់សៀមឲ្យទៅឈរស្រុកគិនតោ ឲ្យអៀវ
ហង៌ទៅឈរស្រុកឡង៌អៀ ក៏ធ្វើជាប្រឹក្សាទឹង៌សេនាគាហានតាំងពួង៌ថា
ហាន់សៀមទឹង៌អៀវហង៌នេះមានសេចក្តីគាប់ប្រសើរទឹង៌យើង តែវយើង
ខំនុកបំរុង៌ចិញ្ចឹមទុកក្នុង៌ស្រុកឈើដីវិនេះឬ ឬក៏ឲ្យទៅឈរក្សាស្រុក
ឯណាវិញ ? ។ គាន់គុយដំកបថា ហាន់សៀមទឹង៌អៀវហង៌នេះ ពីដើម
តាំងបញ្ចុះបញ្ចូលហ្វឹកហាត់គាហានៅស្រុកសួតាំងខាង៌ទិសឯកើត . សុំ
លោកចាត់ឲ្យហាន់សៀមទៅឈរស្រុកគិនតោ ឲ្យអៀវហង៌ទៅនៅឈរ
ស្រុកឡង៌អៀចុះ បើកាលណាបំក្យពួកអ្នកតាំង ២ ទឹង៌មកចុះចូលនៅជា
ពួកម៉ាកប្រើនឡើង ស្រុកទេសក៏ទឹង៌ចំរើនបរិបូណ៌ ។ លីចោ"ឃានស្តាប់ក៏
ចាត់ហាន់សៀមទឹង៌អៀវហង៌ទៅឈរក្សាស្រុកតាំង ២ តំបន់ តាមពាក្យ
គាន់គុយនិយាយនោះ ហើយផ្តាំទឹង៌ហាន់សៀម, អៀវហង៌ថាឲ្យខំរិះគិត
បញ្ចុះបញ្ចូលពួកម៉ាក ឲ្យបានប្រើនឡើង៌ទៀតឲ្យមាំមួន ប្រសិនបើ
យើង៌ទឹង៌មានកិច្ចធុរៈអ្វី ទឹង៌ផ្ញើសំបុត្រទៅដល់អ្នកឲ្យចាត់ការតាមត្រូវ
ការ ។ ហាន់សៀមទឹង៌អៀវហង៌ ក៏លាលីចោ"ចេញទៅឈរស្រុកតាម
ចំណែកវៀង៌ខ្លួន ។ ទំប្រឹក្សាទឹង៌សេនាគាហានតាំងពួង៌ ក៏លាលីចោ
ទៅគាន់ទំលំនៅវាល់គ្នា ។

គាន់តេង៌នោះ លុះត្រឡប់ទៅដល់ផ្ទះ ក៏ចូលទៅសួរគាន់គុយ
ជាបិតាថា ហេតុម្តេចបិតាបានជាសុំលីចោ"ឲ្យហាន់សៀមទឹង៌អៀវហង៌

តាំង ២ នាក់ចេញពីស្រុកឈើដីរវៀងទៅស្រុកគ្រែវិញ ។ តាន់គុយធ្វើយថា ហាន់សៀមនឹងអៀរហាងនេះជាមនុស្សមិនទឹងនួនមាំទាំ បើនឹងទុកចិត្តក៏មិនបានជាច្បាស់ដ បើនឹងឲ្យទៅក្នុងស្រុកឈើដីរយូរទៅ មិនលែងលីប៉ោ" នឹងទំនុកបំរុងឲ្យដល់ខ្លួន បើតាលណាលីប៉ោ"ពប់អានជាទុកចិត្តហើយ អ្នកតាំង ២ គង់នឹងប្លុងចិត្តស្រឡាញ់លីប៉ោ"ជាច្បាស់ដ យើងនឹងរិះគិតធ្វើការតទៅក៏មិនបានស្រួល ។ តាន់តេងយល់ត្រូវក៏និយាយថា "គំនិតរបស់បិតាគិតនេះល្អមែន ខ្ញុំបាទគិតមិនដល់ទេ" ហើយក៏លាបិតាទៅតាន់ទីលំនៅ ។

ឯអ្នូនសុតដែលបាត់យ ខួចវាតសេនាបាហានទឹងគ្រឿងប្រដាប់របស់ទៀ ព្រោះលីប៉ោ"ជាច្រើននោះ ក៏មានតែសេចក្តីខ្មោមនស្សត្រូចចិត្តគិតចង់គំនុំនឹងលីប៉ោ"មិនមានភ្លេច ១ វេលា គិតហើយក៏ធ្វើសំបុត្រ ១ ច្បាប់ទៅដល់ស៊ុនសិក:នៅស្រុកតាំងតាំង សុំសេនាបាហានឲ្យលើកមកជួយសងសឹកកុំបាត់លីប៉ោ ។ ស៊ុនសិកបានទទួលសំបុត្រហើយក៏ដេរអ្នូនសុតថា "វាធយកគ្រាបម្ងាក់របស់អញទុកហើយគិតក្បត់តាំងខ្លួនជាម្ចាស់ផែនដី អញគិតនឹងប្រទូសវ៉ាយវ៉ាឲ្យបាន ឥឡូវវាត្រឡប់មកសុំកងទ័ពអញវិញទៀត" ទើបនិយាយនឹងបំរើថា ដែលចៅហ្វាយឯងឲ្យមកសុំកងទ័ពនោះអញមិនឲ្យទេ អញនឹងលើកទាហានទៅវាយស្រុកឡាំយ៉ុងសងសឹកឲ្យបាន ។

បំរើកាន់សំបុត្រក៏លាសុនសិកត្រឡប់ទៅ ជ្រាប់អ្នួនសុតគ្រប់ប្រការ ។ អ្នួនសុតក៏ដេរស៊ុនសិកថា "អាក្មេងទឹកដោះនៅមាត់ វាកោងព្រហើន និយាយមើលងាយគិតចង់ប្លន់ឯងនឹងអញរៀបៀ អញនឹងលើកទ័ពទៅវាយស្រុកកាំងតាំង ចាប់យកខ្លួនអាស៊ុនសិកឲ្យគាល់តែបាន" ថាហើយក៏បង្គាប់ឲ្យត្រៀមពលរោងា ។

អៀវតៃដឿងទីប្រឹក្សាឆ្លើយអ្នួនសុតថា យើងបានលើកទ័ពទៅវាយស្រុកឈើដីវ ហើយទើបតែត្រឡប់មកដល់ ពលថាហានកំពុងតែខ្សោយហត់ ហេតុម្តេចលោកចង់លើកទៅវាយស្រុកកាំងតាំងទៀត? ស៊ុនសិកនោះជាមនុស្សមានថ្វីដៃខ្លាំងពូកែចំណាន សេនាថាហានក៏ច្រើនសុទ្ធតែពូកែតាំងអស់ គ្រែងលោនឹងចាញ់ប្រៀបគ្នេរដឹង ។ អ្នួនសុតស្តាប់យល់ត្រូវ ក៏បង្គាប់ទៅកងទ័ពឲ្យឈប់បន្ទន់ ។

ឯស៊ុនសិកនោះ លុះបំរើកាន់សំបុត្រវិលត្រឡប់ទៅហើយ ក៏គិតគ្រែងអ្នួនសុតនឹងលើកទ័ពមក ទើបបង្គាប់ឲ្យកេណ្ឌប្រមូលសេនាថាហានតាំងបន្ទាយរង់ចាំទទួលទ័ពអ្នួនសុតនៅមាត់ព្រៃតស្រុកកាំងតាំង ទទួលបួងឲ្យសំបុត្រមកដល់ស៊ុនសិកជាសេចក្តីថា តាំងឲ្យស៊ុនសិកជាលៅហ្វាយស្រុកហុយខេ ហើយឲ្យលើកទ័ពទៅវាយអ្នួនសុតនៅក្រុងឡាំយ៉ុងជាប្រញាប់ ។ ស៊ុនសិកបានស្តាប់ក៏ត្រេកអរនឹងបំណងរបស់ខ្លួន ទើបប្រឹក្សានឹងសេនាថាហានតាំងពួងថា យើងត្រូវលើកកងទ័ពទៅវាយស្រុកឡាំយ៉ុង ។

តៀវដៀវធ្វើយថា ស្រុកឡាំយ៉ុងនោះស្រួលអង្គុយស្បែងអាហារ បរិបូណ៌ មនុស្សម្នាក្នុងទីចំណុះស្រុកសុទ្ធតែអ្នកមានគោគសម្បទ្រែន លោកកុំអាលមើលងាយការ ចូរឲ្យតែងសារទៅដល់ចូវ សុំឲ្យចូវមូលក ទំពាមកជួយរាយគយខាងមុខ រួចសមយើងលើកទៅខ្លប់រាយពីក្រោយ ឃើញថាអ្នកសុតនឹងបរាជ័យផង់យើងជាប្រាកដ ។ សុំនបិកបានស្តាប់ យល់ឃើញតែវ ទើបប្រើគាហានឲ្យកាន់សំបុត្រចូលទៅក្រុងហ៊ីតោ តាមពាក្យតៀវដៀនិយាយនោះ ។

(មានត)

ស្រឡាញ់ជាតិសាស្នាមហាក្សត្រ
ទុកដូចជាស្រឡាញ់កូនចៅយើង

បើចង់ឲ្យកូនចៅខ្ពស់មុខ ត្រូវស្រឡាញ់ជាតិ សាស្នាមហាក្សត្រ ។ ព្រោះបើជាតិសាស្នាមហាក្សត្រថ្កើងហើយ កូនចៅយើងក៏ខ្ពស់មុខដែរ ។ តែបើវាត ៣ នេះរលត់ហើយ កូនចៅយើងក៏ក្រៃនតឿអាប់មុខ លែងមានកេរ្តិ៍ឈ្មោះ ក្នុងប្រវត្តិសាស្ត្រជូចជនជាតិចាម ។

រឿងអារ័ក្សថ្ងៃនរឿងម្ចៃទ្រា

លោក រ៉ាយ-ប៊ុក ក្រមការ

ប្រែពីភាសាចាវ៉ាំងមកជាខ្មែរ

(តមក)

លុះធ្វើពិធីបុណ្យរួចហើយ, ព្រះចាទជាមុតពហ័ន ទ្រង់ចាននាំព្រះទេពីនឹងព្រះអង្គម្ចាស់មិត្រាវសុត្រឡប់ទៅកាន់កុំតូចនោះវិញ ។ ព្រះអង្គម្ចាស់ទាំងបីអង្គកាលស្តេចទៅដល់ ទ្រង់សំដែងការកិច្ចចំពោះព្រះមហាក្សត្រ ។ ទ្រង់ព្រះរាជទានទ្វារសព្វសាធុការ ។ នៅពេលព្រឹកនៃថ្ងៃទីពីរ ព្រះអង្គម្ចាស់ទាំងពីរព្រះអង្គ កាលតើនពីគ្រឡាព្រះបន្ទំហើយ ទ្រង់ចេញពីអាស្រមដើម្បីនឹងស្តេចទៅប្រភាតនៅលើកំតូចមលយគីរ ។ លុះទ្រង់ទាំងពីរអង្គស្តេចទៅដល់ទីនោះ ព្រះចាទជាមុតពហ័នទ្រង់ចានតទៅយល់ដំបូកសមួយហើយខ្ចស់ណាស់ ។ ទ្រង់ក៏មានព្រះបន្ទូលសួរទៅព្រះអនុជថ្លៃ អំពីបុព្វហេតុដែលកើតដំបូកសថ្មែកនេះ ។

ព្រះអនុជថ្លៃទ្រង់តបទៅព្រះដេជ្ឋាវិញថា: មានកូនពស់ជាច្រើនម៉ឺនចេញពីស្ថាននរកមក, បក្សាគរុរ Garur បក្សាពិសិដ្ឋជាព្រះទីនាំងអាទិទេពវិស្ណុចាំបរិភោគកូនពស់នេះ ហើយឆ្នងដែលគំរច្រើនបម្លូលទៅជាដំបូក ។

ព្រះអង្គម្ចាស់ជាមុតពហ័នទ្រង់មានបន្ទូលទៅកាន់ព្រះអនុជថា "ប្អូនវិលទៅអាស្រមវិញដើម្បីបរិភោគចុះ ព្រោះជាពេលដែលបងត្រូ

ធ្វើកិច្ចវត្តខាងសាសនា ។ ព្រះអគ្គម្ចាស់មិត្រាវសុទ្ធក៏វិលត្រឡប់ទៅអស្រមវិញ ។ ព្រះអគ្គម្ចាស់ដ៏មុតពហ៍ទ្ធដ៏ស្តេចទៅខាងមុខបន្តិចស្រាប់តែឮសូរដូចមនុស្សយំ ។ ទ្ធដ៏ក៏យាងតម្រង់ទៅកាន់ទីនោះ ហើយទ្ធដ៏ឧតយល់ខ្លួវយាយចាស់ម្នាក់កំពុងកើតទុក្ខលំបាកដាំងហើយយំផង ទ្ធដ៏ក៏ចិតចូលទៅជិត មានបន្ទូលសួរយាយចាស់នោះថា: "នមាតា! ហេតុម្តេចក៏យំដូចនេះ?" ។ យាយចាស់ក្រាបបង្គំទូលទ្ធដ៏ថា: "ខ្ញុំយំព្រោះបុត្រខ្ញុំជាឥសីឈ្មោះសង្ខដុវ (Sankhchur) ត្រូវបក្សាគរុនធ៌បរិភោគ, ហើយត្រូវវេនពេលនេះខានមិនបានផង" ។ ព្រះអគ្គម្ចាស់ដ៏មុតពហ៍ទ្ធដ៏តបទៅវិញថា: "លោកយាយកុំយំ ខ្ញុំសូមបួងាដីវិតខ្ញុំជំនួសបុត្រលោកយាយ" ។

យាយចាស់ក្រាបបង្គំទូលព្រះអគ្គម្ចាស់ថា: "សូមព្រះអង្គម្ចាស់ទ្ធដ៏កុំធ្វើដូច្នោះ ព្រោះបើទ្ធដ៏ប្រតិត្តព្រះការណីយកិច្ចដូចនេះ យាយនឹងទុកទ្ធដ៏ដូចជាកូនយាយចេញពីសាច់" ។

យាយចាស់ភោលយ៉ាងនេះហើយ ឥសីសង្ខដុវក៏មកដល់ទីនោះ បានស្តាប់ខ្លួវព្រៃបន្ទូលនៃព្រះអគ្គម្ចាស់ហើយក៏ក្រាបបង្គំទូលថា: "នព្រះអង្គ! មានមនុស្សដែលព្រមាច់ទូលបង្គំកំតៃច្រើន ហើយមានស្តាប់ច្រើន ។ តែមនុស្សបប្បុរសដូចជាព្រះអង្គមិនអាចបដិសន្ធិមកគ្រប់ពេលម៉ាងទេ ។ ទ្ធដ៏កុំបួងាព្រះជីវិតដោយសារទូលបង្គំឡើយ ព្រោះថាមានមនុស្សច្រើន

រយមុឺននាក់ សុទ្ធតែជាអ្នកស្រឡាញ់នូវជីវិតរបស់ខ្លួន, ហើយមិនជាការអ្វីទេត្រង់ខ្ញុំស្លាប់ឬរស់នោះ" ។

ព្រះអគ្គមាស់ដ៏មុតពហ័នទ្រង់មានព្រះបន្ទូលតបទៅពស់សង្ឃជូរវិញថា: "នេះជាការណ៍យកចិត្តនៃមនុស្សដែលកាន់សច្ចធម៌ ត្រូវប្រែតិចត្តិតាមពាក្យដែលខ្លួនសន្យា ។ ត្រូវឯងវិលត្រឡប់ទៅកាន់កន្លែងឯងវិញចុះ" ។

ពស់សង្ឃជូរឮបានស្តាប់នូវព្រះបន្ទូលព្រះអគ្គមាស់ ក៏ចូលទៅកាន់ប្លុងទីយដ្ឋាននាងទេវី ក្នុងពេលដែលបក្សាគរុះពីលើមេឃ ។ កាលដែលសត្វនោះចុះមក, ព្រះអគ្គមាស់ដ៏មុតពហ័នបានពិនិត្យយល់នូវដើងបក្សានោះ ដូចពីងពាងប្លុងដើម, មានចំពុសដូចដើមគ្រាត, ពោះដូចកំប៉ុ, កែកដូចខ្នារ ហើយស្លាបដូចពិពក ។ បក្សាហាចំពុសសុះទៅរកព្រះអគ្គមាស់ ។ ដំបូងទ្រង់ឃ្លានគេចរួច, ដល់លើកទីពីគរុះពាំទ្រង់នឹងចំពុស, នាំយកទៅកណ្តាលអាកាស ។ ក្នុងពេលនោះ កង់ព្រះហស្តដែលមានត្បូងទ្លាក់ព្រះបរមនាមព្រះមហាក្សត្រ មានប្រឡាក់ដោយលោហិតទ្លាក់ជ្រុះមក លើព្រះនលាដ ព្រះអគ្គមាស់ក្សត្រី ។ ទ្រង់ដួលសន្លប់ភ្លាត់ព្រះស្មារតី ។ ដល់ព្រះនាងទ្រង់ឃ្លានជ្រាបព្រះស្មារតីវិញ, ទ្រង់ឃាតអាមាត្យទៅក្រាបបង្គំទូលព្រះវរបិតាមាតា អំពីរឿងនេះសព្វគ្រប់ប្រការ ។ ព្រះវរបិតាមាតាទ្រង់ឃ្លានជ្រាបនូវគ្រោះថ្នាក់នេះ, ទ្រង់ស្តេចយាងមកកាន់ទីនោះ ឃ្លានឃើញកង់ព្រះហស្តប្រឡាក់ដោយលោហិត ទ្រង់ព្រះកន្សែងសោយសោកជាខ្លាំង ហើយទ្រង់ត្រមង់ព្រះអគ្គមាស់ក្សត្រី

កំស្តេចយាងតាមស្វែងរកព្រះអគ្គមហេសី ជាលំដាប់តទៅ ។ ទៅពាក់កណ្តាលផ្លូវទ្រង់បានជួបប្រទះនឹងពស់សង្ហុជុរដែលកំពុងវត់លឿន ទៅមុខ ហួសពីព្រះមហាក្សត្រីនឹងព្រះអគ្គមហេសី, ព្រះរាជបុត្រី ។ កាលពស់សង្ហុជុរវត់ទៅដល់ទីកន្លែងដែលបានឃើញព្រះអគ្គមហេសីជាប់ក្នុងក្រញាំ-ដើមបក្សាពិសិដ្ឋ គំរៀកតិះគ្រាមថា: "នុគរុរេម្ចាក់មក, ខ្ញុំម្ចាក់មក, មិនមែនអាហារអ្នកឯងទេ គឺរ៉ូវឈ្មោះសង្ហុជុរនេះជាអាហាររបស់អ្នកឯង" ។

នុគរុបានស្តាប់ពាក្យគំរាមសំឡត់សុត ដោយគិតថាខ្លួនមិនត្រូវបរិភោគបុគ្គល ដែលជាព្រាហ្មណ៍ឬក្សត្រិយ៍, ហើយក្រាបបង្គំទូលសួរព្រះអគ្គមហេសីថា: "នុព្រះអគ្គ! ហេតុម្តេចក៏ព្រះអង្គបួងបាត់ព្រះជន្មវិតដូច្នេះ?" ។ ព្រះអគ្គមហេសីទ្រង់មានព្រះបន្ទូលទៅវិញថា:

"នុគរុរ! រុក្ខជាតិតែងឲ្យម្ចប់ តែម្ចប់នោះមិនមែនរបស់រុក្ខជាតិទេ ហើយរុក្ខជាតិទាំងនេះ តែងហាលកំដៅព្រះអាទិត្យ, តែមានផ្កា, ហើយឲ្យផ្លែដើម្បីប្រយោជន៍អ្នកដទៃ ។

"គុណសម្បត្តិរបស់មនុស្សស្រីប្រុសដូចគ្នានឹងគុណសម្បត្តិនៃរុក្ខជាតិទាំងនេះ ។ បើរូបកាយមិនមានប្រយោជន៍ដល់អ្នកដទៃ តើយើងត្រូវការឲ្យមានរូបកាយនោះធ្វើអ្វី ។ មានសុភាសិតមួយដែលគេធ្លាប់ស្គាល់ថា បើកោសខ្វឹមចន្ទន៍ ក៏មានចេញចំហាយក្រអូប, រសជាតិនៃអំពៅកាន់តែផ្អែមឡើង បើគេសកសំបកហើយគេកាត់ជាកង់ៗ, ចំណែកមាស

បើគេដុតវា ។ កាន់តែមានវស្តុភ្ញីចាំដន្យឡើង ។ ដូនសប្បុរស ពិតមែនតែ
ធ្វើមរណភាពទៅ តែនិន្នាការដែលល្អបរិសុទ្ធស្ថិតនៅ ។ មិនជាអ្វីទេ
បើគេថាមនុស្សប្រុសនោះល្អប្លុកគ្រក់, មិនជាអ្វីទេ បើមនុស្សនោះ
រក្សាកោតទ្រព្យនោះឲ្យតន់ៈនៅ ឬឲ្យចាត់បង់, មិនជាអ្វីទេ បើមនុស្សនោះ
ជាត់ប្តូរស្ត្រី; បើតុកជាមានព្រឹត្តិការណ៍យ៉ាងណាក៏មនុស្សសុចរិត មិន
ចេញពីផ្លូវយុត្តិធម៌ទេ ។

"មនុស្សណាដែលមិនបានយកបូបកាយរបស់ខ្លួន មកប្រើជា
ប្រយោជន៍សាធារណៈ មនុស្សនោះមានជីវិតរស់នៅឥតប្រយោជន៍;
មនុស្សណាដែលមានជីវភាព ប្រើជាប្រយោជន៍អ្នកដទៃ មនុស្សនោះ
មានជីវភាពប្រសើរក្នុងលោក ។

"សុនខមួយ, តារ៉ាមួយ ដែលៈបត្តម្ភជីវិតរបស់វា, តែសុនខនឹង
តារ៉ាណាលះបង់ជីវិត ព្រោះព្រាហ្មណ៍ គោញី មិត្ត នារីឬបរជាតិ តែង
ស្ថិតនៅជានិច្ចឯស្ថានវៃគុន្ឋ (Baikunth) ស្ថានសួគ៌អាទិទេព វិស្ណុ) ។

គរុត្រាបទូលទៅព្រះអង្គម្ចាស់វិញថា: សត្វតិរច្ឆានក៏ពិតរលោកតែងការពារជីវិតខ្លួន ហើយនៅស្ថាននេះតម្រូវឲ្យសត្វដែលបូជជីវិត ដើម្បីជួយសង្គ្រោះអ្នកដទៃ ។ ចូរទ្រង់សូមសេចក្តីអនុគ្រោះអ្វីមួយពីទូលបង្គំ ព្រោះទូលបង្គំមានចិត្តសប្បាយពន់ពេកនឹងសេចក្តីក្សាន្តរបស់ទ្រង់ ។

ព្រះអង្គម្ចាស់ដ៏មុតពហ៌ន ទ្រង់ព្រះសណ្ដាប់នូវបក្សាពិសិដ្ឋគរុ ទ្រង់មានព្រះបន្ទូលថា: "ឧបក្សាពិសិដ្ឋ! បើអ្នកសំបាយចិត្តនឹងយើង។ សូមកុំឲ្យអ្នកបរិភោគឥស់ ហើយឥស់ដែលអ្នកបានអាស្រ័យចាំងប៉ុន្មាន សូមឲ្យមានជីវិតរស់ឡើងវិញ" ។ គរុក៏ទៅយកទឹកអម្រឹតពីស្ថាន នាកមកស្រោចលើឆ្អឹងឥស់ដែលគរជាំងហូរ, ឥស់នោះក៏មានជីវិតរស់ ឡើងវិញ ។ គរុក្រាបបង្គំទូលព្រះអង្គម្ចាស់ថា: "ទ្រង់ព្រះអង្គម្ចាស់! ទ្រង់អាចស្តេចទៅតស៊ូយកពរជសម្បត្តិវិញបានដោយសារទូលបង្គំ" ។

លុះធ្វើអំណោយទាំងនេះចំពោះព្រះអង្គម្ចាស់ស្រេចហើយ, គរុ ក៏វិលត្រឡប់ទៅកាន់គេហដ្ឋានវិញ ។ ចំណែកឥស់សង្ខ្ជុនទឹងព្រះអង្គ ម្ចាស់ដ៏មុតពហ៌នក៏វិលត្រឡប់ទៅកាន់អាស្រមវិញ ។ ទ្រង់ក៏បានស្តេច ទៅជួបនឹងព្រះនាង, ព្រះមាតាបិតាក្មេក ត្រង់ពាក់កណ្ដាលផ្លូវ, ហើយ ក៏វិលត្រឡប់ទៅដល់អាស្រមទាំងអស់អង្គ ។ ដល់ព្រះបិតុលា, ព្រះអង្គ ម្ចាស់អនុជ (ប្អូនដ៏ជូនមួយ) ហើយនឹងព្រះពរជវង្សានុវង្សទ្រង់បានជ្រាបទូល ព្រះអង្គម្ចាស់ដ៏មុតពហ៌នទ្រង់ស្តេចមកដល់ក៏ស្តេចទៅជួបនឹងទ្រង់, ក្រាប សំពះព្រះបាទាហើយក៏បីទ្រង់យកមកដាក់លើព្រះបល្ល័ង្កពរជ្យ ។

អាស្រ័យដល់ថ្ងៃរឿងនេះចប់ហើយ ក្រាបទូលសួរព្រះមហាកស្សត្រ ថា: "ទូលមហាពរជ! តើអ្នកណាមានគុណសម្បត្តិជាងគេ?" ។

ព្រះបាទពិរៈពិក្រមាជិតទ្រង់មានព្រះបន្ទូលតបវិញថា: ពស់សង្ខ័ដុរ។

- ព្រោះហេតុអ្វី, មហាពជ! ។ ព្រះបាទពិរៈពិក្រមាជិតទ្រង់តបថា: "ព្រោះពស់សង្ខ័ដុរវិលត្រឡប់មកបូជាខ្លួនវិញជាថ្មី, ជួយឧបត្ថម្ភព្រះអង្គម្ចាស់ឲ្យបានរួចពីផ្នែញបក្សាគរុរ" ។

អាវ័ក្សក្រាបបង្គំទូលទ្រង់វិញថា: "អ្នកដែលបូជាជីវិតដើម្បីជួយអ្នកដទៃ, បើនិមន្តបញ្ជាក់ថាអ្នកនោះមានគុណសម្បត្តិជាន់ខ្ពស់ប្លុ?" ។ ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលតបភ្លាម: "ព្រះបាទដំបូតពហ័នទ្រង់មានព្រះរាជ្ញាវាក្សតិយ៍, ការណីយកិច្ចនៃព្រះរាជ្ញាក្សត្រិយ៍ត្រូវតែធ្វើការបូជាជីវិតនៃជីវិត, គឺជាសកម្មភាពមួយដែលខ្ញុំមានព្រះសិរីសាស់ណាស់ទេ" ។

អាវ័ក្សបានស្តាប់ខ្លឹមព្រះរាជ្ញាព្រះមហាក្សត្រ, ក៏វិលត្រឡប់ទៅញ្ជះញ្ជួនទឹងរុក្ខជាតិដូចពីកាលមុន, ហើយព្រះមហាក្សត្រក៏លីអាវ័ក្សយកទៅ ។

ចប់រឿងទី ១៥ នៅមានរឿងទី ១៦ តទៅទៀត

(តមក)

រាគា

នវិសេសណាស់កូនស្រីប៉ា! បើកូនធ្វើចិត្តឲ្យបានដូចជាចិត្តម្តាយឯង ។
គឺកូនមិនត្រូវខ្ជិលសេចក្តីស្នាប់ ព្រោះសេចក្តីស្នាប់ជារបស់ធម្មតា ។
មុននឹងស្លាប់ត្រូវធ្វើអ្វីមួយឲ្យមានស្នាដៃ! ឲ្យមានប្រយោជន៍ដល់ប្រទេស
ជាតិសិន រួចចាំស្លាប់ចុះ កេរ្តិ៍ឈ្មោះមិនសាបសូន្យទេកូនស្រី! ។

វិណ្ណានារី

ស្នាប់ដូចម៉ាក់ខ្ញុំប្រសើរណាស់ប៉ាហ្ន៎! ប្រសើរជាងគេទាំងអស់ ។

រាគា

កូនស្រីលែងកើតទុក្ខទៅ នៅផ្ទះសប្បាយរៀនណាកូនស្រី!
ដើម្បីនឹងយកថ្លាក់ខែមកធ្វើបុណ្យឲ្យម្តាយឯង ។

វិណ្ណានារី

ចាស, លោកប៉ា!

ជាកទំ ៥

វគ្គ-រាគា

វគ្គ

យី! អើវិណ្ណានារីដឹងខ្លួនហើយ! នែកុំកើតទុក្ខពេកណាចៅយាយ!

កុំតាមយាយឯងនោះមិនកើតទេ នែចៅអើយ! យាយគ្រាន់តែឮថា ឯងកើតទុក្ខយំសោកយ៉ាងហ្នឹង យាយចាំយកមិនឆ្ងាញ់ទេ! យាយពិបាកចិត្តណាស់ ។

អើលោកកូន! ឯងម្តេចក៏មិនដែលឃើញគេផ្ទះសំបែងសោះ ចាត់នេះចាត់! លែងឃើញគេអើតផ្ទះសោះ! យំចំហើយ កូនឯងធ្លើយ៉ាងដូច្នេះគឺធ្វើឲ្យអញខ្មាសគេកក្នុងជាន់ហ្នឹងហើយ! តាំងតែពីប្រពន្ធឯងស្លាប់ ឯងមិនដែលឃើញគេសួរអញថា ម៉ាក់អើយ! ម៉ាកឯងសុខសប្បាយជាឬទេ? បើថាហៅម៉ាក់ខ្ចាចក់ថោក! ឯងហៅហាង១ គេចុះ! ថានែមេហាងអើយ! ឯងសុខសប្បាយជាឬទេ? ។

វាគា

សូមអត់ទោសអ្នកម្តាយ! ខ្ញុំពុំមែនគេកាត់ចិត្តដាច់អាល័យអំពីអ្នកម្តាយដែលជាអ្នកមានគុណ ហើយជាបុព្វការីរបស់កូនបានទេ ។ ប៉ុន្តែដោយសារកូន ដូចជាអ្នកម្តាយដឹងស្រាប់ ប្រពន្ធទើបតែទើសស្លាប់គេមិនទាន់ទើសបាន១ អាទិត្យផង ទុក្ខរបស់ខ្ញុំ នៅតែពុកណែនក្បាលដើមទ្រូងជាដរាប ពិបាកក្នុងចិត្តណាស់អ្នកម្តាយ! រកតែឈានដើរគេណាក៏សឹងតែមិនរួចដែរ ណាមួយរវល់ទើសកិច្ចការពេជការ ណាមួយរវល់ទើសកិច្ចការក្នុងផ្ទះ ។ កូនទាំងពីរ គ្រាន់តែបាត់មុខខ្ញុំមួយពេលពុំបានទេ. ហេតុនេះសូមអ្នកម្តាយជ្រាប ។ ខ្ញុំពុំមែនគេកាត់ចិត្តដាច់អាល័យពីអ្នកម្តាយទេ ។

វិធ្លី

មិនដល់ទៅមានចិត្តដោយខ្លួនឯង, អញឲ្យបំរើមកហើយ, តង់ឯង
មិនទៅទៀត. ឯងនេះអាងតែមានយសស័ក្តិ, ម្តេចឯងចង់ក្តេចអញឬ?
ឯងចង់ទៅឬមិនទៅ ក៏គ្មាននរណាហ៊ានស្តីលើក្បាលឯងដែរ. បើច្បាប់
រាជការ ឯងចេះគោរពគោតខ្លាច, បើតែង់សំដីរបស់អញ ឯងគ្មានខ្លាច
គោរពទេ, ឯងមើលមកអញម្តេចមិនត្រឹមមិនស្មើនឹងឯងឬ? ។

រាគា

សូមទោសអ្នកម្តាយ! កិច្ចការក្នុងត្រួសារ មិនធំអ្វីជាជាងកិច្ចការរបស់
រាជការផែនដីទេ, បើទុកជាខុសនឹងពាក្យអ្នកម្តាយក៏មិនជាការអ្វីដែរ ។
សូវកុំឲ្យខុសនឹងច្បាប់រាជការ ពីព្រោះការរាជការមិនមែនចេះតែធ្វើទៅទេ,
ការអ្វីនិមួយៗ ដែលគេធ្វើហើយតែងតែមានប្រយោជន៍ ។

វិធ្លី

មានប្រយោជន៍ឬឥតប្រយោជន៍ អញមិនដឹង, អញមិនមែនជា
មនុស្សនយោបាយក្នុងនគរទេ, អញជាម្តាយរបស់ឯង អញចង់ជាឯង,
បើអញនិយាយ ត្រូវឯងស្តាប់អញ, ឯងមិនត្រូវប្រែកែកនឹងសំដីរបស់
អញទេ ។

រាគា

ខ្ញុំបាទសូមប្រែកែកហើយ អ្នកម្តាយ! ចំពោះរឿងនេះ ។

วิฏฺฐี

ចំពោះរឿងនេះ ម្តាយសូមទោសកូន ! កូនប្រែកែមិនបានទេ ! ។

ราคา

អ្នកម្តាយ ! បើកូនប្រព្រឹត្តតាមពាក្យរបស់អ្នកម្តាយ ច្បាស់ជាបណ្តាក្រស្តែខ្មែរ ទឹងនាហ៊ឺនតាំងឡាយក្នុងខេត្តនេះគេមើលងាយខ្ញុំមិនខានទេ ។ គេមុខជានឹងពោលពាក្យពុំពីពោះស្តាប់ឲ្យខ្ញុំពុំខាន ព្រោះខ្ញុំមានបុណ្យសក្តិប៉ុណ្ណឹងដែរ ហើយនៅប្រព្រឹត្តអំពើអាក្រក់បែបហ្នឹងទៀត ។

วิฏฺฐี

នរណាមើលងាយ ! មើលងាយចុះ ! កុំឲ្យបង្កាក់បុណ្យសក្តិ, អញមិនខ្វះបាយឲ្យឯងស៊ីទេ, ស្រែអញតាំងឯង្គែក, ប្រាក់អញចងការពេញតាំងខេត្ត, នរណាក៏ដំពាក់លុយអញដែរ ។

ราคา

ទេ អ្នកម្តាយ ! ប្រាក់គាសរបស់អ្នកម្តាយ ងាយនឹងរកទេ ។ ឯមិត្តភក្តិក្រណាស់ម៉ាក់ ! មិនងាយនឹងរកបានទេ ដែលហៅថាកល្យាណមិត្តនិមួយៗ នោះពិបាកនឹងរកណាស់ ។

วิฏฺฐี

នែ ! ឯងកុំឆោតពេក, ឲ្យតែមានប្រាក់មិនបាច់ខ្វះទេមិត្តនោះ, ឯងចង់យកប៉ុន្មានកប៉ាល់ក៏មិនខ្វះដែរ, អញចំណាយដប់លៀងអស់តែ ១

តាន់រៀល, ឯងប្រែងតែចាប់ដៃគំនាប់ទៅចុះ ។ ឯងមើលជាតិចិន វាមកស្រុកខ្មែរ វាមានស្គាល់នរណា ម្តេចក៏វាទៅយូរៗទៅ វាស្គាល់សុទ្ធតែនាហ្នឹងធំៗ, អ្នកតូចវាមិនចាប់ខ្លីមើលមុខផង ។ តើមកអំពីអ្វី? មិនមកតែអំពីលុយ មកតែអំពីប្រាក់ វាជាក់ហោចប៉ុន្មានមេធំៗ តែ ១ រយរៀលប្តូរ ១ តាន់រៀល ប្តូរហៅទៅស៊ីបុណ្យចូលឆ្នាំវាម្ភៃ៧ តាក់ក្បាលខ្មែរឯងនេះធ្វើជាមិត្តភក្តិចាន់ភ្លាម, ឯងមិនឃើញចិនទៅក្នុងខេត្តវែងវែនសព្វថ្ងៃទេឬ? ។

រាគា

ទេអ្នកម្តាយ! ខ្ញុំមិនចង់ឲ្យគេចាប់អានខ្ញុំដោយសារប្រាក់កាសនោះទេ ប្តូរមួយដោយសារភាក់ដោយឲ្យស៊ីឯកនោះទៀយ គឺខ្ញុំចង់បានតែមិត្តចិត្តត្រង់ប៉ុណ្ណោះទេ, ចាប់អានគ្នាទៅវិញទៅមកដោយយោគយល់ចិត្តថ្លើមគ្នា. មនុស្សយើងគ្មានអ្វីធំជាឯចិត្តទេ អ្នកម្តាយ! ។

រឿ

ណ្តើយកុំនិយាយច្រើន, ថ្ងៃអាទិត្យស្អែកនេះ អញឲ្យឯងទៅរៀបអាពាហ៍ពិពាហ៍ហើយ ។

រាគា

ទេអ្នកម្តាយ! ខ្ញុំមិនទៅពីទីនេះទេ ខ្ញុំមិនត្រមទៅរៀបការទេ ។

វិធ្លី

ឯងមិនព្រមម្តេចនឹងចាន បើអញដណ្តឹងគេហួសទៅហើយ! ឯងចង់ធ្វើឲ្យអញអាម៉ាសមុខដោយសារឯងឬ? ។

រាគា

ទេ កាលដែលអ្នកម្តាយទៅដណ្តឹងកូនគេ ខ្ញុំឥតមានប្រែអ្នកម្តាយទៅកាលណា! អ្នកម្តាយទៅដណ្តឹង ដម្រែតែចិត្តអ្នកម្តាយទេតើ! ហើយពេលនេះបើខ្ញុំមិនយកនាងនោះ អ្នកម្តាយក៏គ្មានអាម៉ាសមុខដោយសារខ្ញុំដែរ។

វិធ្លី

ម្តេចមិនអាម៉ាសមុខ បើអញចានិយាយនឹងគេផ្តែលទៅហើយ គេថាព្រមឲ្យហើយ! តើឯងត្រូវទៅការថ្ងៃអាទិត្យស្អែកនេះ ។

រាគា

ទេអ្នកម្តាយ! បើខ្ញុំពុំព្រមទទួលយកកូនពេលនេះ គឺខ្ញុំគុំមុខឲ្យអ្នកម្តាយសម្លឹមណាស់ ពីព្រោះតែកាលណាការហើយទៅ បើខ្ញុំមិនព្រមទទួលរួមស្នេហាជាមួយនឹងនាង នាងមិនកើតទុក្ខដោយសារខ្ញុំ. ហើយម៉ាក់មុខជានឹងខ្មាសគេជាអនេកពុំខាន ដោយកូនពុំព្រមស្រឡាញ់គ្នាហើយចាស់ៗ ចេះតែបង្ខំ ។

វិធ្លី

ទេ! តែឯងការហើយមុខជាស្រឡាញ់គ្នាមិនខានឡើយ ព្រោះកូនគេរូបល្អណាស់ ហើយជាអ្នកមានយ៉ាងសម្លឹមក្នុងខេត្តស្វាយរៀង

គឺគ្មាននរណាមានដល់គេទេ : ផ្ទះថ្មាំងខ្ពស់ៗ រថយន្តចាំងឡូ ចាវព្រាវ គេមិនចាប់ខ្លះនឹងប្រើប្រាស់ទេ ។

រាគា

ទេវ៉ុកម្ពាយ ! សូមអត់ទោស យើងកុំទៅពឹងបង្អែកនឹងក្តើរបស់ទ្រព្យគេនោះ ។ យើងមានទ្រព្យរបស់យើង គ្រាន់នឹងចិញ្ចឹមជីវិតដែរ យើងមិនចាប់ទៅរស់នៅដោយសារគេទេ ។ អ្នកម្ពាយ ! តែគេមានជាងយើង មុខជាថ្ងៃណាមួយគេហ៊ានមើលងាយយើងមិនខានទេ, ហេតុនេះ កូនពុំព្រមទទួលយកជាដាច់ខាត ។

វិដ្ឋី

បើឯងមិនព្រមទទួលយក អញហ៊ានវាយបណ្តើរឯង ឡូឡើងរថយន្ត, រាយឲ្យអ្នកស្រុកព្រៃវែងមើលមុខឯងឥឡូវ ។ អញធ្វើម្ដាយឯង អញធំជាងឯង, បើអញនិយាយអ្វី ត្រូវឯងស្តាប់ ។

(មានត)

រឿងប្លន់ធនាគារ

លោក ផេង-ជ្រៀ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តមក)

តាំងពីមនុស្សទាំងឡាយឈប់ដើរមកចំផ្លូវខ្ញុំ ហើយខ្ញុំឈប់ទៅរកគេ ខ្ញុំក៏ឈប់ឈ្លោះទៀតណែនទំាមនុស្សទាំងនោះ ខ្ញុំគ្រាន់តែនឹកអាណិត ។ បើខ្ញុំចូលនឹងមនុស្សមានទុក្ខ ខ្ញុំគ្រាន់តែជួយណែនាំដោយពាក្យសំដីប្រដៅ ដូចអ្នកដំណើរដើរមាត់ជ្រោះ គ្រាន់តែហុចដៃទៅឲ្យអ្នកធ្លាក់នោះតោងប៉ុណ្ណោះ ។ ខ្ញុំឃើញមានតែមនុស្សសុចរិតៗ ដែលចូលស្តាប់សំដីខ្ញុំ ។ មនុស្សសំណល់ប៉ុន្មានហៅចូលមកតុំបាន ពាល់រូបសុទ្ធតែមានចិត្ត តែចិត្តហ្នឹងឯងច្រើនតែជំទាស់ដោយរាំងគីតណ្ហារបស់ខ្លួនឯង ។ កន្លងរាងជីវិតរបស់ខ្លួន គេយកតែតត្តតត្តិមសារមកជាអារម្មណ៍ដែលនាំខ្លួនឲ្យវង្វេងរួចហើយតាំងថ្លាងខាងក្រោយ អំពាវនាវរកទេព្តាឲ្យជួយដោយការយល់ខាស់តើតមកតែពីខ្លួនឯង ។ ក្នុងបណ្តាមនុស្សទាំងឡាយរងទុក្ខវេទនា ដែលខ្ញុំបំរុងនឹងនាំឲ្យដើរតាមផ្លូវត្រង់ ខ្ញុំមិនដែលឃើញរូបណាមួយដែលមានទុក្ខព្រោះអ្នកឯទៀតឲ្យ ។ ដំបូងគេស្តាប់ខ្ញុំដោយសង្ឃឹមថាខ្ញុំនឹងជួយគេឲ្យបានបុណ្យ មានឲ្យ លុះឃើញខ្ញុំបង្រៀនឲ្យលោតរំលងចោលបុណ្យសំគ្តីនឹងឲ្យដូច្នោះ គេត្រឡប់ថាខ្ញុំ

ជាមនុស្សមានទុក្ខវេទនាវិញ។ មិនគិតស្វែងរកសេចក្តីសុខសាយទុក្ខដូចគេ ត្រូវការ គេតែងតែជៀសដល់ការប្រព្រឹត្តិស្មាត់នៃខ្ញុំ គេស្មើថាពួកគេឯណោះទើបជាប្រយោជន៍ដល់មនុស្សទាំងឡាយ ហើយតែងប្រឆំទាញឲ្យខ្ញុំចូលក្នុងរណ្តៅជាមួយ។ តែប្រសិនបើខ្ញុំដើរចូលជាមួយគេ ចិត្តខ្ញុំមិនប្រឡាក់ជាមួយឡើយ។ ខ្ញុំច្រែនតែទាញយករឿងខ្លួនឯងមកប្រដៅខ្លួនខ្ញុំ ខ្ញុំលើករឿងដែលកន្លងបួចហើយ យកមកជាក់ត្រជាងនៅពីមុខដើម្បីប្រដៅចិត្ត ការរក្សាព្យាបាលសម្បត្តិទ្រព្យគ្រឿងឈ្មោះតាមរាគនឹងយោបល់ទាំងឡាយដែលមនុស្សលើផែនដីចំប្រឹងកាយជណ្តើមគ្នា។

មនុស្សទាំងឡាយដែលចំឈ្លោះប្រកែក ក៏យគ្នា ច្បាំងគ្នា ដោយកំហឹងយ៉ាងខ្លាំងដើម្បីដណ្តើមយកវត្ថុគ្នានឹមសារ, មិនជាប្រយោជន៍ដ៏ឋិតថេរ មិនខុសគ្នានឹងរលកទឹកក្នុងស្ទឹងដែលខ្យល់ប៉ក់មកទង្គិចគ្នា បែកពពុះ ហូរទៅប៉ះនឹងថ្មហើយរលាយបាត់អស់ រកវិលមកវិញពុំឃើញឡើយ។ ចំណែកខាងខ្ញុំ។ ស៊ូទុកឲ្យទឹកហូរតាមសម្រួលសំដៅមហាសមុទ្រគ្មានកោះត្រើយគឺអនាគតជាតិ ហើយតាមការប្រព្រឹត្តិដ៏ប្រពៃនៃខ្ញុំសព្វថ្ងៃ ខ្ញុំនឹងឡើងទៅដួបនឹងព្រះជាម្ចាស់ ហើយខ្ញុំសង្ឃឹមថានឹងមានសំណាងល្អក្នុងលោកជាតិទៀត។

ប៉ាកជាមែន នៅទីភ្នំនេះ គេមិនឃើញមានរបស់អ្វីជាច្រើនតែគង់មានកន្ទែងមានចំនងស្រួលគួរសមដែរ ប៉ុន្តែសម្រាប់តែជនណាជា

អប្បិច្ចតាដូចខ្ញុំ ។ ស្ទឹងដែលហូរកាត់មុខឆ្នេរខ្ញុំ លាតសន្ធឹងវែង ធ្លងកាត់ព្រៃឈើ លុះចេញពីព្រៃនោះ មានសណ្ឋានជាព្រៃតជីតមួយដ៏វែង មានដើមត្រីក្បាមែកសាខា ដុះនៅលើមាត់ច្រាំង មានមូលត្រជាក់ឈឹងឈ្ងៃឈៃ ។ គេឃើញមានព្រៃគ្មោតដុះតាសតេញ មានដើមដូចសសរ រលើងណាស់ ខ្ពស់ប្រហែលមួយរយជំហាន មានកំពូលស្វឹកលេចឡើងពីលើឈើឯទៀត ដូចជាព្រៃដុះលើព្រៃផងគ្នា ជាពីរជាន់ខាងនេះមានវល្លិតាំងពួកយផ្សេង ។ ឥរិយាក់ព័ន្ធព័ន្ធលើគ្នាតាដើមមួយទៅដើមមួយបង្កើតឡើងជាកំរង់ផ្ការាស្រឡះ ខាងនោះសុទ្ធតែពាំងនេតគឺស្វឹកឈើខៀវស្រងាត់ ។ ឈើខ្ទះធ្លាយកុំនត្រអូបឈ្ងុយឈ្ងប់ រហូតដល់ជាប់ទឹងខោអាវ បើចេញមកហើយដើរជិតគេ។ ជីនថាអ្នកនេះទើបទឹងចេញមកពីព្រៃនោះ ។ រដូវក្តា គេតែឡើកមើលទៅហាក់ដូចគេយកត្រីលទៅត្របតាលើ ។ នោះខាងចុងនិតាយរដូវ មានបក្សាបក្សីជាច្រើនរបៀបមិនដឹងហេតុអ្វីរកយល់មិនឃ្លាន ហើរមកតាមរទេសឆ្ងាយ ។ មិនដែលស្គាល់ទៅនេះត្រើយសមុទ្រម្ខាង នាំគ្នាមកស៊ីផ្លែឈើកន្លែងនេះ មានពណ៌ស្វាយបៃតងខ្ចីផ្លុយគ្នាខ្លឹតពណ៌ស្វឹកឈើចាស់ ។ ដែលកំណៅចុះចាំងត្រូវ ។ នោះបណ្តាបក្សីទាំងនោះ គេស្គាល់ច្បាស់តែសេកយារនិងត្រាបខៀវ ។ ស្មាជាសត្វមានកំណើតនៅក្នុងព្រៃនោះមានពណ៌ប្លែកផ្សេង ខ្លះស្មើរខៀវមុខខ្មៅ លោតលេងប្រឡែងគ្នា ខាងណាលមែកឈើលុតៗ

អាខ្លះយកកន្ទុយវុំនឹងមែកឈើ ទំលាក់ខ្លួនមកកណ្តាលវាល ហោលទៅ
ហោលមកក្នុងអាកាស អាខ្លះទៀត កូនទុបពីក្រោយខ្នងលោតឆ្លុតចុះ
ឆ្លុតឡើង ពីមែកមួយទៅមែកមួយ ។ គាំក្មេងជាអាវុធសម្រាប់ពិឃាត
សត្វ តែអាវុធនេះមិនដែលមកបង្ខាចសត្វតាំងនោះឡើយ ។ គេឮសូរតែ
សម្រែកដ៏សប្បាយ គឺសំឡេងសត្វស្វាបក្នុងសមុទ្រដែលវៃស្រែកឡើង
រំពងព្រៃតាំងមូល ។

ទៅដល់ព្រៃនោះ មិនឆ្ងាយប៉ុន្មានពីកន្លែងទឹកឈូរ លុះមកដល់ទឹកហូរឆ្លាក់មិនធ្វើឲ្យអង្រុតដល់ត្រចៀក គ្រាន់តែស្រួលស្តាប់ទំនឹងមាន
ចំហាយត្រជាក់ផ្សាយមកដល់ គេឃើញមានកូនកុំមួយ ។ ចួនកាល
វេលាថ្ងៃ នាងឡាតូរ នាងម៉ាគីរីត នាងវីរស៊ីនី អាប៉ូលនឹងខ្ញុំ នាំគ្នាទៅ
អាស្រ័យបាយនឹងមូលក្នុងនោះ ។ វីរស៊ីនីជាធីតាធ្លាប់ធ្វើកុសលដល់អ្នកដទៃ
ម្ល៉ោះហើយគ្រាន់តែអាស្រ័យផ្លែឈើមួយទៅស្រែ នាងក៏យកគ្រាប់កប
ក្នុងដីដែរ ។ នាងនិយាយថា កាលណាឈើនោះដុះធំឡើង វាមានផ្លែ
ជាប្រយោជន៍ដល់អ្នកដំណើរបេះស៊ីគ្រាន់បន្តកម្លាំង បើមិនដូច្នោះសោត
គង់សម្រាប់ឲ្យសត្វស្វាបស៊ីដែរ ។ មានមួយថ្ងៃ នាងស៊ីផ្លែល្ហុងទុំទៅ
ក្បែរដើមក្តុំ រួចហើយកប់គ្រាប់ទៅទីនោះ ។ មិនយូរប៉ុន្មាន គេឃើញ
ល្ហុងដុះឡើងយ៉ាងច្រើន អាខ្លះមានផ្លែផង ។ កាលដែលនាងវីរស៊ីនី
ចេញទៅ ដើមល្ហុងនោះទៅជាឆ្ងាយជាងដង្គួងនាងទេ តែល្ហុងជារុក្ខជាតិ

ដុះរហ័ស ចំនួនប្រហែលពីរឆ្នាំក៏ចាន់តំពស់ប្រហែលដប់ហត្ថ មានផ្លែ
ស្អកស្អុះស្អុតតែពុំ ។ អាប៉ូលលោដើរទៅចំកន្លែងហ្នឹងប្រទះឃើញល្ហុង
ដែលវ៉ែស៊ូនីដាំមានផ្លែពុំច្រើន ក៏សប្បាយចិត្តណាស់ តែលោកត្រឡប់
ត្រួយវិញមួយរំពេច មកពីគិតឃើញថានាងទៅចាត់អីក៏យូរម្ល៉ះ ។ រីឯ
ទាំងឡាយដែលយើងឃើញជានិច្ចកាលថ្ងៃ មិនអាចឲ្យយើងយល់ថាជីវិត
នៃយើងប្រព្រឹត្តទៅរហ័សឡើយ ពីព្រោះវត្ថុទាំងនោះដូចសន្សឹមៗ រក
មើលពុំយល់ពុំស្គាល់ មិនដូចជាវត្ថុទាំងឡាយដែលចាត់ពីមុខយើងទៅ
ឃ្លាតឆ្ងាំ ហើយទើបនឹងត្រឡប់ឃើញឡើងវិញ របស់ទាំងនោះអាចឲ្យ
ដំណឹងថាជីវិតនៃសត្វទាំងឡាយប្រព្រឹត្តទៅរហ័សដូចគំនុំហូរ ។
អាប៉ូលតែឃើញដើមល្ហុងកាលណា ត្រួយចិត្តស្រងេះស្រងោចពេក ។
ចួនណាក៏ចង់កាប់ចោល ព្រោះតែឃើញដើមល្ហុងហ្នឹង នាំឲ្យនឹកថានាង
ទៅអីយូរម្ល៉ះ ចួនណាក៏ទុកដើមល្ហុងដូចជាចេតិយមួយកើតមកពីកុសល-
ចិត្តនៃវ៉ែស៊ូនី ក៏នុបចើបដើមល្ហុង ក៏និយាយនឹងដើមល្ហុងជាសំដីប្រកប
ដោយភាពនឹងនាក្យជាទីរលឹកជាទីស្តាយស្រណោះ ។ នុដើមល្ហុង
អើយ ! ខ្លួនអ្នកទៅចាត់ ចេះទុកគ្រាប់ឲ្យដុះនៅក្នុងដៃយើងទៀត តែ
ឃើញកាលណា គួរឲ្យខ្ញុំស្រណោះ គួរឲ្យខ្ញុំគោរពអីម្ល៉ះទេ ។ សូម
ធម្មតាដែលតែងបំផ្លាញទូវត្ថុជាគ្រឿងលោភនៃស្តេចទាំងឡាយ ឲ្យឆួយ
បន្តើតតែការល្អនៃវ៉ែស៊ូនីជាស្រេចក្រមុំអ្នកក្រ ឲ្យមានការតែច្រើនរៀងៗ
ក្នុងដៃនេះ ។ (មានត)

សន្និសិទព្រះពោធិវង្ស ហួត-តាត

ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ជាប្រធាននៃគណៈប្រតិភូខ្មែរ

ថ្លែងអំពីសមាជសាកលលើកទី ២ នៃពុទ្ធសាសនា

នៅទីក្រុងតូក្យូ (ប្រទេសជប៉ុន)

ពុទ្ធសាសនបណ្ឌិត្យ

(ត-មក)

លំដាប់អំពីនេះ សូមចុះព្រះសង្ឃដីកានៃសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត (ជោតញ្ញាណោ) សង្ឃនាយកគណៈមហានិកាយ នឹងសុន្ទរកថា ព្រះពោធិវង្ស ហួត-តាត (វជិរប្បញ្ញោ) ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ដូចតទៅនេះ :

សារលិខិត

របស់

សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត ជោតញ្ញាណោ

សង្ឃនាយកគណៈមហានិកាយ

កម្ពុជរដ្ឋ

កន្លងកាលប្រជុំសន្និសិទគ្រាទី ២ នៃពុទ្ធិកសមាគមពិភពលោកនៅប្រទេសជប៉ុននេះ ខ្ញុំនឹកស្តាយណាស់ដែលពុំបានមកចូលរួមប្រជុំជាមួយនឹងអស់លោក ដូចកាលពីសន្និសិទគ្រាទី ១ ប៉ុន្តែគណៈប្រតិភូខ្មែរដែល

មានព្រះពោធិវង្ស ហួត-តាត វជិរប្បញ្ញោ ជាប្រធានមកកាន់សន្និសីទ នេះក៏ទុកស្មើដូចខ្ញុំបានមកប្រមូលប្រជុំ ជាមួយនឹងអស់លោកដែរ ។

ព្រះពុទ្ធសាសនាក្នុងប្រទេសខ្មែរដែលមានប្រជាជន ៩៨ ក្នុង ១០០ គោរពរាប់អានតាំងពីបុរាណព្រៃនាយមកនោះចាប់តាំងពីគ ស. ១៩៥០ មកដល់ គ. ស. ១៩៥២ នេះ មានការលូតលាស់ចំរើនប្លែកជាងពីដើមយ៉ាងច្រើន ដោយពុទ្ធសាសនិកជនដែលបានដឹងថា ពុទ្ធកសមាគមពិតពិសោកកើតឡើងហើយ ក៏នាំគ្នាចំប្រឹងប្រែងដោយពេញកំលាំង ។

ខ្ញុំមានសង្ឃឹមថា ព្រះពុទ្ធសាសនាគ្រប់ប្រទេស ដែលធ្លាប់បានកាន់គោរពមកហើយ គង់នឹងមានសេចក្តីលូតលាស់ចំរើនដូចគ្នាដែរ ។

បើពុទ្ធមាមកជនគ្រប់ប្រទេស ចំប្រឹងបំពេញកិច្ចខាងព្រះពុទ្ធសាសនាដោយពេញកំលាំងយ៉ាងនេះហើយ, ព្រះអនុត្តរធម៌របស់ព្រះសម្មាសម្ពុទ្ធមុខជានឹងបញ្ចេញពន្លឺរស្មីឆ្ការយទូទៅក្នុងពិភពលោកពុំខាន ។

សព្វថ្ងៃនេះ ខ្ញុំមានជន្មាយុគំរប់ ៦៩ ឆ្នាំបួលក្នុងបច្ចុប្បន្នហើយ, ខ្ញុំយល់ថាអាយុសង្ខារមិនទៀងក៏ពិតមែន ប៉ុន្តែរីឯភាពរបស់ខ្ញុំ ក្នុងការចំប្រឹងទំនុកបំរុងព្រះពុទ្ធសាសនាឥតមានរួញរាយទេ, ខ្ញុំសំគាល់ខ្លួនខ្ញុំដែលចំប្រឹងខ្នះខ្នែង កាន់ការពារព្រះពុទ្ធសាសនា ទុកស្មើដូចជាថាខ្ញុំនឹងមានជីវិតរស់នៅ ១.០០០ ឆ្នាំ ។

ពិតជាខ្លួនខ្ញុំពុំបានមកកាន់មហាសន្និបាតនេះក៏មែន ប៉ុន្តែខ្ញុំបញ្ជូនចិត្តមកកាន់ប្រជុំជាមួយនឹងអស់លោកដោយពាក្យសង្ឃឹមរបស់ខ្ញុំនេះ ។

កង៏នាមនៃតិកុសង្ឃ នឹងពុទ្ធសាសនិកជនកង៏កម្ពុជរដ្ឋ ខ្ញុំសូមជូនពរ
យ៉ាងស្មោះចំពោះ នឹងសេចក្តីសង្ឃឹមយ៉ាងមាំ សុំឲ្យសន្និសិទនេះបាន
សម្រេចផលល្អ ដ៏កនាំប្រជាជនកង៏ពិភពលោក ទៅកាន់ផ្លូវប្រតិបត្តិ
យ៉ាងត្រឹមត្រង់តាមលំអានសាសនានៃព្រះបរមគ្រូ ដើម្បីជាគុណ
ប្រយោជន៍នឹងសន្តិភាពនៃពិភពលោក ។

ព្រះបរមគ្រូជាម្ចាស់ទ្រង់បានគ្រាយផ្លូវនៃព្រះសទ្ធម្មដ៏ប្រសើរ នឹង
សន្តិភាពជានិន្នរ៍ហើយ ។ ខ្ញុំសង្ឃឹមថា: សន្និសិទគ្រាទី ២ នៃពុទ្ធិក-
សមាគមពិភពលោកនេះ នឹងប្រព្រឹត្តទៅដើម្បីឲ្យប្រជាជនគ្រប់ប្រទេស
ប្រតិបត្តិតាមផ្លូវនោះពុំខាន ។

ខ្ញុំសូមជូនសព្ទសាធុការពរចំពោះមហាសន្និបាត សូមបានប្រកប
ដោយវឌ្ឍនភាពគ្រប់យ៉ាង ។

មួយយ៉ាងទៀត, ខ្ញុំសូមផ្សាយមេត្តាចិត្តចំពោះសាកលលោកទាំង
មូល សូមបានប្រកបដោយសន្តិភាពនឹងវឌ្ឍនភាព ដ៏សមរម្យតាមព្រះ
បរមពុទ្ធាថតវែងឆ្ងាយទៅ ដោយអំណាចមេត្តាចិត្តនេះ !

សម្តេចព្រះមហាសុមេធាធិបតី ជួន ណាត ជោតញ្ញាណោ

(សារលិខិតនេះ ព្រះពោធិវង្ស ហ៊ា. ត. វជិរប្បញ្ញោ បានប្រែជា
ភាសាអង់គ្លេស ហើយបោះពុម្ពចែកកង៏ខុតាសនៃមហាសន្និសិទទី ២ នៃ
ពុទ្ធិកសមាគមពិភពលោក នាក្រុងតូក្យូ ប្រទេសជប៉ុន) ។

សេចក្តីរាយការណ៍

របស់ព្រះពោធិវង្ស ហួត - តាត វង្សប្បញ្ញា ជាន់ប្រែជាភាសាអង់គ្លេស ហើយចោះពុម្ពចែកគ្នានៅសមបាសន្និសិទទី ២ នៃពុទ្ធិកសមាគមពិភពលោក នាក្រុងតូក្យូ (ប្រទេសជប៉ុន)

សុន្ទរកថា

អស់លោកចាំងឡាយ !

យើងជាគណៈប្រតិភូនៃកម្ពុជវង្ស ដែលបានមកកាន់ទីមហាសន្និបាតនេះ មានសេចក្តីរីករាយនឹងសេចក្តីពេញចិត្តដ៏ក្រៃលែង ដោយយើងបានដឹងជាយូរមកហើយថាប្រទេសជប៉ុននេះ ជាប្រទេសមួយដែលមានពុទ្ធសាសនាផ្សាយចូលមក តាំងពីពុទ្ធសករាជ ១០៤៥ ជនជាតិជប៉ុនបានទទួលកាន់ពុទ្ធសាសនា. ពុកព្រះពុទ្ធសាសនាជាគន្លងជាផ្លូវសម្រាប់ដើរទៅរកអារ្យធម៌ ទោះបីកាលសម័យមានការប្រែប្រួលយ៉ាងណា ក៏មិនចោះបង់ចោល នៅតែប្រកាន់យកព្រះពុទ្ធសាសនាពុកជាទីគោរពរាប់អានជាដរាបមក ។ ប៉ុន្តែការដឹងរបស់យើង តាមដំណឹងដែលមានក្នុងប្រវត្តិនៃព្រះពុទ្ធសាសនាក្នុងសៀវភៅនានាប្រទេស ក៏ឈ្មោះថាដឹងអំពីចម្ងាយ មានអាការមិនជាក់លាក់ក្នុងចិត្ត ។

ឥឡូវនេះ យើងបានមកកាន់ទីមហាសន្និបាតក្នុងប្រទេសនេះ បានឃើញជាក់ច្បាស់នឹងចក្ខុ នាំឲ្យយើងមានសោមនស្សក្រៃលែង ។

មួយយ៉ាងទៀត, ដោយយើងបានដឹងថា មហាសង្គ្រាមលើកទី ១ នឹងទី ២ នាំឲ្យពុទ្ធិកជនក្នុងប្រទេសនានា ឃ្លាតការប្រស័យរកគ្នាពីប្រទេសមួយទៅប្រទេសមួយ គឺព្រំដែននៃប្រទេសនីមួយៗ ដូចជាទំនប់ទប់មិនឲ្យពុទ្ធិកជនធ្វើការរកគ្នាបាន រហូតដល់ទៅឃ្លាតចាកមិត្តភាពរវាងអ្នកកាន់ព្រះពុទ្ធសាសនាដូចគ្នា បើចេះរួបរួមគ្នា ពង្រឹងគ្នារវាងអ្នកកាន់ព្រះពុទ្ធសាសនា ក៏បានតែក្នុងប្រទេសមួយៗ ប៉ុណ្ណោះ ។ តាំងពីពុទ្ធិកសមាគមពិភពលោកកើតមានឡើង សមាគមនេះអាចលុបទំនប់នោះឲ្យរលាយអស់ ហើយបើកផ្លូវឲ្យពុទ្ធិកជនដែលនៅក្នុងប្រទេសផ្សេងៗ អាចទៅមកប្រស្រ័យនឹងគ្នាបាន ដូចជាក្នុងកាលនេះ យើងជាពុទ្ធិកជនក្នុងប្រទេសនានា ដែលមិនធ្លាប់ឃើញគ្នាសោះ ក៏ត្រឡប់ទៅជាបានមកជួបជុំគ្នា ឃើញមុខគ្នា នេះគឺប្រស្រ័យនឹងពុទ្ធិកសមាគមពិភពលោកដោយពិត ។

ដូច្នេះនាំឲ្យយើងមានសង្ឃឹមថា តទៅក្នុងអនាគតមិនយូរប៉ុន្មាន ដោយអំណាចនៃពុទ្ធិកសមាគមពិភពលោក ពុទ្ធិកជនគ្រប់ប្រទេសនឹងក្លាយទៅជាមិត្តភាពរកគ្នា ហើយអាចរក្សាព្រះពុទ្ធសាសនាឲ្យបានចំរើនរុងរឿងក្នុងពិភពលោកនេះមិនខាន ។

(មានត)

សុន្ទរកថា

លោកដុកទ័រគុណាបលៈបិយៈសេនៈម៉ាឡាលៈសេកេរៈ

ជាប្រធានពុទ្ធិកសមាគមពិភពលោក ក្នុងក្រុងសមាជសាកលលើកទី ២

នៃពុទ្ធសាសនានៅទីក្រុងតូក្យូ (ប្រទេសជប៉ុន)

(តូក្យូ ២៥ កញ្ញា, ១៣ តុលា ១៩៥២)

ពុទ្ធសាសនបណ្ឌិត្យ

(តមុក)

តាំងពីយើងបានជួបគ្នានៅពេលក្រោយនេះ យើងអាចក្រឡេកទៅកាន់ការចលនាខាងព្រះពុទ្ធសាសនា យើងមានមនោសញ្ចេតនាប្រកបដោយសុខស្រួលចំពោះការចំរើន ដែលយើងបានបំពេញខាងព្រះពុទ្ធសាសនានឹងសកម្មភាពនៃសាសនានេះ ។

មានផែនដីកាន់ព្រះពុទ្ធសាសនាខ្លះ បានទទួលកងពេលដ៏ថ្មីនេះនូវសេរីភាពពេញលក្ខណៈ ខ្លះទៀតទទួលការខុសត្រូវចំពោះការត្រួតត្រាប្រទេសរបស់ខ្លួន ។ នៅប្រទេសជប៉ុននេះ យើងបានធ្វើពិធីបុណ្យទី ១.៤០០ រំលឹកដល់ថ្ងៃ ដែលព្រះពុទ្ធសាសនាចូលមកប្រតិស្ថាននៅប្រទេសនេះ ចំណែកឯពុទ្ធសាសនិកជន នៃប្រទេសឯទៀតជាច្រើនដែលស្ថិតនៅខាងត្បូង នឹងអាស៊ីបូព៌ា បានប្រុងប្រៀបក្នុងរយៈវេលា ៤ ឆ្នាំទៀត នឹងធ្វើបុណ្យទី ២.៩០០ ជាឧទ្ទិសកេដើម្បីរំលឹកថ្ងៃបរិនិព្វានៃ

ព្រះសម្មាសម្ពុទ្ធ ។ មានហេតុកេច ដែលគួរសំគាល់បានជាថ្ងៃនក្ខត្តឫក្ស នោះ គឺជាថ្ងៃដែលធ្វើឲ្យព្រះពុទ្ធសាសនា បដិសន្ធិជាប្តីប្រពន្ធជាមួយពលភាពអស្ចារ្យ ។ ក្នុងគ្រប់ទីកន្លែង គេបានឲ្យដំណឹងមកយើង នូវសកម្មភាពសម្បើមជាពន្លឺក ចំពោះពួកពុទ្ធសាសនិកជន ហើយនឹងសេចក្តីបំណងនៃពួកគ្រែព្រះពុទ្ធសាសនា ចង់ស្គាល់ជាក់ច្បាស់នូវទម្រង់នឹងអត្ថន័យនៃពុទ្ធោវាទ នឹងការយកទៅអនុវត្តន៍ ជាពិធីប្រតិបត្តិកងពិតពេលកំនើប ។

ការភ្ញាក់ឡើងនៃព្រះពុទ្ធសាសនា

ទៅប្រទេសឥណ្ឌា ឥឡូវចុងផុតស្បែរពីប្រជាកំនៃការរីបជាន់បរជាតិ ប្រជារាស្ត្រមានកម្លាំងឡើងជាប្តីដោយនឹកទៅដល់ព្រះសាក្យមុនីបរមសម្ពុទ្ធជាម្ចាស់ ព្រះបរមនាមនឹងពុទ្ធោវាទតែងស្ថិតនៅស្ថានទីដ៏ជាកិត្តិយសកងឯហទយវត្តុនជាតិឥណ្ឌាតំាងអស់គ្នា ។ កាលបុណ្យសម្ពោធនៃសាធារណៈវង្កវត្ត នៅសកានៃទីក្រុងណៃវដែល្លី គេបានឃើញព្រះពុទ្ធរូបមួយ ដែលគេយកមកពីមជ្ឈិមមណ្ឌលពុទ្ធសាសនានៅក្រងមថុរៈ ។ ព្រះពុទ្ធរូបនេះគេយកមកស្ថាបនា នៅកងកណ្តាលល្វែងពិធី ជាហេតុឲ្យយល់ជាក់ច្បាស់នូវបំណងប្រជាជននៅទីនោះ ។ ហេតុតំាងនេះបញ្ជាក់ឲ្យឃើញថា មានការប្រែប្រួលអាកប្បកិរិយា ហើយនឹងជាបុព្វណ្ហសម័យថ្មីចំពោះប្រជាការនៃប្រទេសឥណ្ឌា ។ កងពិធីនោះដល់កំងនបើកហើយ មានរស្មីពណ៌ដូចមាស ចោលទៅព្រះពុទ្ធរូបនោះ

ដូចព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មនៅពិត ។ យកព្រះហស្តត្រជាងត្រៃពាជ-
ទានពរសព្វសាធុការ ចំពោះអ្នកដែលមកបូរម្រះដុំនៅកងបន្ទប់ធំទូលាយ
នេះ ធ្វើឲ្យពួកនេះក្រោកឡើងមួយរំពេច សំដែងអាការគោរពដោយ
ស្ងប់ស្ងាត់ ។ គឺប្បាប់រចនាគំរូសត្វសង្ឃព្រះបាទអសោក, ព្រះអធិពាជ
ដែលទ្រង់និយមព្រះពុទ្ធសាសនានោះឯង ដែលរដ្ឋាភិបាលថ្មីប្រែកបដោយ
សេរីភាព នៃប្រទេសឥណ្ឌៀបានយកមកធ្វើជាត្រា ។ ទង់ជាតិនៃ
ប្រទេសឥណ្ឌៀ បានត្រជាងអក្សរធម្មចក្ក: ជាបដិមារូបសម្រាប់
ប្រជាជាតិ ហើយនៅសភាខាងលើមុខព្រះរាមន្ទីរប្រធាន មានចារឹកអក្សរ
ដែលជាបឋមពុទ្ធោវាទ ។ បឋមពុទ្ធោវាទនេះ រដ្ឋាភិបាលបានយកមក
អនុវត្តន៍ទុកជាប្បាវចនា ។

ព្រឹត្តិការណ៍ទាំងនេះ . មិនត្រូវគិតថាត្រឹមតែវត្តពីរយ៉ាងមកជួបប៉ះ
ប្រទះគ្នាទេ គឺជាប្រផ្លែកង្វក់ការប្រែប្រួលសម្បើមអស្ចារ្យចំពោះជោគវាស-
នានៃប្រទេសឥណ្ឌៀ ដោយហេតុថា ក្នុងបច្ចុប្បន្នកាល ប្រទេសនេះ
រៀបប្រុងប្រៀបនឹងធ្វើជាមគ្គុទ្ទេសក៍បង្ហាញ នូវវិជ្ជាខាងសាសនានឹង
វប្បធម៌ ចំពោះប្រជាជាតិអាស៊ី, ពីអតីតកាល ប្រទេសនេះជាអារ្យ-
ប្រទេសនៃពិភពលោក បានផ្តល់នូវវិជ្ជាទាំងឡាយ ទៅប្រទេសជិតខាង
មានបេសកកម្មទូតខាងព្រះពុទ្ធសាសនា បានចេញពីប្រទេសនេះខាងផ្លូវ
ដើងគោកនឹងដើងទឹក នាំព្រះបរមពុទ្ធោវាទយកទៅផ្សាយនៅនានា
ប្រទេសគ្រប់ភន្លែង ។ ក្នុងពេលនោះ ចំណែកខាងសិល្បកម្មក៏បម្រើន

ដូចគ្នាហើតដល់ថ្ងៃដែលវប្បធម៌ ខាងពុទ្ធសាសនាបានចូលទៅស្ថិតនៅ
ដូចអំបោះមាសមួយសរសៃវែញចញលទៅក្នុងស៊ីវិលីហ្សេទ្វីបអាស៊ី ។ នៅទី
ប្រជុំដែលមានសុទ្ធតែវិញ្ញាជននៃប្រទេសឥណ្ឌា ហើយបានឮគេពោលពី
ពីបេសកកម្មនៃព្រះសម្មាសម្ពុទ្ធ តាំងពីថ្ងៃនេះតទៅ មានផែនការណ៍ជា
យ៉ាងសំខាន់កំពុងប្រឹងប្រែបដើម្បីនឹងធ្វើឲ្យកើតមានឡើងជាថ្មី នូវការ
សិក្សាត្រមាំងស្ថាប័ននៃព្រះពុទ្ធសាសនាឲ្យដូចជាកត្តាខុភាព នៃមហា
វិទ្យាល័យនាលន្ទៈដែលមានល្បីល្បាញពីអតីតកាល ។

ប្រទេសចិនគិស្តង់ ដែលស្ថិតនៅជិតប្រទេសឥណ្ឌានិយមកាន់
សាសនាអិស្លាមជាសាសនារបស់រដ្ឋ តែត្រូវឲ្យធ្លាប់ពន់ពេកណាស់ នៅ
ទីនោះមានប្រាសាទបុរាណខាងព្រះពុទ្ធសាសនា ទឹងប្រជាជាតិជារាប់ច្រើន
ជាពុទ្ធសាសនិកជន, ដូចមានសំអាងនូវការខ្នះខ្នែងទឹងសកាពសាទរយ៉ាង
ម៉ាំមួនចំពោះការសិក្សាព្រះពុទ្ធសាសនាមានល្បឿនទៅខាងមុខ ។ ព្រោះ
ហេតុនោះ បានជាប្រទេសនេះឲ្យប្រាក់ជំនួយសម្រាប់សន្ទិសិទ ហើយ
មានការសាងនូវបូជនីយដ្ឋានខាងព្រះពុទ្ធសាសនាជារាប់ច្រើន ។

ឱ្យមានចារិកប្រទេសឥណ្ឌា ទឹងប្រទេសចិនគិស្តង់ ជាពិសេស,
ព្រោះឱ្យចង់សំគាល់ពុកប្រទេសនេះជាទិដ្ឋានុគតិ ដ៏ប្រសើរខាងអាកប្ប-
កិរិយាប្រកបដោយសេចក្តីក្លាស្វាងរុងរឿង ដែលរដ្ឋាភិបាលបានបំពេញ
ចំពោះសាសនាមួយ ដែលមានមតិភាគតិចទៅទីនេះ តែមិនមែនដូច
នោះទេ បើទុកជាមានព្រះមហាក្សត្រ ទឹងព្រះអធិការខ្ពស់ខ្ពស់ទូ

សាសនានេះក៏ដោយ ក៏សាសនានេះ មិនដែលប្រើវិធីហួសប្រមាណនោះសោះឡើយ ។

គុណប្រការនៃព្រះពុទ្ធសាសនា

បើគាលណា ខ្ញុំត្រូវគិតពីរឿងនេះ ខ្ញុំតែងមានមនោសញ្ចេតនាថា ដោយហេតុមានកម្មល្អនៃពុទ្ធសាសនិកជនពាំងនេះ ឬសាសនានេះមិនដែលធ្លើសេចក្តីអាក្រក់ទៅកាន់ជនដទៃ ចានជាកុងរយៈពេលនេះមានផលដ៏ល្អប្រមូលមកកាន់ពីនេះ ។ ក្នុងរយៈវេលាប្រាំ ឬប្រាំមួយសតវត្សមកហើយ ពិភពលោកតែងអន់ថយចុះតាមលំដាប់ ក្នុងពេលដែលដួបប្រទេសពាំងប៉ុន្មាន ព្រមទាំងប្រជាកសិកាំងអស់ស្ថិតនៅទីនៃ។ ឆ្ងាយពីគ្នាចានចូលមកប្រសើយជិតស្និទ្ធ ដោយហេតុមកពីការស្រាវជ្រាវរកយើញនៅក្បួនវិទ្យាសាស្ត្រ ។ ក្នុងពេលនុកាសនេះ យើងចានទទួលនូវសេចក្តីវុឌ្ឍលំចាក ដោយយើងចានទទួលនៅសេចក្តីមិនសន្តោស ដែលកើតឡើងមកពីកិច្ចណែនាំឲ្យអ្នកជនៃចូលមកក្នុងសាសនារបស់ខ្លួន ។ នៅប្រទេសជប៉ុន, យើងចានឃើញជាក់ក្នុងរយៈវេលាគ្រាយនេះ មានការពិសោធន៍ ដែលកើតឡើងដោយប្រើសិទ្ធិហួសប្រមាណ ដើម្បីនឹងផ្ទាស់ប្តូរនូវសាសនាដែលមានមកប្រើនសតវត្ស ទៅនឹងសាសនាមួយថ្មី ។ អនុស្សាវរីយ៍នៃការពិសោធន៍នោះមិនចានជាមានសភាពស្រួលទេ ហើយការទទួលខុសត្រូវធ្ងាក់នៅលើអ្នកជនក នៃសាសនានេះ ។

(មានត)

បញ្ជីរាយនាមថៅអធិការដែលតាំងដ្ឋឹ

របស់ក្រសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៨៦៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុយ - ថរ នាមឆាយា ថនសុវ័ណ្ណ កើតឆ្នាំម្សាញ់ អាយុ ២១ វស្សា ២ ជាគ្រូសូត្រស្តាំ វត្ត - ឃុំ - ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៦៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ លាក់ - ចៀង នាមឆាយា ចៀងសុវ័ណ្ណ កើតឆ្នាំម្សាញ់ អាយុ ២៦ វស្សា ២ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៦៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កែ - ប៉ាត នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំច អាយុ ៤០ វស្សា ១៩ ជាគ្រូសូត្រស្តាំវត្តព្រះមូ ឃុំ - ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៦៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់ សាគំ នាមឆាយា និលបញ្ញា កើតឆ្នាំថោះ អាយុ ៣៩ វស្សា ១៦ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៦៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាប ខ្លូន នាមឆាយា និលជោត កើតឆ្នាំមមែ អាយុ ៦៧ វស្សា ២៦ ជាគ្រូសូត្រស្តាំ វត្តជ្រៃ ឃុំ - ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៦៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សម-ទឹម នាមឆាយា នាគគីរី កើតឆ្នាំថោះ អាយុ ២៣ វស្សា ៣ ជាគ្រូ សូត្រធ្លេង វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៧០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ខ្វក-ស៊ុយ នាមឆាយា ទិលជោត កើតឆ្នាំមមែ អាយុ ៣១ វស្សា ១១ ជាគ្រូសូត្រស្តាំ វត្តទួលលៀប-ឃុំស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៧១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស-សួន នាមឆាយា សុវណ្ណជោត កើតឆ្នាំថោះ អាយុ ២៣ វស្សា ៣ ជាគ្រូសូត្រធ្លេង វត្ត ឃុំ-ស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៧២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អួង-សាត នាមឆាយា សាគសរ កើតឆ្នាំកេង អាយុ ២២ វស្សា ៣ ជាគ្រូ សូត្រស្តាំ វត្តក្តាត ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៧៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ យស់-ជិម នាមឆាយា ជិមសាពេ កើតឆ្នាំកេង អាយុ ២២ វស្សា ២ ជាគ្រូ សូត្រធ្លេង វត្ត-ឃុំ-ស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៧៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-គុប នាមឆាយា សុជម្ពូវ កើតឆ្នាំមមី អាយុ ៤២ វស្សា ២៧ ជាចៅអធិការ វត្តបឹងកណ្តាល ឃុំ ស្រុក-ខែត្រដដែល ។

ភ្នំពេញសន្ទេយ៍

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៥ ខែមេសា លេខ ៤

ព. ស. ២៤៩៥ _ គ. ស. ១៩៥៣



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— អត្ថបទមកថា	ព្រះមហាឧ- ឧបាច	២៤៤
— កថិនកថា (តមក)	ព្រះមហាឧត្តមវិជ្ជាកែ - អឿន ...	២៥១
— សេចក្តីល្អ - សេចក្តីអាក្រក់	លោក ស៊ិន - ហ៊ាន	២៥៩
ផ្នែកអក្សរសាស្ត្រ		
— ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៊ម ...	២៦៥
— រឿងសាមកុក (តមក)	ឧកញ៉ា ឆ្វ - កន	២៧១
— រឿងអាវ៉ក្សថ្លែងរឿងម្តែប្រាំ (តមក) ...	លោក វ៉ុយ - ប៊ុក	២៧៦
— រឿងស្ងាប់ព្រោះជាតិ (តមក)	លោក គង់ — លឹម	២៨៥
— រឿងប៉ូលនឹងវីរ៉ស៊ីនី (តមក)	លោក ផេង - ជ្រើរ	២៩០
កំណត់ទឹងប្រវត្តិការណ៍		
—សន្និសិទព្រះពោធិវង្ស ហួត - ពាត អំពី សមាជសាកលលើកទី ២ នៃពុទ្ធសាសនា	(តមក) ពុទ្ធសាសនបណ្ឌិត្យ ...	២៩៥
—សុន្ទរកថាបណ្ឌិតម៉ាល៉ាឡ៉ៈសេកេរៈថ្លែងក្នុង សមាជសាកលលើកទី ២ នៃពុទ្ធសាសនា	(តមក) ពុទ្ធសាសនបណ្ឌិត្យ ...	៣០១
— ពិធីប្រឡងធម្មវិន័យ នៅវត្តព្រះព្រហ្មរតន៍ ខែត្រសៀមរាប	ព្រះមហាឧត្តមវិជ្ជា កែ-អឿន ...	៣០៦
—បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី(តមក)	ក្រសួងធម្មការ	៣១៨

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៨២រ. ០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

		Pages
PARTIE RELIGIEUSE		
— Attapemakatha	*Brah Maha LE-LACH*	244
— Kathinakatha.....	*Brah Maha Ker-œurn*	251
— Bonne action - mauvaise action	*M. SIN-HEAN*	259
PARTIE LITTERAIRE		
— Education morale (suite)....	*Vén. Pœung-Pam*	265
— Histoire de SAMŖOK (suite)..	*Oknha Nou-Kan*	271
— Les vingt cinq récits du Mauvais Génie (suite)	*M. Ray-Buc*	276
— Mort pour la patrie (suite) ...	*M. Kong-Lim*	285
— Paul et virginie (suite)	*M. Phéng-Chrieu*	290
NOTES ET CHRONIQUES		
— Conférence du Vén. Brah Bodhivangs HUOT-TATH sur le 2e Congrés Mondial Bouddhique (suite)	*Institut Bouddhique*	295
— Discours du Dr MALALASEKERA au 2e Congrés Mondial Bouddhique	— —	301
— Cérémonie d'examen du Dhammavinaya à la pagode de Brah Brahmaratana-Siemreap.....	*Brah moha KER-ŒURN* ...	306
— Nomination des nouveaux Chau-adhikar suite	*Ministère des Cultes*	319

Prix d'abonnement annuel comprenant 12 numéros : 192$00

ស័ព្ទសាធុការពរឆ្នាំថ្មី

ព. ស. ២៤៨៦

ឆ្នាំម្សាញ់ បញ្ចស័កស័ក្តិពិសី ព. ស. សោតថ្មីពីរពាន់បួន
រយទឹងកៅសិបប្រាំមួយឆ្នូន សន្ធ្រាន្តខែរបួនចរចូលឋាន ។
ក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រសិទ្ធិពរថ្វាយ - ជូនសព្វឋាន
ដល់ជាតិសាស្នាមហាក្សត្រកម្ពុជ រដ្ឋខែរឲ្យបានក្តីសុខា ៖
សូមព្រះភូមិន្ទបវរក្សត្រ សោយរាជសម្បត្តិខ្ពាត់សោភា !
សូមក្រុមព្រះពជញ្ញាតិវង្ស មានមហេសក្ខាលាភជ័យជោគ ! ។
សូមក្រុមព្រះសង្ឃទ្រទ្រង់សីលសុទ្ធ និរទុក្ខចាកផុតភ័យកង្វល់លោក !
សូមមានសាមគ្គីកុំបីស្ងួត ប្រយោគព្យាយាមលះកតបី ! ។
សូមព្រះពជរជ្ជាភិបាល ធ្វើស្រាលកង្វល់កលអប្រិយ
បំពេញកិច្ចការគតផែនដី ឲ្យមានសេរីក្តីសាន្តត្រាណ ! ។
សូមក្រុមនាហ៊ុនគ្រប់គ្រងដ្ឋឋ ធំតួចតាំងពួងអម្ចាលម៉ាន
ជានសុខចំរើនគ្រប់ ។ ប្រាណ ស្មោះស្មានបំរើកម្ពុជា ! ។
សូមអស់បណ្តាពស្តេរមជាតិ របួតផុតឃ្លាតទុក្ខវេទនា
រីកចម្រើនសប្បាយពេញភាព គ្រោមម្ចាស់ជាវង្សវ័ន ! ។

ព្រះមហាវេ្ស-ទ្បាប វត្តដួងមុនីវាម ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្វនៃប្រទេសកម្ពុជា កាលពីថ្ងៃ ៨ កើត ខែបុស្ស ឆ្នាំជូតសំរឹទ្ធិស័ក ព. ស. ២៤៩១ (គ.-១-៤៩)

ឥមោ តសេ្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ខ្ញុំព្រះករុណាសូមលើកកំបង់អញ្ជលីប្រណម្យ ចំពោះព្រះត្រៃរតន៍ដែលមានគុណធ្វើកដដល់សត្វកន្លងត្រៃគតិ ដោយសេចក្តីគោរពជាសន្ធេបតែប៉ុណ្ណេះ ។

លំដាប់តពីបទនមស្សការនេះទៅ អាត្មាភាពនឹងដកស្រង់ព្រះពុទ្ធដីកាមួយកន្ទែង ដែលមានកន្លងគម្ពីរធម្មបទខុទ្ទកនិកាយ យកមកសំដែងដើម្បីថ្វាយដល់ទ្រង់ នឹងអស់លោក-អ្នកសាធុសប្បុរសទាំងឡាយ ដែលជាអ្នកទទួលមតិកតីពុទ្ធនុវាទ តុហាតពត់តម្រង់កាយវាចាចិត្តឲ្យបានសុភត្រង់ ជាគ្រឿងក្រែបជញ្ជក់យកនូវរសទាំងឡាយ មានអម្រឹតរសជាទីបំផុត ។ ព្រះពុទ្ធដីកានោះគឺ

អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ
តិណ្ណមញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ

ប្រែថា "បើបណ្ឌិតដឹងខ្លួនថា ខ្លួនជាទីស្រឡាញ់របស់ខ្លួនហើយ ក៏គប្បីរក្សាខ្លួនឲ្យល្អ គួរតំនុកបម្រុងខ្លួនក្នុងវ័យទាំងបី វ័យណាមួយកុំខានឡើយ" ។

ពាក្យថាខ្លួនកង៏ពុទ្ធកាសិតនេះបានដល់ធម្មជាតិពីរយ៉ាង៏ គឺកាយ ๑ ចិត្ត ๑ ធ្យូបញ្ចូលជាមួយគ្នាហៅថាខ្លួន ។ ពួកមហាជនដែលបានកើតមកក្នុង៏សកលលោកសុទ្ធតែស្រឡាញ់ខ្លួនជាង៏អ្នកជវៃប្តូវតួជវៃ សូម្បីមាសពេជ្រដែលគេនិយមថាជារបស់ប្រសើរបំផុត ក៏នៅតែមិនស្រឡាញ់ជាង៏ខ្លួនប្តូស្មើនឹង៏ខ្លួន, សមដូចពុទ្ធកាសិតកង៏គម្ពីរសំយុត្តនិកាយថា ឆត្តិ អត្តសមំ បេមំ "ស្រឡាញ់អ្វីស្មើនឹង៏ខ្លួនឬជាង៏ខ្លួនគ្មានឡើយ" ។ ដ្បិតថាពួកមហាជនដែលចំរេកទួលទាន ដោយកសិកម្មនឹង៏ពាណិជ្ជកម្ម មិនគិតដល់សេចក្តីលំបាកនឹង៏ការហាលថ្ងៃហាលភ្លៀង ឬក៏ពួកត្រួមនាម៉ឺនតួចធំ ដែលចំធ្វើការពេជការកង៏មន្ទីរផ្សេង។ ដោយចង់បានប្រាក់បៀវត្ស ក៏ព្រោះតែស្រឡាញ់ខ្លួន កុំថាឡើយតែមនុស្សដែលមានអាយុវែងគ្រប់គ្រាន់ ដោយហោចទៅសូម្បីតែមនុស្សដែលអន្ទាការមានខ្លាក់ខ្ញីនក្មេង៏ក្មង់ជាដើម ក៏នៅតែស្រឡាញ់ខ្លួនឯង៏ជាង៏អ្នកជវៃ ឬវត្តជវៃដែរ ។

បើបណ្ឌិតដឹង៏ខ្លួនថាជាទីស្រឡាញ់ហើយ គួរតែរក្សាខ្លួនទុកឲ្យល្អ ។ ឯការរក្សានោះមានពីរយ៉ាង៏គឺ រក្សាខ្លួនឲ្យជាប្រយោជន៏កង៏លោកនេះ ๑ កង៏លោកខាង៏មុខ ๑ ។

๑ – ការដែលសង៏គេហស្ថាន មានប្រាសាទច្រាំពីរជាន់ជាដើម សម្រាប់ដែកអាស្រ័យនៅកង៏លោកសន្ធិភសនេះ ដែលជាគ្រឿង៏ការពារនូវមួសសុច នឹង៏ខ្យល់ថ្ងៃភ្លៀង ឬក៏រកថ្នាំសម្រាប់បំបាត់រោគដែលកើត

ឡើងក្នុងសរីរៈរាងកាយរបស់យើង ដូចជាអ្នកខ្វះហាននាយច្រក់អស់រាប់ពាន់រាប់មុឺន ឬ ជួលគ្រូពេទ្យមកឲ្យជួយព្យាបាលរោគ ក៏ព្រោះប្រយោជន៍ចំពោះខ្លួនរបស់គេ ។ ប៉ុន្តែការរក្សានេះជាសេចក្តីរក្សាយ៉ាងតូចបានសេចក្តីសុខចំពោះបុគ្គលម្នាក់ៗ បើរក្សាឲ្យធំទូលាយទៅទៀត បានដល់ការរក្សាពួកគ្រួសញាតិមិត្តសំឡាញ់ ឬក៏ពួតផ្ចុងរួមគំនិតជាមួយគ្នាជួយរក្សាការពារទំនុកបំរុងប្រទេសជាតិមាតុភូមិរបស់ខ្លួន ឲ្យឡើងទៅកាន់ជាអារ្យៈប្រទេស ដូចជាប្រទេសគេជិតខាង ឈ្មោះថារក្សាយ៉ាងធំបំផុតចំពោះខ្លួនឯងផង ផ្សាយសេចក្តីសុខដល់អនុបុរសជារៀនតទៅក្នុងអនាគតផង ។ សេចក្តីដែលបានពណ៌នាមកខាងលើទាំងប៉ុន្មាននេះសុទ្ធតែជាការរក្សាសេចក្តីសុខក្នុងលោកនេះទាំងអស់ ។

๒- បុគ្គលដែលចំដុះខាត់កំចាត់បង់នូវមន្ទិលគឺកិលេស ដែលជាគ្រឿងរួបរឹតធ្វើចិត្តសត្វឲ្យសៅហ្មង ជាចំណងធ្វើបុគ្គលឲ្យវិលវល់ក្នុងកងទាំងបី ទាំងទុស្សាហ៍ធ្វើបុណ្យ មានការរក្សាសីល ៥ សីល ៨ ដើម្បីបន្ធូរបន្ថយនូវកិលេសយ៉ាងគ្រោតគ្រាត ជាហេតុរក្សាខ្លួនមិនឲ្យធ្លាក់ចុះទៅក្នុងអបាយភូមិមាននរកជែ្រតជាដើម នេះជាបដិបទាប៉ែកខាងគ្រហស្ថ ។ បើប៉ែកខាងបព្វជិតវិញត្រូវរក្សាការពារកិរិយាមារយាទរបស់ខ្លួន ឲ្យសមរម្យតាមសមណភេទ គឺមានតន្ត្រីយសំវរៈក្នុងវេលាជែ្រតរិយាបថទាំង ๔ សមគួរតាមវិន័យបញ្ញត្តិ ព្រោះថាអ្នកបួសមិនត្រូវ

ប្រព្រឹត្តល្មើសនឹងព្រះវិន័យទេ ដ្បិតថាព្រះវិន័យជាពស្តុតាងរបស់អ្នកបួស បើអ្នកបួសគ្មានវិន័យជាវត្ថុប្រតិបត្តិ មុខជាក្លាយចិត្តពីអ្នកបួសឥតមានសង្ស័យឡើយ ម្ល៉ោះហើយទាយកទាយិកា អ្នកថ្វាយទូរបុណ្យកុសលសំគាល់តែគេខ្លួនថាជាអ្នកបួសពិត ចំលេះបង់នូវទ្រព្យសម្បត្តិ ដែលគេរកបានមកដោយសេចក្តីនឿយហត់ យល់ជាក់កង់ចិត្តថាជាបុញ្ញក្ខេត្តនឹងមានផលប្រយោជន៍តទៅខាងមុខ តែឯប់ទៅជាគ្មានផលប្រយោជន៍ដូចជាគេយកទៅចាក់ចោលក្នុងទឹកទន្លេវិញ ។ សេចក្តីសន្មែបដែលបានពោលមកខាងលើនេះជាអំពើអាក្រក់ បពូជតមិនត្រូវសន្សំទុកទេ ។ កាលបើអ្នកបួសប្រព្រឹត្តតាមព្រះវិន័យហើយ ឈ្មោះថាជាកុលបុត្រអ្នកទ្រទ្រង់ព្រះពុទ្ធសាសនា ធ្វើព្រះពុទ្ធសាសនា ឲ្យមានពន្លឺរុងរឿងបិតថេរចេរកាលជាបដល់គ្រប់ចុំពាន់ព្រះវស្សា នឹងជាទុំបាយអាចរក្សាខ្លួនមិនឲ្យធ្លាក់ទៅកាន់កំណើតដ៏ថោកទាប មានកំណើតតិរច្ឆានជាដើមរមែងបានសោយសេចក្តីសុខ តង់ហានសួគ៌និងព្រះនិព្វានជាទីបំផុតជាតិ ។ សេចក្តីទាំងប៉ុន្មាននេះ សុទ្ធតែជាការរក្សាខ្លួនក្នុងលោកខាងមុខ ។

ម្យ៉ាងទៀត គួរទំនុកបំរុងខ្លួនទុកក្នុងវ័យទាំងបី វ័យណាមួយកុំខានឡើយ ។ ឯការទំនុកបម្រុងខ្លួននោះមានពីរយ៉ាង គឺទំនុកបំរុងខ្លួនសម្រាប់លោកនេះ ១ សម្រាប់លោកខាងមុខ ១ ។

១ - កាលដែលយើងនៅក្នុងបឋមវ័យ គឺរាប់តាំងពីអាយុ ១ ឆ្នាំ ដរាបដល់អាយុ ៣៣ ឆ្នាំ ត្រូវខំសិក្សារៀនសូត្រលេខនព្វន្តអក្សរសាស្ត្រ

សម្រាប់ជាតិរបស់ខ្លួន នឹងអក្សរសាស្ត្ររបស់ជាតិដទៃ ឲ្យសមតាម
កាលសម័យ ។ ព្រោះថាមនុស្សយើង ដែលបានកើតមកក្នុងលោកមិន
ត្រូវធ្វើជាអ្នកល្ងង់ខ្លៅរកដម្រែវិជ្ជាគ្មានទេ ។ ការដែលគ្មានដម្រែវិជ្ជានេះ
ជាហេតុធ្វើខ្លួនមិនឲ្យមានពន្លឺរស្មី ទាំងគិតអ្វីមិនសម្រេចដូចសេចក្តី
ប្រាថ្នា ។ ធម្មតាមនុស្សល្ងង់តែងធ្វើខ្លួនឲ្យបានទទួលវេទនាឥតមាន
ចន្លោះ បានជាពោលដូច្នេះព្រោះមនុស្សល្ងង់មិនដែលបានធ្វើធំទេ មុខ
ជានឹងនៅជាទាសគេអស់មួយជីវិតមិនខាន នេះមិនមកពីអ្វីទេ មកតែពី
ខ្វះការសិក្សារៀនសូត្រក្នុងសម័យដែលខ្លួនត្រូវរៀនសូត្រ ចុះបើយើងជា
អ្នកចំយកចិត្តទុកដាក់ក្នុងកិច្ចសិក្សារៀនសូត្រនូវដម្រែវិជ្ជាផ្សេង ។ ឲ្យ
សមតាមរយៈកាលសម័យដែលលោកនិយម មុខជាបានជួបប្រទះនូវផល
ប្រយោជន៍អ្វីមួយមិនខាន ហើយនឹងបានទទួលយកនូវផលសន្តិសុខតទៅ
ខាងមុខ បើមិនបានធ្វើនាំមុនតូចធំនឹងគេ ក៏គង់ប្រកបកិច្ចការចិញ្ចឹមជីវិត
ដោយតម្រេះនោះ។ ដោយប្រពៃ រាមដងមិនផ្អាក់ខ្លួនទៅជាមនុស្សបម្រើ
គេដែរ ។

នែយុវជនកុមារកុមារីទាំងឡាយ! ត្រូវគ្រោកឡើង ចូរខំស្វះស្វែង
រៀនសូត្រឲ្យមែនទែន ពាន់សម័យដែលខ្លួនអ្នកនៅក្មេង ព្រោះការរៀន
នេះបានតែខ្លួនអ្នកកំពុងមានវ័យចម្រើន មានសតិស្មារតីដ៏ក្រៀវក្លា អាច
រៀនទន្ទេញអ្វីៗបាប់ចាំមិនសូវក្ងេច ។ បើចាំដល់មជ្ឈិមវ័យបច្ឆិមវ័យ ដែល

យើងមានវ័យជាកណ្តាលនឹងចុងក្រោយបំផុតហើយ មិនដាយនឹងខ្លែងនូវអំពើនេះបានទេ មុខជាដេកសញ្ជប់សញ្ជឹងសោកស្តាយដល់កិច្ចការនោះមិនលែងឡើយ ។ បើយុវជនក្មេងប្រុសស្រីទាំងអស់គ្នា ឃើញសេចក្តីចំរើននឹងសេចក្តីវិនាសដូចពោលមកខាងលើនេះហើយ គួរតែអ្នកចំលះបង់នូវគំនិតវិលៗចូននឹងសេចក្តីរិលច្រអូសចោលចេញ ហើយខំសេចក្តីព្យាយាមខំប្រឹងរៀនសូត្រ ទើបចាត់ថាជាអ្នកចេះដំនុកបម្រុងខ្លួនក្នុងលោកនេះ ។

២- ការដែលដំនុកបម្រុងខ្លួនប្រុងក្នុងលោកខាងមុខនោះ គឺយើងត្រូវប្រើបញ្ញាធ្លុះបញ្ចាំងមើលអត្តភាពកាយនៃអាត្មា ឲ្យឃើញជាក់ច្បាស់ក្នុងចិត្តថា បញ្ចក្ខន្ធរបស់សត្វទាំងអស់ តែងមានសភាវៈប្រែប្រួលជានិច្ច ព្រោះសត្វដែលបានកើតមកក្នុងលោកទាំងអស់គ្នា រមែងជ្រាក់ចុះទៅក្នុងអនិច្ចំ ទុក្ខំ អនត្តា មានរូបពេលណា សុទ្ធតែជារបស់មិនទៀងទាំងអស់ តែងបានទទួលសោយនូវសេចក្តីលំបាកកាយលំបាកចិត្តជាសភាវៈមិនបិតក្នុងអំណាចរបស់ខ្លួន បើយើងឃើញដូច្នេះហើយ គួរខំព្យាយាមដុតបំផ្លាញនូវសេចក្តីអាក្រក់ទាំងប៉ុន្មានដែលមានក្នុងខ្លួនសន្តានកុំឲ្យកើតមានឡើង ហើយទសព្វហ៌បំពេញនូវកុសលចរិយាជាទុច្ចរិតឲ្យបរិសុទ្ធ ផុតចាកសេចក្តីសៅហ្មង ពោលគឺអកុសលធម៌ ។ កាលបើចិត្តយើងបរិសុទ្ធហើយ រមែងមិនមានវិប្បដិសារី គឺមិនមាន

សេចក្តីក្តៅក្រហាយ ដោយឧបសគ្គន្តរាយផ្សេងៗ មានតែសេចក្តីសុខ សប្បាយរីករាយជានិច្ចសព្វកាលទាំងពួង, ទើងជាគុណជាតិដ៏សំខាន់បំផុត សម្រាប់ស្ងួយអត្តភាពរាងកាយរបស់យើង មិនឲ្យក្លាយទៅជាន់កំណើតដ៏ថោកទាប មានកំណើតតិរច្ឆានជាប្រធាន ព្រោះយើងទាំងអស់គ្នា សុទ្ធតែជាអ្នកស្អប់ខ្ពើមកំណើតថោកទាបនោះស្រែពេក មិនដែលនរណាមួយប្រាថ្នាទូវកំណើតនោះសោះឡើយ ។

បើនរជនណា បានលះបង់នូវសេចក្តីអាក្រក់ ហើយទំបំពេញនូវសេចក្តីល្អបរិសុទ្ធិ ដូចបានសំដែងមកនេះ ឈ្មោះថាជាអ្នកទំនុកបម្រុងខ្លួនទុកក្នុងលោកខាងមុខ ។

សំដែងមកក្នុងការស្រឡាញ់ខ្លួនទើងសេចក្តីថែរក្សាខ្លួន ព្រមទាំងការទំនុកបម្រុងខ្លួន ក៏អស់សេចក្តីតែប៉ុណ្ណេះ ។

ទុក្ខប្បត្តា ប ទិទុក្ខា ភយប្បត្តា ប ទិព្ភយា
សោកប្បត្តា ប ទិសោកា ហោន្តុ សព្វេបិ បាណិនោ

ដោយអំណាចនៃធម្មទេសនានេះ សូមផ្សាយមេត្តាចិត្ត ដល់ជនទាំងឡាយទាំងពួងក្នុងលោកទាំងមូល បើសត្វបុគ្គលឯណាដល់ហើយនៅសេចក្តីទុក្ខ សូមឲ្យជាអ្នកចាត់ទុក្ខទៅ ! ដែលដល់ហើយនូវភ័យសូមឲ្យជាអ្នកចាត់ភ័យទៅ ! ដែលដល់ហើយនូវសេចក្តីសោក សូមឲ្យជាអ្នកចាត់សេចក្តីសោកទៅ ! ។

កថាបឋមកថា

រៀបរៀងទេសនាបុព្វបទ - វិសជ្ជនា

ព្រះមហាឧត្តរវិជ្ជា កែ - អឿន រ៉ីរិយប្បញ្ញោ

វត្តព្រះពុទ្ធាវតន៍ ខែត្តសៀមរាប រៀបរៀង

ព្រះទេពសត្ថាស្សរ - ហាយ ពិនិត្យកែសម្រួល

(តមក)

ឧភោតស្សរ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ឧបត្ថម្ភនត្ថាយ ស្ស

សូមនមស្ការចំពោះបដិ ៣ នៃព្រះរតនៈ គឺព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ ដោយសេចក្តីគោរព ។

ឥមិនាបិ បណាមេន សទា សោត្ថី ភវន្តុ នោ

ដោយកិរិយាប្រណម្យថ្វាយបង្គំ ចំពោះគុណព្រះរតនត្រ័យនេះឯង សូមសិរីសួស្តីចំរើនដល់ពុទ្ធបរិស័ទទាំងឡាយ ឲ្យបានសព្វ ។ កាលរៀងទៅ កុំបីឃ្លៀងឃ្លាតឡើយ ។

ឥតោ បរំ តអំពីបទនមស្ការនេះទៅ នឹងបានសំដែងព្រះសទ្ធម្ម-វិសេសទេសនា ជារបៀបបុព្វបទ - វិសជ្ជនា អំពីកឋិនទាន ព្រមទាំងអានិសង្សនៃកឋិនទាន; តែមុននឹងសំដែងនេះ សូមសន្មតតំ ណាមទៅរិញទៅមកសិន ចំណែកអាត្មាភាពខាងណោះ គួរបាននាមថាជា

"មហាថេរៈ" ដោយមានវស្សាច្រើនជាង, ចំណែកលោកម្ចាស់ខាងណោះគួរបានឈ្មោះជា "អនុត្តេរៈ" ដោយមានវស្សាតិចជាងអាត្មាភាព ។

អនុត្តេរៈ: ម្នាលអនុត្តេរ! សូមលោកម្ចាស់ធ្វើដ៏ស្មារតីផ្សៀងសោតប្រសាទចាំស្តាប់ខ្ញុំនឹងបុច្ឆាសួរកងកាលឥឡូវនេះ ។

๑.- ម្នាលអនុត្តេរ! អ្វីដែលហៅថា កឋិន? សូមនិមន្តវិសជ្ជនាមកមើល ។

កន្តេ មហាថេរៈ: បពិត្រមហាថេរដ៏ចំរើន! ដំណើរការណ៍ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងបញ្ញត្តរបៀបមន្ទីរបៀបធម៌ នឹងនាមធម៌ពាក់ព័ន្ធឡាយបានឈ្មោះថា កឋិន, នឹងបានឈ្មោះថា កឋិន ដោយបរមត្ថធម៌ក៏ទេ, ពាក្យថា កឋិន ជាធម៌ឯកដោយវិសេសប្លែកជាងធាតុធាម្មតា ហៅថា កឋិន, សូមទានជ្រាប ។

๒.- សាធុ សាធុ ម្នាលអនុត្តេរ! ចុះកឋិន - សព្ទនេះ បើប្រែតាមធាតុ បានសេចក្តីដូចម្តេច? បើប្រែតាមអត្ថជាដូចម្តេច? សូមនិមន្តប្រែមកហើយអធិប្បាយឲ្យល្មមខ្ញុំស្តាប់បានផងមើល ។

- បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណានឹងប្រែតាមធាតុ រួចប្រែតាមអត្ថ តោះបើល្មមស្តាប់បានឬតុំបានតោះមិនអាចជានាទេ ។ កឋិន សព្ទនេះ បើប្រែតាមធាតុ អដ្ឋកថាថ្លែងថា ធាតុដើមជា "កថ" ប្រព្រឹត្តទៅកងអត្ថពីរយ៉ាង ថា "កិរិយារស់នៅដោយក្រ" ๑ ថា "កិរិយាពោល

សរសើរ" ๑; ឯអត្ថថា "រស់នៅដោយគ្រែ" នោះ ដូចឈើស្នឹងដែលបុគ្គលកាត់យកឈើស្រស់មកចុះធ្វើជាស្នឹង ឯឈើស្នឹងនោះរស់ដុះលូតលាស់ឡើងបានដោយគ្រែតែក មានសេចក្តីឧបមាយ៉ាងណា ឯកបិនគាន ដែលនឹងកើតឡើងតាំងខ្ទើងតែញឹកជាកបិនបានដោយគ្រែតន់តែក មានឧបមេយ្យដូច្នោះដែរ ។ ចំណែកអត្ថថា "គោលសរសើរ" នោះ គឺតែគាន ដ៏វិសេសដែលព្រះអរិយបុគ្គលតាំងឡាយ មានព្រះពុទ្ធជាដើមតែងពោលសរសើរថា "មានផលដ៏វិសេស សម្រេចដល់បុគ្គលតាំងពីរខាង គឺខាងឲយកអ្នកឲ្យក៏បានអានិសង្សច្រើន, ខាងបដិគ្គាហកគឺកុអ្នកទទួលគ្រាលកបិនទឹងបុគ្គល គណៈ ឬសង្ឃដែលអនុមោទនាក៏បានសម្រេចអានិសង្សតាំង ៥ ពេញទីដល់អស់កបិនក្កេត្ត" ។ កបិន - សព្ទនេះ បើប្រែតាមអត្ថគឺសេចក្តីមានពីរយ៉ាង ថា "កាន់យកត្រម" ๑ ថា "ស្តិតស្ទេរ" ๑ ។ ឯកាក្យថា "កាន់យកត្រម" គឺកិកុអ្នកគ្រាល ឬកិកុអ្នកអនុមោទនាអាចកាន់យកនូវអានិសង្ស ៥ មិនឲ្យត្រែចហួសទៅខេត្តដទៃបាន; ពាក្យថា "ស្តិតស្ទេរ" គឺកិកុអ្នកគ្រាលនឹងកិកុអ្នកអនុមោទនាកបិនអាចធ្វើនូវអានិសង្ស ៥ ឲ្យមានទីបំផុតត្រឹមតែញឹកបូណ៌មីខែផល្គុន ឬថាតាំងទៅក្នុងវាឆក្នុងនៃកបិនក្កេត្ត ។ អធិប្បាយថាបើកិកុបានគ្រាលគ្រងឬអនុមោទនាកបិនតាំងពីថ្ងៃ ๑ រោចខែអស្សុជទៅ អានិសង្សក៏បានមាន ๕ ខែ, បើបានគ្រាលឬអនុមោទនាកបិន តាំងពីថ្ងៃតែញឹកបូណ៌មីខែកត្តិកទៅ នោះ

អានិសង្សពាំង ៥ តាំងស្តីតស្តេរនៅអស់កំណត់ហេមន្តរដូវត្រឹមតែ ៤ ខែ; បពិត្រព្រះមហាថេរដ៏ចំរើន! ខ្ញុំព្រះករុណាបានប្រែកបិន សព្វត្រមពាំង សេចក្តីអធិប្បាយបានសេចក្តីប៉ុណ្ណេះ សូមជ្រាប ។

៣.- សាធុ សាធុ លោកម្ចាស់វិសជ្ជនាមកនេះ ខ្ញុំស្តាប់បានចូលចិត្តហើយ ខ្ញុំនឹងសួរតទៅទៀត ។ អើលោកម្ចាស់! កបិននេះ មានពីត្រឹមណាមក? មានដំណើររឿងពីរដូចម្តេច ឬបានជាព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យមានកបិននេះទៅវិញ? សូមលោកម្ចាស់និមន្តសំដែងឲ្យពិភេរក្បោះក្បាយមកមើល ។

- កន្តេ មហាថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន! ការសំដែងឲ្យពិភេរក្បោះក្បាយនោះពុំអាចអះអាងបានទេ ឯរឿងកបិននេះមានឧទានជាវិត្តារពិស្តារ សូមសំដែងតាមសមត្ថភាពនៃការចេះដឹង ចំពោះកបិនដែលមាននៅក្នុងកបិនក្ខន្ធកៈ ដែលព្រះសង្គីតិកាចារ្យពាំងឡាយមានព្រះមហាកស្សបត្ថេរ ជាប្រធាន លោកសង្គាយនាតាំងពុកមកថា :-

សម័យមួយ សម្តេចព្រះកតវន្តបពិត្រ ស្តេចស្ថិតគង់សំពនក្បាន្តព្រះឥរិយាបថអភិរម្យដោយព្រហ្មវិហារធ្លាកដនៅក្នុងព្រះមហាវិហារព្រះជេតពនសុគន្ធកុដី ជាអាពាមនៃអនាថបិណ្ឌិកសេដ្ឋីសាងថ្វាយ ពុំឆ្ងាយអំពីនគរសាវត្ថីពាក់ជប្បរីសីមា គ្រាកាលនោះ មានភិក្ខុពាំងឡាយប្រមាណ ៣០ អង្គ មានប្រកតីគង់នៅក្នុងនគរចាស់ បបួលគ្នាត្រៃចគោចរទៅ

គាន់នគរសោវត្ថី ប្រយោជន៍ដើម្បីនឹងចូលទៅគាល់ព្រះបរមសាស្តាចារ្យ វេលានោះជាវស្សូបគាយិកាសម័យ ជួនព្រះសង្ឃនឹងចូលព្រះវស្សាហើយ ឯភិក្ខុគាំង ៣០ រូបនោះ មានដំណើរមកកុងមគ្គាដ៏ឆ្ងាយ ទើងស្រុតទៅ ឲ្យដល់នគរសោវត្ថីពុំទាន់ ក៏ល្មមដល់ថ្ងៃចូលវស្សា ទើបនាំគ្នាចូលទៅ អាស្រ័យចាំវស្សាទៅក្នុងក្រុងសាកេត ជាខេត្តឡើងនគរសោវត្ថី អស់ចំនួនខែ ៣ តាមសម័យវិតមាសជាកំណត់ លុះដល់ចេញវស្សាបវារណា ហើយ ភិក្ខុគាំង ៣០ រូបនោះ ក៏បបួលគ្នាលាចេញអំពីស្រុកសាកេតបុរី ធ្វើដំណើរទៅកាន់នគរសោវត្ថីតាមផ្លូវពុំទាន់ឋានដល់ ដោយផ្លូវឆ្ងាយ សែនលំបាកវិលែក ព្រោះសម័យនោះក៏ជាវស្សានរដូវ ផ្លូវនោះប្រកប ដោយទូវទឹកភ្លៀងកកស្ទះបាប់ ឯបិតាវស្សាធំ សង្ឃាដិនៃភិក្ខុគាំងនោះ ក៏ជិត ប្រឡាក់ទឹកជោកដោយទឹកភ្លៀងតែរៀងៗ រាល់ដំបន់ពាល់កន្ទែង, ឯសរីរៈកាយនៃភិក្ខុគាំងនោះឯង ក៏និត្យនឿយទ្រុឌទ្រោម លុះល្មមដល់នគរ សោវត្ថី ទើបនាំគ្នាចូលទៅគាល់សម្តេចព្រះដ៏មានស្រីក្នុងព្រះជេតពនមហា វិហារ ។ ឯព្រះដ៏មានព្រះភាគជាអគ្គបុគ្គល ស្តេចទ្រង់យល់ភិក្ខុគាំង ៣០ រូបនោះ ដែលមានវិតចីវរសៅហ្មងដោយទូវទឹកភ្លៀងទទឹកជូរច្មោះ ហើយ ទើបទ្រង់ត្រាស់បដិសណ្ឋារៈ សួរទទួលដោយពុទ្ធដីកាតាមធម្មតា ហើយទ្រង់ព្រះមហាករុណាក្នុងវេនេយ្យពុទ្ធបរិស័ទ អាស្រ័យហេតុនោះ ជាទិដ្ឋាន ទើបមានពុទ្ធដីកាត្រាស់ហៅភិក្ខុគាំងឲ្យមក ប្រដុំសន្ទិដ្ឋាត

ហើយទ្រង់អនុញ្ញាតកបិនត្តារវិនយកម្មថា ..អនុជានាមិ ភិក្ខវេ វិស្សុំ វុត្ថានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ "ម្នាលភិក្ខុទាំងឡាយ! តថាគត អនុញ្ញាតឲ្យពួកភិក្ខុដែលចូលនៅចាំវស្សារួចហើយ ក្រាលកបិនបាន" ។ អត្ថតកឋិនានំ ចោ ភិក្ខវេ បញ្ចាធិសំសានិ កប្បិស្សន្តិ "ម្នាលភិក្ខុទាំងឡាយ! កាលបើអ្នកទាំងឡាយបានក្រាលកបិនហើយ នឹងបានសម្រេចអានិសង្ស ៥ ប្រការដោយពិត" ។ បពិត្រព្រះមហាវេរ! ឯដំណើរដើមដែលនាំឲ្យកើតកបិនក្នុងសាសនា ដូចន័យដែលបានវិសជ្ជនាមកនេះ សូមទានជ្រាប ។

๔.- សាធុ សាធុ ម្នាលអនុត្តរ! ប្រស្នាដែលលោកម្ចាស់វិសជ្ជនាមកពិពេរេក្បោះក្បាយហើយ, ខ្ញុំសូមសួរតទៅទៀត ។ លោកម្ចាស់សំដែងថា "ភិក្ខុដែលបានក្រាលត្រឹមកបិន នឹងភិក្ខុដែលបានទទួលអនុមោទនាទូកបិននោះ ឋានឹងបានសម្រេចអានិសង្ស ៥ ប្រការ" ចុះអានិសង្ស ៥ ប្រការនោះតើគឺអ្វីខ្លះ? សូមរៀបរាប់មកទៀតមើល ។

- បពិត្រព្រះមហាវេរ! ឯអានិសង្ស ៥ ប្រការ ដែលសម្រេចអំពីកបិនទានដល់ពួកភិក្ខុនោះគឺ:

ក)- អនាមន្តចារោ ភិក្ខុណា តុំបានលាតុំបានប្រាប់ភិក្ខុជាសព្រហ្មចារ្យ នៅក្នុងអាវាសជាមួយគ្នា ហើយគ្រាប់ទៅកាន់ត្រកូលក្នុងវេលាត្រឹកប្តវេលាល្ងាច, ភិក្ខុនោះត្រូវអាបត្តិដោយទារុណសិក្ខាបទ; ថា

បើភិក្ខុនោះបានត្រេតឆកបិនក្តី អនុមោទនាកបិនក្តី ទោះបីមិនបានប្រាប់មិនបានលាភិក្ខុជាសព្រហ្មចារ្យទៅជាមួយគ្នា ហើយទៅកាន់ត្រកូល ក៏ឥតត្រូវអាបត្តិ ព្រោះអានិសង្សនៃកបិន អាចការពារអាបត្តិដល់ភិក្ខុនោះឯង ។

ខ)_ អសមាទានបាពោ. ភិក្ខុណាលះត្រៃចីវរឯណាមួយដែលជាទីរក្សាក្នុងកាលអរុណរះឡើងទុកហើយចេញចាកទីលំនៅ ឲ្យកន្លងអរុណមាត្រាតែពាក្យ ១ ទឹង ត្រូវអាបត្តិដោយចីវរវិប្បវាសិក្ខាបទ; បើភិក្ខុនោះបានត្រាលត្រេតឆកអនុមោទនាកបិន ទោះបីលះត្រៃចីវរទុកឲ្យកន្លងពាក្យ ក៏ឥតត្រូវអាបត្តិ ព្រោះអានិសង្សនៃកបិននោះឯង ។

គ)_ គណភោជនំ ភិក្ខុទទួលចង្ហាន់គណភោជនតាំងតែអំពី ៤ រូបឡើងទៅ ហើយមានគាយកមកនិមន្តដោយវោហារត្រេហស្ស មិនសមគួរដល់សមណកប្បជាដើមថា "និមន្តលោកធាន់ចាយ ធាន់សម្ង ធាន់ត្រី ធាន់សាច់ជ្រកជាដើម" ទៅធាន់ក៏ត្រូវអាបត្តិដោយគណភោជនសិក្ខាបទ; បើភិក្ខុតាំងពី ៤ អង្គឡើងទៅ ចាន់ត្រាល ចានអនុមោទនាកបិនហើយ ទោះបីទៅធាន់ភោជននៃគាយកនោះក៏ឥតត្រូវអាបត្តិ ។

ឃ)_ យាវទត្ថចីវរំ ភិក្ខុចានចីវរលាភទាំងពួងមក ហើយពុំចានអធិដ្ឋានវិកប្ប ហើយទុកឲ្យកន្លងពាក្យ ១០ ថ្ងៃទៅដូច្នេះក៏ពុំត្រូវអាបត្តិឡើយ ។

ដ)- យោ បគ្គ បីរុប្បាទោ សោ ឆេសំ ភវិស្សតិ

ចីវរដែលកើតអំពីទាយកថ្វាយចំពោះជាសង្ឃទានក្តី ចីវរកើតអំពីធរ-ណីសង្ឃ គឺថ្លៃស្រែចំការវត្តក្តី មតកចីវរ គឺចីវរបស់កិក្ខុសាមណេរដែលដល់អនិច្ចធម្មក្តី សង្ឃិកចីវរទាំង ៣ ប្រការ ដែលកើតកន្លងដែនតបិនាវាសក៏បានដល់កិក្ខុដែលបានគ្រាលអនុមោទនាកបិនពួកមួយនោះឯង តែកិក្ខុដាច់វស្សាក្តី កិក្ខុដែលចូលបច្ចិមវស្សាគឺចូលក្នុងថ្ងៃ ១ រោចខែស្រាពណ៍នោះក្តី មិនត្រូវបានចំណែកចីវរនោះផងឡើយ ។

បពិត្រព្រះមហាថេរ! ឯកបិនទានមានអានិសង្ឃអាចការពារអាបត្តិ ៥ ប្រការ ដូចសំដែងមកនេះ ចំពោះមានកាលកំណត់ តាំងអំពីថ្ងៃដែលបានគ្រាល - អនុមោទនាកបិនមក ដរាបដល់ថ្ងៃបូណ៌មីខែផល្គុន ជាថ្ងៃបំផុតដោះកបិនដោយប្រការដូច្នេះឯង សូមទានជ្រាប ។

(មានត)

កឋិនទាន មានក្នុង ពុទ្ធសាស្ន, ព្រះត្រាស់ថា បានផល ពីរចំណែក:
អ្នកដែលឲ្យ បានបុណ្យ អតិរេក តាមលោកចែក មានប្រាំ ប្រការណា ។

តំអាយុ វណ្ណៈ និង សុខៈ ពលៈ បដិភាណ តាមតំរ៉ា
អ្នកទទួល តែងបាន អានិសង្ឃា ប្រាំប្រការ ការពារ អាបត្តិបាន ។

សេចក្តីល្អ-សេចក្តីអាក្រក់

លោក សុន-ហាន ស្បៀនសៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

អស់លោក-អ្នកសប្បុរសចាំងឡាយ! អំពើកាយ មានសុភាព ភាពសារ មានសណ្តាប់ធ្នាប់ល្អ មិនឃើញសឃឹចប្រឡែងខាម មិនលួចប្លន់ មិនកាប់សម្លាប់បំផ្លាញជីវិតសត្វនឹងបុគ្គលដទៃ ជាដើម ឈ្មោះថា ការល្អផ្លូវកាយ; អំពើកាយមានសភាពផ្ទុយអំពីនេះ ឈ្មោះថាការអាក្រក់ផ្លូវកាយ; ការពោលពាក្យទន់ភ្លន់ផ្អែមល្ហែមពីពេះជាទីគាប់ចិត្ត ជាពាក្យមានប្រយោជន៍ដល់អ្នកស្តាប់ ជាពាក្យពិតមិនកុតកវកុហក មិនញុះញង់ចាក់រុក មិនឆ្កេះឆ្កៀលរកវឿង មិនបង្កហេតុឈ្លោះប្រកែក ជាដើម ឈ្មោះថាការល្អផ្លូវសំដី; ការពោលវាចាខុសទំនងអំពីនេះ ឈ្មោះថាការអាក្រក់ផ្លូវសំដី; ចិត្តស្លូតបូតមិនព្រហើនកោងកាច មានមេត្តាករុណាគ្រាប្រណីអ្នកដទៃ ស្មោះត្រង់មិនវៀចវេរ ជាដើម ឈ្មោះថាការល្អផ្លូវចិត្ត; ចិត្តព្រហើនកោងកាច គ្មានមេត្តាករុណាមិនស្មោះត្រង់ជាដើម ឈ្មោះថាការអាក្រក់ផ្លូវចិត្ត ។

សត្វលោកតែងស្អប់ខ្ពើមនូវសេចក្តីអាក្រក់ ត្រូវការថ្នាក់ថ្នមចង់បានតែសេចក្តីល្អ តែសេចក្តីអាក្រក់នឹងសេចក្តីល្អ ដែលនឹងកើតមានឡើង

ចានក៏ត្រូវមានការធ្វើជាហេតុ ។ ហេតុនោះ ការធ្វើទើបជារបស់សំខាន់បំផុតក្នុងរឿងល្អនឹងអាក្រក់ មិនគួរមើលងាយការធ្វើថាមានប្រមាណតិចតួចទេ ព្រោះការធ្វើបន្តិចបន្តួចញាយជនឯងនោះឯង ជាហេតុឲ្យច្រើនបាន ។ អស់លោក-អ្នកសប្បុរសទាំងឡាយ ! យើងគួរតក់ស្លុតចិត្តចំពោះការធ្វើប្រការខ្លះ ដែលប្រព្រឹត្តទៅក្នុងផ្លូវមិនល្អ ដឹងហើយហ៊ានធ្វើទាំងបំពានគិតទៅមិនគួរនឹងធ្វើបានសោះ តែត្រឡប់ជាធ្វើបានទៅវិញ, កិរិយាដែលពោលមកនេះ មាននៅពាសពេញក្នុងលោក ។ សូម្បីការធ្វើខ្លះ ដូចសេចក្តីក្រោធជាដើម ម្ចាស់ខ្លួនដឹងហើយថាជារបស់មិនល្អ ដូចជាភ្លើងកងពេលខ្លះក៏ព្រមឲ្យនៅក្រោមអំណាចសេចក្តីក្រោធ បណ្តាយឲ្យសេចក្តីក្រោធញាំញីចិត្តបាន ។ កិរិយាធ្វើបែបនេះអ្នកប្រាជ្ញមានព្រះសម្ពុទ្ធជាដើមមិនទ្រង់សរសើរឡើយ ។

បើមានមនុស្សដទៃមកសំដែងសេចក្តីក្រែវក្រោធជាដើម ដាក់ខ្លួនយើង ។ គង់មិនពេញចិត្ត តែបើខ្លួនយើងធ្វើដល់មនុស្សដទៃវិញ ក៏ចេះតែធ្វើទៅបានឥតមានកោតក្រែងចិត្តគេះឡើយ ។ មនុស្សដែលធ្វើដូច្នេះក៏ព្រោះឃើញតែប្រយោជន៍ផ្ទាល់ខ្លួន ទោសរបស់ខ្លួនឯងមិនឃើញ ទៅឃើញតែទោសមនុស្សដទៃវិញ ។ ការដឹងផ្សេង ។ ដែលបានមកអំពីការឃើញ, ការស្តាប់, ការស្រូបកូនិន, លិទ្ធរស, សម្ផស្ស, ការនឹកគិតនឹងការធ្វើនោះ ត្រូវសេចក្តីឃើញចំពោះខ្លួនជិតជាំងអស់ ច្រើការ

ជាប្រយោជន៍មិនបាន ។ អស់លោកសប្បុរសទាំងឡាយ! សូមកុំភ្លេចថា វិជ្ជាដែលបានរៀនមក ដើម្បីជាគ្រឿងបែតបត្តិឲ្យបានសម្រេចប្រយោជន៍សេចក្តីល្អឲ្យផុតអំពីសេចក្តីអាក្រក់ មួយទៀត គប្បីយល់ថា ការបៀតបៀន, ការមើលងាយ, សេចក្តីអយុត្តិធម៌, ការកំហែង, ការយកប្រៀបនឹងវាចាដែលអាក្រក់ជាដើម ខ្លួនយើងមិនប្រាថ្នាគ្រប់ៗ គ្នា សុទ្ធតែដឹងជាក់ច្បាស់ថា ជាអំពើមិនល្អហើយ តែទោះបីដូច្នោះក៏គង់មានគេហ៊ានប្រព្រឹត្តធ្វើទៅបាន ។ ហេតុនោះផ្លូវច្បាប់សម្រាប់ស្រុកទេស នឹងផ្លូវវិន័យរបស់ពុទ្ធសាសនា ទើបមានឱហាមប្រាមចំពោះការធ្វើអាក្រក់ ។ ការឃើញតែប្រយោជន៍ផ្ទាល់ខ្លួន ជាហេតុមិនឲ្យមានយុត្តិធម៌នៅក្នុងខ្លួន ។ អស់លោក-អ្នកសប្បុរសទាំងឡាយ ត្រូវនាំគ្នាប្រយ័ត្នឲ្យណាស់ ចំពោះអំពើអយុត្តិធម៌នេះ ។ ព្រោះជារបស់កាច, បើពួកមនុស្សប្រយ័ត្នបានហើយ ពួកសត្វក៏រស់នៅជាសុខ នឹងមិនក្តៅក្រហាយ ព្រោះកម្ទាំងដៃរបស់មនុស្សឡើយ ។

ដែលពិតត្រូវតែធ្វើខ្លួនឲ្យជាអ្នកល្អ សូម្បីខ្លួនមិនមានការចេះដឹងច្រើន ក៏អាចនឹងធ្វើបានដោយកំណត់ចិត្តរបស់ខ្លួនឯង ហើយចាំសង្កេតមើលការធ្វើរបស់បុគ្គលដទៃ ដូចសេចក្តីសុខសប្បាយ, ការមិនត្រូវកំហែង, លះកយស, ការមិនត្រូវបៀតបៀន, មានមេត្តាករុណា, នឹងវាចាពាក្យទន់ផ្អែមជាដើម ទាំងនេះយើងពេញចិត្តណាស់, កាលយើងពេញ

ចិត្តហើយអ្នកដទៃក៏ពេញចិត្តដែរ ។ គេធ្វើយ៉ាងនេះដល់យើង។ មិនពេញចិត្ត ក៏គួរចាំទុកព្រមទាំងតាំងចិត្តថា យើងនឹងមិនធ្វើកិរិយាដូច្នេះដល់អ្នកណា ។ ឡើយ ។ គេធ្វើយ៉ាងនេះដល់យើង។ពេញចិត្ត ក៏គួរចាំទុកព្រមទាំងតាំងចិត្តថា យើងនឹងរកឧកាសធ្វើដូច្នេះដល់គេឲ្យបាន ។ កិរិយាធ្វើដូច្នេះ អ្នកប្រាជ្ញហៅថា ចេតោបរិយញ្ញាណ មាននៅក្នុងសន្តានអ្នកណា អ្នកនោះចាត់ថាជាមនុស្សជាន់ខ្ពស់ ជាអ្នកល្អដែលរកបានដោយកម្រ, សេចក្តីអាក្រក់សូម្បីបន្តិចបន្តួចក៏មិនចង់ឲ្យមាននៅក្នុងសន្តានឡើយ ។ ហេតុនេះ អស់លោកសប្បុរសទាំងឡាយ គួរប្រយ័ត្នចំពោះការធ្វើឲ្យមែនទែន កុំបណ្តោយឲ្យខូចសេចក្តីតាំងចិត្តដែលមានក្នុងសន្តានថា ចង់ឲ្យខ្លួនបានជាអ្នកល្អ, ជាអ្នកមានតម្លៃ, ចិត្តមានន័យសម្រាប់គិតនឹកក៏គួរគិតឲ្យហ្មត់ចត់ជាមុន ហើយទើបធ្វើការ, យើងមានន័យធ្វើសេចក្តីល្អជាក់ខ្លួន ក៏គួរលះអាក្រក់ប្រព្រឹត្តល្អ ។ មនុស្សដែលធ្វើសេចក្តីក្តៅក្រហាយឲ្យដល់សត្វលោក, លោកហៅថា "មនុស្សចង្រៃ" លោក" មនុស្សដែលធ្វើគុណសេចក្តីល្អឲ្យដល់សត្វលោកចំរើនុងរឿងលោកហៅថា "អ្នកញ៉ាំងលោកឲ្យភ្លឺស្វាង" ខ្លួនរបស់ខ្លួនឯង ជារបស់រកបានដោយកម្រ មានតម្លៃច្រើន កុំឲ្យតម្លៃនឹងគុណសេចក្តីល្អ របស់ខ្លួននោះអាប់ឧនទាបថោកទៅ ព្រោះការធ្វើរបស់ខ្លួនឯងឡើយ ព្រោះជាការគួរខ្មាសណាស់ ។

អ្នកដែលមិនបានសំឡឹងពិនិត្យខ្លួនឯង ត្រឡប់ទៅសំឡឹងពិនិត្យ
កន្ធផ្សេងវិញ ឈ្មោះថា មិនឃើញសេចក្តីវុសរបស់ខ្លួនទេ សេចក្តី
វុសត្រូវយ៉ាងធ្ងន់ដល់មនុស្សដទៃ ខ្លួនរបស់ខ្លួនឯងវេះតែល្អទាំងអស់ ។
ពើធ្វើបំពានដូច្នេះ លោកនេះ នឹងទៅជាលោកដែលល្ងីងដូរចត់ ហឺរាវ
ទីបំផុតរកសេចក្តីសុខបានដោយកម្រ ដែលមិនត្រង់នឹងសេចក្តីប្រាថ្នា
របស់សត្វលោកឡើយ ។ សេចក្តីល្អ, ហេតុនៃសេចក្តីចំរើន, ហេតុនៃ
សេចក្តីសុខ ដែលរួមហៅថា ធម៌ ព្រះពុទ្ធអង្គទ្រង់ស្វែងរកដោយព្រះអង្គ
ឯង ទ្រង់លះដោយព្រះអង្គឯង ទ្រង់ប្រព្រឹត្តដោយព្រះអង្គឯង ទ្រង់
ល្បងមើលដោយព្រះអង្គឯង អស់រៀល ៦ ឆ្នាំ ស្ទើរតែនឹងអស់ព្រះជន្ម
ទៅហើយ ដែលពាក់ថាជាការកម្រទីបំផុត ។ យើងកើតមកខាងក្រោយ
មិនចាប់ស្រាវជ្រាវរកព្រះធម៌ទេ ព្រះអង្គទ្រង់ត្រាស់ប្រាប់ទុកជាស្រេច
ដូចបរិភោគបាយដែលគេដួសដោះទុកហើយ គួរតែយើងខំាងអស់គ្នាធ្វើ
តាមព្រះអង្គ នឹងធ្វើតាមមិនបានឬ? គិតមើលឲ្យត្រូវគាន់ល្អ បើយើង
ធ្វើតាមមិនបានហើយ ក៏គួរឲ្យខ្មាសណាស់ ។ ខ្លួនរបស់ខ្លួនឯង ហាត់
ពត់បានដោយកម្រ ត្រូវអាស្រ័យសេចក្តីព្យាយាមធ្វើដោយមិនលះធុរៈ
ទើបនឹងតស៊ូបាន, និស្ស័យរបស់មនុស្សដែលចង់ឈ្នះជានិច្ច ទើប
គួរពាប់ថាជានិស្ស័យដែលល្អ ។ ហេតុនេះគប្បីឈ្នះខ្លួនឯងចុះ លោក
ពោលទុកថា អ្នកឈ្នះពួកមនុស្សក្នុងសង្គ្រាមអស់ពាន់ដងក៏មិនប្រសើរ

ស្មើមនុស្សដែលឈ្នះខ្លួនឯងម្តង ។ គប្បីគិតពិនិត្យខ្លួនឯង តយគន់មើលខ្លួនឯង ឲ្យឃើញទោសរបស់ខ្លួនឯង កាលឃើញហើយត្រូវលះរបស់ដែលគួរលះ បំពេញរបស់ដែលខ្វះខាតឲ្យបរិបូណ៌ លុះពិចារណាគ្រប់ទៀតឃើញថាមិនមានទោសហើយគប្បីកាន់យកធម៌ គឺសេចក្តីល្អ សេចក្តីអាក្រក់នេះ ជាអនុស្សរណៈយ៉ប្រចាំចិត្តគ្រប់ពេលវេលា ។

ដើម្បីជាគ្រឿងជាស់តឿនចិត្ត មិនឲ្យធ្វើសេចក្តីអាក្រក់បាន. តអំពីនោះនឹងឃើញខ្លួនឯងជាមនុស្សល្អម្នាក់ក្នុងលោកមុខ តែត្រូវប្រយ័ត្នការឃើញចំពោះខ្លួនឯង ។ ការកំចាត់បង់នូវសេចក្តីឃើញចំពោះខ្លួនឯងជាមុន ទើបយកសេចក្តីយុត្តិធម៌មកជំនួសបាន ធ្វើខ្លួនរបស់ខ្លួនយើងឲ្យស្មើនឹងសត្វលោក ហើយប្រព្រឹត្តឲ្យស្មោះស្មើដែលហៅថាយុត្តិធម៌ ឲ្យសមគួរដល់ឋានៈរបស់ខ្លួន ។ ក៏នឹងបានចំរើនពិតប្រាកដ ។

សេចក្តីល្អជារបស់យើង សេចក្តីអាក្រក់ក៏ជារបស់យើង
គេក៏មានចិត្តយើងក៏មានចិត្ត ធ្វើអ្វីបូរគិតមុខក្រោយ ។

សុិន - ហ៊ាង

ការបណ្តុះជំនឿ

ព្រះមហាឧត្តមវិជ្ជា ធីលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីវគ្គ វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌាធុរក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកឱនិតិត្យកៃ

(តមក)

ប៉ុន្តែ មនុស្សដែលមិនត្រឹះរឹងក្នុងផ្លូវសាសនា ច្រើនតែឃើញថា សាសនាជាពាក្យប្រៀនប្រដៅ ដែលសាស្តាចារ្យបញ្ញត្តឡើងក្នុងយុគនៃមនុស្សល្ងង់ខ្លៅ សម្រាប់ចោកប្តូរតាមមនុស្សជំនាន់នោះៗ ឲ្យធ្លើតាមបំណង លុះដល់មកខាងក្រោយក្តាយទៅជាវត្ថុសង្កត់សង្កិនចំពោះការប្រព្រឹត្តទៅដោយសេរីរបស់មនុស្សទាំងឡាយវិញ ។ តាមការពិត មិនដែលមានប្រទេសឯកភាជ្ឈមហាអំណាចណាមួយ ដែលគ្មានអំណាចខាងច្បាប់ទំលាប់ជាធំខ្ពង់ខ្ពស់បំផុតឡើយ ។ តែសូម្បីមានអំណាចច្បាប់ទំលាប់ជាធំដូច្នោះក៏ដោយ ច្បាប់ទំលាប់ក៏នៅតែគ្រប់គ្រងការពារគ្នាមិនបានជិតស្និទ្ធប្រហែលនឹងសាសនាដែរ ។ ព្រោះអំណាចច្បាប់ទំលាប់ ការពារមនុស្សមិនឲ្យប្រព្រឹត្តខុសបានតែត្រឹមផ្លូវកាយនឹងវាចា ។ ចំណែកសាសនា អាចរក្សាមនុស្សមិនឲ្យប្រព្រឹត្តខុសបានគ្រប់ទាំងផ្លូវគំនូរ ។ បើជាតិណាគ្មានសាសនាប៉ុន្តែងទេ មនុស្សក្នុងជាតិនោះ ក៏នឹងគ្មានគោលចារឹកក្នុងផ្លូវប្រតិបត្តិ អាចប្រព្រឹត្តអាក្រក់ខុសធម៌ទៅតាមទំនើងចិត្តរបស់

ខ្លួនដែលជាហេតុចង្អុលឲ្យឃើញថា ទៅកន្លងអនាគត ដោយសារតែសេចក្តីប្រព្រឹត្តអាក្រក់របស់មនុស្សក្នុងជាតិនោះឯង ជាតិក៏មុខជានឹងដល់នូវសេចក្តីវិនាសលិចលង់មិនខាន មិនអាចតាំងនៅជាជាតិ មានឥស្សរភាពបានឡើយ ។

ព្រះពុទ្ធសាសនា ជាសាសនាប្រចាំជាតិខ្មែរ ។ ព្រះធម៌វិន័យដែលជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហៅថា ព្រះពុទ្ធសាសនា ។ ព្រះធម៌ដែលព្រះអង្គទ្រង់សំដែងទូន្មាន ជាគោលនៃសេចក្តីពិត ឬជាវត្ថុដែលរក្សាទុកនូវសេចក្តីពិត ជាអណ្តូងកើតនៃសន្តិសុខ សូម្បីមានបែកខ្ញែងទៅជាច្រើនយ៉ាងក៏ដោយ ចំណុចមួយបំផុតក៏ទៅរួមនៅកន្លងសេចក្តីពិតដែលចាត់ថាជាវត្ថុធម៌ដ៏ប្រសើរបំផុត អាចឆ្នៃលោកឲ្យល្អបានគ្រប់ករណីគ្រប់ឋានៈ ។ ព្រះវិន័យជាច្បាប់បង្គាប់ដែលព្រះអង្គទ្រង់បញ្ញត្តទុកដើម្បីឃុំគ្រងពួកគណៈ មានអំណាចគឺអាជ្ញាខាងការដាក់ទោសដល់អ្នកប្រព្រឹត្តល្មើស ទំាងធ្វើឲ្យមានរបៀបរៀបរយ នាំឲ្យអ្នកធ្វើខុស បានត្រឡប់ទៅជាធ្វើត្រូវ ទោះបីសេចក្តីខុសនោះមានចេតនាឬមិនមានក៏ដោយ ឲ្យតែជាការមិនត្រឹមត្រូវតាមព្រះវិន័យ ។

ព្រះពុទ្ធសាសនា គឺព្រះធម៌វិន័យនេះប្រសើរបំផុត អាចធ្វើអ្នកដែលស្រឡាញ់កក្តីគោរពប្រតិបត្តិតាម ឲ្យបានសេចក្តីចំរើនផុតចាកទោស ឲ្យចំរើនដោយគុណវុឌ្ឍិ ឲ្យជាមនុស្សល្អ ជាមនុស្សចំរើន

ឲ្យផុតចាកភាពជាមនុស្សអាក្រក់មនុស្សវិនាស នឹង ឲ្យមានសុខផុតចាកទុក្ខបានតាមជាន់តាមសមគួរដល់សេចក្តីប្រតិបត្តិរៀងពលខ្លួន ។ ព្រោះថាព្រះពុទ្ធសាសនា មានសារៈសំខាន់ នៅត្រង់សេចក្តីល្អ សេចក្តីពិត និងសេចក្តីបរិសុទ្ធិយ៉ាងខ្ពស់បំផុត ។ លោកអ្នកដែលពប់អានព្រះពុទ្ធសាសនាតាំងឡាយ ! លោក-អ្នកមានសេចក្តីស្រឡាញ់កក្តីចំពោះព្រះពុទ្ធសាសនាមែនឦនហើយឬនៅ ? សូមពិចារណាមើលចំពោះខ្លួនលោកអ្នកផងចុះ ។ បើលោក-អ្នកមានសេចក្តីស្រឡាញ់កក្តីពិតហើយ លោកអ្នកមុខជានឹងឃើញអង្គនៃសេចក្តីស្រឡាញ់កក្តីនោះ ច្បាស់ប្រាកដនៅក្នុងខ្លួនរបស់លោក-អ្នកមិនខានឡើយ ។ ឯអង្គនៃសេចក្តីស្រឡាញ់កក្តីចំពោះព្រះពុទ្ធសាសនានោះដូចេ្នះ គឺ :

ក)- មានសទ្ធាជ្រះថ្លាកងព្រះពុទ្ធសាសនាយ៉ាងមាំមួន យកព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ នឹងព្រះសង្ឃជាសរណៈទីពឹងទីរឭកវហូតដល់អស់ជីវិត មិនពប់អានសរណៈវត្តដនៃឲ្យលើសលប់ជាង ។

ខ)- តាំងចិត្តសិក្សាព្រះពុទ្ធសាសនា ឲ្យកើតមានបញ្ញាឲ្យចូលចិត្តជាក់លាក់ ឲ្យស្គាល់ទុសត្រូវអាក្រក់ល្អល្មមនឹងកាន់យកជាគោលនៃការប្រតិ្តត្តរបស់ខ្លួនបាន ។

គ)- ប្រតិបត្តិតាមព្រះពុទ្ធសាសនាដោយគោរព គឺតាំងចិត្តលះអាក្រក់ប្រតិ្តត្តល្អ នឹងធ្វើចិត្តឲ្យបរិសុទ្ធិថ្នាផ្សេងៗ តាមព្រះនិយ័យរបស់ព្រះពុទ្ធ ។

ឃ)- ណែនាំអ្នកដែលមិនទាន់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ឲ្យកើតសទ្ធាជ្រះថ្លាទឹងប្រតិបត្តិតាម ដឹកនាំអ្នកដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាខ្លាំងឡើង ទឹងឲ្យរឹងរឹតតែប្រតិបត្តិតាមយ៉ាងតឹងរឹងទៅទៀត

ង)- ទំនុកបំរុងកិច្ចការរបស់ព្រះពុទ្ធសាសនា ទាំងខាងផ្លូវសិក្សា ទាំងខាងផ្លូវប្រតិបត្តិ រហូតដល់កិច្ចការដទៃដែលជាគ្រឿងលើកដំកើងព្រះពុទ្ធសាសនាឲ្យវិវឌ្ឍនាការជាស្ថាពរ ដោយកម្លាំងទ្រព្យ កម្លាំងកាយ ទឹងកម្លាំងដម្រែក្រៃជារបស់ខ្លួន ។

ច)- រក្សាព្រះពុទ្ធសាសនាឲ្យបរិសុទ្ធបរិបូណ៌តទឹងទៅ មិនផ្ទាស់ថ្លែងតែងឲ្យខុសឆ្ងប់ទៅតាមចិត្តគំនិតរបស់ខ្លួន ព្យាយាមលើកខ្លួនឡើងទៅរកព្រះពុទ្ធសាសនា មិនទាញព្រះពុទ្ធសាសនាឲ្យចុះមករកខ្លួនវិញឡើយ ។

ឆ)- ការពារមិនឲ្យកើតមានសេចក្តីវិនាសដល់ព្រះពុទ្ធសាសនា គឺកាត់ផ្តាច់ដើមហេតុ ទឹង រំងាប់កិច្ចការដែលបណ្តាលឲ្យព្រះពុទ្ធសាសនាថោកទាបសៅហ្មងចោលចេញ ។

លោក · អ្នកពុទ្ធសាសនិកជនទាំងឡាយ ! កាលបើលោក · អ្នកប្រាថ្នាទឹងកសាងព្រះពុទ្ធសាសនាឲ្យចំរើនរុងរឿងហើយ ចូរលះបង់សេចក្តីសុខផ្ទាល់ខ្លួនចេញហើយ ខំតាំងព្យាយាមប្រតិបត្តិតាមអង្គនៃសេចក្តីស្នេហាញ៉ាកក្តីដូចថ្ងៃនេះ ដោយតាំងចិត្តសិក្សាទឹងប្រតិបត្តិអប់រំខ្លួនឲ្យ

ល្អត្រឹមត្រូវឡើងជាដាច់ខ្លួន ឃើញហោចណាស់ក៏ឲ្យមានមារយាទល្អ ឬឲ្យមានសីលធម៌សម្រាប់ប្រដុំដួន ឲ្យសមនឹងភាពជាមនុស្សក្នុងលោកនេះ បើយ៉ាងកណ្តាលក៏ឲ្យល្អប្រពៃ សម្រាប់ជាផ្លូវសុគតិកន្លងកន្លងមុខ បើយ៉ាងខ្ពស់ គឺដំរេះចិត្តបង្ហាត់ខ្លួនឲ្យបរិសុទ្ធផុតទៅសេចក្តីវិលត់ទុក្ខ ឬធុតបាកកិលេសដោយអស់ដើង ឬកាលបើសិក្សាចេះដឹងហើយ ចូរធ្វើចំណេះនោះឲ្យកើតផលគឺការប្រតិបត្តិ ធ្វើការប្រតិបត្តិឲ្យកើតផលគឺការផ្ទាប់ថ្នឹក ធ្វើចំណាប់ថ្នឹកឲ្យកើតផលគឺឧបនិស្ស័យ ឧបនិស្ស័យឲ្យកើតផលគឺភាពជាមនុស្សល្អក្នុងលៃតកពេហួតដល់ឋានៈជាមនុស្សលែងខាត់ខាម ឧបនិស្ស័យសេចក្តីល្អធ្ងន់ផុតអំពីលៃតកពេញទៅតាំងនៅលើទីបំផុតលោក (និព្វាន)។ សូម្បីកាលដល់គ្រាត្រូវការ ក្នុងពេលដែលព្រះពុទ្ធសាសនាត្រូវថោកទាប ព្រោះមានភ័យមកញាំញីធ្វើឲ្យសាបសូន្យ ក៏ចូរលោក អ្នកលះបង់ប្រយោជន៍ផ្ទាល់ខ្លួនគប់យ៉ាង ដើម្បីជួយថែរក្សាការពារព្រះពុទ្ធ-ឲ្យបានគង់វង់នឹងចំរើនរុងរឿងឡើងវិញ ។ សូមនឹកដល់សុភាសិតក្នុងសាសនា អស៊ីតិនីបាតជាតកថា "ដើម្បីនឹងរក្សាអាយុ: មនុស្សយើងគប្បីលះបង់ទ្រព្យ, ដើម្បីនឹងរក្សាជីវិត គប្បីលះបង់អាយុ:, តែកាលនឹកដល់ព្រះធម៌ គប្បីលះបង់ឲ្យអស់ទាំងទ្រព្យ ទាំងអាយុ: ទាំងជីវិត" ។

ដើម្បីនឹង រក្សា អាយុ:
ត្រូវហ៊ានស្ម័គ្រ លះបង់ សព្វធនធាន,

ដើម្បីថែ ជីវិត ឲ្យរស់ពន
ត្រូវចិត្តហ៊ាន លះបង់ អង្គកាយា ។
តែដើម្បី រក្សា ព្រះធម៌ថ្លៃ
នៃសម្ដេច ចមរៃត្រ ព្រះសាស្ដា
ត្រូវតែលះ ទាំងអស់ កុំសោកា
គឺកាយា ទ្រព្យធន នឹងជីវិត ។

៣.— ការស្រឡាញ់ភក្ដីបំពោះព្រះមហាក្សត្រ.— ព្រះមហាក្សត្រជាចមមកុដ ជាប្រមុខនៃប្រជាជនរបស់ជាតិ ជាទីប្រជុំចុះនៃអំណាចត្រូវតាមធម៌ (ច្បាប់) ដែលទុកថាជាកំពូលរបស់ជាតិ ក្នុងការរំដោះហេតុការណ៍ខុស-អាក្រក់ នឹង ការពារបច្ចាមិត្ត ។ ប្រមុខនោះប្រៀបដូចជាចំណែកដ៏ប្រសើរបំផុតរបស់ពងកាយ គឺសិរសា ។ សិរសាវមែងជាប្រធានរបស់ពងកាយ ។ បើពងកាយដាច់សិរសាហើយទំនងរស់នៅយ៉ាងណាបាន ។ ព្រះមហាក្សត្រក៏ជាទីគោរពសក្ការបូជាយ៉ាងក្រៃលែងរបស់ប្រជាជន ក្នុងហេតុជាប្រមុខ ប៉ុន្តែគ្មានទំនងសិរសារបស់មនុស្សដែរ បើខ្វះប្រមុខហើយ ប្រជាជនក៏ខ្វះអ្នកដែលជាទីពឹងដើម្បីការពារឲ្យបានសន្តិសុខ ។

(មានត)

រឿងសាមកុក

កណ្ឌទី ១៦

ឧកញ៉ាវិបុលរាជសេនា ឆ្លូ - កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ធឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

តាំងពីបួងឆ្លូ ចាត់ប្រើហែហូទុនដាទ័ពស្រួច ចាត់ឡើពីដាទ័ពស្តាំ លីហ៊ៅដាទ័ពឆ្វេង បួងឆ្លូ ឯងដាទ័ពលួងលើកទៅវាយស្រុកឡាំយ៉ុង រហូតដល់លីហ៊ៅលើកទ័ពទៅវាយស្រុកសៀវដាយ ឡើពីប្រើកាន់យ៉ុងទៅសុំកងទ័ពបួងឆ្លូមកជួយ ។

ឯបួងឆ្លូនោះ តាំងពីខួចតៀនអ៊ុយទៅពេលណា មិនដែលបានសេចក្តីសប្បាយរីករាយសោះ ឲ្យតែមានគិតស្តាយដល់តៀនអ៊ុយពន់ប្រមាណ ចេះតែសែនគ្រឹងសក្ការៈឲ្យមិនដែលដាច់ ហើយឲ្យយកខ្ចីនតៀនមួនជាបុត្រតៀនអ៊ុយមកតាំងជាតដ៏ឡង គឺជំនិតជិតខ្លួន ទទួលមានសំបុត្រសុំនសឹកទៅដល់ បួងឆ្លូក៏មើលដឹងក្នុងសេចក្តីសំបុត្រ ហើយមិនទាន់នឹងថាប្រការម្តេច មានទាហានចូលមកដំរាបថា ស្រុកឡាំយ៉ុងនោះស្រែវអង្គរ

ស្បៀងអាហារតទៀរនេះក្រខ្សត់ណាស់ហើយ អ្នកសុតកំពុងប្រមូលសេនាតាហានទៅវាយដណ្តើមយកស្រុកតាន់លីវ ។ ចូរគូបានឮដូច្នោះក៏គិតឃើញថា "ក្នុងស្រុកឡាំយ៉ុងនោះ តាហានក៏កាន់តែស្ងួចស្តើង បើយើងនឹងលើកទ័ពទៅវាយក៏នឹងបានដោយងាយ" ទើបឲ្យធ្វើសំបុត្រទៅដល់ខ្លៅពី ស៊ុនសិកនឹងលីចុ៉ា ឲ្យលើកកងទ័ពទៅផ្ចប់គ្នាវាយយកស្រុកឡាំយ៉ុង, ហើយខ្លួនចោយិនឲ្យនៅរក្សាស្រុកហ៊ូគោ ហើយប្រមូលពលតាហានបាន ៧០ ម៉ឺន នឹងស្រែអង្ករស្បៀងអាហារ ១ ពាន់រនេះ លើកទៅដល់ដែនស្រុកអ៊ីជៀងជិតស្រុកអ៊ីជីវដែលខ្លៅពីនៅ ។

ឯហាន់សៀមដែលលីចុ៉ាឲ្យទៅឈរស្រែកគំនាគា នឹងអៀវហង ដែលទៅឈរស្រុកឡងអៀបត្រឹតត្តសេចក្តីអាក្រក់ ធ្វើជាចោរដើរទៅឆក់ដណ្តើមប្លន់ យកវបស់ទ្រព្យបណ្តាកស្តូតគប់កូមិលំនៅ ។ មានមនុស្សនាំយកសេចក្តីនោះមកជំរាបខ្លៅពី។ ក៏ពិគ្រោះនឹងគួនអ៊ូ, សៀវហ៊ុយថា "ឲ្យទៅអញ្ជើញហាន់សៀមទឹងអៀវហងមកស៊ុលៀង . បើអ្នកទាំងអស់គ្នាឃើញយើងចោលពែងវេលាណា ត្រូវអ្នកទាំង ២ ហូតក្រចឹកាត់ក្បាលហាន់សៀមទឹងអៀវហងចេញ" ហើយក៏ប្រើចំរើទៅអញ្ជើញហាន់សៀម, អៀវហងមកស៊ុលៀង ។ លុះស៊ុធីកឆ្អែត ខ្លៅពីធ្វើជាស្រុងទឹងចោលពែងស្រាចេញ ។ ឯគួនអ៊ូ, តៀវហ៊ុយដែលឈរកាន់ក្រចឹក្បែរធាក ក៏ស្ទុះចូលមកយកក្រចឹកាត់កហាន់សៀមទឹងអៀវហងស្លាប់នៅទីនោះ ទទួល

មានឧកញ៉ាហានចូលមកជំរាបខ្ញុំព័ថា ចូរឆ្នូនឆ័លើកទ័ពទៅវាយស្រុកឡាំយ៉ុង តឡូវមកដល់ដែនស្រុកអ៊ុងឆៀងហើយ ។ ខ្ញុំព័ដឹងដូច្នោះ ក៏ប្រមូលសេនាឧកញ៉ាហានលើកចេញទៅដួចនឹងចូរឆ្នូ ឲ្យយួរទាំងក្បាលហាន់សៀមនឹងអៀវហាងចូលទៅផង ចូរឆ្នូក្រែខ្ញុំរឃើញខ្ញុំព័ក៏ចេញមកទទួលគំនាប់គ្នាតាមយសសក្តិតូចធំ ។ ខ្ញុំព័ឲ្យយកក្បាលហាន់សៀមនឹងអៀវហាងបង្ហាញចូរឆ្នូហើយនិយាយថា ខ្ញុំធ្វើការគ្រានេះខុសណាស់ សូមមហាឧបរាជអភ័យទោសម្តងចុះ ។

ចូរឆ្នូឆ្លើយថា "ដែលអ្នកធ្វើការបានការដូច្នេះល្អណាស់ហើយ ព្រោះពស្តែដែលមានសេចក្តីក្តៅក្រហាយទាំងប៉ុន្មាន ក៏បានសេចក្តីសុខសប្បាយ ដោយសារដម្រែះជ្រាជ្ញអ្នក ហេតុម្តេចអ្នកមកថាបានសេចក្តីខុសវិញ" ដូច្នេះហើយឲ្យរង្វាន់បំណាច់ដល់ខ្ញុំព័ជាច្រើនហើយនាំខ្ញុំព័លើកទ័ពទៅដល់ដិតស្រុកឈិជីវដែលលើចុ"នៅនោះ ។

លីចុ"ដឹងថា ចូរឆ្នូលើកទ័ពមកក៏ចេញទៅទទួលចូរឆ្នូ។ និយាយនឹងលីចុ"ថា "ប្រសិនបើយើងធ្វើការនេះបានសម្រេចហើយ យើងនឹងគ្រាបទូលព្រះចៅហៀនតេឲ្យតាំងអ្នកជាធំ" ហើយនិយាយល្បួងលួងលោមលីចុ"ជាច្រើន ។ លីចុ"មានសេចក្តីត្រេកអរ ក្រែកឡើងនូនគំនាប់ចូរឆ្នូដោយគោរព ។ ចូរឆ្នូក៏ចាត់លៃហួនទឹងអ៊ីតឹមជានាយទ័ពស្តេចចាត់ខ្ញុំព័ជានាយទ័ពស្តាំ ចាត់លីចុ"ជានាយទ័ពឆ្វេង ខ្លួនចូរឆ្នូឯងនឹងជាមេទ័ពលួងលើកទៅវាយស្រុកឡាំយ៉ុង ។

ពេលនោះអ្នកនាងសុតដឹងថា ចូតូរលើកទ័ពមក ក៏បាត់ភៀវសេនឲ្យ
លើកទាហាន ៥ ម៉ឺន ចេញទៅរង់ចាំតទល់នៅផ្លូវតំបន់ឈើវាលុន ។
ភៀវសេនក៏លើកទាហានចេញពីស្រុកទៅ ទទួលកងទ័ពហែហួនលើក
មកដល់ ។ ភៀវសេនក៏បំផ្លាយសេះចូលចម្ការដ៏ធំធីហែហួនបាន ៣
ក្លែង ។ ហែហួនយកទ្លួនចាត់ភៀវសេនឆ្កាក់ពីសេះស្លាប់ ។ ទាហាន
ចាំងពួងក៏នាំគ្នារត់ចូលទៅក្នុងស្រុកវិញ ។

ឯស៊ុនសិកដែលនៅក្នុងស្រុកកាំងតាំងដឹងថា ចូតូរលើកទ័ពទៅវាយ
ស្រុកឡាំយ៉ុង ហើយក៏ចាត់ចែងប្រមូលសេនាទាហានជាច្រើន លើក
ទៅស្រុកឡាំយ៉ុងតាំងនៅទិសខាងលិច ។ ចូតូរដឹងថា ស៊ុនសិកលើកទ័ព
មកហើយ ក៏ចាត់លីចុ៉ាទៅតាំងទ័ពនៅទិសខាងកើត ចាត់ឡុងពី,
គួនអ៊ូ, តៀវហ៊ុយទៅចោះទ័ពពីទិសខាងត្បូង ខ្លួនចូតូរឯងនឹងសេនា
ទាហាន ៧០ ម៉ឺន ទៅតាំងបន្ទាយនៅទិសខាងជើង ហើយឲ្យសញ្ញាគ្នាថា
ឲ្យលើកចូលឡោមព័ទ្ធដុំវិញស្រុកឲ្យព្រមគ្នា ។

អ្នកនាងសុតឃើញកងទ័ពចូតូរលើកឡោមព័ទ្ធដុំតាំង ៤ ទិសដូច្នោះហើយ
ក៏ប្រឹក្សានឹងសេនាទាហានថា ពេលនេះសត្រូវមកចូតូរធំពន្លឹក អ្នកទាំងពួង
នឹងយល់ឃើញដូចម្តេច? ។ អៀវតៃជៀងឆ្លើយថា ស្រុកយើងពេលនេះ
បណ្តាកស្រូវកំពុងអត់ឃ្លានស្បៀងអាហារ បើនឹងគិតគ្នាលើកទ័ពទៅ
ទល់នឹងចូតូរមិនបានទេ ព្រោះទាហានខាងយើងមានសេចក្តីលំបាកច្រើន

ណាស់ សុំឲ្យលោកប្រុងប្រៀបរៀបចំសេនាគាហានឲ្យខ្មៅត្បូតត្បែរក្បាស្រុកឲ្យមាំមួនពីខាងក្នុង ឯខ្លួនលោកត្រូវនាំគ្រប់គ្រួយទៅតាំងនៅតំបន់ហួយណាំ ដើម្បីទីងាយស្រួលនឹងបានអាស្រ័យស្បៀងអាហារ ។ អ្នកនុតយល់ឃើញត្រូវតើបចាត់ឲ្យឡោហន ១, ងាក់ដាវ ១, លៀងកង ១, តាន់តី ១, ទីងគាហាន ១០ មុខនៅរក្សាស្រុកឡាំយ៉ុង ហើយអ្នកនុតក៏នាំគាហានទីងគ្រប់គ្រងតាំងពួង ចុយទៅនៅឯតំបន់ហួយ ណាំតាមពាក្យអៀវតៃជៀងជំពាមនោះ ។

ចូរដឹងថា អ្នកនុតរត់ចេញពីស្រុក ក៏ឲ្យគាហានឡោមព័ទ្ធដុំវិញ ។ ឯឡោហន, ងាក់ដាវ, លៀងកង, តាន់តីដែលនៅរក្សាស្រុកនោះ ក៏មិនបានចេញច្បាងទីងចូរ ។ ព័ទ្ធស្រុកទុកយូរប្រហែល ១ ខែ-ជ្រុយគាល់តែអស់ស្បៀង ទើបប្រើមនុស្សឲ្យទៅខ្ចីស្បៀងស៊ុនសិកខាងទ័ពចូក បានស្រូវ ១.០ មុខថាំង ចូរគ្រូក៏ឲ្យនាំស្រូវទៅប្រគល់ឲ្យអង្គហៅដែលជានាយជង្រុកស្រូវ ។ (មានត)

សង្គ្រាមកើតដោយហេតុ ៣ យ៉ាង

ជនធ្វើសង្គ្រាមព្រោះតែហេតុ ៣ ប្រការ គឺ ដែនដី ១ មិត្រ ១ នឹងមាសប្រាក់ ១ បើឥតមានហេតុទាំង ៣ នេះ ឬ ហេតុណាមួយទេ គេមិនធ្វើសង្គ្រាមសោះឡើយ ។

ទីណាមិនមានផលចំរើនច្រើនទេ ទីនោះមានតែសេចក្តីវិនាសម្យ៉ាង អ្នកមានប្រាជ្ញាមិនត្រមបង្កើតសង្គ្រាមក្នុងទីនោះទេ ។

បញ្ចតន្ត្រៈ

រឿងអាស័ក្សថ្លែងរឿងម្ដែច្រាំ

លោកវ៉ាយ-ប៊ុក ក្រមការ

ប្រែពីភាសាចាំង់មកជាខ្មែរ

(តម្រង)

រឿងទី ១៦

អារក្សពោលថា: បពិត្រមហាពជពិរ-ពិត្រមាដិត, មានទីក្រុងមួយ ឈ្មោះចន្ទ្រសេខរ (Chandrashekhar) ។ ប្រជាពលស្ដេចនៅទីក្រុងនេះគឺនាយពាណិជឈ្មោះរតន្ទត្ត (Ratandatt), គាត់មានបុត្រីម្នាក់នាមនាងអ៊ុនមទិនី (Un madini) ។ ដល់នាងមានវ័យតរុណីភាព, បិតាបានទៅក្រាបបង្គំទូលព្រះមហាក្សត្រថា:

"សូមទ្រង់ព្រះមេត្តាជ្រាស, ទូលបង្គំមានបុត្រីម្នាក់ នៅក្នុងគេហដ្ឋាន ។ បើព្រះករុណាទ្រង់សព្វព្រះរាជហឫទ័យនឹងបុត្រីទូលបង្គំ, សូមទ្រង់នាំនាងយកទៅចុះ, បើមិនដូច្នោះទេ ទូលបង្គំនឹងឲ្យទៅអ្នកឯទៀត" ។

ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ទូវាក់ចានាយពាណិជ, ទ្រង់ត្រាស់បង្គាប់ឲ្យអាមាត្យចាស់ដែលទំនុកព្រះទ័យ ៣ នាក់ ឲ្យទៅមើលបុត្រីនាយពាណិជ ហើយទ្រង់វិលត្រឡប់មកក្រាបទូលទ្រង់ឲ្យជ្រាបក្នុងរឿងនេះ ។ អាមាត្យដល់ចានទទួលព្រះរាជឧង្ការហើយក៏នាំគ្នាទៅ

កាន់តែហាង្ហានមាយាណាដ ហើយមានចិត្តត្រែតអាពន្ធ្រមាណដោយ
ឃើញកូនស្រីនាយពាណិជ ច្រកបដោយរូបធោមលោមតំណិស្រស់
បំព្រង គេអាចពោលបានថា លំអនាង់នោះគ្មីចាំងចែងដូចជាវស្មីចាលផ្លេ
ផ្សាយចេញពីបន្ទប់គេហាង្ហានដ៏ធំត ។ ចក្ខុនាង់ដូចជាកែកកាន់, សក់នាង
មានសភាពមូលអង្គាញ់ដូចជាពស់ញី, រោមចិញ្ចើមដូចជាខ្សែធ្នូ, ច្រមុះ
នាង់ដូចជាដំពុះសេក, ធ្មេញនាង់ដូចជាគជ្ឈង់សាមសឹបពីរជាក់តម្រៀប
គ្នា, បបូរមាត់នាង់មានសំបុរក្រហមឆ្អៅដូចជាសាច់កាលីបាស្យ (Calebasse
ប្រហែលជាឥឡឹក), កនាង់ដូចកន្ទាប, ដងខ្លួននាង់ដូចភ្លុងទិន, ដៃ-ដើង
នាង់ដូចបុប្ផាឈូកក្រពុំ ។ នាង់មានកំរ្តែដូចព្រះចន្ទ, សម្បុរដូច
ផ្កាចម្ប៉ា, ដំណើរដូចក្ងាន ហើយសព្ទសូរសំឡេង់ដូចជាបក្សាកោកិល
(Coucou indien, Cuculus Indiens ប្រហែលជាសត្វកវែក) ។ នាង
ទេវធីតានៅស្ថានសួគ៌ មានសេចក្តីងឿងឆ្ងល់ជាពន្ធឹកចំពោះសុក្រិតភាព
នៃរូបកង់កាយរបស់នាង់ តើល្អគ្មានភ្លោះ ល្អគន់ត្រមាំង់ល្អឆើត ។
ដល់ឃើញរូបនាង់មានសភាពល្អឯកដូចនេះ, ពួកអាមាត្យក៏ពោលថា:
“ បើស្ត្រីមួយមានលក្ខណៈរូបវិសេសថ្លៃថ្លាចូលទៅក្នុង់មហាច្រកាសាទនៃ
ព្រះមហាក្សត្រនៃយើង៍ មុខជាទ្រង់លុះក្នុង់កណ្តាប់ដៃស្ត្រីនេះមិនខាន,
ទ្រង់ទៅជាទាសករនាង់ ហើយភ្លេចលែង់នឹកនាដល់ព្រះពុទ្ធអាណាចក្រ
ព្រះអង្គ ព្រោះហេតុដូចនេះ ត្រូវតែយើង៍ទៅក្រាបទូលទ្រង់ជាកញ្ញានេះ
មានរូបកង់កាយអាក្រក់ មិនសមរម្យទៅតាមព្រះពុទ្ធចំណង់សោះឡើយ ។

ដល់សម្រែចសេចក្តីដូចនោះហើយ ពួកអាមាត្យក៏វិលត្រឡប់ទៅកាន់ព្រះបរមភជវិញ ក្រាបទូលព្រះមហាក្សត្រថា: "កញ្ញាដែលទូលបង្គំបានឃើញនោះ មិនសមរម្យគួរនឹងឲ្យធ្វើជាព្រះអគ្គមហេសីព្រះអង្គឡើយ" ។ ដល់ព្រះមហាក្សត្រទ្រង់ព្រះសណ្តាប់ទូវ៉ាតាអាមាត្យ, ទ្រង់ក៏បានចាត់អាមាត្យឲ្យទៅជូនដំណឹងនាយពាណិជថា មិនត្រមធ្វើព្រះពជសមវាសនឹងបុត្រីនោះទេ ។

ដល់វិលត្រឡប់ទៅគេហដ្ឋានវិញ, វត្តន្តភាយពាណិជក៏បានឲ្យបុត្រីខ្លួនរៀបវិវាហមង្គលការនឹងលោកចាលភទ្រ (Balbhadr), ជាអគ្គបញ្ជាការកងទ័ពព្រះមហាក្សត្រ ហើយនាងក៏រស់នៅជាមួយនឹងលោកមេទ័ពតមក ។

ខានកាលមួយថ្ងៃ, គេបានពោលថា ព្រះមហាក្សត្រទ្រង់ស្តេចយាងតាមផ្លូវជាមួយនឹងពួកសេនាគាហាន, ហើយនាងអ៊ុនមតិនីទៅលើភនហាលគេហដ្ឋានរបស់ខ្លួន នាងពាក់គ្រឿងអលង្ការ, ក្រឡេកទៅចំព្រះមហាក្សត្រ, ព្រះនេត្រទ្រង់នឹងចក្ខុនាងក៏ប៉ះគ្នា ។ ព្រះមហាក្សត្រទ្រង់ព្រះតម្រិះក្នុងព្រះទ័យថា នាងនេះជានាងធីតាព្រះអាទិទេព, ឬស្រីទេពអប្សរនៅស្ថានសួគ៌ឬជាកញ្ញាបុត្រីមនុស្សសាមញ្ញ ។ ក្នុងមួយរំពេចនោះសុភនាមរបស់នាង គឺលំអរូបនោមស្រស់ប្រិមប្រិយនាងចូលទៅធ្វើឲ្យព្រះទ័យព្រះមហាក្សត្រវង្វេងជាខ្លាំង ហើយទ្រង់ស្តេចយាងវិលត្រឡប់

ទៅព្រះបរមរាជវាំងវិញ ។ នាយទាហានចាំទ្វារព្រះបរមរាជវាំងជាន់
យើញព្រះភក្ត្រខ្ញុំស្រមៃកំដូចនោះ ក៏ក្រាបបង្គំទូលសួរខ្ញុំថា ខ្ញុំ
ព្រះអាពាធឬ? ។

ព្រះមហាក្សត្រខ្ញុំមានបន្ទូលទៅកាន់នាយចាំទ្វារថា: "ឥឡូវនេះ
យើងបានត្រាច់ទៅតាមផ្លូវ, យើងបានយើញស្ត្រីម្នាក់មានរូបឆោមលោម
ពណ៌ស្អាតនៅខាងកនហាលគេហដ្ឋានផ្ទះមួយ ។ យើងមិនអាចដឹង
បានថាជាស្រីទេពអប្សរស្ថានសួគ៌, ឬវិទ្ធានារី (fée) ឬ ស្ត្រីសាមញ្ញ
តែសុកនាមរបស់នាងបានធ្វើឱ្យយើងរំជួលចិត្តជាខ្លាំង ហើយយើងត្រូវ
ជាម្តាយពន់ពេក" ។

នាយឆ្មាំទ្វារក៏ក្រាបទូលព្រះមហាក្សត្រថា: "បពិត្រមហាក
សូមខ្ញុំព្រះមេត្តាជ្រាបទូលបង្គំ, ឯនារីនោះជាបុត្រីនាយពាណិជ
រតន្តុត្ត ហើយនាយពាណិជនេះបានរៀបវិវាហមង្គលការទីធំលោកជាល-
កខ្ញុ អគ្គបញ្ជាការកងទ័ពព្រះអង្គ" ។

ព្រះមហាក្សត្រមានបន្ទូលថា: "មនុស្សដែលយើងប្រើឱ្យទៅ
ពិនិត្យនាងនេះកុហកយើង" ហើយខ្ញុំត្រាស់បង្គាប់ទៅចុងទ្រ (chôbdar)
អ្នកទទួលភៀវឱ្យទៅហៅអាមាត្យនោះមក ។ នាយចុងទ្រ បានទទួល
ព្រះពាក្យរាត្រាម ក៏បានទៅអញ្ជើញអាមាត្យនោះ ។ ភាយណា
អាមាត្យមកដល់ចំពោះព្រះភក្ត្រព្រះមហាក្សត្រ ខ្ញុំមានព្រះបន្ទូលថា:

"យើងបានឲ្យអ្នកឯងទៅបំពេញបេសកកម្មមួយ, ហើយអ្នកឯងមិនបានប្រតិបត្តិតាមបំណងយើង, តែអ្នកឯងត្រឡប់ជាធ្វើកលៗបាយកងចិត្តពោលកុហកយើង អ្នកឯងបានមកប្រាប់យើងជាពាក្យមិនពិត ។ យើងបានឃើញឥឡូវនេះ នាងកញ្ញានោះនឹងក្បែកយើង ។ នាងនេះស្អាតល្អប្រមប្រិយជាសុក្រិត ហើយនាងនេះគ្មានស្ត្រីណាយកមកប្រៀបធៀបនឹងលំអបានឡើយ" ។

អាមាត្យក៏ក្រាបបង្គំទូលព្រះមហាក្សត្រថា: "ព្រះអង្គទ្រង់មានព្រះរាជឫទ្ធានោះពិត ។ តែសូមទ្រង់ព្រះសណ្ដាប់ទូលបង្គំអំពីហេតុដែលទូលបង្គំតាំងអស់គ្នាប្រែជាក្រាបបង្គំទូលព្រះអង្គថា នាងនេះគ្មានសមស័ក្តិឲ្យទេតនា ។ ទូលបង្គំតាំងអស់គ្នាបានគិតគ្នាថា បើស្ត្រីមានលំអយ៉ាងនេះចូលនៅក្នុងមហាប្រាសាទព្រះអង្គ ។ មុខជានៅក្នុងអំណាចស្ត្រីនេះហើយទ្រង់នឹងបោះបង់ចោលកិច្ចការរាជការក្នុងព្រះរាជអាណាចក្រ, ហើយរាជសម្បត្តិក៏នឹងវិនាសដោយហេតុនេះមិនខាន" ។

ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់នូវពាក្យអាមាត្យ, ទ្រង់មានព្រះបន្ទូលថា: "អ្នកឯងពោលនេះជាពាក្យប្រកបដោយវិចារណញ្ញាណពិត" ។ តែទ្រង់ព្រះតម្រិះពៅស្ត្រីនោះជានិរន្តរ៍យប់ថ្ងៃ ទ្រង់ផ្ទំមិនលក់, ព្រួយព្រះរាជហ្ឫទ័យពន់ពេក ។

តែបាលកទ្រមកដល់ ហើយក៏ធ្វើអញ្ជលីកម្មចំពោះព្រះមហាក្សត្រ, ហើយក្រាបបង្គំទូលថា: "បពិត្រមហាពាជ, ខ្ញុំបង្គំ ជាទាសាព្រះអង្គ; នាងអ៊ុនមទិនីជាទាសីព្រះអង្គ ។ ហេតុម្តេចក៏ព្រះអង្គទ្រង់ព្រួយព្រះពជ្ឈាទ័យដោយហេតុនាង? សូមទ្រង់ត្រាស់បង្គាប់ឲ្យនាងចូលមកគាល់ព្រះអង្គក៏ជាការស្រេច" ។

ព្រះមហាក្សត្រទ្រង់ព្រះសណ្តាប់អគ្គបញ្ញាការកដ៏ខ្ជាត ទ្រង់ព្រះក្រោធជាខ្លាំង ព្រោះជាអការណីយកិច្ចមិនគួរធ្វើ, មិនគួរហៅប្រពន្ធអ្នកដទៃមកជិតខ្លួន ។ ទ្រង់មានបន្ទូលថា ហេតុម្តេចក៏អ្នកឲ្យយើងធ្វើដូចនេះ? អ្នកឯងយល់ថាយើងគ្មានសាសនា, ចានជាឲ្យយើងប្រព្រឹត្តបាបអកុសលបែបនេះ? ។ ប្រពន្ធអ្នកដទៃខុសដូចជាមាតា ហើយកោតទ្យអ្នកដទៃមិនមានតម្លៃស្មើនឹងកក់ផង ។ ចូរអ្នកស្តាប់យើង។ ជាមនុស្សយល់តម្លៃអាត្មនអ្នកដទៃ, ដូចជាតម្លៃអាត្មនរបស់ខ្លួន" ។

បាលកទ្រក្រាបបង្គំទូលថា: "នាងនេះជាទាសីទូលបង្គំ ។ ដែលទូលបង្គំថ្វាយទៅព្រះអង្គ, នាងនេះមិនមែនជាប្រពន្ធអ្នកដទៃទេ" ។

ព្រះមហាក្សត្រត្រាស់ថា: "បើយើងប្រព្រឹត្តបែបនេះ, លោកមុខជាបន្ទោសយើងក្នុងកាលជាអនាគត ។ យើងមិនធ្វើដូចនេះទេ" ។

លោកបាលកទ្រក្រាបបង្គំទូលថា: "ទូលបង្គំនាំនាងនេះទៅក្រាគេហដ្ឋានទូលបង្គំ។ ធ្វើនាងនេះឲ្យទៅជានាងជាទាស នឹងនាំចូលមកថ្វាយព្រះអង្គ" ។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលថា: "បើអ្នកឯងធ្វើស្ត្រីសុចរិតទៅជានាងដកទង, យើងនឹងធ្វើទោសដល់អ្នកឯង" ។

ក្នុងពេលនោះ ព្រះមហាក្សត្រទ្រង់មានព្រះទ័យឈ្លក់ដោយកាមតណ្ហាទៅកាន់នាងអ៊ុនមទិនី, ក៏ទ្រង់ទិវង្គត ១០ ថ្ងៃក្រោយតមក ។

ចាលកទ្រក៏ទៅសួរលោកគ្រូរបៃសលោកថា: "ព្រះមហាក្សត្រជាចៅហ្វាយខ្ញុំបាទទិវង្គតហើយ ដោយទ្រង់ស្នេហានាងអ៊ុនមទិនី តើឲ្យខ្ញុំបាទធ្វើម្តេច, សូមលោកគ្រូមេត្តាឲ្យតុវទមកខ្ញុំបាទ" ។

លោកគ្រូតបទៅចាលកទ្រវិញថា: "ករណីយកិច្ចនៃទាសាត្រូវតែអនុវត្តតម្រូវការចៅហ្វាយនាយ" ។

លោកមេទ័ពបានស្តាប់ឮវុតុវទគ្រូ ក៏ទៅកាន់ព្រះមេរុដែលគេបូជាព្រះមហាក្សត្រ ។ ក្នុងពេលដែលគេរៀបចំព្រះសពក្នុងព្រះមេរុនោះ ចាលកទ្រក៏ដួតទឹកហើយសូត្រធម៌ ហើយដល់បូជាព្រះសព លោកគ្រាកឈរឡើង, បែរមុខទៅរកព្រះអាទិត្យ, ដៃថ្វាយបង្គំពោលថា:

"នុទេវ! ខ្ញុំសូមថាបើខ្ញុំត្រាច់រង្គាត់ក្នុងវដ្តសង្សារជាតិបណា ខ្ញុំសូមឲ្យបានបម្រើចៅហ្វាយតែមួយនេះ ហើយរំឭកគុណូបការដែលព្រះអង្គធ្វើចំពោះខ្ញុំ" ។ ដល់ពោលរួចស្រេច, ចាលកទ្រក៏ទន្ទឹងក្បាលលោតទៅក្នុងភ្លើង ។

នាងអ៊ុនមទិនី ដល់ភ្លឺថាស្វាមីនាងទួលមរណភាព, នាងក៏ចាន់ទៅ
សួរលោកគ្រូនាងថា: "លោកគ្រូ, តើករណីយកិច្ចស្ត្រីនោះយ៉ាងណា?"។

លោកគ្រូតបថា: "កិរិយាប្រកបដោយអតិជនភាព កាលណាកិរិយា
នោះមានចិត្តស្មោះស្ម័គ្រចំពោះបុរសណា ដែលបិតាមាតាបានប្រគល់ឲ្យជា
ស្វាមី ។ គេបានសរសេរទុកក្នុងសៀវភៅពិសិដ្ឋថា កិរិយាធ្វើឲ្យអាយុ
ជីវិតខ្លី បើនាងនេះអត់អាហារហើយប្រតិត្តធ្វើទុក្ខបុព្វបូជាយរបស់ខ្លួន
ក៏ពេលដែលស្វាមីនាងនៅរស់នៅឡើយ, ហើយដល់នាងនេះលះបង់
អាយុសំខារទៅ។ ក៏តក្កឹងស្ថានឧត ។ គេបានសរសេរថា បើស្វាមី
នោះមានសភាពអាក្រក់យ៉ាងណាក៏ដោយ, នាងនេះអាចយោងខ្លួនឯង
រួចពីទុគ្គតិភព ដោយបម្រើស្វាមីចិត្តស្មោះត្រង់ ហើយបើកិរិយាណាបាន
បំពេញករណីយកិច្ចហៅថា សតិ (Sati) ដំហានដែលនាងឈានទៅ
កាន់ទីប៉ាឆាមានតម្លៃស្មើគ្នានឹងពលីកម្មសេះមួយ ។ បើទុកជាស្ត្រីនោះ
មានគុណសម្បត្តិយ៉ាងណា ក៏មិនស្មើនឹងគុណធម៌ "សតិ" នេះសោះ
ឡើយ" ។

នាងអ៊ុនមទិនីបានស្តាប់ទូន្មានលោកគ្រូហើយ នាងបានឆ្លងទឹក
ធ្វើចិត្តស្ងប់ស្ងាត់ ហើយក៏បវិច្ចាគទ្រព្យសម្បត្តិសំខាន់ទៅពួកព្រាហ្មណ៍
ហើយនាងក៏អញ្ជើញទៅកាន់ព្រះមេរុ ហើយបែរមុខទៅខាងអរុណរះ

ពោលថា: "ទ្រង់ព្រះអាទិទេព! ខ្ញុំម្ចាស់ជាទាសីព្រះអង្គក្នុងដំរីភពអនាគត" ។ ដល់នាងពោលដូចនេះ នាងក៏ស្ទុះទៅអង្គុយលើព្រះមេរុនោះ រួចកាយនាងក៏ឆេះរលាយអស់គ្មានសល់ ។

ដល់អារក្សថ្លែងរឿងនេះចប់សព្វគ្រប់ហើយ ក៏ក្រាបទូលសួរមហាពជថា: "ទុមហាពជ! តើអ្នកណាមានគុណសម្បត្តិជាងគេ?"

ព្រះបាទពិរៈពិក្រមាដិតមានព្រះបន្ទូលថា: "ព្រះមហាក្សត្រ" ។

អារក្សក្រាបទូលសួរព្រះអង្គថា: "ព្រោះហេតុអ្វី?" ។

មហាពជមានព្រះបន្ទូលថា: "ព្រះមហាក្សត្របានលះបង់នូវនារីប្រពន្ធអគ្គបញ្ញាការកង់ចំពោះ ដែលគេយកមកថ្វាយព្រះអង្គហើយ ស៊ូលះបង់ជីវិត តែបានស្រោចស្រង់នូវព្រះពជកិត្តិយស ។ ករណីយកិច្ចអ្នកបំរើ គឺត្រូវតែធ្វើពលិកម្មនូវជីវិត ព្រោះចៅហ្វាយរបស់ខ្លួន ហើយករណីយកិច្ចរបស់ភរិយា គឺស៊ូមរណភាពនៅលើចំ៉ានៅជាមួយសេចក្តីស្នេហាចំពោះស្វាមី ព្រោះហេតុដូចនេះ បានជាព្រះមហាក្សត្រទ្រង់មានគុណសម្បត្តិជាងអ្នកឯទៀត" ។

អារក្សបានស្តាប់ព្រះបន្ទូលមហាពជ ក៏វិលត្រឡប់ទៅព្យរខ្លួនលើរុក្ខជាតិវិញ ហើយមហាពជបានទៅទាញយកអារក្សនោះមកវិញលើលើព្រះអង្សាហើយទ្រង់នាំទៅ ។

ចប់រឿងទី ១៦ មានរឿង ១៧ នៅទៀត ។

មាន ៣ ឈុត

លោក គង់-លឹម ធិស្សវិតសាលាគរុវិជ្ជា ភ្នំពេញ តែង

(តមក)

ឆាកទី ៦

ភតី-វន្ទី-វណ្ណនារី-ភតា

ភតី

ម៉ែ! លោកយាយៗគិតរៀបចំការលោកប៉ាខ្ញុំ ឲ្យមានប្រពន្ធទៀតឬ?។

វន្ទី

អើ អញគិតរៀបយ៉ាងនាប់ គឺរៀបក្នុងថ្ងៃស្អែកនេះឯង តើឯងចូលចិត្តឬទេ? ។

ភតី

ទេ លោកយាយអើយ! អាណិតតែខ្ញុំទៅ ខ្ញុំមិនអាចគាំទឹងចំអើម្តាយបុងមួយទៀតទេ ខ្ញុំស្អប់ណាស់ម្តាយបុងនោះ ខ្ញុំគ្មានចូលចិត្តបន្តិចទេ ។

វន្ទី

នែ! ចៅឯងក៏នោតអ្វីម៉្លេះ? ម្តាយបុងឯណាថា, ម្តាយបុងដែលយាយប្រុងនឹងរៀបការឲ្យប៉ាឯងនេះ ប្រសើរណាស់ ចិត្តគេល្អណាស់

ទៅ ! គេមិនមែនចិត្តប្រកបដោយទោស: មោហៈច្រើននោះទេ ។ គេអ្នកវៀនសូត្រចេះដឹងច្រើនជ្រុះណាស់ទៅ ! ។ គេរៀនជាប់ដល់ "សញ្ញាប័ត្រមធ្យមសិក្សា" ទៅហើយ ហើយគេបានធ្វើពិជគារមកប៉ន្មាំហើយ ។ ប្រាក់ខែគេតាំងពាន់ ។ ឥពុកម្តាយគេអ្នកមានសម្បត្តិសម្បើមណាស់ ។

រ៉ាគី

ទេ លោកយាយ ! អាណិតតែខ្ញុំតាំងពីនោក់នេះទៅ ! ខ្ញុំមិនព្រមឲ្យលោកចុះយកប្រពន្ធទៀតទេ ខ្ញុំសូមដាំបាយសូបំរើលោកចាំខ្ញុំ ។ ពីព្រោះម្តាយចុង សូមលោកយាយជ្រាប មុនដំបូងគេធ្វើល្អនឹងយើងណាស់ តែដល់ឃ្លាបន្តិចទៅ សឹងថាមួយឆ្នាំមិនខាន់ទេ ! គេមុខតែនឹងស្អប់ខ្ញុំតាំងពីនោក់នេះហើយ ។ តែកាលណាចាំខ្ញុំស្រឡាញ់គេមែនទែនទៅ គេធ្វើបាបខ្ញុំហើយ ខ្ញុំមុខតែនឹងទទួលសេចក្តីវេទនាដូចពាក្យចំនួញក្មេង នៅក្នុងសៀវភៅបឋមវិជ្ជាទេមរភាសាថា: "កូនអើយឥតម៉ែឥតមានគេថែ ដូចម៉ែផងខ្លួន" យ៉ាងដូច្នេះដាដែរ ។

រ៉ាជ្ញី

ទេ ! សំដីឯងតាំងនេះ មិនមែនជាការពិត ការមែននោះទេ ! រឿងដែលឯងនាំមកនិយាយនេះ គឺគេចេះតែភរយកពុម្ពជាក់ឲ្យពេញសៀវភៅទៅទេ ឯងកុំទៅជឿធ្វើអ្វី មិនមែនជារឿងពិតទេ, ឯរឿងពិតនោះ

តើដូចជាពាក្យគេថា: រឹងម្តាយចុង ខំនុកបុរង ឲ្យចេះរៀនសូត្រ ឲ្យ
ចានចេះដឹង ដោយចិត្តគេស្ងួត ឲ្យចេះរៀនសូត្រ ចានបុណ្យចាន
សំភ័ត្ត" យ៉ាងដូច្នេះជាដើម ទើបគេហៅថាពាក្យអ្នកចាស់ប្រៀងដៅ ។

វាគី

ទេ លោកយាយ! ខ្ញុំរៀនមកដល់ឆ្នាំហើយ ខ្ញុំប្រឡងយក
សញ្ញាប័ត្រមធ្យមសិក្សាក្នុងឆ្នាំនេះហើយ ខ្ញុំមិនដែលឃើញសៀវភៅខ្មែរ
ឯណា គេអធិប្បាយរឿង ដូចលោកយាយមានប្រសាសន៍ទេ ។
នែ វណ្ណាវី អូន! លោកយាយតិតរៀបចំប៉ាយើង ឲ្យមានប្រពន្ធមួយ
ទៀតក្នុងវេលាថ្ងៃស្អែកនេះហើយ! ។

វិណ្ណាវី

លោកយាយ! លោកយាយរៀបចាំខ្ញុំឲ្យមានប្រពន្ធទៀតឬ?
ខ្ញុំ ទេព្តាអើយ! ខ្ញុំមិនត្រូវចាំខ្ញុំយកប្រពន្ធទៀតទេ ។ សូមអត់ទោស
ទៅលោកយាយ! ខ្ញុំមិនឲ្យចាំខ្ញុំទៅរៀបអាពាហ៍ពិពាហ៍ទេ ខ្ញុំស្អប់
ណាស់ម៉្លេះយចុងនោះ ។

វ៉ាគី

យី! ហើយចុះវាម៉េចវា ក្មេងតាំងអស់ហ្នឹង! ឲ្យសុទ្ធតែមារមក
ជ្រែកខ្ញុំជាមួយហើយ, មើលចុះទេព្តាអើយ តាំងពីនាក់នេះ វាជ្រែក
ខ្ញុំហើយ វាធ្វើឲ្យខ្ញុំខ្មាសគេហើយក្នុងជាន់ហ្នឹង ។

រឿងនេះច្បាស់ជាម្តាយក្មេកអាហ្នឹងនាំញុះញង់ហើយ គ្មាននរណាទេ, បើមិនជួយចូកជួយថែវ កុំតែយកដើងកទឹក ។ បើដូច្នោះខ្ញុំទៅរកកំនុំអ្នកតាព័ន្ធង់ឲ្យស្តាលដែ គឺគ្មាននរណាទេ ច្បាស់ជាយាយសង្វិតហ្នឹងហើយ ដុតឲ្យខ្ញោចកេចឲ្យទៅ! មេកញ្ចាស់នេះចំហើយវាចង់ប្រកៀងទុកយកខ្លួនវាទៀតឬដូចម្តេចហ្នឹង ។ ក្តៅចិត្តណាស់ខ្ញុំរឿងហ្នឹង ។

ចប់ ឈុតទី ២

ឈុតធី ៣ ជាកធី ១

វន្ធី-តារា

វន្ធី

អ្នក! កូនយើងវាបានជាអត់ឮ ស្លាប់ប្រពន្ធទៅហើយ ខ្ញុំគិតពីចារណាវែងខ្លីទៅ ថាវាវេទនាណាស់, ចាយទឹកគ្មាននរណានឹងមើលខុសត្រូវឲ្យ, បើមានប្រពន្ធទៅ គ្រាន់នឹងប្រពន្ធមើលថែទាំរក្សា ។ បើវានៅតែម្នាក់ឯងដូច្នេះ ខ្ញុំយល់ឃើញថាវាពិបាកណាស់អ្នក! ។

តារា

ការត្រង់ហ្នឹង ខ្ញុំពុំហ៊ានអារកាត់ តាមតែចិត្តខ្ញុំទេ! បើអ្នកចង់ឲ្យការនេះបានសម្រេចធាប់ មានតែអ្នកហោះទៅមកសួរទៅ ។ យើងនឹងអាចធ្វើទៅតាមអំពើចិត្តរបស់យើងនោះមិនកើតទេ, មិនងាយទេអ្នក! ការនិមួយ ។ អស់ច្រើនណាស់ ។

វិធ្លី

ទេអ្នក! ត្រង់ការចំណាយប្រាក់នឹងការនោះ អ្នកកុំព្រួយឲ្យសោះ ស្រេចតែលើរូបខ្ញុំតាំងអស់ ។ ប៉ុន្តែខ្ញុំពិបាកចិត្តនឹងកូនហ្នឹងណាស់ ។ ខ្ញុំបានសួរវាមួយដងជាពីរដងរួចទៅហើយ វាចេះតែមានពាក្យប្រកែកប្រណាំងជាដរាប គឺវាមិនត្រមតាមពាក្យខ្ញុំសោះ, ខ្ញុំបានទៅជណ្តឹងកូនគេហួសទៅហើយ ចាំនឹងរៀបការកូនថ្ងៃស្អែកនេះ ខ្ញុំពិបាកចិត្តណាស់អ្នក ក្នុងពេលនេះ ។

គារ៉ា

ខ្! អ្នកបានទៅជណ្តឹងកូនគេទៅហើយ! ម្តេចក៏អ្នកប្រញាប់អ្វីម៉្លេះ ។

វិធ្លី

អ្នក! ចិត្តខ្ញុំមិនមែនទៅនឹងស្អប់ជូចជាចិត្តអ្នកទេ ។ គឺខ្ញុំមិនចង់ឲ្យកូនរបស់ខ្ញុំទៅពោះម៉ាយយូរ តែទុកយូរទៅក្រែងលោក្រមុំប្តូរមេម៉ាយស្រពោនឯណាមួយរត់ទៅនឹងទៅ ដាយឬ? នែអ្នក! ខ្ញុំចង់រៀបការយ៉ាងរហ័សក្នុងរវាងថ្ងៃស្អែកនេះ ។

គារ៉ា

ខ្ អ្នករៀបការក្នុងថ្ងៃស្អែកនេះ! ស្ងាប់ហើយក៏ប្រញាប់អ្វីម៉្លេះ សឹងតែស្ងោកកន្ទោងមិនទាន់! អ្នកធ្វើយ៉ាងដូច្នេះ ហាក់ដូចជាជ្រុលណាស់ ។

លោកផេង-ជ្រៃ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តមក)

បើកាលណាវាមកកូមខ្ញុំ (តាចាស់) ច្រើនដងជាខ្ញុំចូលវានៅក្រោមដើមល្វាន់នោះមិនខាន ។ ថ្ងៃមួយ ខ្ញុំឃើញវាអង្គុយតែម្នាក់ឯងត្រចោមក្បាលជង្គង់ មុខស្រងូតស្រងាត់នៅក្បែរដើមល្វាន់ ខ្ញុំបានទៅនិយាយលេងនឹងវា។ ឆ្លើយមកដូចមានតទៅនេះ :

« ខ្ញុំព្រួយអីម្ល៉ះទេ នាងក្រមុំឡាតួរទៅបានពីរឆ្នាំពីរខែហើយ, ច្រើនខែកន្លះហើយ នាងមិនដែលឲ្យដំណឹងអ៊ីសោះ ។ គេជាអ្នកមានទ្រព្យហើយ ឆ្លើមើចខ្លួនខ្ញុំជាអ្នកខ្មៅតិត គេភ្លេចខ្ញុំហើយ ។ ខ្ញុំចង់ដឹងកប៉ាល់ទៅច្រកទេសចាក់ឯងរកធ្វើការបំរើស្តេច ដើម្បីសន្សំឲ្យបានច្រើន កាលណាមានសម្បត្តិហើយ ខ្ញុំនឹងបានធ្វើជានាម៉ឺនធំក្នុងហួងរួចខ្ញុំសុំរៀបការជាមួយនឹងនាងវ៉ីស៊ីនី » ។

ខ្ញុំឆ្លើយថា: ឧសំឡាញ់! អ្នកឯងវែកឆ្ងាយច្រើនដងបានឯងថាប់អញថាខ្លួនមានជាតិមិនល្អ?- ។

– ម្តាយខ្ញុំប្រាប់ថាឯចឹង តែចំណែកខ្លួនខ្ញុំៗ មិនដឹងដូចម្តេចហៅថាជាតិទេ ខ្ញុំមិនយល់ថាខ្ញុំមានជាតិរោកជាងគេ ឬមួយគេមានជាតិថ្លៃជាងខ្ញុំនោះ ខ្ញុំមិនដឹងទេ ។

– នៅប្រទេសបារាំង ជាតិហ្នឹងហើយគេអាចហាមឃាត់ការពារជាការដ៏ធំ ។ កុំថាឡើយដល់ទៅធ្វើនាហ្នឹងធំ សូម្បីតែការងារអ្វីមួយគួរសមក៏ពុំបានផង ។

– អ្នកឯងបាននិយាយប្រាប់ខ្ញុំជារឿងដងហើយថា មនុស្សយ៉ាងណាក៏ដោយក៏គង់បានធ្វើដំណែរនៅប្រទេសបារាំង ។ អ្នកបានរាប់ឈ្មោះមនុស្សដែលមានល្បីឈ្មោះធំៗ នៅស្រុកបារាំង សុទ្ធតែចេញមកពីត្រកូលតូចៗ តែបានទៅជួយការពារផែនទឹកផែនដីឲ្យគង់វង្ស ឲ្យរុងរឿងដោយសារ ។ ឥឡូវអ្នកចង់បំភាន់ចិត្តក្លាហានរបស់ខ្ញុំ ។

– នែកូន! អញមិនឃាត់ឃាំងអ្នកទេ អញបាននិយាយនឹងឯងតាំងពីមុន តែរឿងហ្នឹងជាអតីតរឿង ឥឡូវនេះ វត្តចាំងឡាយផ្លាស់ប្តូរប្រែប្រួលអស់ហើយ របស់អ្វីក៏មានដំណែរដែរ នៅប្រទេសបារាំងសព្វថ្ងៃនេះ, ដីប្រទេសបារាំងត្រឡប់ទៅជាកេរ្តិ៍ខ្មែនៃក្រុមអភិជន ឬមួយជាចំណែកនៃពួកខ័ណ្ឌអស់លើង ។ ព្រះគុណផែនដីបីដូចជាព្រះអាទិត្យ មានតាហ្នឹងធំៗ នឹងពួកខ័ណ្ឌចោមរោមជុំវិញដូចពពក រកតែកូនស្តេចមួយនឹងអាចចាំងមកឲ្យត្រូវអ្នកឯងស្មើរតែពុំបានផង ។ តាំងដើមកំណើតមិនស្មើពិបាក

ចានជាគេយើញមានរឿងដូចអញចានច្រើបង់ឯង ។ ហើយវិជ្ជានឹង សក្តិយសចំរើនឡើងគ្រប់កន្លែង ដូចជាដីទើបនឹងកាន់ថ្មី មានដីជាតិសព្វ អន្លើ ។ តែស្តេចផែនដីដែលស្គាល់មនុស្ស ហើយចេះរៀសជាក់ឲ្យត្រូវ សមតាមវិជ្ជារៀងខ្លួននោះគ្រាណាស់ ។ តាមធម្មតា ស្តេចតែងតែ បណ្តោយតាមនាហ្មឹននឹងពួកទ័ពដែលនៅចោមរោមជានិច្ចកាល ។

– ចុះបើខ្ញុំរកអ្នកធំណាឲ្យជួយទំនុកបំរុងផងតុំចានឬ? ។

– បើចង់ឲ្យអ្នកធំទំនុកបំរុង ត្រូវបំរើតាមលោកចំត្តនឹងសេចក្តី សប្បាយរបស់គេ ។ អ្នកឯងនឿងតែមិនសំរេចដូចចិត្តចង់រហូត ព្រោះឯងមានជាតិមិនល្អ ហើយជាអ្នកសុចរិត ។

– ចុះបើខ្ញុំធ្វើការអ្វីប្រកបដោយចិត្តក្លាហាន ចាំសំដី នឿងក្នុងកិច្ច ទាំងពួង ទស្សាហ៍ធ្វើការងារ នឿងតែនឹងនឹងមិត្តសម្លាញ់ បើដូច្នេះ តើខ្ញុំ មិនគួរជាទីពាក់រកនៃនាហ្មឹនធំណាមួយ ដូចខ្ញុំបានយើញមានគេធ្វើឯចឹង ក្នុងរឿងពង្សាវតារពីបុរាណមក ដែលអ្នកបង្រៀនឲ្យខ្ញុំអាន ។

– ឧកូនសម្លាញ់! ក្នុងសម័យកាល្រកឹតនឹងរ៉ូម៉ាំងពីដើមឯចឹងមែន ព្រោះនាហ្មឹនធំមានសេចក្តីគោរពនូវអំពើល្អ ហើយយើងបានយើញ មនុស្សមានឈ្មោះល្បីតាំងហ្មង ច្រើនចេញមកពីត្រកូលពន្លឹ ហើយ អញមិនដែលដឹងថា អ្នកមានឈ្មោះល្បីណាមួយដុះដាលឡើងមកពីអ្នកធំ ជួយទំនុកបំរុង ។ អំពើជាកុសលតាំងឡាយ នៅប្រទេសចាក់ឯ កុំតែ

មានសេចក្តីសុចរិត មុខជានឹងត្រឡប់ទៅជាធម៌ដ៏ថោកទាបជ្រុតដូចមិនមានដូចជាអញបានជ្រាបឯងពីមុនឯចឹង ព្រះគុណាទ្រង់លើកអំពើទាំងឡាយខាងលើនេះ ឲ្យជាធម៌ដ៏ទុតគ្គទុត្តមម្តង។ ដោយសារទ្រង់បានប្រទះដោយព្រះអង្គឯង តែសព្វថ្ងៃនេះ ហានៈគួរកន្លែងការ គេសំចៃទុកសម្រាប់ឲ្យអ្នកណាមានជ្រាក់យកមកទិញ ។

- បើគ្មាននាហ្នឹងធំ ខ្ញុំទៅចូលដៃជាមួយនឹងពួកខ្ញុំ ។ ខ្ញុំគិតកេងឲ្យសមតាមគំនិតនឹងយោបល់នៃពួកនោះ ហើយខ្ញុំនឹងជាទីស្រឡាញ់ពេញចិត្តមិនខាន ។

- បើដូច្នោះ មានតែឯងគោងធ្វើដូចមនុស្សផងទាំងពួង ហើយឯងត្រូវលះបង់នូវចិត្តទៀងត្រង់ដើម្បីស្វែងសម្បត្តិ ។

- បើឯចឹងទេ! ខ្ញុំត្រូវស្វែងរកតែសេចក្តីទៀងត្រង់ សេចក្តីពិត ។

- បើដូច្នេះ គេមិនខាន់ទាំងមានចិត្តស្នេហាផង គេមុខជាត្រូវស្អប់មុនវិញហើយ ព្រោះពួកខ្ញុំមិនត្រូវការនឹងពាក្យពិតប៉ុន្មាន ។ មតិទាំងប៉ុន្មាន គឺគិតឲ្យសមតែនឹងមនុស្សចិត្តលោក ព្រោះវាគិតឲ្យបានខាងតែត្រួតពីលើគេ ។

- បើឯចឹង ខ្ញុំមិននៅតែរងទុក្ខវេទនាដូច្នេះហើយ បើត្រង់កន្លែងណាក៏ចូលមិនចុះសោះគ្រប់មុខគ្រប់ក្រសួង ។ ខ្ញុំមុខជាត្រូវនៅធ្វើការរកស៊ីតែម្នាក់ឯងក្នុងព្រៃឆ្ងាយពីវ័ស៊ីនីហើយ ។

ត្រង់នេះអាប្ញូលដកដង្ហើមធំ ។

— ចូរឯងយកព្រះជាម្ចាស់ទុកជាមេបា យកជាតំមនុស្សទុកជាខ្លួនឯង ។ ពួកក្រុមត្រកូលខ្ពង់ខ្ពស់ ពួកទ័ព ពួកពស្ដេចធ្វើការអ្វីតាមអំពើចិត្តនឹងតាមចំណង់របស់គេ ត្រូវបំរើគេជាញឹកញាយដោយចិត្តទុច្ចរិត ព្រះជាម្ចាស់នឹងជាតំមនុស្ស ត្រូវការពីយើងតែអំពើល្អ ។

“ចុះហេតុអីក៏ឯងចូលចិត្តចង់ឲ្យថ្កើង ប្លែកពីមនុស្សទាំងឡាយ? គំនិតដូច្នេះមិនមែនជាគំនិតដែលព្រះជាម្ចាស់បង្កើតទេ ដ្បិតថាបើអ្នកពាល់គ្នាមានគំនិតបែបនេះដូចគ្នា អ្នកទាំងនោះមុខជានឹងធ្វើចម្បាំងជាមួយប្រទេសជិតខាងពុំខាន ។ ត្រូវឯងចូលចិត្តបំពេញកិច្ចរបស់ខ្លួនដែលព្រះជាម្ចាស់បានដាក់ទុកឲ្យមក ចូរឯងត្រៃកអនឹងសំណាងខ្លួន គឺត្រង់ឥសនានេះហើយដែលនាំឲ្យឯងមានចិត្តស្មោះត្រង់ចំពោះខ្លួន ហើយមិនបង្ខំខ្លួនកុំដូចជានាហ៊ីនធំឲ្យគេខ្វះយកសេចក្ដីស្រួលពីអ្នកតូចទាប ហើយឲ្យអ្នកតូចវារខ្វះខ្វាសនៅរកខ្លួនដើម្បីធ្វើការចិញ្ចឹមជីវិត ។ ដើម្បីរស់នៅអ្នកត្រូវនៅកន្លែងប្រទេសមានទំនងដែលខ្លួនមិនបាច់ត្រូវការបំពាន់ មិនបាច់បញ្ឆោរ មិនបាច់ធ្វើខ្លួនឯងឲ្យថោកទាប កុំដូចជាអ្នកខ្វះ ស្វែងទៅឲ្យកន្លែងប្រទេសឧបត្ថម្ភ ។

(មានត)

សន្ទិសិទព្រះពោធិវង្ស ហ្សូត - តាត

ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ជាប្រធាននៃគណៈប្រតិភូខ្មែរ

ថ្វែងអំពីសមាជសាកលលើកទី ២ នៃពុទ្ធសាសនា

នៅទីក្រុងតូក្យូ (ប្រទេសជប៉ុន)

ពុទ្ធសាសនបណ្ឌិត្យ

(ត-ចប់)

កាលពីឆ្នាំ ១៩៥០, សម្តេចព្រះមហាសុមេធាធិបតី ជួន · ណាត ដោតញ្ញាណោ សង្ឃនាយក ជាប្រធាននៃគណៈប្រតិភូប្រទេសកម្ពុជា ចានទិមន្តទៅប្រជុំធ្វើសមាជនៅក្រុងកោលម្ប៊ូ នាប្រទេសលង្កា ក្នុងការបង្កើតពុទ្ធិកសមាគមពិភពលោក ក្នុងទុកាសនោះ សម្តេចបានថ្លែងពីកិច្ចការខាងព្រះពុទ្ធសាសនា ក្នុងប្រទេសកម្ពុជា ជូនអស់លោកទាំងឡាយឲ្យបានជ្រាប ១ លើកហួចហើយ ។

វេលានេះ យើងសូមថ្លែងម្តងទៀតយ៉ាងសង្ខេប ជូនអស់លោកទាំងឡាយ ដូចតទៅនេះ :

តាំងអំពីពេលក្រោយ ដែលសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកនិមន្តត្រឡប់ពីការប្រជុំនៅលង្កាទ្វីប ទៅកាន់ប្រទេសកម្ពុជាវិញ សម្តេចបានថ្លែងពីកិច្ចការប្រជុំនោះ ថ្វាយព្រះករុណា ជាម្ចាស់ជីវិតប្រទេស

កម្ពុជា ត្រមាំងបានថ្វែងឲ្យពលរដ្ឋខ្មែរ នៅក្នុងក្រុងនឹងខេត្តក្រៅបាន ស្គាប់បានយល់ នូវអង្គការណ៍នៃពុទ្ធិកសមាជយ៉ាងច្បាស់លាស់ ។

សេចក្តីថ្វែងរបស់សម្តេច នាំឲ្យពុទ្ធមាមកជនតាំងឡាយ មានចិត្តត្រេកអរ កើតសេចក្តីជ្រះថ្លាចំពោះព្រះពុទ្ធសាសនា កាន់តែមាំមួនឡើងជាងពីមុនទៅទៀត ។

ចំណែកពជរដ្ឋាភិបាល ដែលមានព្រះមហាក្សត្រីយ៍ជាប្រមុខ ក៏ខំប្រឹងដួយបំពេញកិច្ចការ ដែលទាក់ទងដល់ព្រះពុទ្ធសាសនា ឲ្យមានដំណើរដឿនទៅមុខដោយលំដាប់ ។

រីឯពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគ សម្រាប់ប្រទេសកម្ពុជាដែលជាសាខាផ្នែក១នៃពុទ្ធិកសមាគមពិភពលោក ក៏ពួកពុទ្ធបរិស័ទបានបង្កើតហើយ សមាគមនោះនឹងចាប់អនុវត្តតាំងពីចុងឆ្នាំ ១៩៥២ នេះតទៅ ។

មួយយ៉ាងទៀត, យើងយល់ថាអស់លោកតាំងឡាយគង់បានជ្រាបថា ប្រទេសកម្ពុជាសព្វថ្ងៃនេះ ជារដ្ឋមួយដ៏តូច មានប្រជាជនចំនួនជិត ៤ លាននាក់ប៉ុណ្ណោះ ។

ចំនួននេះ រាប់តាំងពីព្រះមហាក្សត្រីយ៍, ព្រះពជវង្សានុវង្ស ទឹងមន្ត្រីគ្រប់តំណែង រហូតដល់ប្រជាពលរដ្ឋ តាំងក្នុងក្រុងនឹងខេត្តក្រៅសុទ្ធតែជាអ្នកកាន់ព្រះពុទ្ធសាសនាទាំងអស់ ប៉ុន្តែមានសល់ខ្លះក៏មិនហួសពីចំនួន ១០០ នាក់ ដែលងាកចិត្តទៅកាន់សាសនាឯទៀត ស្ទើរ

តែកំចាំងគំនិតនៃប្រជាជនពុំអាចដឹងពាល់គ្នាថា មានខ្មែរក្រៅសាសន៍នៃព្រះពុទ្ធដូច្នោះក៏សឹងថាបាន ។

អំពីចំណួនវត្តអារាមនិងបព្វជិត

វត្តអារាមខាងព្រះពុទ្ធសាសនា, សព្វថ្ងៃនេះ មានចំនួន ២.៧៦៣ វត្ត ចំណែកខាងពួកបព្វជិតគាំងកុកគាំងសាមណេរ ដែលអាស្រ័យនៅក្នុងវត្ត ដែលមានចំនួនដូចខាងលើនេះ រួបរួមគាំងអស់ក្នុងឆ្នាំនេះមានចំនួន ៨០.២៣ ២ រូប, ប៉ុន្តែចំនួននេះមិនទៀងទៅជាដែលទេ ជួនកាលច្រើនជាង ជួនកាលតិចជាង ។

អំពីសាលារៀនបែកខាងព្រះពុទ្ធសាសនា ព្រះមហាក្សត្រិយ៍ជាបម្ងុំនៃប្រទេសកម្ពុជា ព្រមទាំងព្រះពជរជ្ញាកិបាលដែលជាអ្នកកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន បានបង្កើតឲ្យមានសាលារៀន បែកខាងព្រះពុទ្ធសាសនាតាំងពី ៣០ ឆ្នាំកន្លងទៅហើយ ដរាបដល់បច្ចុប្បន្ននេះ មានសាលារៀន ៣ ប្រភេទ គឺ:

១ — សាលាបាលីវង. — សាលានេះមានក្នុងក្រុងនឹងខែត្រក្រៅ ជាសាលាដែលប្រជាជនសុំបង្កើតឲ្យមានឡើង សម្រាប់ឲ្យកុំក្មេងសាមណេររៀនវេយ្យាករណ៍បាលី, រៀនប្រែពីបាលីជាខ្មែរ, រៀនតែងសេចក្តីខ្មែរ, រៀនលេខនព្វន្ត, រៀនពុទ្ធប្បវត្តិ ព្រមទាំងរៀនវិន័យផង ។ សាលានេះត្រូវរៀនកំណត់ ៣ ឆ្នាំ ត្រូវប្រឡងចេញពីសាលាក្នុងគារ

ឧបត្ថម្ភក៍របស់ពុទ្ធសាសនិកជន ។ សព្វថ្ងៃនេះមានចំនួន ៣០០ តំបន់, មានសិស្សដែលប្រឡងចេញក្នុងមួយឆ្នាំៗ ច្រើនជាង ២.០០០ រូប ដែលបានទទួលសញ្ញាប័ត្រសម្រាប់សាលាបាលីវេង ។

២ — សាលាបាលីជាន់ខ្ពស់ .— សាលានេះបង្កើតនៅក្នុងក្រុងភ្នំពេញ ជាសាលាបិតនៅក្នុងការឧបត្ថម្ភរបស់ពុទ្ធសាសនិកជន មានព្រះមហាក្សត្រីយ៍ជាប្រមុខ ។ សាលានេះជ្រើសរើសយកសិស្ស ដែលប្រឡងចេញពីសាលាបាលីវេងក្នុង ១ ឆ្នាំយក ១០០ រូបឲ្យចូលរៀន ។ សាលានេះសម្រាប់បង្រៀនបាលី, សំស្ក្រឹត, ភាសាបារាំង និងវិជ្ជាខាងសាសនាខ្លះ ខាងផ្លូវលោកខ្លះ ។ សិស្សរៀនគ្រប់ ៤ ឆ្នាំ ត្រូវប្រឡងចេញយកសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ។ សព្វថ្ងៃសាលានេះមានចំនួនសិស្សជាង ៤០០ រូប រួមទាំងសិស្សជាតិវៀតណាម និងសិស្សជាតិលាវ ដែលវង្គាកិច្ចលោកបញ្ជូនមកឲ្យរៀនផង ។

(ក្នុងបច្ចុប្បន្នកាលនេះ រដ្ឋាភិបាលមានព្រះមហាក្សត្រីយ៍ជាប្រមុខកំពុងតែរៀបចំពង្រីកសាលានេះឲ្យមាន ៣ ថ្នាក់ថែមទៀត គឺជ្រើសរើសយកសិស្សដែលប្រឡងចេញ មានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ហើយឲ្យរៀន ៣ ឆ្នាំតទៅទៀត ដើម្បីឲ្យពួកបព្វជិតជាសិស្សទាំងនោះបានចេះភាសាបរទេស មានភាសាបារាំងនិងអង់គ្លេសជាដើមឲ្យបាន

ម៉ាំមួន ជាហេតុនឹងឲ្យព្រះសង្ឃមានផ្លូវប្រែស្រ័យទាក់ទងព្រះពុទ្ធសាសនា នឹងនានាប្រទេសបានដោយស្រួល) ។

๓ - សាលាធម្មវិន័យ.- សាលានេះព្រះមហាក្សត្រិយ៍បានរួបរួមជាមួយនឹងរដ្ឋាភិបាល នឹងសម្តេចព្រះសង្ឃនាយក បានបង្កើតឲ្យមានឡើងក្នុងប្រទេសចាំងមូល សម្រាប់បង្រៀនធម៌នឹងវិន័យព្រះពុទ្ធ-សាសនា ។ តទៅអនាគត សាលានេះត្រូវឲ្យមានគ្រប់ភ្នក់អាចារ្យក្នុងប្រទេស កិក្ខុសាមណេរគ្រប់រូបត្រូវតែរៀនខានពុំបាន ។

ព្រះមហាក្សត្រិយ៍ដែលបង្កើតសាលានេះឡើង ដោយយើញថាមានប្រយោជន៍ធំធេលាយក្នុងព្រះពុទ្ធសាសនា ហើយឲ្យមានផលប្រសើរដល់ពលរដ្ឋក្នុងប្រទេសផង ដូចខាងក្រោមនេះ :

ក) ព្រះសង្ឃក្នុងប្រទេសចាំងមូលនឹងមានការចេះដឹងដូចគ្នា ។

ខ) កាលបើចេះដឹងដូចគ្នាហើយ ព្រះសង្ឃគ្រប់ភ្នក់នឹងមានអធ្យាស្រ័យគ្នាវគ្នា មិនវ្វែងគំនិតគ្នាខាងផ្លូវសីលធម៌តាមលំអានព្រះបរមពុទ្ធោវាទ ។

គ) កាលបើមានអធ្យាស្រ័យគ្នាវគ្នាហើយ នឹងនាំឲ្យព្រះសង្ឃមានសាមគ្គីធម៌ ចេះរួបរួមគ្នា ចេះស្រឡាញ់រាប់អានគ្នា តាមលំអានព្រះធម៌វិន័យ ។

ឃ) កាលបើព្រះសង្ឃគ្រប់វត្តមានការរួបរួមគ្នាហើយ ពួកគ្រហស្ថ ដែលនៅជុំវិញវត្តអារាម ក៏នឹងមានសាមគ្គីធម៌ក្នុងផ្លូវសីលធម៌ផងដែរ ។

ង) កាលបើបព្វជិតនឹងគ្រហស្ថមានសាមគ្គីធម៌ហើយ សេចក្តីសុខសាន្តក៏នឹងកើតមានឡើងដែរ, បើសេចក្តីសុខសាន្តកើតមានហើយ ប្រជាជនក្នុងប្រទេសនឹងអាចបំពេញមុខការគ្រប់យ៉ាង ឲ្យបានសម្រេច ឲ្យមានសេចក្តីចំរើនឡើងតាមធម៌បាន ទាំងព្រះពុទ្ធសាសនាក៏នឹងបានរុងរឿង ។

យើងបានរៀបរាប់ពីកិច្ចការខាងព្រះពុទ្ធសាសនាកុងកម្ពុជរដ្ឋ ជូនអស់លោកអ្នកទាំងឡាយឲ្យបានជ្រាប ដោយសង្ខេបត្រឹមតែប៉ុណ្ណេះ ។

ទីបំផុតនេះ យើងសូមគុណព្រះរតនត្រ័យគឺ: ព្រះពុទ្ធ, ព្រះធម៌ និងព្រះសង្ឃជួយអភិបាលរក្សាពុទ្ធិកសមាគមពិភពលោក របស់យើងទាំងអស់គ្នា នឹងអស់លោកទាំងឡាយឲ្យបានសេចក្តីសុខ - ចំរើន អស់កាលជាអង្វែងតរៀងទៅ ។

យើងសូមផ្សាយមេត្តាចិត្ត សូមសាកលលោកបានប្រកបដោយសុខភាពដ៏ខ្ជៀងខាត់ប្រាកដតាមផ្លូវធម៌ ។

លោកដុកទ័រគុណបល:បិយសេន:ម៉ាឡាល:សេកេរ:

ជាប្រធានពុទ្ធិកសមាគមនិកតលោក ថ្លែងក្នុងពេលសមាជសាកល លើកទី ២ នៃពុទ្ធសាសនា នៅទីក្រុងតូក្យូ (ប្រទេសជប៉ុន)

(តូក្យូ ២៥ កញ្ញា, ១៣ តុលា ១៩៥២)

ពុទ្ធសាសនបណ្ឌិត្យ

(តមក)

គួរសរសើរពន់ពេកចំពោះព្រះពុទ្ធសាសនា ដែលមានប្រវត្តិមិនដែលមន្ទិលសៅហ្មងដោយអកវណីយកិច្ចខាងគុណការសាសនា ទឹងការណែនាំបញ្ចុះបញ្ចូលហួសប្រមាណ, ទឹងការកំហែងយកច្បាក់ធ្វើមនុស្សឲ្យក្រែងលំបាក ឬដោយប្រើវិធីកំឡុចគំរាម ព្រមទាំងនយោបាយដ៏ខ្ពង់ខ្ពស់ ដើម្បីឲ្យបានអ្នកចូលច្រើន ។ ព្រះពុទ្ធសាសនាមិនដែលណែនាំឲ្យអ្នកដទៃចូលក្នុងសាសនាខ្លួនទៅទីប្រជុំជន ។ ដោយវិចារណញ្ញាណដូចនេះ ឃានជាលោកដុកទ័រកុង្ស្រសរសេរក្នុងសៀវភៅមួយនាម Buddhis, Its Essence and D veloppements ប្រែថា ព្រះពុទ្ធសាសនាចំពោះបុព្វហេតុនឹងសកម្មភាព ថា: មានអធិប្បវេសជាច្រើនដែលប្រវត្តិសាស្ត្រឃានចារឹកទុកថា ជាអធិប្បវេសកាចសាហាវ ដែលមានឃាឃានពាលទុច្ចរិត ព្រមទាំងនាក, សង្គ្រាមទឹងពួកចៅក្រមជាអ្នកគ្រប់គ្រង ។

ប្រទេសទាំងនេះ មិនមានប្រទេសណាមួយអាចស្មើតទៅបានបីសតវត្ស ។ ម្យ៉ាងវិញទៀត មានការចលនានៃពួកសម្ងួយាចកដែលស្ម័គ្រចិត្តរាប់អានខាងការក្រែកជាងមានគោគ្រែព្យ ប្រាន់ធ្វើសច្ចាធិដ្ឋានថា លែងប្រព្រឹត្តទុច្ចរិតទាំងពីយាជសត្វ, ពួកនេះបានយកពេលទំនាស់ទៅគិតកិច្ចការប្លែកអស្ចារ្យហើយក៏បង្កើតនៅក្នុងហាទយវត្ត ទូរប្រទេសប្រកបដោយអច្ឆរិយភាព ដែលមិនដែលមានអ្នកណាឃើញសោះឡើយ ពួកនោះច្រើនប្រមាទមើលងាយទូវត្តដែលគេទាំងអស់គ្នារាប់អាន ច្រើនពេញចិត្តទូវត្តដែលគេទាំងអស់គ្នាប្រមាទ, សភាពស្មុគស្មាញ ចិត្តសប្បុរស, ការពិចារណាដោយទៅស្រឡាំងស្រឡាត់ ។ តែត្រង់ណាដែលអធិប្រទេសទាំងនោះ ប្រកបដោយពលភាពកើតឡើងដោយចិត្តលោភ ស្អប់ខឹង សភាពមិនពិត ស្ថិតនៅបានត្រឹមតែពីរបីសតវត្ស, ការលះបង់ចោលទូវទុច្ចរិតសត្វយ៉ាង ប្រាន់ដឹកនាំព្រះសង្ឃខាងព្រះពុទ្ធសាសនាឲ្យទៅកាន់សេចក្តីចម្រើន តាំងពី ២.៥០០ ឆ្នាំមកហើយ ។

ការសិក្សាព្រះពុទ្ធសាសនា

ដោយយើងជាពួកពុទ្ធបរិស័ទ្ធ យើងមិនត្រូវភ្លេចថា ព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ទ្រង់បានត្រាស់បង្គាប់ ឲ្យយើងប្រុងប្រយ័ត្នរក្សាយទូវសិទ្ធិដ៏ប្រសើរនេះ ដើម្បីសេចក្តីល្អ ទំនឹងសេចក្តីសុខចំពោះសត្វលោកទាំងអស់ ព្រមទាំងសុខមង្គលដល់ទេវតា ទំនឹងមនុស្ស

ទាំងឡាយ ។ ទាំងនេះទាំងឲ្យយើងមានការណាយកចិត្តសំខាន់ ត្រង់ឲ្យស្គាល់ ជាក់ច្បាស់នូវខ្លួនយើងចំពោះលក្ខណៈនេះ មុនទើបផ្សាយទៅកាន់អ្នកដទៃ ។ ហើយត្រង់នេះ យើងត្រូវស្ថិតនៅចំបញ្ហាជំមួយ គឺការអប់រំបុត្រធីតារបស់យើង ។ ប្រវត្តិសាស្ត្របានបង្រៀនយើងថា ព្រះពុទ្ធសាសនាមានគុណូបការៈត្រង់ការសិក្សានៅទីណា ដែលព្រះពុទ្ធសាសនានេះផ្សាយទៅដល់ ព្រោះថាព្រះពុទ្ធសាសនាជាសាសនាប្រកបដោយស្មារតីស្វាធ្យាយ ហើយការសិក្សានេះជាផ្លូវសំខាន់មួយដែលនាំទៅកាន់អភិសម្ពោធ ។ នៅប្រទេសដែលកាន់ព្រះពុទ្ធសាសនា, វត្តអារាមទើបសាលាពាន គេទុកអាសនៈនេះជាសាលារៀនដែលបុត្រធីតាបានទៅសិក្សារៀនសូត្រ ដោយមានតាបិតាបង្រៀនហ៊ុំយ៉ាថ្លៃរៀន បន្តិចបន្តួច ឬមិនបង់សោះក៏បាន ។ ប្រទេសខ្លះ ដែលនៅកំពង់អនិស្សរភាពនៃបរជាតិមានការសំខាន់ចំពោះតលយុទ្ធ ក្នុងការបំផ្លាញបំបាត់នូវវប្បធម៌នៃប្រជាពលរដ្ឋប្រទេសនោះ ដើម្បីទើបធ្វើឲ្យប្រជាពលរដ្ឋស្ថិតនៅក្រោមបង្គាប់បញ្ជាខ្លួន ។

មធ្យោបាយសំខាន់ដែលត្រូវកើត ដើម្បីទើបសម្រេចនូវតុំណាងនោះ គឺកិច្ចត្រួតត្រាខាងការសិក្សា ។ ប្រទេសជាច្រើន មានវប្បធម៌ចាស់នៃប្រទេសនោះ បានកែប្រែវិធានការនៃការសិក្សា ដែលផ្តាច់អប់រំពីអតីតកាល យកវិធានការថ្មីមកដំឡូស ។ វិធានការនោះ មាន

មូលដ្ឋានចំពោះប្រពៃណីនិយម នឹងដំនឿដែលមានសភាពខុសពីចរិត
និស្ស័យនៃប្រជាកសិករដែលខ្វួនត្រួតត្រា ។ ទាំងនេះនាំឲ្យវិនាសសាប
សូន្យនៅសាលាវត្តដែលជាទីសម្រាប់ព្រោះសាបន្ធូរវប្បធម៌ ខាងព្រះពុទ្ធ-
សាសនា ។ វិធានការថ្មីក្នុងការសិក្សានេះ ចាន់ប្រគល់ឲ្យបេសកជន
បរជាតិយកមកបង្ហាត់បង្រៀន ដែលមានវត្ថុបំណងចង់ឲ្យអ្នករៀននោះ
ចូលទៅកាន់សាសនារបស់ខ្លួន ។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលចានជួយ
សោហ៊ុយរៀនក្នុងកិច្ចបញ្ជុះបញ្ចូលសាសនានេះ ដែលពួកបរជាតិ
យោសនាផ្សាយដោយឥតអៀនខ្មាសសោះឡើយ ។

សេចក្តីអាក្រក់ដែលកើតឡើង ដោយការប្រែប្រួលចំពោះបដិវត្ត
នេះមានភាពសម្បើមអស្ចារ្យ ។ ក្នុងប្រទេសចាំងប៉ុន្មាននៅទ្វីបអាស៊ី
ព្រះពុទ្ធសាសនាទទឹងវប្បធម៌ខាងព្រះពុទ្ធសាសនាអន់ថយន្ធូរតម្លៃ ជា
លំដាប់តមក ។ កិត្យានុភាពនៃព្រះសង្ឃដែលជាអ្នករក្សាទុកន្ធូរ
ព្រះធម៌ក្នុងរយៈវេលាជាច្រើនសតវត្ស ត្រូវអន់ថយធ្លើឲ្យប្រជាកសិកចាំង
នោះខ្លាយ ន្ធូរសេចក្តីរាប់អាននៃចៅអាវាសវត្ត ។ បុរសនឹងស្ត្រី
ចម្រើនវ័យវឌ្ឍនាការឡើង រស់នៅក្នុងកំសួលជាសម្ភារៈប្រយោជន៍
ត្រមចាំងប្រយោជន៍ផ្ទាល់ខ្លួន មានចិត្តគិតទៅការប្រឡងធ្លើការកន្ត្រាក
តែគួរឲ្យស្តាយពន់ពេក បុរសនឹងស្ត្រីចាំងនោះ ស្ថិតនៅក្នុងអវិជ្ជាចំពោះ
សាសនានឹងវប្បធម៌ ។ ដ៏ជូនដីតានៃបុរសស្ត្រីនោះពេញចិត្តហួសជីវិត

របស់ខ្លួនទៅទៀត ។ សាសនានឹងរីឯធម៌នេះ បានធ្វើឲ្យប្រទេសនាំង
នេះមានឈ្មោះល្បីល្បាញ, សម្បូណ៌ដោយគោគទ្រព្យ, សន្តិភាពហើយ
ទឹងការពេញចិត្តខាងក្នុងហួសវែ ។ តែគឺតំណាងល្អ ពេលដែល
បញ្ចុះបញ្ចូលឲ្យចូលកាន់សាសនានេះនឹងជិតផុតរលត់ជាអវសានកិច្ច ពិត
មែនតែកិច្ចនេះ មានធ្លើដោយណាក់បំពួនទោះគឺកន្លែងក្នុងកំព្រា, មន្ទីរ
ពេទ្យឃុលភេត, មន្ទីរពេទ្យ, ហើយនៅមានតិចណាស់ចំពោះសាលា-
រៀនជាច្រើន ។

នៅប្រទេសក្នុងទ្វីបអាស៊ីខ្លះ លទ្ធិជាតិនិយមដែលកើតឡើង
ជាថ្មី បានបញ្ជាក់ថា មានការសិក្សាព្រះពុទ្ធសាសនាបានផុះផុលឡើង
ជាថ្មី នៅប្រទេសខ្លះដូចជាកោះស៊ីឡង់, សភាពដែលកើតថ្មីនេះ បាន
សេចក្តីចម្រើនជាអនេកប្បការ ។ តែចំពោះការណ៍ខាងលើនេះ ត្រូវ
ព្យាយាមធ្វើដំណើរតទៅទៀត ព្រោះថាត្រូវតែមានសាលាអប់រំព្រះពុទ្ធ-
សាសនាជាច្រើន ប្រកបដោយសោភណាលក្ខណៈ ចំពោះកូនប្រុស
ហើយនឹងកូនស្រី ។ ពួកពុទ្ធសាសនិកជនមិនអាចនឹងមានចិត្តនៅស្ងៀម
បាន បើកូនប្រុសនឹងកូនស្រីនិមួយ ។ មិនមានមធ្យោបាយក្នុងកិច្ច
សិក្សា ដែលមានប្រយោជន៍ហើយ ត្រូវតែធ្វើគម្រប់ថ្នាក់-ជាន់ តាំងពី
ថ្នាក់កុមារដ្ឋានរហូតទៅដល់មហាវិទ្យាល័យ ។

(មានត)

តំណែលប្រឡងធម្មវិន័យ

នៅវត្តព្រះព្រហ្មវត្តន៍ ខេត្តសៀមរាប

ព្រះមហាឧត្តមរដ្ឋា កែ-អឿន (រ៉ាយប្បញ្ញោ)

រៀបរៀង

កាលពីថ្ងៃអង្គារ ១ កើតខែបុស្ស ឆ្នាំរោងឯកស័ក ព.ស. ២៤៨៥ ត្រូវនឹងថ្ងៃទី ១៦ ខែធ្នូ គ.ស. ១៩៤២ មានពិធីប្រឡងធម្មវិន័យចំពោះសិស្ស ២៥០ រូប ទាំងថ្នាក់ត្រី-ថ្នាក់ពេ ដែលបានសិក្សាក្នុងសាលាធម្មវិន័យវត្តនានាក្នុងខេត្តសៀមរាប គឺវត្តព្រះព្រហ្មវត្តន៍ ១ វត្តពាជបូពិ ១ វត្តកេស្សរពាម (ធម្មយុត្តិ) ១ ក្នុងស្រុកសៀមរាប, វត្តធម្មិស្សរពាម ១ វត្តព្រហ្មចន្ទ ១ វត្តមុនជ្ឈាន ១ ក្នុងស្រុកស្ងួនគម, វត្តព្រះពុទ្ធឯកពាជ្យ ១ ក្នុងស្រុកជីក្រែង, ទីដ៏វត្តធិបតី ១ ក្នុងស្រុកពួក ។ សិស្សទាំងនោះសុទ្ធតែជាសិស្សក្រៅអំពីសិស្សដែលសិក្សាបំពេញវិជ្ជាធម្មវិន័យក្នុងវត្តលោកគ្រូអនុគណ គ្រប់ស្រុកក្នុងខេត្តសៀមរាប ។ កាលប្រឡងក្នុងលើកនេះ ក្រសួងធម្មការ ទីដ៏ក្រសួងសម្តេចព្រះសង្ឃនាយក បញ្ជាការឲ្យប្រឡងរួបរួមក្នុងកន្លែងតែមួយ គឺយកវត្តព្រះព្រហ្មវត្តន៍ជាទីប្រឡង ។ ការប្រឡងនេះ អតិៈធិកនុទ្ធាវិគណាស់ ហាក់ដូចជាមានពិធីបុណ្យមួយដ៏អស្ចារ្យ ក្នុងព្រះពុទ្ធសាសនា, ក្នុងទីវត្តទាំងមូល

ប្រជាប់ដោយទង់ជាតិ, ទង់ព្រះពុទ្ធសាសនាធំ-តូច តាំងពីមុខសាលា-ធម្មវិន័យដរាបដល់ក្បោងទ្វារកំពែងក្រៅ: សាលាធម្មវិន័យ, សាលាបាលីថ្មី ក៏សុទ្ធតែតាក់តែងវិចិត្រចេតនា ដោយទង់ជាតិ ទង់សាសនាធំ-តូចជាលំអ, នៅសាលាធម្មសភាមានរៀបគ្រឿងសក្ការបូជា ថ្វាយចំពោះព្រះរតនត្រ័យ, នៅខាងដើមសាលាធម្មវិន័យទល់សាលាធម្មសភា មានមន្ទីរយោសនាការតូច ១ សម្រាប់ពុទ្ធបរិស័ទចូលសង្ខា, ក្នុងមន្ទីរនេះមានតាក់តែងដោយរូបថតជាច្រើន មានរូបថតកាលបុណ្យព្រះសារីរិកធាតុ ទល់ព្រះអរហន្តធាតុដង្ហែមកកាន់ព្រះរាជធានីភ្នំពេញជាដើម; នៅវេលាយប់ពិធីបុណ្យនេះមានទេស្សនីយភាពដ៏រុងរឿងដោយចង្កៀងអគ្គិសនី បញ្ចេញរស្មី ខៀវ, លឿង, ក្រហម, ស. គួរជាទីនាំហាទយវិត្តឲ្យត្រេកអរវាន់ពេក ។

កម្មវិធី

ថ្ងៃទី ១ .— ពិធីបុណ្យនេះ បានប្រារព្ធធ្វើតាំងពីល្ងាចថ្ងៃ ១៥ ខែធ្នូ ដោយមានពុទ្ធបរិស័ទ អញ្ជើញពីវត្តនានាឆ្ងាយជិតមកជួបជុំជាច្រើនជួយឧបត្ថម្ភកិច្ចការប្រឡងនេះ, ម៉ោង ៨ កន្លះទិវាព្រះមហាឧត្តមវិជ្ជាកែ-អឿន សំដែងធម៌ទេសនា ជាធម្មប្បដិសណ្ឋារៈ ។

ថ្ងៃទី ២.— គឺថ្ងៃ ១ កើតខែបុស្ស (១៦-១២-៥២) ម៉ោង ១១ កន្លះ ពុទ្ធបរិស័ទអង្គាសចង្ហាន់ដល់កិក្ខុ-សាមណេរ ។

មោ៉ង ៣ រសៀលជួបជុំសិស្សគាំងពីរថ្នាក់ ហៅឈ្មោះសិស្សឲ្យចាប់លេខតុរួច ទៅអង្គុយតាមកន្លែងតុនឹងចែកក្រដាសសម្រាប់ប្រឡង, សិស្សអង្គុយតាមកន្លែងរៀបរយហើយ, ពួកក្រុមប្រយោគមានព្រះសុមង្គលសីលាចារ្យជាអធិបតីបើកប្រយោគទី ១ គឺសាសនសុភាសិតគាំងថ្នាក់ត្រីទោ ដែលនៅក្នុងស្រោមបិទកាសល់១ ហើយសរសេរនៅក្តារធំ ឲ្យសិស្សតែង ។

សាសនសុភាសិតគាំងពីរថ្នាក់ដូចមានខាងក្រោមនេះ

ប្រយោគទី ១

សាសនសុភាសិត

ធម្មវិន័យថ្នាក់ត្រី

ថ្ងៃទី ១៦ ខែធ្នូ $\frac{២៤៨៥}{១៩៥២}$

បដិភាតុ តំ ភាយិ យំ ជញ្ញា អរិតមត្តនោ
ដឹងថាកម្មណាជាប្រយោជន៍ដល់ខ្លួន គួរប្រញាប់ប្រញាល់ធ្វើនូវកម្មនោះឲ្យបានមុនគេ ។

ចូរអធិប្បាយភាសិតនេះឲ្យសមហេតុផល ព្រមទាំងលើកយកភាសិតឯទៀតមកប្រកបជាមួយផង តែត្រូវបញ្ចូលសេចក្តីនៃភាសិតនោះឲ្យសមតាមសេចក្តីនៃភាសិតដើម ។

ប្រយោគទី ១

សាសនសុភាសិត

ធម្មវិនិយ ថ្នាក់ទោ

ថ្ងៃទី ១៦ ខែធ្នូ ๒๕๙๕ / ๑๙๕๒

ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស ឯសម្មការិ.ជា
សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ។

យសតែងចំរើនដល់អ្នកមានព្យាយាមរៀសរៀ ១, អ្នកមានស្មារតី ១, អ្នកមានការងារស្អាត ១, អ្នកមានប្រកបតិចិារណាចេះពិចារណាធ្វើ ១, អ្នកប្រុងប្រយ័ត្ន ១, អ្នកមានប្រកបតិរស់នៅដោយធម៌ ១, អ្នកមិនប្រមាទ ១ ។

ចូរអធិប្បាយភាសិតនេះឲ្យសមហេតុផល ព្រមទាំងលើកយកភាសិតឯទៀតមកប្រកបជាមួយផង តែត្រូវបញ្ចូលសេចក្តីនៃភាសិតនោះឲ្យសមតាមសេចក្តីនៃភាសិតដើម ។

មោ៌ង ៨ យប់ និមន្តព្រះវិនិយធរ ឯក-ញឹម ទីឆ៌ព្រះអាចារ្យ សុខ-សាន្ត សំដែងធម៌ទេសនាបុច្ឆា-វិសជ្ជនា, បន្ទាប់ពីនោះ ក្រុមកង ឯកទេសប្រគំតូរ្យតន្ត្រី ទីឆ៌ប្រឹងចំរៀងជាតិជាច្រើនបទ ។

ថ្ងៃទី ៣ - គឺថ្ងៃ ២ កើតខែបុស្ស (១៧-១២-៥២) មោ៌ង ៨ ព្រឹក ជួបជុំសិស្សដូចមុន អធិបតីបើកប្រយោគទី ២ គឺបញ្ហាវិនិយប្បញ្ញត្តិថ្នាក់ត្រី-ទោ ៥ ១ ឲ្យសិស្សសរសេរធ្វើយ, ដូចមានខាងក្រោមនេះ

ប្រយោគទី ២

បញ្ហាវិនយប្បញ្ញត្តិ

ធម្មវិន័យ ថ្នាក់ត្រី

ថ្ងៃទី ១៣ ខែធ្នូ ២៤៩៥ / ១៩៥២

๑.- ចុះពាក្យថាវិន័យ តើបានសេចក្តីដូចម្តេច? មានប៉ុន្មានយ៉ាង? អ្វីខ្លះ? អ្នកដែលប្រតិបត្តិតាមច្បាប់វិន័យ តើមានប្រយោជន៍ដូចម្តេច?

๒.- ចុះបាតិមោក្ខសំវរសីល តើសម្រេចដោយចេតសិកណា? បានជាសម្រេចដោយចេតសិកនោះ តើព្រោះហេតុអ្វី?

๓.- កិក្ខុទទួលស្លា, តែ, កាហ្វេ, ទុកឲ្យកន្ទុងពីរថ្ងៃទៅ ហើយយកវត្ថុដែលខ្ជូនទទួលទុកនោះមកធាន់ ដោយអាងថាខ្ជូនឈឺ តើត្រូវអាបត្តិអ្វី?

๔.- ចុះកិក្ខុប្រើប្រាស់ចីវរប្បច្ច័យ តើមានប្រយោជន៍ប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

๕.- កិក្ខុធ្វើវេជ្ជកម្ម តើគួរធ្វើដល់បុគ្គលបែបណា? មិនគួរធ្វើដល់បុគ្គលបែបណា? មានប៉ុន្មានយ៉ាង? អ្វីខ្លះ?

ប្រយោគទី ៤

បញ្ហាវិនយប្បញ្ញត្តិ

ធម្មវិន័យ ថ្ងាក់ទោ

ថ្ងៃទី ១៣ ខែធ្នូ ២៤៨៥ / ១៩៤២

១.- សិក្ខាបទដូចម្តេចខ្លះ ហៅថាសិក្ខាបទគ្រែជាតិមោក្ខ? ព្រះអង្គទ្រង់បញ្ញត្ត អនុញ្ញាតសិក្ខាបទតាំងនោះបន្ថែមមកទៀត តើទ្រង់យល់ឃើញប្រយោជន៍ដូចម្តេច? ចូរអធិប្បាយ ។

២.- តិក្ខុធាន់សាច់មិនបានពិចារណា ឲ្យស្គាល់ថាជាសាច់នេះសាច់នោះ តើត្រូវអាបត្តិអ្វី?

៣.- តិក្ខុប្រើប្រាស់ចីវរជាច់ចិទ្ធាំងអាយុ៥មិនដាច់ ហើយដើរទៅកាន់ស្រុក តើត្រូវអាបត្តិអ្វី?

៤. ចុះអតិសមាចារៈ បានសេចក្តីដូចម្តេច? ចូរអធិប្បាយ ។

៥.- សន្ធិវិហារិក មិនប្រកបដោយធម៌អ្វីខ្លះ ដែលឧបជ្ឈាយ៍បណ្តេញចេញពីវត្ត? បើឧបជ្ឈាយ៍បណ្តេញចេញហើយ តើត្រូវប្រព្រឹត្តដូចម្តេចទៀត ដើម្បីកុំឲ្យត្រូវអាបត្តិទុក្កដ? ។

មៅង៏ ៣ រសៀល អធិបតីបើកប្រយោគទី ៣ គឺធម្មប្បញ្ញាថ្ងាក់គ្រែ-ទោ ៥ ១ ឲ្យសិស្សសរសេរធ្វើយ, ដូចមានសេចក្តីខាងក្រោមនេះ

ព្រះយោគាវចរ ៣

ធម្មប្បញ្ហា

ធម្មវិនិយ ថ្នាក់ត្រី

ថ្ងៃទី ១៣ ខែធ្នូ ២៤៩៥ / ១៩៥២

១.- ចុះសទ្ធាបានសេចក្តីដូចម្តេច? ព្រោះហេតុអ្វីបានជាសទ្ធានេះបើមាននៅក្នុងក្រុមធម៌ណា សុទ្ធតែនៅក្នុងទី ១ ឬនៅខាងដើមក្រុមធម៌នោះជាដរាប? ចូរអធិប្បាយ ។

២.- បុណ្យទឹងបាប បើមិនបាច់កសាងសោះទេ តើឲ្យផលឬមិនឲ្យ? បើឲ្យផល តើឲ្យដូចម្តេច? ចូរអធិប្បាយ ។

៣.- អប្បមាទៈ ទឹងសតិ ធម៌ទាំងពីរនេះបានសេចក្តីដូចម្តេច? មានសេចក្តីប្លែកគ្នាដូចម្តេច?

៤.- ព្រះពុទ្ធសាសនា ដែលចំរើនរុងរឿងទៅបាន តើដោយអាស្រ័យបរិស័ទប៉ុន្មានពួក? អ្វីខ្លះ? បរិស័ទទាំងនោះ តើប្រកបដោយធម៌ប៉ុន្មានយ៉ាង? អ្វីខ្លះ?

៥.- ប្រទេសដូចម្តេចហៅថាបដិរូបទេស (ប្រទេសសមគួរ)? សំដៅយកប្រទេសណា? អ្នកនៅក្នុងប្រទេសនោះ តើមានសេចក្តីចំរើនដូចម្តេច?

ប្រយោគទី ៣

ធម្មប្បញ្ញា

ធម្មវិនិយ ថ្នាក់ទោ

ថ្ងៃទី ១៣ ខែធ្នូ ៤៤៩៥ / ១៩៥២

១.- វត្ថុទាំងពួងសុទ្ធតែមានគ្រឿងជូសខាត់ឲ្យស្អាតទាំងអស់, ចុះចិត្តរបស់មនុស្ស តើមានធម៌អ្វី ជាគ្រឿងជូសខាត់ឲ្យបរិសុទ្ធ? ហៅថាធម៌អ្វី? មានប៉ុន្មានយ៉ាង? អ្វីខ្លះ?

២.- ការសិក្សាក្នុងព្រះសាសនា តើចែកចេញទៅជាប៉ុន្មានថ្នាក់? អ្វីខ្លះ? អ្នកដែលកំពុងសិក្សា តើហៅថាអ្វី? មានប៉ុន្មានពួក? អ្នកដែលសិក្សារួចហើយ តើហៅថាអ្វី? មានប៉ុន្មានពួក?

៣.- វិញ្ញាណ ទឹងផស្សៈ ទាំងពីរនេះ តើកើតឡើងដោយអាស្រ័យអ្វី? មានកិច្ចផ្សេងគ្នាដូចម្តេច?

៤.- មេត្តានឹងករុណា ទាំងពីរនេះមានសេចក្តីផ្សេងគ្នាដូចម្តេច? ចូរអធិប្បាយ ។

៥.- កុសលធម៌ទាំងពួង ដែលបានចំរើន លុតលាស់ឡើងជាលំដាប់ តើអាស្រ័យមកពីធម៌អ្វីជាដំនួយ? ចូរអធិប្បាយធម៌នោះឲ្យល្អ ស្តាប់បានមកផង ។

មោ៉ង ៨ យប់ទិមន្តលោកគ្រូចៅអធិការ ពុធ-ប៊ុណ្ណ វត្តខេមរាភិ-
រាម (គណៈធម្មយុត្តិ) សំដែងធម៌ទេសនា ។

ថ្ងៃទី ៤.- គឺថ្ងៃ ៣ កើតខែបុស្ស (១៨-១២-៥២) មោ៉ង ៨ ព្រឹក
ជួបជុំសិស្សដូចមុន អធិបតីបើកប្រយោគទី ៤ គឺបញ្ហាពុទ្ធប្បវត្តិនិងប្រស្ន
អន្តរពុទ្ធប្បវត្តិថ្នាក់ត្រី-ចោ ៥ ១ ឲ្យសិស្សសរសេរធ្វើយ. ដូចមានខាង
ក្រោមនេះ

ប្រយោគទី ៤

បញ្ហាពុទ្ធប្បវត្តិ

ធម្មវិន័យ ថ្នាក់ត្រី

ថ្ងៃទី ១៨ ខែធ្នូ ២៤៩៥ / ១៩៥២

១.- ព្រះសម្មាសម្ពុទ្ធកាលបានត្រាស់ដឹងដំបូងថ្មីៗ តើព្រះអង្គ
ទ្រង់សំដែងធម៌អ្វី? ធម៌នោះបានសេចក្តីដូចម្តេច? ហៅថាវចនៈអ្វី? ទ្រង់
សំដែងឲ្យអ្នកណាស្តាប់?

២.- ព្រះពុទ្ធចាត់ជាបុព្វការីយ៉ាងវិសេស តើពុទ្ធមាមកជនត្រូវតប
បការៈដល់ព្រះអង្គដោយវិធីបែបណា? ចូរអធិប្បាយ ។

ញ.- ចុះព្រះអង្គទ្រង់ប្រសូតនៅឆ្នាំណា ? ថ្ងៃ - ខែ - ឆ្នាំណា ? រាប់តាំងពីនោះមកទល់នឹងថ្ងៃ - ខែ - ឆ្នាំដែលប្រឡងនេះ តើបានប៉ុន្មានឆ្នាំហើយ ?

៤ - ចុះព្រះអង្គស្តេចយាងទៅ ចូលបរិនិព្វានក្នុងឆ្នាំណា ? ទ្រង់យល់ឃើញដូចម្តេច បានជាស្តេចទៅចូលបរិនិព្វានកងឆ្នាំនោះ ?

៥.- ចុះលោកណាជាប្រធាន ក្នុងការចែកព្រះបរមសារីរិកធាតុ ? ចែកទៅនគរណាខ្លះ ? អ្នកមេចំណែកនោះ តើមានបានអ្វីនឹងគេដែរឬទេ ?

ព្រះយោគីធ ៤

ប្រស្នាអង្គពុទ្ធប្បវត្តិ

ធម្មវិន័យ ថ្នាក់ទោ

ថ្ងៃទី ១៨ ខែធ្នូ $\frac{\text{២៤៩៥}}{\text{១៩៥២}}$

១. ចុះអនុពុទ្ធ សំដៅយកលោកដែលមានសភាពដូចម្តេច ? ប្រុស ឬស្ត្រី គ្រហស្ថ ឬបព្វជិត ?

២.- បណ្តាសាវ័កទាំងអស់ តើសាវ័កណាដែលជាចំបងលើសាវ័កឯទៀតៗ ? សាវ័កនោះតើលោកមានសណ្តាប់ធ្នាប់នឹងធ្វើប្រយោជន៍ទុកដល់ពុទ្ធសាសនិកជនជាន់ក្រោយឲ្យយកតម្រាប់បានឬដូចម្តេចខ្លះ ?

๓.- ចុះព្រះអានន្ទលោកមានអគ្គដ្ឋានជាអ្វី? មានឯតទគ្គៈខាងអ្វី? លោកមានគុណចំណាប់ដល់ពុទ្ធសាសនិកជនដូចម្តេចខ្លះ?

๔.- ចុះអនុពុទ្ធអគ្គ្ឋណាមុនបរិនិព្វាន លោកបានសំដែងធម្មិថ្វាយព្រះបរមគ្រូស្តាប់? ធម៌ដែលលោកសំដែងនោះ តើមានសេចក្តីដូចម្តេច?

๕.- ចុះអគ្គសាវ័កទាំងពីរស្តាំឆ្វេង លោកមានគុណធម៌និងមានប្រយោជន៍ដល់យើងដូចម្តេចខ្លះ? ក្នុងពេលដែលគេនាំព្រះសារីរិកធាតុរបស់លោក មកដំកល់ទុកក្នុងប្រទេសយើងរាង ๖ ថ្ងៃ តើនាំបណ្តាលឲ្យទឹកចិត្តរបស់ពុទ្ធសាសនិកជនប្លែក ព្រមទាំងឲ្យមានគំនិតយល់ឃើញដូចម្តេចខ្លះ? ចូរអធិប្បាយ ។

ម៉ោង ๑๑ ប្រជុំពួកក្រុមមេប្រយោគ សិស្ស ឧបាសក ឧបាសិកា ចតុរបន្ទៅទីសាលាបាលីថ្នល់, សាលាធម្មវិន័យ, បរិវេណវិហារ, មន្ទីរយោសនាការ, ទុកជាអនុស្សាវរីយ៍ក្នុងពិធីបុណ្យប្រឡងធម្មវិន័យ ។

ម៉ោង ๑๑ កន្លះ អង្គាសចង្ហាន់ដល់កិកុសាមណេរជាង ๒๐๐ អង្គ ។

ម៉ោង ๓ រសៀលក្រុមមេប្រយោគ ចាត់ចែងធ្វើការប្រមូលសំណុំរឿងប្រឡងនឹងសេចក្តីកត់ហេតុផ្សេង ។ ព្រមទាំងចុះហត្ថលេខា ។

ម៉ោង ๗ ជួបជុំក្រុមមេប្រយោគ ទំនិសិស្សជាង ๒๐๐ រូប ព្រមទាំងឧបាសក ឧបាសិកាជាច្រើនមកុះករណាស់ណាន់តាន់តាប់ រួចសូត្រ

ធម៌ដ៏ឃ្លាតឆ្ងាយនូវសាសនាពុទ្ធសាសនាក្នុងការដល់ឥស្សរជនទាំងឡាយ មានលោក វរសេនីយ៍ត្រី ព្រមទាំងពួកពុទ្ធបរិស័ទទាំងឡាយ, បន្ទាប់ពីនោះ ព្រះមហាឧត្តមវិជ្ជា កែ អឿន ថ្លែងប្រាប់ពីសេចក្តីអំណាចដល់ឥស្សរជនទាំងឡាយ ព្រមទាំងពុទ្ធបរិស័ទដែលបានជួយឧបត្ថម្ភក្នុងការប្រឡងនេះ, ក្រោយមក ទើបលោកវរសេនីយ៍ត្រី ឈួន-ម្ទុលពេជ្រ ថ្លែងប្រាប់ពីតបមកវិញ នឹងជាសំគាល់ដល់ព្រះសង្ឃ ឲ្យចំរើនសូត្រធម្មវិន័យ នឹង ជាសំគាល់ដល់ប្រជាជនទាំងឡាយ ឲ្យមានសាមគ្គីធម៌ ។

ម៉ោង ៨ កន្លះ និមន្តព្រះអាចារ្យឈឺន-ញួន សំដែងធម៌ទេសនា។ ចប់ពួកគង់ឯកទេសលេងល្ខោនជាតិនឹងបញ្ចាំងកុនជូនបងប្អូនរួមជាតិមើល ។

ប្រឡងធម្មវិន័យកន្លងពេលនេះ ក្រសួងធម្មការនឹងក្រសួងសម្តេចព្រះសង្ឃនាយក ប្រទានតាំងអធិបតីមេប្រយោគដូចមានខាងក្រោមនេះ

១.— ព្រះសុមង្គលសីលាចារ្យមេគណ វត្តដំណាក់ ជាអធិបតី

២. ព្រះមហាឧត្តមវិជ្ជា កែ-អឿន ជួសអនុគណវត្តព្រះពុទ្ធរតនៈ ជាសមាជិក

៣.— ព្រះសុធម្មបញ្ញា ចាប ពៅ វត្តស្វាយ "

៤.— ព្រះវិន័យធរគណ ឈិត តឹក វត្តដំណាក់ "

៥.- លេខាធិការគណៈ ម៉ាន់ ឡាយ វត្តដំណាក់ ជាលេខាធិការ អធិបតីបានតាំងសមាជិក ១ ក្រុមទៀត ដើម្បីជួយត្រួតត្រាតាមបន្ទុប់ប្រឡង គឺ:

១.- ព្រះវិន័យធរអនុគណ ឯក ញឹម ជាសមាជិក

២.- ព្រះអាចារ្យ សុខ សាន្ត " "

៣.- ព្រះអាចារ្យ គោ-ឈួន " "

៤. ព្រះអាចារ្យ លិវ-លន " "

ក្នុងរោងបុណ្យប្រឡងធម្មវិន័យប៉ុន្មានថ្ងៃនេះ លោកវរសេនីយ៍ត្រី ឈួន-ម្ទុលពេជ្រ បានអំណោយរថយន្តធំ ៣ គឺរថយន្ត ២ សម្រាប់ដឹក ១ ស រថយន្ត ១ សម្រាប់ដឹកមនុស្សមកពីទីឆ្ងាយ ព្រមទាំងវត្តផ្សេងៗ មានអង្គរជាដើម ទឹងបរិច្ចាគហិរញ្ញវត្ថុ ១៥០០ រៀល, លោកយាយ យ៉ឹម ជាមាតាលោកវរសេនីយ៍ត្រី បានបរិច្ចាគហិរញ្ញវត្ថុ ៥០០ រៀល, សាលាខែត្តបានអំណោយរថយន្តធំ ១ សម្រាប់ដឹកមនុស្សទឹងវត្តផ្សេងៗ ដែរ ព្រមទាំងហិរញ្ញវត្ថុ ២០០ រៀល, ឧបាសក ឃ្លោក អេង ឧបាសិកា ផ្លុយ បរិច្ចាគហិរញ្ញវត្ថុ ៣០០០ រៀល, ជំគល់ទុក ឧបត្ថម្ភកិច្ចការប្រឡង ព្រមទាំងក្រសួងរាជការគ្រប់តម្លៃង ទឹងពុទ្ធបរិស័ទជិតឆ្ងាយ បានជួយឧបត្ថម្ភកិច្ចបុណ្យប្រឡងនេះ ជាបជល់រួចកិច្ចប្រឡង ។

របស់ក្រសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៨៧៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ម · ហង់ នាមឆាយា ហន្ទវិជ្ជា កើតឆ្នាំឆ្លូវ អាយុ ៤៨ វស្សា ២៦ ជាគ្រូសូត្រស្តាំ វត្ត · ឃុំ · ស្រុក · ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៧៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សន · ឡោម នាមឆាយា ឡោមសិរី កើតឆ្នាំថោះ អាយុ ២៣ វស្សា ៤ ជាចៅអធិការ វត្តសំសាន ឃុំកាលោ ស្រុក · ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៧៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យិម · ង៉ាក់ នាមឆាយា ញាណសភេ កើតឆ្នាំថោះ អាយុ ២៣ វស្សា ៤ ជាគ្រូសូត្រស្តាំ វត្ត ឃុំ · ស្រុក · ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៧៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ញែម · សាត នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំថោះ អាយុ ២៣ វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្ត · ឃុំ · ស្រុក · ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៧៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជោក ថោង នាមឆាយា ចន្ទសភេ កើតឆ្នាំកេង អាយុ ៣៤ វស្សា ១៣ ជាចៅអធិការវត្តកាលោ ឃុំ · ស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៨០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យស់-ថោង នាមធាយា គ្មាន .. កើតឆ្នាំវក អាយុ ៣០វស្សា ១១ ជាចៅអធិការវត្តបឹងខ្នោរ ឃុំស្វាយជូនកែវ ស្រុក-ខ្វែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៨១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស-ខេត នាមធាយា ធម្មសុវ័ណ្ណ កើតឆ្នាំឆ្លូវ អាយុ ២៥វស្សា ៥ ជាចៅអធិការវត្តចន្ទរង្សី ឃុំ-ស្រុក-ខ្វែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៨២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ តឹម-រឹង នាមធាយា គ្មាន... កើតឆ្នាំខាល អាយុ ២៤ វស្សា ៣ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ ស្រុក-ខ្វែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៨៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កែន-ចេង នាមធាយា ចន្ទជោត កើតឆ្នាំថោះ អាយុ ២៣ វស្សា ៣ ជាគ្រូសូត្រឆ្វេង វត្ត ឃុំ-ស្រុក-ខ្វែត្រដដែល ។


សញ្ញាប័ត្រលេខ ៨៨៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម សេង នាមធាយា ញាណជោត កើតឆ្នាំឆ្លូវ អាយុ ៣៧វស្សា ១២ ជាគ្រូសូត្រស្តាំ វត្តស្វាយជូនកែវ ឃុំ-ស្រុក-ខ្វែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៨៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាប ធិរ នាមធាយា ចន្ទសុវ័ណ្ណ កើតឆ្នាំរកា អាយុ ២៩ វស្សា ៩ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខ្វែត្រដដែល ។

(មានត)

ភគ្គមសទ្ទយា

ទស្សនាវដ្តី ផ្សាយដំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៥ ខែឧសភា លេខ ៥

ព.ស. ២៤៩៦ – គ.ស. ១៩៥៣



សេចក្តីជូនដំណឹងអំពីព្រះត្រៃបិដក

ពុទ្ធសាសនបណ្ឌិត្យ សូមប្រគេនទ័ព្ទជូនដំណឹង ។

ដូចតទៅមុន, ពុទ្ធសាសនបណ្ឌិត្យបានប្រគេន-ជូនដំណឹងម្តង ហើយថា សៀវភៅព្រះត្រៃបិដកពីភាគ ៣៧ ដល់ ៤៤ បុរាំងទឹង ចោះពុម្ពឲ្យហើយក្នុងឆ្នាំ ១៩៥៣ នេះឯង, ឥឡូវ យើងសូមបញ្ជាក់ថា សៀវភៅទាំងនោះ ដែលកំពុងចោះពុម្ពសព្វថ្ងៃ ទើងចោះឲ្យហើយស្រេច ចេញពីពេងពុម្ពត្រមៃ គ្នា កុងខែ តុលា ឬ វិច្ឆិកា ឆ្នាំ ១៩៥៣ នេះជាកំណត់ ។ ឯតម្លៃដូចតទៅនេះ :-

ភាគ ៣៧	ថ្លៃ ៦១វ.០០	ភាគ ៤១	ថ្លៃ ១០០វ, ០០
" ៣៨	" ៩២, ០០	" ៤២	" ៨៧, ០០
" ៣៩	" ៨២, ០០	" ៤៣	" ៧៥, ៨០
" ៤០	" ៧២, ០០	" ៤៤	" ៧២, ០០

បូកសរុប ៦៤១វ. ០០

ដូច្នេះ អស់លោក-អ្នកជាវជាន់មុនដែលមិនទាន់បានបង់ថ្លៃគ្រប់ចំនួននេះនៅឡើយក្តី អស់លោក-អ្នក ដែលត្រូវការជាវថ្មីក្តី សូមអញ្ជើញយកប្តូរតម្លៃទាំងនេះទៅបង់ជូនពុទ្ធសាសនបណ្ឌិត្យជាមុនឲ្យស្រេចដោយរួសរាន់ៗ

(តទៅក្រោយទាំងក្រោយ)



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— ទុលភបុគ្គល ២ ពួក	ព្រះមហា ប៉ាន់ - ដុន	៣២៣
— កថិនកថា (តមក)	ព្រះមហាឧត្តមវិជ្ជា កែ - អ៊ឿន ..	៣៣១
— មតិកនៃពួកពុទ្ធបរិស័ទ	លោក ប៊ូ - ប៊ូ	៣៣៤
ផ្នែកអក្សរសាស្ត្រ		
— ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ឹង - ប៊ម ...	៣៤៤
— រឿងសាមកុក (តមក)	ឧកញ៉ា ង្វ - កន	៣៥១
— រឿងអាវ៉ក្សថ្លែងរឿងម្តែជ្រាំ (តមក) ...	លោក វ៉ាយ - ប៊ុក	៣៦២
— រឿងស្ងាប់ព្រោះជាតិ (តមក)	លោក គង់ — លឹម	៣៦៩
— រឿងប៉ូលនឹងវីរ៉ស៊ីនី (តមក)	លោក ផេង - ជ្រើរ	៣៧៨
— សកម្មភាពនៃក្រុមដំនុំទំនៀមទម្លាប់ខ្មែរ ..	ពុទ្ធសាសនបណ្ឌិត្យ	៣៨៤
កំណត់ទឹកប្រវត្តិការណ៍		
— សុន្ទរកថាបណ្ឌិតម៉ាឡាឡ៊ះសេកេរៈថ្លែងក្នុង សមាជសាកលលើកទី ២ នៃពុទ្ធសាសនា	(តមក) ពុទ្ធសាសនបណ្ឌិត្យ...	៣៩២
— បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី(តមក)	ក្រសួងធម្មការ	៣៩៩

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដាវ ១៩២រ. ០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE — Pages

— Les deux Dullabhapuggala...	*Brah Mala Pann-Chun*....	323
— Kathinakatha (suite).....	*Brah Maha Ker-œurn*	331
— L'héritage des Bouddhistes	*M. Bou-Po*.	338

PARTIE LITTERAIRE

— Education morale (suite)....	*Brah maha Pœung-Pam*....	344
— Histoire de SAMŒOK (suite)..	*Oknha Nou-Kan*	351
— Les vingt cinq récits du Mauvais Génie (suite)	*M. Ray-Buc*	362
— Mort pour la patrie (suite) ...	*M. Kong-Lim*	369
— Paul et Virginie (suite)	*M. Phéng-Chrieu*	378
— Activité de la Commission des Mœurs et Coutumes	*Institut Bouddhique*	384

NOTES ET CHRONIQUES

— Discours du Dr. MALALASEKERA au 2e Congrés Mondial Bouddhique (suite).	*Institut Bouddhique*	392
— Nomination des nouveaux Chau-Adhikar suite	*Ministère des Cultes*	399

Prix d'abonnement annuel comprenant 12 numéros : 192800

ឧស្សកបុគ្គលពីរពួក

ព្រះមហា ប៉ាន់-ជុន វត្តលង្កា ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្វនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ កើត ខែបុស្ស ឆ្នាំជូតសំរឹទ្ធិស័ក

ព. ស. ២៤៩១ (១៤ - ១ - ៤៩)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

រតនត្តយំ វន្ទាមិ

សូមថ្វាយបង្គំនូវប្រជុំបីនៃព្រះរតន: គឺព្រះពុទ្ធ ព្រះធម៌ ទឹងព្រះសង្ឃ :ដោយសេចក្តីគោរព ។

បន្ទាប់អំពីនមស្សការដែលជាសេចក្តីខ្ញីនេះទៅ អាត្មាភាពសូមសំដែងធម្មទេសនា តាមសមគួរដល់កាលវេលា ។

កោ សាធវោ បតិត្តសាធុសប្បុរសទាំងឡាយ ! កុងទុកាសនេះ អាត្មាភាពសូមសំដែងអំពីបុគ្គលកម្រមានកងលោក ។ ពិតមែនតែកងសកលលោកមានមនុស្សច្រើនពាក់ជោយរយលាន ប៉ុន្តែបើនិយាយឲ្យឃើញច្បាស់តាមតម្រាស់នៃព្រះសម្មាសម្ពុទ្ធថា បុគ្គលពីរពួក កម្រមានទៅកងលោក ។

បុគ្គលពីរពួកនោះគឺ បុព្វការី ១, កតញ្ញូកតវេទី ១ ។ បុគ្គលណាបានចំនុកបម្រុងផ្តើមគេមុន នាំឲ្យគេបានលួតលាស់ដុះដាលឲ្យបានសេចក្តីសុខ បុគ្គលនោះឈ្មោះថា បុព្វការី ។ បុគ្គលណាបានទទួល

សេចក្តីទំនុកបម្រុងនោះ ហើយដឹងគុណមិនភ្លេច តែងនឹកឃើញរឿយ ៗ ជានិតបទបការគុណវិញ បុគ្គលនោះឈ្មោះថា កតញ្ញូកតវេទី ។ បើនិយាយដោយសង្ខារណៈ តាមតែបុគ្គលណាក៏ដោយដែលបានទំនុកបម្រុងគេ បុគ្គលនោះឈ្មោះថា បុព្វការី; អ្នកដែលដឹងគុណហើយបានតបស្នងសងគុណវិញ ពុំគោរពតិយត្រង្គើយ ហៅថា កតញ្ញូកតវេទី ។

ប៉ុន្តែបើនិយាយតាមន័យសំខាន ដែលតែងតែមាននោះ គឺ :-

មាតាបិតា ជាបុព្វការីរបស់កូនប្រុសកូនស្រី ព្រោះជាអ្នកចិញ្ចឹមថែរក្សា ទំនុកបម្រុងធ្លាប់ធ្លាំមកូនប្រុសកូនស្រី, កូនប្រុសកូនស្រីណាដឹងគុណហើយ បានតបនិតបការគុណចំពោះមាតាបិតា កូនប្រុសស្រីនោះឈ្មោះថា កតញ្ញូកតវេទី ។

ព្រះសម្ពុទ្ធ ជាសាស្តាចារ្យនៃយើង បានប្រកាសពាក្យប្រៀនប្រដៅដ៏ល្អថ្លៃវិសុទ្ធ ប្តូរដែលបានតែងតាំងគម្ពីរគ្មួនច្បាប់ដ៏ត្រឹមត្រូវច្បាប់ប្រយោជន៍ពិត ។ ទុកឲ្យយើងខាងក្រោយតាន់តាម ៗ មក អ្នកដែលដឿស្តាប់តាម បានរៀនសូត្រត្រិះរិះពិចារណា តាន់តាមទៅក៏កើតផលប្រយោជន៍បានដួបប្រទះសេចក្តីសុខសេចក្តីចំរើន តាមដាន់តាមថ្នាក់ ដោយសាសនាឬគម្ពីរគ្មួនច្បាប់ដ៏ល្អថ្លៃវិសុទ្ធត្រឹមត្រូវសំភ្លឹងនោះ ហើយជាអ្នកដឹងគុណបានតបបការគុណវិញ អ្នកនោះឈ្មោះថា កតញ្ញូកតវេទី ។

គ្រូអាចារ្យ ជាបុព្វការីរបស់សិស្ស ព្រោះជាអ្នកបង្ហាត់បង្រៀនឲ្យមានចំណេះវិជ្ជា, សិស្សដែលដឹងគុណហើយ ឃានតបទុបការគុណគ្រូអាចារ្យវិញ ហៅថា កតញ្ញូកតវេទី ។

ព្រះមហាក្សត្រ ជាបុព្វការី របស់ប្រជាជនក្នុងព្រះពុទ្ធអាណាចក្ររបស់ព្រះអង្គ, ប្រជាជនជាអ្នកមានស្មារតីគោរពព្រះពុទ្ធារបស់ខ្លួនដោយយល់ដាក់ថា: ខ្លួនបានសេចក្តីសុខចំរើន ដោយសារគ្រប់គ្រងផែនដី ដែលមានព្រះមហាក្សត្រជាប្រមុខ ក៏ពេញចិត្តព្រមប្រតិបត្តិតាមគន្ធង្ហប់សម្រាប់ផែនដី ប្រជាជននោះឈ្មោះថា កតញ្ញូកតវេទី ។

មាតាបិតា ធំជំ បុព្វធិតា

ក្នុងសកលលោកបើរាប់តែចំនួនមនុស្សដែលមានមាតាបិតា និងកូនប្រុស-ស្រីច្រើនជាអនេក មិនមែនក្រៃទេ ព្រោះមនុស្សក្នុងលោកដែលកើតតៗ គ្នាមកនោះមានច្រើនណាស់ តែដែលកម្រមាននោះគឺមិនសូវមានមាតាបិតា ដែលខំនុកបំរុងសង្រ្គោះបុត្រធីតាឲ្យបានត្រឹមត្រូវតាមបែបបទ ច្រើនតែសើសៗ ខ្វះៗ ត្រូវតែធំណោះ ខ្វះតែធំឈោះ មិនសូវគ្រប់ ព្រោះហេតុនោះបានជាថាកម្រមានក្នុងលោក ។

ឯបែបបទដែលមាតាបិតាត្រូវខំនុកបំរុងបុត្រធីតានោះមាន ៥ យ៉ាង គឺ:

១.- ចិញ្ចឹមបីបាច់ថែរក្សា ដោយមិនទំរើសកូនឲ្យធំចិត្ត, ឲ្យឡើងចាស

ការសិក្សាណា បើយើញកូនធ្វើអំពើអាក្រក់ប្រញាប់ប្រញាល់រវើរវាយ ហាមឃាត់ការពារកុំឲ្យ មិនធ្វេសប្រហែសបណ្តែតបណ្តោយ ប្រាប់ប្រដៅឲ្យស្គាល់ទោសទុច្ចរិត ឲ្យកូនខ្លាចរអាងចាលរួញគំនិតលែងធ្វើអំពើអាក្រក់តទៅទៀត ។

២.- ប្រៀនប្រដៅឲ្យកូនរៀនការងារសុចរិតប្រព្រឹត្តល្អតាមគន្ធឋមិ ប្រាប់ពន្យល់អំពីផលសុចរិតឲ្យច្បាស់លាស់ឲ្យកូនជឿស្តាប់ សិក្សាគំនិតពេញចិត្តស្រឡាញ់ផ្លូវល្អ; បង្ហាត់ឲ្យសិក្សាកន្លងផ្លូវសុចរិតតាំងតែពីតូចមក ។

៣: ប្រដៅកូនឲ្យចូលកន្លងការចេះដឹងគឺ: បង្ហាត់កូនឲ្យរៀនពាក្យ, រៀនគិត, រៀនបូក. រៀនដក, រៀនសង, រៀនគុណ. រៀនចែក, រៀនសរសេរ, រៀនគ្រោង, រៀនសូត្រស្មានការជាដើម ឲ្យចូលតាំងពីតូចមក មិនបណ្តែតបណ្តោយឲ្យកូនងាស់តាំងគំនិតប្រាជ្ញាក្នុងការចេះដឹង លុះដល់កូនមានអាយុចំរើនធំល្មមឲ្យរៀនចំណេះវិជ្ជាហើយ ចាន់ទុំកបំរុងកូនឲ្យរៀនសិល្បសាស្ត្រនឹងចំណេះវិជ្ជាផ្សេងៗ តាមសមគួរដល់កាលៈទេសៈ នឹងសម័យនិយម មិនបណ្តែតបណ្តោយឲ្យលង់ខ្ចៅ; ឲ្យកូនប្រុស-ស្រី រៀនអក្សរឲ្យចេះជាមុន រួចសឹមឲ្យរៀនចំណេះវិជ្ជាផ្សេងៗ តទៅទៀត ។

៤.- ត្រូវរៀបចំឲ្យមានផ្ទះសំបែងសមគួរដល់ពូជពង្សជាតិត្រកូលនឹងទ្រព្យធនជាដើម ត្រូវប្រុងប្រយ័ត្នកំចាត់ការរៀបចំឲ្យហួសហេតុ

ហួសខ្នាត ប្រយ័ត្នកុំឲ្យដាច់ទ្រព្យធន ដល់ថ្នាក់លក់ក្តើរ បញ្ចាំក្តើរ ឬជំពាក់បំណុលគេរុំកោះ ត្រាំត្រែងយូរទៅ ត្រូវរៀបចំកូនឲ្យល្មមសមគួរ ដល់ការគួរកុំឲ្យខាស់ខ្នាត ។

៥.- គិតលៃលកចំណាយទ្រព្យសម្បត្តិឲ្យរៀនចំណេះវិជ្ជា, ត្រូវទិញគ្រឿងប្រដាប់ឲ្យកូនគុបតែងខ្លួនខ្លះ . ឲ្យកូនមានសំលៀកបំពាក់គ្រាន់បើ មិនកំណាញ់សូរិតសូរញ ហួសប្រមាណ, ក្នុងវេលាចែកទ្រព្យសម្បត្តិឲ្យ ត្រូវចែកឲ្យហើយ ឲ្យតឹមត្រូវតាមលក្ខណៈច្បាប់ កុំទុកនូវាសឲ្យកូនឈ្លោះប្រកែកគ្នាទៅខាងមុខ ។

បែបបទដែលកូនប្រុស - ស្រីត្រូវគោរពបូជាមាតាបិតាមាន ៤ យ៉ាងគឺ:

១.- ថ្នាក់ថ្នមបីបាច់ញ៉ឹមរក្សាមាតាបិតាឲ្យពេញលេញ ឲ្យដូចកាលមាតាបិតាចិញ្ចឹមរក្សាខ្លួន បើបានលើសជាងនោះរឹងតែប្រសើរណាស់ ។

២.- ធ្វើការងារជំនួសមាតាបិតា មិនគោរតើយសោះអង្គុយបណ្តែតបណ្តោយ ឲ្យមាតាបិតាខ្ញើយហត់ដកបដល់ចាស់ជរា ទោះបីខ្លួនមានស្វាមីភរិយា បែកមុខការរបរឃ្លាតចេញពីមាតាបិតាទៅហើយ ក៏ត្រូវតែជួយធ្វើកិច្ចការងារ តាមកាលវេលាម្តងៗ ដែលនឹងខានពុំបាន ។

៣.- តាំងវង្សត្រកូលរបស់មាតាបិតា មិនធ្វើឲ្យអ្នកមានគុណកើតទុក្ខព្រួយចិត្តព្រោះខ្លួន ។

៤. គោរពប្រណិប័តន៍ ឲ្យល្អមមាតាបិតាពេញចិត្តឲ្យខ្លួនសម្បត្តិ
ក្តើសម្បាច់, ប្រយ័ត្នរក្សាខ្លួនក្តើអាកវដំណែលដែលមាតាបិតាចែកឲ្យ
មិនបំប្ចិចបំប្ចាញឲ្យខូចខាតភ្លាយវិនាសអន្តរាយបាត់បង់អសារតគារ ។

៥. លុះតតអំពីមាតាបិតាទៅ ត្រូវលើកសព សង្ការ ដោយគោរព
យ៉ាងផ្តិតផ្តង់ ធ្វើទក្ខិណានុប្បទានឧទ្ទិសផលញ្ញូនទៅរឿយៗ ។

មាតាបិតានឹងកូនប្រុស-ស្រីដែលបានបំពេញកិច្ចរបស់ខ្លួនតាមបែប
បទ ដូចបានថ្លែងមកខាងលើនេះ ទើបចាត់ជាបុព្វការី កតញ្ញូកតវេទី
ពេញខ្នាតត្រឹមត្រូវ ។

ព្រះសម្ពុទ្ធ ធំឯ ពុទ្ធសាសនិកជន

ព្រះសម្មាសម្ពុទ្ធជាមនុស្សអស្ចារ្យដែលហៅថា "អច្ឆរិយមនុស្ស,
ឬអស្ចារ្យមនុស្ស" ។ ព្រះអង្គមិនមែនមានរាល់កាលសម័យទេ យូរៗ
ម៉ើបមានម្តង ព្រោះហេតុនោះបានជាគ្រមានក្នុងលោក ។ ព្រះសម្ពុទ្ធ
ដែលជាគ្រូដើមរបស់យើង ទ្រង់មានព្រះទ័យពេញប្រៀបដោយសេចក្តី
អាណិតអាសូរ ទ្រង់ឲ្យសត្វលោករួចរដោះចាកទុក្ខ, កាលព្រះអង្គជិត
ចូលព្រះបរមនិព្វានទ្រង់ទំប៊ីន៍ត្រៀតប្រាន់ទុកផ្តាំថា "អ្នកទាំងឡាយ
ចូរកុំប្រហែសឆ្ងួស" ។ ដោយហេតុនេះ យើងជាពុទ្ធបរិស័ទ គួរប្រតិបត្តិ
តាន់តាមលំអានធម៌វិន័យ ពុទ្ធសាសនាដែលជាផ្លូវនាំយើងឲ្យបានដួប
ប្រទះសេចក្តីសុខត្រមាំងសេចក្តីចំរុងចំរើន យើងនឹងបានឈ្មោះថា
កតញ្ញូកតវេទី ចំពោះព្រះអង្គ ។

គ្រូអាចារ្យ និង សិស្ស

កុំប្រាប់និយាយដល់គ្រូអាចារ្យដែលបង្ហាត់បង្រៀនប្រដៅចំណេះវិជ្ជាគ្រប់យ៉ាងពិត។ សូម្បីតែលោកណាដែលកំពុងតែប្រៀនប្រដៅកូនសិស្ស ឬប្រៀនប្រដៅចំពោះធម៌ខឹងប្រាប់ត្រឹមត្រូវ សំគ្តិសិទ្ធិពិតប្រាកដ ដែលជាពាក្យមានប្រយោជន៍ គួរឱ្យគួរស្តាប់ យើងបានស្តាប់ពាក្យនោះចាំបានហើយយកមកត្រិះរិះប្រតិបត្តិតាមទៅតើតសេចក្តីសុខចំរើន លោកអ្នកនោះឈ្មោះថា បុព្វការីរបស់យើងដែរ, យើងត្រូវដឹងគុណ ហើយតបគុណកុំក្រេចឱ្យសោះ យើងទើបឈ្មោះថាកតញ្ញូកតវេទី ។

ព្រះមហាក្សត្រ និង ប្រជាជន

ព្រះមហាក្សត្រដែលទ្រង់គ្រប់គ្រងប្រទេសនីមួយ ។ ព្រះអង្គជាសម្មតិទេព "ទេពតាដោយសន្មត" ទ្រង់ព្រះនាមថា ព្រះរាជា ព្រោះទ្រង់ប្រកបដោយការសង្គ្រោះប្រជាជនដោយសង្គហធម៌ ៤ យ៉ាង គឺ:

១. - ប្រទានទេយ្យវត្ថុឱ្យ

២.- មានព្រះរាចាគួរចង់ឮចង់ស្តាប់

៣.- ទ្រង់ប្រព្រឹត្តអំពើជាប្រយោជន៍

៤.- ទ្រង់តាំងព្រះអង្គស្មើ។ គឺប្រើឫកពាឱ្យល្មមតេញ៉ាចិត្តប្រជាជន

ទ្រង់តម្រង់ប្រជាជនដោយទសពិធរាជធម៌ សម្រាប់ព្រះរាជាមាន ១០ យ៉ាង គឺ:

១.— ទ្រង់ឲ្យទាន

២.— រក្សាសីល ៥ ជានិច្ច

៣.— បំណាយព្រះពរជទ្រព្យទំនុកបំរុងប្រទេសជាតិ

៤.— មានព្រះទ័យទៀងត្រង់

៥.— មានព្រះកាយទន់ភ្លន់សុភាព

៦.— រក្សាទុច្ចោសថសីលតាមកំណត់កាល

៧.— មិនត្រេកអែរក្រោធធ្វើឲ្យប្រជាជនក្តៅក្រហាយ

៨.— មិនបៀតបៀនអ្នកដទៃ

៩.— មានសេចក្តីអត់ធន់

១០.— មិនបំពានលើធម៌លើច្បាប់ ។

ដោយហេតុនេះទើបទ្រង់ព្រះនាមថា បុព្វការីរបស់ប្រជាជន ។

ប្រជាជនដែលបានសេចក្តីសុខ ដោយសារការគ្រប់គ្រងរបស់ព្រះពជា, ប្រជាជនកាលបានដឹងយ៉ាងនេះហើយ ត្រូវជាអ្នកដឹងគុណតាំងចិត្តស្មូតត្រង់ចំពោះរាជការផែនដី ជួយយកអាសាផែនដី ដោយស្មោះស្ម័គ្រមានស្មារម៉ីភ័ក្តិ ចំពោះព្រះពជា ចំពោះរាជការផែនដី ឥតមានរំងិលរំងើយ ឬសង្ស័យរាជការ យ៉ាងនេះ ហៅថា កតញ្ញូកតវេទី ។

អាត្មាភាពសំដែងមកអំពីបុគ្គលវាក្រ ២ ពួក ដោយសង្ខេបតាមគួរដល់កាលវេលាខ្លី សន្មតថាចប់តែប៉ុណ្ណេះ ឯង ។

សូមសិរីសួស្តីមានដល់អស់ទេមរជនអ្នកស្តាប់គ្រប់ៗ គ្នា ។

រៀបទេសនា បុច្ឆា-វិសជ្ជនា

ព្រះមហាឧត្តមវិជ្ជា កែ-អឿន រិយប្បញ្ញោ

វត្តព្រះព្រហ្មវត្តន៍ ខេត្តសៀមរាប រៀបរៀង

ព្រះទេពសត្ថា សូរ-ហាយ ពិនិត្យកែសម្រួល

(តមក)

៥.– សាធុ សាធុ អនុត្តរៈ ម្នាលអនុត្តរៈ! អនុត្តរៈសំដែងអំពីអានិសង្ស ៥ ប្រការ របស់កិកូដែលបានក្រោលកបិនទឹងអនុមោទនាកឋិនានោះពេញហ៊ែត្រឹមត្រូវហើយ ចុះទាយកជាម្ចាស់ទាននោះ តើព្រះអនាវរណញ្ញាណទ្រង់សំដែងថាមានអានិសង្សដូចម្តេចខ្លះ? សូមលោកម្ចាស់វិសជ្ជនាមក ។

– ភន្តេ មហាវេរៈ បពិត្រព្រះមហាវេរដ៏ចំរើន! កឋិនទាននេះ កាលបើសំដែងនូវផលដោយកាលទានសោត ក៏ជាទក្ខិណាទានដ៏បរិបូណ៌ មានផលច្រើនពាំងអ្នកបរិភោគ ទឹងអ្នកជួយខ្វល់ខ្វាយសមដូចបរិយាយក្នុងទិគមគាថា សម្តេចព្រះមហាករុណាទ្រង់សំដែងក្នុងកាលទានសូត្រថា កាលេ ទទ្ទិ សប្បញ្ញោ ទទញ្ញូ តតមប្ជរា ប៉ុណ្ណោះជាដើមសេចក្តីថា បុគ្គលពាំងឲ្យអ្នកមានប្រាជ្ញា ដឹងនូវភាពនៃអ្នកប្រាជ្ញ សន្តានល្អ មានចិត្តកំណាញ់ប្រាសចាកហើយ។ បរិភោគនូវវត្ថុទានផ្សេងៗ តាមសមគួរដោយសភាពអនុគ្រោះនឹងបូជា, កាលេន ទិន្នំ អរិយេសុ

ฐิฉฺภาตเรสุ ตาทิสุ ตាយកអ្នកបរិច្ចាគទានបានឲ្យហើយដោយកាល ចំពោះព្រះអរិយបុគ្គលទាំង៤ឆ្ងាយ ដែលលោកឆ្ងាយអំពីកិលេសវិសេស ដោយសេចក្តីប្រតិបត្តិស្ងួតត្រង់ ពុំឃ្លើសឃ្លង់ដោយកាយវាចាចិត្ត សុបតិបត្តិស្មើ ពុំកកើកដោយអំណាចលោភធម៌ទាំង ៨ ប្រការ(๑); វិប្បសន្នមនា តស្ស វិបុលា ហោតិ ទក្ខិណា: ទានជាគ្រឿងចំរើនសម្បត្តិរបស់បណ្ឌិតជននោះ។ ជារបស់បុគ្គលមានចិត្តដ្រះថ្លា ហើយគួរជាទក្ខិណាបរិបូណ៌ដោយវិសេសជាវិបាកសម្បត្តិ, យេ ឧ តត្ថ អនុមោទន្តិ វេយ្យាវច្ចំ กរោន្តិ วา ជនដំពូកណាដែលពុំមែនជាម្ចាស់ទាន គ្រាន់តែជាអ្នកជួយអនុមោទនាត្រេកអរសាទរតាមទានគេនោះក្តី ឬមួយជនដំពូកណាជួយធ្វើវេយ្យាវច្ចកម្មខ្លះឆ្ងាយ យកកាយទៅបំរើកិច្ចការកបិនទាននោះក្តី, ឯ តេឥ ទក្ខិណា ฐิตา ទក្ខិណាទានក៏ពុំមានថយចុះ ព្រោះហេតុនោះ, តេបិ បុញ្ញស្ស ภาคิโน ជនទាំង៤ឆ្ងាយដែលត្រេកអរតាមការដូច្នេះ ជាអ្នកមានចំណែកបុណ្យដែលបានអនុមោទនាជាបត្តានុមោទនាមយៈនឹងវេយ្យាវច្ចមយៈនោះ, តស្មา ទេ អប្បដิวานปิตฺโต យตฺถ ทินฺนំ มหปฺผลំ ព្រោះហេតុដូច្នោះ សាធុជនជា

---

๑ លោភធម៌ ๘ ប្រការគឺ: ๑— លាភោ បានលាភ, ๒— អលาภោ ពំបានលាភ, ๓— យសោ មានយស, ๔— អយសោ ពំមានយស, ๕— សุขំ សេចក្តីសុខ, ๖— ទุกฺขំ សេចក្តីទុក្ខ, ๗— ธัมฺมา ការពិះពេញ, ๘— បสංสา សេចក្តីសរសើរ ។

បណ្ឌិតម៉ន្តគប្បីមានចិត្តរួញរាកំណាញ់ គប្បីឲ្យនូវទានចំពោះបដិគ្គាហក: ដែលគួរទទួលនូវទេយ្យទាននោះ ។ ទាននោះឯងមានផលានិសង្សជាកំយោភាពនៃគ្រលេងណាស់, ប្បញ្ញាធិ បរលោកស្មឹ បតិដ្ឋា ហោតិ បាណិធំ បុណ្យជាគ្រឿងចំរើនគួរជាទីពឹងពំនាក់នៃពួកសត្វកន្លងលោកទៅខាងមុខ ។ កបិនភាននេះ កាលបើសំដែងដោយគុណានិសង្សជាទក្ខិណាទានដ៏បរិបូណ៌សមដូចសេចក្តីកន្លងនិគមគាថា កន្លងកាលទានសូត្រដោយប្រការដូច្នេះ ។ ខ្ញុំបានវិសជ្ជនាមកអំពីអានិសង្សនៃកបិនទានរបស់ឥយកជាម្ចាស់ទាន ដោយសេចក្តីមង្ឃឹចប្បុ"ណ្ណោះ សូមទានជ្រាប ។

៦.— សាធុ សាធុ ម្នាលអនុត្តរៈ! ប្រស្នាដែលលោកម្ចាស់វិសជ្ជនាមកពិរោះណាស់ហើយ ខ្ញុំនឹងសួរតទៅទៀត ។ អើលោកម្ចាស់ ចុះហេតុអ្វីក៏ហៅថាកបិនទាន? នឹងហៅថា ចំរើនទាន វិញតុំបានទេឬ? សូមទិមន្តឆ្លើយពន្យល់សេចក្តីឲ្យសព្វគ្រប់មកមើល ។

– បពិត្រព្រះមហាវេរៈ! បានជាហៅថាកបិនទាននោះ បើនិយាយតាមបាលី កន្លងន្តកវិនិយ័ ក៏មានអាការនឹងពិពីច្រើនយ៉ាងណាស់ តែសូមសំដែងតែខ្លី ។ ល្មមស្តាប់ចូលចិត្តបាន, ដែលលោកហៅថាកបិនទានព្រោះទានដើម្បីកបិន ទាំងផលានិសង្សក៏មានពីរចំណែក គឺ: ឥយកអ្នកបរិច្ចាគនោះ ប្រកបដោយផលានិសង្សជាអសង្ខ្យេយ្យចំណែក ១, ខាងបដិគ្គាហក: គឺកិកអ្នកទទួលសោតក៏ប្រកបដោយអានិសង្ស ៥ ប្រការ

ដូចបានសំដែងមកហើយនោះចំណែក ១ ។ ហេតុនោះ ទាននេះទើប
បាននាមហៅថាកឋិនទាន ដោយទាយកថ្វាយនឹងធ្វើទាននេះ មាន
កម្មវិធីកំណត់ត្រឹម ២៩ ថ្ងៃ ក្នុងមួយឆ្នាំប៉ុណ្ណោះ គឺតាំងពី ១ រោចខែ
អស្សុជ ដរាបទៅដល់ថ្ងៃពេញបូណ៌មីខែកត្តិក ជាបំផុតខ្លួកបិន, បើ
ផុតអំពី ២៩ ថ្ងៃទៅហើយ ទោះទាយកទាយិកា មានទ្រព្យមានសម្បត្តិ
មានសទ្ធាប៉ុន្មាន។ ក៏មិនអាចធ្វើបានឡើយ ទាននេះទើបថាកឋិនទាន
ជាទានកម្រនឹងធ្វើបាន ។ ចំណែកខាងសង្ឃទានក្តី បាដបុគ្គលិកទានក្តី
ជាទានមិនមានកាលបរិច្ឆេទកំណត់កាលឡើយ, ស្រេចតែទាយកទាយិកា
មានសទ្ធាជ្រះថ្លា ចង់ធ្វើថ្ងៃណាវេលាណា ក៏ធ្វើបានមិនមានហាមឃាត
ដូចកឋិនទាននេះឡើយ, កឋិនទាននេះហើយ ជាទក្ខិណាទានប្រកប
ដោយកម្មវិធីដោយឡែកពិត ទាំងមានផលវិសេសលើសទានទាំងពួង
មួយឡែតកឋិនទាននេះ ជាការកម្រទាំងពីរយ៉ាងគឺទាយកអ្នកធ្វើ ប៉ើពុំ
ធ្វើវត្ថុសព្វបរិច្ចេកក្នុងការធ្វើ ក៏ទៅជាបាដបុគ្គលិកទានវិញ ពុំពេញជា
សង្ឃទាន ជាកឋិនទានឡើយ ចំណែកខាងបដិគ្គាហក: គឺកិកអក
ខ្ទួល កាលបើពុំចេះកុងកឋិនត្តារកិច្ច មិនចេះនូវបុព្វកិច្ច ៧ ប្រការមាន
កាត់-ដេរ-គក់-ជ្រលក់ជាដើម មិនចេះអានិសង្សទាំង ៥ ចាំនូវមាតិកា
ទាំង ៨ ក៏មិនអាចដើម្បីធ្វើកឋិនត្តារកិច្ចនោះបានឡើយ ។ មួយទៀត
ការដែលលោកអ្នកគ្រងមិនឡើងជាកឋិននោះ សំដែងដោយអនត្ថតាការ

២៤ប្រការ ដែលព្រះបរមសាស្តាទ្រង់បញ្ញត្តទុកកឋិនបិនទុន្ទុក: មានសេចក្តីពិស្តារណាស់ ពេលនេះគ្រាន់តែសំដែងពុទ្ធប្បញ្ញត្តិ ទាន់ពោសនៃវិត្រចីវរកបិនោះដោយសង្ខេប។ តាមន័យពុទ្ធប្បញ្ញត្តិថា "សំពត់ចីវរនោះបើពុំត្រូវខ្នាត ខាតមាត្រាតឹងឬវែងហួសប្រមាណជាងចីវរព្រះសុគតក៏ក្រាលមិនឡើងជាកបិន ១, វិត្រចីវរនោះពុំបានកាត់ជាកន្សែងតូចធំឲ្យជាបញ្ចខ័ណ្ឌ, សត្តខ័ណ្ឌ ឬជានវខ័ណ្ឌ, ឬក៏ជាឯកាទសខ័ណ្ឌមិនត្រូវតាមរបៀបកុនិន័យ ក៏ក្រាលមិនឡើងជាកបិន ១, សំពត់នោះជាយវែងមានផ្ការតាវល្លិ ឬជាផ្ទៃផ្សេង។ ក៏ក្រាលមិនឡើងជាកបិន ១, ចីវរនោះគឺតែជ្រលក់ដោយទឹករមៀត ទឹកល័ខ ព្រហ្មិតលឿងខ្ចីដូចសំបុកក្តុកដំរី ឬក្រហមដូចព័ណ៌ស្វាពុំ ឬដកគាំ ឬសម្បៅ ស្វាយ បៃតង ច្រាលដូចសម្បុរមាស ឬសម្បុរផ្កាចា ក៏ក្រាលមិនឡើងជាកបិនឡើយ ព្រោះហេតុនោះហើយបានជាកបិនទាននេះពិបាកធ្វើណាស់ លុះតែអ្នកជ្រាបធ្វើវិធ្វាសទើបធ្វើបាន; បពិត្រព្រះមហាវេរ! ខ្ញុំព្រះករុណាសំដែងមកដោយសង្ខេប។ ប៉ុណ្ណេះ សូមទានជ្រាប ។

៧.- ម្នាលអនុត្តរ! ខ្ញុំជ្រាបហើយ តែខ្ញុំចង់ដឹងថា ឯព័ណ៌ចីវរដែលព្រះសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យជ្រលក់ដោយទឹកអម្ពត់នោះតើមានប៉ុន្មានប្រការ គឺអ្វីខ្លះ? ព័ណ៌ជ្រលក់នោះ សំដៅយកព័ណ៌បែបណា ទើបសមគួរដល់សមណសារូបដែលអាចក្រាលឡើងជាកបិនបាន?; សូមសំដែងតាមច្បាប់ឲ្យច្បាស់មកមើល ។

- ภนฺเต เถร: ปติ[ต]ปฺปเถร: ฉ้อเรือน! ฉันใดเรือนนั้นพระสมฺ-
สมฺพุทฺธ [ทรงอนุญาตอุทกกรรมในวินัยนั้นว่ามี ๖ อย่าง]ดังพุทธดำรัสว่า
อนุชานามิ ภิกฺขเว น วนิตาย มูลรชนํ ขาทรชนํ ปตฺตรชนํ
ปุปฺผรชนํ ผลรชนํ มญฺชิฏฺฐิยา ! ตถาคตอนุญาต
ทึกเปล่า ๖ อย่าง คือทึกเปล่าเกิดแต่มะม่วง ๑ ทึกเปล่าเกิดแต่
ขนุน ๑ ทึกเปล่าเกิดแต่สมอ ๑ ทึกเปล่าเกิดแต่ฝรั่ง ๑ ทึก
เปล่าเกิดแต่ผัก ๑ ทึกเปล่าเกิดแต่ใบไม้ ๑; ทึกเปล่าทั้ง ๖ อย่าง
นี้ ตั้งไว้ด้วยกำลังเวลาอันสมควร ตกอย่างน้อยเปลี่ยนเปลี่ยนเป็น
เปลือกเปลี่ยนเป็นแก่น ได้ชื่อว่าทึกเปล่า ชื่อว่าทึกเปล่านั้น เป็นของ
สมควรแก่สมณสารูป เพื่อจะรับประเคนได้, ถ้าเมื่อวินัยนั้นมีชื่อว่าสมณสารูป มีกลิ่นเหม็น
เน่าเป็นต้นมาแล้วอย่างนี้ ทึกเปล่าอันเป็นของสมควรแก่สมณสารูปนั้นเป็นของ
ไม่สมควรแก่สมณสารูปนั้นเป็นของ ไม่ส

លោកម្ចាស់ សំពត់យ៉ាងណា ខ្លះ ដែលគួរធ្វើជាកឋិនបាន? សូមវិសជ្ជនា អធិប្បាយមកមើល ។

- បពិត្រព្រះមហាថេរ! ឯសំពត់គួរធ្វើជាកឋិនបាននោះ, ព្រះភគវន្ត មុនី ទ្រង់អនុញ្ញាតសំពត់ ៦ យ៉ាង គឺ ខោមំ សំពត់ដែលធ្វើពីសម្បកឈើ ១ កប្បាសិកំ សំពត់ដែលធ្វើពីប៉ុយកប្បាស ១ កោសេយ្យំ សំពត់ដែលធ្វើពីសូត្រ ១ កម្ពលំ សំពត់ដែលធ្វើពីកេមសត្វ (រៀវលែងតែធ្វើពីសក់មនុស្ស) ១ សាណំ សំពត់ដែលធ្វើពីសម្បកដែ្ន ១ ភង្គំ សំពត់ដែលធ្វើពីរបស់ទាំង ៥ យ៉ាងខាងដើមនេះ ដែលគេត្បាញចម្រុះលាយគ្នា ដូចយ៉ាងសំពត់សូត្រលាយអំបោះជាដើម ១ សំពត់មានជាតិទាំង ៦ យ៉ាងនេះ គោះជារបស់ថ្មីសុទ្ធក្តី, ដំនុំក្តី, ចាស់ក្តី, ជាសំពត់បង្សុកូលគឺទស់បានពីគំនរសម្រាមជាដើមក្តី, ជាសំពត់ទ្រាក់តាមកន្លែង (សំដៅយកវបស់គេចោលមិនចាប់ទិញក្តី, មានព័ណ៌ស្តុក, ព័ណ៌ស្បើងក្តី, ព័ណ៌ដទៃតែអាចលាងឲ្យជ្រះព័ណ៌នោះចេញបានក្តី, ហើយជាសំពត់លាតគ្នាន ផ្ចាក់ចង្កត់គ្នា ជាសំពត់ល្មមដេរតែត្រឹមស្បង់ ១ ប៉ុណ្ណោះ ក៏គួរធ្វើជាកឋិនបាន; បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណាបានវិសជ្ជនាមកអំពីសំពត់ដែលធ្វើជាកឋិនមានបាន ដូចសេចក្តីដែលបានសំដែងមកនេះ សូមមានជ្រាប ។

(មានត)

មតិកនៃពួកពុទ្ធបរិស័ទ

ធម្មទាយាទសូត្រ ក្នុងសុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក

ឃុនបណ្ឌាន្តរក្ស ប៊ុ - ប៉ូ

ក្រសួងពុទ្ធសាសនបណ្ឌិត្យជាអ្នកប្រែ

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះ ព្រះអង្គបានត្រាស់ហៅភិក្ខុទាំងឡាយមកថ្លែងថា :—

ម្នាលភិក្ខុទាំងឡាយ ! អ្នកទាំងឡាយចូរយកធម៌(១) របស់តថាគត ជាមតិក កុំយកអាមិស(២) ជាមតិកឡើយ តថាគតមានសេចក្តីអនុគ្រោះចំពោះអ្នកទាំងឡាយថា ធ្វើម្តេចហ្ន៎ ពួកសាវ័កបស់តថាគត គួរយកធម៌ជាមតិក កុំយកអាមិសជាមតិកឡើយ ។ ម្នាលភិក្ខុទាំងឡាយ ! បើអ្នកទាំងឡាយយកអាមិសជាមតិក មិនយកធម៌របស់តថាគតជាមតិកហើយ គង់តែមានអ្នកផងតិះដៀលអ្នកទាំងឡាយដោយហេតុនោះថា ពួកសាវ័ករបស់ព្រះសាស្តា សុទ្ធតែយកអាមិសជាមតិក មិនយកធម៌ជាមតិកទេ ។

---

១ ធម៌ជាមតិកនេះ បានដល់ធម៌ ២ យ៉ាងគឺ និប្បរិយាយធម៌ ធម៌ជាចំណែកខាងលោកុត្តរធម៌ទាំង ៩ មានសោតាបត្តិមគ្គជាដើម ១, បរិយាយធម៌ ធម៌ជាចំណែកខាងរបស់បុគ្គលដែលកំពុងប្រព្រឹត្តធ្វើសីល - សមាធិ - បញ្ញា ឬ ឈាន - សមាបត្តិ ដើម្បីដល់នូវព្រះនិព្វាន ១ ។

២ អាមិសជាមតិក បានដល់អាមិស ២ យ៉ាង គឺ និប្បរិយាយាមិស បានដល់បច្ច័យទាំង ៤ មានចីវរប្បច្ច័យជាដើម ១, បរិយាយាមិស បានដល់ទានវិសេស មានអន្នទានជាដើម ១ ។ អដ្ឋកថា ។

ទាំងតថាគត ត្រូវអ្នកផងតិះដៀលដោយហេតុនោះថា ពួកសាវ័កបស់ព្រះសាស្តា សុទ្ធតែយកអាមិសជាមត្តិក មិនយកធម៌ជាមត្តិកឡើយ ។ បើអ្នកទាំងឡាយយកធម៌បស់តថាគតជាមត្តិក មិនយកអាមិសជាមត្តិកទេ ក៏តែងមានអ្នកផងតិះដៀលអ្នកទាំងឡាយដោយហេតុនោះថា ពួកសាវ័កបស់ព្រះសាស្តា សុទ្ធតែយកធម៌ជាមត្តិក មិនមែនយកអាមិសជាមត្តិកទេ ។ ទាំងតថាគតក៏តែងមានអ្នកផងតិះដៀលដោយហេតុនោះថា ពួកសាវ័កបស់ព្រះសាស្តាសុទ្ធតែយកធម៌ជាមត្តិក មិនមែនយកអាមិសជាមត្តិកទេ ។ ម្នាលភិក្ខុទាំងឡាយ ! ព្រោះហេតុនោះ ក្នុងកាលឥឡូវនេះ អ្នកទាំងឡាយចូរយកធម៌បស់តថាគតជាមត្តិក កុំយកអាមិសជាមត្តិកឡើយ ។

ម្នាលភិក្ខុទាំងឡាយ ! ក្នុងទីនេះ តថាគតបរិភោគស្រេច ឃាត់លែងទទួលទៀត គ្រប់គ្រាន់ឆ្អែតស្កប់ស្កល់ គួរតាមប្រមាណហើយ ឯបិណ្ឌបាតបស់តថាគតនៅសល់ច្រើន ជារបស់គួរចាក់ចោល ។ គ្រានោះ មានភិក្ខុពីរូបមកដល់ កំពុងតែមានសេចក្តីស្រេកឃ្លានក្រៃបសង្កត់ជាខ្លាំង តថាគតក៏ប្រាប់ភិក្ខុទាំងពីរូបនោះថាតថាគតឈប់ឆាន់ហើយ ឯបិណ្ឌបាតបស់តថាគតនេះនៅសល់ច្រើន ជារបស់គួរចាក់ចោល បើអ្នកទាំងឡាយចង់ឆាន់ចូរឆាន់ចុះ បើអ្នកទាំងឡាយ មិនចង់ឆាន់ទេ តថាគតនឹងចាក់ចោលក្នុងទីដែលគ្មានស្មៅស្រស់ ឬនឹងចាក់ចោល

ក្នុងទឹកដែលគ្មានសត្វ ឥឡូវនេះ ។ បណ្តាកិកុតាំងពីរបូនោះកិកុ ๑ រូបគិតថា ព្រះដ៏មានព្រះភាគទ្រង់សោយស្រេចហើយ បិណ្ឌបាតរបស់ព្រះដ៏មានព្រះភាគនេះនៅសល់ច្រើន ជារបស់គួរចាក់ចោល បើពួកយើងនឹងមិនឆាន់ទេ ព្រះដ៏មានព្រះភាគនឹងចាក់ចោល ក្នុងទីគ្មានស្មៅស្រស់ ឬនឹងចាក់ចោលក្នុងទឹកដែលគ្មានសត្វឥឡូវនេះ ព្រះអង្គបានត្រាស់ប្តាប់ហើយថា ម្នាលកិកុតាំងឡាយ ! អ្នកតាំងឡាយចូរយកធម៌របស់តថាគតជាមគិក កុំយកអាមិសជាមគិកឡើយ ឯបិណ្ឌបាតនេះក៏ជាអាមិសមួយដែរ បើដូច្នោះមានតែអាត្មាអញកុំបរិភោគបិណ្ឌបាតនេះឡើយ នឹងធ្វើអត់សេចក្តីស្រេកឃ្លានេះ ឲ្យអស់មួយយប់មួយថ្ងៃ ។ កិកុនោះក៏មិនឆាន់បិណ្ឌបាតនោះ ហើយធ្វើអត់សេចក្តីស្រេកឃ្លានោះ អស់មួយយប់មួយថ្ងៃ ។ គ្រានោះ កិកុទីពីរគិតថា ព្រះដ៏មានព្រះភាគទ្រង់សោយស្រេចហើយ ឯបិណ្ឌបាតរបស់ព្រះដ៏មានព្រះភាគនេះ ក៏នៅសល់ច្រើន ជារបស់គួរចាក់ចោល បើពួកយើងមិនឆាន់ទេ ព្រះអង្គនឹងទ្រង់ចាក់ចោល ក្នុងទីដែលគ្មានស្មៅស្រស់ ឬនឹងចាក់ចោលក្នុងទឹកដែលគ្មានសត្វឥឡូវនេះ បើដូច្នោះមានតែអាត្មាអញគួរឆាន់ចង្ហាន់បិណ្ឌបាតនេះ ឲ្យបាត់សេចក្តីស្រេកឃ្លាន ទុំឲ្យបានប្រព្រឹត្តទៅអស់មួយយប់មួយថ្ងៃនេះឯង ។ កិកុនោះក៏ឆាន់ចង្ហាន់បិណ្ឌបាតនោះ បានបន្ទោបង់សេចក្តីស្រេកឃ្លាន បាត់អស់កម្លាំង ប្រព្រឹត្តទៅអស់មួយយប់

មួយថ្ងៃនោះឯង ។ ម្នាលកិកុំតាំងឡាយ! កិកុដែលឆាន់ចង្ហាន់បិណ្ឌបាតនោះ បានបន្ទោបង់សេចក្តីស្រែកឃ្វាន ជាត់អស់កម្ចាំង ប្រព្រឹត្តទៅអស់មួយយប់មួយថ្ងៃនោះឯងក៏មិនជាអ្វី ។ តែឯកិកុទីមួយនោះឯង គួរជាទីបូជាដោយវិសេសផង ជាទីសរសើរបស់តថាគតផង ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះថាការមិនឆាន់ចង្ហាន់បិណ្ឌបាតនោះ អាចធ្វើឲ្យកិកុនោះប្រព្រឹត្តទៅដើម្បីសេចក្តីជ្រុលច្រាលផង ដើម្បីសេចក្តីសន្ទោស ដើម្បីមានចិត្តផ្សេងផង ដើម្បីជាមនុស្សដែលគេចិញ្ចឹមងាយ ដើម្បីប្រារព្ធនូវព្យាយាមអស់កាលជ័យរអែងឆ្ងែឆ្ងាយទៅបាន ។ ម្នាលកិកុំតាំងឡាយ! ព្រោះហេតុនោះ ក្នុងធម្មវិន័យនេះ អ្នកតាំងឡាយចូរយកធម៌របស់តថាគតជាមគ្គ កុំយកអាមិសជាមគ្គឡើយ ។

ព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកានេះចប់ហើយ ក៏ស្តេចក្រោកចាកអាសនៈទ្រង់ពុទ្ធដំណើរទៅកាន់វិហារ ។

កាលព្រះអង្គទ្រង់ព្រះពុទ្ធដំណើរទៅមិនយូរប៉ុន្មាន ព្រះសារីបុត្រដ៏មានអាយុក៏ហៅកិកុំតាំងឡាយមកកន្លែងវេលានោះហើយប្រាប់ថា ម្នាលអាវុសោតាំងឡាយ! ព្រះសាស្តាទ្រង់មានសេចក្តីសូប៌ស្ងាត់ហើយ ពួកសាវ័កក្នុងសាសនានេះមិនហាត់ធ្វើនូវវិវេក មិនលះបង់នូវពួកធម៌ដែលព្រះសាស្តាទ្រង់ត្រាស់ឲ្យលះបង់ ចែរទៅជាអ្នកប្រព្រឹត្តល្មោកច្រែន ជាអ្នកខាន់សាសនាជូរៗ នាំអាទិឲ្យប្រព្រឹត្តទន្ទឹម ជាអ្នកជាក់ធុរៈកន្លងវិវេក

គឺមិនបំពេញកិច្ចក្នុងព្រះនិព្វាន ។ ម្នាលអាវុសោទាំងឡាយ ! បណ្តាភិក្ខុទាំងនោះ ភិក្ខុជាថេរៈក្តី ជាមជ្ឈិមក្តី ជានវកៈក្តី នឹងមានគតិនឹងដឿលដោយហេតុ ៣ យ៉ាង គឺ :

๑ - ព្រះសាស្តាទ្រង់មានសេចក្តីសូប់ស្ងាត់ហើយ តែមានពួកសាវ័កមិនហាត់ធ្វើនូវវិវេក ។

๒ - ពួកសាវ័កមិនលះបង់នូវធម៌ ដែលព្រះសាស្តាទ្រង់សំដែងប្រាប់ឲ្យលះបង់ ។

๓ - ពួកសាវកជាអ្នកប្រព្រឹត្តល្មោកច្រើន ជាអ្នកកាន់ (សាសនា) ធូរៗ នាំអាទិព្រហ្មចរិយប្រព្រឹត្តទន្ទាប ជាអ្នកជាក់ធុរៈក្នុងវិវេក ។

ម្នាលអាវុសោទាំងឡាយ ! ព្រះសាស្តាទ្រង់មានសេចក្តីសូប់ស្ងាត់ហើយ ពួកសាវ័កក៏សិក្សាតាមនូវវិវេកផង លះបង់នូវពួកធម៌ដែលព្រះសាស្តាទ្រង់សំដែងប្រាប់ឲ្យលះបង់ផង មិនជាអ្នកប្រព្រឹត្តល្មោកច្រើនផង មិនកាន់ (សាសនា) ធូរៗ ផង មិនជាក់ធុរៈក្នុងការប្រព្រឹត្តិទន្ទាបផង ជាប្រធានក្នុងវិវេកធម៌គឺព្រះនិព្វានផង ។ ម្នាលអាវុសោទាំងឡាយ ! បណ្តាភិក្ខុទាំងនោះ ភិក្ខុជាថេរៈក្តី ជាមជ្ឈិមក្តី ជានវកៈក្តី រមែងមានអ្នកផងសរសើរដោយហេតុ ៣ យ៉ាង គឺ

๑ - ព្រះសាស្តាទ្រង់មានសេចក្តីសូប់ស្ងាត់ហើយ ទាំងពួកសាវ័កសិក្សាតាមនូវវិវេក ។

២- ពួកសាវ័កជាអ្នកលះបង់នូវពួកធម៌ដែលព្រះសាស្តាទ្រង់សំដែងប្រាប់ឲ្យលះបង់ ។

៣- ពួកសាវ័កមិនប្រព្រឹត្តល្មោភច្រើន មិនកាន់ (សាសនា) ធ្ងរៗផង មិនជាក់ជុះក្នុងការប្រព្រឹត្តខុសច្បាប់ផង ជាប្រជានក្នុងវិវេកធម៌គឺព្រះនិព្វានផង ។

ម្នាលអាវុសោទាំងឡាយ ! ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ រមែងមានពួកសាវ័កជាអ្នកសិក្សាតាមនូវវិវេកដោយហេតុទាំង ៣ យ៉ាងប៉ុណ្ណេះឯង ។

ម្នាលអាវុសោទាំងឡាយ ! មជ្ឈិមាបដិបទា គឺសេចក្តីប្រតិបត្តិយ៉ាងកណ្តាល ប្រព្រឹត្តទៅដើម្បីលះបង់នូវបាបធម៌ទាំងឡាយ មានលោភៈជាដើម ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ គឺឃើញនូវសច្ចៈទាំង ៤ ផងជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតញាណ គឺដឹងនូវសច្ចៈទាំង ៤ ផង ប្រព្រឹត្តទៅដើម្បីរម្ងាប់កិលេស ដើម្បីដឹងច្បាស់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីព្រះនិព្វាន ។ (ឯមជ្ឈិមាបដិបទានោះ គឺអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិជាដើម មានសម្មាសមាធិជាទីបំផុត) ។

ព្រះសារីបុត្តដ៏មានអាយុ ចាន់សំដែងសូត្រនេះចប់ហើយ កិក្ខុទាំងនោះក៏មានចិត្តត្រេកអរពេញចំពោះភាសិតរបស់ព្រះសារីបុត្តដ៏មានអាយុ ។

ការបណ្តុះនិស្ស័យ

ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាចាលីវង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌាឆ្មុក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

ជាតិខ្មែរ ជាជាតិឯកភាព្យ មានព្រះមហាក្សត្រជាដំណសន្តតិវង្ស មកតាមលំដាប់ ដោយត្រឹមត្រូវតាមច្បាប់ទំលាប់នឹងប្រពៃណីនៃស្រុកទេស ។ ព្រះមហាក្សត្រនោះព្រះអង្គជាអ្នកទ្រទ្រង់ទុកនៅព្រះពាជអំណាចក្នុងការញ៉ាំងការណីយកិច្ចរបស់ជាតិ ឲ្យដំណើរទៅកាន់សេចក្តីសុខសេចក្តីចំរើនតាមវដ្តធម្មន្តា ព្រះអង្គជាប្រមុខនៃប្រជាជនខ្មែរទ្រង់គ្រប់គ្រងប្រទេសជាតិឲ្យតាំងនៅជារដ្ឋឯកភាព្យ មានឥស្សរភាពពេញលេញតរៀងទៅ ទ្រង់ជាអគ្គសាសនូបត្ថម្ភក៍ គឺព្រះអង្គឆ្ពោះព្រះភក្ត្រទំនុកបំរុងរក្សាព្រះពុទ្ធសាសនា ឲ្យបានចំរើនរុងរឿងបំតេះវេស្ថាពរ ដែលចាត់ថាជាប្រយោជន៍ដ៏ធំវិសេសជាតិនឹងខ្លួនយើងជាពលរដ្ឋ មិនតែប៉ុណ្ណោះទ្រង់បានតាំងចេញទ្រង់ព្រះផ្នួស[1] ដើម្បីឲ្យបានជាបច្ចាស់

---

១ ព្រះមហាក្សត្រខ្មែរពីអតីតដែលចេញទ្រង់ព្រះផ្នួសក្នុងពុទ្ធសាសនានោះ មានច្រើនអង្គតែបើពោលចំពោះ ព្រះមហាក្សត្រខ្មែរក្នុងបច្ចុប្បន្ននេះវិញ ក៏គឺព្រះបាទសម្តេចព្រះនរោត្តមសីហនុវ៉ែន ដែលចេញទ្រង់ព្រះផ្នួសកាលពីថ្ងៃទី ៣១ កក្តដា ដល់ថ្ងៃទី ១ វិច្ឆិកា ឆ្នាំ ១៩៤៧ ។

ទ្វេរកិច្ចការទាំងផ្លូវព្រះពុទ្ធសាសនាផង ទ្រង់ជាអ្នកឃុំគ្រងពួកយើងឲ្យ
បានផុតភ័យអន្តរាយនៃជីវិត, ពាក្យទាំងទ្រព្យសម្បត្តិ ឲ្យបានទទួល
សេចក្តីសប្បាយរីករាយត្រជាក់ត្រជំតៗ គ្នាមកដល់គ្រានេះ ។

ហេតុដូច្នេះ កាលបើយើងស្រឡាញ់កត្តីចំពោះជាតិហើយក៏ត្រូវតែ
ស្រឡាញ់កត្តីចំពោះព្រះមហាក្សត្រ ដែលជាប្រមុខរបស់ជាតិផង ប្រៀប
ដូចជាយើងស្រឡាញ់គ្រួសារ ត្រូវស្រឡាញ់កត្តីចំពោះប្រធាននៃគ្រួសារ
ទាំងអ្នកដែលស្រឡាញ់ពួកគណៈ ត្រូវស្រឡាញ់កត្តីចំពោះប្រធាននៃពួក
គណៈផងដូច្នោះ ។ អង្គនៃសេចក្តីស្រឡាញ់កត្តីចំពោះព្រះមហាក្សត្រ
នោះ គឺ :

ក) - ពាក់អាន ព្រះអង្គថាជាព្រះប្រិយមហាក្សត្រៃរបស់ខ្លួន ដោយ
ចិត្តដ៏បរិសុទ្ធ ដូចជាបុត្រធីតាដ៏ល្អដែលស្រឡាញ់ពាក់អានមាតាបិតារបស់
ខ្លួន ថាជាមាតាបិតាយ៉ាងពិតប្រាកដដូច្នោះ ។

ខ) - ធ្វើសក្ការបូជា គោរពកោតក្រែង ចំពោះព្រះអង្គដោយ កាយ
វាចា ចិត្ត មិនប្រព្រឹត្តល្មើសចំពោះព្រះអង្គដោយប្រការណាមួយ . ដូចជា
បុត្រធីតាដ៏ល្អដែលគោរពកោតក្រែងស្រឡាញ់ចំពោះមាតាបិតារបស់ខ្លួន
ជានិច្ច មិនប្រព្រឹត្តល្មើសដោយកាយ វាចា ចិត្ត ឬ គិតលុបលាងគុណ
មើលងាយយ៉ាងណាមួយដូច្នោះ ។

គ) - ជួយការពារនឹងកំចាត់ភ័យវិបត្តិ មិនឲ្យមកប៉ះពាល់ពុះពារលើ
ព្រះអង្គបាន នឹងមិនធ្វើការណាមួយដែលជាហេតុឲ្យមានអន្តរាយចំពោះ

ព្រះអង្គ ឬជាហេតុមិនឲ្យព្រះអង្គបានសុខសំពន្ធកន្ត ព្រះពជហឫទ័យ ធ្វើតែការណាដែលចំរើនដល់ព្រះអង្គ ទំនងដែលនាំឲ្យព្រះអង្គបានរីកាយ ព្រះពជហឫទ័យ ដូចជាបុត្រធីតាដ៏ល្អ ដែលតាំងចិត្តប្រតិបត្តិបំរើមាតាបិតារបស់ខ្លួន ឲ្យនៅជាសុខសម្រាន្តដូច្នោះ ។

ជាតិខ្មែរអ្នកជាតាំងឡាយ សូមចាំទុកកុំភ្លេចថា "អង្គព្រះប្រិយ-មហាក្សត្រ តាំងនៅកន្លែងបាន:ជាទីគោរពសក្ការបូជា អ្នកណាមួយទំនស្មើសមិនបាន" ។ តែត្រូវកុំពោលត្រឹមសំដីឡើយ ត្រូវប្រតិបត្តិតាមអង្គនៃសេចក្តីស្រឡាញ់កក្តីចំពោះព្រះមហាក្សត្រ ដូចពោលមកហើយដោយកតញ្ញូកតវេទី សុចរិតស្មោះត្រង់ គោរព សក្ការបូជា ចំពោះព្រះអង្គដោយចិត្តបរិសុទ្ធកុំខាន ។

៤.— ស្រឡាញ់ភក្តីចំពោះរដ្ឋធម្មនុញ្ញ.— រដ្ឋធម្មនុញ្ញ គឺច្បាប់ធំលាប់ដ៏ខ្ពស់បំផុតរបស់ប្រទេស ជាកំពូលនៃនីតិបញ្ញត្តិ គឺបញ្ញត្តិរបស់ច្បាប់ដែលមានអំណាចខ្ពស់បំផុតក្នុងផែនដី ទំនងជាវិធីដំណើរការទូទៅសម្រាប់កំណត់ទៃត្រៃដែននៃការគ្រប់គ្រងប្រទេស ឲ្យមានគោលចារិកមាំមួនដែលគ្មាននរណាមួយ អាចទំនងធ្វើការគ្រប់គ្រងទៅតាមគាប់ចិត្តបានតាំងជាច្បាប់មានរបៀបការគ្រប់គ្រងប្រទេស ក្នុងន្លះទំនុកបំរុងឲ្យកើតសុខរំងាប់ទុក្ខរបស់ប្រជាជននៃជាតិ ប្រគល់ឲ្យនូវសិទ្ធិក្នុងការគ្រប់គ្រងផ្នែសម្បើងស្រុកទេស ដល់បណ្តាពស្ត្រ ផ្សារភ្ជាប់នូវព្រះមហាក្សត្រនឹង

ប្រជាពលរដ្ឋឲ្យរួមដៃគ្នា ចាត់ការគ្រប់គ្រងប្រទេសដោយសាមគ្គីធម៌ ទទួលជានាក្នុងការឃុំគ្រងសិទ្ធិរបស់ប្រជាពលរដ្ឋនៃជាតិ ទុកជាគោលចារឹកចង់ក្លាប់នឹងការពារការក្បត់ប្រទេសជាតិ សាសនា ព្រះមហាក្សត្រ ឲ្យបិតថែរក្សាពារជាយូរអង្វែងតរៀងទៅ ។

រដ្ឋធម្មនុញ្ញនេះ គ្រែអំពីការប្រើជាច្បាប់ខ្ពស់បំផុតរបស់ប្រទេសហើយ គង់តែនៅជាសញ្ញាប្រជាគមរបស់ប្រជាពលរដ្ឋនៃជាតិទៀត ។ ព្រោះអាចបង្កឲ្យកើតសាមគ្គីធម៌ ជាច្បាប់មានការចង់ឆ្លាក់ប្រជាជាតិ ឲ្យមានការជិតដិតស្និទ្ធស្នាលគ្នាយ៉ាងមាំមួន លែងឲ្យមានការរើរូសដែលធ្លាប់តែមានជាប់គ្នានឹងគ្នារវាងពួកនឹងរវាងជាន់ទៀត ជាបង្គោលសម្រាប់រក្សាសន្តិភាពខាងក្នុងបានខ្លួនឯង ទាំងជារបងរនាំងដែលការពារប្រទេសឲ្យឈរដំហរនៅរឹងប៉ឹងយ៉ាងក្រៃលែង អាចធ្វើឲ្យប្រទេសជាតិកើតជាដុំជាផែនស្អុកស្អម្ភមាំមួនមានសន្តិសុខ នឹងឲ្យចំរើនរុងរឿងថ្កុំថ្កើងឡើងខាន់អារ្យប្រទេសធំៗ បានផង ។

ហេតុដូច្នេះ រដ្ឋធម្មនុញ្ញទើបជាអគ្គការអំណោយសេចក្តីសុខ នឹងជាគោលទីពឹងដ៏ក្សេមក្សាន្តរបស់ប្រជាជាតិ បើមិនមានរដ្ឋធម្មនុញ្ញជាគ្រឹងរក្សាការគ្រប់គ្រងដ៏រឹតរបស់ប្រជាជាតិឲ្យតាំងនៅជាសុខទេ ប្រជាជនក៏ខ្វះខាតវត្ថុឃុំគ្រងអស់ចំណែក ដែលអាចនាំឲ្យមានសភាពតាំងនៅក្នុងការឃុំគ្រង នូវដំរឹតមិនប្លែកអំពីសត្វតិរច្ឆាន ដូចពោលមកហើយខាង

ដើមនោះឡើយ ។ កាលបើវដ្ដធម្មនុញ្ញ មានគុណានុភាពដ៏ខ្លាំងក្លាយ៉ាងនេះហើយ ពួកប្រជាជាតិខ្មែរ គួរតែស្រឡាញ់កត្តីដ៏កល់ទុកក្នុងចិត្តខ្ពស់ទឹងថ្នមរក្សាទុកនូវវដ្ដធម្មនុញ្ញនោះដោយសេចក្តីពេញចិត្ត ដរាបដល់តល្បាវសាន ឲ្យដូចជាជាតិ, សាសនា, ព្រះមហាក្សត្រដូច្នោះ គឺត្រូវប្រតិបត្តិតាមអង្គនៃសេចក្តីស្រឡាញ់កត្តី ចំពោះវដ្ដធម្មនុញ្ញដូចតទៅនេះ :-

ក)- គោរពស្រឡាញ់របៀបការគ្រប់គ្រងប្រទេសរបស់ខ្លួនតាមបទបញ្ញត្តិនៃវដ្ដធម្មនុញ្ញ ។

ខ)- មិននិយមត្រេកអរក្នុងការគ្រប់គ្រងប្រទេសរបស់ខ្លួនដោយវិធីដទៃឬដែលខុសចាកវដ្ដធម្មនុញ្ញ ។

គ)- រក្សាការពារ នឹងទុកបំរុងផ្ដុងផ្ដើមការគ្រប់គ្រងប្រទេសរបស់ខ្លួន ឲ្យដំណើរទៅត្រូវត្រង់គ្រប់គ្រាន់ តាមវិធីនៃវដ្ដធម្មនុញ្ញ ។

ឃ)- ទំការពារឃាត់ឃាំងកំចាត់បង់នូវអំពើដែលជាគ្រឿងបំផ្លេចបំផ្លាញវដ្ដធម្មនុញ្ញ នឹងការគ្រប់គ្រងតាមរបៀបដទៃ ឬដែលខុសចាកវដ្ដធម្មនុញ្ញរបស់ខ្លួន ។

ង)- ប្រតិបត្តិខ្លួនឲ្យត្រូវ តាមបទបញ្ញត្តិនៃវដ្ដធម្មនុញ្ញ ដើម្បីឲ្យសម្រេចប្រយោជន៍ដល់ខ្លួននឹងជាតិ ។

លោក-អ្នកកម្ពុជាទាំងឡាយ ! នេះហើយជាអង្គនៃសេចក្តីស្រឡាញ់កត្តីចំពោះវដ្ដធម្មនុញ្ញ ។ សូមនឹកជានិច្ចថា "វដ្ដធម្មនុញ្ញ មិនមែនប្រតិបត្តិ

តាមលោក-អ្នកទេ លោក-អ្នកទេតើ ដែលត្រូវប្រតិបត្តិតាមវដ្ដធម្មន្ញា ហើយវដ្ដធម្មន្ញានោះ បើលោកអ្នកប្រតិបត្តិតាមហើយ គាចពិតក្តីកក្ខ លោក-អ្នកឲ្យមានសេចក្តីសាមគ្គីព្រមព្រៀងគ្នា ឲ្យបានទទួលប្រយោជន៍ ពេញលេញ ឲ្យមានសិទ្ធិ ឥស្សរភាព សេរីភាពដោយខ្លួនៅគ្រប់គ្នា ។

រតនៈដែលឃុំគ្រងយើងទាំង ៤ គឺ ជាតិ, សាសនា, ព្រះមហាក្សត្រនិង វដ្ដធម្មន្ញានេះ រមែងជាបង្គោលនៃសេចក្តីសុខ ទឹងជាទីពឹងដ៏ក្សេមក្សាន្ត របស់ប្រជាជាតិកម្ពុជា ។ ជាតិ តែងឃុំគ្រងយើងឲ្យជាខ្មែរអ្នកជា មានឥស្សរភាព ។ សាសនា តែងឃុំគ្រងយើង ឲ្យជាមនុស្សប្រសុទ្ធ ។ ព្រះមហាក្សត្រ តែងឃុំគ្រងយើង ឲ្យបានសេចក្តីត្រជាក់ត្រជុំជាកិត្តិយស ។ វដ្ដធម្មន្ញា តែងគ្រប់គ្រងយើងឲ្យមានសិទ្ធិសេរីភាព សមភាពនឹងភាតរភាពដោយពេញលេញ ។

ដូច្នេះ ពួកយើងគ្រប់គ្នា ទើបគួរស្រឡាញ់កក្តីចំពោះជាតិ, ចំពោះសាសនា, ចំពោះព្រះមហាក្សត្រ នឹងចំពោះវដ្ដធម្មន្ញា ដោយទឹកចិត្តដ៏បរិសុទ្ធស្អាតផូរផង់ ។ ពួកយើង ចូរយល់ឲ្យច្បាស់ថា ជីវិតដែលប្រកបដោយសេចក្តីស្រឡាញ់កក្តីចំពោះរតនៈទាំង ៤ នេះ ជាជីវិតនៃកិត្តិយសដ៏ខ្ពង់ខ្ពស់ ។ ឯជីវិតដែលប្រកបដោយការរៀចរេទុយិស លុបគុណគេ មើលងាយគេ ជាជីវិតនៃមរណភាពមុនមរណកាល ។

កើតស្លាប់តែ១គ្រា គ្មាននរណាស្លាប់ ២ ដង
ចេះត្រូវកុំកន្ធ់ ត្រូវនឹកជាតិជាង់ជីវិត ។

ព្រោះបើជាតិសាបសូន្យ ខ្មែរទាំងក្បួនត្រូវភ័យកិត
ប្លាន់ទុក្ខញាំញីគំនិត តែវៃគិតក៏លែងបាន ។
កាលជាតិសាបសូន្យហើយ នរណាឡើយនឹងសុខសាន្ត
មានតែមនុស្សតិរច្ឆាន ទើបក្សេមក្សាន្តក្រាមដើងគេ ។
សាសនានៃព្រះពុទ្ធ គ្មានពិរុទ្ធឯណាទេ
អាចនាំអស់យើងគេ ឆ្ពោះទៅកាន់សន្តិសុខ ។
ដូច្នេះយើងទាំងឡាយ ត្រូវខ្ជាប់ខ្ជួនកុំសំពុត
ប្រតិបត្តិឲ្យពេញមុខ ដើម្បីសុខប្រទេសជាតិ ។
ព្រះប្រុយមហាក្សត្រ សោយសម្បត្តិជាទាយាទ
ព្រះអង្គតែងខ្វីឃ្មាត ស្វែងរកសុខមកឲ្យព្រស្តុ ។
ដូច្នេះខ្មែរទាំងឡាយ ត្រូវខ្ជាប់ខ្ជួនកុំទីសទាស
នាំគ្នាច្រើនពេញពាស មកគោរពស្តាប់ព្រះអង្គ ។
រដ្ឋមន្ត្រីញ៉ាញ ជាគ្រឿងជួញជនមិនត្រង់
ជាប្បាប់តែតម្រង់ នូវការខុសឲ្យត្រូវបាន ។
ជាគោលនៃបញ្ញត្តិ ទាំងវិបត្តិគ្រប់ទីហាន
ដឹកនាំជនគ្រប់ប្រាណ ឲ្យក្សេមក្សាន្តមានសេរី ។
ដូច្នេះខ្មែរទាំងគន ត្រូវគោរពដោយឃ្មាតខ្វី
លើកជាក់លើសិរសី កុំគប្បីបណ្តាយឡើយ ។

(មានត)

កណ្ឌទី ១៦

ឧកញ៉ាវិបុលរាជសេនា ឆ្ង-កន ប្រៃរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាំងរៀនសូត្របើបានអាន
នឹងបេះឧបាយកល់បំណាន
ទាំងមានសន្តានស្នេហាជាតិ ។

អង់ហៅកំនិយាយនឹងចូឆូថា ស្រូវនៅក្នុងដង្រែកយើងនោះកាន់តែតិចណាស់ទៅហើយ យូរទៅប្រហែលជាហានទាំងពួងនឹងខ្វះខាត ។ ចូឆូឆ្លើយថា បើដូច្នោះត្រូវតែអ្នកគិតគូរចែកស្រូវឲ្យហាននោះ បន្ថយចំនួនឲ្យតិចជាងមុនឲ្យល្មមនឹងបង្ការទុក ត្រាតែការយើងនោះសម្រេច ។ អង់ហៅដំពាយថាដែលលោកនឹងធ្វើដូច្នោះ ខ្ញុំបាទយើញថាហានទាំងពួងនឹងមានសេចក្តីតូចចិត្ត ព្រោះបរិភោគមិនឆ្អែតគ្មានកំឡាំងធ្វើការ គង់នឹងប្រែចិត្តមិនគិតខំប្រឹងធ្វើការរឿនផ្គើណ៌សង្គ្រាម ។ ចូឆូតបថា យើងនឹងរិះគិតមិនឲ្យហានទាំងពួងតូចចិត្តបាន គឺត្រូវធ្វើចាំងឲ្យតូចរាល់ស្រូវ

ថែកថាហាន ។ អង់ហៅក៏ធ្វើតាមពាក្យចូឆូថា ។ ថាហានតាំងពួនខ្លួលយកស្រែវៅធ្វើអាហារបរិភោគ មិនបានគ្រប់គ្រាន់ពេញកំឡាំងក៏តូចចិត្តណាស់ នាំគ្នានិន្ទាចូឆូថា ចំណែកខាងការងារចេះតែប្រើឲ្យធ្វើ ចំណែកខាងអាហារឲ្យស្រែវស៊ីមិនឆ្អែតពេញសេញ បើមិនមានកំឡាំងហើយកាលណាឡើយនឹងធ្វើសឹកសង្គ្រាមដូចម្តេចបាន ។

លុះដល់មជ្ឈិមយាម ចូឆូក៏ប្រើបំរើដែលទំនុកទុកចិត្ត ឲ្យទៅលបចាំស្តាប់សេចក្តី ដែលថាហានតាំងពួននិយាយតូចចិត្តនោះ ក៏បានឮសំឡេងនិយាយគ្នានិន្ទាចូឆូផ្សេង។ ចូឆូក៏តាំងរិះគិតយកចិត្តសេនាថាហានឲ្យមានសេចក្តីទំប្រឹងធ្វើការលើកគ្នាចូលចូនយកស្រែកនោះ ក៏ឲ្យហៅខ្លួនអង់ហៅមកនិយាយថា យើងនឹងសុំរបស់ជាសំឡាញ់នៃអ្នកតែមួយ៉ាងនឹងបានយកចិត្តសេនាថាហាន អ្នកនឹងឲ្យយើងបានឬទេ? ។ អង់ហៅធ្វើយថា ខ្ញុំបាទគ្មានរបស់អ្វីនឹងឲ្យមហាឧបរាជទេ ។ ចូឆូធ្វើយទៀបថា យើងចង់ទិក្សាលអ្នក អង់ហៅក៏តក់ស្លុតរន្ធត់កង្វល់ចិត្តធ្វើយថា ខ្ញុំបាទគ្មានទោសខុសព័ន្ធអ្វីសោះ ហេតុម្តេចមហាឧបរាជចង់កាត់ក្បាលខ្ញុំបាទដូច្នោះ ។ ចូឆូធ្វើយថា "ខ្លួនអ្នកគ្មានទោសខុសពីអ្វីទេ តែថាយើងសុំកាត់ក្បាលជាឧបាយឲ្យសេនាថាហានដឿចូលចិត្តគិតខំធ្វើការ សូម្បីកវីយាបុត្រវបស់អ្នកនឹងស្តុតប័ក្សពួកដែលនៅខាងក្រោយ យើងនឹងខ្លួលបីបាច់ថែរក្សាចិញ្ចឹមព្យាបាល មិនឲ្យមានសេចក្តីគោកយ៉ាកលំបាកតវៅមុខឡើយ"

និយាយហើយ អង់ហៅមិនទាន់ទឹងថាដូចម្តេចផង ចូឆូក៏ប្រើតាហានឲ្យ
ចាប់ខ្លួនអង់ហៅនាំទៅកាត់ក្បាលក្នុងវេលានោះ ហើយដោតក្បាលផ្ទាល
ស្រែកអាត្រៃសថា អង់ហៅធ្វើជានាយឃ្វាំងស្រូវ ចំហូរតែបំបាត់
មហាឧបាជលបលួចធ្វើចាំងតូចវាល់ស្រូវចែក ឲ្យតាហានបានស៊ីមិន
គ្រប់គ្រាន់ ។

ខណៈនោះ បណ្តាតាហានតាំងពួនក៏បានដឹងឃើញគ្រប់គ្នា ក៏អស់
សេចក្តីសង្ស័យ ។ ចូឆូក៏ឲ្យប្រកាសឃោសនា ឲ្យបណ្តាតាហានតាំងពួន
ចូលមកបើកស្រូវឲ្យសម្រេចកន្លះរាត ៣ ថ្ងៃ ហើយចូឆូក៏ឲ្យកំដាប់ពាក្យទឹង
តាហានតាំងពួនថា "យើងទឹងលើកទ័ពចូលវាយទំលាយយកស្រុកក្នុង
វេលានេះ បើនរណាមិនមានចិត្តត្រង់ទឹងប្រឹងធ្វើការវេទ ឲ្យចេញមុខមក
យើងទឹងកាត់ក្បាលចេញ" ហើយក៏ដេញតាហានឲ្យដឹកដីទំលុះកំពែង
ស្រុកនោះ ។ តាហានក្នុងកំពែងក៏ឡើងលើសែនបាញ់ធ្នូចម្រុះចេញមក
ហើយទំលាក់ដុំថ្មចុះមកទៀតបីដូចគ្រាប់ភ្លៀង ។ តាហានចូឆូ ២ នាក់
ដែលចូលទៅដឹកគូទំលាយកំពែងនោះ ក៏ថយមកវិញ ព្រោះខ្លាចត្បិញ
ទឹងដុំថ្ម ។ ចូឆូឃើញក៏យកគ្រប៉ាត់ក្បាលតាហានតាំង ២ នាក់នោះស្លាប់
ហើយបោះទម្លាក់ក្នុងគូនោះ ។ តាហានតាំងឡាយឃើញដូច្នោះក៏មិន
អាចទឹងកថយមកវិញ ។ ចូឆូក៏បង្ខំឲ្យតាហានដឹកកកាយទំលាយកំពែង
ធ្លាយចូលទៅកន្លះស្រុកបាន ។ តាហានចូឆូក៏ចាត់តាប់សម្លាប់កន្លះទ័ពក្នុង

ស្រុកវិនាសស្ងាប់ជាច្រើន ហើយត្រូតគ្នាចាប់ជាន់ខ្លួន ឡោហង៍, តាន់គី, ងាក់ដីវ, លៀងកង ទាំង ៤ នាក់ ។ ចូឆ្លូសួរកអ៊ួនសុតថា ព្រះត៎ទៅតាំងទ័ពនៅណា? ។ ឈ្មោះ៤នាក់ឆ្លើយថា អ៊ួនសុតត៎ទៅស្រុកហួយ-ណាំ ។ ចូឆ្លូក៏ឲ្យយកខ្លួនទាំង ៤ នោះទៅសម្លាប់ផ្តាលកណ្តាលផ្លូវ ឲ្យបណ្តាអ្នកស្រុកត្រកល្បែកយើញទាំងអស់គ្នា ។ ឯរបស់ទ្រព្យដែលមាននៅកង់ស្រុកនោះ ចូឆ្លូក៏ឲ្យដឹកយកមកចំណាយចែកចាយឲ្យសេនាពាហានតាមសមគួរ ហើយឲ្យដុតផ្ទះសម្បែងកង់កន្លែងស្រុកនោះអស់ឯនសល់ ។

ចូឆ្លូក៏ប្រកាន់ឯសេនាពាហានទាំងពួងថា យើងនឹងលើកទ័ពទៅតាមអ៊ួនសុត តើអ្នកទាំងពួងនឹងយល់ឃើញដូចម្តេច? ។ ស៊ុនហុកឆ្លើយថា វេលានេះស្បៀងអាហារបស់យើងក៏រៀសត្ថណាស់ហើយ បើនឹងលើកទ័ពទៅតាមក៏ួនសុតនោះ ខ្ញុំបានយល់ឃើញថា ពាហានទាំងពួងនឹងបានសេចក្តីខ្វៃយត្រួយលំបាក សុំឲ្យលោកលើកត្រឡប់ចូលទៅក្រុងហ៊ីរគាវិញស្រួលជាង ព្រោះនឹងបានបំរុងសេនាពាហានឲ្យមានបរិបូណ៌សិន បើដល់រដូវស្រូវខ្ទុងក៏ស្រែវេលាណា ស៊ីមត្រឡប់មកធ្វើការតន់នឹងបានដោយស្រួល ។ ចូឆ្លូបានស្តាប់ពាក្យនោះដាមិនទាន់គិតជាយ៉ាងណា ខ្លួលៈចាហង៍ជូនសំបុត្រមកដល់ចូឆ្លូថា តៀវស៊ុវជាកូយតៀវចេតចង់គិតគ្នានឹងឡោះតៀវដែលនៅស្រុកកេងដីវ លើកទ័ពទៅវាយស្រុកសៀងយ៉ុង

ទឹងស្រុកគាំងឡេង ឃានតគាំងច្បាំងគ្នាទឹងចោហង ជាច្រើនក្តាហើយ ចោហងធន់ថ្លៃដៃតៀវស៊ីវមិនឃានសុំឲ្យមហាឧបរាជលើកទ័ពទៅជួយ ។ ចូឆូយើញសេចក្តីសំបុត្រដូច្នោះ ក៏និយាយទឹងស៊ុនសិកថា អ្នកចូរលើកទ័ពទូកទៅកាំងស្តាត់ពីក្រោយផ្លូវស្រុកគេងដ៏វគុកឲ្យមាំ ដើម្បីទឹងឲ្យឡៅតៀវអន្ទះសាវវែកកុំឲ្យធ្វើការតេទៅឃាន កាលណាយើងច្រូងច្រៀបរៀបចំការខាងណេះស្រេច ទឹងលើកទ័ពទៅស្រុកសៀងយ៉ុងទឹងស្រុកគាំងឡេង វាយទំលាយគយពីមុខ ។

ស៊ុនសិកឧទ្ទូលពាក្យចូឆូហើយក៏លើកទ័ពចេញទៅ លុះស៊ុនសិកទៅដល់ហើយ ចូឆូក៏ឲ្យហៅលីប៉ោទឹងឡៅតីមកនិយាយថា អ្នកទាំង ២ កុំបីមានចិត្តគិតអាឃាដឥឡាឃានគ្នាតទៅមុខឡើយ ត្រូវតែជួយគ្នាគិតទំនុកបំរុងផែនដីដើម្បីឲ្យព្រះចៅហៀនតេទង់ឃានសេចក្តីសុខ យើងទឹងសុំឲ្យឡៅតីត្រឡប់ទៅនៅស្រុកសៀវផាយវិញ ។ លីប៉ោឧទ្ទូលពាក្យចូឆូហើយក៏លាលើកទ័ពត្រឡប់ទៅស្រុកឈីដ៏វ ។ ចូឆូក៏និយាយទឹងឡៅតីថា អ្នកដឹងកល់យើងឬទេ ? យើងឲ្យអ្នកទៅនៅស្រុកសៀវផាយវេលានេះ យើងទឹងបញ្ជោតឲ្យខ្លាំងក្លាក់អណ្តូង បើអ្នកទៅហើយចូរត្រែះត្រៃតគូរគ្នាទឹងតាន់តុយតាន់តេង ទំធ្វើការឲ្យសំរេចឃានជាធាប់ ។ ឡៅតីក៏លាចូឆូទៅតាំងនៅស្រុកសៀវផាយ ។ ចូឆូក៏លើកទ័ពត្រឡប់ទៅស្រុកហ៊ូគោ ហើយប្រមូលពលយោធាលើកទៅច្បាំងទឹងតៀវស៊ីវ ។ ឧទ្ទូល

តាហានចូលទៅជំរាបបង្គួថា ខ្ញុំនអ៊ុយនឹងដ៏សុិបសម្ងាប់លីឈុយគុយតីស្លាប់
ហើយ តឡូវយកក្បាលតាំង ២ នោះនឹងស្តេចព័ក្សពួកមកជូនលោក ។
បង្គួមានសេចក្តីត្រេកអរណាស់ចេញមកទទួលខ្ញុំនអ៊ុយនឹងដ៏សុិប ហើយ
ឲ្យតាហាននាំយកស្តេចព័ក្សពួកលីឈុយគុយតីទៅកាប់យកក្បាលដោត
ផ្ចាលត្រៀមទ្វារស្រុកហើយនាំយកសេចក្តីនោះទៅក្រាបបង្គំទូលព្រះចៅ
ហៀនតេ ។ ខ្ញុំដ៏ជាបគ្រប់ប្រការ ខ្ញុំមានព្រះពរជាប្អូនយសោមនស្ស
ត្រេកអរថា "ផែនដីយើងវេលានេះនឹងបានសេចក្តីសុខអស់បម្រែងបម្រែ
ហើយ" ទើបមានព្រះដម្រាស់ឲ្យហៅខ្ញុំនខ្ញុំនអ៊ុយនឹងដ៏សុិបចូលទៅក្រាប
បង្គំគាល់កងទីព្រះពរភេនរម្យ ហើយខ្ញុំនក្រាសព្រះពរជានលៀង
អាហារ ឲ្យខ្ញុំនអ៊ុយនឹងដ៏សុិបបរិភោគជាមួយនឹងនាហ្មឺនខ្ញុំរាជការតាំងពួង
រួចខ្ញុំនព្រះពរជានតាំងខ្ញុំនអ៊ុយជាបងទៅចៀងគុន, តាំងដ៏សុិបជាទៀន-
លោដៀងគុន គឺនាយតាហានកំចាត់ចោរ ហើយមានព្រះដម្រាស់ឲ្យ
ខ្ញុំនអ៊ុយន៏ងដ៏សុិប នាំស្តេចព័ក្សពួកទៅឈរស្រុកតៀវអាន់ ។ ខ្ញុំនអ៊ុយ
នឹងដ៏សុិបក៏ក្រាបថ្វាយបង្គំលាទៅឈរវែតតាមព្រះតម្រាស់ ។ បង្គួក៏
ក្រាបបង្គំទូលព្រះចៅហៀនតេថា តៀវស៊ីវតប់តិតគ្នានឹងឡៅតៀវលើក
ទ័ពទៅវាយស្រុកសៀវយ៉ុងនឹងស្រុកកាំងឡេង ទូលព្រះបង្គំជាខ្ញុំសូម
ព្រះពរជានថ្វាយបង្គំលា លើកទ័ពទៅកំចាត់តៀវស៊ីវកងសម័យនេះ
ឯរាជការគ្រប់ចំពួកកងក្រុង ទូលព្រះបង្គំជាខ្ញុំចាត់ឲ្យស៊ុនហុតនៅត្រួតត្រា

រក្សា" ហើយក៏ថយទៅរៀបចាត់ចែងសេនាឲ.ហានលើកចេញពីទីក្រុងទៅ ។ ព្រះចៅហៀនតេស្តេចដូនដំណើរចូឆូដល់ក្នោងទ្វារ ។ ព្រះចៅហៀនតេសោយរាជសម្បត្តិគង់ក្រុងហ៊ូតោបាន ៣ ព្រះវស្សា ។

កាលចូឆូលើកទ័ពទៅនោះ ជារដូវស្រូវគោជសាលីកំពុងទុំស្រុះបណ្តាមនុស្សម្នាមហាជនដែលនៅក្បែរខាងផ្លូវ ដឹងឃើញថាកងទ័ពចូឆូលើកទៅដល់ទីណា ក៏នាំគ្នាភ័យខ្លាចរត់ចោលស្រែចម្ការអស់ ។ ចូឆូឃើញដូច្នោះក៏ហាមប្រាមនាំយទ័ពនាយកងតាំងពួងថា "បើនរណាទៅបៀតបៀនបណ្តាពស្តូអ្នកស្រុក ឬដើរជាន់ស្រូវគោជសាលីសូម្បីតែ ១ គុម្ពក្តី យើងនឹងកាត់ក្បាលនាយទ័ពនាយកងនោះទុកជាបំពាម" រួចក៏ឲ្យប្រកាសយោសនាប្រាប់ប្រាមបណ្តាពស្តូអ្នកស្រុក ដែលភ័យរត់ទៅនោះឲ្យវិលមកនៅក្នុងភូមិឋានដូចដើមវិញ ។ ពស្តូអ្នកស្រុកវិលមកឃើញរបស់ទ្រព្យមិនមានខូចបាត់អន្តរាយ ហើយឮថាចូឆូហាមប្រាមពលទាហានដូច្នោះ ក៏មានសេចក្តីត្រេកអរសរសើរគ្រប់គ្នាថា មហាឧប៉ាជមានសេចក្តីប្រណីអាណិតពស្តូណាស់ ទើងរកអ្នកឯណាស្មើគ្មាន ។

ឯនាយទ័ពនាយកងតាំងពួង កាលលើកទ័ពទៅដល់ពាក់កណ្តាលផ្លូវ បើត្រូវលើផ្លូវស្រែនៅទីណាក៏លោតចុះពីលើសេះ ដៃជិកសេះវែកគុម្ពស្រូវគោជសាលីដើរទៅត្រែះខ្លាចអាជ្ញាចូឆូ សូម្បីតែខ្លួនចូឆូឯងនោះសោត ក៏ជិះសេះច្រើតហានវែកគុម្ពស្រូវពីខាងមុខដរាប លុះសេះនោះ

ដើរទៅ មានសត្វ ១ នៅក្នុងស្រែវាផ្លើលហ៊ោរឡើង សេះនោះក៏ភ្ញាក់ស្ទុះច្រឡោតចូលទៅក្នុងស្រែ ជាន់ដង្កែងគុម្ពស្រូវគោជសាលីបាក់ល្អិតជាច្រើនគុម្ព ចូធូរឃើញដូច្នោះ ក៏ធ្វើទុក្ខាយដើម្បីនឹងឲ្យតាហានតាំងពួនស្រឡាញ់រាប់អាននឹងគោតខ្លាច ព្រោះឃើញថាយុត្តិធម៌ត្រឹមត្រូវណាស់ ក៏តាំងឲ្យហៅនាយទ័ពនាយកងតាំងពួនមកប្រាប់ថា ឥឡូវខ្ញុំនយើងបានធ្វើទុសនឹងអាជ្ញា ហើយឲ្យអ្នកតាំងពួនកាត់សេចក្តីធ្វើទោសយើងចុះ ។

ដូផៅទីប្រឹក្សាក៏ជំរាបសួរចូធូថា មហាឧបរាជធ្វើទុសពីអ្វី? ។ ចូធូក៏ពណ៌នារឿងពីរវប្រាប់ពីសេះផ្លើលជាន់គុម្ពស្រូវនោះ ឲ្យដូផៅស្តាប់ថា "ពីដើមយើងជាក់អាជ្ញាហាមប្រាមពួកពលតាហានតាំងអស់ ថាបើធ្វើខូចបាក់បែកគុម្ពស្រូវរបស់ក្រីក្រត្រូវមានទោស ឥឡូវត្រូវលើខ្លួនយើងធ្វើទុសខ្លួនឯង បើនឹងស្ងៀមបំបាត់សេចក្តីនោះចេញ បណ្តាមនុស្សតាំងពួនក៏នឹងតិះដៀលដំនៀលថា ខ្លួនយើងមិនបានគាំងនៅកងផ្សេងត្រូវយុត្តិធម៌" ថាហើយហូតក្រចៀដែលសៀតពីក្រោយនោះចេញ ធ្វើទំនងជានឹងអាវកខ្លួនឯងសម្លាប់ ។

គុយកែកយ៉ស្ទុះសូរត់ទៅដណ្តើមក្រចៀពីដៃចូធូបានហើយឃាត់ថា ដែលមហាឧបរាជធ្វើដូច្នេះក៏គួរណាស់ហើយ តែថាខ្លួនខ្ញុំបាទនឹងនាយទ័ពនាយកងនៅតាហានតាំងពួងនៅជាសុខបាន ក៏ព្រោះតែព្រះតេជព្រះគុណមហាឧបរាជឃុំគ្រងរក្សា ដ៏ឥឡូវនេះបើមហាឧបរាជនឹងសម្លាប់ខ្លួន

ឯងចេញ យើងខ្ញុំតាំងឡាយក៏គ្មានទីពឹងពំនាក់សោះ, ព្រះគុណអើយ តាំងពីថ្ងៃនេះទៅក៏នៅមានតែទុក្ខព្រួយលំបាកពន់ពេកណាស់ ។ ចូតូ ស្តាប់ច្បាស់ក៏ធ្វើជាជកដង្វើមធំហើយនិយាយថា "អ្នកថាដូច្នេះត្រូវហើយ តែអ្នកនឹងសុំឲ្យជាប់តាមពាក្យនោះមិនបានទេ ត្រូវតែយើងធ្វើឲ្យមានបែបផែនទុក" ថាហើយក៏យកក្រប៉ិកាត់សក់ពីលើក្បាលរបស់ខ្ញុំហុចឲ្យទៅតាហានកាន់យកទៅសែកអាកាសគ្រប់តំបន់តាមឆ្នូវថា មហាឧបាជ្ឈាខ្ញុំនឹងអាជ្ញាហើយ កំមិនបានសោកស្តាយដល់ជីវិតគិតនឹងសម្លាប់ខ្លួនចេញ តែបណ្តានាយទំពនាយកងនាំគ្នាសុំអង្វរឲ្យលើកទោស ចានជាមហាឧបាជកាត់សក់នេះជំនួសក្បាល ឲ្យអ្នកទាំងឡាយមើលឲ្យឃើញជាបែបផែនតទៅចុះ ។ បណ្តាសេនាតាហាននឹងអាណាប្រជានុកស្តេចទាំងពួង ក៏នាំគ្នាសរសើរពាក់អាននឹងកោតខ្លាចអំណាចចូតូលើសជាងពីដើម ។ ចូតូក៏បង្ខិតលយោជាលីលាស្រួតរូតទៅប្លាំងនឹងតៀវស៊ីវ ។

ឯតៀវស៊ីវនោះលុះដឹងថាចូតូលើកទ័ពមក ក៏ចាត់សំបុត្រទៅដល់ទ្លៃតៀវឲ្យលើកទ័ពមកឲ្យបាត់ពីក្រោយ ខ្លួនតៀវស៊ីវនឹងលុយឈើ, តៀវសៀនក៏លើកតាហានទៅតាំងនៅក្រៅបន្ទាយចាំទទួលប្លាំងនឹងចូតូ។ ទទួលចូតូលើកទ័ពមកដល់ ។ តៀវស៊ីវឃើញចូតូស្រែកដេរថា អាចោរជាងចេះសំដីពិរោះឲ្យមនុស្សវង្វេងដឿ អញមិនដឹងជាអាឯងចេះកូតកុហកអាក្រក់លើសសត្វតិរច្ឆាន ។ ចូតូបានឮដូច្នោះក៏ខឹងណាស់ ដេញទៅជូ

ឲ្យបំផ្ទាយសេះចូលទៅតយុទ្ធនឹងតៀវស៊ីវ៉ា ក៏ប្រើតៀវសៀនឲ្យចេញមកតស៊ូនឹងខ្លះធ្លាន ៣ ក្បួន ។ ខ្លះធ្លាយកន្ទុយចាក់តៀវសៀនធ្លាក់ពីលើសេះស្ទាប់ ។ តៀវស៊ីវឃើញដូច្នោះ ក៏គិតថានឹងតស៊ូនឹងចូរធ្លូមិនបាន ទើបបរសេះវេះនាំ ឥហានចូលទៅកន្ត្រក់ស្រុកសៀរយ៉ុង ហើយឲ្យបិទទ្វារស្រុកទុកជុំវិញមាំមួន ហើយចាត់ឥហានឲ្យឡើងយាមល្បាតលើសែនកំពែង ។

ចូរធ្លូក៏លើកឥហានឡោមព័ទ្ធជុំវិញពីក្រៅ មើលទៅឃើញជ្រាលជ្រៅពន្លឹក បើនឹងលុយកាត់ទឹកទៅក៏មិនបាន ទើបប្រើឥហានឲ្យជញ្ជូនឈើនឹងស្មៅមកចង់ទុកជាច្រើន ហើយសង់សែនល្បាតតាមជុំវិញទ្វារស្រុកទាំង ៤ ទិស ចូរធ្លូតែងឡើងមើលគ្រប់សែនពេញ ៣ ថ្ងៃ ឃើញឥហានដែលល្បាតលើសែនកំពែងទិសខាងកើតស្ងប់ស្ងៀង ក៏ប្រើឥហានឲ្យជញ្ជូនពេជិនឹងស្មៅ ទៅតរទុកខាងទ្វារបស្ចឹម ហើយប្រាប់ឥហានទាំងពួងថា យើងនឹងលើកវាយទំលាយល្បាតទិសនេះ ។

ការសៀងទ័ប្រឹក្សាឃើញដូច្នោះក៏ជំរាបតៀវស៊ីវថា ដែលចូរធ្លូឲ្យរៀបចាត់ការដូច្នេះ ខ្ញុំបាទយល់ថា ធ្វើជាការមុខបាយ ខ្ញុំបាទសូមធ្វើការលល់ប្រាជ្ញាចូរធ្លូឲ្យចាញ់យើងឲ្យបាន ។ តៀវស៊ីវក៏សួរទៅការសៀងថា អ្នកនឹងគិតធ្វើការលល់ប្រាជ្ញាចូរធ្លូនោះ តើនឹងគិតធ្វើដូចម្តេច? ។ ការសៀងជំរាបថា ខ្ញុំបាទឃើញចូរធ្លូឡើងលបមើលលើសែន ៣ វេលា ហើយ ចូរធ្លូឃើញឥហានខាងយើងទិសបូព៌ានោះស្ងប់ស្ងាត់ ឃ្លានជាចូរធ្លូ

ឲ្យដញ្ជូនយកឈើនឹងស្មៅទៅតរពុកខាងទិសបស្ចឹម ដើម្បីនឹងឲ្យយើងប្រុងប្រយ័ត្នខាងទិសបស្ចឹម ឯគំនិតចូរូប្រែត្រឡប់ទៅចំណាយខាងទិសបូពាទេ គឺបំណងនឹងធ្វើកងពេលយប់នេះជាប្រាកដ ខ្ញុំបាទនឹងបង្គាប់ឲ្យពួកអ្នកស្រុកស្វែកពាក់តែងខ្លួនបន្ទូលទៅជាតាហាន ឡើងទៅរក្សាគយខាងទិសបស្ចឹមបែបប្រុងប្រយ័ត្នឲ្យមាំមួន តែពួកតាហានទាំងអស់របស់យើង។ ត្រូវប្រមូលមកបង្គាប់ចាំខាងទិសបូពាវិញ បើចូរូលើកមកធ្វើការវេលាណាយើងឲ្យអុចផ្លាវជាសញ្ញា ឯតាហានដែលបង្គាប់ឲ្យចេញមកឲ្យប់ទាំងសងខាង គង់តែចូរូនឹងបរាជ័យរបស់យើងជាប្រាកដ ។ តៀវស៊ីវយល់ឃើញត្រូវ ក៏បង្គាប់ឲ្យធ្វើតាមពាក្យការសៀងថានោះជាស្រេច ។

ឯតាហានដែលគយឃ្លាំយោមល្បាត ក៏នាំយកហេតុទៅដំរាបចូរូថាឥឡូវតៀវស៊ីវ ប្រមូលសេនាតាហានទៅបំរុងការប្រយ័ត្នខាងទិសបស្ចឹមច្រើនណាស់ ឯខាងទិសបូពាក៏មានតាហានបន្តិចបន្តួចស្លុចស្តើងទេ ។ ចូរូបានស្តាប់ដូច្នោះ ក៏សោមនស្សត្រេកអរស្មានក្នុងចិត្តថា នឹងសមប្រកបតាមគំនិតគិតទុក ទើបបង្គាប់តាហានទាំងពួងឲ្យប្រុងប្រៀបរៀបខ្លួនកាន់គ្រឿងសស្ត្រាវុធទុកឲ្យត្រៀមគ្នា ។ លុះពេលយាម ៣ ជ្រុយ ចូរូក៏បរពលឲ្យចុះហែលទឹកកងគូរូឆ្ពោះទៅខាងទិសបូពាដល់ទ្វារកំពែង ស្តាប់សំឡេងក៏មិនមានមនុស្សនឹងតវ៉ា តាហានទាំងអស់គ្នា ក៏ពាំរំលាយចូលតាមទ្វារទៅកងក្នុងស្រុកបាន ។

(មានត)

រឿងអាវ័ក្សថ្ងៃនរឿងឆ្កែច្រៀ

លោក រ៉ាយ-ប៊ុក ក្រមការ

ប្រែពីភាសាឥណ្ឌមកជាខ្មែរ

(តមក)

រឿងទី៧ប៉ប្រាំពីរ

អាវក្សក្រាបទូលមហាពជថា: "បពិត្រមហាពជ! មានព្រាហ្មណ៍ម្នាក់នាមទេវសម៌ (Dévas barma) មានគេហដ្ឋាននៅនគរឧជ្ជ័ន (Ujjain)។ ព្រះមហាក្សត្រទ្រង់ព្រះនាមមហាសំន (Mahà sain) សោយរាជ្យនៅនគរនោះ។ ទ្រង់មានព្រះរាជបុត្រមួយអង្គព្រះនាម តុណេការ (Tunèkar)។ ព្រះរាជបុត្រអង្គនេះជាអ្នកលេងល្បែងស៊ីសងហួសប្រមាណ ចាញ់អស់ធនធានដែលព្រះបិតាទ្រង់ព្រះរាជទាន ទាល់តែក្រុមព្រះរាជវង្សានុវង្សបណ្តេញទ្រង់ចេញពីព្រះនគរ។

ព្រះអង្គម្ចាស់ទ្រង់ស្តេចចេញពីព្រះនគរ គ្មានគោគទ្រព្យបន្តិចបន្តួចជាប់ខ្លួនជាមួយសោះឡើយ។ ដល់ទ្រង់ស្តេចទៅអស់ពីរបីថ្ងៃ, ឃ្លានទៅដល់នគរមួយ។ នៅនគរនោះ ទ្រង់ឃ្លានខ្លាំងឃើញព្រះយោគីម្នាក់រូបអង្គុយមានផ្សែងចេញពីក្បុះ។ ទ្រង់ឃ្លានសំដែងនាវាភាពចំពោះព្រះយោគីនោះរួចក៏គង់នៅកងទីដ៏សមគួរ។ ព្រះយោគីក៏ក្រាបទូលសួរទ្រង់

ថា ខ្ញុំមានព្រះបំណងចង់សោយព្រះក្យាឬទេ! ។ ខ្ញុំតបវិញថា: "ម្តេចក៏ខ្ញុំមិនចង់បរិភោគ ឲ្យតែលោកឲ្យមកខ្ញុំចុះ អាហារអ្វីក៏ដោយ" ។

ព្រះយោគីក៏បានយកលោកក្បាលខ្មោចមនុស្សមួយ មកជាក់អាហារ ហើយក៏យកមកថ្វាយខ្ញុំ ។ ដល់ព្រះយោគីឃើញថាព្រះអង្គម្ចាស់មិនសោយនូវក្យាហារទាំងនោះ ព្រះយោគីនោះក៏សូត្រវេបមន្តមួយបទ ស្រាប់តែមានយក្ខិនីមួយមកដល់ ។

យក្ខិនីនោះ លើកដៃអញ្ជលីថ្វាយបង្គំព្រះយោគីហើយពោលថា: "ខ្ញុំព្រះអង្គ! ខ្ញុំម្ចាស់នឹងធ្វើតាមបង្គាប់ព្រះអង្គទាំងអស់" ។ ព្រះយោគីក៏បានបង្គាប់ទៅយក្ខិនី ឲ្យយកអាហារដែលព្រាហ្មណ៍ (ព្រះអង្គម្ចាស់) នេះត្រូវការទៅជូនព្រាហ្មណ៍ ។ យក្ខិនីក៏បានសាងប្រាសាទមួយល្អអស្ចារ្យ ហើយក៏បាននាំយកវត្ថុទាំង៥ប្រាន ដែលជាទឹតម្រែក យកទៅតម្កល់ក្នុងប្រាសាទនោះ ។ រួចយក្ខិនីនាំយកព្រាហ្មណ៍នោះ ទៅអង្គុយលើកៅអីមួយ ហើយក៏យកម្ហូបអាហារថែមទាំងខាទនីយាហារជាច្រើនយ៉ាង ។ កាលណាព្រាហ្មណ៍បានបរិភោគនូវភោជនាហារ ដែលឆ្ងាញ់ពីសារួចហើយ, យក្ខិនីបានយកហិបមួយមកជាក់ចំពីមុខ ហើយក៏បានលាបប្រេងព្រំសព្វសព៌ាង្គកាយនូវរមៀត, ទឹកចន្ទន៍ លាយនឹងទឹកផ្កាកុលាប្រគប់អូបឈ្ងុយឈ្ងប់ ហើយយកសំលៀកបំពាក់មានសភាពស្តើងសាច់ហ្មត់ច្រះទឹកអប់, យកបុប្ផាតម្រងមកពាក់ក ហើយក៏នាំព្រាហ្មណ៍នោះមកលើគ្រែក៏ទ្បីពេលនោះ ។ បន្តិចទៀត, ជួនជាយប់, នាងយក្ខិនីក៏មកអង្គុយ

ដិតព្រាហ្មណ៍, ហើយនិទ្ទោដាមួយព្រាហ្មណ៍រហូតមួយរាត្រី, សប្បាយ
ត្រេកត្រអាលក្នុងកំលេសកាមនឹងវត្ថុកាម ។ លុះដល់បុព្វណ្ហសម័យ,
នាងយក្ខិនីនោះក៏វិលត្រឡប់ទៅទីកន្លែងវិញ ។ ព្រាហ្មណ៍ក៏ទៅជូនប់
ព្រះយោគីនោះថា: "លោកគ្រូ! នាងយក្ខិនីទៅបាត់ហើយ តើលោក
គ្រូឲ្យខ្ញុំធ្វើយ៉ាងណា" ។ ព្រះយោគីតបថា: "នាងយក្ខិនីនេះមក
កាន់ទីនេះបានដោយអានុភាពវិជ្ជា ហើយនាងអាចស្ថិតនៅបាន ចំពោះ
បុគ្គលណាដែលអាចសង្កត់សង្កិនខ្លួនចិត្ត កុំឲ្យលុះក្នុងកាមតណ្ហា" ។

ព្រាហ្មណ៍នោះក៏តបទៅព្រះយោគីវិញថា: "សូមលោកគ្រូមេត្តា
ប្រគល់ខ្លួនវិជ្ជានោះមកខ្ញុំៗ នឹងយកទៅប្រើការតាមត្រូវការ" ។

ព្រះយោគីក៏បានឲ្យទៅព្រាហ្មណ៍នូវរូបមន្តមួយបទ រួចបង្គាប់ថា:
"ចូរអញ្ជើញទៅអង្គុយនៅកន្លែងកាលយប់ កន្លែងកាលពាក់កណ្តាល
អធ្រាត្រ ឲ្យអស់រយៈវេលាសែសិបថ្ងៃ ដោយមានចិត្តថានឹងសិក្សា
រៀនសូត្រឲ្យចាំស្ទាត់នូវរូបមន្តនោះ" ។

ព្រាហ្មណ៍នោះ ក៏ធ្វើតាមបង្គាប់ព្រះយោគីសព្វគ្រប់ប្រការ, ហើយ
ពិតមែនតែមានទុក្ខហានិមិត្តគួរឲ្យតក់ស្លុតភ័យខ្លាច. ព្រាហ្មណ៍ក៏មិនមាន
ខ្លាចអ្វីសោះឡើយ ។ កាលណាពេលដែលគំរិតផុតហើយ ព្រាហ្មណ៍
ក៏វិលត្រឡប់មកជូនប់ព្រះយោគីថា: "លោកគ្រូ! ខ្ញុំបានធ្វើតាមបង្គាប់
លោកគ្រូហើយ" ។ ព្រះយោគីតបថា: "ចូរបំពេញកិច្ចដែលតាម

កំរិតពេលដូចមុន, អង្គុយនៅកងភ្លើង" ។ តែព្រះអង្គម្ចាស់គុណាករ
ទ្រង់ចាន់សូមអនុញ្ញាតព្រះយោគីទៅសួរគ្រួសារបានម្តង, ដោយសន្យា
នឹងព្រះយោគី ថាបំពេញកិច្ចរួច នឹងវិលត្រឡប់មកប្រព្រឹត្តប្រតិបត្តិ
តាមលោកគ្រូមិនហ៊ានខាន ។

ព្រះអង្គម្ចាស់គុណាករ លុះបានអនុញ្ញាតហើយ ក៏ស្តេចវិលត្រឡប់
មកកាន់នគរវិញ ។ ដល់ទ្រង់ស្តេចទតឃើញនូវព្រះមាតាបិតានឹងព្រះ
ពជវង្សានុវង្ស ទ្រង់ក៏លោតទៅនុបព្រះសូរង, ហើយទ្រង់ព្រះកន្សែងជា
មួយនឹងព្រះពជវង្សានុវង្ស ។ ព្រះបិតាមានបន្ទូលថា: "នុគុណាករ! តើ
កូនឯងទៅឯណា កងរយៈវេលាយូរម្ល៉ះ? ហេតុម្តេចក៏ឯងក្លេចផ្លុះសម្បែ
ដូចនេះ? ។ នុកូនអើយ! មានគម្ពីរពោលថា: អ្នកណាបោះបង់ចោល
ភរិយា ដែលមានចិត្តស្មោះត្រង់នឹងខ្លួន ស្ថិតនៅឆ្ងាយពីនាង មិន
ស្រឡាញ់នាង, តែនាងមានចិត្តកក្តីនឹងស្វាមីពន់ពេក, អ្នកនោះ គេពុក
ជាអ្នកនិរទេស ។ មានគម្ពីរខ្លះពណ៌នាថា: គុណសម្បត្តិអ្វីមិនស្មើនឹង
គុណសម្បត្តិគ្រួសារសោះឡើយ, ថាអ្វីក្នុងពិភពលោក មិនអាចធ្វើ
ខ្លួនឲ្យសប្បាយ ទឹកមុខស្រស់ស្រាយបាន ក្រៅពីស្ត្រីដែលនៅកង
គេហដ្ឋាន, ថាអ្នកណាដែលប្រមាថមើលងាយមាតាបិតា, គេពុកជា
មនុស្សថោកទាប ហើយព្រះពុទ្ធមានព្រះពជនដ្ឋារថា: "អ្នកចាំង
អស់នោះគ្មានអ្នកណាស្រោចស្រង់ឲ្យផុតពីទុក្ខបាន" ។

ព្រះអង្គម្ចាស់គុណាករខ្ញុំក្រាបទូលព្រះបរមរាជបិតាវិញថា: "រូបកាយនេះមានឈាមនឹងសាច់ជាសមាសភាព គឺជាអណ្តើជង្វរ, បើតាមធម្មជាតិរបស់វា វាមានតំណួលផ្សាយជាកូនស្អុយ បើយើងមិនបានថែទាំរូបកាយនោះថ្ងៃណាមួយ ។ អ្នកណាមិនស្រឡាញ់រូបកាយនេះ អ្នកនោះជាមនុស្សល្ងង់, ហើយអ្នកណាដែលគ្មានចិត្តប្រកាន់ខ្ជាប់ស្អិតទៅនឹងរូបកាយអ្នកនោះគេទុកជាបណ្ឌិត ។ តើតនឹងស្អប់នេះជាបទបញ្ញត្តិច្បាប់នៃរូបកាយទាំងនេះ ។ តើយើងនឹងអាចទុកចិត្តលើរូបកាយនេះបានឬទេ? បើទុកជាយើងចង់ធ្វើឲ្យរូបកាយមានសភាពបរិសុទ្ធស្អាតយ៉ាងណា, ក៏រូបកាយនោះមិនចេះបរិសុទ្ធទៅបាន ។ ថ្ងៃដើរគេយកសម្រាមទៅដាក់ ថ្ងៃនោះមិនអាចស្អាតបានទេ ។ គេលាងហើយលាងទៀតទៅវាដុំធ្យូង ក៏ដុំធ្យូងនោះមិនអាចប្រែជាពណ៌សបានឡើយ ។ តើធ្វើម្តេច រូបកាយនេះដែលមានវត្ថុមិនស្អាត, ស្មោកគ្រោក, ចេញចូលជានិច្ចនិរន្តរ៍, ធ្វើឲ្យទៅជាស្អាតបាន?" ។

ព្រះអង្គម្ចាស់គុណាករខ្ញុំមានបន្ទូលដូចនោះហើយខ្ញុំបន្តមតទៅទៀតថា: "តើមាតាមានអ្វី? តើបិតា, ភរិយា, បងប្រុសមានអ្វី? គឺជាបទបញ្ញត្តិច្បាប់នៃពិភពលោក, តើតហើយស្អប់ ។ ចុះអ្នកណាធ្វើពលិកម្មហើយនឹងសក្ការបូជាដោយយល់ថាព្រះអគ្គីជាព្រះអាទិទេព ហើយអ្នកណាដែលគ្មានវិចារណញ្ញាណយល់ថាអាកាសអ្នកតាជាព្រះអាទិទេពរបស់

ខ្លួន ។ ពួកយោគីគិតថា ព្រះហរិស្ថិតនៅក្នុងខ្លួន ។ ខ្ញុំមិនបានបំពេញករ-
ណីយកិច្ចខាងគ្រួសារ, តែខ្ញុំរស់នៅប្រព្រឹត្តប្រតិបត្តិតាមវិន័យយោគី" ។

ដល់ទ្រង់មានព្រះបន្ទូលដូចនោះហើយ, ទ្រង់ក៏ចេញពីព្រះបរម-
ភដំណាក់, រួចត្រឡប់ទៅកាន់អាស្រមព្រះយោគីវិញ ហើយទ្រង់គង់នៅ
លើភ្លើង សូត្របូមន្តគាថា. តែយក្ខិនីនោះមិនរួចត្រឡប់មកវិញសោះ
ឡើយ ។ រួចទ្រង់ក៏ស្តេចទៅរកព្រះយោគី ។ ទូលសួរទ្រង់ថា:
"វិទ្យាសាស្ត្រ (ប្រហែលជាយក្ខិនី) មិនមកឬ?" ។ ទ្រង់មាន
បន្ទូលតបថា "មិនឃើញមកទេ, លោកគ្រូ!" ។

អាវក្សបានឮណាទូវឿងនេះចប់សព្វគ្រប់, ទើបក្រាបបង្គំទូល
សួរមហាភដថា: "បពិត្រព្រះចមកត! ហេតុដូចម្តេចបានជាវិជ្ជាមិនចូល
មកស្ថិតនៅក្នុងចិត្តនៃខ្ញុំគុណកវ?" ។

ព្រះមហាភដទ្រង់មានព្រះបន្ទូលតបទៅអាវក្សវិញថា "បានជា
វិទ្យាសាស្ត្រ (មិនដឹងជាយក្ខិនីឬយក្ខិនីនេះជាបដិមារូបនៃវិជ្ជាសាស្ត្រឬ
វិជ្ជា, ឬក៏ការគ្រាស់ដឹងឃើញច្បាស់ទូវធម៌?) មិនមក ព្រោះថាព្រះអង្គ
ម្ចាស់នេះ ទ្រង់មានព្រះទ័យឃ្មេងឃ្មោង ហើយគេពោលថា: "អ្នក
ណាដែលមានចិត្តនឹងខ្លួន, រូបមន្តនោះអាចឲ្យផលដ៏វិសេសវិសាល"
មានគេពោលថា: "កិត្តិនាមមិនអាចមានបានចំពោះអ្នកណាដែលជា
អសប្បុរស, អ្នកណាដែលគ្មានសច្ចធម៌, អ្នកនោះ ជាអហិរិកបុគ្គល

(impudent) ។ អ្នកណាដែលប្រតិត្តនុច្ចវិត អ្នកនោះមិនអាចមានកោតក្រែងខ្លាចឡើយ ហើយអ្នកណាមិនដែលធ្វើសមាធិចិត្ត អ្នកនោះមិនអាចឃើញព្រះអរិយទេព" ។

អារក្សវៃតាល (Baitâl) ក្រាបបង្គំទូលសួរមហាក្សត្រទៀតថា: "ព្រះអង្គម្ចាស់ ខ្ញុំមានព្រះបំណងចង់បានទូរវិជ្ជាវិសេសវិសាលនោះខ្លាំងក្លាក្លៅ, តើត្រង់ណាដែលខ្ញុំប្រមាទ?" ។

មហាក្សត្រាស់តបទៅអារក្សវិញថា: "ព្រះអង្គម្ចាស់ខ្ញុំមិនបានទៅសិក្សារៀនសូត្រវបមន្តនោះ ខ្ញុំស្តេចទៅសួរព្រះពជវង្សាទុវង្សវិញ, បានជាព្រះយោគីខ្វាល់ ហើយពោលថា: ម្តេចក៏បង្ហាត់បង្រៀនវិជ្ជាដល់សាវ័កដែលមានចិត្តភាយមាយដូចនេះ ព្រោះហេតុដូចនេះ បានជាខ្ញុំមិនបានទូរវិជ្ជានោះ ហើយមានគេពោលថា: ជោគវាសនាត្រូតត្រាលើមនុស្សលោក ទោះមនុស្សនោះមានពលភាពយ៉ាងណាក៏ដោយ, ឬបំពេញកិច្ចការដោយប្រាជ្ញាយ៉ាងណា, មនុស្សនោះត្រូវទទួលផលតាមអំណាចរបស់ជោគវាសនាទាំងអស់" ។

អារក្សដែលបានឮមហាក្សត្រខ្ញុំមានព្រះបន្ទូលចប់សព្វគ្រប់, ក៏វិលត្រឡប់ទៅកាន់ភក្តិដូចពីដើម, ហើយមហាក្សត្រខ្ញុំបានទៅយកអារក្សនោះលើលែព្រះអង្គារហើយក៏នាំយកទៅ ។

វិធ្លី

ទេ ខ្ញុំថាមិនដែលទេអ្នក! ខ្ញុំគិតយ៉ាងនេះគឺខ្ញុំគិតដល់អ្នកដែរ ។

តារា

ទេ បើអ្នកគិតដល់ខ្ញុំ អ្នកមិនអាចនឹងហ៊ានប្រព្រឹត្តបែបហ្នឹងទេ ។

វិធ្លី

ណ្ហើយ! គំនិតសូញ្ញាសាញច្រើន ខ្ញុំមិនចូលចិត្តទេ! ខ្ញុំចង់ឲ្យ ការនេះបានសម្រេចយ៉ាងឆាប់, ឯណាអានោះទៅណាបាត់ហើយ, អ្នកឯងយកទៅលាក់ហើយឬ? ។

តារា

និយាយឲ្យស្រួលបួលអ្នក! ប្រសាសន៍របស់អ្នកថ្ងៃងមកនេះ មិន គួរឲ្យខ្ញុំផ្ទៀងត្រចៀកស្តាប់ទេ! ហើយមិនគួរអ្នកហ៊ានពោលពាក្យ យ៉ាងនេះចំពោះមុខខ្ញុំសោះ ខ្ញុំមិនត្រូវការទៅលាក់កូនរបស់អ្នកធ្វើអ្វី ។

វិធ្លី

បើអ្នកមិនលាក់ ម្តេចក៏កូនខ្ញុំមិនដែលឃើញទៅផ្ទះខ្ញុំសោះ តាំង តែពីប្រពន្ធវាស្លាប់ទៅ, ជាង ១ អាទិត្យហើយ វាមិនដែលឃើញទៅ អើតផ្ទះខ្ញុំ ខ្ញុំឆ្ងល់ណាស់ ។

តារា

តែងំកូនអ្នកទៅអើតផ្ទះប្តូមិនទៅ ខ្ញុំឥតបានទៅដឹងរឿងហេតុនោះទេ កុំបាច់អ្នកឆ្ងល់ធ្វើអ្វី មិនដែលមាន គ្នាកំពុងតែព្រួយចិត្ត ដេកកើតទុក្ខពាល់ថ្ងៃហើយឲ្យគ្នាទស្សាហ៍ដើរទៅមកទៀត, អ្នកមិនដឹងទេ តើកូនអ្នកសព្វថ្ងៃ កើតទុក្ខយ៉ាងណា ? ។

វិជ្ជី

ព្រោះតែវាកើតទុក្ខហ្នឹងហើយ ឃានជាខ្ញុំរកប្រពន្ធឲ្យវាទៀតដើម្បីនឹងធ្វើកុំឲ្យវាកើតទុក្ខពេក ឲ្យវាល្មៃទុក្ខបន្តិច ។ នែអ្នក! វាកើតទុក្ខតែនៅមិនទាន់ឃានគ្នាទេ តែដល់វាឃានគ្នាជាប្តីប្រពន្ធទៅ វាក្ងេចឃាត់ទៅហើយ សេចក្តីទុក្ខសោករបស់វានោះ ។

តារា

ការតែងំហ្នឹង ខ្ញុំពុំអាចនឹងអធិប្បាយដំរាបអ្នកឃានទេ ! ស្រែចតែលំគំនិតអ្នកចេះតែខ្វៃទៅចុះ ។

ឆាកទី ២

វិជ្ជី-រាគា-តារា

តារា

មើលកូនប្រុសម្តាយ ! ម្តាយចង់សួរកូនឯង អំពីរឿងប្រពន្ធកូនឯងឯក្រោយនេះបន្តិច, តម្លៃវាមកឯងយកអ្នកឯងទៅរៀបការក្នុងថ្ងៃ

ស្អែកនេះ ឯខេត្តស្វាយរៀង តើឯងនឹងថាយ៉ាងដូចម្តេច? កិច្ចត្រង់ហ្នឹង ស្រេចតែឯងចេះលៃលកទៅចុះ ម៉ាក់មិនរាំង មិនបង្ខិតបង្ខំឯងទេ ស្រេចតែតាមអំពើចិត្តឯងចុះ ។

រាគា

អ្នកម្តាយ! សូមអ្នកម្តាយជ្រាបថា សេចក្តីស្នេហារបស់ខ្ញុំ លែងដុះដាលកើតឡើងទៀតហើយ គឺលែងត្រូវការនឹងរូបស្ត្រីដែលយកមកធ្វើជាប្រពន្ធជាកូនទៀតទេ ។ ខ្ញុំស៊ូតែនៅពោះម៉ាយយ៉ាងដូច្នេះឲ្យតាល់តែអស់ជីវិត ។

តារា

ចុះបើម្តាយរបស់ឯង បានដណ្តឹងកូនគេហួសទៅហើយ តើឯងនឹងអាចឲ្យម្តាយឯងឈប់ឯណាបាន ។ នែកូនប្រុសម្តាយ! ពាក្យថាស់លោកថា "សូវបង់ប្រាក់កុំឲ្យតែបង់សំដី" ឬថា "រនាបបាក់គ្រាន់នឹងដួសបាន បើសំដីហួស គ្មានអ្វីនឹងដួសបានទេ" ហេតុនេះកូន! ចូរឯងគិតឲ្យវែងឆ្ងាយ ។ អាណិតម្តាយឯង ឬអាណិតកូនប្រសើរជាង? ទៅលើរូបទាំង ៣ នេះ ស្រេចតែលើឯងលៃលកគិតមើលទៅ ។ ឯរូបម្តាយមិនអីទេ, ហាក់ដូចជាដើងក្រោយទេ ។

រាគា

អ្នកម្តាយរបស់ខ្ញុំ ពិបាកណាស់ បើខ្ញុំគិតតែតាមសេចក្តីអាណិតអាសូរដល់ខ្លួនរបស់គាត់នោះ គឺខ្ញុំត្រូវតែខ្ជិលធ្វើតាមសំដីរបស់គាត់ ។

ប៉ុន្តែបើតាមចិត្តដែលក្តៅនឹងគាត់ធ្វើហួសយ៉ាងដូច្នេះ គឺខ្ញុំមិនយកទេ អាណិតកូនណាស់ កូនទៅតូច កំពុងស្រឡាញ់កិច្ចការរៀនសូត្រ, តែខ្ញុំបានប្រពន្ធមួយទៀត ប្រហែលជាក់មិនសូវគិតនឹងកិច្ចការរៀនសូត្រប៉ុន្មានទេ រវល់តែប្រទូសរ៉ាយនឹងម្តាយចុងរាជាពុំខាន ។ ហើយបើខ្ញុំរស់នៅវាគ្រាន់បើ ចុះបើខ្ញុំស្លាប់ទៅ ប្រហែលជាម្តាយចុង គេមិនត្រែកត្រអាលនឹងទុកបំរុងឲ្យរៀនសូត្រ បានតេញលេញដូចជារស់នៅទេ ។

អ្នកម្តាយសូមមេត្តាអត់ទោសទៅចុះ ខ្ញុំមិនត្រមទទួលយកទេ ។

វិធី

ចុះឯងមិនត្រមធ្វើម្តេចនឹងកើត បើអញជណ្តឹងកូនគេហួសទៅហើយ ។

រាគា

អ្នកម្តាយអញ្ជើញទៅនិយាយដូនគេទៅវិញទៅ ! រូបមនុស្សវាក់មិនមែនដូរប្តូរអ្វីដូចជាចំណីអាហារនោះទេ ។

វិធី

ទេ ! អញជាមនុស្សធ្លាប់តែគេអង្វរ អញមិនដែលទៅអង្វរអ្នកណាឲ្យបានម្តងទេ តាំងតែពីអញដឹងក្តីកាលណាមក គឺសុទ្ធតែគេ

និយាយអង្វរមកវាកអញ ដោយពាក្យទន់, តែគេអង្វរអញ អញមិនដែលទៅលើកដៃសំពះអ្នកណាឲ្យបានម្តងទេ ។

រាគា

អ្នកម្តាយ! សេចក្តីគោរពរបស់មនុស្សប្តីប្រពៃភាព មិនជាការពិបាកប៉ុន្មានទេ, មិនថោកអ្វីនឹងដៃ ថ្លៃអ្វីនឹងមាត់ គេគ្រាន់តែឮសំដីរបស់យើងតួញក្អែរ គេគ្រាន់តែឃើញដៃយើងលើកឡើងនឹងសំពះ គេទន់ចិត្ត មានសេចក្តីអាណិតដល់យើងភ្លាម ។

រិទ្ធី

ទេ! បើដូច្នោះឯងទៅអង្វរខ្លួនឯងចុះ អញមិនទៅទេ អញខ្មាសមុខគេណាស់ ។

រាគា

ឲ្យខ្ញុំទៅម្តេចនឹងបាន! ខ្ញុំមិនមែនជាអ្នកដណ្តឹងឯណា គឺប្រុសអ្នកម្តាយទេតើ ដែលជាអ្នកមេបានោះ ខ្ញុំទៅនិយាយនឹងគេមិនកើតទេ ។ មិនមែនអង្វរគេថាមិនយកទេ តែកុងវ៉ាង ១០ ឬ ២០ ផ្ទាំតទៅមុខទៀត ខ្ញុំត្រូវទទួលយក ។

រិទ្ធី

បើយ៉ាងដូច្នេះ ឯងមិនចាំបាច់ថាអង្វរធ្វើអ្វីទេ! ឯងថាឯងមិនយកតែម្តងទៅ វាស្រួលថាជាង ។ អញដឹងហើយ កិរិយារបស់ឯងនេះ

ឯងរកតែឧបសគ្គណាដែលយកមកពាំងជំទាស់ការណ៍ហ្នឹង ឲ្យតែខាងការមិនកើត ។ ឯងគ្រាន់តែហាមាត់ឡើងក្លាម អញយល់ក្លាម គឺដូចជាជាងគំនូរគ្រាន់តែវាសឡើង គេអាចស្គាល់រូបគំនូរបាន ។

រាគា

អ្នកម្ដាយគិតមើល! ឲ្យខ្ញុំទទួលដូចម្ដេច បើខ្ញុំនៅតែកើតទុក្ខណែនក្នុងដើមទ្រូង មិនទាន់បានស្លៀកបន្ដិចផង ។ អ្នកម្ដាយ! ខ្ញុំសូមជំរាបនូវពាក្យ ១ ឃ្លាខាងក្រោយនេះថា ជាតិនេះគឺខ្ញុំជាប់ថ្នាំតែមួយនឹងមួយ ខ្ញុំសូមសច្ចាថានឹងមិនឲ្យស្ដ្រីឯណាមកប៉ះពាល់ដល់ខ្លួនខ្ញុំបានទៀតទេ ខ្ញុំសុខចិត្តនៅពោះម៉ាយ ពាក់កំណាត់ខ្មោកាន់ទុក្ខនាងប្រពន្ធខ្ញុំ ឲ្យតាល់តែខ្ញុំអស់ជីវិត ។

វិដ្ឋ

ចុះអាកាគា! អាឯងក៏ពាក:អ្វីច្រើនម៉្លេះអា! ទៅ ទៅ! អាឯងទៅដេកអោបធរប្រពន្ធអាឯងទៅ ។ អ្នកតាវ! ត្រូវអ្នកតំចាត់អាហ្នឹងឲ្យវាចេញពីលើធ្នូរអ្នកទៅ លែងឲ្យវានៅ ខ្ញុំស្អប់ណាស់, អាដែងកូនមិនស្គាប់បង្គាប់ ។ ខ្ញុំចង់តែប្ដឹងកដការខាងក្រុមនគរបាលឲ្យមកចាប់អាហ្នឹងជាក់វេយន្ដល្ងាចនេះតែម្ដង ។

គារា

ន! អ្នកម្ដាយចង់ទៅប្ដឹង ឲ្យក្រុមនគរបាលមកចាប់ខ្ញុំទៅការ ។
ន! អ្នកម្ដាយអើយ ខ្ញុំមិនដែលបានប្រទះនឹងប្រាប់ប្ដូមាត្រានៃរដ្ឋធម្មនុញ្ញ

ត្រង់ណាសំដែងអំពីរឿងអាពាហ៍ពិពាហ៍ដោយបន្ទុំនេះទេ, ពាក្យរលោកមិនមែនយល់ខុសដូចអ្នកម្ដាយមានប្រសាសន៍នេះឡើយ ។

វិទូ

លែងនិយាយ! នែអ្នកតាក! អ្នកហើយជាកសិណសាក្យរបស់ខ្ញុំ! ខ្ញុំនឹងប្ដឹងជាក់ទោសអានេះឲ្យគេយកពាក្យត្រសួងតុលាការតែម្ដង! អាកូនវ៉ែរូស! អាកូនមិនដោយដំបូនមាន! អាកូនព្រហើនកោងកាច! ។

(ចេញ)

តារា

មើលសព្វៗទៅ ហាក់ដូចជាពិបាកនឹងនិយាយណាស់! ទំនងដូចជាខ្ចប់សតិបញ្ញាអស់ទៅហើយ បានជាចេះតែពោលពាក្យបែបយ៉ាងដូច្នេះ ។

រាគា

ចូរម៉ាក់សង្កេតមើលចុះ! កិរិយារបស់អ្នកម្ដាយខ្ញុំ! គាត់ជាមនុស្សប្រកាន់ច្រើនណាស់! ជាមនុស្សមាន: ចចេស ខ្ជូនខុសប្រកាន់ថាជាត្រូវ និយាយឥតបើគិត អាងតែខ្ជូនអ្នកមានសម្បត្តិ ។

តារា

កូនឯងត្រូវប្រុងយ័ត្នពាក្យសំដីរបស់ឯងឲ្យមែនទែន កុំពោលពាក្យទ្រគោះបោះបោកឲ្យគាត់ បើទុកជាខឹងយ៉ាងណាក៏ដោយ ចេះតែនិយាយឲ្យស្រួលទៅ, ធ្វើម្ដេចបាស់យ៉ាងដូច្នេះហើយ រញ៉ាំរញ៉ូវច្រើនណាស់ ។

ឯងមិនឮទេ! គាត់ចូលមកដល់ផ្ទះក្តាមស្រាប់តែថាអញលាក់ឯង អញចង់ចាន់ឯង គាត់មកដាក់ផ្ទៃផ្តាឲ្យអញ សុទ្ធតែអញមេម៉ាយស្រពោនសុទ្ធតែអញអ្វីៗ ឯណាតែផ្តាស ។ (រាងចេញ)

ឆាកទី ៣

រាគី-រាគា-វណ្ណានារី

រាគី

លោកចា៎មានរឿងហេតុអ្វី ក៏ចេះតែព្រមត់ខ្ញាំងៗ អ្វីសម្បើមម្ល៉េះ? ។

រាគា

កូន! លោកយាយរបស់ឯងគាត់ខឹងណាស់ ព្រោះចា៎មិនព្រមទៅរៀបការកូនថ្លៃស្អែកនេះ ឥឡូវគាត់ទៅប្តឹងក្រមនគរចាលចាត់ទៅហើយ ឲ្យគេមកចាប់ចា៎ដាក់វេយន្តយកទៅការកូនថ្លៃស្អែកនេះ ។

រាគី

លោកយាយ! នុលោកយាយអើយ! លោកយាយមិនខ្វាសគេទេកូនអំពើរបៀបហ្នឹង, គ្រាន់តែកិច្ចអាពាហ៍ពិពាហ៍របស់កូនឯងចាំចាប់ទៅប្តឹងដល់រាជការឲ្យនាំអំពល់ទុក្ខ ដោយរឿងរំកាចរំកោចយ៉ាងដូច្នេះ ។ លោកចា៎កុំទៅឲ្យសោះណាលោកចា៎! បើអ្នកណាវ៉ាមកចាប់ ទុកឲ្យខ្ញុំវ៉ាយដំនួសលោកចា៎ ខ្ញុំកុំពុងតែស្អប់ប៊ូលិសអូចៗយ៉ាងនេះផង ។

នែវណ្ណានារីអូន! លោកយាយយកចា៎ទៅការកូនថ្លៃស្អែកនេះហើយ ។

(រាងចូល)

វិណ្ណ៌ជារី

ច្រែកដហើយឬបង! ខ្ញុំលោកយាយម្តេចក៏ច្រឡាប់អ្វីសម្បើមម្ល៉ះ, ម៉ាក់ខ្ញុំស្ទាប់ទៅមិនទាន់ចុះខ្ញុំ អាទិត្យផង ម្តេចក៏បង្ខំរៀបការយ៉ាងដូច្នេះ។

រាគី

នែ, លោកយាយទៅប្តឹងប៉ូលិសហើយ! ឲ្យវាមកចាប់ប៉ាយើងយកទៅរៀបការ ពីព្រោះប៉ាលោកច្រកែកណាស់ ។

វិណ្ណ៌ជារី

បងកុំភ័យ! មិនអីទេការប៉ុណ្ណឹង បងទុកឲ្យខ្ញុំយំឲ្យចាល់តែគេធ្វើការមិនកើត បងកុំភ័យឲ្យសោះ ខ្ញុំស្រែកយំឲ្យផ្តើលគេឯង ធ្លោឲ្យចាល់តែគេលែងប៉ាទើបខ្ញុំសុខចិត្ត ។

រាគី

ប្អូនយំចុះ! ទុកឲ្យបងវាយ! បងវាយទាំងអស់ អាណាចូលផ្ទះយើងទាំងប៉ុន្មាន ។

វិណ្ណ៌ជារី

បងឯងវាយលោកយាយដែរឬ?

រាគី

វាយទាំងអស់ឲ្យតែប៉ះមុខ! យាយហ្នឹងតែតែវាយច្រែនជាងគេផង ព្រោះតែយាយហ្នឹងតើដែលជាអ្នកនាំខូច យាយហ្នឹងហើយជាមេប៉ះចោរ។

(មានត)

រឿងប្លន់ធនាគារ

លោក ដេង-ជ្រៃ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តមក)

ដំបូន្មានដែលឯងនៅអាចឲ្យឯងធ្វើនូវអំពើល្អ ប្រាន់ដោយងាយអាចឲ្យឯងតាំងខ្លួនជាមនុស្សចិត្តល្អ និយាយពិត ស្មោះត្រង់ មានតម្រិះចេះអត់ធ្មត់ស្គាល់ប្រមាណ ចិត្តបរិសុទ្ធ ចិត្តខ្ជួលឈួយ ចេះអាណិត មានគុណធម៌គង់ខ្លួន គ្មានអកុសលធម៌ណាមួយមកធ្វើឲ្យរញ៉ាមចិត្តដ៏ផូរផង់របស់ឯងដែលកំពុងរីក ។ ទេព្រោះឲ្យឯងមានឯកឧត្តមចិត្តគ្មានកេរ្តិ៍ មានចិត្តស្មោះចំពោះការងារ មានម៉ត្តិច្រើន, ស្តេចផែនដីដែលឯងចូលចិត្តចង់ប្រាន បុណ្យស័ក្តិអំពីព្រះអង្គ ទ្រង់មិនមែនសប្បាយចិត្តនឹងឯងឡើយ ។

– ខ្ញុំលោកអើយ! ពាក្យសំដៅតែគ្មានវ៉ីស៊ីនី បើគ្មានឯងហើយ ខ្ញុំក៏គ្មានចិត្តល្អទាំងអស់ បើមានវ៉ីស៊ីនី ខ្លួនខ្ញុំមានត្រឹម ។ តំណាងហ្នឹងហើយជាកំណើត ជាជ័យមង្គល ជាសម្បត្តិរបស់ខ្ញុំ ។ តែដ្បិតបងប្អូនវ៉ីស៊ីនី ចង់ឲ្យនាងមានប្តីនាហ្នឹងធំ ព្រោះគេឃ្លានជាអ្នកជ្ញាជ្ញ មានល្បីឈ្មោះ មកពីខំស្ទឹងស្វាធ្យានសូត្រ ខំអានគម្ពីរ, បើដូច្នេះ ខ្ញុំគិតចង់ទៅរៀនដូចគេដែរ ។ បើខ្លួនខ្ញុំមានវិជ្ជាការណា ខ្ញុំនឹងជាមនុស្ស

មានប្រយោជន៍ដល់ផែនដីដោយពន្លឺ គឺបញ្ញានៃខ្ញុំ គ្មានធ្លាប់ដល់អ្នកណា គ្មានស៊ីដោយសារអ្នកណា ខ្ញុំទៅជាមនុស្សគ្រាន់បើមួយ ហើយសំរស់ស្តីនឹងមានចំពោះខ្លួនខ្ញុំតែម្នាក់ឯង ។

— តុកូន ! អ្នកមានវិជ្ជាសឹងគ្រប់មាន ជាងអ្នកមានទ្រព្យនឹងមានជាតិ គឺវិជ្ជានេះហើយជាទ្រព្យយ៉ាងធំបំផុត ព្រោះគ្មានអ្នកណាអាចដកហូតយកបាន ហើយយើងទៅទីណាវិជ្ជាជាប់នឹងខ្លួនយើងទៅផង នឹងជាទីស្រឡាញ់នៃមហាជន តែវិជ្ជាថ្លៃណាស់ ។ តេស្សែងរកបានមកដោយការអត់ធ្មត់នឹងសការៈគ្រប់យ៉ាង ដោយចិត្តឈឺចាប់ដ៏រហ័សយ៉ាងសំខាន់ដែលធ្វើឲ្យមានសេចក្តីលំបាកខាងក្នុងនឹងខាងក្រៅ ដោយមនុស្សផងគ្នាធ្វើទុក្ខបុកម្នេញពេក ។ នៅប្រទេសបាំង ពួកព្រះអង្គម្ចាស់មិនធ្លាប់ឮឈ្មោះកូនការពាហានឡើយ ហើយមនុស្សជាច្រើនចូលចិត្តដើរតាមផ្លូវដែលឯងគិត ព្រោះគេចង់ឲ្យមានធ្លាប់ជាវាងវៃ ។ ឯងថាមកមើល តើឯងចង់បំរើមនុស្សលោកឬអ្វី? តែអ្នកណាមួយ កុំបាច់យកច្រើន តែសំណាងមួយក្តាប់ទៅជាំនឹងដី អ្នកឈ្មោះថាជាមនុស្សមានប្រយោជន៍ដល់មនុស្សផងគ្នាជាងឲ្យគម្ពីរមួយ ។

— អីស្រីដែលជាំដើមល្អឯងហ្នឹងឈ្មោះថា ហុចប្រយោជន៍ដ៏ល្អដល់មនុស្សជាតិកន្លងវែងជាងស្រីនោះធ្វើបណ្ណាល័យទៅទៀត ។

កន្លងណៈនោះ អាប៉ូលស៊ុះទៅនុបដើមល្អឯងហើយថើបដោយកាមភាគចិត្ត ។

— បណ្ដាគម្ពីរចាំង ឡាយ គម្ពីរដែលសំដែងពីសមភាព សិនេហភាព មនុស្សភាព សាមគ្គីធម៌នឹងច្បាប់នៃព្រះគ្រិស្ត នាំបណ្ដាលជាហេតុឲ្យ កើតក្តៅក្រហាយអន្តរកំបុកក្នុងប្រទេសអ៊ីរុបអស់រវាងសតវត្សមួយ ។

« រឿងប្រកាប់ប្រចាក់ជាផ្លូវទុច្ចរិតដែលមានជាច្រើនតាំងពីដើមមក ក៏នៅមានរហូតដល់ឥឡូវនេះ ។ ដូច្នេះ អ្នកណាមួយនឹងចូលចិត្តនិពន្ធនូវ គម្ពីរជាប្រយោជន៍ដល់មនុស្សក្នុងលោក! ឯងចាំឬទេ អ្នកច្បាប់ចាំង ឡាយ ដែលសំដែងនូវធម៌សុចរិតហើយបានដល់នូវសេចក្តីទុក្ខ យ៉ាងធំរហូត អស់ជីវិតក៏មាន? ។ ហោមែ (Homer) ជាអ្នកតែងកាព្យយ៉ាងល្បីឈ្មោះ ដើរសុំទានគេស៊ីទេ អស់មួយជីវិត ។ សុក្រាត (Socrate) ដែលជាអ្នកតែងពាក្យប្រៀនប្រដៅច្បាប់ទំនៀមទំលាប់ដ៏ល្អដល់អ្នកនគរ អាតេនី សឹងស្លាប់ដោយគ្មានឯងចំពុល ។ លោកប្លាតុន (Planton) ជាសិស្សលោក សុក្រាតត្រូវប់ទៅជាទាសៈគេ ព្រោះតែស្តេចដែលទំនុកបំរុងលោក មុន លោកខាងលើនេះទៅទៀត មានអ្នកច្បាប់ម្នាក់ឈ្មោះពីតាគ័រ Pythagore) ត្រូវគេចាប់ដុតចាំងរស់មកតែពីការពោលថាមនុស្សនឹងតិរច្ឆានមិនប្លែក គ្នាប៉ុន្មាន ។ បើយ៉ាងដូច្នេះតើឲ្យអញថាដូចម្តេច? មានអ្នកច្បាប់ល្បីឈ្មោះ ជាច្រើនណាស់ទៀត ដែលបានទទួលទុរសេចក្តីអន្តរាយបែបយ៉ាងនេះ តែគ្រាន់តែអំពើអកុសលៗសគ្គាប៉ុណ្ណោះ ។ ជាតិមនុស្ស លោកប្រកបដោយចិត្ត អតត្តញ្ញូ ចូលចិត្តចង់ស្តាប់អ្នកច្បាប់ចាំងនោះដែរ

អ្នកប្រាជ្ញណាមួយដែលផុតពីទុក្ខទោស លុះណាតែខ្លួនទៅនៅឆ្ងាយ
ពីពួកមនុស្សសាមញ្ញ ឬពីគ្នាឯង ។

"ឯងឃើញឬទេ បើចង់ឲ្យមានកេរ្តិ៍ឈ្មោះខាងអក្សរសាស្ត្រ ត្រូវឲ្យចិត្ត
តឹមត្រូវស៊ូបូរដំរៃខ្លួន ? ។ ម្យ៉ាងទៀត ឯងស្មានថាអ្នកមានសម្បត្តិនៅ
ឯប្រទេសបាំងត្រូវការនឹងវិជ្ជាហ្នឹងឬ? មិនដូច្នោះទេ គេអផ្សុកនឹងមនុស្ស
ចេះខាងអក្សរសាស្ត្រណាស់ ដ្បិតវិជ្ជាអក្សរមិនមានទាំមកនូវបុណ្យសក្តិ
កងព្រះនគរ កងផ្កាយជការ ឬនឹងនាំឲ្យបានធ្វើការងារកងហួង ដល់
មនុស្សអ្នកចេះនោះសោះ ។ កងសតវត្សនេះ ពន្ធីគឺប្រាជ្ញនឹងសេចក្តី
សុចរិតមិនមែនឲ្យប្រយោជន៍អ្វីឲ្យប្លែកប៉ុន្មានទេ ព្រោះការរាជការកង
ព្រះនគរសុទ្ធតែតម្លៃជាប្រាក់ អ្នកណាចង់ធ្វើរាជការ លុះតែមានប្រាក់
យកទៅសូកគេ ទើបបានការធ្វើ ។ ពីដើមវិជ្ជាអក្សរសាស្ត្រឲ្យប្រយោជន៍
ផ្សេង។ ប្រែទៅខ្វែងកងរាជការខាងសង្ឃ កងតុលាការនឹងរដ្ឋបាល សព្វ
ថ្ងៃនេះ ឲ្យប្រយោជន៍តាន់តែសរសេរសៀវភៅទុកសម្រាប់ឲ្យគេអាន
ប៉ុណ្ណោះ ។ ហើយលទ្ធផលនេះ មិនសូវជាទីពេញចិត្តនៃមហាជនក៏ពិត
មែន តែគង់មានប្រយោជន៍ជានិច្ចតាមជាតិនៃវិជ្ជា ។ គម្ពីរទាំងឡាយនេះ
ជាពន្ធីដល់ទីឆ្ងាយ សម្រាប់លួងមនុស្សមានទុក្ខក្តៅក្តុលណា បំភ្លឺជាតិ
ទាំងឡាយនាំឲ្យចេះនិយាយការពិត ទាំងស្តេចផែនដីក៏ដោយ ។ បើ
កុំយល់ទាស់ គឺទុកជាតារាវគាពមួយដ៏សំខាន់ដែលខ្ពង់ទាំងឡាយតោង

មានចំពោះមនុស្សស្មានតណ្ហាល ។ តើមនុស្សពួកណាដែលមិនសុខចិត្ត
នឹងការខុចុរិតនឹងសេចក្តីមើលងាយ នៃជនទាំងឡាយជាអ្នកមានទ្រព្យ
បើកាលណាគេដឹងច្បាស់ជាស្មាដៃនៃខ្លួននឹងប្រព្រឹត្តទៅបាន ពីសតវត្ស
មួយទៅសតវត្សមួយ ពីសាសន៍មួយទៅសាសន៍មួយ សម្រាប់ជារបា
ដល់ចិត្តយល់ភាន់ ដល់អ្នកតំណាចអាក្រក់ ហើយគេបញ្ចេញកេរ្តិ៍ឈ្មោះ
ពីរហោស្ថានជាកន្លែងលំនៅនៃខ្លួនទៅរំលុបរំលាងកេរ្តិ៍ឈ្មោះ នៃព្រះពាជ
ទាំងឡាយដែលបានកសាងច្បាសាទធំ ។ ជាវត្តតែងវិនាសទៅកងអន្ទង់
គឺការក្ងេច ទោះបីមានមនុស្សឧស្សាហ៍អួតសរសើរក៏ដោយ ។

– បើឯចិន ខ្ញុំចង់បានកេរ្តិ៍ឈ្មោះហ្នឹង ដើម្បីផ្សាយទៅលើវិស័យនឹង
នឹងជាប្រយោជន៍កងលោកផង ។ តែអ្នកដែលចេះដឹងច្រើន ប្លែអ្នកថា
ល្ងង់មើល តើយើងទាំងពីរនាក់នឹងបានគ្នាជាប្តីប្រពន្ធឬទេ? ខ្ញុំចង់ធ្វើ
ជាអ្នកច្បាស្រ ទោះបីម្តេចម្តា គ្រាន់តែឹងស្គាល់ការណ៍ខាងអនាគត ។

– នែកូន! អ្នកណាចង់រស់ ចាំបាច់តែស្គាល់អនាគតអី! តែឲ្យដឹង
សេចក្តីទុក្ខមុន នាំឲ្យតែត្រួយគតប្រយោជន៍, តែដឹងទុក្ខមុនច្បាកដ នាំឲ្យ
ធ្វើទាស់ទែងដល់ទៅឆ្លៀកាយទៀត ។ គេថែមទាំងមិនត្រូវគិតឲ្យសព្វ
គ្រប់ពេកផង អំពីរបស់ដែលនៅដុំវិញខ្លួន ។ ព្រះជាម្ចាស់ដែលបង្កើតឲ្យ
យើងចេះពិចារណាដើម្បីសម្រាប់គ្នាន់នូវរបស់ត្រូវការ ហើយបង្កើត
របស់ដែលយើងត្រូវការ ដើម្បីជាទំនប់ដល់គំនិតយើង ។

– អ្នកថា នៅប្រទេសជប៉ុន តែមានជ្រាក់ គេអាចរកបានបុណ្យ
ស័ក្តិដោយងាយ ។ ខ្ញុំគិតទៅស្មើនឹងទ្រព្យឯប្រទេសបេង្គាល (bengal)
ឲ្យមានបរិបូណ៌ហើយនឹងរៀបការជាមួយវ៉ែស៊ីនី ។ ខ្ញុំបងគិតដំរកប៉ាល់
ទៅស្អែក ។

– ម៉េច? អីឯងដើរចាលម្តាយវ៉ែស៊ីនី នឹងម្តាយខ្លួនឯង? ។

– ប៉ុនអ្នកខ្លួនាន់ខ្ញុំឲ្យទៅប្រទេសកូឡុំដើម្បីរកធនធាន ។

– គាលណោះ ដែលវ៉ែស៊ីនីនៅក្នុងទីនេះ ។ ឥឡូវគឺឯងហ្នឹង
ហើយជាបង្គោលជាពំនឹងដល់ម្តាយឯងនឹងម្តាយនាង ។

– វ៉ែស៊ីនី នឹងបញ្ជូនលុយកាក់មកចិញ្ចឹមលោកតាំងពីរបាននោយ
ស្រួល ព្រោះបងប្អូនមានទ្រព្យ ។

– អ្នកមានទ្រព្យជួយចិញ្ចឹមខ្លួន លុះណាតែខ្លួនជួយលើកមុខគេនៅ
កណ្តាលមហាជនផង ។ ខ្លះអីបងប្អូនគេ គួរឲ្យអាណិតជាងនាងឡាគួរ
ទៅទៀត ហើយគ្មាននរណាជួយចិញ្ចឹម ស៊ូលះបង់ការសប្បាយទៅនៅ
សម្ងំកងវត្តដើម្បីឲ្យវាស់ខ្លួន ។

(មានត)

សកម្មភាពនៃក្រុមជំនុំនៀមទម្ងាប់ខ្មែរ

លោក ជាប - ពិនថ្លែងដំណឹងវិទ្យុប្រទេសកម្ពុជា នៅថ្ងៃទី ៣១ / ១ / ៥៣ ព. ស. ២៤៩៥

ដំរ្បាយបេញ្ញពីពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

អស់លោក - អ្នកតាំងឡាយ !

ខ្ញុំបាទបានទទួលកិត្តិយសមកប្រស្រ័យជាមួយអស់លោក - អ្នកតាំងឡាយដោយសំឡេងវិទ្យុប្រទេសកម្ពុជា ក្នុងនាមពុទ្ធសាសនបណ្ឌិត្យ រៀបរាប់អំពីសកម្មភាពរបស់ក្រុមជំនុំនៀមទម្ងាប់ខ្មែរ ដែលព្រះរាជ-រដ្ឋាភិបាលបានតាំងឡើងដើម្បីស្រាវជ្រាវនឹងរក្សាទុកនូវឯកសារ ស្តីអំពីប្រពៃណីរបស់ខ្មែរយើងឲ្យគង់នៅ ជាឯកសារសម្រាប់ប្រទេសកម្ពុជាតទៅអនាគត ។

ឯវិធានការដែលក្រុមជំនុំនៀមទម្ងាប់ខ្មែរបានចាត់ការមកហើយនោះ មានដំណើរដូចរៀបរាប់ជូន ដោយសង្ខេបតទៅនេះ :-

១ - ប្រឡងប្រជែងពាល់ឆមាសនៃឆ្នាំទីមួយៗ គឺ ៦ ខែប្រឡងម្តង រវាងបេក្ខជនដែលស្ម័គ្រចិត្តប្រឡង ដើម្បីឲ្យបេក្ខជនទាំងនោះជូនឯកសារ រឿងនៀមទម្ងាប់ខ្មែរ ចំពោះរឿងណាដែលមិនទាន់មានបរិបូណ៌ដល់ក្រុមជំនុំ តាមដែលក្រុមជំនុំត្រូវការស្រាវជ្រាវរក ។

២ - ស៊ើបសួរយកការរឿងនៀមទម្ងាប់ខ្មែរ ចំពោះសមាជិកឆ្លើយឆ្លងក្នុងខែត្រទីឆ្ងាយស្រុកនានា ដែលក្រុមជំនុំបានតាំងប្រចាំការសម្រាប់

សាកសួរ ដោយបានឲ្យសមាជិកឆ្លើយឆ្លងតាំងនោះ សរសេរឯកសារផ្សេងៗឲ្យការជារឿយៗ ។

ពួកវិញ្ញាជនដែលយល់ច្បាស់នូវខុត្តមប្រយោជន៍ របស់ក្រុមដំនុំនេះ បានចុះឈ្មោះជាបេក្ខជន នឹងសមាជិកឆ្លើយឆ្លងជាច្រើនរូប បានសរសេរឯកសារទំនៀមទម្លាប់ផ្សេងៗ ផ្ញើទៅប្រឡងនឹងឲ្យការទៅក្រុមដំនុំ ។

ខាងការប្រឡងប្រជែង.— កាលដល់ចុងធមាសនីមួយៗ ក្រុមដំនុំបានជួបជុំពិនិត្យឯកសារបស់បេក្ខជនតាំងនោះ, ឯកសារដែលល្អៗ បានឲ្យជាប់តាមថ្នាក់ បានជូនវង្វាន់ ដូចក្នុងប្រកាសដែលជូនដំណឹងជាមុន ។

ខាងការសមាជិកឆ្លើយឆ្លង.— កាលដល់ចុងធមាសនីមួយៗ ក្រុមដំនុំបានយកឯកសារផ្សេងៗ របស់សមាជិកតាំងឡាយមកពិនិត្យ ហើយបានជូនវង្វាន់តាមថ្នាក់ល្អអាក្រក់របស់អ្នកឲ្យការ នឹងតាមចំនួនឯកសារតិចច្រើន ។

ចំពោះធមាសទី ២ នៃឆ្នាំ ១៩៥២ ដែលក្រុមដំនុំបានចាត់វិធានការប្រឡងប្រជែង ២រឿង គឺទំនុកច្រៀងបុរាណរបស់ខ្មែរ ១រឿង, មហាស្រែពខ្មែរ ១រឿង នោះបានលទ្ធផលដូចតទៅនេះ :-

រឿងទំនុកច្រៀងចាន ជាប់ ៣រូប គឺ

- លោក គង់-ចន្ធូន: នៅឃុំដៃជ្រៀន ស្រុកតៃឈរ ខេត្តកំពង់ចាមបានជាប់លេខ ២ ត្រូវបានវង្វាន់ជាប្រាក់ ១៩០រៀល ។

- លោក សោម-ហុម ក្រឡាបញ្ជីរុំវ៉ែត នៅខាងលិចសាលាវចនា ភ្នំពេញ ចានជាប់លេខ ៤ ត្រូវចានរង្វាន់ជាប្រាក់ ១០០រៀល ។

- លោក កូ-តាកែ ស្មៀនឃុំ ឃុំអន្ទង់ត្នោត ស្រុកក្រគរ ខែត្រពោធិសាត់ ចានជាប់លេខ ៤ ត្រូវចានរង្វាន់ជាប្រាក់ ១០០រៀល ។

រឿងមហោស្រពចានជាប់ ១រួប ៣

- លោក សោម-ហុម ក្រឡាបញ្ជីរុំវ៉ែត នៅខាងលិចសាលាវចនាក្រែងភ្នំពេញ ចានជាប់លេខ ៣ ត្រូវចានរង្វាន់ជាប្រាក់ ១២០រៀល ។

ការប្រឡងលើកនេះគ្មានជាប់រង្វាន់លេខ ១ ទេ ដោយមិនមានឯកសារដែលគួរឲ្យជាប់ថ្នាក់នោះចាន ។

សេចក្តីប្រកាសលទ្ធផលនៃការប្រឡងដូចរៀបរាប់មកនេះ ទុកជាការប្រកាសកិត្តិយសរបស់បេក្ខជនដែលចានយកចិត្តទុកដាក់ ធ្វើការបំពេញកិច្ចរបស់ក្រុមដំនុំទំនៀមទម្លាប់ខ្មែរ ដែលជាក្រុមស្រាវជ្រាវរក្សាទុកនូវអារ្យធម៌របស់ប្រទេសជាតិឲ្យចានចម្រើន ។

សេចក្តីប្រកាសផលទ្ធផលបែបនេះ ក្រុមដំនុំចានផ្សាយក្នុងវិទ្យុទឹងសារពត៌មានកម្ពុជា រាល់ពេលដែលប្រឡងជាប់គ្រប់ធមាសនីមួយៗរៀងរាល់ឆ្នាំ ។

ក្នុងធមាសទី ១ ខាងដើមឆ្នាំ ១៩៥៣ នេះ ក្រុមដំនុំនឹងប្រកាសបើកប្រឡង ២ រឿងទៀត គឺរឿងទី ១ អំពីភ្ជាប់ពាក្យសុីស្ងា, រឿងទី ២

អំពីក្តីដ៏ ។ ការប្រឡងលើកនេះមានបន្ថែមរង្វាន់ច្រើនលើសមុន ដូច
មានប្រកាសផ្សាយខ្លះៗហើយ សូមអស់លោកវិញ្ញាជនទាំងឡាយ
សរសេរឯកសារដូចជំពាក់ចាត់ដើមធ្វើៗប្រឡងឲ្យបានច្រើន ដើម្បីឲ្យ
បានចម្រើនឯកសារអារ្យធម៌ខ្មែរយើងតៗគ្នា ។

ផ្នែកសមាជិកធ្វើយធ្វន ក្រុមជំនុំបានស្រង់យកនាម នឹងកិច្ចការ
របស់សមាជិកខ្លះ មកផ្សាយក្នុងវិទ្យុ នឹងចុះកង់សារពត៌មានកម្ពុជាពីមុនខ្លះ
រួចមកហើយ ជាការប្រកាសកិត្តិយសរបស់សមាជិកទាំងឡាយដែលបាន
ជួយធ្វើការក្រុមជំនុំ ។

វេលានេះ ក្រុមជំនុំសូមប្រកាសកិត្តិយស របស់សមាជិកធ្វើយធ្វន
ខ្លះទៀត ចំពោះនាមនឹងកិច្ចការ ព្រមទាំងឯកសារបស់សមាជិកខ្លះ
ដែលពុំទាន់បានផ្សាយនៅឡើយ ។

ក្រុមជំនុំមានអំណរណាស់ ចំពោះការដែលអស់លោកជាសមាជិក
ធ្វើយធ្វនបានឲ្យការនោះ តែសូមជំរាបថា ឯកសារដែលអស់លោកបាន
ឲ្យមកនោះ មានច្រើន ដែលក្រុមជំនុំពុំអាចយកមកថ្វែងដំណាលគ្នាក្នុង
ពេលនេះបាន ។ ដូច្នេះ បើមិនឃើញមាននាមក្នុងទីនេះ សូមអស់លោក
កុំឆ្ងល់ ព្រោះក្នុងទីនេះក្រុមជំនុំជ្រើសយកចំពោះតែនាមសមាជិកនឹងឯក-
សារដែលបានទទួលពីត្រឹមខែមករា ខែកុម្ភៈ នឹងខែមីនា ឆ្នាំ ១៩៥២
ហើយនឹងចំពោះឯកសារដែលអ្នកសរសេរឲ្យការ បានប្រាប់គោលប្រាប់
ដើមកំណើតច្បាស់លាស់ ។

ឯនាមនឹងឯកសាររបស់សមាជិកធ្វើយធ្ងន់ ដែលត្រូវយកមកថ្លែងក្នុងវេលានេះ ដូចរៀបរាប់តទៅនេះ :-

លោក សាំង-លិន នៅឃុំល្វេ ស្រុកស៊ីធរកណ្តាល ខេត្តត្រៃវែង បានឲ្យឯកសាររឿងទំនៀមទម្លាប់ធ្លាក់ក្បាលដណ្តើរផ្ទះ ជារូបក្បាលសេះ លោកថាគេធ្លាក់រូបនេះដើម្បីការពារដម្បីអារ៉ុសកូន នឹងដម្បីធ្ងន់ តាមដំនឿរបស់អ្នកស្រុក ។ លោកនេះបានបញ្ជាក់ដើមកំណើតឯកសារនេះថា "លោកបានដឹងទំនៀមនេះ អំពីសំណាក់ឈ្មោះព្រាប-ប៊ុត នៅឃុំល្វេ ស្រុកស៊ីធរកណ្តាល ខេត្តត្រៃវែង" ។

ចំពោះការធ្វើដំណើរ លោក សាំង-លិន បានឲ្យការថា "សម័យបុរាណ អ្នកស្រុកមុននឹងធ្វើដំណើរទៅទីណា ។ ទោះផ្លូវទឹកក្តី គោកក្តី តែងមើលពេលល្អអាក្រក់ ថ្ងៃលិចអណ្តែត នឹងដង្ហើមរស់ដង្ហើមស្លាប់" ។ ថា "លោកបានចម្ងឹកក្បួននេះ តាមក្បួនខ្ទុនរ៉ឹងខុតដ៏ចម្លែក ជាក្បួនមើលពេលគ្រប់យ៉ាងល្អិតល្អណាស់" ប៉ុន្តែទាស់តែលោកនេះពុំបានប្រាប់ដើមកំណើតថាក្បួននេះរបស់អ្នកណានៅទីណាឡើយ, បើប្រសិនជាលោកនេះប្រាប់ដើមកំណើតក្បួននេះផង នោះជាការគាប់ប្រសើរណាស់ ។

រឿងនេះ ក្រុមជំនុំស្រាវជ្រាវរកឃើញក្នុងសេចក្តីកត់ហេតុរបស់អ្នកដំណើរជាតិចិនម្នាក់ឈ្មោះ ជាវ-តាកួន ដែលបានមកកាន់ប្រទេសខ្មែរយើងក្នុងសតវត្សរ៍ទី ១៣ (រវាងឆ្នាំពី គ.ស. ១២៩៥ ទៅ ១២៩៧) បានធ្វើ

សេចក្តីពិយការណ៍អំពីទំនៀមទម្លាប់ខ្មែរក្នុងសម័យនោះចំនួន ៤០ មាតិកា; ក្នុងមាតិកា ទី ១១ និយាយដល់ "ទំនៀមការធ្វើដំណើរ" របស់ប្រជាជនជាតិខ្មែរយើងថា "សម័យនោះ ខ្មែរចេះក្បួនហោរាសាស្ត្រយ៉ាងជំនាញ អាចព្យាករណ៍អំពីចន្ទគ្រាស នឹងសូរ្យគ្រាសបានច្បាស់លាស់; ... ថា "ខ្មែរជាន់នោះមានទំនៀមប្រកាន់ថ្ងៃល្អ - អាក្រក់ (លិចអណ្តែត) សូម្បីតែគេដើរទៅទិសខាងកើត ឬទិសខាងលិចក៏មានពាក់ថ្ងៃលិច ថ្ងៃអណ្តែតជាដរាប។ រហៀបនេះ សូម្បីស្រែ។ ក៏ចេះដែរ" ... ជាន់នោះ។

លោកគ្រូពុទ្ធសិរី ចាប-ចន្ទ វត្តក្តីក្រៅ ឃុំខ្នាវស ស្រុកស្រីសុន្ទរ ខេត្តកំពង់ចាម បានឲ្យសាវតារស្រុកខ្មែរ។ ក្នុងសាវតារនេះបានឲ្យការ ១ កន្លែង ថាកាលពីដើមព្រះថោង បានយកតង ១ ទៅកប់ក្រោមដើមធ្លក ធ្វើទុយដើម្បីនឹងដណ្តើមយកនគរពីព្រះបាទអស្សថៃពាជ។ កាលបរិវារក្រាបបង្គំទូលសួរថា "ទ្រង់គិតឲ្យសង់ព្រះពាជដំណាក់នៅទីណា?" ទ្រង់តបថា "ធ្វើឯណាកើតបើកំពុងក្តីគ្នា"។ ព្រោះហេតុដូច្នេះបានជាជាប់ឈ្មោះថាកំពុងក្តីដរាបមកដល់សព្វថ្ងៃនេះ (នៅក្នុងស្រុកដីក្រែង ខេត្តសៀមរាប)។

លោកគ្រូអង្គនេះបានឲ្យដើមកំណើតនៃបញ្ចាកថា នៃបញ្ចាកមានឈ្មោះដើម ៤ យ៉ាង គឺទី ១ ហៅនៃនាងវែង, ទី ២ ហៅនៃសារសៃវែង, ទី ៣ ហៅនៃស្រុកខ្មែរ, ទី ៤ ហៅនៃធនញ្ជ័យ។ បានជាហៅដូច្នេះ ព្រោះនៃនេះធនញ្ជ័យនៅស្រុកខ្មែរយើង បានផ្តើមធ្វើជាដំបូងថ្វាយស្តេចក្រែងចិនទៅ

ស្រុកចិន រួចលុះមានព្រះកត្តិដូចសុនខ្ញុ ព្រោះសុនខឈ្មោះអាមេរីនៅស្រុកខ្មែរយើងទៀតបាត់កំណើត, ស្តេចនោះបើអ្នកណាហ៊ានដើរមើលចំព្រះកត្តិទេ ឲ្យយកអ្នកនោះទៅសម្លាប់; ធនញ័យចង់មើលព្រះកត្តិទេ ទើបផ្តើមធ្វើនំសរសៃវែង ។ យកទៅថ្វាយ ។ ស្តេចស្រុកចិនឲ្យធនញ័យក្មួកស្លៀកមើលមុន រួចលោកក្មួកធនញ័យយកដៃកាន់សរសៃនំវែងបញ្ចូកកង់មាត់ ដើរមើលមុខឡើងក្រែកលបសំឡឹងមើលព្រះកត្តិស្តេចស្រុកចិន, ហេតុនេះបានជាជាប់ឈ្មោះថានំបញ្ចូកតាំងពីពេលនោះមក ។

លោក អុង-តាមហ៊ាន ស្នៀនប៊ុយ៉ូក្នុមិចាល ស្រុកសង្កែ ខេត្តបាត់ដំបង បានឲ្យឯកសារក្បួនសង់ផ្ទះរបៀបខ្មែរបុរាណ ដែលមានរៀបរាប់ពីរបៀបធ្វើក្នុមិ ធ្វើផ្ទះ រហូតដល់ធ្វើគ្រែដោយសព្វគ្រប់ល្អិតល្អណាស់ ។

ក្រមជំនុំបានទទួលឯកសារឿងសង់ផ្ទះច្រើនបែបប្លែក។ គ្នា ប៉ុន្តែលោកនេះ បានយល់ពាក្យសំនួរយើងសព្វគ្រប់ លោកបានបញ្ជាក់ដើមកំណើតនៃក្បួនសង់ផ្ទះនេះ ថាលោក បានចម្លងត្រឹមត្រូវតាមក្បួនដើមរបស់លោកតាអាចារ្យព័ន្ធនៅភូមិជាប់វត្តអញ្ជាញ ឃុំបុស្សរ៉ែក្រោក ស្រុកមង្គលបុរី ខេត្តបាត់ដំបង ។

លោក ធូ-អ៊ុក ប៊ូធ៌តុង សាលាខេត្តតាកែវ បានឲ្យឯកសារឿងជម្បាញខ្មែរ ។ យើងសូមអរគុណលោកនេះ ដោយលោកបានពន្យល់ច្បាស់លាស់អំពីតិត្ថាញខ្មែរ ថែមទាំងគូរគំនូរពន្យល់អំពីជម្បាញ ទីនប្រែជាប់ប្រឹក្សាការត្បាញបែបខ្មែរយើងផង ។

បើប្រសិនជាលោកនេះ អធិប្បាយអំពីរបៀបដែលកត់ត្រាវិរបៀបប្រើសំពត់ហូលផ្សេងៗ ទំនងដើមកំណើតសំពត់ចបុចផងខ្មែរ នោះជាការល្អណាស់ ព្រោះជាការដែលពុំសូវមានអ្នកណាឲ្យការមកក្រុមដំនុំ ហើយក្រុមដំនំកំពុងតែស្រាវជ្រាវរកដើមកំណើតការនោះផង ។

សេចក្តីនេះ យើងចង់បង្ហាញឲ្យយើញថា ឯកសារឿងទំនៀមទម្លាប់អ្វីរបស់ខ្មែរ យើងក៏ត្រូវការដែរ ឲ្យតែមានដើមកំណើត ហើយអធិប្បាយឲ្យសព្វគ្រប់ល្មមយកជាការបាន ។ មួយយ៉ាងទៀត ដល់ថ្ងៃអនាគត លុះអារ្យធម៌របស់ខ្មែរយើងកាន់តែចម្រើនឡើង ខ្មែរយើងនឹងភ្លេចអារ្យធម៌ខ្មែរសម័យបុរាណអស់ ។ ឯកសារដែលយើងប្រមូលទុកសម័យនេះហើយ ដែលអាចនឹងបំភ្លឺដល់អ្នកសម័យក្រោយនោះបាន ដូចសម័យបច្ចុប្បន្នដែលយើងស្រាវជ្រាវរកឿងព្រាវ អំពីប្រាសាទនគរវត្តសម័យបុរាណនោះដែរ ។

នៅទីបំផុតនេះ ក្រុមដំនុំសូមអំពាវនាវដល់អស់លោកអ្នកស្តាប់អ្នកអានទាំងឡាយ ដែលធ្លាប់បានស្តាប់ បានឃើញ បានចេះចាំនូវប្រពៃណីខ្មែរ សូមបណ្តុះធន្លុះដ៏ល្អនឹករលឹកដល់ការចេះចាំ ហើយសូមសរសេរឯកសារឿងទំនៀមទម្លាប់ខ្មែរណាមួយ តាមដែលអស់លោកពេញចិត្តឲ្យការទៅក្រុមដំនុំ ដើម្បីទុកជាក្តីរំឭកនូវទុកឯកសាររបស់ក្រុមដំនុំទំនៀមទម្លាប់ខ្មែរ ជាប្រយោជន៍របស់ជាតិនឹងជាគោលចារឹកប្រទេសតទៅ ។

ក្រុមដំនុំសូមទទួលអំណរគុណយ៉ាងខ្ពស់ចំពោះអស់លោកទុកជាមុន ។

លោកដុកទ័រគុណបណ្ឌិតបិយៈសេនៈម៉ាឡាលៈសេកេរៈ

ជាប្រធានពុទ្ធិកសមាគមពិភពលោក ថ្លែងក្នុងសមាជសាកលលើកទី ២

នៃពុទ្ធសាសនានៅទីក្រុងតូក្យូ (ប្រទេសជប៉ុន)

(តូក្យូ ២៥ កញ្ញា, ១៣ តុលា ១៩៥២)

ពុទ្ធសាសនបណ្ឌិត្យ

(តមក)

ត្រូវញ៉ាំងឲ្យក្មេងទាំងនោះ រស់នៅក្នុងយុវនភាពប្រកបដោយបរិយាកាសផ្សាយចេញពីឧត្តមគតិនៃព្រះធម៌ ដែលធ្វើឲ្យក្មេងទាំងនេះស្ថិតនៅរឹងប៉ឹងក្នុងដំនឿ ព្រមទាំងមានសទ្ធាដោយក្តីហាន ដើម្បីជាទិដ្ឋានុគតិចំពោះសាសនារបស់ខ្លួន ។ ក្មេងទាំងនេះអាចប្រតិបត្តិនូវគុណធម៌ពីរយ៉ាង គឺ គុណានិសង្សជាជំរើសដែលជាមូលដ្ឋាននៃពុទ្ធោវាទ ។ យើងក៏មិនត្រូវភ្លេចដែរនូវការសិក្សានៃក្មេងដំទន់ ព្រមទាំងក្មេងដែលមានរូបកាយវិកលវិការសោះឡើយ ។ នៅប្រទេសខ្លះ ដែលអប់រំព្រះពុទ្ធសាសនា, វដ្ឋកុំបាលបានណែនាំសាលាគ្រហស្ថទាំងថ្នាក់កុមារដ្ឋាន ដោយមិនគិតដល់វិជ្ជាដ៏វៈ ហើយការសិក្សាទាំងសាសនាមិនបានយកទៅបញ្ចូលក្នុងកម្មវិធីនៃការសិក្សាសោះឡើយ ។ ទាំងនេះមកពីបំណងអ្នកគាន់អំណាច មិនចង់ឲ្យមានគ្រោះថ្នាក់ឥតប្រយោជន៍ ។ តែមានព្រឹត្តិការណ៍ថ្មី ដែលកើត

ឡើងពាសពេញ បញ្ជាក់ឲ្យឃើញច្បាស់លាស់ថា បុរសនឹងស្ត្រីដែលចម្រើនវ័យធំឡើង គ្មានទុត្តមគតិខាងសាសនា នាំឲ្យមានភ័យដល់សន្តិភាព នឹងសុភមង្គលនៃពិភពលោក ។ ព្រោះហេតុដូចនេះ គឺថាត្រូវមានការណីយកិច្ចដ៏ប្រសើរ ចំពោះរដ្ឋាភិបាល ដែលត្រូវទទួលការពុះត្រូវខាងការសិក្សាជាសាធារណៈ រៀបចំអង្គារឲ្យកូនសិស្ស បានសិក្សារៀនសូត្រហើយដល់ចេញពីសាលា ត្រូវមានចំណេះគ្រប់គ្រាន់ខាងសាសនា ដែលបានអប់រំតាំងពីកំណើតមក ។ ខ្ញុំមានសោមនស្សចិត្តពន់ពេកដោយខ្ញុំបានពោលថា នេះហើយជានយោបាយដែលរដ្ឋាភិបាលសើរនៃប្រទេសខ្ញុំ គឺគោរពសីលធ៌ត្រូវប្រព្រឹត្ត, ប្រតិបត្តិតាម ។ គឺជាទិដ្ឋានគតិគួរយកតម្រាប់តាមចំពោះអ្នកទាំងអស់គ្នា ដែលមានចំណងឲ្យអ្នករស់នៅក្នុងអនាគតកាលបានសេចក្តីសុខ ។

ព្រះសង្ឃ

ចំពោះកិច្ចការខាងសិក្សា ហើយនឹងការញុំាងឲ្យសង្គមចម្រើន, មុខការសំខាន់នេះ គឺត្រូវព្រះសង្ឃកាន់កាប់ ។ សូម្បីតែតែងតំាងនៅក្នុងដែលជំនួលាយសម្បុណ្ណដោយទាយជ្ជទាន ចំពោះការធ្វើយកកម្រៃខ្លួនឯង ព្រះសង្ឃក៏ត្រូវយកគ្រហស្ថជាទីពឹងផ្អែក ។ ខ្ញុំសូមបន្ថែមទៀតថា ទាយជ្ជទានទាំងនេះជារបស់ក្រណាស់ ហើយពួកសមាជិកខាងព្រះសង្ឃចំពោះប្រទេសដែលខ្ញុំស្គាល់ ក៏ត្រូវពឹងផ្អែកទៅលើគ្រហស្ថទាំងអស់ ។

ចំណែកកិច្ចការ ដែលត្រូវការពាល់ថ្លៃក៏ដូចនោះដែរ ។ គឺជាការណ៍យកចិត្ត ជាដំបូង ដែលត្រូវយើងគិតចំពោះព្រះសង្ឃត្រង់ការធ្វើឲ្យព្រះសង្ឃបាន សុខស្រួល ។ ត្រូវធ្វើសម្ពន្ធមិត្តកិច្ចជានិរន្តរ៍នឹងព្រះសង្ឃ ដើម្បីនឹងញ៉ាំងសកម្មភាពខាងសាសនា ឲ្យប្រព្រឹត្តទៅ ។ យើងមិនត្រូវភ្លេចថា ព្រះសង្ឃជាអ្នករក្សាទុក នូវគម្ពីរសាស្ត្រាបស់យើង បន្ទៃមនូវគ្រឹះមាតិកនៃអក្សរសាស្ត្រខាងសាសនា ព្រមទាំងរក្សាទុកនូវសភាពបរិសុទ្ធស្អាតនៃសាសនាក្នុងពេលកលិយុគនៃប្រវត្តិសាស្ត្រ ។ ថ្ងៃណាដែលព្រះសង្ឃធ្លាក់ចុះវិនាសបង់, ថ្ងៃនោះសាសនាយើងក៏រលត់ ។

បើយើងពិនិត្យនូវស្ថានការណ៍បច្ចុប្បន្ននៃព្រះសង្ឃ មានរឿងក៏រាជាច្រើនបែបដែលយើងយល់ថា គួរយកមកពណ៌នាក្នុងទីនេះ ។ ព្រោះហេតុដូចនេះយើងមិនត្រូវយល់ថា មិនពិត ត្រង់ការបាក់បែកជាខ្លាំងចំពោះព្រះសង្ឃនឹងគ្រហស្ថ ឥឡូវនេះយើងឃើញថា ព្រះសង្ឃមិនមែនជាមគ្គុទ្ទេសក៍, អ្នកទស្សនវិទូនឹងជាអ្នកកល្យាណមិត្តនៃគ្រហស្ថដូចពីអតីតកាល ។ ត្រូវចាត់ចែងការពីរយ៉ាងក្នុងម្ជុយរំពេចដើម្បីនឹងការពារនូវសភាវៈបែបនេះ កុំឲ្យមានតទៅអនាគតទៀត គឺ:-

ទី ១ ត្រូវស្ថាបនានូវសាលាគរុវិជ្ជា ចំពោះសង្ឃសមាជិក ដែលគេត្រូវបង្ហាត់បង្រៀនមិនត្រឹមតែអត្ថបទនៃព្រះពុទ្ធសាសនាទេ ថែមទាំងកិច្ចការស្រាវជ្រាវសម័យបច្ចុប្បន្ន នូវវិទ្យាសាស្ត្រព្រមទាំងភាសាទំនើប

ដែលជាហេតុឲ្យព្រះសង្ឃទាំងនោះ បើកន្ទុយជ្រាជ្រាឲ្យបានក្លឹស្វាងរុងរឿង ចំពោះកិច្ចការដែលមានដុំវិញក្នុងពិភពលោក ។ បើគ្មានចំណេះទាំងនេះទេ ព្រះសង្ឃមិនអាចនឹងធ្វើឲ្យយើងគោរពគោតខ្ចាច ឬ ប្រតេនមុខការទាងត្រួតត្រាន្ទុយបញ្ហាដីវភាព ដែលជាប់មានមកក្នុងមួយថ្ងៃៗ ។ ម្យ៉ាងវិញទៀត ការដែលអប់រំបែបនេះនាំឲ្យព្រះសង្ឃទាំងនោះ មានសមត្ថភាពត្រង់ធ្វើពុទ្ធបេសកកម្មឲ្យបានផលល្អ ចំពោះប្រទេសទាំងនោះ ដែលមិនទាន់ស្គាល់ព្រះពុទ្ធសាសនាច្បាស់លាស់ ព្រមទាំងផ្សាយព្រះពុទ្ធសាសនាឲ្យជ្រួតជ្រាបទៅក្នុងប្រជាជនទាំងអស់ ព្រមទាំងប្រយោជន៍នៃវិជ្ជា, សង្ឃដ៏ក្សាហានទឹងការពិសោធន៍ថ្លៃថ្លារបស់ព្រះសង្ឃទាំងនេះ ។

ទី ២ ពួកគ្រូហស្តត្រូវប្រែស្រយ័ត្នគ្នាជាមួយនឹងព្រះសង្ឃ, ដែលជាគ្រូខាងជ្រាជ្រា ដោយត្រូវទៅទាន់វត្តអារាមមិនត្រឹមតែថ្ងៃបុណ្យ ថែមទាំងថ្ងៃឯទៀតផង ។ វត្តអារាមនេះ ត្រូវត្រៀបទៅជាមជ្ឈដ្ឋានសកម្មភាពខាងព្រះពុទ្ធសាសនា ព្រមទាំងពួកសង្ឃសមាជិកនឹងចៅអាវាសវត្តជាតិ ឬមានតែងតាំងតាមច្បាប់ត្រឹមត្រូវ ។ ត្រូវទទួលកំហុសចំពោះពួកយើងដោយភាគច្រើន, គឺកិច្ចការដែលទៅវត្តនោះរយាលពន់ពេកហើយ, បើនឹងបានទៅ ក៏ទៅដើម្បីថ្វាយបង្គំព្រះ ហើយសូត្រធម៌ទៅតាមគាថាព្រះសូត្រ ដែលយើងមិនស្គាល់ន័យថែមទៀតផង ។ កិច្ចការដែលប្រព្រឹត្តបែបនេះមិនសមមៀទៅតាមវិចារណញ្ញាណ ត្រូវតែបោះបង់

ចោលចេញ ។ ប៉ុន្តែចំពោះយើងជាពុទ្ធសាសនិកជន ថ្ងៃសប្ដាហ៍ដែលបានប្រកាសជាផ្លូវការថា ជាថ្ងៃឈប់សម្រាកសិន ត្រូវគ្នានឹងថ្ងៃដែលសាសនាបានបញ្ញត្តិឲ្យឈប់ ហើយយើងបានប្រើពេលវេលានោះក្នុងអកម្មកាព ឬក្នុងកិច្ចស្វែងរកនូវការសប្បាយក្នុងអាមិស ។ ព្រោះហេតុដូចនេះបានជាយើងមិនអាចកំណត់ឈប់ទៅតាមថ្ងៃបុណ្យ ក្នុងសាសនា. ដែលយើងនឹងត្រូតពិប្រៃពៃណីនិយមរបស់យើង ។ មានប្រទេសខ្លះដូចជាប្រទេសស៊ុយអែត ចំពោះរដ្ឋាភិបាលគ្រហស្ថបានទទួលស្គាល់នៅថ្ងៃនេះ ដែលមានសារសំខាន់ ។ ខាងពុទ្ធសាសនា ហើយថ្ងៃពីរនោះ គេទុកជាថ្ងៃបុណ្យតាមផ្លូវការ, តែអ្វីក៏មិនអាចផ្ទាស់ប្ដូរបាន នូវការទស្សនាសប្ដាហ៍: ឯទីវត្តអារាម ដែលអាចប្រព្រឹត្តទៅបាន ចំពោះបុរាណនិយម ។ គឺជាបញ្ហាមួយយ៉ាងសំខាន់បំផុត ដែលយើងត្រូវពិនិត្យយ៉ាងម៉ឺងម៉ាត់ តទៅអនាគត ។

កិច្ចដែលត្រូវការទានមិនបាន ក្នុងការស្ថាបនានូវបូជនីយដ្ឋានដែលពួកពុទ្ធសាសនិកជនអាចនឹងអញ្ជើញទៅធ្វើនមស្សការបូជាចំពោះខ្លួន ឬច្រើនគ្នា ហើយការធ្វើនូវបូជនីយដ្ឋាននេះ ដើម្បីនឹងផ្សាយនូវព្រះធម៌នាំឲ្យកើតបញ្ហាមួយ គឺការស្ថាបនានូវប្រទេសជាច្រើន មានបច្ចឹមប្រទេសជាដើម ។ បញ្ហានេះ ពុទ្ធសាសនិកជនខាងទ្វីបអឺរុប បានពិនិត្យជាយូរណាស់មកហើយ ហើយមានខ្លះពោលថា មិនមានមធ្យោបាយ

អ្វីដែលទឹងរកនូវច្រើនក៏ចំណាយដើម្បីទឹងស្តាបនា ត្រមាំងថែទាំរក្សា
ទុកនូវមជ្ឈមណ្ឌលនេះ នេះជាពេលទុកាសដ៏ល្អ ដែលពួកសុទ្ធបុគ្គល
ខាងព្រះពុទ្ធសាសនានៃប្រទេសក្នុងទ្វីបអាស៊ី ដោយបុញ្ញនិធី ដោយធ្វើ
អំណោយនូវព្រះធម៌ ដែលតាមព្រះបរមគុណ្ឌោរាទ មានសភាពទុត្តម
ផុត ។ ខ្ញុំសូមរំលឹកអ្នកអំពីសេចក្តីស្នើនូវការសង់ព្រះវិហារមួយ នៅទី
ក្រុងឡុងដែលជាមជ្ឈមណ្ឌល ចំពោះប្រទេសនៃអឺរុបខាងលិច ។
ព្រះសង្ឃដែលទឹងត្រូវណែនាំមជ្ឈមណ្ឌលនោះ រងំចាំនូវមធ្យោបាយ
ផ្សេងៗ ក្នុងការនោះ ។ វិធានខាងព្រះពុទ្ធសាសនា គឺការស្តាបនានូវ
ព្រះសង្ឃក្នុងប្រទេសនីមួយៗ ដែលមានពួករដ្ឋាភិបាលសមាសភាព,
មានឥស្សរភាព ត្រង់គ្មានអ្នកក្រៅទៅត្រួតត្រាបាន គឺព្រះសង្ឃទាំង
នេះមានការណីយកិច្ចតែប្រព្រឹត្តទៅតាមវិន័យពុទ្ធសាសនាប៉ុណ្ណោះ ។
ព្រោះហេតុដូចនេះ គួរតែយោបល់ប្រៃបនេះ, ពួកប្រជាជនខាងទ្វីបអឺរុប
ទឹងអាមេរិកយកតម្រាប់តាម, តែដើម្បីទឹងរង់ចាំ ឲ្យយោបល់ទាំងនោះ
មានសភាពពិតមែន, ត្រូវតែចាត់ព្រះសង្ឃជាច្រើន ទៅកាន់ប្រទេស
ដែលកាន់ព្រះពុទ្ធសាសនា ។ ខ្ញុំអាចបន្ថែមបានថា ព្រះសង្ឃទាំងនេះ
ត្រូវជ្រើសរើសចំពោះព្រះសង្ឃដែលមានចរិយាត្រឹមត្រូវ ។ ខ្ញុំមិនអាច
ពណ៌នាឲ្យវែងឆ្ងាយតទៅទៀត អំពីរឿងនេះដែលមានមកក្នុងពេល
សន្ទិសិទនេះ ។ តែដើម្បីទឹងរង់ចាំទុកាសដ៏ល្អទៅថ្ងៃក្រោយ, យើងត្រូវ
បត្តម្ភ ទៅពួកក្រុមខាងព្រះពុទ្ធសាសនា ដែលស្ថិតទៅក្នុងប្រទេសខាង

អ៊ីរុបនឹងអាមេរិក មានប្រទេសខ្លះមានបែកយោបល់គ្នា ចំពោះបញ្ហាកូមិ-
សាស្ត្រនឹងការសាសាស្ត្រ. ពិតមែនតែមានប្រទេសខ្លះបានរក្សាសម្ពន្ធភាព
នឹងក្រុមដែលស្គាល់ ។ គឺយើងត្រូវជួយពួកក្រុមដែលនៅឃ្លាតឆ្ងាយ
ពីយើង ដោយចែករំលែកគ្នាទៅវិញទៅមក ។ នេះជាវត្តមាននៃ
សមាគមយើង ។ ព្រោះនៅក្នុងក្រុមទាំងនោះ គឺមានប្រាថ្នាចង់ជួយគ្នា
ដោយចិត្តស្មោះស្ម័គ្រប៉ុណ្ណោះ ។ ព្រោះហេតុដូចនេះ ជាការណ៍យកចិត្ត
ទុកដាក់មិនបាន ចំពោះពួកក្រុមទាំងនោះ នឹងពួកពុទ្ធសាសនិកជន,
ត្រង់ធ្វើសម្ពន្ធភាពជាញឹកញាយ នឹងអង្គការកណ្តាលមួយដូចជាសមាគម
យើង ។ ពិតមែនតែសមាគមនេះធ្វើការដោយលំបាក, ហើយទើបនឹង
ដំណើរការដំបូងក៏គង់បានឆ្ពោះធ្វើការគមនាគមន៍ហើយ ស្ថិតនៅក្នុងការ
ប្រែប្រួលជានិរន្តរ៍ចំពោះពួកក្រុមនឹងពួកជនពិសេស ក្នុងកូមិភាគនៃ
ពិភពលោក, មានខ្លះស្ថិតនៅទីឆ្ងាយក៏មាន ។ ព្រោះហេតុដូចនេះយើង
ត្រូវតែធ្វើតុល្យការអំពីសារសំខាន់ នឹងដំណែនៃលិខិតសរសេរឆ្លើយរវាងជាតិ
ដែលយើងបានដឹងថា មានប្រយោជន៍តើតារាល់វេហ ។ ក្នុងសម័យ
បច្ចុប្បន្ន កិច្ចការទាំងនេះ គឺធ្វើចំពោះអ្នកស្មោះស្ម័គ្រ ដែលយើងសូម
សំដែងតវ៉ាទីជម្រកនៅទីនេះ ។ តែមានថ្ងៃណាមួយក្នុងកាលជាអនាគត
ប្រហែលជាថ្ងៃនោះដឹងដល់ហើយ ដែលយើងត្រូវការអគ្គលេខាធិការ
អាចិន្ត្រៃម្នាក់ ។ ម្យ៉ាងទៀត, យើងត្រូវការមូលនិធិ, ខ្ញុំសូមរំឭក
លោកអ្នកកុំភ្លេចនូវបញ្ហានេះសោះឡើយ ។

(មានត)

បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

របស់គ្រសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៨៨៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឃួន-យិម នាមឆាយា សុវណ្ណជោត កើតឆ្នាំច អាយុ ៤៤ វស្សា ២០ ជាចៅអធិការ វត្តអង្គរកា ឃុំចឹងត្រាញ់ ស្រុកសំរោង ខែត្រតាកែវ ។

សញ្ញាប័ត្រលេខ ៨៨៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-ណុប នាមឆាយា ព្រហ្មជោត កើតឆ្នាំខាល អាយុ ៣៦ វស្សា ១៥ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៨៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជួន-ធី នាមឆាយា ព្រហ្មជោត កើតឆ្នាំជូត អាយុ ៤៦ វស្សា ៦ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៨៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ញ៉ែប-នៅ នាមឆាយា គ្មាន ... កើតឆ្នាំរកា អាយុ ៤០ វស្សា ២០ ជាចៅអធិការ វត្តមៀន ឃុំមៀន ស្រុកព្រៃឈរ ខែត្រកំពង់ចាម ។

សញ្ញាប័ត្រលេខ ៨៩០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សឿ-យិម នាមឆាយា មង្គលសត្ថា កើតឆ្នាំជូត អាយុ ៣៨ វស្សា ១៨ ជាគ្រូសូត្រស្តាំ វត្តត្រពាំងព្រះ ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៩១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ថ្ងាន-លាង នាមឆាយា សុវណ្ណបញ្ញាកេសរ កើតឆ្នាំកុរ អាយុ ២៧ វស្សា ៦ ជាគ្រូសូត្រធ្វេង វត្តឃ្យោយ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៩២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កឿក-ម៉ុម នាមឆាយា ឥន្ទកេសរ កើតឆ្នាំមមី អាយុ ៤៤ វស្សា ២៤ ជាចៅអធិការវត្តឧត្តមស្តេច ឃុំឆាយ ស្រុកចាក្ខ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៨៩៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ យស់-លួន នាមឆាយា ឥន្ទកេសរ កើតឆ្នាំវក អាយុ ៤២ វស្សា ២២ ជាចៅអធិការវត្តគគ្យាពម ឃុំព្រៃកកក់ ស្រុកស្ទឹងត្រង ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៨៩៧ ចុះថ្ងៃពុធ ៩ កើតខែបុស្ស ឆ្នាំឆ្លូវឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ ឡុង-ចាន នាមឆាយា សុវណ្ណជោត កើតឆ្នាំរោង អាយុ ៤៦ វស្សា ២៦ ជាចៅអធិការ វត្តកែវព្រះភ្លើង ឃុំលេខ ៦ ក្រុងភ្នំពេញ ក្រុមម្ឿង ។

សញ្ញាប័ត្រលេខ ៩១០ ចុះថ្ងៃសុក្រ ៩ កើតខែមាឃ ឆ្នាំឆ្លូវឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ ច្បាក់-ផង់ នាមឆាយា ធម្មសរ កើតឆ្នាំខាល អាយុ ៦០ វស្សា ៤១ ជាចៅអធិការ វត្តព្រៃអារ ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ ។

(មានត)

ការដែលពុទ្ធសាសនបណ្ឌិត្យ សុំឲ្យអស់លោក-អ្នកបង់តម្លៃជាវ
ជាមុនដូច្នេះ ប្រយោជន៍ដើម្បីចាត់ការរៀបចំបញ្ជើធ្វើសៀវភៅទាំងនោះមក
ប្រគេន-ជូនឲ្យបានរហ័សនាប់ផង ប្រយោជន៍ដើម្បីលើកកំណាត់ចំនួន
សៀវភៅដែលត្រូវបោះពុម្ពក្នុងមួយភាគៗ កុំឲ្យខ្ជះខ្ជាតផង ព្រោះអស់
លោក អ្នកគង់ជាបស្រាប់ហើយថា ការខ្ជះខ្ជាតសៀវភៅភាគនីមួយៗ
តទៅថ្ងៃមុខនោះ មិនងាយនឹងស្វែរើបោះពុម្ពបំពេញឡើងវិញ សម្រាប់
ជាវប្រគេន-ជូនឲ្យបានគាន់ចិត្តនាប់ភ្លាមៗទេ ។

ភ្នំពេញ, ថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៥៣

ពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញសុទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៥ ខែមិថុនា លេខ ៦

ព.ស. ២៤៩៦ — គ.ស. ១៩៥៣



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
— មិត្តកថា	ព្រះមហាឧត្តមវិជ្ជា បុង - ប៊ីម	៤០៣
— កថិនកថា (តមក)	ព្រះមហាឧត្តមវិជ្ជា កែ - អឿន	៤១៨
ផ្នែកអក្សរសាស្ត្រ		
— ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៊ីម	៤២៣
— រឿងសាមកុក (តមក)	ឧកញ៉ា ឆ្ង - កន	៤២៨
— រឿងអាវ៉ក្សថ្លែងរឿងម្តៃជ្រាំ (តមក)	លោក វ៉ាយ - ប៊ុក	៤៣៣
— រឿងស្ងាប់ព្រោះជាតិ (តចប់)	លោក គង់ — លឹម	៤៤៣
— រឿងចិញ្ចៀនទិព្យ	អ្នកស្រីសារីយ៉ាន់	៤៥៣
— រឿងប៉ូលនឹងវីរ៉ស៊ីនី (តមក)	លោក ផេង - ជ្រឿរ	៤៥៨
— សកម្មភាពនៃក្រុមដំនុំទំនៀមទម្លាប់ខ្មែរ	ពុទ្ធសាសនបណ្ឌិត្យ	៤៦៣
កំណាត់ទឹងប្រវត្តិការណ៍		
— សុន្ទរកថាបណ្ឌិតម៉ាល៉ាឡ៉ៈសេកេរៈថ្លែងក្នុងសមាជសាកលលើកទី ២ នៃពុទ្ធសាសនា	(តមក) ពុទ្ធសាសនបណ្ឌិត្យ	៤៧០
— ទំធីបុណ្យរដ្ឋឆ្នាំព្រះវិហារ វត្តពោធិវាល ខេត្តបាត់ដំបង	ព្រះមហាឧត្តមវិជ្ជា កែ - អឿង	៤៧៥

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដារ ១៨២.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

		Pages
PARTIE RELIGIEUSE		
— Mittakatha.....	*Brah Maha Peung-PAM*.....	403
— Kathinakatha (suite).....	*Brah Maha Ker-œun*	418
PARTIE LITTERAIRE		
— Education morale (suite)....	*Brah maha Peung-Pam*.	423
— Histoire de SAMŁOK (suite)..	*Oknha Nou-Kan*	428
— Les vingt cinq récits du Mauvais Génie (suite)	*M. Ray-Buc*	433
— Mort pour la patrie (fin)	*M. Kong-Lim*	443
— La bague magique.....	*Mme SARIS-YANN*.....	453
— Paul et Virginie (suite)	*M. Phéng-Chrieu*	458
— L'activité de la Commission des Mœurs et Coutumes	*Institut Bouddhique*	463
NOTES ET CHRONIQUES		
— Discours du Dr. MALALASEKERA au 2e Congrés Mondial Bouddhique (suite)	*Institut Bouddhique*	470
— Gérémonie d'inauguration du temple de Vat Poveal.....	*Prah Maha Ker-Œurn*.....	475

Prix d'abonnement annuel comprenant 12 numéros : 192800

មិត្តកថា

ព្រះមហាឧត្តមរដ្ឋា ដែលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាថ្មាល័រវត្តបទុមវតី ក្រុងភ្នំពេញ

ទេសនាជាកិច្ចប្រចេសកម្ពុជា កាលពីថ្ងៃ ១៩ កើតខែផល្គុន ឆ្នាំជូតសំរឹទ្ធិស័ក
ព. ស. ២៤៩១ (១៣-៣-៤៩)

ឧមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ឧមត្តំ រតនត្តយស្ស

សូមនមស្សការ បំពោះប្រជុំ ៣ នៃព្រះគុណ:ដោយគោរព ។

ពេលនេះ អាត្មាភាពនឹងសំដែងព្រះធម្មទេសនា ពណ៌នាអំពី "មិត្តកថា" ផ្សាយតាមវិស្យកម្ពុជា ថ្វាយចំពោះទ្រង់ នឹងចែកជូនដល់អស់លោក-អ្នកចាំងស្តាយ តាមន័យពុទ្ធភាសិតថា:

អត្តមិ ជាតមិ សុខា សហាយា

"សំឡាញ់ចាំងស្តាយ អាចនាំសេចក្តីសុខមកឲ្យ
កាលពេលដែលសេចក្តីត្រូវការកើតឡើង" ។

មុនដំបូងសូមពណ៌នាអំពី
ហេតុដែលនាំឲ្យស្វែងរកមិត្តសំឡាញ់

នរជនដែលកើតឡើងក្នុងលោកសន្និវាស មិនចំពោះជាតិណា ស្រុកស្រុកណា សុទ្ធតែត្រូវមានមិត្តសំឡាញ់គ្រប់ៗគ្នាចាំងអស់, នឹងនៅធំតែ

ម្នាក់ឯងពុំបាន, ព្រោះដំបូងយើងត្រូវអាស្រ័យអាហារជាគ្រឿងបន្តុបន្ថែមជីវិត, ក្រៅពីនេះ ត្រូវអាស្រ័យគ្រឿងស្លៀកដណ្តប់ ទីនៅអាស្រ័យនឹងថ្នាំកែរោគ ដែលហៅថាបច្ច័យ ៤ គឺគ្រឿងអាស្រ័យដើម្បីធ្វើជីវិតឲ្យបានទទួលសេចក្តីសុខដ៏ពេញលេញ តាមសមគួរដល់អត្តភាព ។ បើពោលយ៉ាងក្រៃផ្ចង់ គឺយើងត្រូវអាស្រ័យវត្ថុអម្បាលនេះជានិច្ចទាន់ពុំបាន ។ កាលបើដូច្នេះ យើងនឹងនៅតែម្នាក់ឯងដូចម្តេចកើត, ព្រោះថាកាលបើយើងមិនពឹងអ្នកដទៃហើយ យើងនឹងធ្វើជីវិតរបស់យើង ឲ្យប្រពឹត្តទៅដោយសួស្តីពុំបានឡើយ មុខជាស្លាប់មិនខាន ។ ដ្បិតជីវិតក្នុងវ័យក្មេងនៅមិនទាន់មានសេចក្តីដឹង សេចក្តីអង់អាចដែលនឹងចិញ្ចឹមជីវិតដោយខ្លួនឯងទេ ។ យើងត្រូវអាស្រ័យអ្នកដទៃ គឺមាតាបិតា, បើយើងមិនអាស្រ័យគេទេ តើនឹងបានអាហារពីណាបរិភោគ, បានសំពត់ពីណាស្លៀកដណ្តប់, បានថ្នាំពីណាកែរោគ, បានទីណាអាស្រ័យនៅ, បាននរណាថែរក្សា ។ សូម្បីយើងបានរស់រួចជីវិត មានវ័យធំធាត់ឡើងដោយអាស្រ័យអតិបិយមិត្តខាងដើមគឺមាតាបិតា ចិញ្ចឹមថែរក្សាមកហើយក៏ដោយ, យើងក៏ត្រូវតែរកសេពគប់មិត្តសំឡាញ់ជំពូកដទៃតទៅទៀត ។ ព្រោះកិច្ចការគ្រប់យ៉ាង មិនមែនសុទ្ធតែធ្វើម្នាក់ឯងកើតទេ មានការងារខ្លះហួសវិស័យនឹងសមត្ថភាពដែលបុគ្គលម្នាក់ៗ ធ្វើឲ្យសម្រេចទាន់កាលបាន, បើយើងមិនមានមិត្តសំឡាញ់ជួយធ្វើទេ តើយើងនឹងធ្វើកិច្ចការទាំងនោះ

ឲ្យសម្រែចដូចម្តេច, ដូច្នេះ ទើបយើងត្រូវមានសំឡាញ់ជាកល្យាណ-
មិត្តសម្រាប់ជួយធ្វើ ។ សូម្បីបុពណាចារ្យ ក៏លោកបានពោលទុកមក
ដែរថា "បើហួសកម្លាំងនឹងលើ ត្រូវបាមាត់ស្តីភ្ញៀវឲ្យជួយរែក
ជួយសែង" ដូច្នេះ ។ ហេតុនេះមនុស្សជាតិដែលកើតខ្សើងក្នុង
លោកសន្និវាសនេះ ទំនងចិញ្ចឹមជីវិតរបស់ខ្លួន ឲ្យបានទទួលសេចក្តីសុខ
សេចក្តីចំរើនត្រមាំងសេចក្តីលូតលាស់ ត្រូវតែអាស្រ័យអ្នកដទៃជា
កម្លាំងជាប ។ ដំបូងត្រូវអាស្រ័យមាតាបិតាជាអ្នកឲ្យកំណើត តទៅ
ត្រូវអាស្រ័យគ្រូអាចារ្យជាអ្នកឲ្យជម្ងឺនៃប្រៀនប្រដៅ ដើម្បីឲ្យមាន
ដំរេះវិជ្ជា សេចក្តីចេះដឹង សេចក្តីអង់អាច រហូតដល់ដឹងចាបបុណ្យគុណ
ទោសដែលជាផ្លូវល្អឬផ្លូវអាក្រក់ចំពោះខ្លួន; ហេតុទាំងអម្បាលនេះឯង
"ជាហេតុដែលនាំឲ្យស្វែងរកមិត្តសំឡាញ់" ។

ពិធីសង្កេតមិត្ត

អ្នកដែលស្វែងរកសំឡាញ់បានហើយ ត្រូវពិនិត្យរកសំឡាញ់ដែល
មានថ្នាក់ជាមិត្តថែមទៀត ។ ការសង្កេតរកមនុស្សដែលគួរចាត់ថា
ជាមិត្ត ត្រូវសង្កេតដូច្នេះ គឺជនណាដែលជាគឿនរួមការងារជាមួយគ្នា
ជននោះលោកឲ្យឈ្មោះត្រឹមតែសំឡាញ់ប៉ុណ្ណោះ, មិនឲ្យឈ្មោះថាមិត្ត
ឡើយ; លុះតែអ្នកណាដែលជាអ្នកស្និទ្ធស្នាលទុកចិត្តគ្នា គឺមានសាមគ្គីចិត្ត

មិត្តធម៌ដល់គ្នានឹងគ្នា អ្នកនោះទើបគួរហៅថាមិត្តបាន ។ ខសំខាន់ដែលត្រូវដឹងគឺសម័យដែលខ្លួនមានធុរៈកើតឡើង បើនរណាមានទឹកចិត្តអើពើជួយធ្វើកិច្ចការទាំងនោះឲ្យសម្រេចបាន ដោយសំដែងទឹកចិត្តដ៏បរិសុទ្ធអាណិតអាសូរមិនបាច់ពឹង អ្នកនោះទើបហៅថាមិត្ត; អ្នកដែលជួយអំពើនេះមិនគួរហៅថាមិត្តទេ ។

ដើម្បីនឹងពិនិត្យឲ្យដឹងថា នរណាជាមិត្ត នរណាមិនមែននោះ សូមនាំយកគាថាតំណែងតិរបស់ចាណក្យព្រាហ្មណ៍ មកដាក់ក្នុងន័យនេះជាគ្រឿងសង្កេត :

១.— នៅស្មៀមៗ នរណាមិនជាមិត្តរបស់នរណា ហើយនរណាក៏មិនជាសត្រូវរបស់នរណា; លុះតែមានហេតុកើតទើបដឹងបានថា នរណាជាមិត្ត នរណាជាសត្រូវ ។

២.— បងដឹងខ្ចីកំដរឲ្យមើលក្នុងពេលធ្វើការងារ, បងដឹងវង្សត្រកូលឲ្យមើលក្នុងពេលដែលខ្លួនបានទុក្ខ, បងដឹងមិត្តសំឡាញ់ឲ្យមើលក្នុងពេលមានធុរៈឬអន្តរាយ, បងដឹងភរិយាឲ្យមើលក្នុងពេលខ្សត់ទ្រព្យសម្បត្តិ ។

គោលសំខាន់ពីរខនេះ ជាគ្រឿងប្រដាប់សម្រាប់សង្កេតរកហេតុរបស់មនុស្សដែលត្រូវជាមិត្ត; ដើម្បីនឹងសង្កេតមិត្តឲ្យបានច្បាស់លាស់

តទៅទៀតត្រូវពិនិត្យរកលក្ខណៈរបស់មិត្ត; ព្រោះការសេពគប់មិត្តមិនមែនសុទ្ធតែបានផលប្រយោជន៍ខាងល្អមួយចំណែកទេ មានជួនកាលត្រឡប់ជាឲ្យបាននូវសេចក្តីវិនាសទៅវិញ ស្រេចហើយតែអ្នកសេពគប់ប៉ះទៅលើមិត្តល្អឬមិត្តអាក្រក់ ។

មិត្តណាដែលធ្វើសេចក្តីវិនាស ឲ្យកើតឡើងដល់ខ្លួនន៍ងអ្នកដទៃទាំងក្នុងលោកនេះនឹងលោកខាងមុខ មិត្តនោះចាត់ជាមិត្តអាក្រក់ មិនគួរសេពគប់ ។ មិត្តណាធ្វើប្រយោជន៍ឲ្យកើតឡើងដល់ខ្លួនន៍ងអ្នកដទៃទាំងក្នុងឥឡូវនេះនឹងបរលោក មិត្តនោះចាត់ថាជាមិត្តល្អគួរសេពគប់ ។

អស់លោកទាំងឡាយ កាលបានជ្រាបដូច្នេះហើយ បើចង់ប្រយោជន៍ ដ៏ធំទូលាយដល់ខ្លួនន៍ងប្រទេសជាតិ សូមកុំសេពគប់នឹងមិត្តអាក្រក់ឡើយ សូមសេពគប់តែនឹងមិត្តល្អ ១ ចំណែក ឲ្យសមគ្នានឹងគោលធម៌ក្នុងធម្មបទថា:

"មិនត្រូវសេពគប់បាបមិត្ត
មិនត្រូវធ្វើស្និទ្ធនឹងមិត្តអធម:
ត្រូវគប់តែមិត្ត កល្យាណ:
ហើយនឹងភ្ជាប់ភក្តិជាក់ខ្ពស់" ។

គោលសំខាន់ ១ នេះជាគ្រឿងរំឭកមនុស្សកុំឲ្យសេពគប់នឹងបាបមិត្ត ឲ្យសេពគប់តែមិត្តល្អម្យ៉ាង, ព្រោះមិត្តដែលលោកចាត់ថាជា កល្យាណ-

មិត្តនោះ តែងជួយដឹកនាំគឿនក្នុងផ្លូវដែលល្អ ទំនងជួយការពារមិនឲ្យ
សេចក្តីអន្តរាយកើតឡើង តាមលក្ខណៈដែលលោកចែកទុកដូច្នេះថា:

អហិតាត្រូតិមេធក្ខ
ហិតេ ចាតុប្រវត្តិនម៏
វ្យសនេ ចាបរិត្យាត-
ស្ត្រីធិ មិត្រលក្ខ្យណាម៏

"លក្ខណៈរបស់មិត្តល្អមាន ៣ យ៉ាង គឺ: ១ - ហាមឃាត់មិត្ត មិន
ឲ្យធ្វើអំពើឥតប្រយោជន៍ ២- ណែនាំមិត្តឲ្យធ្វើតែអំពើមានប្រយោជន៍
៣ - ពេលមានហេតុកើតឡើង មិនលះបង់គ្នា" ។

លក្ខណៈរបស់មិត្តល្អ ៤ យ៉ាងដោយឡែកទៀត គឺ:

១ - ការពារគឿន ដែលគេចស្មារតី

២- ការពារទ្រព្យសម្បត្តិ ដែលគឿនធ្វេសប្រហែស

៣- កាលមានភ័យ អាចជាខំពឹងពំនាក់បាន

៤- កាលមានធុរៈកើតឡើង បានមកជួយដោយមិនបាច់ពឹង ។

មិត្តសំឡាញ់ដែលមានលក្ខណៈដូច្នេះ បណ្ឌិតគួរសេពគប់ដើម្បី
បានជាកំឡាំងជួយគ្នាទៅវិញទៅមក ក្នុងសម័យដែលមានទុក្ខធុរៈ ។

ការសេពគប់មិត្ត

ដោយគុណានុភាពនៃមិត្តដូច្នេះ ឋានជាមនុស្សជាតិត្រូវតែរកសេពគប់មិត្ត ។ ក៏ការដែលសេពគប់មិត្តនេះ គឺការធ្វើសេចក្តីស្និទ្ធស្នាលឲ្យកើតឡើងដល់គ្នានឹងគ្នា រហូតដល់ទុកចិត្តគ្នា ដោយច្រើនថ្ងាល្អទៅវិញទៅមក ។ ការគប់មិត្តមិនចំពោះបុគ្គល ១ រូប។ ឡើយ, ដោយហោចទៅ សូម្បីមិត្តសំឡាញ់ដែលកើតជាមួយគ្នា ឬ ដែលកើតខាងក្រោយក៏ត្រូវអាស្រ័យគ្នាដែរ មិនរើសថាជាតិ, សាសនា, ភាសាជាមួយគ្នា ឬផ្សេងជាតិ ផ្សេងសាសនា, ផ្សេងភាសា, ផ្សេងស្រុក, ផ្សេងនគរឡើយ ឲ្យតែសម្ព័ន្ធភាពល្មមផ្សាយទៅបាន ទីបំផុតគឺឲ្យទៅចាំងសកលលោក; ការអាស្រ័យនូវគ្នានឹងគ្នា នឹងប្រព្រឹត្តទៅបែបណាក៏ដោយ ក៏ហៅថាសម្ព័ន្ធភាពដែរ; សម្ព័ន្ធភាពនេះជាគ្រឿងបង្អាប់មនុស្សចាំងឡាយ មិនឲ្យនៅតាមទំនើងចិត្ត, ដុំពួកខ្លះក៏ជាកិច្ចប្តូនាទីធម្មតា ដែលមនុស្សត្រូវធ្វើតាមឋានានុរូបដែលជាប់ទាក់ទងគ្នាយ៉ាងណាមួយ, ដុំពួកខ្លះក៏ជាកិច្ចប្តូនាទីយ៉ាងធំបំផុត ដែលនរជនត្រូវធ្វើមានពុំបាន, ដូច្នេះ ឃើញថា "មនុស្សជាតិក្នុងលោកនេះនឹងនៅតែម្នាក់ឯងពុំបានទេ" សូម្បីមានពុទ្ធដីកាដែលយើងធ្លាប់ដឹងស្ទើរតែគ្រប់គ្នាមកហើយថា "អត្តា ហិ អត្តនោ នាថោ ខ្លួនឯងជាទីពឹងរបស់ខ្លួន, កោ ហិ នាថោ បរោ សិយា អ្នកដទៃណាមួយនឹងជាទីពឹងរបស់ខ្លួនបាន" ដូច្នេះក្តី សេចក្តីនៃភាសិតពីរខាងនេះ ក៏មានន័យដោយ

ទៀក គឺជាបុព្វនុរាគ សម្រាប់ខ្លួនមនុស្សឲ្យបង្ហាត់ខ្លួនឲ្យបានល្អមុន ហើយ សឹមពឹងអ្នកដទៃជាខាងក្រោយ, ព្រោះកាលបើយើង គ្មានគុណសេចក្តីល្អក្នុងខ្លួនទេ តើនរណាមួយនឹងជាទីពឹងរបស់យើងបាន ។

ដើម្បីនឹងយកប្រយោជន៍ ដ៏ពេញលេញអំពីសម្ពន្ធភាពដែលកើតឡើងដល់មនុស្សយើង, "មិត្តភាព" ដែលជាគុណធម៌ ១ សម្រាប់បណ្តុះបញ្ញា, បណ្តុះសេចក្តីដឿនឹងសេចក្តីជ្រះថ្លា ទើបត្រូវមានគុណធម៌គឺ សាមគ្គីចិត្ត, មេត្តាចិត្ត, ករុណាចិត្តនឹងមិត្តធម៌ ចំពោះភ្លឿនមិត្តភក្តិ ទាំងឡាយចូលមកឧបត្ថម្ភក់ថែមទៀត ។

គុណធម៌សម្រាប់ផ្សារមិត្តភាពឲ្យជាប់គ្នា

សាធុជនទាំងឡាយ សូមជ្រាបថា "សម្ពន្ធភាព" តែងប្រព្រឹត្តទៅដោយហេតុ ២ យ៉ាង គឺ ដោយធម្មតា ១ ដោយការបង្កើតថ្មី ១ ។

ព្រះពុទ្ធជាន់ដើមស្តេច, មាតាបិតានឹងបុត្រធីតា, ស្វាមីនឹងភរិយា ព្រមទាំងញាតិសន្តានជាមិត្តនឹងគ្នា ឬ នាយចៅហ្វាយនឹងបាវព្រាវ, គ្រូអាចារ្យនឹងសិស្សានុសិស្ស ក៏ជាមិត្តនឹងគ្នាដែរ; មិត្តចំពូកនេះ ចាត់ថាជា "មិត្តដោយធម្មតា" ។

ការចង់មិត្តនឹងអ្នកដទៃ មិនចំពោះមនុស្សម្នាក់ៗ ឬជាតិជាមួយគ្នា ដូចបដល់ប្រទេស ចង់ស្គាននេតិនឹងប្រទេសឯទៀត; មិត្តបែបនេះចាត់ថាជា "មិត្តដែលត្រូវបង្កើតថ្មី" ។

ការសេពគប់មិត្តទាំង ២ ប៉ុពួកនេះ ក៏ដើម្បីទំនងជួយរក្សាគ្នាទៅវិញទៅមក ឲ្យបានសេចក្តីចម្រើនលូតលាស់ទាន់សម័យ; តែថា សូម្បីមិត្តដែលធម្មតាតែងមកហើយក៏ដោយ ក៏នៅតែមានកាលខ្វះបែកបាក់គ្នាទៅវិញ, ដូចជាធ្លាប់ជ្រាបមកៈហើយថា ព្រះពុទ្ធជាទំងបណ្តាពស្តេកើតស្អប់គ្នាក៏មាន, មាតាបិតាទំងបុត្រធីតាកាត់កាល់គ្នាចោលក៏មាន, ភរិយាទំងស្វាមីលះលែងគ្នារហូតដល់ប្រកួតប្រកាន់គ្នាក៏មាន ។ ញាតិសន្តានបងប្អូនក្មួយជាសត្រូវបំផ្លាញគ្នាទៅវិញទៅមកក៏មាន, មិត្តសំឡាញ់អ្នករួមកិច្ចការជាមួយដោយហានៈជាអ្នកបង្អាប់បញ្ឆោទំងអ្នកតូច ដែលនៅក្រោមបង្អាប់បញ្ឆោបែកសាមគ្គី មិនមានសេចក្តីស្រឡាញ់មូលមិត្តនូវគ្នាទំងគ្នាក៏មាន; ករណីអម្បាលនេះ សឲ្យយើញថាៈ សូម្បីតែហានៈ ដែលធម្មតាតែងមកស្រាប់នោះ គង់មិនអាចទំងអំណោយនូវសេចក្តីសុខសេចក្តីចំរើនដល់គ្នាទំងគ្នាជានិច្ចទេ ។ ដើម្បីទំងធ្វើមិត្តដោយធម្មតាទំងមិត្តដែលត្រូវបង្កើតថ្មី ឲ្យជាប់គ្នាបិតទៅរៈទៅបាន, ត្រូវអាស្រ័យទឹកបន្សាវបានដល់សាមគ្គីចិត្តមិត្តធម៌ គឺចិត្តដែលស្រុះស្រួល មានសេចក្តីស្រឡាញ់អាណិតអាសូរច្បាច្ចាស្អួដល់គ្នាទំងគ្នា ជាគុណធម៌ចូលមកផ្សាវមួយជាន់ទៀត ទើបសម្ពន្ធភាពដែលមានហើយនោះ នុនចូលគ្នាយ៉ាងជិតស្និទ្ធល្មមទំងទទួលសន្តិសុខជានិច្ចទៅ ។

ទឹកបន្សាវគឺគុណធម៌ទាំងនោះ ត្រូវប្រើដូចេះ គឺមិនចំពោះតែអ្នកដែលមានហានៈខាងអាជីវៈស្មើគ្នា ឬតូចធំជាងគ្នាឡើយ គួរតែធ្វើសាមគ្គី

ចិត្តមិត្តធម៌ ឲ្យប្រព្រឹត្តទៅរវាងគ្នានឹងគ្នា តាមហ៊ានខ្លួនប្រកបកុំខាន ដើម្បីឯង ជាអ្នកតូច មិត្តដែលជាអ្នកធំ គួរតាំងនៅក្នុងមេត្តាករុណា, ព្រោះជាធម៌មានគុណានុភាព សមគួរដល់លក្ខណៈរបស់អ្នកធំ ។ ឯមិត្តដែលជាអ្នកតូចវិញក៏គួរតាំងចិត្ត ទទួលស្តាប់បង្គាប់ដោយយកចិត្តទុកជាក់ តាមហ៊ានៈរបស់ខ្លួនដែរ ។ ចំណែកមិត្ត ដែលតាំងនៅក្នុងហ៊ានៈស្មើគ្នា ត្រូវយកតិច្ចទុកជាក់ជួយថែរក្សា, ជួយការពារ, ជួយជាស់តឿនកឿនមិត្តកុំឲ្យខ្លួនដែលភ្លេចស្មារតី, ជួយរំលឹក, ជួយណែនាំ, ជួយរក្សាដំណែងនាទីការងារទ្រព្យសម្បត្តិឲ្យគ្នានឹងគ្នា; កាលមានធុរៈ ឬ កើយន្តពាយកើតឡើង អាចជាទីពឹងបាន, មិនលះបង់គ្នាក្នុងគ្រាមានវិបត្តិ, ព្រមទាំងរាប់អានរហូតដល់វង្សត្រកូលរបស់មិត្ត ។

ជនអ្នកសេពគប់មិត្ត កាលប្រព្រឹត្តតាមធម៌នេះហើយ, រមែងធ្វើសម្ពន្ធភាពរបស់ខ្លួនឲ្យប្រព្រឹត្តទៅ ដោយសួស្តីជានិច្ចរាល់បាន ។ ដូច្នេះឃើញថា: សាមគ្គីចិត្តមិត្តធម៌នេះ មានគុណានុភាពយ៉ាងសំខាន់ មិនត្រឹមតែធ្វើមនុស្សដែលជាផៅពង្សជាមួយគ្នា ឲ្យជាមិត្តនឹងគ្នាប៉ុណ្ណោះទេ ថែមទាំងផ្សារមនុស្សដទៃនឹងមនុស្សដទៃ ឲ្យជាមិត្តនឹងគ្នាបានទៀតផង ។

ប្រយោជន៍នៃការសេពគប់មិត្ត

មិត្តជាគ្រឿងកក់ក្តៅចិត្តយ៉ាងធំបំផុត មិនចំពោះតែមនុស្សទេ សូម្បីយានពាហនៈនឹងវត្ថុដែលយើងមានស្រាប់ ឬ គុណធម៌ គឺ បុណ្យ

កុសល កំជាមិត្តរបស់យើងដែរ ព្រោះមានឥទ្ធានុភាព នឹងសមត្ថភាព អាចធ្វើឲ្យចិត្តកក់ក្តៅបាន, សមដូចជាពុទ្ធភាសិតក្នុងខ្លះ ក្នុងធម្មបទថា:

"ពួករនេះជាមិត្ត របស់មនុស្សអ្នកដើរផ្លូវ;
បុណ្យកុសលគាំងឡាយ ដែលធ្វើទុកដោយខ្លួនឯង
ជាមិត្តជិតតាមខ្លួនទៅក្នុងកន្លែងខាងមុខ" ។

គុណានុភាពនៃការសេពគប់មិត្តសំឡាញ់ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ នៅមានទៀតច្រើនជាអនេក តែក្នុងទីនេះ សូមពណ៌នាដោយសង្ខេប ។

មនុស្សយើងដែលអាស្រ័យនៅក្នុងសកលលោក ចាប់តាំងពីផ្ទះមួយខ្នងឡើងទៅរហូតដល់ភូមិ, ឃុំ, ស្រុក... នឹងប្រទេសជាតិ ដូចពីគ្នា ក៏ត្រូវតែអាស្រ័យគ្នាជួយគ្នា ក្នុងកិច្ចការផ្សេងៗ ច្រើនខ្លះតិចខ្លះតាមសមត្ថភាពរបស់ខ្លួន, ដូចអស់លោកជ្រាបស្រាប់ហើយ បច្ចុប្បន្នសម័យនេះគ្រប់តែប្រទេស មិនកំណត់ថាជិតឬឆ្ងាយ គេកំពុងតែត្រូវការណាស់ខាងការផ្សាយមិត្តភាពរកគ្នានឹងគ្នា ដើម្បីទទួលយកដោយពេញចិត្ត ទូរស័ព្ទសាស្ត្រ សេចក្តីចេះដឹងនឹងការស៊ីវិល្ហៃ ដែលជាមូលហេតុនៃសេចក្តីសុខ សេចក្តីចំរើន មកជាក់ក្នុងប្រទេសរបស់ខ្លួន តាមនិស្ស័យនៃម្ចាស់ប្រទេស ឥតប្រទេសណាមួយនៅឯតែឯងទេ, ព្រោះមិត្តភាពនេះ ជាកម្លាំងខាងក្រៅមួយយ៉ាងធំបណ្តាច់ដែលនឹងធ្វើអ្នកសមាគមឲ្យ

ដល់នូវសេចក្តីចំរើន ឬ សេចក្តីវិនាស ។ សូម្បីព្រះសម្មាសម្ពុទ្ធ
ក៏ទ្រង់ត្រាស់ហើយថា "ម្នាលភិក្ខុទាំងឡាយ! កាលធ្លើបច្ច័យខាងក្រៅ
ឲ្យជាហេតុហើយ តថាគតមិនឃើញហេតុដទៃ សូម្បីណាមួយដែល
ប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសយ៉ាងធំឲ្យដូចជាការមានមិត្តអាក្រក់នេះ
ឡើយ, ការមានមិត្តអាក្រក់ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសយ៉ាង
សម្បើម" ទើងទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! តថាគតមិនដែល
ឃើញហេតុដទៃ សូម្បីណាមួយដែលទើងប្រព្រឹត្តទៅដើម្បីប្រយោជន៍
យ៉ាងធំ ឲ្យដូចជាការមានមិត្តល្អនេះ; ការមានមិត្តល្អ រមែងប្រព្រឹត្តទៅ
ដើម្បីប្រយោជន៍ទុឡាភិក" ។ ដោយអាស្រ័យពុទ្ធភាសិតប៉ុណ្ណេះជា
គ្រឿងអាង ក៏ល្មមឲ្យឃើញថា: ការសេពគប់មិត្ត ជាកម្មាងមួយ
យ៉ាងធំបំផុត, មិនចំពោះតែបុគ្គលមួយរូបៗឡើយ; ការសេពគប់លើ
មិត្តអាក្រក់ ផ្សាយទៅដល់សង្គមណា រដ្ឋណា, សេចក្តីវិនាស, សេចក្តី
សាបសូន្យ, ការក្តៅក្រហាយចិត្ត រមែងមានក្នុងសង្គមនោះរដ្ឋនោះ; ការ
សមាគមដោយមិត្តល្អប្រព្រឹត្តទៅដល់ក្រុមណា ដែនណា ប្រទេសណា,
សេចក្តីសុខ, សេចក្តីចំរើន, ការកក់ក្តៅចិត្ត តែងមានដល់ក្រុមនោះ
ដែននោះ ប្រទេសនោះ ។ ដោយគុណានុភាពនៃការមានមិត្តសំឡាញ់
ដូច្នេះ ឋានជាន១ដែនត្រូវណ្តុះសាមគ្គីធម៌ គឺ សេចក្តីព្រមព្រៀងគ្នាស្រុះ
ស្រួលគ្នា ដែលជាគ្រឿងបណ្តុះមិត្តភាពនោះឲ្យមានពេញពោរឡើង

ចំពោះពួកគ្រឿនមិត្តភ័ក្តិ ផ្ទះ, ភូមិ, ឃុំ, ស្រុកទឹងប្រទេសជាតិជិតខាង ទើបទឹងនាំយកនូវសេចក្តីសុខសម្រាន្ត មកកាន់ពួកគណៈរបស់ខ្លួនដោយបរិបូណ៌, សូម្បីព្រះសម្មាសម្ពុទ្ធដែលជាធម្មស្សាមី ក៏ទ្រង់សំដែងអំពីអានិសង្ស នៃសាមគ្គីនោះដែរថា: សុខា សង្ឃស្ស សាមគ្គី សេចក្តីព្រមព្រៀងនៃពួកគណៈ រមែងឲ្យកើតសុខ, សង្ឃេសំ សង្ឃភ្ជ-តានំ សាមគ្គី វិឌ្ឍិសាធិកា ការស្រុះស្រួលមូលមិត្តនៃជនទាំងពួង ដែលជាពួកគណៈអាចញ៉ាំងសេចក្តីចំរើនឲ្យកើតបាន ។

ប្រទេស ជាតិ សាសនា មហាក្សត្រទឹងរដ្ឋធម្មនុញ្ញ អាចទឹងតាំងនៅយឺនយូរបាន ក៏ព្រោះអាស្រ័យសាមគ្គីចិត្តមិត្តធម៌របស់ប្រជាជាតិទាំងមូលដែលបានស្រុះស្រួលពួតដៃគ្នា ដួយថែរក្សាដោយភាពជាកល្យាណមិត្តបែបណាមួយ ។

សាធុជនទាំងឡាយ ដូចបានជ្រាបស្រាប់ហើយ សេចក្តីថ្លៃថ្លើងរុងរឿង, ការល្បីខ្ចរខ្ចាយយ៉ាងទូលាំទូលាក ដោយកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតនៃកម្ពុជរដ្ឋ ដរាបដល់ប្រទេសជិតខាងទទួលដឹងឮតាមប្រវត្តិសាស្ត្រ, សាវតារសាស្ត្រកងសម័យកន្លងទៅហើយ ដែលមានច្បាសាទបុរាណខ្លះជាគួយ៉ាងស្រាប់តើតឡើងបាន ក៏ព្រោះអាស្រ័យសាមគ្គីចិត្តរបស់កម្ពោជិកជនទាំងមូល ដែលបានព្រមព្រៀងពួតដៃគ្នាដោយការចងគ្នាជាមិត្តកងសម័យនោះ ។

ការសាបរលាប, ការអាប់ឧនរស្មីនៃប្រទេសកម្ពុជា កន្លងសម័យមុន នេះបន្តិចនោះកើតមានឡើង ក៏ព្រោះការបែកសាមគ្គីនៃកម្ពោជិកជនដែលមិនបានស្រុះស្រួលចងចាប់គ្នាដោយមិត្តភាព ។

ការបានរើបៗ ឡើង, ការមានពន្ធឹស្វាងរុងរឿងបន្តិចឡើងវិញក្នុងសម័យឥឡូវនេះ កើតឡើងបានក៏ព្រោះអាស្រ័យសាមគ្គីចិត្តមិត្តធម៌របស់អ្នកកម្ពុជាភាគច្រើន ។ បើគ្មានតែជនភាគច្រើន មានសាមគ្គីចិត្តមិត្តធម៌ចំពោះគ្នានឹងគ្នាប៉ុណ្ណោះប្រកានៃប្រទេសកម្ពុជាបានរើបៗ ឡើងយ៉ាងនេះទៅហើយ ចំណង់បើកម្ពោជិកជនទាំងមូលបានស្រុះស្រួលព្រមព្រៀងគ្នាទៀត តើពន្ធឹនៃប្រទេសកម្ពុជានឹងមានយ៉ាងណាទៅ ។

មិនត្រឹមតែសម័យបច្ចុប្បន្នទេ សូម្បីក្នុងសម័យព្រេងនាយក៏សាមគ្គីចិត្តមិត្តធម៌ អាចហុចឲ្យដោយមិនចាប់សូម នូវជ័យជំនះនឹងសេចក្តីរុងរឿងយ៉ាងឧឡារិកដល់ប្រទេសជាច្រើន ដែលបានចងចាប់គ្នាដោយមិត្តភាពដែរ តែថាដោយប្រទេសទាំងនោះ មានជនជាតិបែកសាមគ្គីគ្នាក្នុងខាងក្រោយ, ក៏ត្រូវទទួលបរាជ័យវិញ; គួរយ៉ាងដូចស្តេចលីច្ឆវី ដែលបានទទួលដោយមិនចាប់ខ្លឹមប៉ុន្មាន នូវជ័យជំនះអំពីព្រះបាទអជាតសត្តុរាជ ក៏ព្រោះអាស្រ័យសាមគ្គីចិត្តមិត្តធម៌នៃប្រជារាស្ត្ររបស់ព្រះអង្គ; តែពេលក្រោយត្រូវប់ជាបរាជ័យចាញ់ព្រះបាទអជាតសត្តុរាជវិញ ក៏ព្រោះបណ្តារាស្ត្ររបស់ព្រះអង្គបែកសាមគ្គីគ្នា ។

អធិប្បាយមកប៉ុណ្ណេះ ក៏ល្មមយើញថាបាន ថាការសេពគប់មិត្តល្អ
មានផលប្រយោជន៍ជាអនេក ព្រោះអាចនឹងឆ្លុះគ្នាទៅវិញទៅមកក្នុង
ការដែលធ្វើរបស់ហួសវិស័យមនុស្សម្នាក់ៗ ឲ្យសម្រេចទាន់សម័យបាន;
ជួយការពារគ្នាកុងពេលដែលមានគ្រោះថ្នាក់តែឯង នឹងជួយការពារ
ខ្លួនកិត្តិយសនៃគ្នានឹងគ្នា ត្រមាំងប្រទេសជាតិឲ្យគង់វង្សបានផង, បាន
ជាព្រះគន្ថកម្ពុនិទ្ទេសខ្លួនឧបនាយកដែលឲ្យកសេពគប់មិត្តសំឡាញ់ ដោយ
ទ្រង់សំដែងផលប្រយោជន៍នៃមិត្តសំឡាញ់ថា "អត្ថម្បិ ជាតម្បិ សុខា
សហាយោ មិត្តសំឡាញ់ទាំងពួកយកអាចនាំសេចក្តីសុខមកឲ្យ ក្នុង
ពេលដែលសេចក្តីត្រូវការកើតឡើង" ដូច្នេះ ។

រាជា គោ សុខិតោ រជ្ជេ ហោតុ កម្ពោជិកា សុខី
រតនត្តយានុភាវេន យាបេនំ ហោតុ និដ្ឋិតំ

ទីបំផុតនៃព្រះធម្មទេសនានេះ សូមឲ្យព្រះរាជារបស់យើងទាំងឡាយ
តាំងនៅជាសុខកុងរាជសម្បត្តិ, ទើងសូមឲ្យអ្នកកម្ពុជាទាំងអស់គ្នាបាន
សេចក្តីសុខ; ដោយអានុភាពនៃព្រះរតនត្រ័យ សូមឲ្យសេចក្តីបួងសួង
(នេះ) បានសម្រេច (យ៉ាងនេះប៉ុកាន) ។

អាត្មាភាព សំដែងព្រះធម្មទេសនា អំពី "មិត្តកថា" ក៏ចប់ដោយ
សង្ខេបតែប៉ុណ្ណេះឯង ដំ ។

៩.- សាធុ សាធុ អនុត្តរៈ ម្ចាស់អនុត្តរៈ! ប្រសិនដែលលោកម្ចាស់វិសជ្ជនាមកនេះត្រឹមត្រូវហើយ ។ ចុះអ្នកណាខ្លះសមគួរជាទាយកធ្វើកឋិនទានបាន? សូមវិសជ្ជនាមកមើល ។

បពិត្រព្រះមហាថេរៈ! ឯអ្នកដែលសមគួរជាទាយកធ្វើកឋិនទានបាននោះ ពោលតាមកង់គម្ពីរសុមង្គលវិលាសិនីថា យេន កេនចិ ទេវេន វា មនុស្សេន វា បញ្ចង្គំ សហធម្មិកានំ អញ្ញតរេន ទិន្នំ វិដ្ដតិ

"ឯអ្នកដែលសមគួរជាទាយកធ្វើកឋិនទានបាននោះ គឺ ទេវតាក្តី មនុស្សក្តី សហធម្មិក:ចាំង ៥ គឺ ភិក្ខុក្តី ភិក្ខុនីក្តី សាមណេរក្តី សាមណេរីក្តី សិក្ខមានាក្តី អ្នកចាំងអស់នេះ .សមគួរជាទាយកធ្វើកឋិនទានបាន" សូមទានជ្រាប ។

១០.- សាធុ សាធុ អនុត្តរៈ ម្ចាស់អនុត្តរៈ! ត្រូវហើយ ចុះកំណើតកឋិនចាន លោកអ្នកណាជាទាយកធ្វើជាដំបូង ក្នុងកាលដែលព្រះអង្គគង់

ជន្មាយុទៅបានធ្វើចំពោះព្រះសង្ឃក្នុងពេលនោះ? សូមលោកម្ចាស់សំដែងឲ្យជាក់ច្បាស់, ព្រោះរឿងនេះពុទ្ធបរិស័ទគាំងឡាយចង់ជ្រាបណាស់ ទើងបានយកជាទិដ្ឋានុគតិ តទៅខាងមុខទៀត ។

- បពិត្រព្រះមហាថេរដ៏ចំរើន! ឯកំណើតកបិនទានដែលនាយកផ្តើមធ្វើជាដំបូងនោះគឺ "ព្រះបាទបសេនទិកោសល" ដូចមានរឿងដំណាលដោយសង្ខេបតទៅនេះ :-

កាលនោះព្រះបាទបសេនទិកោសល ព្រះអង្គបានតាក់តែងចាត់ចែងព្រះកបិនទាន នាំទៅថ្វាយចំពោះព្រះភិក្ខុសង្ឃ មានអង្គព្រះកច្ចាយនត្ថេរជាប្រធាន ។ ព្រះកច្ចាយនត្ថេរទទួលគ្រងតាមគន្ធង្គកបិនត្តារកិច្ចសម្រេចសព្វប្រការ, គ្រាកាលនោះ ព្រះបរមសាស្តាចារ្យ កំទ្រង់ត្រាស់ទេសនាសរសើរកុសលផលបុណ្យកបិនទាន នៃព្រះបាទបសេនទិកោសលជាដរាប ដោយអនេកបរិយាយ ហើយទ្រង់ត្រាស់នាំអតីតនិទានៃព្រះអង្គកាលអន្លោលជាតិជា នរជីវទុគ្គតបរមពោធិសត្វ បានជួយទូលឲ្យថាត់ការកបិនទាននៃនាយកុដុម្ពីក៍នាំថ្វាយព្រះចមមុនី គឺព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមបទុមុត្តរៈ ព្រះអង្គទ្រង់ប្រោសប្រទានឲ្យព្រះសុជាតត្ថេរជាអគ្គសាវ័កនៃព្រះអង្គគ្រងក្នុងគ្រានោះ, ឯអង្គព្រះបរមសាស្តាជាម្ចាស់នៃយើងនេះ ព្រះអង្គក៏បានពុទ្ធព្យាករណ៍ទំនាយអំពីសំណាក់នៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈអំពីកាលនោះមក លុះព្រះអង្គបានត្រាស់ហើយ

ទើបទ្រង់សំដែងព្រះសទ្ធម្មវិសេសទេសនា ប្រាប្តនូវបុព្វចរិយានៃព្រះអង្គអំពីកាលព្រះអង្គកើតជា នរជីវទុគ្គតពោធិសត្វ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈមកនោះ ស្រេចហើយ ព្រះអង្គទ្រង់អនុញ្ញាតសំពត់កបិនដល់កិកូទាំងឡាយ ដែលមានពៃតិរវទុព្ទលភាព ហើយទ្រង់បញ្ញត្តនូវសិក្ខាបទ ដែលព្រះសង្គីតិកាចារ្យបានពោលទុកក្នុងគ៌ម្ពីរមហាវគ្គដោយពិស្តារ ហើយទ្រង់ទេសនាសរសើរផលានិសង្សនៃកបិនទាននេះថា មានផលវិសេសលើសលន់ពន់ប្រមាណណាស់ ។

លំដាប់នោះមានព្រះថេរៈ ១ ព្រះអង្គ ព្រះនាមនារទត្ថេរបានស្តាប់ព្រះធម្មទេសនាកបិនានិសង្សដូច្នោះហើយ ទើបលោកមានហឫទ័យដ៏ពេញដោយបីតិជ្រះថ្លា គិតថា "កបិនទានមានផលានិសង្សអស្ចារ្យយ៉ាងនេះ គួរអាត្មានឹងសាងថ្វាយដល់ដំនុំសង្ឃម្ពងចុះ"; កាលព្រះនារទត្ថេរលោកគិតដូច្នោះហើយ ទើបលោកដោះឡើងទៅកាន់ត្រកូលញាតិ ហើយលោកបបួលពពួកញាតិលោកឲ្យជួយក្នុងការកបិនទាន លុះបានគ្រប់គ្រឿងកបិនហើយ លោកនាំអង្គព្រះកបិននោះទៅកាន់អាស្រមមួយអន្លើដោយពពួកញាតិជាបរិវារ ។ លុះបានដល់អាស្រមហើយ ព្រះនារទត្ថេរក៏យកសំពត់កបិននោះ ដម្កល់ទៀបព្រះចក្ខុយុគលនៃព្រះតថាគត ហើយសូត្រវែរថ្វាយដោយចាលីថា ឥត្តេ ឥមានិ បីរានិ ពុទ្ធប្បមុខស្ស ភិក្ខុសង្ឃស្ស កបិនច្ឆាយ ទស្សាមិ ប្រែជាសេចក្តីថា

"បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណាសូមថ្វាយនូវចីវរទាំង៦ឡាយនេះដល់ព្រះភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធជាប្រធាន ដើម្បីគ្រាលជាកបិនក្នុងឥឡូវនេះ" ។ គ្រានោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះអង្គក៏ឲ្យប្រជុំភិក្ខុចាំង៦ឡាយ ៥០០ រូប ហើយញ៉ាំងភិក្ខុចាំង៦ឡាយមានការដោនូវចីវរកបិនជាដើមឲ្យសម្រេចសព្វគ្រប់ប្រការ កាលនោះឯង ។ សាធុវោ បពិត្រសាធុសប្បុរសចាំង៦ឡាយ ! ឯកិរិយាដែលព្រះនារទត្ថេរធ្វើកបិនដើម្បីភិក្ខុសង្ឃមានអង្គព្រះពុទ្ធជាប្រធាននោះ ក៏កើតជាអស្ចារ្យអស់ដំខុំសង្ឃសឹងនាំគ្នានិយាយសរសើរកុសលផលបុណ្យ នៃព្រះនារទត្ថេរជាអនេកបរិយាយ កាលនោះសម្តេចព្រះឈ្នះមារក៏ទ្រង់ត្រាស់ប្រកាសនាំនូវអតីតនិទាននៃព្រះអង្គ កាលកើតជាស្តេចបរមចក្កពត្តាធិរាជ ១ ព្រះអង្គទ្រង់ព្រះនាមព្រះបរមចក្កវិជិតរាជ ប្រកបដោយអំណាចជាធំក្នុងទ្វីបចាំង ៤ មានទ្វីបតូច ២ ពាន់ជាបរិវារ ព្រះអង្គបានសាងកបិនទាន ថ្វាយព្រះពុទ្ធទ្រង់ព្រះនាមព្រះកោណ្ឌញ្ញសម្មាសម្ពុទ្ធដែលត្រាស់ដឹងក្នុងសារកប្បជាកប្បកន្ទឯយ៉ាងនោះ នាំមកសំដែងជាសណ្តាប់ធ្មាប់ភិក្ខុចាំង៦ឡាយ ក្នុងព្រះសាសនាដោយពិស្តារជាអនេកបរិយាយ ។ ក្នុងទីនេះអាត្មាភាពសំដែងសេចក្តីតែខ្លី។ នាំមកឲ្យយើញតួបុគ្គលអ្នកធ្វើគឺព្រះបាទបសេនទិកោសលជាបច្ចុប្បន្ននិទាន ព្រះនរជីវុគ្គតពោធិសត្វនឹងនាយកុដម្ពីក៍នោះក្តី ស្តេចបរមចក្កវិជិតរាជនោះក្តី ពីរនិទាននេះជា

អតីតនិទាន ចំណែកខាងព្រះសង្ឃអ្នកធ្វើសេត. គឺព្រះនារទត្ថេរជា បច្ចុប្បន្ននិទាន, និទានព្រះនារទត្ថេរធ្វើកឋិនេះគួរយកជាបែបយ៉ាងបាន ហេតុនេះទើបឃើញបព្វជិតទាំងឡាយពីបុរាណធ្វើកឋិនតៗ មក ព្រោះ អាស្រ័យនិទាន ព្រះនារទត្ថេរនេះឯង; បពិត្រព្រះមហាវេរ! ខ្ញុំព្រះ ករុណាបាននាំនិទាន មកដោយសង្ខេបតែប៉ុណ្ណេះ សូមទានផ្ទាប ។

១១– កល្លោសិ អនុត្តរៈ ម្នាលអនុត្តរ! លោកម្ចាស់ធ្លៀវឆ្លាស ឥតវៀរមែន ចេះតាញនិទាននាំមកសំដែងប្រៀបធ្យប់យអធិប្បាយស្តាប់បាន ដោយងាយ ល្មមពុទ្ធបរិស័ទទាំងឡាយសន្និដ្ឋានចូលចិត្តយកជាបែប យ៉ាងបានហើយ, លំដាប់តពីនេះទៅខ្ញុំបើកយកប្រស្នាដទៃមកសួរតទៅ ទៀត ។ អើលោកម្ចាស់ កាលបើគាយកជាឆ្អឹកបិនចូលមកវេរចំពោះ ព្រះសង្ឃហើយ តើសង្ឃត្រូវទទួលដោយអាការដូចម្តេច? សូមលោក ម្ចាស់វិសជ្ជនាមក ហើយអាងគម្ពីរផង ដើម្បីជាគោលចារឹកមាំមួនតទៅ ។

(មានត)

ការបង្ហាត់និស្ស័យ

ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាជាតិវរ៉ា វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌាន្តរ៉ាក្ស ប៊ុ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តមក)

ឧទាយបង្ហាត់និស្ស័យទី ៦

និស្ស័យរាប់អានគ្នា

លោកអ្នកនិភ័យគាំងឡាយ! លោកអ្នកបានជ្រាបពីខាងដើមរួចមកហើយថា តាមគោលកន្លងច្បាប់សង្គមវិទូនោះ មនុស្សយើងវាមែងជាសង្ឃកូតិ គឺជាសត្វស្រែកដែលត្រូវរួបរួមគ្នាជាពួក ចាប់ដើមតាំងអំពីជាគ្រួសារ ជាស្រុក ជាភូមិ រហូតដល់ជាប្រទេស. ទឹងត្រូវជាប់ចាក់ទងគ្នា កន្លងការបន្តសមាគម ទឹងនៅបែកខ្ញែកគ្នារាត់រាយដោយមិនរួមគ្នាឬមិនជាប់ចាក់ទងគ្នាមិនបាន ។ សូម្បីកន្លងប្រវត្តិសាស្ត្រក៏ត្រូវជាប់គ្នាដោយខ្សែលោហិត ឬផៅពង្សពន្ធុ ទឹងត្រូវជាប់តខ្សែលោហិតគ្នាមក ដោយលទ្ធិប្រពៃណី ឬទំនៀមទំលាប់ដែលត្រូវតែនៅរួមគ្នាជាពួកគណៈ ដែលហៅថា "ជាតិ" សូម្បីទឹងបែកខ្ញែកគ្នាចេញទៅនៅឆ្ងាយពីគ្នាយ៉ាងណាក៏ដោយ ក៏ល្មគណៈពណ៌សម្បុរទឹងភាសាសំដីនិយាយសំដែងឲ្យឃើញថាជាខ្សែជាតិជាមួយគ្នាដែរ ។

មនុស្សយើង សូម្បីជាប់គ្នាដោយខ្សែលោហិតនឹងជាប់ខ្សែគ្នាមកដោយលទ្ធិប្រៃវេណី ដែលអាចពាប់ថាជាខ្សែលោហិតជាមួយគ្នាដូចគោលមកហើយក៏ដោយ ក៏គុប្បីជ្រាប ១ ជាន់ទៀតថា ការនៅរួមគ្នានៃមនុស្សពួកច្រើននោះ រមែងធ្វើឲ្យកើតហេតុការណ៍ នឹងបណ្តាលឲ្យកើតសុខ, ទុក្ខ, ចំរើនវិនាសឡើង ដល់គ្នានឹងគ្នាបាន ។ បើមនុស្សមានសីលធម៌ចេះពាប់អានស្រឡាញ់គោរពកោតក្រែងចិត្តគ្នា មើលឃើញដំណែនៃភាពជាមនុស្សដូចគ្នា មិនភ្លេចថា "យើងជាមនុស្ស ឯអ្នកដទៃក៏ជាមនុស្សដែរ" មានមេត្រីចិត្តមិត្តភាព មានកិរិយានឹងវាចាសុភាពគួរលំនោចចំពោះគ្នា លើកដំកើងសរសើរទឹងដួយអនុគ្រោះចំពោះគ្នានឹងគ្នាហើយ រមែងបង្កឲ្យកើតសន្តិសុខនឹងសេចក្តីចំរើនបិតថែស្តាយរឡើងដល់គ្នានឹងគ្នា ។ តែបើជាមនុស្សគ្មានសីលធម៌ មិនចេះពាប់អានលើកដំកើងសរសើរគ្នា សំដែងអាការបុបគុណមើលងាយគ្នា ធ្វើសេចក្តីអាក្រក់ ចង្រៃពោរពេញទូសព្យាយកាចសាហាវចំពោះគ្នា ច្បាច្បាយកប្រហារគ្នា ប្រថ្នាបៀតបៀនសង្កត់សង្កិនខាំសាច់គ្នាស៊ីដូចសត្វតិរច្ឆាន កំមុខជាត្រូវបំពេញទុក្ខភ័យក្តៅក្រហាយឲ្យដល់គ្នានឹងគ្នា ។

ពិតមែន ស្រុកណា ផ្ទះណា ដែលមានសេចក្តីពាប់អានស្រឡាញ់គ្នា ចូលទៅតាំងនៅជានាយចៅហ្វាយហើយ ស្រុកនោះ ផ្ទះនោះរមែងជាទីនៅដ៏សុខសម្រាន្ត ធ្វើឲ្យកើតពន្ធឹស្វាងរុងរឿងរីកចម្រើនសប្បាយស្រស់

ស្រាយរឹតមុខរកគ្នា ។ បើយើងបាននៅក្នុងស្រុកភូមិដូច្នោះ ប៉ុន្តែនឹងបាននៅក្រោមដើមឈើដែលមានម្លប់ត្រជាក់ មានហ្វូងសត្វស្លាបចោមភេមហិចហើរទៅមក មានសូរសៀងនិយាយគ្នាល្វែងល្វើយ នឹងបញ្ចុកអាហារគ្នា ជាទីគួរឲ្យក្តើតក្តើនចិត្តយ៉ាងក្រៃលែង ។ ដូច្នេះ ដើម្បីនឹងឲ្យការនៅរួមគ្នានឹងការជាប់ជាក់ទង្គិចគ្នាបានសន្តិសុខ នឹងវឌ្ឍនាការស្នាព័ន្ធយើងទើបគួរបណ្តុះនិស្ស័យរាប់អានគ្នាតាមថ្នាក់ជាញាតិមិត្ត នឹងជាអ្នកធំអ្នកតូច ឬ អ្នកស្មើគ្នា ។ ការសំដែងកាយវាចាសុភាពនុងលំនោនចំពោះគ្នា ប្រព្រឹត្តខ្លួនស្មោះស្មើ លើកដំកើង ឋានៈគ្នាតាមទំនងដែលគួរនឹងអើពើដឿស្តាប់គ្នានេះ ជាលក្ខណៈនៃសេចក្តីរាប់អានគ្នា ។ បើលោក-អ្នកសំដែងកាយវាចាសុភាពនុងលំនោនចំពោះគ្នា ប្រព្រឹត្តខ្លួនឲ្យស្មោះស្មើ លើកដំកើងសរសើរស្តាប់បង្គាប់គ្នាតាមឋានៈអ្នកធំនឹងអ្នកតូចរហូតទៅជាអាចិណ្ណវត្ត ដក់ជាប់នៅក្នុងសន្តានហើយ លោក-អ្នកបានឈ្មោះថា ជាអ្នកមាននិស្ស័យរាប់អានគ្នា ។

លោក-អ្នកគង់ធ្លាប់បានឃើញហើយ មនុស្សខ្លះចូលចិត្តនៅស្ងៀម ។ បែរឲ្យគេ មិនអើពើរមើល - ស្តាប់ក្នុងកាលដែលមានគេនិយាយជាមួយ, មនុស្សខ្លះធ្វើក្តុងក្តាំនាំឲ្យជាទីរំខានចិត្តដល់អ្នកដទៃ បើអង្គុយឬឈរទេនឹងផ្លូវនៃណា ក៏ធ្វើព្រងើយកន្តើយ, មិនចៀសផ្លូវឲ្យអ្នកនោះ ខ្លះដើរដិតឬឈរដិតអ្នកដែលអង្គុយ ក៏ដើរបៃបចង់កន្ទុងសីស:

(ក្បាល) ឬដើរដិតសីស: ឬក៏ឈរបៃបចង់ជាន់សីស: តុំនោះឈរ
ច្រត់សីស: ខ្ញុះក៏ក្រែកវែកគេចេញទៅដោយមិនបានសួរមាសំគេ
កាលបើមានក្រៀវទៅណាមកណា ក៏មិនក្រែកទៅទទួល-ទៅអញ្ជើញ
ឬស្រស់ស្រាយច្រស់យ៉ដោយពាក់ពាក់ ។ នរណានិយាយរ៉ូវក៏ចោទ
ប្រកាន់ ចាប់ថ្នាក់គេ មិនថាខុសឬត្រូវឡើយ ជាមនុស្សរ៉ឹងរូស ប្រមាទ
មើលងាយមនុស្សដ៏ទៃ ឃើញថាគេសុទ្ធតែអន់ជាងខ្លួនតាំងអស់ មិន
ទុកជាក់ពិរោអធ្យាស្រ័យតាមដែលសមដែលគួរ ជាមនុស្សលុបគុណ
ពាយឫក លើកដំកើងខ្លួនដើម្បីសង្កត់អ្នកដទៃដោយចូលចិត្តថាជាគ្រឿង
ធ្វើឲ្យគេថោកទាប ហើយឋានៈរបស់ខ្លួនក៏នឹងខ្ពស់ត្រដែតឡើង ទំពាយ
ឫកដោយនឹកសំគាល់ក្នុងចិត្តថាខ្លួនជាមនុស្សល្អ ជាមនុស្សសំខាន់ មិន
មានសម្ងាត់ពាក្យ:ចំពោះនរណាមួយ ទំដំឡើងអំណាច ដំឡើងធង់ដោយ
យល់ថាខ្លួនជាអ្នកធំ ជាមនុស្សខ្ពង់ខ្ពស់ថ្លៃឯយសថ្លៃឯសំក្តី ចិត្តរ៉ឹងត្អឹង
រ៉ឹងរូសយោរយៅយង់ឃ្នង ប្រដៅគ្រ មិនត្រមជឿមិនត្រមស្តាប់ពាក្យ
ជាសំគ្រើនណែនាំខ្នាន ប្រែនប្រដៅរបស់នរណាតាំងអស់នេះ ឈ្មោះ
ថាជាមនុស្សមិនពាប់អានអ្នកដទៃ ។

សេចក្តីអាក្រក់ទាំងនេះ ជាទីគួរឲ្យខ្ជាសខ្ជៃលែង ។ សូម្បីត្រឹម
តែនិយាយអាក្រក់ចំពោះគ្នាប៉ុណ្ណោះ ប្រសិនបើគិតមើលតែស្មើរៗពាក់ៗ
ក៏ឃើញថាហាក់ដូចជាការចង្កិចបង្កូចសោះ តែកាលបើពិគ្រោះឲ្យល្អិត

ស្អួនៅ គង់នឹងឃើញថាជាទោសដ៏ធំក្រៃលែង ។ បើលោក-អ្នកព្រម
បណ្តោយឲ្យអំពើបែបនេះ ចូលមកគ្របសង្កត់ចិត្តខ្លាំតែស៊ប់ស្ងួនហើយ
លោក-អ្នកក៏នឹងទៅជាសត្រូវយ៉ាងកាចសាហាវ ព្រោះនឹងធ្វើដំណឹង
(សេចក្តីដឹង) ខាងក្នុងរបស់លោក-អ្នកឲ្យអាក្រក់ឆ្អែរូសទៅតាមកិរិយា
ខាងក្រៅ ពាំងបំផ្លាញភាពជាមនុស្សល្អឲ្យអស់ទៅផង ខ្លួនលោក-អ្នក
ក៏នឹងក្លាយទៅជាមនុស្សមានទិស្ស័យអាក្រក់ គ្រោតគ្រាតរឹងរូសលុប
គុណមើលងាយអ្នកដទៃ ។ ដូច្នេះ ការសំដែងកាយវាចាគ្រោតគ្រាត
ទើបចាត់ថាជាគ្រឿងសំគាល់នៃការមិនរាប់អានគ្នា ។

មនុស្សមានទិស្ស័យមិនរាប់អានអ្នកដទៃ សូម្បីនៅក្នុងទីណា ក៏មាន
តែការបង្កសេចក្តីក្រោធឲ្យកើតឡើងដល់គ្នានឹងគ្នាក្នុងទីនោះ ដូចជាកាល
សំដែងសេចក្តីអាក្រក់ចំពោះអ្នកណា អ្នកនោះរមែងក្រោធមិនពេញចិត្ត
ហើយនឹងស្អប់ខ្ពើម បើទំបញ្ចេញចំពោះមនុស្សដទៃច្រើនគ្នាផង ក៏រឹង
តែតែបន្ថែមចំនួនមនុស្សដែលក្រោធខឹងស្អប់ខ្ពើមច្រើនឡើងដែរ ឥតមាន
អ្នកល្អណាមួយ ប្រាថ្នាសមាគមសេពគប់រកឡើយ ។

(មានត)

កណ្ឌទី ១៦

ឧកញ៉ាវិបុលរាជសេនា ង្វ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ធំងបេះខុបាយកលបំណាន
ទាំងមានសង្គ្រានស្នេហាជាតិ ។

ឯគាហានតៀវស៊ីវដែលតួនបង្គប់នៅទីនោះ ក៏អុចផ្ទាំរបោះឡើងជាសញ្ញា ហើយនាំគ្នាចេញស្រមកទាំងសងខាង ព្រតគ្នាវាយទួបចាប់កាប់សម្លាប់កងទ័ពចូឆូស្លាប់ជាសជាច្រើនណាស់ នៅរសាត់ប៉ុន្មានក៏ទន្ទ្រានសុះរត់រួចថយចេញទៅក្រោយ ។ តៀវស៊ីវក៏បរពលដេញបណ្តាយទៅ ។ ឯចូឆូនឹងបណ្តាគាហាន ដែលនៅរក្សាបន្ទាយក៏ភ្ញាយបែកខ្ចែកទៅជាមួយគ្នា ។ តៀវស៊ីវក៏ដេញចំពារទៅទៀតបានចម្ងាយប្រហែល ៣០០ សិន (១២ គ.ម.) ជួនភ្លឺស្រាង តៀវស៊ីវក៏នាំគាហានវិលចូលមកស្រុកវិញ ។

ចូរឲ្យយើញអ៊ីគឺមនឹងលើយ"យត្រូវត្រួញជាច្រើនអន្ទៀ កំឲ្យត្រួតរាប់
ភាហានមើលឃើញចាត់ប្រហែល ៥ ដុំនថ្ងាយ ។ ភាសៀងដឹងថា
ចូរឲ្យចូរភាតភាហានជាច្រើន កំនិយាយនឹងតៀវស៊ីវថា សុំឲ្យលោកមាន
សំបុត្រទៅដល់ខ្លៅពៀវនៅស្រុកកេងដីវ ឲ្យខ្លៅពៀវទៅចាំស្លាក់រយ
ចូរឲ្យ យើញថានឹងចាប់ខ្លួនចូរឲ្យបាន ។ តៀវស៊ីយើញត្រូវ ទើបតែង
សំបុត្រផ្ញើទៅឲ្យខ្លៅពៀវ ។

ខ្លៅពៀវបានទទួលសំបុត្រដឹងសេចក្តីហើយ កំប្រមូលសេនា
ភាហាននឹងលើកទៅចាំស្លាត់ចូរឲ្យ ទទួលដឹងដំណឹងថា សុំនសិកលើកទ័ព
ចូរមកតាំងនៅចាក់អាវស្រុកកេងដីវ ។ ខ្លៅពៀវទើបប្រឹក្សានឹងកេង-
លៀងថា តៀវស៊ីវមានសំបុត្រមកដល់យើង ឲ្យលើកទ័ពទៅស្លាក់រយ
ទ័ពចូរឲ្យ តឲ្យវស៊ុនសិកក៏លើកទ័ពមកគិតនឹងរយយកស្រុកយើងៗ នឹង
គិតប្រការដូចម្តេចទៅវិញ ។ កេងលៀងធ្វើយថា ដែលស៊ុនសិកលើក
មកគ្រានេះ ជាគំនិតរបស់ចូរឲ្យ តឲ្យវចូរឲ្យបាជ័យនឹងថ្វីដៃតៀវស៊ីវហើយ
មុខជាស៊ុនសិកធ្វើការមិនសម្រេច យើងនឹងលើកទ័ពទៅរយបន្ទៃមឲ្យ
ចូរឲ្យបែកទ័ពចាញ់យើងឲ្យបាន ទើបមិនកើតមានសេចក្តីអន្តរាយដល់
យើងខាងក្រោយ ។ ខ្លៅពៀវយល់ឃើញត្រូវក៏ចាត់ប្រើហាងចលើក
ភាហានទៅស្លាក់បង្ខំទ័ពស៊ុនសិកកុំឲ្យត្រួងចូលមកបាន ។ ខ្លៅពៀវក៏
លើកទ័ពទៅចាំស្លាក់ទ័ពចូរឲ្យនៅដែនស្រុកអាន់ចុងគួន ។

តៀវស៊ីវកាលផ្ញើសំបុត្រទៅឲ្យឡៅតៀវហើយ ក៏ចាត់ខាហានលើកទ័ពតាមចូឆួទៅ ។ កាលវ៉ែលចូឆួបែកទ័ពទៅនោះ មិនបានឲ្យខាហានស្រូតរូតច្រញាប់ លើកទ័ពលំហែទៅតាមផ្លូវជាប្រក្រតី លុះទៅដល់ខន្ទេប៉ុកស៊ុយ ចូឆួក្លែងធ្វើជាយំសោក ។ ខាហានចាំងពួនយើញដូច្នោះ ក៏ដំរាបសួរចូឆួថា លោកយំសោកជាទុក្ខព្រោះហេតុអ្វី? ។ ចូឆួឆ្លើយថា យើងមកដល់ទីនេះ. ឲ្យចេះតែមានចិត្តគិតនឹកលឹកដល់តៀនអ៊ុយ ដែលស្លាប់ ព្រោះធ្លាប់មកជាមួយគ្នាជាមិត្តភក្តិកំសត់កម្រ" ហើយក៏ឲ្យតែងតាំងគ្រឿងសក្ការៈអុចធូបទៀនជ្រួចស្រាសែនឲ្យតៀនអ៊ុយ ។ ខាហានចាំងពួនក៏យំសោកចាំងអស់គ្នា ហើយចូឆួក៏សែនឲ្យចោងាំងជាកូន នឹងចោអាន់ប៊ុនជាកូយ ហើយនឹងបណ្តាកូនខាហាន ដែលស្លាប់ចាំងប៉ុន្មាន ហើយលើកខាហានធ្វើខន្ទេប៉ុកស៊ុយទៅ ។ ខ្ជួលមានចំរើសេះនាំសំបុត្រស៊ុនហុកមកជូនចូឆួ។ មើលសេចក្តីដឹងថា តៀវស៊ីវឲ្យឡៅតៀវលើកកងទ័ពមកស្ទាក់នៅជែនស្រុកអាន់ប៊ុងគួន ឲ្យលោកគិតការពារប្រយ័ត្នឲ្យមាំមួន ។ ចូឆួក៏ធ្វើសំបុត្រតបទៅឲ្យស៊ុនហុកថា "ដែលឡៅតៀវលើកទ័ពមកស្ទាក់ផ្លូវទុកនោះ ហើយតៀវស៊ីវលើកទ័ពតាមមកពីក្រោយ យើងដឹងអស់ហើយ បានជាយើងដើរទ័ពលំហែតែ ១ ថ្ងៃ ១០០ សិន (៤ គ.ម.) ដើម្បីនឹងគិតជាកល។ ចាយបញ្ជូនតៀវស៊ីវ នឹងឡៅតៀវឲ្យមានចិត្តកំរើបធ្វេសប្រហែស យើងនឹងវាយយកជ័យជំនះឲ្យបាន ដែល

ស៊ីនហុកអំលឹកស្នាតើយើងទោះ យើងក៏អរគុណណាស់ហើយ កុំឲ្យស៊ីន-ហុកវិតក្តៅឡើយ" ដូច្នេះហើយលើកខ័ពៅដិតនឹងដល់ស្រុកអាន់ចុងគួន ព្រះកិត្តិស័ព្ទថាកងខ័ពតៀវស៊ីវលើកដិតខាន់ហើយ ។ លុះដល់ពេលព្រលប់ ចូធូក៏បង្គាប់ថាហានឲ្យញែកគ្នាជា ២ កង ឲ្យដឹកអំលុងពួនខ្លះ ពួនកងគុម្ពតែឈើខ្លះ ពួនកងគុម្ពស្មៅចាំងសងខាងផ្លូវខ្លះ ចម្ងាយប្រហែល ៩-១០ សិន (៤០០ម.) ហើយឲ្យតាំងបន្ទាយអែបៅខាងក្នុងក្បែរផ្លូវខ្លះ ឲ្យថា-ហានៅរក្សាបន្ទាយតិចល្មមសមគួរ បើយើញខ័ពតៀវស៊ីវតាមមកដល់ឲ្យ ថាហានក្នុងបន្ទាយសម្រុកឲ្យស្ងៀម ចាំតែតៀវស៊ីវលើកចូលវាយបន្ទាយ គ្រាណា ឲ្យអុចផាវជាសញ្ញាឡើង ឲ្យថាហានចាំង ២ កងលើកចេញ មកខ្ទប់ចាំងសងខាង ឯតៀវស៊ីវក៏បង្វិលលើកខ័ពៅចាំងយប់ មិនចាន់យើញ បន្ទាយដែលចូធូតាំងទុក ក៏លើកថាហានបង្ហូរចូលៅដួចកងខ័ពតៀវ តៀវ ហើយសួរថាបានដួចនឹងកងខ័ពចូធូឬទេ? ។ តៀវតៀវធ្វើយថា មិនបានដួចប្រទេះទេ ។ លុះព្រឹកឡើងថាហានដំរកតៀវស៊ីវថា_ ចូធូតាំងបន្ទាយនៅក្បែរនឹងដើងកុំខាងក្រោយ យើញថាហានក្នុងបន្ទាយមានស្ងួច ស្ងើងទេ ។ តៀវស៊ីវនឹងតៀវតៀវអែរណាស់ ទើបលើកខ័ពប្រសព្វគ្នាចាំង សងខាងរួមជាកង ១ ហើយក៏លើកចោមរាយទំលាយបន្ទាយចូធូចាំងថ្ងៃ ។

ចូធូក៏អុចផាវជាសញ្ញាឡើង, ឯថាហានដែលបង្គាប់ចាំងសងខាងផ្លូវ ក៏លើកចេញស្រមកវាយខ្ទប់ប្រសព្វគ្នា កាប់សម្លាប់ខ័ពតៀវស៊ីវនឹងតៀវ

ពៀវស្ងាប់ជារច្រើន ។ តៀវស៊ីវនឹងឡៅពៀវកំបែកវត់ទៅ ចូឆួកំលើកទាហានស្រួតទៅចាល់តែផុតដែនស្រុកអានចុងគួន ទើបតាំងបន្ទាយនៅទីនោះ ។ ឡៅពៀវនិយាយនឹងតៀវស៊ីវថាពេលនេះយើងចាញ់កលចូឆួដោយដឹងកលមិនដល់ ។ តៀវស៊ីវឆ្លើយថា តឡូវទាហានយើងនៅកំពុងហត់នឿយណាស់ ត្រូវតែសម្រាកឈប់ឲ្យទាហានមានកំឡាំងកាលណា នឹងគិតការសងសឹកចូឆួឲ្យបានវិញ ។ ឡៅពៀវយល់ឃើញត្រូវក៏ឲ្យតាំងបន្ទាយនៅក្នុងទីនោះ ។

ឯស៊ុនហុកដែលនៅរក្សាស្រុកដល់ដឹងក្នុងសំបុត្រចូឆួហើយ ទទួលឮកិត្តិស័ព្ទថា អ៊ិនសៀវនឹងលើកទ័ពទៅវាយស្រុកហ៊ូគោ ក៏ធ្វើសំបុត្រប្តឹងមកចូឆួតាមដំណើរហេតុនោះ ។ ចូចូឮដូច្នោះក៏ទោមនស្សត្អូចចិត្តពេក ទើបប្រមូលសេនាទាហានស្រួតលើកទ័ពត្រឡប់ចូលទៅក្រុងហ៊ូគោ ។ ឯតៀវស៊ីវឮថា ចូឆួលើកកងទ័ពត្រឡប់ទៅស្រុកហ៊ូគោហើយ ក៏រៀបប្រមូលសេនាទាហានលើកទៅតាមចូឆួ ។ កាសៀងនិយាយហាមឃាត់ថា ដែលលោកនឹងលើកទៅតាមលើកនេះ ខ្ញុំយល់ឃើញថា គង់ចាញ់គេជាអសារឥតការ ។ ឡៅពៀវឆ្លើយថា ពេលនេះបានការល្អហើយ នឹងមិនលើកតាមទៅ ចុះនឹងនៅធ្វើអ្វីឲ្យព្រួយការ ។

(មានត)

រឿងអាត៌ក្សត្រៃងរឿងម្លៃច្រាំ

លោកវ៉ាយ-ប៊ុក ក្រមការ

ប្រែពីចាវ៉ាំងមកជាខ្មែរ

(តមក)

រឿងទីដប់ប្រាំបី

អាត៌ក្សត្រៃាបបង្គំទូលថា: បពិត្រមហាពាជ! មាននគរមួយឈ្មោះ កុពលបុរៈ (Kubalpur ប្រែហេលជា កមលបុរៈ ប្រែថា នគរកមល, នគរដាំឈូក) ។ ព្រះមហាក្សត្រដែលសោយរាជ្យនៅនគរនោះ ទ្រង់ព្រះនាមសុទក្សិ (Sudakshi) ។ នៅកន្លែងនគរនោះ មានពាណិជម្នាក់ឈ្មោះ ធនក្សិ (Dhanaskhi) គាត់មានបុត្រីម្នាក់នាមនាង់ធនវតី (Dhanvati) ។ នាយពាណិជបានរៀបចំនូវរឿងហាមង្គលការ នាង់ទៅនឹងប្រុសកម្លោះម្នាក់ឈ្មោះគូរិទត្ត (Gauridatt) តាំងពីយុវនវ័យ ។ ឯគូស្វាមីភរិយានេះបានបុត្រីម្នាក់នាមនាង់មោហនី (Mohani) ។ ប៉ុន្មានឆ្នាំក្រោយតមកគូរិទត្តទទួលអនិច្ចកម្ម ។ ញាតិសន្តានខាង់ស្វាមីនាង់ធនវតី បានដណ្តើមយកទ្រព្យសម្បត្តិពីនាង់អស់គ្មានសល់ ។ នាង់គ្មានធនធាន, បានដឹកដៃបុត្រីនាង់ ដើរចេញពីគេហដ្ឋានរបស់នាង់កន្លងពេលយប់ងងឹត ធ្វើដំណើរទៅកាន់គ្រឹហាបិតាមាតា ។ ដល់នាង់ត្រាច់តាមផ្លូវនាង់រត្ងើងផ្លូវ, បានទៅដល់ថ្លុបដ្ឋានមួយដែលគេកុំពុងធ្វើទណ្ឌកម្មចោរម្នាក់ ដោយយក

ឈើរស្រែចមួយបុកពីក្បាលធ្លាក់ចូលទៅក្នុងគោះវឿន តែចោរនោះនៅរស់នៅឡើយ ។ ក្នុងពេលនោះយប់ជ្រងឹត នាងធនវតីចាប់ដេរដើរចោរនោះនឹងដៃនាង ។ ចោរនោះក៏ស្រែកថា: "នាងឯងធ្វើឲ្យយើងឈឺពន់ពេកណាស់" ។

នាងធនវតីតបថា: "ខ្ញុំគ្មានចំណងនឹងធ្វើឲ្យអ្នកឈឺចាប់សោះឡើយ, សូមអ្នកអត់ទោសខ្ញុំចុះ" ។

ចោរពោលថា: "នៅស្ថាននេះគ្មានអ្នកណាឲ្យទុក្ខឬឲ្យសុខទេ ។ គេទទួលតែទុក្ខ ដែលព្រះអាទិទេពបានកត់ក្នុងជោគវាសនា ហើយអ្នកផងពោលថា យើងបានធ្វើនេះឬបានធ្វើនោះជាអ្នកខ្លាំងពូកែ, ព្រោះថាមនុស្សមានខ្សែជោគវាសនាខ្លាំងណាស់ ។ ខ្សែនោះដឹកនាំអ្នកពីទីនេះទៅទីនោះ ។ គ្មានអ្នកណាអាចយល់ព្រះរាជបំណងនៃព្រះអាទិទេពទេ ។ មនុស្សកាត់ខ្សែបំណងនេះ តែងធ្វើខ្សែបំណងជាថ្មីមួយទៀតមិនចេះអស់មិនចេះហើយ" ។

នាងធនវតីបានស្តាប់វាចារបស់ចោរក៏សួរថា "អ្នកជាអ្វី?" ។ ចោរក៏តបទៅនាងវិញថា "ខ្ញុំជាចោរ, ខ្ញុំបានទទួលទុក្ខកម្មនេះបីថ្ងៃហើយតែខ្ញុំនៅតែមានជីវិតនៅឡើយ" ។ នាងក៏សួរទៅវិញថា "ព្រោះហេតុអ្វី?" ។

– ព្រោះខ្ញុំមិនទាន់មានប្រពន្ធនៅឡើយ ប្អូរនាងឲ្យបុត្រីនាងមកជាប្រពន្ធខ្ញុំ ហើយខ្ញុំនឹងជូននាងនូវរូបិយអាស្សរហ្គី (Assrahi រូបិយមាសតម្លៃ ៤០ ត្រណាត) ចំនួនមួយក្រូ (Crore ou Karôr គឺ ១ លាន អាស្សរហ្គី) ។

ពិតមែនតែចិត្តកំណាញ់ជាឫសគល់នៃបាបធម៌ តណ្ហាជាហេតុឲ្យ
កើតទុក្ខ គ្រោះថ្នាក់ជាប្រភពនៃសេចក្តីលំបាក ។ បើអ្នកណាការ
ពារកុំឲ្យសភាពទាំងបីនេះកើតឡើងបាន, អ្នកនោះអាចរស់នៅជាសុខក្នុង
លោក ។ តែអ្នកទាំងអស់ចៀសវៀងនូវសភាពទាំងបីនេះមិនផុត ។ ចិត្ត
កំណាញ់ចូលទៅគាក់ចិត្តនាងធនវតីក្នុងពេលនោះ ។ នាងក៏បានប្រគល់
បុត្រីទៅឲ្យចោរហើយសួរថា "តើអ្នកមានមធ្យោបាយយ៉ាងណាឲ្យកូន
ប្រុសមួយបដិសន្ធិក្នុងគេហដ្ឋានបាន?" ។

ចោរតបថា "កាលណាបុត្រីនាងនឹងទៅជាភរិយាគេអនាគត,
នាងត្រូវហៅព្រហ្មណ៍ស្អាតម្នាក់, ហើយក៏ឲ្យបុត្រីនាងព្រមទាំងប្រាំរយ
មុហារ្ស (muhars រូបិយមាស) ហើយនាងជាបុត្រីមុខជាប្រសូតិកូន
ប្រុសមួយមិនខាន" ។

ដល់នាងធនវតីបានស្តាប់ពាក្យចោរហើយ, នាងក៏បានដឹកដៃកូន
ស្រីប្រគល់ឲ្យណាឈើស្វែចចោះជាប់នោះបួនដុំ, ហើយប្រគល់កូនស្រីនាង
ឲ្យទៅចោរធ្វើជាប្រពន្ធ ។ ចោរក៏ពោលថា: "នាងកើត, នៅជិតអណ្តូង
ឥដ្ឋ មានដើមអដបាលទិគ្រោធមួយដើម ។ នៅពីនេះខ្ញុំបានយករូបិយ-
មាសទៅកប់ទុកចូរនាងអញ្ជើញទៅយកចុះ" ។ ចោរនោះពោលរួចហើយ
ក៏ទទួលមរណភាពក្នុងពេលនោះ ។ នាងធនវតីបានទៅដល់ទីកន្លែង
ដែលចោរនោះប្រាប់ នាងបានយករូបិយមាសនោះទៅជូនមាតាបិតា ។

នាងបានថ្វែងនូវឿងរ៉ាវដំណាបបិតាមាតាសព្វគ្រប់, នាងក៏អញ្ជើញ
បិតាមាតាទៅនៅឯភូមិដែលស្វាមីនាងនៅ ។ នាងបានចាត់ឲ្យសង់
គេហដ្ឋានមួយធំហើយក៏នៅក្នុងនោះ ។ បុត្រីរបស់នាងក៏ចំរើនវ័យវឌ្ឍនា
ការ រហូតដល់តុណាវ័យក្នុងពេលនោះ នាងកំពុងនឹងយកលេងលើកន
ហាលជាមួយសហជីវិនីរបស់នាងម្នាក់, ស្រាប់តែនាងក្រឡេកទៅឃើញ
ព្រាហ្មណ៍ដ៏ឧត្តម្នាក់ ត្រាច់តាមថ្នល់, នាងក៏មានចិត្តប្រតិព័ទ្ធស្នេហាទៅ
រកព្រាហ្មណ៍នោះ ។ ហើយនាងក៏បានពឹងមេនំម្នាក់ឲ្យជូនព្រាហ្មណ៍នោះ
រៀងជិតមាតា ។ មេនំក៏ធ្វើតាមបង្គាប់នាង ។ មាតានាងដល់បានឃើញ
ព្រាហ្មណ៍ដ៏ឧត្តមនោះក៏ពោលថា: "ម្នាលព្រាហ្មណ៍! កូនស្រីខ្ញុំពេញក្រមុំ
ហើយ, ចូរព្រាហ្មណ៍នៅជាមួយនឹងកូនស្រីខ្ញុំចុះ ដើម្បីនឹងឲ្យនាងមាន
កូនប្រុសមួយតពូជវង្សត្រៃទៅ ។ ខ្ញុំជូនអ្នកខ្ញុំមួយរយរូបិយមាស" ។

ព្រាហ្មណ៍នោះក៏ព្រមទទួលតាំងអស់ ។ អ្នកតាំងពីរក៏ពុងតែ
សន្ទនាគ្នាទៅវិញទៅមក, ទទួលយប់មកដល់ ។ នាងក៏យកម្ហូបអាហារ
មកជូនស្វាមីពីសារ ។

សុភាសិតមួយពោលថា: តណ្ហាកើតឡើងដោយហេតុ ៧ យ៉ាងគឺ
គ្រឿងក្រអូប, ស្ត្រី, សំលៀកបំពាក់, មូ, ម្ហូបអាហារ, គ្រែនិទ្រា និង
គ្រឿងអលង្ការផ្សេង។ ។

ដល់នាងនឹងស្វាមីបានស្ថិតនៅជាមួយគ្នាមួយយប់ក្នុងបន្ទប់ គ្រែ
ត្រអាលសប្បាយនូវតាមតណ្ហាតាមចិត្ត, លុះព្រឹកឡើង ព្រាហ្មណ៍នោះ

វិលត្រឡប់ទៅផ្ទះវិញ ។ ឯនាងក៏មកអង្គុយជិតពួកសហជីវិនីរបស់នាង ដូចដើម ។ មានសហជីវិនីនាងម្នាក់សួរនាងថា: "នាងដែលស្ថិតនៅជាមួយមិត្តនាងយប់មិញ តើមានចិត្តសប្បាយរីករាយយ៉ាងណាខ្លះ?" ។

នាងក៏តបវិញថា: "កាលខ្ញុំអង្គុយនៅជិតព្រាហ្មណ៍នោះ ខ្ញុំមានមនោសញ្ចេតនាពិរោមពិស្បែកជាបបម, រួចដល់ព្រាហ្មណ៍ញញឹមមកកេរខ្ញុំហើយកាន់ដៃខ្ញុំ។ មានចិត្តគោរពន់ហើយខ្ញុំជឿខ្លួនខ្ញុំថាខ្ញុំធ្លាក់ទៅនៅក្នុងកណ្តាប់ដៃព្រាហ្មណ៍គឺខ្ញុំចាញ់, ព្រាហ្មណ៍នោះ នៅជាម្ចាស់ទៅហ្ន៎យខ្ញុំ. តមកខ្ញុំក្លឹកស្មារតីមិនដឹងអ្វីទៀតសោះឡើយ" ។

គេពោលថា: ស្ត្រីមិនដែលក្លៀវក្លាមីឧត្តម, ក្លាហាន, មានប្រាជ្ញ, ជាទៅហ្ន៎យ, មានចិត្តសប្បុរស, មានគុណធម៌ប្តូរបត្តម្ភស្ត្រីគ្រប់យ៉ាងក្នុងដីវភាពបច្ចុប្បន្ននឹងអនាគត ។

ក្នុងពេលនោះ នាងមោហនីមានគតិ លុះដល់គ្រប់ទសមាសនាងប្រសូតបុត្រមួយ ។ ដល់យប់ទី ៦ នាងប្រសូតបុត្រពួចស្រេច, នាងបានយល់សប្តិឃើញព្រះយោគីម្នាក់ មានសក់ក្រងដូចជាកន្ទេលលើក្បាល; នៅលើថ្ងាសមានរូបព្រះចន្ទក្លឹងចាំង កាយលោកលាបដោយផេះនៃណ. មកគោញីដែលគេយកទៅដុតហើយ ពាក់ខ្សែពិសិដ្ឋពណិសរបស់ព្រាហ្មណ៍ ព្រះយោគីនោះអង្គុយនៅលើអាសនៈធ្វើនឹងបុប្ផាបទុមសមានពាក់កង ១ ធ្វើនឹងឥស់សនឹងកង ១ ទៀត ធ្វើនឹងក្បាលសាកសពដៃមួយកាន់លោកក្បាលសាកសព, ដៃមួយទៀតកាន់គ្រឿងដែកមាន

ធ្មេញបី ។ លោកបានបង្ហាញរូបនិមិត្ត ចំពោះមុខនាងមានសភាពសំបើមអស្ចារ្យហើយពោលថា: "ស្អែកពេលព្រាត់កណ្តាលអធ្រាត្រស្ងាត់ ចូរយកល្អីមួយធំដាក់រូបិយមាស ១.០០០ មុហារ្យ. ព្រមទាំងបុត្តកងនោះផង រួចយកទៅបោះបង់ចោលមុខក្លោងទ្វារព្រះបរមរាជវាំង" ។ ដល់នាងស្តាប់រាចាព្រះយោគីកងនិមិត្តនោះ នាងក៏ភ្ញាក់ពីនិទ្រា, បើកភ្នែក, លុះព្រឹកឡើង, បាននៅពណ៌នារឿងយល់សប្តនោះ ជំរាបនាងធនវតីជាមាតា ។ នាងជាមាតាបានស្តាប់សំដីនាងមោហនីកូនស្រីចប់សព្វគ្រប់, នាងក៏យកល្អីធំនោះមកដាក់រូបិយមាសនឹងទៅប្រុស, យកទៅដាក់ចោលនៅមុខព្រះបរមរាជវាំងតាមបង្គាប់ព្រះយោគី ។

កងពេលនោះ ព្រះមហាក្សត្រខ្ទង់និមិត្តឃើញបិសាចមួយមានដៃដប់, ក្បាលប្រាំ, ភ្នែកបី; ហើយនៅលើក្បាលនីមួយៗ មានព្រះចន្ទមានព្រះខន្ធធំៗ កាន់នៅនឹងដៃដែកមានធ្មេញបី ។ បិសាចនោះមានរូបខ្ទង់ព្រាយសំបើមអស្ចារ្យ មកដល់ចំព្រះភ័ក្ត្រព្រះមហាក្សត្រក៏ក្រាបបង្គំទូលថា: "សូមខ្ទង់ព្រះមេត្តាជ្រាស! នៅក្លោងទ្វារខាងមុខមានល្អីមួយធំ ។ សូមខ្ទង់យកទារកដែលនៅកងល្អីនោះ, ទារកនោះជាអ្នកគ្រប់គ្រងព្រះរាជអាណាចក្រព្រះអង្គក្នុងកាលជាអនាគត" ។ ព្រះមហាក្សត្រិយ៍ខ្ទង់ក៏បើកព្រះនេត្រ មានព្រះរាជឫទ្ធារៅកាន់ព្រះអគ្គមហេសីអំពីរឿងដែលខ្ទង់និមិត្តនោះ ។ ខ្ទង់បានតើនឡើងពីក្រឡា

ព្រះបន្ទុំ ខ្ញុំដឹងតយល់ល្អីមួយធំនៅក្នុងផ្ទះខាងមុខព្រះបរមរាជវាំង ។ ខ្ញុំបានបើកល្អីនោះហើយ ឃើញយល់ឱកម្ចាក់ត្រមាំងរូបិយមាស ១.០០០ ។ ខ្ញុំក៏បានបីឱកនោះយកមកដាក់លើព្រះជង្ឃា (ជង្គង់) នៃព្រះអគ្គមហេសី ។ ឯរូបិយមាសខ្ញុំឲ្យនាយទ្វារបាលយកមកតាមក្រោយព្រះអង្គ ។ ពេលនោះទន្លួលឫទ្ធិឈ្មោសម័យ, ព្រឹមហាក្សត្រិយ៍ខ្ញុំចេញពីក្នុងព្រះបន្ទុំ, ត្រាស់បង្គាប់ឲ្យហៅបណ្ឌិតនឹងហោរាហើយមានបន្ទូលថា: "តើនៅលើរូបឱកនេះមានរាជលក្ខណៈឬទេ?" ។

ក្នុងពេលនោះមានព្រាហ្មណ៍ម្នាក់ក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ថា "បពិត្រមហារាជ! នៅលើរូបឱកនេះមានលក្ខណៈបីយ៉ាងគឺ: ជើងខ្ញុំធំទូលាយ, ថ្ងាសខ្ពស់, មុខធំ ។ ក្រៅពីលក្ខណៈខាងលើ ឱកនេះមានរូបលក្ខណៈសាមសិបពីរយ៉ាងទៀត ដែលផ្សេងពីមនុស្សសាមញ្ញ ។ សូមខ្ញុំកុំព្រួយព្រះរាជហឫទ័យអ្វីសោះឡើយ ឱកនេះមុខជានឹងបានសោយរាជសម្បត្តិជាស្តេចក្នុងកាលជាអនាគតមិនខាន" ។

ព្រះមហាក្សត្រិយ៍ ខ្ញុំមានព្រះទ័យសោមនស្សពន់ពេក, ខ្ញុំបានធ្វើព្រះរាជអំណោយដល់ព្រាហ្មណ៍ហោរានោះ ទ្ងូវខ្សែកគជង្ឃ ត្រមាំងសេះវត្ថុឯទៀតជាច្រើន ហើយខ្ញុំត្រាស់បង្គាប់ឲ្យដាក់ព្រះនាមឱកនោះ ។ តែពួកបណ្ឌិតបានក្រាបបង្គំទូលខ្ញុំថា: "សូមខ្ញុំព្រះមេត្តាជ្រាស! សូមព្រះអង្គខ្ញុំគង់ដឹងព្រះអគ្គមហេសី ហើយ

សូមយកព្រះភូសាវែងស្រោបព្រះអង្គទាំងពីរ ហើយសូមព្រះអគ្គមហេសី ជាក់ព្រះពាជបុត្រលើព្រះជង្ឃា ។ សូមទ្រង់គ្រាស់បង្គាប់ឲ្យប្រជាពស្តេចមកជួបជុំនៅទីនេះ ដើម្បីនឹងរៀបពិធីបុណ្យជាទក្សិណ ។ នៅក្នុងពេលនោះ, ទូលបង្គំនឹងជាក់ព្រះនាមព្រះពាជបុត្រទៅតាមបទបញ្ជាត្តិគម្ពីរពុទ្ធសិង្ឃ" ។

ព្រះមហាក្សត្រិយ៍ទ្រង់គ្រាស់បង្គាប់ទៅរដ្ឋមន្ត្រីរបស់ព្រះអង្គឲ្យរៀបចំតាមបង្គាប់ហោរា ។ រដ្ឋមន្ត្រីក៏បានចាត់មនុស្សឲ្យផ្សាយដំណឹងអំពីបដិសន្ធិព្រះពាជបុត្រ ព្រមទាំងហៅប្រជាពស្តេចទៅកាន់ពិធីបុណ្យជម្ងោះ ។

ប្រជាពស្តេចទាំងប្រុសស្រីក៏បាននាំគ្នាទៅកាន់ព្រះបរមពាជវាំង គ្រប់គេហដ្ឋានបានធ្វើចុតហ្វាយថ្វាយពរដ៏យមង្គលសិរីសួស្តីគ្រប់ចំពូក, ភ្លេងមហោស្រពពុះពារកក្រឹងព្រះបរមពាជវាំងហើយក៏ចាប់ផ្តើមបុណ្យនោះ ។

ព្រះមហាក្សត្រិយ៍នឹងព្រះអគ្គមហេសី ទ្រង់បានជាក់ព្រះពាជបុត្រលើព្រះជង្ឃា ទ្រង់គង់នៅក្នុងព្រះតំណាក់ដែលគេរៀបចំទុកវេទិសក្ការបូជា ព្រមទាំងភាទនិយាហារមានទំបង្អែមជាដើម ក្នុងពេលវេលាមង្គលការប្តីពិធីបុណ្យផ្សេងៗ ហើយដល់ពិធីបុណ្យរួច គេយកនំបង្អែមនោះចែកទៅជាទាន ។ ពួកព្រាហ្មណ៍ក៏តាំងសូត្រនូវវេទ ។ មានព្រាហ្មណ៍ម្នាក់ជាបណ្ឌិតហោរា បានពិនិត្យមើលពួកតារាទាំងប៉ុន្មានតំណត់ពេលវេលាដ៏គួរនឹងដោគជតាតំណើត ហើយក៏ដាក់ព្រះនាមព្រះពាជបុត្រថា ហរិទត្ត (Haridatt ប្រែថាអំណោយព្រះវិស្ណុ) ។

ហាទៃគ្គទ្រង់ចម្រើនវ័យរហូតមានការពេញវ័យ ។ លុះដល់អាយុ ៩ ឆ្នាំ ទ្រង់បានអានជាប់ទូវិសាស្ត្រ ៦ យ៉ាង និងទីវិទ្យាសាស្ត្រ ១៤ យ៉ាង ហើយមានប្រាជ្ញាវាងវៃជាបំផុត ។ កាលពេលនោះ ឆន្ទៈព្រះអាទិទេពក៏បានសម្រេច ។ ព្រះវរបិតា ព្រះវរមាតា ទ្រង់សោយព្រះទិព្វជន្មគត ។ ព្រះរាជបុត្រនោះទ្រង់បានឡើងសោយរាជសម្បត្តិ ទ្រង់បានគ្រប់គ្រងប្រជារាស្ត្រដោយយុត្តិធម៌ ។ ដល់ទ្រង់គ្រប់គ្រងរាជសម្បត្តិ បានពីរបីវស្សា ទ្រង់ព្រះតម្រិះថា: "អញកើតមកក្នុងលោកនេះ ដោយសារបិតាមាតារបស់អញ ។ តើអញបានប្រព្រឹត្តការណីយកិច្ចអ្វីចំពោះលោកអ្នកដ៏មានគុណទាំងពីរ, មានសុភាសិតមួយពោលថា: អ្នកណាដែលមានចិត្តសប្បុរសចំពោះអ្នកដទៃ អ្នកនោះជាបណ្ឌិត, ដល់ធ្លាមរណកាលទៅទទឹងទៅកើតឯស្ថានសួគ៌ ។ តែអ្នកណាមួយមានចិត្តមិនបរិសុទ្ធស្អាត, ធ្វើធុតង្គស្ទឹងស្មាធ៌, ឲ្យទានសូត្រធម៌សិក្សារៀនសៀវភៅពិសិដ្ឋមិនបានការ ។ ការណីយកិច្ចចំពោះវិញ្ញាណក្ខន្ធដែលស្លាប់បាត់បង់ទៅហើយ ធ្វើដោយគ្មានសទ្ធាមិនបានផល ហើយជីដូនជីតាយើងក៏មិនអាចសោយនូវផលនោះបាន" ។

ព្រះមហាក្សត្រិយ៍ទ្រង់ព្រះតម្រិះដូច្នោះហើយ ទើបមានព្រះបន្ទូលនឹងព្រះអគ្គឯងថា: "ការណីយកិច្ចរបស់អញ គឺការរៀបចំពិធីបុណ្យព្រះធាតុនៃព្រះវរបិតាព្រះវរមាតា ហើយនឹងធ្វើសក្ការបូជាចំពោះវិញ្ញាណក្ខន្ធរបស់លោកអ្នកដ៏មានគុណទាំងនេះ" ។

ទ្រង់ស្តេចយាងទៅកាន់គយា, ទ្រង់ក៏បួងសួងដល់ព្រះបរមនាមព្រះវរបិតាព្រះវរមាតា ហើយទ្រង់ចាំនវៀបចំសក្ការបូជា មានបិណ្ឌៈ (ពំនូតចាយឬមេម្សៅដែលគេយកទៅបូជាសព) នៅលើស្មឹងផល្គុ, ទ្រង់ចាំនតទៅឃើញដៃបីលើកចេញពីលើទឹក ។ ទ្រង់មានព្រះវិចិកិច្ឆា (ព្រះទ័យឆ្ងល់សង្ស័យ) ពន់ពេក ហើយទ្រង់មិនយល់ថា: បិណ្ឌៈនេះមិនដឹងជាបូជាទៅអ្នកណា ។

ដល់ពណ៌នាចប់ហើយ អាវ៌ក្សក៏ក្រាបទូលមហាភជថា: "បពិត្រមហាភជពិត្រម! តើបិណ្ឌៈនេះ ត្រូវបូជាទៅអ្នកណា?" ។ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលថា: "ត្រូវឲ្យទៅចោរ" ។

អាវ៌ក្សក្រាបទូលតបព្រះមហាក្សត្រិយ៍ថា: "ព្រោះហេតុអ្វី?" ។

ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលតបទៅវិញថា: "កិច្ចដែលព្រាហ្មណ៍បង្កើតទារកនោះ គេទិញរួចហើយ, មហាភជសុទក្សិចាន់ទទួលរូបិយមាសមួយពាន់ដើម្បីនឹងបីបាច់ថែរក្សាទារកនោះ ។ ព្រាហ្មណ៍នឹងមហាភជសុទក្សិមិនត្រូវបានបិណ្ឌៈនោះឡើយ" ។

អាវ៌ក្សបានស្តាប់នូវព្រះបន្ទូលព្រះបាទពិត្រម ក៏វិលត្រឡប់មកកាន់រូបជាតិវិញ ។ ព្រះមហាក្សត្រិយ៍ចង់អាវ៌ក្សនោះរួចទ្រង់លើលើព្រះអង្គាយកទៅ ។

ចប់ រឿងទី ១៨ នៅមានរឿងទី ១៩ តទៅទៀត

រឿងស្ងាប់ព្រោះជាតិ

មាន ៣ ឈុត

លោក គង់-លឹម និស្សិតសាលាគរុវិជ្ជា ភ្នំពេញ តែង

(ត-ចប់)

វណ្ណនារី

បងមិនខ្វាចថាបងទេ បងវាយលោកយាយ?

រាគី

ទេអូន! ត្រង់បុណ្យថាបលើកចោល ១ ពេលសិន! កុំឲ្យឆ្ងាប់ គ្រាន់តែម៉ាក់ឯងស្ងាប់ក្លាម គាត់រកបពន្ធឲ្យថ្មីក្លាម! ត្រង់ឯងទៅកំព្រាៗ ឯណោះម្តេចក៏គាត់មិនគិតផង ទៅគិតឯប៉ាដែលមានម្តងរួចទៅហើយ។ កុំមាត់អូន! ឮសូវតែមាត់ស្រែកចូលមកហើយ កុំមាត់ទៅឲ្យស្រួម។

ជាកទី ៤

រាគា-រាគី-វណ្ណនារី-តារា

រាគា

(ស្រែកនៅក្នុងឆាករួចចេញមកក្រៅ) អៃយ៉ូយ, កូនអើយ! គប់ប៉ាញ់ប៉ាហើយ! ចោរលួចប៉ាញ់ប៉ាហើយ! កូន! អៃយ៉ូយ!

រាគី

អ្វីប៉ា?

រាគា

គេលួចចាញ់ចា"ហើយកូន !

វិណ្ណានារី

ត្រូវត្រង់ណាលោកចា"? ត្រូវត្រង់ណា ?

រាគា

ចំដើមទ្រូងតែម្តង កូនអើយ ! អូយ !... ។

វិណ្ណានារី

យាយអើយ ! គេលួចចាញ់ចា"ខ្ញុំហើយ ។

រាគី

អូននៅមើលចា"ចុះ ទុកឲ្យបង្ដេញតាមអាចារកំណាច ។

វិណ្ណានារី

ឧ ! លោកចា"អើយ ! កម្មអ្វីក៏ក្រៃសម្លេះ ។

តារា

អ្វីកូន ! កូនមាសម្តាយ, ឧកូនអើយ ! ម្តាយកើតទុក្ខយ៉ាងធំទៀតហើយ ! ចុះអាណាហ៊ឹងក៏ចិត្តអ្វីធំសម្បើមម្ល៉េះ ម្តេចក៏មិនមាញកាំកូនចាញ់ឥតវិញ ។

រាគា

ខ្ញុំនឹកឃើញដែរអ្នកម្ចាស់, សេចក្តីសង្ស័យ ។ ប៉ុន្តែដោយខ្ញុំនឹកឃើញថាបើនឹងបាញ់តេវក់ ក៏ជាការឥតប្រយោជន៍ គឺគ្មានចង់បានថ្លៃដែរហើយ បានជាគ្នាខំមកប្លន់ជីវិតយ៉ាងដូច្នេះ ។

តារា

ចុះកូនគ្មានល់មុខអាទេ អាចារកំណាចនោះ!

រាគា

នៅមិនឆ្ងាយអំពីនេះប៉ុន្មានទេ បច្ចាមិត្តរបស់ខ្ញុំ កាលដែលខ្ញុំទៅប្រតិបត្តិការ ខ្ញុំបានប្រកែកប្រណាំងឈ្លោះគ្នានឹងសត្តិពីរម្នាក់ដែលជាអ្នកមានហ៊ានន្តវសត្តិស្មើនឹងខ្ញុំ ។ រួបគេនឹងខ្ញុំក៏ទាញគ្រឿងសស្ត្រាវុធប្រជែងតែនឹងធ្វើកិច្ចអាឃាតតែជោយខ្លួន ។ ប៉ុន្តែបានលោកវរសេនីយ៍ឯកលោកឃាត់មិនឲ្យខ្ញុំប្រព្រឹត្តអំពើអាក្រក់ដ៏ឈាមកនេះ ។ សេចក្តីគុំគួនរបស់សត្រូវខ្ញុំក៏ចេះតែមានជាប់រហូតមក ឯអ្នកមកប៉ងនឹងសម្លាប់ខ្ញុំនេះគឺជាកូនរបស់វ័ណ្ណ - ហ្គួននេះឯង ។

តារា

ឃើអាវ័ណ្ណ - ហ្គួន! អាវ័ណ្ណ - ហ្គួនមិនគួរចិត្តដល់ម្ល៉ឹងទេ! អាប្រើកូនរបស់អា ឲ្យមកបាញ់សម្លាប់កូនអញយ៉ាងដូច្នេះ អាឯងគង់មានថ្ងៃណា

មួយ អញធ្វើយាតកម្មតបអាវិញជាពុំខាន អាក្បត់ផែនដី! អាក្បត់ជាតិ! អាឯងគ្មានរួចពីកណ្តាប់ដៃរបស់អញទេ ។

រាគា

អ្នកម្តាយសូមអត់ទោសទៅចុះ! សូមអ្នកម្តាយកុំធ្វើអាឃាតតបនឹងសត្រូវដែលមកបំផ្លាញជីវិតរបស់ខ្ញុំនេះ ។ អ្នកកុំធ្វើឲ្យសោះ ជីវិតខ្ញុំមួយបើនឹងស្លាប់ទៅក៏មានប្រយោជន៍ដល់ប្រទេសជាតិ ក្នុងពេលពីមុនជាច្រើនណាស់ហើយ បើសិនណាខ្ញុំស្លាប់ នាមរបស់ខ្ញុំក៏មិនសាបសូន្យដែរ ស្លាប់ដោយសារប្រទេសជាតិប្រសើរណាស់អ្នកម្តាយ ក្តើរឈ្មោះមិនមែនអន្តរាយបាត់សាបសូន្យជួបជាអ្នកជាទៃទេ ។ ហេតុនេះអ្នកម្តាយ បើកាលណាខ្ញុំដាច់ខ្យល់ស្លាប់ទៅវេលាណា សូមអ្នកម្តាយកុំរកឿនហេតុនេះឲ្យសោះ សូមបំភ្លេចចោលតែម្តងទៅ កុំប្តឹងផ្តល់ធ្វើអ្វី គឺជាព្រៃងសំណាងរបស់ខ្ញុំ មានកុសលដ៏ល្អណាស់ដែលបានទទួលអកាលមរណៈយ៉ាងដូច្នេះ ។

ឆាកទី ៥

វន្ធី-រាគា-រាតី-វណ្ណនារី-តារា

វន្ធី

អើ! អាឯងបានការធ្វើហើយជាន់ហ្នឹង ធ្វើវាឲ្យដឹងចិត្តថាអ្នកវន្ធីម្តង! កុំឲ្យវាធ្វាប់ អាកូនរឹងរូស ។ ឯណា ទៅណាហើយ តារមិលំគុណនោះ!

អាឯងមិនរួចពីកណ្តាប់ដៃអញទេ ។ (ស្ទាំងកាំងដោយយើញកូនដេកស្លុត) នែ! វាអ្វីហ្នឹង! ចានជាដេកស្តឹងស្លុតយ៉ាងនេះ អាពគា! ។

វាគា

អ្នកម្តាយ! ចូរអ្នកម្តាយកុំកំយុងធ្វើអ្វីអំពីកិច្ចអាពាហ៍ពិពាហ៍របស់ខ្ញុំ, អ្នកម្តាយមិនចានអាម៉ាសមុខដោយសារខ្ញុំទេ ។ ចូរអ្នកម្តាយយករឿងព័ត៌ដែលអ្នកម្តាយចានយើញជាក់ទឹងក្នែកនេះ ទៅដំពបដន្ទឹងអ្នកម្តាយថ្មីទៅចុះ! ច្បាស់ជាគេមិនរករឿងហេតុទឹងអ្នកម្តាយទេ ហើយអ្នកម្តាយក៏មានសេចក្តីត្រែកអរក្នុងចិត្តដែរ! ពោលគឺអ្នកម្តាយមិនចានអាម៉ាសមុខដោយសារខ្ញុំទេ ។

វិធ្ជ

(ស្ទុះទៅអ្នកតាព) អ្នក! វាយ៉ាងដូចម្តេចហ្នឹង?

តារា

ចាសអ្នក! មិនគួរសោះ គ្រាន់តែកូនចេញទៅក្រៅ អើតកស្តោះទឹកមាត់ទៅពនហាល ១ ក្នែត ស្រាប់តែមានអាចោរកំណាចមិនដឹងជាមកពីណា មកលបចាប់កូនត្រូវចំដើមខ្ចែងតែម្តង ។

វិធ្ជ

(ភ័យ) កូនមាសម្តាយ។! កូនមុខតែស្លាប់ចោលម្តាយហើយ, កូនអើយកូន! យើចំជាពិចាកកន្ត្រឹងចិត្តខ្ញុំណាស់លោកអើយ! មនុស្សយើង

វាមានអាចិត្តអាក្រក់! អាចិត្តល្អ! អាចិត្តអន្ទៃយ! អាឈាមឆ្កៀ
អាហ្នឹងវាដេករកតែរឿងហេតុនឹងគេតែម្តង! យីចំហើយហ្ន៎! ហើយចុះ
កូនឯងស្គាល់មុខវាទេ? ។

វាគា

បើខ្ញុំកជាខ្ញុំស្គាល់មុខវា ក៏អ្នកម្តាយមិនត្រូវទៅរករឿងហេតុធ្វើអ្វីដែរ,
អ្នកម្តាយអកាលមរណៈរបស់ខ្ញុំយ៉ាងដូច្នេះប្រសើរណាស់! ចូរអ្នកម្តាយ
ចាំឲ្យប្អាស់ថានាមរបស់ខ្ញុំមិនសាបសូន្យទេ សេចក្តីមរណភាពដោយ
សារជាតិប្រសើរវិញ ។

វិដ្ឋី

មិនគួរសោះ! បើថាមនុស្សចិត្តអាក្រក់ទៅចុះគួរតែស្អប់! ចុះកូន
របស់ខ្ញុំជាមនុស្សមួយ អ្នកមានគុណដល់ផែនដីដែរ; បានធ្វើការកុង
កងទ័ពជើងគ្រមរក្សាប្រទេសជាតិតាំងតែពីអាយុ ១៨ ឆ្នាំ រៀងរហូតមក
ដាល់ឆ្នាំចាស់ប៉ុណ្ណោះហើយ (ចំនួនអាយុ ៤០ ឆ្នាំគត់) ជាន់ធ្វើការតស៊ូ
ដាល់តែមានថ្វីដៃ, ពជការតាំងផែនដីក៏ជាន់ស្គាល់កិរិយានឹងសមត្ថភាព
ដ៏ខ្ពស់ខ្ពស្តរបស់កូនខ្ញុំ, ជាន់ពាក់ស័ក្តិរៀងរហូតតាំងពីតូចដាល់តែឡើងធំៗ
ដាល់ដាប់, ជាន់ហានន្តរៈជាអនុសេនីយ៍ទោ ។ កូនខ្ញុំ ជាន់យកកម្លាំង
នឹងបញ្ជាទៅការពារកុងអាណាខេត្ត ជាន់សន្តិសុខធ្វើការឲ្យផលដល់
នគរប៉ុណ្ណឹងហើយ នៅតែមានមនុស្សអាក្រក់វាមិនពេញចិត្តវាទៀត,
វាច្រណែននិន្ទានឹងកូនខ្ញុំ នេះហៅជាចំហើយហ្ន៎! ។

ចំការមាធមិទៅកូន ! ម្តាយគ្មានអ្វីជាទីពឹងទេ, គ្មានអ្វីនឹងចែកឲ្យអ្នកបានទេ ក្នុងពេលនេះ, មានតែព្រះពុទ្ធព្រះធម្មិព្រះសង្ឃនេះហើយជាទីពឹង ។ ចំការនាទៅកូន ! ពុទ្ធោ អរហំ។ ។

រាគា

បាទអ្នកម្តាយ ! កូនឮទៅណាហើយ? ចូរចូលមកជិតប៉ាកូន ! ។

រាគី

(រត់ចូល) រត់រកមិនឃើញទេលោកប៉ា ! មិនដឹងជាវត់គេចទៅតាមផ្លូវណាទេ ! តាមផ្លូវមាត់ទន្លេក៏មិនដឹង តាមផ្លូវទៅភាមរក៏មិនដឹង ខ្ញុំរត់ស្ទាត់រកពាំងអស់ រកមិនឃើញ ។

រាគា

ចុះអញមានប្រើឯងឯណា ឯងចេះតែរត់រកតាមអំពើចិត្តឯងទេតើ ។ កូនឯងយកកូនសោនេះទៅចាក់ទ្វារយកសៀវភៅពាំងពីរ ដែលអញដាក់នៅលើដើងពានមក ។

រាគី

សៀវភៅហ្នឹងឬលោកប៉ា?

រាគា

វណ្ណនារី កូន ! កុំយំធ្វើអ្វី ធ្វើម្តេចកម្មវបស់ឯង ទុតុកទឹកស្មានថាទឹងបានទំនុកបំរុងអ្នកឲ្យរៀនសូត្របានដោយបរិបូណ៌ ប៉ុន្តែធ្វើម្តេចឥឡូវ

ច្រើជាផ្លូវអក្សរសាស្ត្រ, គឺតាមផ្លូវអក្សរសាស្ត្រនេះហើយកូន! ដែលអាចលើកតម្កើងកម្ពុជរដ្ឋឲ្យថ្កុំថ្កើងទៅថ្ងៃក្រោយ ។ កូន! បើកាលណាបឋមឆ្នាំជាប់សញ្ញាប័ត្រហើយ ចូរកូនទៅរៀនតំណែងខាងមុខទៀតនៅសាលាគរុវិជ្ជាកុំពេញ ដើម្បីនឹងបញ្ជាក់អំពីចំណេះរបស់កូន. ត្រូវកូនរៀនឲ្យជាប់ថ្នាក់ ចានហានៈដ៏ខ្ពង់ខ្ពស់កងក្រសួងសិក្សាធិការ, បឋមឲ្យចានហានៈជាសាស្ត្រាចារ្យចាំឈប់កូន! ។

កូនមាសឪពុកខាងពីរ! ចូរកូនកុំភ្លេចបណ្តាំឪពុកឲ្យសោះ ត្រូវកូនចារទុកក្នុងវិញ្ញាណរបស់កូនឲ្យជាប់. សំដីរបស់ឪពុកឆាំងប៉ុន្មានម៉ាត់នេះ ។

ឪពុកមុខជានឹងទទួលសេចក្តីអញ្ជើញនៃមច្ចុរាជហើយ ។ បុគ្គលកងដើមទ្រូងណាស់កូន! ។

វិណ្ណាវី

ចាសលោកប៉ា! កូននឹងទទួលចាំឲ្យជាប់នៅកងចិត្តកូនមិនឲ្យភ្លេចទេសេចក្តីប្រៀនប្រដៅរបស់លោកប៉ា ។

រាគា

អ្នកម្តាយ! អ្នកមានគុណខាងពីរ ចូរអ្នកម្តាយអាណិតខ្ញុំជួយចិញ្ចឹមកូនខ្ញុំខាងពីរនេះផង ទំនុកបំរុងឲ្យរៀនសូត្រឲ្យបានពេញបរិបូណ៌ ច្រើក

អាយុនឹពុកដល់ហើយ ។ កូន! កូនប្រុស! កូនស្រីមាសនឹពុក! នឹពុក
គ្មានអ្វីជារបស់មានដង្ហែនឹងបែកឲ្យកូនទេ មានតែសៀវភៅទាំងពីរនេះ
ហើយ ។ រាល់កូន! នឹពុកទុកក្តីសៀវភៅនេះឲ្យឯង សៀវភៅទាំង
សឹកសង្គ្រាមជ័យ ចូរកូនយកទៅរៀនចុះ ។ អំណើះឥតពីនឹពុកទៅ
ពេលណា ដល់ពេលប្រឡងឌីប្លូមហើយ ត្រូវកូនប្រឡងចូលសាលា
យុទ្ធនាធិការខេមរភូមិន្ទ ១ រំពេច ដើម្បីនឹងរៀនចំណេះវិជ្ជាទាំងពលិកម្ម
ដើម្បីនឹងធ្វើការបំរើប្រទេសជាតិដោយផ្លូវសឹកសង្គ្រាម ។ កុំខ្វាចស្ងាប់
កូន! បើអ្នកបានស្ងាប់ ដូចនឹពុកយ៉ាងដូច្នេះប្រសើរណាស់ ។ បើសិន
ណាជាកូនបានទទួលសេចក្តីមរណភាព នៅលើទឹសមរភូមិនោះ ត្រៃង
សំណាងរបស់កូនក៏ធំវិតតែវិសេសណាស់ សង្ឃឹមដល់នគរកុំខ្វាច
ស្ងាប់ ស្ងាប់ត្រាមទង់ជាតិកម្ពុជាប្រសើរណាស់ ។

រាគី

ជាទសោកប៉ា! ខ្ញុំជាទសូមជានាសច្ចាថានឹងទទួលប្រតិបត្តិតាម
គន្ធង់ធម៌ដ៏ល្អប្រពៃនេះ សូមលោកប៉ាជឿជាក់ថា ប្រសាសន៍លោកប៉ា
ទាំងប៉ុន្មាននេះខ្ញុំទទួលថែរក្សាទុកមិនឲ្យក្ងេច ។

រាគា

វណ្ណ-នារីកូនស្រីប៉ា! ចូរកូនទទួលយកសៀវភៅនេះ គឺជាសៀវភៅ
ច្បាប់សម្រាប់ធ្វើជាអ្នកគ្រូ, កូនត្រូវបំរើប្រទេសជាតិដោយកំលាំងចិត្តនឹង

៥០ ម៉ឺនរៀលនេះ ដែលកូនបានសន្យាទុក ចូរអ្នកម្តាយទុកលៃលកគ្រាន់តែចំណាយឲ្យកូនខ្ញុំតាំងពីរនេះ រៀនសូត្រឲ្យបានជាសិរី បើចាយប្រាក់នេះអស់ហើយ កេរមតិករបស់ខ្ញុំតាំងប៉ុន្មាន ត្រូវអ្នកម្តាយដំទុំគាល់ទៅចុះ! ដើម្បីនឹងយកប្រាក់មកចិញ្ចឹមកូនសំឡាញ់របស់ខ្ញុំតាំងពីរនេះ ដើម្បីនឹងធ្វើការបំរើប្រទេសជាតិទៅអនាគត ។

ខ្ញុំសូមខមាទោសចំពោះអ្នកម្តាយតាំងពីរ លើកិច្ចការណ៍ណាដែលខ្ញុំបានប្រព្រឹត្តក្តួនឆ្គងនឹងអ្នកម្តាយ សូមកុំឲ្យខ្ញុំមានវេរាជាបរៀរ ។

(រាំងនឹងធ្លាក់)

(ខ្មោចនេះ ត្រូវគ្រប់ដោយទង់ជាតិខ្មែរ)

ចប់

គ្រង់គ្រងល្អ តាំងឲ្យបំរើង

គ្រប់គ្រងអាក្រក់ តាំងឲ្យវិនាស

ការគ្រប់គ្រងប្រជាជនតាំងឡាយដោយល្អ ជាមធ្យោបាយដ៏ប្រសើរដែលនាំទៅកាន់ឃ្លាំងគឺស្ថានសួគ៌, ការសង្កត់សង្កិនប្រជាជនខ្លាំង ជាផ្លូវនាំឲ្យវិនាស សេចក្តីចំរើន ឲ្យកើតសេចក្តីអាក្រក់ទឹងការអត់ឃ្លាន ។

បញ្ជូតន្ត្រៈ

រឿងចចៀនធំៗ

អ្នកស្រីសារីយ៉ាន់ ប្រែពីបារាំងមកជាខ្មែរ

មានន័ទានថា កាលពីព្រេងនាយ មានព្រះមហាក្សត្រិយ៍មួយព្រះអង្គគ្រងទ្បីបតាំងមូល ទ្រង់ប្រកបដោយគុណធម៌ដ៏ប្រពៃ ទ្រង់ជំនុំដំរះក្តីដោយសុចរិត ហើយទ្រង់បង្ហាញសមភាពចំពោះមហាជនតាំងមូល ។ ក្នុងសម័យរាត្រីមួយ ពេលដែលទ្រង់កំពុងផ្ទំលក់ ទ្រង់សុបិននិមិត្តថា "មានទៅតាមកថ្វែងប្រាប់ទ្រង់ថា: នុ! ព្រះមហាក្សត្រអើយ! សូមទ្រង់តើនឡើងគង់សេះឆាប់នេះ ទ្រង់ស្តេចឆ្ពោះទៅកន្លែងមួយដែលនៅក្នុងច្រកភ្នំ ហើយនៅទីណាដែលដើងសេះផុងចុះទៅក្នុងដី សូមទ្រង់ជីកដីត្រង់កន្លែងនោះ ទ្រង់នឹងប្រទះឃើញគំរបមួយ លុះទ្រង់បើកគំរបនោះទៅ ទ្រង់នឹងឃើញជណ្តើរមួយវែងចុះទៅក្រោម ដែលមានជល់ទៅ ៣០០ កាំ សូមទ្រង់យាងចុះតាមជណ្តើរនេះដោយតមកុំពោលវាចាអ្វីឲ្យសោះគាល់តែជល់ទៅក្រោម ទៅចុងចំផុតទ្រង់នឹងឃើញទ្វារមួយទៀតដែលមានកូនសោជាប់នៅនោះ ទ្រង់យកកូនសោបើកទ្វារនោះទៅដោយស្ងៀមស្ងាត់ ទ្រង់នឹងឃើញកំណប់មួយដ៏ស្តុកស្តម្ភ មានរូបលង់ហិនមួយនៅរក្សា រូបនោះនឹងស្រែកគំរាមទ្រង់, ប៉ុន្តែសូមទ្រង់កុំខ្លាចកុំតក់ស្លុតឲ្យសោះ លុះទ្រង់ចូលទៅជិត ទ្រង់នឹងឃើញចិញ្ចៀនមួយនូវដៃរូបលង់ហិននោះ ទ្រង់យកចិញ្ចៀននោះមក, លុះទ្រង់យកចិញ្ចៀនបានវេលាណា

រូបលង់ហិនទឹងអស់អំណាចលើខ្ញុំដៅវេលានេះ; ចិញ្ចៀននេះប្រកបដោយលក្ខណៈ ៣ យ៉ាងគឺកាលណាខ្ញុំបៀមកងព្រះទន្ត ខ្ញុំនឹងអាចបំបាំងព្រះអង្គបាត់, កាលណាខ្ញុំដាក់ចិញ្ចៀននោះទៅលើដី បំរើរបស់ចិញ្ចៀននឹងបង្ហាញខ្លួនឲ្យខ្ញុំឃើញ ហើយវានឹងធ្វើតាមបង្គាប់ខ្ញុំគ្រប់យ៉ាង, បើខ្ញុំពាក់ចិញ្ចៀននោះជាប់នៅព្រះហស្ត គ្មាននរណានឹងមកបៀតបៀនខ្ញុំបានឡើយ" ។

ព្រះរាជាខ្ញុំតើនឡើងហើយការនាធមិថា "ខ្ញុំសូមឲ្យព្រះជាម្ចាស់ជួយថែរក្សាខ្ញុំកុំឲ្យអារក្សសាតន៍មកបៀតបៀនបាន" ។ ប៉ុន្តែដឹងជាអារក្សសាតន៍ ឬព្រះដ៏មានព្រះហឫទ័យសប្បុរស ដែលធ្វើឲ្យទំមិត្តឃើញដូច្នេះ? ខ្ញុំតើនឡើងស្រប់ព្រះភ័ក្ត្រ ខ្ញុំសូត្រធម៌ថ្វាយបង្គំហើយនឹកគុណព្រះមានបុណ្យសូមលោកជួយកុំឲ្យអារក្សសាតន៍មកបៀតបៀនខ្ញុំបាន រួចខ្ញុំក៏ផ្ទំទៅវិញ ។

នៅកងពេលដែលខ្ញុំកំពុងផ្ទំលក់ ទេវតាមកពន្យល់សប្តិខ្ញុំថា: "តើនឡើងសូមខ្ញុំគង់សេះចានេះទៅកន្លែងនុ៎ះ លុះសេះផុងដើងទៅកន្លែងណា សូមខ្ញុំដីកដីកន្លែងនោះ ខ្ញុំនឹងឃើញគំរបមួយ សូមខ្ញុំបើកគំរបនោះឡើងហើយធ្វើយ៉ាងនេះ។ ដូចដែលបានបង្គាប់ពីកាលដំបូង" ។ ព្រះរាជាខ្ញុំតើនឡើងដោយរីករាយខ្ញុំស្រប់ព្រះភ័ក្ត្រ សូត្រធម៌ហើយថ្វាយបង្គំពីរដង ខ្ញុំសរសើរដល់គុណរបស់ព្រះជាម្ចាស់ហើយក៏ផ្ទំទៅវិញ ។

ព្រះពាជាទ្រង់សុបិននិមិត្តជាគំរប់បីដង ដូចកាលពីរដងដំបូងទៀត ទ្រង់តើនឡើងហើយទ្រង់រំពឹងគិតថា: "ការយល់សុបិននិមិត្តនេះ ប្រាកដជាបណ្តាលមកអំពីព្រះដ៏មានព្រះហឫទ័យសប្បុរស ពុំមែនមកពីអារក្សសាតន៍ទេ" ។ ទ្រង់ក្រោកឡើងពីក្បាច់ទូលស្រប់ព្រះភ័ក្ត្រហើយទ្រង់តាវ៉ាធមិលុះដល់ភ្លឺ ។ កាលនោះទ្រង់បង្គាប់ឲ្យរៀបក្បួនសេនាតាហាន ហើយត្រាស់បង្គាប់ឲ្យគេរកសេះប៉ាដែលទេពនិមិត្តបង្គាប់ឲ្យយក ។ គេក៏នាំសេះនោះមកថ្វាយទ្រង់ ។

ព្រះពាជាទ្រង់ឡើងគង់សេះឆ្ពោះទៅកន្លែងដែលទេពនិមិត្តបង្ហាញជាមួយនឹងព្រះពជបុត្រាបីព្រះអង្គដែលព្រះជាម្ចាស់ថ្វាយជាវង្វាន់ដល់ទ្រង់ ។ លុះមកដល់ទីក្នុង ព្រះពាជាទ្រង់បំផាយសេះសំដៅទៅកន្លែងនោះបន្តិចស្រាប់តែដើងសេះជុងទៅកងដី ទ្រង់លោតពីលើសេះចុះមក ។ លុះសេនាតាហានមកដួបជុំគ្នាណា ទ្រង់ក៏ត្រាស់បង្គាប់ឲ្យដកដើងសេះហើយដីកដីនៅកន្លែងនោះក្រាម ។ សេនាទាំងឡាយក៏ធ្វើតាមព្រះពាជបញ្ជា លុះដីកជ្រៅបន្តិចទៅក៏ប្រទះឃើញគំរបមួយ សេនាក៏ទូលព្រះមហាក្សត្រថា: "ព្រះករុណាជាម្ចាស់ យើងខ្ញុំបានឃើញគំរបមួយនៅទីនោះ" ។ ព្រះពាជាទ្រង់ព្រះសន្តាប់ហើយក៏បង្គាប់ឲ្យជំឡើងព្រះពន្ធារនៅទីនោះ ទើបទ្រង់បង្គាប់ឲ្យបើកគំរបឡើង ។ នៅក្រោមគំរបនោះមានកាំជណ្តើរ ១ វែង ។ ព្រះពាជាចង់យាងចុះទៅហើយ ប៉ុន្តែពួកសេនា

ទាហាននឹងមន្ត្រីតូចធំ ចូលទៅគ្រាបអង្វរទ្រង់ថា: "សូមព្រះករុណាជា អម្ចាស់ដ៏វិតលើត្បូង កុំទ្រង់ចុះធ្វើអ្វី ទូលព្រះបង្គំជាខ្ញុំពាល់គ្មានឹងចុះទៅ ជំនួស" ។ ប៉ុន្តែព្រះមហាក្សត្រមានព្រះបន្ទូលថា: "គ្មាននរណាដទៃ ទៀតត្រូវចុះ ក្រៅអំពីអញទេ" ។ ក្រោយនោះ ព្រះពាជបុត្រាច្បង ឹងបន្ទាប់ពីព្រះអង្គស្ទុះចូលទៅអង្វរទ្រង់ទៀតថា: "ព្រះបិតា! ទូល ព្រះបង្គំជាខ្ញុំគាំងពីរនាក់ឹងចុះជំនួសព្រះអង្គ" ។ ប៉ុន្តែព្រះពាជានៅតែ ឆ្លើយថា: "គ្មាននរណាដទៃត្រូវចុះទេ ក្រៅពីអញ" ។ នៅខណៈ នោះ ព្រះពាជបុត្រាពៅបង្អស់ព្រះនាម អាលី-ត្នេលេប៊ី រត់មកដិតព្រះ អង្គហើយទូលទ្រង់ថា: "ព្រះបិតា! ទុកឲ្យទូលព្រះបង្គំចុះជំនួសព្រះអង្គ បើការណាទូលព្រះបង្គំស្លាប់ ទុកដូចជាទូលព្រះបង្គំនៅរស់ ទូលព្រះ បង្គំនឹងនិយាយរឿងរ៉ាវទូលព្រះបិតាតាមដែលទូលព្រះបង្គំជ្រាបឃើញ" ។ ប៉ុន្តែព្រះមហាក្សត្រមានព្រះបន្ទូលថា: "កូនសំឡាញ់! ចូរឯងទៅ អង្គុយនៅកន្លែងឯងវិញទៅ គ្មាននរណាត្រូវចុះទៅក្នុងនោះ ក្រៅអំពី អញឡើយ" ។

ការចេះសរបស់ព្រះអង្គធ្វើឲ្យអាលី-ត្នេលេប៊ី កើតទុក្ខជាខ្លាំងហើយ ទៅអង្គុយយំនៅកន្លែងខ្លួនវិញ ។

ព្រះមហាក្សត្រទ្រង់យាងចុះតាមដណ្តើរនោះ លុះតែផុត ៣០០ កាំ ព្រះអង្គទ្រង់ឃើញទ្វារមួយធំអស្ចារ្យ ហើយមានកូនសោមួយយ៉ាងធំជាប់

នៅនោះ ខ្ញុំចាប់យកកូនសោនោះមក ហើយនឹកព្រះនាមព្រះជាម្ចាស់យ៉ាងខ្លាំងៗ ព្រមទាំងសូមឲ្យលោកជួយរក្សាខ្ញុំផង ទើបខ្ញុំបើកទ្វារចូលទៅ ខ្ញុំឃើញរូបលង់ហិនមួយយ៉ាងធំសំបើម, នៅពេលដែលខ្ញុំយាងដំរង់ចូលទៅជិត រូបនោះបញ្ចេញសម្លែកមួយយ៉ាងគួរឲ្យខ្លាចអស់ទាំងក្នុងនឹកមកស្តេចវិញ ប៉ុន្តែខ្ញុំចេះតែចូលទៅជិតហើយហូតយកចិញ្ចៀនពីម្រាមដៃមក ។ លុះចិញ្ចៀនបានមកព្រះមហាក្សត្រគ្រាលណា រូបនោះក៏អស់អំណាចទៅ ហើយដួលស្លាប់នៅដដែ ។ ព្រះពាខ្ញុំទស្សនាអស់សម្បត្តិនៅក្នុងទីនោះ ឃើញមានត្បូងមុត្តា, ប្រាក់ទឹងមាសច្រើនជាពន្លឹក ខ្ញុំទឹកចង់ដឹងនូវលក្ខណៈចិញ្ចៀននោះ ហើយក៏ខ្ញុំដាក់ផ្ទាល់ទៅនឹងដ ។

ក្នុងមួយរំពេចនោះ ស្រាប់តែមានអមនុស្សម្នាក់ឈរជ្រៅនៅមុខព្រះអង្គហើយពោលថា: "ទូលព្រះបង្គំជាខ្ញុំ មកជាបំរើព្រះករុណាជាម្ចាស់ជីវិតលើត្បូង, ព្រះអង្គខ្ញុំតំអក់ទឹងប្រើរបស់ដែលគេថ្វាយព្រះអង្គណាស់" ។ ព្រះមហាក្សត្រខ្ញុំមានព្រះបន្ទូលសួរថា "ឯងជាអ្វី? ឯងឈ្មោះអ្វី? ឯងធ្វើអ្វី?" ។

- ទូលព្រះបង្គំជាខ្ញុំបំរើនៃចិញ្ចៀននេះ ទូលព្រះបង្គំជាខ្ញុំឈ្មោះម៉ែមូនដែលមានកុលសម្ព័ន្ធដល់ទៅ ៧០ នៅត្រកាមបង្អាប់ ទូលព្រះបង្គំមានការៈទឹងទទួលធ្វើតាមព្រះពាជបញ្ជាព្រះអង្គទាំងអស់ ។ (មានត)

លោកផែង-ជ្រៃ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តមក)

– យីប្រទេសនុះបអីចេះ? បើដូច្នេះ ត្រូវឲ្យវីរ៉ស៊ីនី ត្រឡប់មកស្រុកនេះវិញ ។ ប្រយោជន៍អ្វីនឹងញាតិមានសម្បត្តិ ពីដើមនៅក្នុងខ្លួមនេះ សប្បាយចិត្តសឹងស្ងាប់ស្អាតអស់ពីចិត្ត កាលណាយកកូនតន្ទែងត្រហម ឬយកផ្កាមកសៀតជោតរុំជុំវិញក្បាល, ចូរត្រឡប់មកវិញ វីរ៉ស៊ីនី! ចូរចុះចោលចេញពីប្រាសាទនឹងស័ក្តិយសនោះទៅ ។ ចូរត្រឡប់មកកាន់ទីក្នុងនេះវិញ មកលេងក្រែមម្ទប់ឈើទាំងឡាយ មកលេងក្រែមដើមដូងយើងវិញ តឡូវអ្នកប្រហែលមានទុក្ខព្រួយខ្លាំងណាស់ហើយមើលទៅ ។ រួចហើយអាប៉ូលតាំងទ្រហោយំ ។

– "នលោកឪពុក! សូមលោកមេត្តាកុំលាក់ទឹងខ្ញុំឲ្យសោះ សូមប្រាប់ខ្ញុំឲ្យត្រង់មកមើល តើខ្ញុំនឹងបានវីរ៉ស៊ីនី ជាប្រពន្ធឬទេ? ដោយហោចទៅ សូមឲ្យខ្ញុំដឹងតែប៉ុណ្ណោះចុះ ថានាងនៅស្រឡាញ់ខ្ញុំដូចដើមដែរឬអី? ដែលនាងបានទៅនៅកណ្តាលពួកនាហ្នឹងធំៗ ទាំងឡាយសុទ្ធតែនៅដឹតស្តួច ហើយដែលនៅលេងនឹងនាងជាធម្មតា ។

— នែសំឡាញ់ ! អញហ៊ានសន្យាថានាងទៀងតែនៅស្រឡាញ់ឯង ដោយហេតុច្រើនប្រការណាស់ ហើយបើសង្កេតឲ្យដាច់ស្រែចទៅ គឺព្រោះនាងមានចិត្តធម៌កន្ទុយ ។

គ្មានតែពួកសំដីប៉ុណ្ណោះ អាប៉ូលហាក់មកនុបកខ្ញុំ សប្បាយចិត្តពេក ហាក់ដូចអណ្តែតខ្ទុងឡើងខ្ពស់អាកាស ។

— "លោកនុពុកជឿថាស្រីតាំងឡាយនៅនុប ខ្លួចកាចដូចជាក្នុងរឿងល្ខោន នឹងរឿងកងគម្ពីរដែលលោកនុពុកឲ្យខ្ញុំអានដែរឬ? ។

— ស្រីដែលខ្លួចកាចមានច្រើនតែក្នុងប្រទេសណាដែលពួកប្រុស។ ច្រើនសុទ្ធតែមនុស្សមុខ្លោ ។ ការកំហែងនាំឲ្យកើតល្បិចចេះបញ្ឆោត ។

— យ៉ាងដូចម្តេចដែលគេហៅថាចិត្តមុខ្លោនឹងស្រី? ។

— កាលណាគេរៀបចំកូនឲ្យមានផ្ទះសំបែង ហើយមិនស្ងួរចិត្តអ្នកតាំងសងខាង : ដូចស្ត្រីក្រែមុំនឹងតាចាស់ ស្ត្រីអ្នកជិងការខ្មុសត្រូវជាមួយនឹងប្រុសទីងមោង ។

— ចុះហេតុអ្វីក៏គេមិនរៀបការក្មេងនឹងក្មេង ស្រឡាញ់នឹងគ្នា? ។

— ព្រោះទៅប្រទេសបាកាំង ពួកកំឡោះមិនសូវមានធនធានល្មមនឹងរៀបការ ។ លុះខ្ទុងចាស់កាលណាទើបសន្សំទ្រព្យបានច្រើន ។ កាលនៅកំឡោះ គេទៅខ្លួចកាចនឹងស្រីអ្នកជិតខាង ដល់វេលាចាស់ ក៏ឈប់ស្រឡាញ់ស្រីកំណាន់នោះទៅ ។ គេបំភាន់ស្រីក្មេងបែបយ៉ាងដូច្នេះមិន

ដឹងអស់ចំនួនប៉ុន្មាន គេក៏ត្រឡប់បំភាន់ទៅវិញ មិនដឹងអស់ថាអស់ប៉ុន្មានដែរ ។ រឿងនេះគឺជាកិច្ចនៃធម៌ សម្រាប់លោកដែលគេប្រើត្រួតមនុស្សពាំងមួល អ្នកល្អថ្នឹងគូនឹងអ្នកល្អ អ្នកអាក្រក់ថ្នឹងគូនឹងអ្នកអាក្រក់ ។ ពួកមនុស្សនៅតុបច្រែនប្រែលម្ងំជាខ្មោគដ៏សាញ៉ាំដូច្នោះ រឿងនេះកើតមានកាន់តែច្រែនឡើង ក្នុងបណ្តាមហាជនត្រាតែធនធានទៅតរនៅលើតែជនប៉ុន្មានរូប ទំនងនេះប្រហែលគ្នានឹងសួនច្បារ ដែលកូនឈើពាំងឡាយអាចដុះបាន លុះណាតែឈើធំៗ ជួយការពារនឹងកំដៅព្រះអាទិត្យតែមានសេចក្តីថ្កែកគ្នាបន្តិច, លំអសួនច្បារកើតមកតែពីដើមរុក្ខជាតិពីរ - បីដើម ចំណែកស្រុកទេសចំរើនរុងរឿងឡើងដោយសារមានភស្តុច្រែនហើយមានចិត្តស្មើគ្នា មិនមែនមកពីអ្នកមានសម្បត្តិច្រែនបីបួននាក់នោះឡើយ ។

- បើឯងចង់រៀបការ ចាំបាច់ត្រូវការឲ្យមានសម្បត្តិច្រែនធ្វើអ្វី? ។
- ដើម្បីដេកស៊ីស្រណុកក្នុងថ្ងៃណាដែលយើងមិនធ្វើការអ្វី ។
- ចុះហេតុអីក៏មិនធ្វើការ? បើខ្ញុំធ្វើការសព្វថ្ងៃស្លឹងស្ងាប់ ។
- ដ្បិតនៅតុប ហត្ថកម្មថោកឥតបានសំណង គេហៅថាអបញ្ញកម្ម ។

ការក្លែងក្លាយនេះឯងហើយជាការគិតមើលងាយជាងគេបំផុត ។ អ្នកដំនាងថ្ងៃថ្ងូរជាងអ្នកស្រែ ។

អាប៊ូលលាន់មាត់ថា យើ! អីនៅតុប គេមើលងាយកិច្ចការដែលចិញ្ចឹមជីវិតរបស់មនុស្ស, លោកឯតុកមានប្រសាសន៍យ៉ាងហ្នឹង ខ្ញុំមិនទាន់យល់សោះ ។

តាថាស់-ឧកូន! ខ្ញុំនឹកដែលកើតមកហើយនៅតែក្មេងនៃ អ្នកមិនងាយយល់ការណ៍ប្រែប្រួលផ្លេសផ្លាសនៃលោកិយឡើយ គេចេះរៀបចំគំនិតមានយោនឲ្យត្រឹមត្រូវ មានរបៀប មិនមែនឲ្យសាំញ៉ាំទេ ។ លំអាងក្នុង ចិត្តសប្បុរស សេចក្តីសុខស្រួល សុទ្ធតែមានចំណែកដោយខ្លួនតាមថ្នាក់, ការអាក្រក់នៃកាយវាចាក្រៅ សេចក្តីអាក្រក់នឹងសេចក្តីទុក្ខព្រួយមិនមានចំណែកតាមថ្នាក់ឡើយ ។

- អ្នកមានខ្លៅ សប្បាយណាស់ មើលទៅ! ព្រោះគ្មានអ្វីជាទំនប់ដល់ចិត្តចង់ ។ ចិត្តដែលត្រូវការត្រង់ណា អាចធ្វើបានត្រង់នោះដោយរីករាយ ។

- មានសេចក្តីរីករាយខ្លះ គេបានមកមិនបាច់អស់លុយការក៏ម៉ាន ។ ឯងមិនដែលដឹងទេ ដូចជាសេចក្តីសុខស្រួលនៃការសម្អាត .មកពីមានកំឡាំង, ស៊ីឆ្ងាញ់មកពីឃ្លាន, ផឹកបានមកពីស្រេក, សេចក្តីសប្បាយកើតឡើងពីចិត្តស្រឡាញ់ នឹងកើតឡើងព្រោះមានគេស្រឡាញ់ខ្លួន ករណីនេះក៏មកតែពីអត់យូរពេកនឹងស៊ូប្រជិតៗ ។ អ្នកមានខ្លៅដែលធ្លាស់ចាកសេចក្តីសុខទាំងនោះ មកពីមានការប្រយ័ត្នដល់សេចក្តីត្រូវការទៅ

អនាគត ។ សេចក្តីអផ្សុកធុញទ្រាន់មកពីឆ្អែតពេក ការឆ្អែនឆ្អមមកពីមានធនធានច្រើនហើយអត់អ្វីបន្តិចមិនបាន រហូតដល់ការសប្បាយធំក៏គេមិនពេញចិត្តដែរ ។ ផ្ការីកបានមួយពាន់ត្រអូបស្រួលបានតែមួយខណៈ ចំណែកបន្ទាប់ក៏ឡើងវិញតែមួយ បើមុតឈឺចាប់ណាស់ ។ សេចក្តីទុក្ខតែមួយកើតមានឡើងនៅកណ្តាលនៃសេចក្តីសប្បាយរីករាយ នៃពួកអ្នកមានទ្រព្យ ដូចជាបន្ទាមួយនៅកណ្តាលនៃផ្កាកូឡាបចាំងឡាយ ។ ចំណែកអ្នកឧត្តរវិញ មិនដូច្នោះឡើយ សេចក្តីរីករាយតែមួយកើតឡើងនៅកណ្តាលនៃសេចក្តីទុក្ខចាំងឡាយ ដូចជាផ្កាមួយនៅកណ្តាលនៃបន្ទាចាំងឡាយ, គេស្វាយសេចក្តីសប្បាយរីករាយនោះដោយចិត្តក្លាហាន ។ រឿងនេះបានជាមានលេចឡើងខ្លាំងដោយសារការផ្ទុយគ្នា ។ ធម្មតាលោកបានឋឹងហើយជាស្រេច ។ ភាពមួយជារបស់នៃអ្នកមានទ្រព្យ ភាពបន្ទាប់ជារបស់នៃអ្នកឧត្តរ ។ តែក៏ភាពទាំងពីរនេះ មនុស្សសុទ្ធតែភ្ញាក់ផ្អើមិនងាយទប់ទល់បាន ព្រោះសេចក្តីសុខស្រួល សំដៅយកតែងការជាទុបេក្ខានឹងមានចិត្តធម៌ ។

– ចុះយ៉ាងដូចម្តេចហៅ ចិត្តធម៌?

– នែកូន! អ្នកខំធ្វើការដើម្បីចិញ្ចឹមម្តាយនឹងញាតិ ហើយមិនត្រូវការចង់ឲ្យអ្នកណាដឹង អ្នកណាសរសើរទេ ។ ចិត្តធម៌គឺជាកម្លាំងមួយកើតឡើងដោយញាណសម្បយុត្តអសង្ខារិក ដើម្បីបំពេញកិច្ចជាកុសលដល់អ្នកដទៃ ដោយចង់ឲ្យត្រូវនឹងព្រះជាម្ចាស់តែម្យ៉ាង ។ (មានត)

សេចក្តីកាន់នៃក្រុមជំនុំនៃព្រះពុទ្ធសាសនាខ្មែរ

លោក ជាប - ពិត ថ្លែងជាកិត្តិយុ ប្រទេសកម្ពុជា

ពីថ្ងៃទី ២៨ - ២ - ៥៣ ព.ស. ២៤៩៥

ធ្វើឱ្យបេញ្ញពីពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

អស់លោកគាំង ឡាយ !

ក្នុងសាសនេះ ខ្ញុំបាទតាង នាមពុទ្ធសាសនបណ្ឌិត្យ បានកិត្តិយសមក បរិយាយអំពីបុណ្យមាឃបូជា តាមអត្ថបទដែលព្រះតេជព្រះគុណ ព្រះ ញាណគោសលញ្ញាណ ឈឹន ក្រុមជំនុំព្រះវិនៃបិដក រៀបរៀង ជូនជាប្រជាប់សតិបញ្ញាការចេះដឹងរបស់ពុទ្ធបរិស័ទតទៅ :-

អស់លោកគាំង ឡាយបានជ្រាបហើយថា ថ្ងៃ១៥កើត ខែមាឃ ជាថ្ងៃនក្ខត្តឫក្សធំដែលជាបវេណីមួយរបស់ព្រះពុទ្ធសាសនា សម្រាប់ ពុទ្ធបរិស័ទធ្វើពុទ្ធបូជា ហើយជាថ្ងៃបុណ្យ ដែលកម្ពុជរដ្ឋបានតាក់តុកជា បវេណីរបស់ប្រទេស សម្រាប់ប្រជាជនខ្មែរជាតិធ្វើសក្ការបូជា តាំងពី បុរាណកាល, ព្រះពជរដ្ឋាភិបាលយើង តាំងពីរដ្ឋកាលព្រះករុណា ព្រះ បាទសម្តេចព្រះស៊ីសុវត្ថិ - មុនីវង្ស មក ក៏បានសង្គ្រោះចូលជាថ្ងៃបុណ្យ តាមផ្លូវការដូចបុណ្យតាំងពួន ។

ដោយថ្ងៃពេញបូណ៌ ខែមាឃ ជាថ្ងៃនក្ខត្តឫក្សធំនក្ខត្តមមួយសម្រាប់ កម្ពុជរដ្ឋដូចរៀបរាប់មកហើយ បានជាតែដល់ថ្ងៃនេះកាលណាតែងឃើញ

បណ្តាពុទ្ធបរិស័ទជាតិខ្មែរយើងទាំងគ្រហស្ថទាំងបព្វជិត បញ្ជប់ការបលិពោធនាំគ្នាធ្វើពុទ្ធបូជាតែរៀងខ្លួន ។ ឧបាសក ឧបាសិកា គ្រប់ភូមិស្រុកសឹងស្ទើរតែពាក់ស្អាតជាត នាំគ្នាកាន់គ្រឿងសក្ការៈដើរជាពួកជាកង ចូលទៅកាន់វត្តអារាមធ្វើពុទ្ធបូជា ជាឧឡារិក ដោយសេចក្តីជ្រះថ្លាយ៉ាងអស្ចារ្យគ្រប់គ្នា ព្រោះក្នុង ១ ឆ្នាំមានធ្វើបុណ្យមាឃបូជាតែម្តង ។

បុណ្យមាឃបូជា យើងជាពុទ្ធបរិស័ទគួរជ្រាបដូចរៀបរាប់តទៅនេះ :—

បុណ្យមាឃបូជា ប្រែថា "បុណ្យថ្វាយគ្រឿងសក្ការៈចំពោះព្រះរតនត្រ័យ ត្រង់ថ្ងៃពេញបូណ៌ ខែមាឃ" ដោយមានគោលសំខាន់ ២ ប្រការ គឺ

គោលសំខាន់ទី ១: បុណ្យមាឃបូជា គឺជាបុណ្យរំលឹកដល់ថ្ងៃពេញបូណ៌ ខែមាឃ នៃឆ្នាំរកាសប្តស័ក មុនពុទ្ធសករាជ ៤៥ ឆ្នាំ ជាថ្ងៃនក្ខត្តឫក្សជុំ ១ របស់ព្រះសក្យមុនីបរមគ្រូរបស់យើង ដែលមានតែម្តងក្នុងវាងពុទ្ធកាលរបស់ព្រះអង្គមាន ៤៩ ព្រះវស្សា ។

ដ្បិតមានដំណាលថា: ក្នុងបឋមពោធិកាល គឺឆ្នាំដែលព្រះសម្មាសម្ពុទ្ធបរមគ្រូរបស់យើងទើបនឹងត្រាស់ដឹងថ្មីៗ ក្រោយពេលដែលព្រះសារីបុត្ត នឹងព្រះមោគ្គល្លានបានសម្រេចសាវកបារមីញាណរួចហើយ ព្រះពុទ្ធអង្គទ្រង់ស្តេចចុះចាកភ្នំគិជ្ឈកូដ មកកាន់វត្តវេឡុវ័នដ៏ត្រកាំងគ្រឹះ

ទ្រង់ប្រថាប់កណ្តាលទីប្រជុំព្រះវិសុទ្ធិសង្ឃ អង្គព្រះអរហន្តចំនួន ១.២៥០ អង្គជាទីប្រជុំប្រកបដោយអង្គ ៤ ហៅថា "ចាតុរង្គិកសន្និបាត" ព្រះអង្គទ្រង់តាំងព្រះសារីបុត្តជាអគ្គសាវ័កស្តាំ ព្រះមោគ្គល្លានជាអគ្គសាវ័កឆ្វេង ហើយ ទ្រង់សំដែងនូវទេសនាតិមោក្ខកណ្តាលទីប្រជុំនោះ ។

ចាតុរង្គិកសន្និបាត ជាបវេណីរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ តាំងអំពីបុពណ្ហរៀងមក ប៉ុន្តែតែព្រះអង្គខ្លះមានតិចជង ព្រះអង្គខ្លះមានច្រើនជង ហើយទង់ព្រះសង្ឃសាវ័កដែលមកប្រជុំនោះ អង្គខ្លះមានចំនួនតិច អង្គខ្លះច្រើនជាង គ្នាប៉ុណ្ណោះ ។ ឯព្រះសម្មាសម្ពុទ្ធបរមគ្រូយើងមានតែម្តង ហើយចំនួនព្រះអរហន្តសាវ័កមានត្រឹមតែ ១.២៥០ អង្គ ។

ការជួបជុំសាវ័កគ្រានោះ ឆានជាហៅថា "ចាតុរង្គិកសន្និបាត" ព្រោះជាការជួបជុំប្រកបដោយអង្គ ៤ គឺ

ក) ថ្ងៃពេញបូណ៌មី ខែមាឃ ជាថ្ងៃឧបោសថ;

ខ) ព្រះអរហន្តទាំង ១.២៥០ អង្គឆានមកជួបជុំឯង១ មិនបាច់នរណានិមន្ត;

គ) ព្រះអរហន្តទាំងនោះ សុទ្ធតែជាព្រះខីណាស្រពសម្រេចអភិញ្ញាទាំង ៦ គ្រប់ព្រះអង្គ;

ឃ) ព្រះអរហន្តទាំងនោះ សុទ្ធតែជាឯហិភិក្ខុបួសផ្ទាល់ព្រះពុទ្ធអង្គ ដោយមានសត់ពុកមាត់ពុកចង្អាកោរស្រាប់ៗ មានចាត្រទឹងត្រៃពីរសម្រេចដោយបុញ្ញឫទ្ធិស្រាប់ៗគ្រប់ព្រះអង្គ ។

ពោលសំខាន់ទី ២ : បុណ្យមាឃបូជា គឺ ជាបុណ្យរំលឹកដល់ថ្ងៃពេញបូណ៌ខែមាឃ ជាថ្ងៃនក្ខត្តឫក្សធំមួយទៀត មុនពុទ្ធសករាជចំនួន ៣ ខែ ដែលព្រះសម្មាសម្ពុទ្ធបំរុងនឹងប្រគល់ នូវព្រះឱវាទបាតិមោក្ខ ដល់ព្រះសង្ឃសាវ័កដាក់ព្រះជន្មាយុសង្ខារ របស់ព្រះអង្គ ។

សឹងមានដំណាលថា: ក្នុងបច្ចិមពោធិកាលដែលព្រះពុទ្ធអង្គទ្រង់គាំងនៅក្នុងបច្ចិមវ័យ មុនថ្ងៃបរិនិព្វាន ៣ ខែ ព្រះអង្គទ្រង់ប្រថាប់នៅនាជាតិលចេតិយ ។

វេលានោះ ក្នុងមារចិត្តជាបមកនិមន្តទូលឲ្យព្រះអង្គឲ្យបរិនិព្វាន, ព្រះអង្គទ្រង់មានព្រះបន្ទូលនឹងមារថា

"នែមារ! អ្នកកុំជាប់ខ្វល់ខ្វាយ, មិនយូរប៉ុន្មាននៅតែ ៣ ខែទៀតទេ តថាគតនឹងបរិនិព្វានហើយ" ។

កាលទ្រង់តំណាត់ព្រះជន្មដូច្នេះ ហៅថា "ដាក់ព្រះជន្មាយុសង្ខារ" ព្រះពុទ្ធដីកានេះ តែងលើថ្ងៃពេញបូណ៌ខែមាឃដូចថ្ងៃចាតុរង្គីកសន្និបាតដែរ ថ្ងៃកន្លែងថ្ងៃពេញបូណ៌ខែមាឃ កាលជាតុរង្គីកសន្និបាត នៅកន្លែងបឋមពោធិកាល គឺវេលាព្រះអង្គទើបនឹងបានត្រាស់ នាព្រះជន្ម ៣៥ ឆ្នាំ; ថ្ងៃពេញបូណ៌ខែមាឃ កាលទ្រង់ដាក់ព្រះជន្មាយុសង្ខារ នៅកន្លែងបច្ចិមពោធិកាល គឺវេលាព្រះអង្គជិតបរិនិព្វាន នាព្រះជន្មគ្រប់ ៨០ ឆ្នាំ ព្រះវស្សាគ្រប់ ៤៥ ប៉ុណ្ណោះ ។

វេលាទ្រង់ជាក់ព្រះជន្មាយុសង្ខារនោះ មានការកើតអំពើកញ្ជាប់ញ៉ែរដែនដីយ៉ាងធំ គួរភ្ញកភ្ញឹកព្រឺព្រេមព្រឺស្បែក ទាំងមហាមេឃក៏ខ្ជុះទឹកមានផ្គរលាន់ឮអឺងកងរំពង ជាមហាអស្ចារ្យ ។

អ្រែយ៉ោយថ្ងៃពេញបូណ៌ ខែវិសាខ ជាថ្ងៃមានគោលសំខាន់ ២យ៉ាងដូចបរិយាយមកនេះហើយ ឃានជាពុទ្ធបរិស័ទ្ធគ្រប់ប្រទេសដែលកាន់ព្រះពុទ្ធសាសនា ទុកថ្ងៃនេះជាទិនាកិលក្ខិតដ៏មួយសម្រាប់ពុទ្ធបរិស័ទរៀបគ្រឿងសក្ការបូជាថ្វាយព្រះរតនត្រ័យ ជាបវេណី ពាល់ប្រទេស, ទាំងប្រទេសកម្ពុជាយើងក៏ឃានទុកថ្ងៃនេះ ជាបវេណីរបស់ប្រទេសដូចគ្នា ។

ប្រសិនបើមានបញ្ហាកើតឡើងថា ការធ្វើមាឃបូជាមានប្រយោជន៍យ៉ាងណាខ្លះ?

សូមឆ្លើយឲ្យហើយថា មានប្រយោជន៍យ៉ាងនេះ គឺ

១ - ប្រយោជន៍ជាការណីយកិច្ចដ៏ប្រពៃមួយយ៉ាង របស់ពួកពុទ្ធបរិស័ទដែលត្រូវតែរំលឹក ដល់ថ្ងៃនក្ខត្តឫក្ស ជាគោលសំខាន់នៃពុទ្ធសាសនា ហើយនឹងបានថ្វាយសក្ការបូជា ចំពោះព្រះរតនត្រ័យនាថ្ងៃនក្ខត្តឫក្សនោះ តាមគាប់អំធ្យាស្រ័យ ដើម្បីជាកស្តុតាងបង្ហាញពិភពលោកឲ្យឃើញជាក់ថា ប្រទេសកម្ពុជា ជាប្រទេសប្រតិបត្តិព្រះពុទ្ធសាសនាយ៉ាងជាក់ស្តែង ។

២ - ប្រយោជន៍ឲ្យពួកពុទ្ធបរិស័ទ ដែលបានមកធ្វើសក្ការបូជានោះ កើតមានសេចក្តីសាមគ្គីស្មោះស្ម័គ្រគ្នា ដើម្បីលះបង់ទ្រព្យជំនួយកសាងសន្ថាន

ដែលធ្លាប់មានមកពីវង្សពុទ្ធបរិស័ទផងគ្នា ដោយសារពេលដែលជួបជុំនោះ
នាំគ្នានឹកពីវគុណពុទ្ធគុណជាអារម្មណ៍តែមួយយ៉ាង;

๓- ប្រយោជន៍បានតន្ទូវបណ្ដាំធម៌ដ៏ថ្លៃថ្លា នៃព្រះពុទ្ធសាសនា
ដើម្បីញ៉ាំងពពួកយុវជនពុទ្ធបរិស័ទ ក្នុងអនាគតឲ្យចេះតែដឿងជាក់ថា ថ្ងៃ
ពេញបូណ៌មី ជាថ្ងៃនក្ខត្តឫក្សធំ សម្រាប់ពុទ្ធបរិស័ទប្រជុំធ្វើពុទ្ធ-
បូជា ជាទំនៀមក្នុងព្រះពុទ្ធសាសនាតទៅ មិនដាច់ឡើយ;

๔- ប្រយោជន៍បានជាស់តឿនន្ទូវស្មារតី នៃពុទ្ធបរិស័ទក្នុងបច្ចុប្បន្ន
ដែលជ្រះថ្លាស្រាប់ហើយ ឲ្យវិតតែជ្រះថ្លាចំពោះធម៌វិន័យពុទ្ធសាសនា
តឹងរ៉ឹងឡើង តាមកម្លាំងសទ្ធាវៀងៗខ្លួន ឲ្យមានដំហានឈានទៅខាងមុខ
ជាដរាបតទៅក្រោយ ដោយនឹកឃើញដល់ដំណើរវិវឌ្ឍនៃការប្រតិបត្តិ
របស់ខ្លួនៗ;

๕- ប្រយោជន៍ជាប្រទីបត្រាលបំភ្លឺដល់ពុទ្ធបរិស័ទ ដែលពុំទាន់
យល់ឲ្យបានយល់ច្បាស់ ដោយបានមកធ្វើសក្ការបូជាហើយ បានស្ដាប់
ន្ទូវប្រវត្តិនៃសក្ការបូជានោះថា ការធ្វើបុណ្យមាឃបូជានេះ គឺជាបុណ្យ
រំលឹកគុណព្រះរតនត្រ័យ ចំពោះថ្ងៃនក្ខត្តឫក្សធំៗ ទាំងពីរគ្រា គឺថ្ងៃចាតុ-
រង្គីកសន្និបាតតាំងអគ្គសាវ័ក នឹងថ្ងៃជាក់ព្រះដន្ទាយុសង្ខារនៃព្រះគោតម
បរមគ្រូរបស់យើងទាំងឡាយ ជាថ្ងៃដែលរាប់ចេញក្រោយពីថ្ងៃនេះទៅវិញ
ជាង ๒,๔๙๕ ឆ្នាំមកហើយ ។

បរិយាយមកកាន់អត្ថបទស្តីពីបុណ្យមាឃបូជា ដែលចាត់ជាទំនៀម
ទម្លាប់ខ្មែរមួយបាន ។ ក្នុងផ្នែកទំនៀមបុណ្យព្រះពុទ្ធសាសនា ចប់
ដោយសង្ខេបតែប៉ុណ្ណោះ ។

ថ្ងៃមុខ ខ្ញុំបានគិតបរិយាយពីរឿងទំនៀមទម្លាប់ខ្មែរ មានប្រការ
ផ្សេងៗទៀត សូមអស់លោកប្រុងចាំអានចាំស្តាប់ ជាប្រដាប់សតិបញ្ញា
ការចេះដឹងតទៅ ។

សេចក្តីរួបរួម

ពេញបូណ៌ខែមាឃរៀងរាល់ឆ្នាំ ជាថ្ងៃប្រចាំនក្ខត្តបុក្ស
ដែលយើងជាពុទ្ធសាសនិក គប្បីរលឹកចាំជាក់លាក់ :
មួយ – ថ្ងៃចតុរង្គសន្និបាត ដែលព្រះលោកនាថភ្នំសារ័ក
ពីរ – ថ្ងៃព្រះអង្គទ្រង់បានជាក់ ព្រះជន្មទៀងជាក់នឹងនិព្វាន !

ចាប – ពិន

លោកដុកទ័រគុណបលៈបិយៈសេន្ទៈម៉ាលាលៈសេកេរៈ

ជាប្រធានពុទ្ធិកសមាគមពិភពលោក ថ្លែងក្នុងសមាជសាកលលើកទី ២
នៃពុទ្ធសាសនានៅទីក្រុងតូក្យូ (ប្រទេសជប៉ុន)
(តូក្យូ ២៥ កញ្ញា, ១៣ តុលា ១៩៥២)

ពុទ្ធសាសនបណ្ឌិត្យ

(តទៅ)

អក្សរសាស្ត្រ

អក្សរសាស្ត្រ គឺសភាពដ៏ល្អមួយយ៉ាងក្នុងកិច្ចរឿងទាំងឡាយដែលមនុស្សកិច្ច
ទៅវិញទៅមក ព្រមទាំងប្រយោជន៍ថាសាធារណៈ ។

សេចក្តីសោមនស្សរបស់ខ្ញុំ ដ៏ពន្លឹកនោះគឺខ្ញុំពិនិត្យទៅឃើញនូវ
សេចក្តីចម្រើនខាងអក្សរសាស្ត្រសម្រាប់អស្សារតាំងពីប៉ុន្មានឆ្នាំមុននេះ ។
សៀវភៅដែលបានបោះពុម្ពលក់មានចំនួនជាច្រើនម៉ឺនក្បាល, បញ្ជាក់
ឲ្យឃើញនូវផលប្រយោជន៍ដ៏ពន្លឹក នៃព្រះពុទ្ធសាសនាក្នុងពិភពលោក
អត្ថបទដែលបោះពុម្ពផ្សាយមានជាច្រើនបែប ។ បឋម, មានការិយាល័ត្រ
ជាច្រើន ខ្លះចេញក្នុងសប្តាហ៍ម្តង, ខ្លះ ១៥ ថ្ងៃម្តង, ខ្លះមួយខែម្តង,
មានសៀវភៅខ្លះខែត្រីមាស, ពីរខែតអនុសំវច្ឆរៈ សៀវភៅទាំងនោះ
បានបោះពុម្ពផ្សាយជាភាសាច្រើន, ភាសាខ្លះបានប្រែទៅនឹងបស្ចឹម

ប្រទេស ហើយមានចុះរឿងការសំខាន់ៗ ខាងព្រះពុទ្ធសាសនានឹងបញ្ហា
ព្រះពុទ្ធសាសនា ។

សៀវភៅនោះគេបានស្គាល់គ្រប់ៗគ្នាហើយ មានផ្សាយពាសពេញ
ពិភពលោក ។ ខ្ញុំមិនបានពាយនាមការិកប័ត្រនោះទេ ដោយខ្ជាប់ក្រែង
ពាយនាមមិនសព្វគ្រប់ក្លេចខ្លះ ។ ការិកប័ត្រទាំងអស់ត្រូវតែយើង
ជួយឧបត្ថម្ភពេញលក្ខណៈ ហើយត្រូវតែយើងលើកទឹកចិត្តអ្នកដែលធ្វើ
ព្រោះអ្នកទាំងនេះបានបំពេញនូវតួបំណងដ៏ប្រសើរ គួរឲ្យស្ញាយិតន់ពេក
មានអ្នកខ្លះត្រូវស្រែកអំពាវនាវឲ្យយើងជួយមូលនិធិ ។ រឿងនេះលំបាក
តន់ពេក ហើយយើងបានដឹងថា ការិកប័ត្រដែលបោះពុម្ពផ្សាយ
ចេញមិនបានតាមបំណង គឺជាការិកប័ត្រមានសភាពវិសេសជាងគេ ។
គួរឲ្យអាណិតអាសូរដល់អ្នកទាំងនេះ ដែលពឹងផ្អែកទៅលើបុគ្គលដែល
មានសទ្ធាតិចតួចស្តួចស្តើងយ៉ាងដូចនេះ ។

ឧសថមួយ សម្រាប់ការពារនូវការរៃបែបនេះ គឺស្ថិតនៅក្នុងការ
បន្ថែមចំនួនសៀវភៅ ដែលត្រូវបោះពុម្ពផ្សាយ. តែដូចជាការិយមានមក
ពីមុនជាញឹកញយ តម្លៃបូកប៉ាន់សៀវភៅនីមួយៗ ច្រើនជាងតម្លៃដែល
លក់ ។ លទ្ធផលនៃការបោះពុម្ពផ្សាយសៀវភៅទាំងនោះ នាំទៅការ
សេចក្តីខាតជាបរិយោសាន ។ មធ្យោបាយគឺត្រូវស្ថាបនានូវមូលនិធិ
កណ្តាលសម្រាប់បោះពុម្ពផ្សាយ ព្រោះហេតុដូចនេះបានជាត្រូវមាន

ប្រាក់ដំនួយដែលត្រូវដកយកសម្រាប់ផ្ទេរទៅឲ្យ គាល់កប័ត្រណាដែលត្រូវការជាងគេ ។ ពិតមែនតែមានសេចក្តីលំបាកជាច្រើនប្រការ ខាងការអភិបាលនឹងការផ្សេងៗ ហើយបញ្ហានេះត្រូវជ្រើសរើសដោយសេចក្តីអនុគ្រោះ ដល់កាលកប័ត្រណាមួយ, តែមិនមែនឧបសគ្គធំណាស់ណាទេ ។ ក្រៅពីសៀវភៅចោះពុម្ពផ្សាយរឿងព្រះពុទ្ធសាសនាជាពិសេសនេះ មានសៀវភៅឯទៀតដែលចោះតុម្ពទៅតាម ទេសៈ កាលៈ នូវរឿងព័ត៌ដែលមានតម្លៃបំផុតខាងព្រះពុទ្ធសាសនា, ហើយនឹងពួកពុទ្ធសាសនិកជន, ជាហេតុឲ្យមានបញ្ហាខាងបណ្ណាល័យ ត្រូវតាំងយោបល់បន្ថែមចំពោះការស្ថាបនានូវលេខាធិការដ្ឋានអាស៊ីខ្ពស់នៃពុទ្ធិកសមាគមពិភពលោក ។ ជាកិច្ចដ៏សំខាន់ ដែលឲ្យមានបណ្ណាល័យប្រកបដោយសន្ទុះចំពោះតម្លៃនៃអត្ថបទ ដែលជ្រើសយកតែសារៈប្រយោជន៍ព្រោះមានអ្នកនិពន្ធសៀវភៅ ឬសេចក្តីពិនិត្យ អំពីព្រះពុទ្ធសាសនាច្រើនប្រភេទក្នុង, ឬការច្បាំង. ដូនកាលដោយឆន្ទៈផងក៏កិច្ចអ្នកនិពន្ធ ដែលមានបំណងចង់បញ្ជាក់ថា សាសនារបស់ខ្លួន មានសហភាពឧត្តុង្គឧត្តមជាងពុទ្ធោវាទ ដោយគ្មានអ្វីជាគោលសម្រាប់ដឹកនាំ មានបុគ្គលជាច្រើន ដែលពេញចិត្តខាងព្រះពុទ្ធសាសនាតែច្រើនការច្បាំងនាំឲ្យខូចប្រយោជន៍ខ្លួនត្រូវតាំងខូចតម្លៃធម៌ ។

សៀវភៅនឹងដែក ឬស្ពាន់បន្ទាស់ សម្រាប់ចារឹកព្រះពុទ្ធសាសនា, មានធ្វើជាច្រើន, តែមានប្រទេសខ្លះដូចជាប្រទេសអេស្ប៉ាញ នឹង

ប្រទេសចាំង ឡាយ ខាងទ្វីបអ៊ីរុបឯកើតដែលរកសៀវភៅ ឬបន្ទាស់ស្តាន់ ចាកែព្រះពុទ្ធសាសនាមិនបាន ។ ចំពោះប្រទេសជាច្រើនខាងទ្វីបអ៊ីរុប ខាងកើត មានការគមនាគមន៍ខាងផ្លូវព្រះពុទ្ធសាសនាដោយលំបាក, តែការលំបាកនេះមិនមាននៅប្រទេសអេស្ប៉ាញសោះឡើយ ។ ប្រទេសខាងទ្វីបខាងកើតមិនបាននិយមរាប់អានព្រះពុទ្ធសាសនាច្រើន ព្រោះសិទ្ធិហាមមិនឲ្យប្រជាស្ត្រី អានអក្សរសាស្ត្រពុទ្ធសាសនា ។ នេះគឺជាសភាពផ្ទុយនឹងប្រជាជាធំជូលាយនៃសតវត្សទីមែ ដែលយកពន្ធជារបស់ពោះវិទ្យាចាំងនេះ គឺវិទ្យាដែលមានហេតុចាក់ទងខាងផ្លូវប្រជា ។ តែវឿងនេះមានសភាពខាងក្រៅបញ្ហាខាងលើ ហើយត្រូវបន្តទៅជាចូលកងអង្គការសហប្រជាជាតិសម្រាប់អប់រំការសិក្សា, វិទ្យាសាស្ត្រនឹងវប្បធម៌ដែលខ្ញុំសង្ឃឹមថា អង្គការនេះនឹងយកបញ្ហាទៅដោះស្រាយតាមគួរការ ។

អត្ថបទនឹងសេចក្តីប្រែ

ក្រៅពីគម្ពីរដើម មានអត្ថបទនឹងសេចក្តីប្រែ ដែលបានចោះពុម្ពផ្សាយនូវព្រះធម៌នៃព្រះសម្មាសម្ពុទ្ធ ។ មានគម្ពីរដែលកែប្រែទៅតាមអក្សរប៉ុន្មាន ឬឡាតាំងនៃព្រះត្រៃយបិដក មានជាច្រើនតាំមកហើយ តែសៀវភៅទាំងនោះ មានផ្នែកជាច្រើនឥឡូវចំណាយអស់ហើយត្រូវតែចោះពុម្ពសាជាថ្មី ។ ឯព្រះត្រៃយបិដកភាសាបាលីមានផ្នែកច្រើន បានប្រែជាភាសាអង់គ្លេសត្រមទាំងភាសាបារាំងនឹងអាល្លឺម៉ង់ ហើយមាន

ផ្នែកខ្លះទៀត ប្រែជាភាសាអ័តាល្ី ។ សៀវភៅព្រះត្រ័យបិដកទាំងនេះ ត្រូវតែចោះពុម្ពឡើងជាថ្មី ។ ខ្ញុំមានចិត្តសោមនស្សពន់ពេកដោយបានឃើញថា ព្រះត្រ័យបិដកជាលីមានអត្ថបទខាងព្រះធម៌ ចំពោះគណៈពុទ្ធសាសនាថេរវាទ បានប្រែជាភាសាជប៉ុននឹងភាសាចិន ។ សេចក្តីប្រែជាភាសាជប៉ុនបានសំរេរេរាំងអស់ តែក្នុងសម័យបច្ចុប្បន្ន គេឃើញមានតែសៀវភៅពីរដែលមានសេចក្តីប្រែជាភាសាចិន ។ សៀវភៅពីរនេះមានប្រែជាភាសាចិនចប់កន្លងពេលមហាសង្គ្រាមលើកមុន នេះត្រូវតែពិនិត្យផ្ទៀងផ្ទាត់ជាថ្មីមុននឹងយកទៅចោះពុម្ពផ្សាយ ។ តែធំនេះត្រូវគិតពីមូលនិធិជាបញ្ហាសំខាន់ ហើយដែលខ្ញុំពណិនាទៅទីនេះព្រោះមានចិត្តសង្ឃឹមថា គង់មានអ្នកសប្បុរសជាតិចិនខ្លះដែលមានសទ្ធាជ្រះថ្លា, អាចស្វែងរកជ្រុកក្នុងការចោះពុម្ពសៀវភៅនេះបាន ។ ចំណែកខាងវិញ្ញាជនដែលគេត្រូវការនេះ លោកប្រធានប្រែបទនឹងជួយពិនិត្យផ្ទៀងផ្ទាត់នូវសៀវភៅនេះ ក្រៅពីនេះមានអត្ថបទសំខាន់ៗជាច្រើន ខាងលទ្ធិមហាយាន រង់ចាំសេចក្តីប្រែចំពោះភាសាជវែងទៀត ដូចជាភាសាអង់គ្លេស ឬភាសាបារាំង ។ ពិតមែនតែការប្រែនេះ ត្រូវឆ្លងកាត់ពីជាងមួយសតវត្ស ក៏កិច្ចខាំងនេះនៅច្រើនណាស់ ហើយការចោះពុម្ពក៏ត្រូវចំពេញដោយធាប់ហើយ ។

(មានត)

តំណែបុណ្យ

ធ្វើឆ្នាំព្រះវិហារវត្តពោធិវាល ខេត្តត្បូងឃ្មុំ

និង

បុណ្យចំរើនព្រះជន្មព្រះតេជព្រះគុណព្រះមុនីកោសល
អ៊ុំ-ទួត មេគណ ខេត្តត្បូងឃ្មុំ

ព្រះមហាឧត្តមវិជ្ជា កែ-អឿន ស្តីទីអនុគណ
វត្តព្រះពុទ្ធវត្តន៍ ខេត្តសៀមរាប រៀបរៀង

កាលនៅថ្ងៃព្រហស្បតិ៍, សុក្រ, សៅរ៍, ១១, ១២, ១៣ កើតខែ
ពិសាខ ឆ្នាំម្សាញ់បញ្ចស័ក ព. ស. ២៤៩៦ គឺថ្ងៃទី ២៣, ២៤, ២៥ ខែ
មេសា គ. ស. ១៩៥៣, នៅវត្តពោធិវាលមានធ្វើពិធីបុណ្យដ៏ឧឡារិក
គឺបុណ្យធ្វើឆ្នាំព្រះវិហារថ្មីជាន់ក្រោយ និងបុណ្យចំរើនព្រះជន្មាយុព្រះតេជ
ព្រះគុណព្រះមុនីកោសល អ៊ុំ ទួត មេគណ គំរប់ ៦១ ឆ្នាំ ។ ការធ្វើ
ព្រះវិហារដែលមិនទាន់បានសម្រេចនេះ ដោយពុទ្ធបរិស័ទដែលមានវ័យ
ចាស់ៗ តែងនឹកព្រួយដល់សង្ឃារាធម៌ដែលមិនទៀងទាត់ ក្រែងការកសាង
វិហារនេះមិនទាន់បានសម្រេច ខ្លួនលះបង់បញ្ចកន្ធទៅកាន់បរលោកនាយ
ទៅមិនទាន់បានធ្វើកុសលនេះ ទើបធ្វើបុណ្យធ្វើឆ្នាំបង្ហាញទុកទាន់ខ្លួនមាន

ដ៏វិតវែងនៅឡើយ ។ កាលវត្ថុបំណងនេះកើតមានហើយក៏ចាត់ចែងវិធានការតាំងគ្រឿងសក្ការបូជាដល់ព្រះរតនត្រ័យ ក្នុងផ្លូវត្តពោធិវ៉ាលតាំងមូល វិចិត្រវចនាប្លែកៗ គឺ: នៅមាត់ផ្លូវដែលចូលទៅកាន់វត្ត មានធ្វើក្លោងទ្វារមួយវិចិត្រវចនាដោយគ្រឿងលំអផ្សេងៗ ទន់ភ្លើងអគ្គិសនីបញ្ចេញរស្មីចំពែងចំញាចនឹងប្រដាប់ដោយទង់ជាតិទង់សាសនា, នៅក្លោងទ្វារនោះមានចារឹកអក្សរថា "សូមគោរព សម្តេចព្រះមហាសុមេធាធិបតី" ។ នៅត្រង់កំពែងវត្តមានធ្វើក្លោងទ្វារមួយទៀត តាក់តែងគ្រឿងលំអនឹងអំពូលភ្លើងអគ្គិសនីបញ្ចេញពន្លឺខៀវ - ស - ក្រហម - លឿងជាច្រើន, ក្នុងទីវត្តតាំងមូលសុទ្ធតែសំអាតគ្រប់កន្លែង គឺនៅថ្មីព្រះវិហារថ្មី មានធ្វើកជវ័តព័ទ្ធជុំវិញខ្នាត់ខ្នែងតែងដោយស្លឹកឈើស្រស់មានទង់ជាតិ ទង់សាសនាធំៗ ចង់ជុំវិញ ព្រះវិហារ; នៅជុំនព្រះវិហារខាងក្រៅតាំង ៤ ទិស មានពេងរៀបតាំងតុសក្ការបូជាថ្វាយដល់ព្រះរតនត្រ័យ ពេងតាំងនោះសុទ្ធតែតាក់តែងប្លែកៗពីគ្នា ។ ខាងក្នុងព្រះវិហារនៅលើងកណ្តាល មានរៀបចំគ្រឿងសក្ការបូជា, នៅលើងខាងត្បូងរៀបអាសនៈ សម្រាប់ព្រះសង្ឃ, លើងខាងជើងនឹងកណ្តាលសម្រាប់ពុទ្ធបរិស័ទ ។

នៅជុំនព្រះវិហារចាស់ខាងក្រៅតាំង ៤ ទិស ក៏មានពេងតាំងតុរៀបគ្រឿងសក្ការបូជាថ្វាយដល់ព្រះរតនត្រ័យដែរ ដោយមានវត្ថុតាំង ៤ គឺ:

វត្តក្តៅ ១ វត្តពោធិកង ១ វត្តចំរើស ១ វត្តសង្កែ ១ មកជួយរៀបចំវិចិត្រវចនា
សុទ្ធតែប្លែក ។ គឺ:

• នៅខាងត្បូងព្រះវិហារចាប់មានធ្លីបុស្បក ១ កំពស់ប្រហែល
៥ ម៉ែត្រ មានជណ្តើរសម្រាប់ឡើងទៅលើទាំង ៤ ទិស, នៅជុំវិញបុស្បក
មានរាជវត្តិវិចិត្រវចនាដោយគ្រឿងលំអប្លែក ។, ក័ពូលបុស្បកមាន ៥ រួត
សុទ្ធតែពាសដោយសពត់ទេសៈក ប្រកបដោយក្បូរក្បាច់ក្រដាសចំរុះ
ពណ៌គ្រប់យ៉ាង, នៅជុំវិញបុស្បកមានភ្នំនឹងពេងសម្រាប់ទទួលព្រះ
សង្ឃមានឋានន្តរស័ក្តិ នឹងតស្បោងក្នុងវិចិត្រ ។

ក្នុងពិធីបុណ្យទាំង ៣ ថ្ងៃនេះ មានពុទ្ធបរិស័ទនឹងប្រជាជនក្នុងវិចិត្រ
ជាច្រើនណែនណាន់តាន់តាប់មកដើរដោស អញ្ជើញទៅអនុមោទនាបុណ្យ
ទ្វឹងទៅមើលកំសាន្តក្នុងពិធីបុណ្យគ្រប់ពីរពីរ ។

ក្រុមវិធី

ថ្ងៃទីមួយ.— ថ្ងៃទី ២៣ ខែមេសា គ.ស. ១៩៥៣

១.— វេលាម៉ោង ៥ រសៀល រៀបគ្រឿងសក្ការបូជាព្រះរតនត្រ័យ
ក្នុងទីព្រះវិហារថ្មី នឹងក្នុងពេងតាំងតុជុំវិញព្រះវិហារ ។

២.— វេលាម៉ោង ៨ យប់ អញ្ជើញពួកពុទ្ធបរិស័ទជួបជុំក្នុងទីព្រះ
វិហារថ្មី ដើម្បីនមស្ការព្រះរតនត្រ័យ និមន្តព្រះសង្ឃចំនួន ២០ អង្គចំរើន

ព្រះបរិត្តដួងព្រះវិហារថ្មី ហើយនិមន្តព្រះគ្រូអនុគណ កែ អឿន ស្រុកសៀមរាប សំដែងធម៌ទេសនា តាមកាលដ៏សមគួរ រួចលេងរបាំផ្សេង ។ ។

ថ្ងៃទី៣.— ថ្ងៃទី ២៤ ខែមេសា គ. ស. ១៩៥៣

១.— វេលាមោង ៧ ទឹង ៣០ នាទី ប្រគេនយាគូបំពោះព្រះសង្ឃ;

២.— វេលាមោង ១១ វេរកន្លាហារ ប្រគេនព្រះសង្ឃ;

៣.— វេលាមោង ២ រសៀល រៀបគ្រឿងសក្ការៈកងសាលាធម្មសភា ទឹងពេងតាំងតុដុំវិញព្រះវិហារថ្មី;

៤.— វេលាមោង ៣ ទឹង ៣០ នាទី អញ្ជើញពុទ្ធបរិស័ទជួបជុំកងទីសាលាធម្មសភា ដើម្បីនមស្ការព្រះរតនត្រ័យ រួចនិមន្តព្រះសង្ឃចំនួន ៦១ រូបចំរើនព្រះបរិត្តពុទ្ធមន្ត ។

បន្ទាប់មក បណ្ឌិតមហាឡាយ - អ៊ិច ថ្លែងដីវប្រវត្តិព្រះតេជព្រះគុណ ព្រះមុនីកោសល ។

លុះចប់ហើយ ព្រះរាជាគណៈនិងមន្ត្រីសង្ឃគ្រប់ដំណាងសូត្រជយន្តោ ប្រគេនដំយមទ្ឋលចំពោះព្រះតេជព្រះគុណ ព្រះមុនីកោសល, រួចព្រះតេជព្រះគុណ ព្រះមុនីកោសល និមន្តទៀងគន់លើបុស្បក ។

ព្រះតេជព្រះគុណ ព្រះពោធិវង្ស, ព្រះរាជាគណៈ, ឯកទត្តមរាជប្រតិភូ និងលោកប្រតិភូជាំរាំង ប្រចាំទៃត្រជាត់ដំបង និមន្ត អញ្ជើញ

ឡើងលើបុស្បក ច្រោះសុគន្ធភ្លីលើព្រះហស្តព្រះតេជព្រះគុណ ព្រះមុនីកោសល ហើយនិមន្ត អញ្ជើញចុះទៅគង់ - អង្គុយកន្លែងកំពុងវិញ ។

ព្រះតេជព្រះគុណ ព្រះមុនីកោសល កាលបានទទួលសុគន្ធភ្លីរួចហើយ និមន្តចុះពីលើបុស្បកមកធ្វើកិច្ចបដិសណ្ឋារៈចំពោះឯកន្តុមពជ-ប្រតិកូ នឹងលោកប្រតិកូឫកាំងប្រចាំខែត្រចាត់ដំបងចំនួន ១៥ នាក់ ។

បន្ទាប់មក ព្រះតេជព្រះគុណព្រះពោធិវង្ស នឹងលោកអ្នកពជការខ្មែរ - ឫកាំង និមន្ត - អញ្ជើញទស្សនាកំសាន្តកេងតាំងតុដុំវិញព្រះវិហារ ។

៥. - វេលាម៉ោង ៨ យប់ អញ្ជើញពុទ្ធបរិស័ទដួបជុំកន្លែងទីសាលាធម្មសភា និមន្តព្រះតេជព្រះគុណពោធិវង្សសំដែងធម្មទេសនា ។

ថ្ងៃទី៣.- ថ្ងៃទី ២៥ ខែមេសា គ.ស. ១៩៥៣.

១.- វេលាម៉ោង ៧ នឹង ៣០ នាទី ច្រកគេនយាគូចំពោះព្រះសង្ឃ,

២.- ដល់ម៉ោង ១០ និមន្តព្រះសង្ឃចំនួន ៥០០ រូប បិណ្ឌបាត,

៣.- ដល់ម៉ោង ១១ ច្រកគេនកត្តាហារចំពោះព្រះសង្ឃចំនួន ៦១ រូប;

៤ - វេលាម៉ោង ៨ យប់ និមន្តព្រះចាត់ពោធិពម សំដែងធម្មទេសនា ជាការបង្ហើយបុណ្យ ។

ព្រះតេជព្រះគុណព្រះមុនីកោសល មេគណ ខែត្រចាត់ដំបង សូមទទួលសក្ការៈកុសលពាសីកន្លងទៅនេះ ចំពោះព្រះប្រិយមហាក្សត្រិយ៍

ព្រមទាំងព្រះពរជ័យក្នុងរឿង សូមឲ្យខ្ញុំគង់នៅក្នុងសិរីរាជសម្បត្តិខ្ពាត់
កយាជាសុខសាន្ត សម្បាន្តក្នុងព្រះកាយពល ដើម្បីសម្រេចព្រះធាវ
តីព្រះមេត្តាព្រហ្មវិហារ គ្របដណ្តប់លើប្រជាជនក្នុងកម្ពុជរដ្ឋ កុំបីមាន
ឧបស័គ្គមកពាំងព្រះរាជហឫទ័យខ្ញុំបានឡើយ ។

ម្យ៉ាងទៀត ព្រះពរបំណងឯណាដែលព្រះអង្គខ្ញុំយាងទៅ
នានាប្រទេស ដើម្បីតាមការតាំយកឯកភាពឲ្យបានបរិបូណ៌ ដល់ប្រទេស
កម្ពុជា ព្រះពរបំណងនោះ សូមឲ្យបានសម្រេចគ្មានបីអាក់ខានឡើយ,
ទាំងសូមឲ្យអស្ចារ្យសុខ ដែលកើតនៅក្នុងប្រទេសសព្វថ្ងៃ ដោយតេជៈនៃ
ព្រះរតនត្រ័យនឹងកុសលដ៏ប្រសើរក្នុងពេលនេះ ។
